# ជីវប្រវត្តិសង្ខេប នៃទស្សនវិទូ ក្រិកដ៏ល្បីល្បាញជាងគេ ក្នុងបុរាណកាល

ដោយ FÉNELON

ប្រែសំរួលដោយ

សុទ្ធ~ប៉ូលិន

ការផ្សាយរបស់សារពត៌មាន «អង្គរបុរី»

រក្សាសិទ្ធិគ្រប់យ៉ាង

គ.ស. ២០០៤ ★ ព.ស. ២៥៤៨

# ទាចារអ្នកផ្សាយ

ក្រោយសម័យអន្តរកប្បរបស់ខ្មែរក្រហម សៀវភៅនិងឯកសារជាច្រើនបានត្រូវបាត់បង់ ឬបានត្រូវគេបំផ្លាញចោល ដែលបណ្តាលឲ្យមានការលំបាកលំបិនយ៉ាងខ្លាំងក្លាដល់ការសិក្សារៀនសូត្រ នៃសិក្ខាកាមជនខ្មែរជំនាន់ក្រោយ ។

ដើម្បីជាវិភាគទាន ដល់ចំណេះដឹងក្នុងផ្នែកសិក្សា «ទស្សនវិជ្ជា» សារពត៌មានអង្គរបូរីមានសេចក្តីរីករាយលើកយកសៀវភៅដ៏មានចំណាស់មួយ ចងក្រងឡើងដោយលោក FÉNELON អ្នកនិពន្ធជាតិបារាំងដ៏ល្បីល្បាញម្នាក់ នៅក្នុងសតវត្សទី ១៨ មកចុះផ្សាយជូនប្រិយមិត្តអ្នកអានជាលំដាប់លំដោយ ។



លោក FÉNELON

លោកសុទ្ធ-ប៉ូលិន បានចំណាញពេលវេលាមានតម្លៃរបស់លោក ធ្វើការបកប្រែសៀវភៅដ៏កម្រកបានមួយនេះ ដើម្បីទុកជាឯកសារសំរាប់ប្រចាំបណ្ណាល័យរបស់លោកអ្នក និងដើម្បីទុកធ្វើការស្រាវជ្រាវ សំរាប់យល់ដឹងអំពីជីវិតនៃទស្សនវិទូក្រិកទាំងអស់នោះ ព្រមទាំងការឈ្វេងយល់របស់ពួកគេ ដែលបានធ្វើឲ្យសង្គមមនុស្សយើងនេះត្រូវប្រែប្រួល បត់បែន ឬរត់បុកទង្គិចទៅតាមនោះ ។

តាងនាមលោកសុទ្ធ-ប៉ូលិន ខ្ញុំបាទសូមលើកវណ្ណកម្មនេះ ជូនដល់អ្នកស្នេហាអក្សរសិល្ប៍ទាំងអស់ ជាពិសេសអ្នកស្រឡាញ់ចូលចិត្តខាងផ្នែកទស្សនវិជ្ជា នូវភាតរភាពយ៉ាងជ្រាលជ្រៅជាទីបំផុត ។

លី~ឌៀប
ចាងហ្វាងការផ្សាយនៃសារពត៌មាន«អង្គរបូរី»
ថ្ងៃទី១ សីហា ២០០៤

# ជីវិតរបស់អាណាការស៊ី
# ANARCHARSIS

គាត់បានចូលមករស់នៅក្រុងអាត្លែន នៅក្នុងសម័យអូឡាំព្យ៉ាដទី៤៧, ហើយ ត្រូវបានគេសម្លាប់នៅពេលបន្តិចក្រោយមក បន្ទាប់ពីគាត់បានវិលត្រឡប់ទៅស្រុក របស់គាត់វិញ ៖ ត្រង់នេះហើយដែលគេអាចសន្និដ្ឋានបានថា គាត់បានកើតមកក្នុង សម័យទស្សនវិទូផ្សេងៗ ដែលបានរៀបរាប់រួចមកហើយ ។

* *

*

អាណាការស៊ី, ជនជាតិស៊ីត (Scythe) មានគោរម្យងារដ៏ខ្ពង់ខ្ពស់ក្នុងចំណោម អ្នកប្រាជ្ញទាំងឡាយ ។ គាត់ត្រូវជាប្អូនរបស់អាណាគ្ស៊ីដា, រាជានៅប្រទេសស៊ីធី ហើយត្រូវជាកូនរបស់ងូរស់ ហើយនិងស្រីជាតិក្រិកម្នាក់ ៖ គឺហេតុដូច្នេះហើយ ទើប គាត់មានមធ្យោបាយអាចរៀនចេះភាសាដល់ពីរ។ គាត់មានបញ្ញាស្មារតីវាងវៃហើយ មានសំនួនហោវារប្លែកគេថែមទៀតផង ។ គាត់មានសេចក្តីក្លាហានមោះមុត ប្រកប ដោយកិរិយានឹងនរនៅគ្រប់រឿងអ្វីៗទាំងអស់ដែលគាត់សំរេចធ្វើ ។ នៅគ្រប់ពេល ទាំងអស់ គាត់ស្លៀកពាក់ដោយរុំខ្លួននឹងសំពត់ពីរជាន់ ហើយរស់នៅដោយសារ តែផឹកទឹកដោះគោ និងបរិភោគប្រហ្លូម៉ាស់តែប៉ុណ្ណោះ ។ សុន្ទរកថារបស់គាត់តែង ប្រព្រឹត្តទៅតាមបែបផែនជាឃ្លោងឃ្លាខ្លីៗ ប្រជ្រៀតចូលគ្នា ហើយមានលក្ខណ: ប្រញាប់ប្រញាល់ផង ។ ហើយដោយបុរសម្នាក់នេះ គ្មានការរាថយក្នុងរឿងអ្វីៗទាំងអស់ គាត់តែងតែបានសំរេចគោលដៅ ក្នុងកិច្ចការដែលគាត់បានជ្រៀតជ្រែកចូល ធ្វើជានិច្ច ។ របៀបបែបបទដែលគាត់និយាយស្តី ពោរពេញដោយសេចក្តីមាន: និងប្រកបដោយអត្ថន័យផងដែរ បានក្លាយទៅជាចង្កោមសុភាសិតរួចទៅហើយ ។ កាលណាមានជនណាម្នាក់ខំយកតម្រាប់តាមគាត់ នោះត្រូវគេចាត់ទុកថា « ខំថ្លែង សុន្ទរកថាតាមនាយស៊ីត » ។

អាណាការស៊ីបានចាកចេញពីប្រទេសស៊ីធី ដើម្បីមករស់នៅក្រុងអាត្លែន ។ នៅពេលមកដល់ភ្លាមកាលណា គាត់បានទៅគោះទ្វាររបស់សូឡុង, ហើយក៏បាន ប្រាប់អ្នកដែលរត់មកបើកទ្វារឲ្យគាត់ថា គាត់មកទីនោះដោយចេតនា ពីព្រោះគាត់មា

នប៉ងប្រាថ្នាចង់ជួបសូឡុង និងរស់សំណាក់នៅផ្ទះគាត់អស់មួយរយៈពេល ។

សូឡុងក៏បានតបឆ្លើយដោយសំដីដូច្នេះថា គេមានសិទ្ធិដើរតួជាភ្ញៀវ តែនៅក្នុងប្រទេសផ្ទាល់របស់ខ្លួនឯង, ហើយនៅត្រង់កន្លែងណាដែលខ្លួនមានទំនាក់ទំនងជាមួយអ្នកដទៃតែប៉ុណ្ណោះ ។ ពេលនោះ អាណាការស៊ីក៏ដើរចូលទៅ ៖ « យីអើ ! គាត់ពោលទៅកាន់សូឡុង, បើឯងកំពុងនៅក្នុងស្រុករបស់ខ្លួនស្រាប់, ហើយនៅក្នុងផ្ទះរបស់ខ្លួនទៀតផង... គឺឯងនេះហើយដែលត្រូវជ្រើសរើសភ្ញៀវរបស់ខ្លួនឯង... ដូច្នេះចូរឯងចាប់ផ្ដើមចងមិត្តភាពរវាងយើងទាំងពីរនាក់ទៅប្រសើរជាង ។ សូឡុងមានការភ័ន្តភាំងនឹងការឆ្លើយតបដ៏រហ័សរហួនបែបនេះ ក៏បានសុខចិត្តទទួលអាណាការស៊ីជាភ្ញៀវ ហើយក៏បានកសាងមិត្តភាពជាមួយគាត់នេះយ៉ាងជិតស្និទ្ធមែនទែន ដែលមានដំណើររហូតពេញមួយជីវិតរបស់អ្នកទាំងពីរតែម្ដង ។

អាណាការស៊ីមានចំណូលចិត្តផ្នែកខាងកំណាព្យកាព្យឃ្លោងពេកណាស់ ។ គាត់បានសរសេរអំពីច្បាប់ក្បួនជាកំណាព្យជាភាសាស៊ីត ជាមួយក្បួនធ្វើសឹកសង្គ្រាមផង ។ គាត់បានពោលថា ផ្លែទំពាំងបាយជូរតែងតែផ្ដល់នូវផលផ្លែបីយ៉ាង ៖ សេចក្ដីត្រេកសប្បាយ, ភាពស្រវឹងអួរទីទួរ ហើយនិងសេចក្ដីសោកស្ដាយជាក្រោយ ។

គាត់មានសេចក្ដីងឿងឆ្ងល់ពេកណាស់ ដែលថានៅគ្រប់ទីកន្លែងសភាសាធារណៈ ដែលគេរៀបចំធ្វើឡើងនៅទីក្រុងអាត្មែន គឺច្រើនតែពួកអ្នកប្រាជ្ញដែលមានភារៈបញ្ជូនសំណុំរឿងទៅធ្វើការបកស្រាយ ហើយច្រើនតែពួកមនុស្សឆ្កួត ដែលជាអ្នកមានភារៈខាងសំរេច ។ ម្យ៉ាងវិញទៀត គាត់មិនបានយល់ផងសោះថា ហេតុអ្វីបានជាអ្នកផងនាំគ្នាដាក់ទោសពិន័យចំពោះមនុស្សដែលជេរប្រមាថគ្នា ហើយបែរជាផ្ដល់រង្វាន់ដល់ពួកកីឡាករនិងពួកអ្នកលេង ដែលឡើងវាយប្រតប់គ្នា រហូតដល់កើតរបួសធ្ងន់ធ្ងរទាំងសង្ខាងទៅវិញ ។

គាត់រឹតតែឆ្ងល់ទៅទៀត ដែលពួកជនជាតិក្រិក នៅពេលណាដែលចាប់ផ្ដើមបរិភោគអាហារ តែងតែក្រេបស្រាក្នុងកែវតូចៗ, ក៏ប៉ុន្តែគេតែងលើកអកផឹកប្រណីក្នុងកែវធំៗ នៅពេលណាដែលគេចាប់ផ្ដើមមានលក្ខណៈស្រវឹង ។ គាត់មិនដែលអាចទ្រាំទ្របាននឹងសេរីភាពនៃពួកជនជាតិក្រិក ដែលនាំគ្នាស៊ីផឹកឥតត្រាប្រណីនៅក្នុងឱកាសជប់លៀងម្ដងៗ ។

ថ្ងៃមួយ គេបានសួរគាត់ថា តើមានមធ្យោបាយអ្វីទៅដើម្បីកែប្រែចិត្តមនុស្សម្នាក់ឲ្យបោះបង់ស្រាចោលមួយជីវិត ។ គ្មានវិធីអ្វីប្រសើរជាង, គាត់ពោលតប, ការទៅយកមនុស្សប្រមឹកម្នាក់ យកមកដាក់នៅពីមុខគេនោះទេ, ដូច្នេះទៅ សាមីខ្លួនមានឱកាសពិចារណារឿងស្រវឹងបានមួយសប្បាយ ។

មានម្ដងគេសួរគាត់ថា តើមានគ្រឿងភ្លេងអ្វីខ្លះទៅនៅស្រុកស៊ីធី ។ គាត់បានឆ្លើ

យតបវិញថា នៅទីនោះវាគ្មានទាំងដើមទំពាំងបាយជូរផង ។

គាត់បានអះអាងបញ្ជាក់ថា ប្រេងដែលពួកកីឡាករយកទៅលាបខ្លួនមុនពេលប្រយុទ្ធ គឺជាការរៀបចំជំរុញមនុស្សឲ្យមានលក្ខណៈជាឆ្កែឆ្កួត ។

ថ្ងៃមួយ បន្ទាប់ពីបានគិតពិចារណា អំពីកំរាស់ក្តារក្រាលនៃនាវាមួយ គាត់ក៏បានឧទានឡើងខ្លាំងៗ ៖ «អនិច្ចា ! អ្នកធ្វើដំណើរតាមសមុទ្រ ឋិតនៅចម្ងាយតែ៤ ម្រាមប៉ុណ្ណោះពីសេចក្តីស្លាប់ » ។

គេបានសួរគាត់ថា តើនាវាអ្វីទៅដែលមានការច្បាស់លាស់ជាងគេ ៖ – គឺ, គាត់ឆ្លើយតប, នាវាដែលបានចូលដល់ក្នុងផែរួចស្រេចហើយ ។

គាត់បានពោលជាញឹកញាប់ថា មនុស្សយើងម្នាក់ៗត្រូវចេះធ្វើជាម្ចាស់ការ នៃអណ្តាតនិងក្រពះរបស់ខ្លួនឯង ។

គាត់មានទម្លាប់ នៅពេលចូលនិទ្រា ដាក់ដៃមួយពីលើមាត់របស់ខ្លួនឯង ដើម្បីបង្ហាញឲ្យឃើញថា គាត់គ្មានរឿងអ្វីដែលគួរប្រយ័ត្នប្រយែងឲ្យលើសពីរឿងអណ្តាតរបស់គាត់នោះឡើយ ។

អ្នកស្រុកអាត្ទែនម្នាក់បានស្តីបន្ទោសឲ្យគាត់នៅវេលាថ្ងៃមួយថា គាត់ជាជនជាតិស៊ីត ៖ –ប្រទេសរបស់អញបណ្តាលឲ្យខ្លួនអញខូចកិត្តិយសក៏ពិតមែន, គាត់ឆ្លើយតប, ប៉ុន្តែឯងនេះវិញ ឯងកំពុងបន្ថោកបន្ទាបប្រទេសរបស់ខ្លួនឯងហើយ ។

គេបានសួរគាត់ថា តើមនុស្សយើងម្នាក់ៗ មានអ្វីដ៏ល្អប្រសើរជាងគេទាំងអស់នៅក្នុងខ្លួន ហើយតើមានអ្វីដែលអាក្រក់កំណាចជាងគេទាំងអស់ផងដែរ ។ គឺអណ្តាត, គាត់ពោលតប ។

–ការមានមិត្តភក្តិតែម្នាក់គត់, គាត់ពោល, ឲ្យតែជាមិត្តភក្តិពិតប្រាកដ ជាការប្រសើរឆ្ងាយជាជាងមានមិត្តភឿនមួយចំភ្លូស ដែលចាំតែបត់ក្បាលដើរចេញនៅពេលដែលរាសីអ្នកធ្លាក់ចុះ ។

នៅពេលដែលគេសួរគាត់ថា តើមានមនុស្សរស់ច្រើនជាងមនុស្សស្លាប់ឬទេ ? – ពួកអ្នកដែលនៅតាមសមុទ្រ, គាត់ឆ្លើយតប, តើគួរចាត់ទុកជាជំពូកមនុស្សយ៉ាងណាដែរ ? ។

គាត់បាននិយាយថា ទីផ្សារជាកន្លែងដែលមនុស្សបានបង្កើតឡើងសំរាប់បោកបញ្ឆោតគ្នាទៅវិញទៅមក ។

ថ្ងៃមួយនៅពេលដែលគាត់ដើរតាមផ្លូវ មានយុវជនភ្លីភ្លើម្នាក់ បានបញ្ចេញអាកប្បកិរិយាប្រមាថចំពោះរូបគាត់ ។ អាណាការស៊ីសម្លឹងមើលមុខក្មេងនោះចំ ហើយពោលរបៀបព្រងើយថា ៖

– ណែអ្នកអន្ទិត បើឯងមិនអាចទទួលទានស្រាតាំងពីក្មេងទៅហើយ ឯងនឹង

មានឱកាសផឹកស្រាគ្រប់ពេលវេលា នៅពេលឯងក្លាយទៅជាមនុស្សចាស់ជរា ។

គាត់បានប្រៀបធៀបយ៉ាងធម្មតាជាទីបំផុតថា ច្បាប់ក្រមមានលក្ខណៈដូចតែសំបុកពីងពាងដូច្នោះ, ម៉្លោះហើយគាត់ក៏បានសើចចំអកឲ្យសូឡុង ដែលខំប្រឹងស្ប៉ង់តុបតែងសេចក្តី៩-១០ឃ្លា ដើម្បីឃាត់ឃាំងរាំងរាតណ្ហារបស់មនុស្សទាំងឡាយ ។

គឺគាត់នេះហើយដែលបានរកឃើញវិធីធ្វើឆ្នាំងដី ដោយសារការប្រើកង់រទេះមួយ ។

ថ្ងៃមួយ អាណាការស៊ីបានទៅស្នើរសួរព្រឹទ្ធាចារ្យម្នាក់នៅវិហារអាប៉ូឡុង ដើម្បីគ្រាន់តែចង់ដឹងថា តើមាននរណាដែលមានបញ្ញាជាងរូបគាត់ឬទេ ៖ « ប្រាកដហើយ, នេះជាចម្លើយរបស់ហោរា, គឺជាមនុស្សម្នាក់ឈ្មោះ មីសុងដឺស្វែន ។ អាណាការស៊ីក៏មានការភ្ញាក់ស្រឡាំងកាំង ពីព្រោះមិនដែលឮឈ្មោះអំពីមនុស្សម្នាក់នេះសោះ ។ គាត់ក៏បានស្វែងស្វែងតាមទៅរកជនចម្លែក រហូតដល់ក្នុងភូមិមួយដែលបុរសនេះបានលាក់ខ្លួន ។ គាត់ក៏បានដើរទៅរកឃើញជនឯកោអនាថា ដែលកំពុងតែប៉ះពាវនង្គ័លរបស់ខ្លួន ។

– ឱមីសុង ! គាត់ឧទានឡើង, ពេលនេះពុំមែនជាពេលដែលត្រូវភ្ជួរដីនោះទេ !

– ផ្ទុយទៅវិញ, មីសុងឆ្លើយ, គឺពេលនេះហើយ ដែលគេត្រូវជួសជុលនង្គ័លរបស់ខ្លួន... ដោយហេតុថា វាមានកន្លែងមួយបាក់បែកត្រូវដោះស្រាយ ។

ជនដែលឈ្មោះមីសុងនេះ បានត្រូវបួតុងរាប់ចូលក្នុងចំណោមអ្នកប្រាជ្ញ ។ គាត់បានដកខ្លួនថយមករស់នៅតែម្នាក់ឯងត្រមង់ត្រមោច នៅទីកន្លែងមួយដែលគាត់គ្មានទំនាក់ទំនងជាមួយនឹងជនណាទាំងអស់... គឺដោយហេតុថា មកពីគាត់ស្អប់មនុស្សគ្រប់រូប គ្មានសល់នរណាម្នាក់ទេ ។ គេបានឃើញគាត់ក្នុងសម័យថ្ងៃមួយ នៅកន្លែងគៀនកោះដាច់ស្រយាល ដែលកំពុងតែសើចម្នាក់ឯងយ៉ាងពេញទំហឹង ។ មនុស្សម្នាក់បានចូលទៅក្បែរគាត់ហើយសួរគាត់ថា ម្តេចបានជាគាត់សើចខ្លាំងម្ល៉េះ, បើគ្មាននរណាម្នាក់នៅជាមួយគាត់ផង ។ បុរសនោះឆ្លើយថា ព្រោះតែរឿងហ្នឹងហើយបានជាធ្វើឲ្យគាត់របូតសំណើចទប់មិនបាន ។

❑ ❑

❑

# ជីវិតរបស់អាណាសាកូរ៉ា
# ANAXAGORAS

កើតនៅជំនាន់អូឡាំព្យាដទី៧០, ស្លាប់ទៅវិញនៅជំនាន់អូឡាំព្យាដទី៨៨ ក្នុងជន្មាយុ៧២ឆ្នាំ ។

*　　　*

*

អាណាសាកូរ៉ា ជាកូនប្រុសរបស់អេយេស៊ីប៊ុល បានទទួលចំណេះដឹងខាងផ្នែករូបសាស្ត្រដ៏ទូលំទូលាយវែងឆ្ងាយ លើសពីទស្សនវិទូនានាដែលបានកើតមុនជំនាន់គាត់ ។ គាត់មានកំណើតនៅក្លាសូម៉ែន ដែលជាទីក្រុងមួយនៅយ៉ូនី នៅក្នុងគ្រួសារមួយដ៏ខ្ពង់ខ្ពស់ ទាំងដោយពូជពង្សវង្សត្រកូលផង និងទាំងដោយទ្រព្យសម្បត្តិដ៏ស្តុកស្តម្ភដែលក្រុមគ្រួសារនេះមានផង ។ គាត់បានរីកចំរើននៅក្នុងបញ្ញានិងចំណេះដឹង នៅក្នុងអូឡាំព្យាដទី៧៦ ។

គាត់ជាសាវ័ករបស់អាណាក់ស៊ីម៉ែន... ចំណែកអាណាក់ស៊ីម៉ែនជាសាវ័ករបស់អាណាក់ស៊ីម៉ង់ឌើរ ។ ជនក្រោយនេះជាសិស្សរបស់ត្អាលែស ដែលពួកជនជាតិក្រិកទូទៅបានចាត់ទុកថា ជាអ្នកប្រាជ្ញទី១របស់ជាតិគេ ។ អាណាសាកូរ៉ាមានចំណូលចិត្តខាងផ្នែកទស្សនវិជ្ជាខ្លាំងពេកទៅ រហូតដល់គាត់បានលះបង់ចោលនូវកិច្ចការផ្សេងៗនៅក្នុងរដ្ឋកិច្ច នៅក្នុងឯកជនកិច្ច ដើម្បីជីកគាស់កកាយតែអំពីមុខវិជ្ជានេះតែមួយ ។ ឪពុកម្តាយរបស់គាត់បានព្រមានចំពោះរូបគាត់ថា ការមិនខ្វល់ខ្វាយអើពើដូច្នេះនឹងបណ្តាលឲ្យទ្រព្យសម្បត្តិរបស់គាត់ រលាយរលត់ហិនហោចអស់ជាពុំខាន ៖ ការប្រៀនប្រដៅបែបនេះ ពុំមានឥទ្ធិពលអ្វីបន្តិចបន្តួចទៅលើចិត្តថ្លើមរបស់គាត់ទាល់តែសោះ ។ គាត់បានដកខ្លួនថយចេញពីស្រុកកំណើតរបស់គាត់ ហើយគិតខ្វល់ខ្វាយស្វែងរកតែការពិតប៉ុណ្ណោះ ។ ជនម្នាក់បានស្តីបន្ទោសដល់គាត់ថា គាត់នេះមិនបានរវីរវល់អើពើនឹងប្រទេសជាតិកំណើតរបស់គាត់សោះ ។ គាត់បានឆ្លើយតបដោយចង្អុលទៅជើងមេឃ ៖ « ផ្ទុយទៅវិញ... ខ្ញុំស្រឡាញ់ប្រទេសខ្ញុំខ្លាំងណាស់ » ។ គាត់បានសំរេចមករស់នៅក្រុងអាតែ្មន ដោយផ្លាស់ទីកន្លែងសាលាដែលមានរៀបចំតាំងនៅស្រុកមីឡេត៍ តាំងពីសម័យត្អាលែសមកម្ល៉េះ ( ត្អាលែសជាស្ថាបនិកសាលានៅមីឡេត៍ ) យកមករៀបចំតាំងនៅទីក្រុងអាតែ្មនវិញ ។ តាំងពីអាយុ២០ឆ្នាំកាល

ណាមក គាត់បានបង្ហាត់បង្រៀនទស្សនវិជ្ជាជារៀងរហូតមក ហើយបានបន្តវិជ្ជាជីវៈនេះអស់រយៈពេល៣០ឆ្នាំ ។

ក្នុងសម័យថ្ងៃមួយ គេបាននាំសត្វចៀមមួយ ដែលមានស្នែងដុះនៅចំកណ្តាលថ្ងាស ចូលមកក្នុងគេហស្ថានរបស់ប៉េរីក្លែស ។ លោកគ្រូទាយឡមពង់ក៏បានប្រកាសភ្លាមមួយរំពេចថា ក្រុមបក្សពីរដែលបានបែងចែកទីក្រុងអាតែ្នន ច្បាស់ជានឹងបូករួមចូលគ្នាទៅជាអំណាចតែមួយវិញ ។ ក៏ប៉ុន្តែអាណាសាកូរ៉ាបានពោលថា រឿងហេតុស្នែងដុះកណ្តាលក្បាលនេះ គឺបណ្តាលមកពីខួរក្បាលវាមិនពេញលលាដ៍ ដែលមានរាងទ្រវែងពងក្រពើ ម្ល៉ោះហើយផ្នែកខាងចុងក៏មានរាងស្រួច នៅចំត្រង់កន្លែងដែលមានឫសស្នែងត្រូវដុះតែម្តង ។ គាត់ក៏បានយកក្បាលចៀមមកពុះជាពីរឲ្យអ្នកផងមើល... សភាពការណ៍ក៏បានបង្ហាញឡើងដូចដែលគាត់បានពោលពិតមែន ។ រឿងនេះបានផ្តល់កិត្តិយសចំពោះអាណាសាកូរ៉ាយ៉ាងច្រើន ។ ក៏ប៉ុន្តែលោកគ្រូឡមពង់ក៏បានទទួលកិត្តិយសដ៏ក្រាស់ក្រែលផងដែរ ដោយហេតុថាបន្តិចក្រោយមក ក្រុមបក្សនយោបាយរបស់ធុយស៊ីឌីដក៏ដួលរលំអស់ទៅ ម្ល៉ោះហើយកិច្ចការរបស់រដ្ឋទាំងប៉ុន្មាន ក៏បានធ្លាក់ទៅក្នុងកណ្តាប់ដៃរបស់ប៉េរីក្លែសទាំងអស់ ។

អ្នកផងបានចាត់ទុកថា អាណាសាកូរ៉ាជាជនជាតិក្រិកទី១ ដែលបានសំរាំងសំរួចសម្ពន្ធទស្សនវិជ្ជាមួយជូនដល់សាធារណជន ។ គាត់បានទទួលស្គាល់ថា ទ្រឹស្តីចំបងនៅក្នុងលោក គឺសភាពឥតព្រំដែននៃចក្រវាឡ ហើយនិងបញ្ញាញាណដែលរៀបចំវត្ថុធាតុសព្វយ៉ាង ព្រមទាំងបង្កើតឲ្យមានមនុស្សសត្វនៅលើលោកនេះ ។ គឺដោយមូលហេតុនេះហើយបានជាទស្សនវិទូនៅក្នុងសម័យនោះ ហៅគាត់ថាជា «បញ្ញាញាណ » ។ គាត់មិនបានជឿថា បញ្ញានេះបានបង្កើតវត្ថុធាតុឲ្យចេញមកពីសភាពទទេនោះឡើយ ក៏ប៉ុន្តែគាត់បានជឿថា គឺបញ្ញានេះឯងដែលបានរៀបចំឲ្យមានសណ្តាប់ធ្នាប់នៃវត្ថុសព្វយ៉ាង ។ កាលពីដើមដំបូង, គាត់ពោល, របស់សព្វសារពើបានស្ថិតនៅលាយឡំគ្នា ហើយមានសភាពជាន់ពីលើគ្នាទីណាត់ទីងណែងតែដូច្នេះរៀងរហូតមក គឺរហូតដល់ថ្ងៃមួយដែលបញ្ញាញាណបែងចែកវត្ថុទាំងនេះឲ្យដាច់ចេញពីគ្នា ព្រមទាំងបានរៀបចំឲ្យរបស់និមួយៗរស់នៅក្នុងសណ្តាប់ធ្នាប់ ដូចយើងបានឃើញសព្វថ្ងៃ ។ អូវីឌ ( Ovide ) បានបញ្ចេញមនោសញ្ចេតនាបែបនេះឯង យ៉ាងច្បាស់លាស់ នៅពេលដែលគាត់បានចាប់ផ្តើមលាតត្រដាងទ្រឹស្តីនៃការប្រែក្រឡាធាតុរបស់គាត់ ។ ម៉្យាងវិញទៀត អាណាសាកូរ៉ាមិនដែលបានទទួលស្គាល់អាទិទេពណាមួយក្រៅពីបញ្ញាញាណនេះទេ ដែលគាត់បានយល់ថា ជាអ្នកបានបង្កើតពិភពលោករស់នៅសព្វថ្ងៃ ។ គាត់មានការខកចិត្តជាមួយនឹងព្រះក្លែងក្លាយជាច្រើន ដែលមនុស្សជំនាន់ដើមនាំគ្នាគោរពកោតខ្លាច ។ ម្ល៉ោះហើយជនឈ្មោះលូស៊្យាងក៏បានដើរផ្សា

យរបៀបក្លែងបន្លំថា យូពីទើរ ( ព្រះឥន្ទ ) បានបង្កើតឲ្យមានកាំរន្ទះ បាញ់តំរង់ទៅលើអាណាសាកូរ៉ារួចបាត់ទៅហើយ... គឺបណ្ដាលមកពីការមើលងាយមើលថោកដែលគាត់បានសំដែងចំពោះព្រះអាទិទេពផ្សេងៗ ។

* *

*

អាណាសាកូរ៉ាបានអះអាងថា ធម្មជាតិទាំងឡាយមិនដែលមានសភាពទទេនោះឡើយ... អ្វីៗក៏មានភាពពោរពេញ ចំណែកវត្ថុនិមួយៗ បើទោះជាមានទំហំតូចយ៉ាងណាក្ដី ក៏អាចត្រូវបំបែកបានគ្មានទីបញ្ចប់ ។ សូម្បីតែសត្វសុជ... ឧបមាបើមានអ្នកជំនាញពូកែ ដើម្បីបែងចែកជើងរបស់សត្វល្អិតនេះ នោះគេនឹងអាចទាញចំណែកយកទៅបោះបាចសាចរាយប៉ាយទៅ១០០ពាន់លានមេឃឯណោះ ហើយទោះជាយ៉ាងណាក៏គេមិនអាចទាញចំណែកឲ្យបានអស់ដែរ ព្រោះវាត្រូវនៅសល់តទៅទៀត ដែលគេអាចយកមកចែកបានដោយគ្មានព្រំដែន ។

គាត់មានជំនឿថា នៅក្នុងរូបកាយនិមួយៗ, ក្នុងមនុស្សសត្វក្ដី, ក្នុងវត្ថុធាតុក្ដីតែងតែមានធាតុតូចៗដូចគ្នាជាគុលិកា ៖ ឧទាហរណ៍ដូចឈាមជាដើម គឺតែងតែបង្កើតឡើងដោយគ្រាប់គុលិកាតូចៗជាឈាម, ដូចជាទឹកជាដើម តែងតែបង្កើតឡើងដោយគ្រាប់គុលិកាតូចៗជាទឹក, ចំពោះវត្ថុធាតុផ្សេងៗ ក៏មានលំនាំសម្ពន្ធដូចគ្នាដែរ ។ របៀបចងសម្ពន្ធនៅក្នុងធម្មជាតិដូចៗគ្នានេះ ត្រូវគាត់ឲ្យឈ្មោះថា homoeomeria ។ គឺទៅតាមរបៀបនេះឯងហើយ ដែល ឡាអ៊ែរ្ស បានលាតត្រដាងអំពីទ្រឹស្ដីរបស់គាត់ផងដែរ ។

អ្វីៗដែលគេអាចជំទាស់នឹងអាណាសាកូរ៉ាបាន គឺសភាពចាំបាច់ដែលរូបកាយទាំងឡាយនៅក្នុងធម្មជាតិ តែងតែត្រូវបង្កបង្កើតឡើង ដោយចំណែកប្លែកខុសគ្នាទាំងអស់... ឧបមាដូចជាឆ្អឹងសត្វកាន់តែរីកធំឡើង នៅពេលជាមួយគ្នា ដែលសត្វមិនដែលបានបរិភោគឆ្អឹងផង, ចំណែកសរសៃសត្វចេះតែរីកចំរើនផងដែរ នៅពេលដែលសត្វមិនដែលយកសរសៃជាអាហារផង; ចំណែកកំណាត់នៃឈាមកាន់តែរីកទំហំធំឡើងនៅពេលជាមួយគ្នា ដែលសត្វមិនដែលបានផឹកឈាមទាល់តែសោះ ។ ទស្សនវិទូរូបនេះ ក៏បានឆ្លើយតបវិញថា តាមសេចក្ដីពិត វាគ្មានរូបកាយអ្វីនៅក្នុងលោកនេះ ដែលត្រូវបង្កបង្កើតឡើងដោយចំណែកដូចគ្នាទាំងអស់នោះទេ; ដូចជានៅក្នុងស្មៅជាដើម វាតែងតែមានជាតិសាច់, ជាតិឈាម, ជាតិឆ្អឹង, ជាតិសរសៃ...ពីព្រោះដោយហេតុថា សត្វរស់រានមានជីវិតដោយជាតិនេះឯង ។ ប៉ុន្តែយើងគួរគិតថារូបកាយនិមួយៗ តែងតែជញ្ជក់យករសជាតិសំខាន់ជាងគេ ដែលមានឈ្មោះនាម

នៅក្នុងរូបរបស់ខ្លួនឯង... មានជាឧទាហរណ៍របស់ខ្លះដែលគេហៅថាឈើ ឬក៏ស្មៅ ...វាទាល់តែរបស់ទាំងនោះត្រូវបង្កបង្កើតដោយចំណែកឈើ ឬចំណែកស្មៅច្រើនជាងគេបំផុត... ម្ល៉ោះហើយគ្រាប់គុលិកាជាឈើ ឬជាស្មៅត្រូវបានរៀបចំប្រមូលយ៉ាងក្រាស់ក្រែលនៅលើផ្ទៃសរពាង្គកាយរបស់គេ ។

គាត់បានយល់ថា ថ្ងៃគ្រាន់តែជាដែកក្តៅមួយដុំធំជាងជ្រោយប៉េឡូប៉ូណែស ( **Péloponèse** ) តែប៉ុណ្ណោះ ។ ចំណែកព្រះច័ន្ទវិញ គ្រាន់តែជាដុំវត្ថុធាតុមួយដែលពន្លឺជ្រៀតចូលមិនបាន... ព្រមទាំងជាទីកន្លែងមួយដែលមនុស្សអាចរស់នៅបានដោយហេតុថានៅទីនោះ មានវាល មានភ្នំ ដូចតែនៅលើផែនដីនេះផងដែរ ។ ចំណែកពពួកផ្កាយដុះកន្ទុយវិញ គឺគ្រាន់តែជាកំរងផ្កាយផ្សងព្រេងជាច្រើន ដែលជួបប្រទះហើយប្រមូលផ្តុំគ្នាដោយចៃដន្យ ។ ចំណែកព្រះពាយបោកបក់វិញ ត្រូវប្រគុំឡើងដោយសារតែធាតុកំដៅថ្ងៃធ្វើឲ្យខ្យល់រីងគាំង ។ ចំណែករន្ទះវិញត្រូវបង្កបង្កើតឡើងដោយពពករត់បុកទង្គិចគ្នា... នៅក្នុងពេលជាមួយគ្នានោះ ផ្លេកបន្ទោរក៏លេចធ្លោឡើង ក៏ដោយសារតែដុំពពកវាឆ្កួតគ្នាផងដែរ ។ ចំណែកការរញ្ជួយផែនដីវិញ គឺវាបណ្តាលមកពីខ្យល់ថប់ដែលសម្ងំកប់នៅក្នុងរូងនៃផែនដី រីឯទឹកទន្លេនីល ( ទន្លេនៅប្រ-ទេសអេហ្ស៊ីព្ទ ) ដែលវាចេះតែហៀរហូរលិចតំបន់ជិតខាង គឺគ្មានបណ្តាលអ្វីក្រៅតែពីដុំទឹកកកនៅស្រុកអេត្យូពី ដែលវារលាយទៅហើយបានបំប៉ោងប្រភពនៃទន្លេនេះឲ្យរីកធំឡើង ។

អាណាសាកូរ៉ាបានយល់ថា គឺជាកម្លាំងខ្យល់ដែលបានបង្កើតឲ្យមានចលនារបស់តារានានា ហើយនៅពេលដែលគេនិយាយផ្ទុញផ្ទាល់ឲ្យគាត់វិញថា ដំណើរទៅនិងមកនៃតារាមួយចំនួន ដែលគេអាចមើលឃើញចុងប៉ូចនៃផែនដីទាំងសង្ខាងនោះតើវាយ៉ាងណាដែរ... គាត់ក៏បានឆ្លើយតបវិញថា រឿងទាំងអស់នេះគឺបណ្តាលមកពីសម្ពាធនៃខ្យល់ ដែលរុញទៅរុញមក, រុញក្រុមតារាឲ្យមានដំណើរទៅមកដូចដែករុស្ស៊ីរ នៅពេលដែលតារាទាំងនេះរសាត់មកដល់ដំណាក់ការមួយ ។

គាត់បានអះអាងថា ផែនដីមានភាពសំប៉ែត... ហើយម្យ៉ាងទៀត ដោយដីមានទម្ងន់ធ្ងន់ជាងគេបំផុត ដីក៏កាន់កាប់ទីកន្លែង ដែលទាបជាងគេនៅក្នុងលោកនេះ ។ ចំណែកទឹកវិញដែលហូរនៅលើផ្ទៃនៃផែនដី បានត្រូវធ្វើឲ្យរីងស្ងួតដោយសារតែកំដៅថ្ងៃ ដែលផ្លាស់ប្តូរធាតុទឹកឲ្យទៅជាផ្សែង ។ ផ្សែងទឹកទាំងនេះ បានត្រូវហួតឡើងទៅលើជាអាកាស ហើយធ្លាក់មកវិញក្លាយត្រឡប់ទៅជាភ្លៀង ។

នៅពេលរាត្រី នៅពេលដែលមានធាតុអាកាសស្ងប់ស្ងាត់ល្អ គេអាចមើលឃើញរង្វង់សស្កុង ដែលគេហៅថាផ្លូវនៃទឹកដោះ ។ អ្នកប្រាជ្ញបុរាណខ្លះបានយល់ថាជាមាគ៌ាដែលព្រះអាទិទេពទាំងឡាយ តែងធ្វើដំណើរទៅជួបនឹងព្រះយូពីទើរ

(ព្រះឥន្ទ) ។ អ្នកប្រាជ្ញខ្លះទៀតបានយល់ថា គឺជាទីកន្លែងមួយ ដែលស្រូបយកព្រលឹងនៃវិរជនទាំងប៉ុន្មាន បន្ទាប់ពីរូបកាយរបស់ពួកគេស្លាប់អស់ទៅហើយ ៖ អាណាសាកូរ៉ាបានយល់ច្រឡំត្រង់កន្លែងនេះ ជាមួយគ្នានឹងពួកក្រុមទស្សនវិទូឯទៀតៗទាំងអស់ ។ គាត់បានយល់ថា រឿងនេះគ្រាន់តែជាការបញ្ចាំងឆ្លុះនៃពន្លឺថ្ងៃ ដែលឆ្លងកាត់មេឃ ហើយដែលធ្វើឲ្យយើងមើលឃើញថាជាដូច្នេះ, គឺពីព្រោះដោយហេតុថា រវាងផែនដីហើយនិងមាត់នៃទឹកដោះ វាឥតមានតារាភ្លឺអ្វីមួយនៅចំត្រង់ចន្លោះកណ្ដាល ដែលអាចមានពន្លឺភ្លឺថាំង ឲ្យលើសពន្លឺថ្ងៃនោះបានឡើយ ។

គាត់បានពោលថា សត្វដែលមានជីវិតរស់នៅជាដំបូងនៅលើផែនដីនេះ គឺបានឧប្បត្តិកឡើងដោយសារធាតុកំដៅហើយនិងទឹកសន្សើម... ហើយជាបន្ទាប់មកសត្វទាំងនេះក៏បន្តពូជកូនចៅតវង្សត្រកូលជារៀងរហូតមក ។

បើមានថ្មអ្វីមួយធ្លាក់មកពីលើមេឃ ៖ អាណាសាកូរ៉ាក៏ទាញយោបល់ភ្លាមមួយរំពេចថា មេឃនៅខាងលើធ្វើពីថ្មទេតើ... ចំណែកដំបូលមេឃដែលមានសភាពកោងនោះ នៅមានល្បឿនលឿនពេកក្រៃ ហើយប្រសិនបើចលនាដ៏គំហុកនេះឈប់តែមួយភ្លែតនោះ... ម៉ាស៊ីននៃភពផែនដីទាំងមូល នឹងត្រូវរបើករបាញខ្ទេចខ្ទីអស់តែមួយពព្រិចភ្នែក ។

ថ្ងៃមួយគាត់បានប្រកាសថា នឹងមានថ្មមួយដុំធ្លាក់មកពីព្រះអាទិត្យ ៖ ព្រឹត្តិការណ៍ក៏បានកើតឡើងដូចដែលគាត់បានទាយទុកជាមុនពិតមែន, ដុំថ្មបានធ្លាក់ចូលទៅក្នុងទន្លេអេកូស ។

អាណាសាកូរ៉ាធ្លាប់មានជំនឿថា អ្វីៗដែលសព្វថ្ងៃមានរូបរាងជាដីគោក, កាលពីព្រេងនាយធ្លាប់មានភាពជាសមុទ្រពេញលេញ, ហើយអ្វីៗដែលសព្វថ្ងៃមានរូបរាងជាសមុទ្រពេញលេញ កាលពីព្រេងនាយមានសភាពជាដីគោក ។

ជនម្នាក់បានសាកល្បងសួរគាត់ថា តើសមុទ្រអាចមានលទ្ធភាពរាតត្បាតឡើងលើកំពូលភ្នំឡម្ពសាកបានពីរបីថ្ងៃឬទេ ៖ « ពិតប្រាកដហើយ, គាត់ឆ្លើយតប, វៀរលែងតែពេលវេលាមិនទាន់មកដល់ » ។

គាត់បានពោលថា ទ្រព្យសម្បត្តិដ៏ល្អប្រសើរជាងគេនៅលើភពផែនដីនេះ គឺការត្រេកត្រអាលក្នុងការគន់មើលនូវអាថ៌កំបាំងទាំងឡាយ ដែលមានបង្កប់នៅក្នុងធម្មជាតិ ។

គឺហេតុដូច្នេះហើយ បានជានៅពេលគេសួរគាត់ថា តើការចាប់ជាតិកំណើតរបស់គាត់មានផលប្រយោជន៍សំរាប់អ្វីដែរក្នុងលោកនេះ ៖ គាត់ឆ្លើយថា គឺសំរាប់គយគន់មើលផ្ទៃមេឃនិងផែនដី... មើលព្រះអាទិត្យ, ព្រះច័ន្ទ និងវត្ថុដ៏ល្អប្រណិតឯទៀតៗ ។

ជនម្នាក់បានសួរគាត់ថា តើបុរសណាទៅដែលជាមនុស្សសប្បាយជាងគេបំផុតនៅលើលោកនេះ ? ។ នោះគឺច្បាស់ជាពុំមែនពួកក្រុមមនុស្ស ដែលឯងយល់ស្មាននោះទេ, គាត់ឆ្លើយតប, ជននោះគឺស្ថិតនៅក្នុងចំណោមមនុស្សដែលឯងបានយល់ថា ជាក្រុមជនវេទនារហេមរហាម ។

គាត់បានឮបុរសម្នាក់ដែលចេះតែត្អូញត្អែរថា ខ្លួនច្បាស់ជានឹងយកឆ្អឹងមកចោលនៅស្រុកគេមិនខាន ៖ « វាមានទាស់ខុសអ្វីប៉ុណ្ណឹង, អាណាសាកូរ៉ាបានពោលទៅកាន់ជននោះ, វាឥតមានទីកន្លែងណាមួយនៅលើពិភពលោកនេះ ដែលគ្មានផ្លូវចុះទៅឋាននរកនោះទេ » ។

ថ្ងៃមួយ គេបានប្រាប់គាត់ថា កូនគាត់បានទទួលសេចក្ដីស្លាប់ ។ គាត់បានទទួលយកដំណឹងនេះដោយចិត្តនឹងថ្កល់ ៖ « ខ្ញុំដឹងជាស្រេចមុនទៅហើយ ( គាត់ពោលឡើង ) ថាកូនដែលខ្ញុំបានបង្កើតមក គឺគ្រាន់តែជាជនម្នាក់ ដែលចៀសស្លាប់មិនរួចប៉ុណ្ណោះ ។ បន្ទាប់ពីចេញវាចាដូច្នេះហើយ គាត់ក៏បានធ្វើដំណើរទៅកប់កូនរបស់គាត់ដោយខ្លួនឯង ។

សេចក្ដីគោរពនិងស្ងើចសរសើរចំពោះទស្សនវិទូរូបនេះ ពុំបានស្ថិតស្ថេរយូរឡើយនៅទីក្រុងអាត្វែន ។ ពួកអ្នកស្រុកនៅអាត្វែនបានលើកយកសំណុំរឿងរបស់គាត់បញ្ជូនទៅឲ្យពួកចៅក្រម... ដោយចោទប្រកាន់រូបគាត់ជាសាធារណៈ ។ បុព្វហេតុនៃការចោទប្រកាន់នេះ ត្រូវគេតំណាលតមកប្លែកៗពីគ្នា ។ ការចោទប្រកាន់ជាទូ-ទៅក្នុងមតិមហាជន គឺស្ថិតនៅត្រង់គាត់មិនបានគោរពព្រះ ដោយហ៊ានអះអាងថា ថ្ងៃដែលអ្នកផងគោរពនិងស្រឡាញ់ដូចព្រះអាទិទេព គឺគ្រាន់តែជាដុំដែកមួយដ៏ក្ដៅតែប៉ុណ្ណោះ ។ អ្នកខ្លះទៀតបានពោលថា ហួសពីបទឧក្រិដ្ឋកម្មនៃការមិនជឿព្រះ, អាណាសាកូរ៉ាបានត្រូវចោទពីបទក្បត់ជាតិថែមទៀត ។ នៅពេលដែលគេមកប្រាប់គាត់ថា គាត់ត្រូវកាត់ទោសប្រហារជីវិតដោយពួកអ្នកទីក្រុងអាត្វែន, គាត់ហាក់ដូចជាគ្មានរំភើបញ្ជាប់ញ័រអ្វីសោះ ។ « ជាយូរណាស់មកហើយ, គាត់ពោល, ដែលធម្មជាតិក៏បានកាត់ទោសរបៀបដូច្នេះដែរចំពោះពួកអ្នកទាំងនេះ » ។

ប៉េរីក្លែស ដែលធ្លាប់ជាសាវ័ករបស់គាត់បានប្រឹងប្រែងការពាររូបគាត់យ៉ាងខែងរែងមែនទែន រហូតដល់គេបានបន្ធូរបន្ថយទោសឲ្យគាត់ខ្លះៗ ។ ពួកចៅក្រមក៏បានកាត់ទោសឲ្យគាត់បង់ផាកពិន័យជាប្រាក់៥តម្លឹង ( នៅក្នុងបុរាណកាលក្រិក, តម្លឹងគឺជាទម្ងន់២០ទៅ២៧គីឡូ ។ បន្ទាប់មកគឺជាចំនួនលុយដែលមានតម្លៃស្មើនិងមាសឬប្រាក់មួយតម្លឹង )... ហើយនិងបាននិរទេសរូបគាត់ឲ្យទៅរស់នៅបរទេស ។ អាណាសាកូរ៉ាបានទទួលទុក្ខទោសទណ្ឌកម្មដោយចិត្តរឹងប៉ឹងអង់អាច ។ គាត់បានចំណាយពេលនៃការឃ្លាតចាកស្រុកទេសរបស់គាត់ ដើម្បីធ្វើដំណើរទៅប្រទេសអេយីព្ទ និង

ទីកន្លែងដទៃផ្សេងៗទៀត ដើម្បីជជែកវែកញែកពិភាក្សាជាមួយនឹងអ្នកចេះដឹងជាច្រើនគ្នា ហើយនិងដើម្បីដឹងជ្រួតជ្រាបនូវទំនៀមទំលាប់បរទេស ។ បន្ទាប់ពីការស្វែងរកចំណេះដឹងដោយសុខចិត្តសុខកាយរួចហើយ, គាត់ក៏បានវិលត្រឡប់មកក្លាសូម៉ែន ដែលជាទីកន្លែងស្រុកកំណើតរបស់គាត់វិញ ។ គាត់បានសង្កេតឃើញថា ដីចំការរបស់គាត់គ្មាននរណាថែទាំ គ្មាននរណាដាំដំណាំទាញយកផលផ្លែផ្កាអ្វីទាំងអស់ គឺត្រូវគេបោះបង់ចោលទាំងស្រុង ៖ « បើរបស់ទាំងនេះមិនត្រូវរលត់រលាយទេ, គាត់ពោល, អាត្មាអញនឹងត្រូវរលត់រលាយខ្លួនឯង » ។

* *

*

អាណាសាគូរ៉ាបានខំប្រឹងប្រែងលើសពីធម្មតា ដើម្បីបង្ហាត់បង្រៀនផ្តល់ចំណេះវិជ្ជាទៅប៉េរីក្លែស, មិនត្រឹមតែប៉ុណ្ណេះ បានទាំងបំរើនៅក្នុងរដ្ឋាភិបាលរបស់បុគ្គលនេះទៀតផង ។

ប៉េរីក្លេសពុំបានសំដែងនូវការដឹងគុណាគ្រប់គ្រាន់ចំពោះគ្រូរបស់ខ្លួននោះឡើយ ។ អ្នកខ្លះបានទាំងចោទទៀតផងថា បុគ្គលនេះបានបោះបង់ចោលលោកគ្រូរបស់ខ្លួន នៅពេលចុងចប់នៃជីវិតរបស់គាត់ ។

អាណាសាគូរ៉ា នៅពេលដឹងថាខ្លួនចាស់ជរា, ក្រីក្រ ហើយត្រូវគេបោះបង់ចោល, ក៏រុំខ្លួនក្នុងអាវម៉ង់តូ ( អាវក្រាស់ទ្រវែង ) របស់គាត់ ហើយបានសំរេចចិត្តបណ្តោយខ្លួនឲ្យស្លាប់ដោយសេចក្តីអត់ឃ្លាន ។

ប៉េរីក្លែសដែលបានដឹងរឿងនេះ ដោយមានគេលួចប្រាប់ ក៏កើតសេចក្តីតក់ស្លុតក្នុងចិត្តយ៉ាងខ្លាំង ។ ជននេះក៏បានខំរត់ប្រញាប់ប្រញាល់ទៅជួបអាណាសាគូរ៉ា ។ កូនសិស្សក៏បានអង្វរករលោកគ្រូឲ្យផ្លាស់ប្តូរការសំរេចចិត្តវិញ ។

ប៉េរូក្លែសបានខំប្រឹងបញ្ជាក់ពន្យល់អំពីស្ថានភាពទន់ខ្សោយរបស់រដ្ឋ នៅពេលដែលរដ្ឋបាត់បង់មនុស្សសំខាន់ម្នាក់ដូចរូបគាត់, អាណាសាគូរ៉ានិងការអភ័ព្វរបស់ខ្លួនឯងផ្ទាល់ នៅពេលដែលខ្លួនបាត់បង់ទីប្រឹក្សាម្នាក់ដែលប្រកបដោយភក្តីភាព ។ អាណាសាគូរ៉ាក៏បើកបង្ហាញមុខជិតដាច់ខ្យល់របស់គាត់ ៖

« ឱ ! ប៉េរីក្លែស, គាត់ពោល, មនុស្សដែលត្រូវការប្រើចង្កៀង ក៏មានការចាំបាច់ដាក់ប្រេងទៅក្នុងចង្កៀងនោះដែរ » ។

ឡាអ៊ែរក្សបានធ្វើសេចក្តីរាយការណ៍ថា អាណាសាគូរ៉ាបានទទួលមរណភាពនៅឡម្ពសាក ហើយនៅពេលដែលគាត់ហៀបក្សៀរតែផុតរលត់ជីវិត, ពួកអ្នកមុខអ្នកការនៅក្នុងទីក្រុងទាំងអស់ បានមកសួរយោបល់គាត់ថា តើគាត់មានបង្គាប់បញ្ជាឲ្យ

ធ្វើអ្វីទេ ? ។ គាត់ក៏បានផ្តាំទៅអ្នកទាំងនោះថា គួរអនុញ្ញាតឲ្យក្មេងៗឈប់សំរាកមួយឆ្នាំម្តង ព្រមទាំងឲ្យពួកគេលេងសប្បាយនៅថ្ងៃដែលគាត់ស្លាប់ ។

ទំនៀមទំលាប់ដូច្នេះ ក៏ត្រូវគេបានប្រកាន់គោរពតាមជាយូរអង្វែងឆ្នាំតមក ។ អាណាសាកូរ៉ា មានអាយុ៧២ឆ្នាំនៅពេលដែលគាត់ស្លាប់ ។ គឺនៅក្នុងអូឡាំព្យាដទី៨៨ ។

❏ ❏

❏

# ជីវិតរបស់អង់ទីសតែន
# ANTISTHÈNE

( គាត់ធ្លាប់មានឋានៈជាសាវ័ករបស់សូក្រាត, ធ្លាប់រស់នៅក្នុងកាលសម័យជាមួយគ្នានឹងប្លាតុង, និងសាវ័កដទៃផ្សេងៗទៀតរបស់សូក្រាត ) ។

○

... ពួកសាវ័ករបស់សូក្រាតទាំងអស់គ្នា, បន្ទាប់ពីគ្រូរបស់ខ្លួនបានស្លាប់បាត់ទៅ, បានត្រូវចែកជាបីក្រុមផ្សេងៗគ្នា, ដែលគេហៅថាពួកស៊ីនីក, ពួកអាកាដេមីក, និងពួកស៊ីរ៉េណាអ៊ីក។

អង់ទីសតែនជាមេក្រុមរបស់ពួកស៊ីនីក ( កកន ៖ Cyniques ..ពួកមិនសូវខ្វល់ខ្វាយនឹងច្បាប់សុជីវធម៌, នឹងសីលធម៌ដែលត្រូវចាត់ទុកថាជាអំពើពុតត្បុត,... នឹងទំនៀមទម្លាប់ នឹងរបៀបរស់នៅសមរម្យនៅក្នុងសង្គមជាតិ អង់ទីសតែនអាចប្រៀបប្រដូចបានទៅនឹងពួកមេបក្សស្នូមនៅក្នុងរឿងបុរាណចិន ... ) ។ មានពាក្យនិទានផ្សេងៗគ្នាពីច្រើនស្រទាប់មជ្ឈដ្ឋាន ទាក់ទងនិងក្រុមទស្សនវិទូ ដែលគេហៅថាពួកស៊ីនីក ៖ អ្នកខ្លះបានពោលថា គេបានប្រសិទ្ធនាមឲ្យពួកអ្នកទាំងនេះដូច្នេះ ក៏ដោយសារតែពួកនេះរស់នៅដូចសត្វឆ្កែ ។ អ្នកខ្លះទៀតបានពោលថា គឺដោយព្រោះទីកន្លែងដែលអង់ទីសតែនបានបង្ហាត់បង្រៀន នៅមិនឆ្ងាយប៉ុន្មានពីមាត់ទ្វារមួយរបស់ទីក្រុងអាតែ្ថនដែលគេហៅថាស៊ីណូសាគ ( Cynosargues ) ។

អង់ទីសតែន ជាកូនប្រុសរបស់ជនទីក្រុងអាតែ្ថនម្នាក់ ដែលមានឈ្មោះថាជាអង់ទីសតែនដូចគ្នា, និងរបស់ស្រីបម្រើម្នាក់ ។ នៅពេលដែលអ្នកខ្លះបានស្តីបន្ទោសឲ្យគាត់ថា ម្តាយរបស់គាត់មកពីស្រុកព្រីស៊ី ( Phrygie ៖ ស្រុកអ្នកងារ ឬខ្ញុំកញ្ជះគេ) ...គាត់បានឆ្លើយតបទៅគេវិញថា ៖ « អស់លោកចង់ថាម៉េចក៏បានដែរ; ស៊ីបែលដែលត្រូវជាម្តាយរបស់ព្រះ ...មិនគឺមកពីស្រុកនោះដូចតែគ្នាទេឬ ?? » ។

... មុនដំបូងគាត់មានឋានៈជាសាវ័ករបស់វាគ្មិនគ្គរស៊ីយ៉ាស (Gorgias) ។ បន្ទាប់មកគាត់ក៏បានបង្ហាត់បង្រៀនដោយសម័ត្ថភាពខ្លួនឯងអស់មួយរយៈពេល ។ ដោយគាត់មានទេពកោសល្យជាពន់ពេក ក្នុងការបញ្ចេញសំនួនវោហារ... អ្នកផងបានរត់មកពីគ្រប់ទិសទីដើម្បីស្តាប់ពាក្យសំដីរបស់គាត់ ។ កេរ្តិ៍ឈ្មោះដ៏ល្បីល្បាញរបស់សូ

ក្រាតបានប្រទាញទឹកចិត្តរបស់គាត់ឲ្យទៅទទួលមេរៀនរបស់ទស្សនវិទូរម្នាក់នេះ។ នៅពេលដែលគាត់ត្រឡប់មកវិញ ដោយគាត់មានសេចក្ដីពេញចិត្តនឹងសូក្រាតខ្លាំងពេកទៅ អង់ទីសតែនក៏បាននាំសាវ័ករបស់គាត់ ទៅបញ្ចូលសាលារបស់សូក្រាតតែទាំងអស់ មិនត្រឹមតែប៉ុណ្ណោះគាត់បានសម្រេចចិត្តថា មិនទទួលវិជ្ជាក្នុងសាលាណាផ្សេងទៀតទេ ។ គាត់មានលំនៅឋាននៅក្នុងផៃពីរ៉េ ... ម៉្លោះហើយក្នុងមួយថ្ងៃៗ គាត់បានធ្វើដំណើរចម្ងាយ៨០ស្តាដ ( យោជន៍ ? ) ដើម្បីបំពេញសេចក្ដីត្រេកត្រអាលរបស់គាត់ក្នុងការទៅស្ដាប់ដំបូន្មានរបស់សូក្រាត ។

អង់ទីសតែនជាមនុស្សម្នាក់រស់នៅដូចអ្នកសច្ចំ ពោលគឺប្រកបដោយវិន័យតឹងរ៉ឹងជាទីបំផុត ។ គាត់បានបន់ស្រន់ចំពោះព្រះថា សូវឲ្យគាត់កើតរោគឆ្កួតវិញល្អជាជាងនឹងការជាប់ជំពាក់ចិត្តជាមួយនឹងជីវិតស្រើបស្រាល ។ គាត់បានដាក់ក៏រិតបន្ដឹងបន្តែងជីវភាពរបស់ពួកសាវ័ករបស់គាត់ជាអតិបរិមា ។ នៅពេលដែលជនម្នាក់បានសួរគាត់ថា ហេតុអ្វីបានជាគាត់ធ្វើដូច្នេះ គាត់បានឆ្លើយថា ៖ « តើពួកពេទ្យហ្មព្យាបាលមិនធ្វើដូច្នេះដែរទេឬ ក្នុងការថែទាំព្យាបាលអ្នកជំងឺ ? » ។

គឺអង់ទីសតែននេះឯង ដែលបានចាប់ផ្ដើមពាក់អាវម៉ង់តូឌុប ( ពីរជាន់ ), ប្រកបដោយថង់យាមមួយនិងដំបងឈើច្រត់ ដែលជាសញ្ញាចំបងនិងសម្បត្តិទ្រព្យរបស់ពួកក្រុមទស្សនវិទូស៊ីនីកទាំងអស់... ដែលអនុញ្ញាតឲ្យពួកគេប្រណាំងប្រជែងនឹងព្រះយូពីទើរតែម្ដងក្នុងការស្វះស្វែងតណ្ហើមយកសុភមង្គល ។ គាត់បានទុកពុកចង្ការឲ្យវែងធ្លាក់ចុះក្រោម ដោយមិនដែលបានប៉ះពាល់តែបន្តិចបន្តួចសោះឡើយ ។ មិនត្រឹមតែប៉ុណ្ណោះ គាត់ស្លៀកពាក់ដោយរបៀបខ្ជីខ្ជាជាទីបំផុត ។

គាត់មានការពេញចិត្តនឹងចិត្ត នឹងធម្មក្រិត្យាតែមួយមុខប៉ុណ្ណោះ (វិជ្ជាទាក់ទងនឹងផ្នែកសីលធម៌ ) ហើយបានចាត់ទុក វិទ្យាសាស្ត្រអ្វីផ្សេងៗទៀតជារបស់ឥតប្រ-យោជន៍ ។

គាត់បានយល់ថាសម្បត្តិទ្រព្យដ៏មានតម្លៃថ្លៃថ្នូរជាទីបំផុតនៅលើផែនដីនេះ គឺការគោរពវិន័យសីលធ៌ម ហើយនិងការមាក់ងាយសភាពសំបូរសប្បាយមានបាន ។

ពួកទស្សនវិទូស៊ីនីកទាំងអស់បានរស់នៅក្នុងបែបបទតឹងរ៉ឹង និងមធ្យ័តក្រៃលែង ។ ពួកគេបានរស់នៅដោយបរិភោគតែបន្លែផ្លែឈើតែប៉ុណ្ណោះ ។ ពួកគេផឹកតែទឹកហើយមិនដែលមានការទើសទាល់អ្វីនឹងដេកផ្ទាល់ដោយដី ។ ពួកស៊ីនីកបានអះអាងថា ព្រះជាម្ចាស់មិនដែលត្រូវការចង់បានរបស់អ្វីសោះទេ... ម៉្លោះហើយបើកាលណារូបយើងទាំងអស់គ្នាលែងត្រូវការចង់បានអ្វីទាំងអស់ គឺមានន័យថាពួកយើងទាំងអស់គ្នាកំពុងតែខិតចូលទៅជិតក្បែរនិស្ស័យរបស់ព្រះរួចហើយ ។ ពួកគេទាំងអស់គ្នាបានលើកដម្កើងជីវិតកិត្តិយស ក្នុងការមាក់ងាយកិត្តិយស, ទ្រព្យសម្បត្តិ, សេចក្ដី

ថ្លៃថ្នូរនិងសេចក្ដីចំណេញសុខស្រួលទាំងប៉ុន្មាន ដែលធម្មជាតិឬព្រេងសំណាងបានផ្ដល់ ។ ម្យ៉ាងវិញទៀត គឺជាពួកជនព្រហើនកោងកាចមុខក្រាស់គ្មានចេះអៀនខ្មាស់នឹងនរណា ... ដែលគ្មានដែលរារែកឬខ្លាចរអារ ក្នុងការប្រព្រឹត្តអំពើដ៏អាមាស់ថោកទាបជាទីបំផុតដែរ ។ ពួកគេគ្មានចេះស្គាល់ការគួរសម, គ្មានចេះរបៀបសមរម្យ, គ្មានស្គាល់របៀបថ្លៃថ្នូរ ... ហើយមិនដែលយកចិត្តយកថ្លើមនរណាទាំងអស់ ។

○

អង់ទីសតែនជាមនុស្សមានបញ្ញាខ្ពង់ខ្ពស់ណាស់ ជាអ្នកមានសំដីខ្លឹមសារដែលគេចូលចិត្តប្រាស្រ័យទាក់ទងជាមួយជាពន់ពេក, គាត់អាចបង្វិលការពិភាក្សានៅក្នុងសភាររបស់គាត់បានតាមចំណង់ ។

គាត់បានសំដែងនូវសេចក្ដីក្លាហានដ៏ពិតប្រាកដនៅក្នុងសង្គ្រាម នៅតាណាក្រាដែលនៅទីនោះគាត់បានបញ្ចេញស្នាដៃចម្បាំងរបស់គាត់យ៉ាងគួរឲ្យស្ញប់ស្ញែង ។ សូក្រាតពេលបានទទួលព័តមានដូច្នេះ ក៏មានសេចក្ដីពេញចិត្តពេកណាស់ ។ ក៏ប៉ុន្តែនៅពេលបន្តិចក្រោយមក ដោយមានមនុស្សម្នាក់បានចោទប្រកាន់គាត់ថា ម្ដាយរបស់គាត់មានសញ្ជាតិជាព្រីស៊ី ... អង់ទីសតែនក៏បានឆ្លើយតបវិញថា ៖ « លោកចង់ថាម៉េច ? លោកនឹកស្មានថាមនុស្សដ៏ខ្លាំងពូកែម្ល៉ឹងៗ ( ដូចខ្ញុំ ) ... អាចកើតចេញមកត្រឹមតែពីអាពាហ៍ពិពាហ៍រវាងជនអាតែ្ទនប្រុស ហើយនិងជនអាតែ្ទនស្រី តែប៉ុណ្ណោះទេឬ? » ។ ថ្ងៃក្រោយមកទៀត សូក្រាតក៏មិនអាចចៀសវាង មិនស្ដីបន្ទោសអង់ទីសតែនបាន ... អំពីសភាពឆ្មើងឆ្មៃរបស់គាត់នេះ ។

ថ្ងៃមួយ ... សូក្រាតឃើញអង់ទីសតែន ចេះតែបង្វិលអាវម៉ង់តូរបស់គាត់ , ដើម្បីឲ្យអ្នកផងបានឃើញអំពីប្រហោងអាវម៉ង់តូនេះ ដែលវាធ្លុះធ្លាយរហែកអស់មួយចំហៀង ។ សូក្រាតក៏បានពោលថា ៖ « ឱ! អង់ទីសតែន អញបានឃើញ អំនួតក្អេងក្អាងរបស់ឯងធ្លាយចេញមកតាមរន្ធអាវម៉ង់តូរបស់ឯងមែនពិត ! » ។

នៅពេលដែលអង់ទីសតែនបានឮ ពួកជនអ្នកទីក្រុងអាតែ្ទនអួតអាងថា ថាពួកខ្លួនមានដើមកំណើតនៅក្នុងទីក្រុង ដែលគេកំពុងរស់នៅស្រាប់ ... គាត់ក៏បានពោលចំអកឲ្យវិញថា ៖ « រឿងនេះ ក៏វាមិនសូវខុសគ្នាពី រឿងសត្វអណ្ដើកនិងសត្វខ្យង ... ពីព្រោះសត្វអណ្ដើកហើយនិងសត្វខ្យង វារស់នៅទីកន្លែងកំណើតរបស់វាតែប៉ុណ្ណោះ ...មិនដែលទៅណាឆ្ងាយពីទីនោះទេ » ។

សម័យថ្ងៃមួយ បុរសម្នាក់បានយកកូនរបស់ខ្លួន មកបង្ហាញដល់អង់ទីសតែន

ដើម្បីឲ្យធ្វើជាសាវ័ករបស់គាត់ ហើយក៏បានសួរដល់គាត់ថា ៖ « តើកូនប្រុសរបស់ខ្ញុំត្រូវការរបស់អ្វីនៅក្នុងពេលនេះ ? » ។ អង់ទីសតែនក៏បានពោលតបថា ៖ « គឺសៀវភៅថ្មីមួយ, ស្លាបប៉ាកាថ្មី ហើយនិងក្តាខៀនថ្មីសំរាប់ឆ្លាក់អក្សរមួយចំនួន » ។ និយាយបែបនេះ, អង់ទីសតែនបានចង់សំដែងឲ្យឃើញថា ដួងវិញ្ញាណរបស់កូនប្រុសម្នាក់នេះ វាត្រូវតែដូចក្រមួនថ្មី ដែលគ្មានទាន់មាននរណាឆូតឬឆ្លាក់ ឲ្យចេញជាសំណាមអ្វីទាំងអស់ ។

★ មានម្តងគេបានចោទសំនួរចំពោះគាត់ថា របស់អ្វីដែលគួរឲ្យស្រើបស្រាលចង់បានជាងគេបំផុត ?

« គឺ, អង់ទីសតែនឆ្លើយ, លក្ខណៈនៃមនុស្ស ដែលបានស្លាប់ទៅវិញដោយមានសេចក្តីសប្បាយក្នុងចិត្តទៅជាមួយផង ...» ។

★ គាត់មានទំនាស់ចិត្តនឹងពពួកមនុស្សច្រណែនគេ ...ដែលមានការល្វីងជូរចត់ក្នុងចិត្តជាខ្លាំង ហើយបណ្តាលឲ្យរីងរៃតែរូបខ្លួនឯង ហាក់ដូចជាធាតុដែកដែលត្រូវស៊ីរបេះរបាញដោយសារច្រែសរបស់ខ្លួនឯងបង្កើត ។ អង់ទីសតែនមានយោបល់ថា ប្រសិនបើគេបង្ខំឲ្យគាត់ជ្រើសរើស, គាត់នឹងជ្រើសរើសយកលក្ខណៈជាសត្វក្អែកវិញ ... វាប្រសើរគ្រាន់បើជាជាងក្លាយខ្លួនទៅជាពួកមនុស្សច្រណែននិន្ទារគេ គឺដោយហេតុថា សត្វក្អែកយ៉ាងច្រើនណាស់វាហែកចោះតែមនុស្សស្លាប់ ... ចំណែកពពួកមនុស្សច្រណែនគេវិញ ច្រើនតែនាំគ្នាហែកហួរមនុស្សដែលកំពុងតែនៅរស់ ។

★ ថ្ងៃមួយ ជនម្នាក់បាននិយាយប្រាប់គាត់ថា សង្គ្រាមតែងតែបណ្តាលឲ្យស្លាប់ដល់ជនរងគ្រោះជាច្រើន ។ អង់ទីសតែនក៏បានឆ្លើយតបវិញថា ៖ « ការនេះជាការពិត, ក៏ប៉ុន្តែសង្គ្រាមវាបានបង្កើតឲ្យមានជនរងគ្រោះវេទនាច្រើនជាង ពួករងគ្រោះដែលវាប្រមូលយកទៅ »។

★ នៅពេលដែលអ្នកខ្លះ បានស្នើរសុំឲ្យគាត់រៀបរាប់អធិប្បាយអំពីបុគ្គលភាពរបស់ព្រះ តើមានរូបរាងយ៉ាងណា... គាត់បានឆ្លើយតបវិញថា គ្មានអ្វីដែលអាចមានរូបរាងដូចព្រះនោះទេ... ម្ល៉ោះហើយគឺជាអំពើឆ្កួតលីលាសុទ្ធសាធរបស់មនុស្សដែលចេះតែចង់ស្គាល់រូបព្រះតាមរូបចម្លាក់នានា ...» ។

★★★ អង់ទីសតែន ចង់ឲ្យបុគ្គលម្នាក់ៗគោរពសត្រូវរបស់ខ្លួន ។ ..គឺដោយហេតុថាពួកសត្រូវរបស់យើងតែងតែយល់ពីកំហុសរបស់យើងច្បាស់លាស់ មិនត្រឹមតែប៉ុណ្ណោះ បានយកកំហុសទាំងនេះទៅបោះពុម្ពផ្សាយ ។ នៅក្នុងលក្ខណៈនេះ ...ពួកសត្រូវអាចជាគុណប្រយោជន៍ដល់យើង, ពីព្រោះពួកគេបានផ្តល់លទ្ធភាពឲ្យយើងកែកំហុស ។

★★★ គាត់បានពោលថា គួរគោរពនិងស្រឡាញ់មិត្តភ័ក្តិសុចរិត ជាជាបងប្អូនរប

ស់ខ្លួនឯង ,  ពីព្រោះថាចំណងដែលចងគ្នាដោយសារកម្លាំងសីលធ៌មវាអាចខ្លាំងនិងជាប់លាប់ជាងចំណងសាច់ឈាម ។

★★★ គេគួរតែឋិតនៅក្នុងចំណោមមនុស្សភាគតិច  ដែលមានបញ្ញានិងវិចារណញ្ញាណតទល់នឹងមនុស្សភាគច្រើនដែលជាមនុស្សឆ្កួត .. ជាជាងឋិតនៅក្នុងចំណោមពពួកមនុស្សភាគច្រើនដែលសុទ្ធសឹងតែជាមនុស្សឆ្កួតដែលតទល់នឹងមនុស្សភាគតិចដែលមានបញ្ញា ។

★★★ ថ្ងៃមួយ គាត់បានឮពពួកជនទុច្ចរិតដែលបានថ្លែងសរសើររូបគាត់ ។  គាត់ក៏បានភ្ញាក់មាត់ដូច្នេះថា ៖ « ឱ! ព្រះជាម្ចាស់... តើខ្ញុំមានកំហុសអ្វីទៅបានជាមានរឿងដូច្នេះ ? » ។

★★★ គាត់មានយោបល់ថា ...   ពពួកជនដែលមានបញ្ញាមិនចាំបាច់រស់នៅតាមច្បាប់ទម្លាប់នោះទេ ..ក៏ប៉ុន្តែពួកគេ  តែងរស់នៅស្របតាមច្បាប់សីលធ៌មតែមួយមុខក៏គ្រប់គ្រាន់រួចស្រេចហើយ ។

★★★...មិនអាចមានរឿងអ្វីៗ ដែលជារបស់ចម្លែក...  ឬដែលមានលទ្ធភាពធ្វើឲ្យគាត់ទាស់ចិត្តបាននោះទេ,  ពីព្រោះទាក់ទងនឹងរឿងបញ្ហាគ្រប់យ៉ាង  ដែលអាចកើតមានឡើងនៅក្នុងជីវិត ... គឺគាត់បានគ្រោងទុកជាមុន  នឹងប្រុងប្រៀបរួចស្រេចបាច់អស់ជាយូរមកហើយដើម្បីទប់ទល់នឹងព្រឹត្តិការណ៍ជាយថាហេតុ ។

★★★... គាត់បានពោលថា សេចក្តីថ្លៃថ្នូរ ហើយនិងបញ្ញាញាណ  ជារបស់តែមួយ , ម្ល៉ោះហើយនៅលើលោកនេះ គ្មានអ្វីថ្លៃថ្នូរជាងបញ្ញាជននោះទេ ( អ្នកប្រាជ្ញ ) ។

★★★... សេចក្តីប្រុងប្រយ័ត្ន ជាកំផែងមួយយ៉ាងក្រាស់  ...ដែលគេមិនអាចវាយបំបាក់បំបែកឬឆ្លងកាត់បាន ។

★★★...មធ្យោបាយដ៏ពិតប្រាកដដើម្បីស្វែងរកសភាពអមតៈរបស់ព្រះ ,  គឺគេត្រូវចេះរស់ដូចព្រះដូច្នោះឯង ។ ហើយដើម្បីស្វែងរកសេចក្តីសុខនិងសុភមង្គលនៅលើលោកនេះ ...គេគ្មានត្រូវការកម្លាំងអ្វីក្រៅតែពីកម្លាំងឆន្ទៈរបស់ស្ងួក្រាតតែប៉ុណ្ណោះ ។

★★★...ក្នុងសម័យថ្ងៃមួយ  បុរសម្នាក់បានសួរគាត់ថា   តើភរិយាបែបណាដែរដែលគេត្រូវស្វះស្វែងរក...  គាត់ក៏បានឆ្លើយតបវិញថា ៖ « បើឯងយកប្រពន្ធរូបអាក្រក់ ... មិនយូរមិនឆាប់  ឯងគង់តែទាស់ចិត្តនឹងរូបនាងជាមិនខាន,...  ក៏ប៉ុន្តែបើឯងយកប្រពន្ធរូបល្អ ... ក៏គ្មានរឿងអ្វីគួរអស្ចារ្យដែរ ...  នាងនឹងក្លាយទៅសាម៉ញ្ញជនដូចតែគេដូចតែឯង ។

○

★★★...ថ្ងៃមួយគាត់បានឃើញជនកំផិតម្នាក់  ( មនុស្សលួចប្រពន្ធគេ ) ... កំពុង

តែរត់ប្រាយផាស់ក្រញាំ... អង់ទីសតែនក៏បានពោលថា ៖ « ឱ ! ជនអភ័ព្វអើយ ... ឯងគួរតែចៀសវាងរឿងគ្រោះកាចអស់ទាំងនេះបាន ដោយគ្រាន់តែចាយលុយមួយអូបូលតែប៉ុណ្ណោះឯង ( លុយសេនក្រិកដែលមានតម្លៃតិចតួចស្តួចស្តើង ... ប្រហែល១/៦នៃដ្រាក់ ) » ។

★★★គាត់បានដាស់តឿនក្រុមសាវ័ករបស់គាត់ទាំងអស់ ឲ្យខំប្រមែប្រមូលទ្រព្យធនទាំងប៉ុន្មាន ..ដែលសូម្បីតែមានកើតខ្យល់ព្យុះឬក៏ទូកលិច ក៏គេមិនអាចបាត់បង់ទៅវិញបានដែរ ។

★★★ កាលណាគាត់មានសត្រូវណាម្នាក់ គាត់បានបន់ស្រន់ឲ្យបុគ្គលនោះ មានទ្រព្យសម្បត្តិគ្រប់បែបយ៉ាង លើកលែងតែបញ្ញាញាណតែប៉ុណ្ណោះ ។

★★★ កាលណាជនណាម្នាក់ថ្លែងរៀបរាប់នៅចំពោះមុខគាត់ អំពីជីវិតពោរពេញដោយសោភ័ណភាពនិងសភាពឆ្ងាញ់... គាត់ក៏លាន់មាត់ថា ៖ « ឱ ! ព្រះជាម្ចាស់... ជីវិតបែបនេះ គួរតែមានដល់កូនចៅនៃសត្រូវរបស់យើងទៅចុះ !» ។

★★★ កាលណាគាត់ក្រឡេកឃើញស្រីណាម្នាក់ តែងខ្លួនស្អាតបាតស្រស់ប្រិមប្រិយ ... គាត់តែងតែដើរសំដៅទៅរកផ្ទះរបស់ស្រីនោះមួយរំពេច ...ដើម្បីកោះហៅប្តីរបស់នាងឲ្យយកគ្រឿងអាវុធនិងសេះរបស់គេ មកបង្ហាញឲ្យគាត់មើល ៖ បើគាត់យល់ឃើញថា របស់អស់ទាំងនេះមានគុណភាពល្អអាចប្រើប្រាស់បាន ... គាត់ក៏អនុញ្ញាតឲ្យស្រីនោះ សំអិតសំអាងខ្លួនបានមួយសេរីទៅចុះ , ដោយហេតុថានាងមានស្វាមីម្នាក់ដែលមានសមត្ថភាពគ្រប់គ្រាន់អាចការពាររូបនាងបាន ។ ក៏ប៉ុន្តែ បើគាត់យល់ឃើញថា គ្រឿងអាវុធទាំងនោះមិនសមរម្យទេ គាត់ក៏បួលយោបល់ឲ្យស្រីនោះដោះគ្រឿងអលង្ការចេញពីខ្លួនទាំងអស់ ដោយគាត់ខ្លាចក្រែងថានាងនឹងក្លាយទៅជាអ្នករងគ្រោះរបស់ជនទីមួយដែលចង់ប្រព្រឹត្តអំពើកំហែងកំហល់ទៅលើរូបនាង ។

★★★ គាត់បានប្រាប់បូរីជននៅទីក្រុងអាតែន ឲ្យទឹមនង្គ័លដោយមិនបាច់ពិនិត្យពិច័យអ្វីទាំងអស់, ដោយយកសេះមកទឹមជាមួយនឹងលា ។ លុះមានអ្នកខ្លះនិយាយមកឲ្យគាត់ថា, ធ្វើដូច្នេះមិនជាការល្អទេ ដោយហេតុថាសត្វលាមិនមានលក្ខណ:ត្រឹមត្រូវសំរាប់ព្យួរដីសោះឡើយ ... នោះគាត់ក៏បានឆ្លើយតបវិញថា ៖ « អស់លោកចង់និយាយថាយ៉ាងម៉េចក៏បានដែរ, នៅពេលដែលពួកអស់លោកបោះឆ្នោតជ្រើសរើសពួកចៅក្រម ដើម្បីធ្វើគណកម្មការរដ្ឋាភិបាល .. តើអស់លោកមានបានសង្កេតមើលថាតើពួកអស់លោកទាំងនេះ មានលក្ខណ:ត្រឹមត្រូវដើម្បីធ្វើការគ្រប់គ្រងប្រទេសជាតិនោះឬដែរ ...ឬក៏ពុំមានលក្ខណ:ត្រឹមត្រូវនោះទេ ? ... អស់លោកគ្រាន់តែធ្វើការសម្រេចជ្រើសរើសទៅ ... នោះក៏វាជាការចប់គ្រប់គ្រាន់ទៅហើយ ...។

ថ្ងៃមួយ គេបាននិយាយប្រាប់គាត់ថា ប្លាតុងបាននិយាយអាក្រក់ពីរូបគាត់ ។ «

បើអីចឹងល្អហើយ, គាត់ពោល, ខ្លួនខ្ញុំក៏វាមិនខុសពីរូបស្តេចប៉ុន្មាន ...កាលណាធ្វើគុណដល់គេ ...មានតែគេនិយាយអាក្រក់មកវិញប៉ុណ្ណោះ ។

...គាត់បានពោលថា គឺជាការមួយដែលគួរឲ្យចង់សើចក្រៃលែង, ដែលអ្នកផងខំប្រឹងរើសអង្កាមចេញពីអង្ករ... ខំប្រឹងចែកអំពើល្អជាមួយនឹងអំពើអាក្រក់... ខំប្រឹងដកហូតពីកងទ័ពនូវពួកយោធាឥតប្រយោជន៍ ... នៅពេលជាមួយគ្នាដែលគេពុំបាននឹកគិតដកចេញពួកជនច្រណែននិន្ទារពីសាធារណរដ្ឋសនោះផងសោះ ។

កាលណាមានគេស្តីបន្ទោសឲ្យគាត់ថា គាត់ចូលចិត្តតែទៅទាក់ទងជាមួយនឹងមនុស្សដែលមានជីវិតមិនល្អ ... គាត់បានឆ្លើយវិញថា ៖ « ចង់ថាម៉េចក៏បានដែរ, តើពួកពេទ្យហ្នុទាំងឡាយ មិនទៅធ្វើការទាក់ទងជាមួយនឹងពួកមនុស្សជម្ងឺទេឬ? ... តើពេទ្យទាំងអស់នោះ មានត្រូវឆ្លងរោគគ្រុនពីកាលណា ? » ។

អង់ទីសតែនជាមនុស្សម្នាក់ដែលចេះអត់ធ្មត់ក្រៃពេក ។ គាត់តែងដាស់តឿនពួកសាវ័ករបស់គាត់ទាំងអស់ឲ្យចេះអត់ទ្រាំ ដោយគ្មានសេចក្តីតក់ស្លុតឬច្រឡោតខឹង ...ចំពោះពាក្យសំដីប្រមាថមើលងាយទាំងឡាយ ដែលអ្នកផងនិយាយប្រាស់ឆ្ពោះទៅលើពួកគេ ។

គាត់បានដាក់ទោសយ៉ាងធ្ងន់ធ្ងរទៅលើប្លាតុង ដែលគាត់យល់ថាជាបុគ្គលម្នាក់ស្រឡាញ់តែសេចក្តីរុងរឿងនិងមុខមាត់ ... ហើយគាត់មិនដែលបានខកខានក្នុងការចំអកនិងបន្តុះបង្អាប់ចំពោះប្លាតុងអំពីរឿងនេះទេ ។

...នៅពេលដែលជនម្នាក់បានសាកសួរគាត់ថា តើគាត់បានចំណេញអ្វីទៅ ដែលបានខំប្រឹងរៀនទស្សនវិជ្ជានោះ ? គាត់ក៏បានឆ្លើយតបថា ៖ « ... គឺដើម្បីឲ្យខ្លួនខ្ញុំមានការទំនាក់ទំនងជាមួយនឹងរូបខ្លួនឯង ... និងចេះធ្វើអ្វីៗដោយឆន្ទៈរបស់ខ្លួនឯង... នៅពេលដែលអ្នកឯទៀតៗប្រតិបត្តិធ្វើអំពើដូចគ្នា តែនៅក្នុងលក្ខណៈណាដែលមានការបង្ខំតែប៉ុណ្ណោះ » ។

...អង់ទីសតែនតែងតែរក្សានូវមនោសញ្ចេតនាដឹងគុណ ឬកតញ្ញូតាធម៌, ជានិច្ចជាកាល, ចំពោះសូក្រាតដែលត្រូវជាគ្រូរបស់គាត់ ។ អ្នកខ្លះថែមទាំងបានពោលថា គឺអង់ទីសតែននេះឯងហើយ ដែលបានសងសឹកសេចក្តីស្លាប់របស់សូក្រាត ។ គឺដោយហេតុថា មានមនុស្សជាច្រើនធ្វើដំណើរមកតាំងពីចុងស្រុកនៃប៉ុង-អឺកស៊ីន ( Pont- Euxin ) គ្រាន់តែនៅក្នុងគោលបំណងចង់ស្តាប់ពាក្យទូន្មានរបស់សូក្រាត ។ អង់ទីសតែន ក៏នាំពួកអ្នកទាំងនេះឆ្ពោះទៅរកផ្ទះរបស់អានីត ... ដោយពោលថា ៖ « សូមអស់លោកមើលចុះ, បុគ្គលនេះមានបញ្ញាជាងសូក្រាតឆ្ងាយណាស់ ... គឺពីព្រោះរូបគាត់នេះហើយដែលបានចោទប្រកាន់សូក្រាត » ។ ការនឹករឭកឃើញដល់សូក្រាត ក៏បានធ្វើឲ្យមហាជននៅទីនោះ មានសេចក្តីរំភើបញាប់ញ័រជាពន់ប្រមាន

...ពួកគេក៏បានដេញអានីតឲ្យចេញពីទីក្រុងនោះជាប្រញាប់ ។ ពួកគេក៏បានចាប់ខ្លួនឈ្មោះម៉េលីត ...ដែលជាអ្នកបានចាប់ទោសអូសដំណើរដល់សូក្រាតផងដែរ ...ហើយក៏បាននាំយកជននេះទៅពិឃាតចោល ។

...អង់ទីសតែនបានផ្លាក់ខ្លួនឈឺ ..ដោយមានរោគរបេងផ្លាក់ឈាម ។ ពេលនោះគេហាក់ដូចជាដឹងថា ចំណង់នៃការរស់នៅតទៅទៀត... បានធ្វើឲ្យគាត់សុខចិត្តជ្រើសរើសយកជីវិតមួយសោះកក្រោះ ប្រកបដោយជម្ងឺរ៉ាំរ៉ៃ ... ជាជាងយកសេចក្ដីស្លាប់ភ្លាមៗ ។ ពីព្រោះ ឌីយ៉ូសែន ( ឡឺស៊ីនីក ) ... ដែលត្រូវជាសាវ័ករបស់គាត់... ថ្ងៃមួយបានចូលក្នុងបន្ទប់របស់គាត់ ដោយកាន់កាំបិតស្នៀតមួយលាក់ក្នុងអាវម៉ង់តូ ។ ពេលនោះ អង់ទីសតែនបានពោលថា ៖ « ឱ! តើនរណាទៅហ្ន៎ ... ដែលអាចជួយរំដោះរូបខ្ញុំឲ្យផុតពីសេចក្ដីទុក្ខបាន » ។ ឌីយ៉ូសែន ក៏ទាញកាំបិទស្នៀតរបស់ខ្លួនចេញមក ហើយពោលថា ៖ « គឺអានេះនៃហ៏លោកគ្រូ ! » ។ « - អញចង់រំដោះខ្លួនអញពីសេចក្ដីឈឺចាប់ , អង់ទីសតែនពោលទៅកាន់ឌីយ៉ូសែន, មិនមែនចង់រំដោះខ្លួនឲ្យផុតពីជីវិតនោះទេ ។

អង់ទីសតែនទំនងដូចជាបានអួតអាងថា អ៊ែរគូល ( ព្រះអាទីទេពនៃកម្លាំង ) ... ជាគ្រូរបស់ពួកស៊ីនីក។ ពីព្រោះអ្នកកវីអូសូន ...នៅក្នុងកំរងកំណាព្យរបស់ខ្លួន ..បានប្រគល់ពាក្យសំដីទៅឲ្យអង់ទីសតែនដូច្នេះថា ៖

**Inventor primus Cynices, ego quoe ratio istàc**
**Alcides multò dicitur esse prior**
**Alcidà quondam fueram doctore secundus ;**
**Nunc ego sum Cynices primus etille Deus.**

❑ ❑

❑

# ជីវិតរបស់អារីសទីព
# ARISTIPE

( ជាទស្សនវិទូម្នាក់ ដែលបានរស់ក្នុងកាលសម័យជាមួយគ្នានឹងប្លាតុង ... នៅក្នុងអូឡាំព្យ៉ាដទី ៩៦ ...)

អារីសទីពមានដើមកំណើតនៅស៊ីរ៉េន, នៅប្រទេសលីប៊ី ។ កេរ្តិ៍ឈ្មោះដ៏ល្បីល្បាញរបស់សូក្រាតបានធ្វើឲ្យជននេះចាកចេញពីប្រទេសកំណើតរបស់ខ្លួន ដើម្បីមកតាំងទីលំនៅៗក្រុងអាត្ហែន... ដើម្បីគ្រាន់តែមានសេចក្តីសប្បាយរីករាយនឹងបានស្តាប់សូក្រាតប៉ុណ្ណោះ ។ គាត់បានក្លាយទៅជាសាវ័កម្នាក់ដ៏សំខាន់របស់ទស្សនវិទូម្នាក់នេះ ... ក៏ប៉ុន្តែគាត់បានរៀបចំរបៀបរស់នៅរបស់គាត់ទៅតាមក្បួន ដែលផ្ទុយប្រឆាំងស្រឡះនឹងទ្រិស្តីទាំងឡាយ បង្ហាត់បង្រៀននៅក្នុងសាលាដ៏ឧត្តុង្គឧត្តមរបស់សូក្រាត ។ គឺគាត់នេះហើយដែលបានបង្កើតក្រុមសាលាមួយផ្សេង ដែលមានឈ្មោះថា ស៊ីរ៉េណាអ៊ីក ( Cyrénaïque ), ដោយហេតុថាអារីសទីព ដែលជាលោកគ្រូធំនៅក្នុងសាលានោះ មានដើមកំណើតមកពីទីក្រុងស៊ីរ៉េន ។

អារីសទីពជាបុគ្គលម្នាក់មានគំនិតជ្រៅជ្រះក្រៃលែង, មានវោហាឆ្លើយឆ្លងផ្ទួញផ្ទាល់រហ័សរហួន ។ គាត់មានទេពកោសល្យខាងធ្វើការសន្ទនានិយាយស្តី, ហើយចេះរកគំនិតកំប្លុកកំប្លែង ឬចំអកតាំងពីរឿងកំប៉ិកកំប៉ុកតូចតាចឡើងទៅ ។ មួយថ្ងៃៗគាត់គិតតែពីរករបៀបសរសើរលើកតម្កើងពួកស្តេច ហើយនិងពួកអ្នកធំៗ ។ គាត់សុខចិត្តធ្វើអ្វីៗសព្វបែបយ៉ាង ដើម្បីអែបអបចាក់បណ្តោយ ឬយកចិត្តពួកអ្នកទាំងនេះ ។ គាត់តែងតែធ្វើឲ្យពួកនេះសើចសប្បាយក្អាកក្អាយ ហើយទាមទារបានមកវិញនូវរង្វាន់ជាទីគាប់ចិត្ត ។ កាលណាពួកអ្នកធំជេរប្រមាថឬបង្អាប់រូបគាត់ ៗតែងតែមានវិធីតបតឲ្យរឿងនេះក្លាយទៅជាសំណើចចំអកបញ្ច្រាស់ទៅវិញ ... ម៉្លោះហើយគ្មាននរណាម្នាក់អាចធ្វើឲ្យគាត់មានសេចក្តីឈឺចាប់ក្នុងរឿងអ្វីមួយសោះឡើយ ... បើទោះជាគេមានគោលបំណងយ៉ាងណាក៏ដោយ ។ គាត់មានការប៉ិនប្រសប់ក្រៃពេកក្នុងការនិយាយផ្គោះផ្គង... ជាហេតុឲ្យគាត់បានសម្រេចជោគជ័យនូវគ្រប់កិច្ចការអ្វីៗដែលគាត់បានធ្វើ ។ គាត់មានបញ្ញាស្មារតីនៅនឹងមិនច្រឡោត នៅក្នុងគ្រប់កាលៈទេសៈ, គាត់មិនដែលនឹកចេះខ្មាស់អៀនក្នុងពិធីគួរសម ឬរឿងបែបបទសមរម្យអ្វីឡើយ ។ ប្លាតុង នៅក្នុងពេលខ្លះបាននិយាយមកកាន់រូបគាត់ដូច្នេះថា ៖ « ឱ! អារីសទីព, នៅ

ក្រោមមេឃលើដីនេះ មានតែរូបឯងម្នាក់ប៉ុណ្ណោះ ដែលមានចិត្តគំនិតនៅនឹងថ្កល់ ... បើទោះជាត្រូវវ័ណ្ឌកន្ទបកណ្ដាច់កណ្ដាចក្ដី ... ឬក៏នៅក្នុងសម្លៀកបំពាក់ក្រហមឆ្អៅដ៏ថ្កុំថ្កើងរុងរឿងក្ដី ...» ។

អូរ៉ាស (Horace), កាលណានិយាយទាក់ទងនឹងអារីសទីព, បានពោលអះអាងថា គាត់នេះចេះដើរសំដែងតួនៅក្នុងគ្រប់បុគ្គលិកលក្ខណៈ។ ហើយគាត់តែងតែមានសេចក្ដីសោមនស្សរីករាយនៅក្នុងរឿងរបស់អ្វីបន្តិចបន្តួច ដែលគាត់មាន... នៅក្នុងពេលជាមួយគ្នាដែលគាត់ខំប្រឹងប្រែងស្រវាឱបឲ្យបានច្រើនជាងមុន ។

គុណសម្បត្តិអស់ទាំងនេះ បានធ្វើឲ្យស្ដេចផ្ដាច់ការ ដេនីស-ឡឺទៀរ៉ង់មានការគាប់ចិត្តយ៉ាងខ្លាំង ។ ម្ល៉ោះហើយនៅក្នុងគំនិតរបស់ស្ដេចនេះ ...អារីសទីពមានតម្លៃដ៏ខ្ពង់ខ្ពស់ច្រើនលើសលប់ពួកអ្នកលុតក្រាបឯទៀតៗ ។ អារីសទីពតែងតែធ្វើដំណើរជាមួយស្ដេចទៅស៊ីរ៉ាគុស ...ដើម្បីទៅធ្វើជប់លៀងនៅទីនោះ ។ នៅពេលណាដែលគាត់ធុញថប់ជាមួយនឹងស្ដេចអង្គនេះ, គាត់តែងតែទៅលេងកំសាន្ដ ក្នុងផ្ទះអ្នកធំផ្សេងៗទៀត ។ ហើយដោយនៅក្នុងមួយជីវិតរបស់គាត់ ៗតែងតែដើរទៅលេងសប្បាយនៅក្នុងវាំងស្ដេចនានា...ឌីយ៉ូសែន-ឡឺស៊ីនីក ដែលរស់នៅក្នុងសម-យកាលរបស់គាត់ដែរ... បានប្រសិទ្ធនាមឲ្យគាត់ថា ជាឆ្កែរបស់ស្ដេច ។

○

ថ្ងៃមួយ, ដេនីសបានស្ដោះទឹកមាត់ទៅលើមុខរបស់គាត់ ។ ហេតុការណ៍នេះបានបង្កើតឲ្យមានការ លំបាកចិត្តដល់សាក្សីម្នាក់ ដែលបានដើរនៅក្នុងហ្វូងនោះផងដែរ ។ ក៏ប៉ុន្តែអារីសទីពបែរជាសើចក្អាកក្អាយសប្បាយចិត្តទៅវិញ ។ គាត់ពោលថា ៖ « យើងមិនត្រូវថ្ងូរក្នុងរឿងបែបនេះទេ ។ ពួកអ្នកនេសោទដើម្បីចាប់កូនត្រីតូចមួ-យ សុខចិត្តលោតទៅក្នុងសមុទ្រ រហូតដល់ទទឹកជោគពេញទាំងខ្លួន ។ ចំណែកខ្ញុំដើម្បីចាប់ត្រីបាឡែនមួយប៉ុនណាប៉ុនណី ... គ្រាន់តែទទឹកមុខទទឹកមាត់បន្តិចបន្តួចមានជាការអ្វីប៉ុណ្ណឹង ? » ។

មានពេលម្ដងទៀត ដេនីសមានការទាស់ចិត្តជាខ្លាំងជាមួយនឹងគាត់ ។ នៅពេលដែលអ្នកផងកំពុងរៀបចំខ្លួនចូលអង្គុយជប់លៀង... ស្ដេចអង្គនេះ បានរៀបចំឲ្យគាត់ទៅអង្គុយនៅកន្លែងចុងក្រោយគេបំផុត ។ អារីសទីព គ្មានកើតទុក្ខអ្វីសោះឡើ-យ អំពីរឿងនេះ ៖ « មើលទំនងទៅ, គាត់ពោល ( ហៅស្ដេចថាលោក) , លោកហា-ក់ដូចជាចង់ផ្ដល់កិត្តិយសដល់កន្លែងនេះជាខ្លាំងណាស់មែនទេ ? » ។

អារីសទីពជាសាវ័កទី១ របស់សូក្រាត ក្នុងការចាប់ផ្ដើមទាមទារយកកម្រៃពីមេរៀនអ្វីៗដែលគាត់បានបង្ហាត់បង្រៀនដល់អ្នកដទៃ ។ ហើយដើម្បីធ្វើរឿងនេះឲ្យ

ទៅជាទំនៀមទម្លាប់... សម័យថ្ងៃមួយ គាត់ក៏បានបញ្ជូនជាប្រាក់ចំនួន២០មីន ( កកន ៖ មួយមីនជាប្រាក់ក្រិកមានកំណត់ជា១០០ដ្រាក់; – Mine : Antiquité grecque : poids et monnaie de 100 drachmes ) ជាអំណោយរបស់ខ្លួនគាត់ផ្ទាល់ទៅសូក្រាត ។ សូក្រាតមិនបានព្រមទទួលយកប្រាក់នេះ, មិនត្រឹមតែប៉ុណ្ណោះ គាត់ថែមទាំងបានសំដែងការមិនសប្បាយចិត្ត អំពីអាកប្បកិរិយាបែបនេះរបស់សាវ័ករបស់គាត់ទៀតផង កាលពេលដែលគាត់នៅរស់, ក៏ប៉ុន្តែអារីសទីពហាក់ដូចជាពុំមានខ្វល់ខ្វាយក្នុងចិត្តអំពីរឿងនេះឡើយ ។ នៅពេលដែលអ្នកផងបានស្តីបន្ទោសឲ្យគាត់ព្រមទាំងបានផ្ទុញផ្ទាល់ចំពោះគាត់ ដោយបង្ហាញនូវសប្បុរសធម៌របស់គ្រូរបស់គាត់ ដែលមិនដែលបានទាមទារអ្វីពីនរណាសោះ, គាត់ក៏បានឆ្លើយតបវិញថា ៖ « ឱ ! ម្ចាស់ថ្លៃ ... រឿងនេះវាខុសគ្នា ! ពួកអ្នកធំៗទាំងឡាយនៅក្រុងអាតែ្មន តែងតែតណើ្តមកិត្តិយសគ្នា ដើម្បីបញ្ជូនទៅសូក្រាត នូវរបស់អ្វីៗគ្រប់យ៉ាងដែលគាត់ត្រូវការ ។ រហូតដល់សូក្រាត មានកាតព្វកិច្ចបញ្ជូនមួយភាគធំ ទៅឲ្យម្ចាស់ដើមគេវិញ...។ ចុះចំណែកខ្ញុំវិញ... មិនដែលមានឈ្នួលបម្រើកំបែកក្បាលណាម្នាក់នឹកគិតមកដល់ខ្ញុំផង...» ។

មានបុរសម្នាក់បាននាំយកកូនប្រុសរបស់ខ្លួនយកមកឲ្យគាត់ជួយបង្ហាត់បង្រៀន ព្រមទាំងបានសុំឲ្យគាត់យកចិត្តទុកដាក់ ឲ្យបានយ៉ាងច្រើនទៀតផង ។ អារីសទីពក៏បានទាមទារយកតម្លៃឈ្នួលជាប្រាក់ចំនួន៥០ ដាក់ ។

– យីអើ ! ច្រើនម្ល៉េះ ?, ឪពុករបស់កូនក្មេងឧទានឡើង, ប្រាក់ដល់ប៉ុណ្ណោះ ...គេអាចយកទៅទិញឈ្នួលបម្រើម្នាក់បានយ៉ាងស្រួលរួចស្រេចទៅហើយ !

– អើ ! បើអីចឹង ឯងយកទៅទិញឈ្នួលបម្រើទៅ , អារីសទីពពោលតប, ... តាមរបៀបនេះឯងនឹងអាចមានឈ្នួលបម្រើដល់ពីរនាក់ទៀតផង !!...

... គឺមិនមែនដោយហេតុថា អារីសទីពជាជនកំណាញ់ក្រៅតម្រានោះទេ, ផ្ទុយទៅវិញ គាត់ចង់បានលុយយ៉ាងច្រើនដើម្បី ត្រឹមតែយកមកធ្វើការចំណាយតែប៉ុណ្ណោះ... ហើយដើម្បីគ្រាន់តែចង់បង្ហាញដល់អ្នកដទៃអំពីរបៀបចាយប្រាក់ ។

ថ្ងៃមួយ គាត់បានធ្វើដំណើរតាមសមុទ្រ, មានជនម្នាក់បានលួចខ្សឹបប្រាប់គាត់ថា នាវាដែលគាត់កំពុងតែជិះនេះ ជានាវារបស់ពួកក្រុមចោរសមុទ្រ ។ ព្លដូច្នោះ អារីសទីពក៏ទាញយកប្រាក់ទាំងប៉ុន្មាន ដែលគាត់មាននៅក្នុងហោប៉ៅយកមកធ្វើជារាប់មើល បន្ទាប់មកក៏ទម្លាក់លុយដោយចេតនាចោលទៅក្នុងសមុទ្រអស់ ។ គាត់ធ្វើជាស្រែកថ្ងូរត្អូញត្អែរ...ហាក់ដូចជាលុយនោះរបូតធ្លាក់ពីដៃគាត់ដូច្នោះឯង, រួចហើយគាត់និយាយខ្សឹបៗសំរាប់ខ្លួនឯងថា ៖ « វាគួរតែអារីសទីពបាត់បង់ប្រាក់ទាំងអស់របស់ខ្លួន...ជាជាងត្រូវវិនាសស្លាប់ខ្លួនដោយសារតែប្រាក់.. » ។

មានពេលម្តងទៀត, គាត់បានឃើញថាឈ្នួលបម្រើរបស់គាត់ ដែលកំពុងតែធ្វើដំណើរតាមគាត់មានការលំបាកក្រៃលែងក្នុងការដើរទៅមុខឲ្យទាន់រូបគាត់, ដោយហេតុថាប្រាក់ដែលឈ្នួលនេះដឹកជញ្ជូនវាមានទម្ងន់ធ្ងន់ហួសពេក ។

– ចូរឯងបោះចោលទៅ, គាត់ពោល, នូវអ្វីៗដែលឯងមានច្រើនហួស, ចូរឯងយកតែរបស់ណាដែលឯងជញ្ជូនរួច ។

អូ៉រ៉ាស កាលណាគាត់ប្រៀនប្រដៅពពួកជនដែលស្វិតស្វាញខ្លាំងពេក ខាងប្រមូលឱបក្រសោបទ្រព្យធនយកមកសន្សំទុក... តែងតែទាញឧទាហរណ៍របស់អារីសទីពមកធ្វើជាគំរូ ។

អារីសទីពចូលចិត្តបរិភោគម្ហូបឆ្ងាញ់ជាពន់ពេកណាស់, ហើយគាត់មិនដែលនឹកស្តាយស្រណោះប្រាក់កាសសោះឡើយ កាលណាគាត់មានឱកាសទិញម្ហូបចំណីដែលគាត់យល់ថាមានគុណភាពដ៏ល្អប្រសើរ ។ ថ្ងៃមួយគាត់បានទិញពែរខ្មើច (មាន់ព្រៃ) មួយមានតម្លៃ ៥០ដ្រាក់។ ជនម្នាក់ក៏ចៀសវាងមិនបានក្នុងការស្តីបន្ទោសឲ្យគាត់ អំពីការចាយវាយដោយឥតបើគិតនេះ ។

– ប្រសិនបើពែរខ្មើចនេះ មានតម្លៃតែមួយអូបូល ( មួយកាក់ ), សំនួររបស់អារីសទីព, តើឯងទិញឬទេ ?

– ប្រាកដហើយ, ជនដែលទាស់ចិត្តនោះពោល ។

– ចំណែកអញ, អារីសទីពឆ្លើយតប, អញយល់ថាតម្លៃប្រាក់៥០ដ្រាក់របស់អញមានតម្លៃមិនបានប្រាក់ មួយអូបូលរបស់ឯងនោះផងទេ ។

មានពេលម្តងទៀត គាត់បានទិញស្ករគ្រាប់មួយកែវដោយត្រូវបង់តម្លៃប្រាក់យ៉ាងច្រើនហួសប្រមាណ។ បុរសម្នាក់ដែលនៅក្បែរទីនោះក៏មានការទាស់ចិត្តជាខ្លាំង ។

– ប្រសិនបើស្ករទាំងនេះមានតម្លៃតែបីអូបូល, សំដីរបស់អារីសទីព, ឯងច្បាស់ជាដាច់ចិត្តទិញយកជាមិនខាន...មែនទេ ?

–មែន ! ជននោះឆ្លើយ...

– បើអីចឹង, អារីសទីពឆ្លើយតប, ខ្លួនអញពុំមានលក្ខណៈជាជនល្មោភស៊ីណាស់ណា... ឲ្យស្មើនឹងរូបឯងដែលជាជនកំណាញ់ស្វិតនោះទេ ! ។

កាលណាគេស្តីបន្ទោសឲ្យគាត់ថា គាត់ចូលចិត្តរបៀបរស់នៅសប្បាយហ៊ឺហារខ្លាំងពេកណាស់, គាត់តែងឆ្លើយតបវិញថា ៖ « ប្រសិនបើគេចូលចិត្តបន្ទោសម្ហូបឆ្ងាញ់, ម្តេចក៏ពួកគេចូលចិត្តបង្កើតពិធីជប់លៀងធំៗអ្វីម៉្លេះ កាលណាគេធ្វើបុណ្យថ្វាយព្រះ ?...» ។

ទោះបីតុងក៏ដោយ, ដែលគេយល់ថាជាមនុស្សម្នាក់ចូលចិត្តរស់នៅតាមបែបបទខ្ពង់ខ្ពស់, ក៏មានកាតព្វកិច្ចត្រូវព្រមានអារីសទីពអំពីការដែលគាត់នេះ រស់នៅដោយ

សប្បាយ ឬក៏នៅក្នុងសភាពឆ្អាញ់ហួសប្រមាណពេក ។ អារីសទីពក៏ពោលទៅកាន់ប្លាតុងដូច្នេះថា ៖

– តើឯងយល់ថាដេនីសជាមនុស្សត្រឹមត្រូវឬទេ ?

– ជាមនុស្សត្រឹមត្រូវពិតមែន, ប្លាតុងពោលយល់ស្រប...

– បើអីចឹង, ចម្លើយរបស់អារីសទីព, ឯងមិនឃើញទេថា បុគ្គលនោះវារស់នៅក្នុងសភាពឆ្អាញ់ជាងរូបអញទៅទៀត ...ម្ល៉ោះហើយ មនុស្សសុច្ចរិតនៅតែសុច្ចរិតដដែលដូច្នោះឯង... ថ្វីបើគេបរិភោគម្ហូបឆ្ងាញ់យ៉ាងណាក្តី ...វាគ្មានការទាស់ខុសអ្វីទេ ! ។

ថ្ងៃមួយឌីយ៉ូសែនកំពុងអង្គុយលាងត្រកួនទៅតាមទម្លាប់ធម្មតារបស់គាត់, ស្រាប់តែគាត់ឃើញអារីសទីពដើរកាត់ ។ ឌីយ៉ូសែនក៏ពោលដូច្នេះទៅកាន់អារីសទីពថា ៖

– ប្រសិនបើឯងសុខចិត្តបរិភោគតែត្រកួនដូចរូបអញ, ឯងច្បាស់ជាមិនលំបាកលំបិនដើរទៅចែចង់ស្តេច ( ទៅឡែបឡប ) រាល់តែថ្ងៃនោះទេ ។

– ចំណែកឯងវិញ, អារីសទីពពោលតប, ប្រសិនជាឯងចេះសម្រាំងសិល្បៈទៅចែចង់ស្តេច...ឯងច្បាស់ជាលែងចង់ស៊ីត្រកួនជាមិនខានដែរ...!

❑

★ ថ្ងៃមួយស្តេចដេនីស... បានផាំស្រីស្អំជាន់ខ្ពស់យកមកតាំងសំញែងនៅមុខអារីសទីពចំនួនបីនាក់, ហើយអនុញ្ញាតឲ្យបុគ្គលនេះជ្រើសរើសបានមួយសប្បាយ។ អារីសទីពមិនបានជ្រើសរើស បែជាប្រមូលយកតែទាំងអស់។ « ការជ្រើសរើសមិនប្រាកដប្រជាទេ, គាត់ពោល, លោកអ្នកដឹងស្រាប់ហើយ អំពីលទ្ធផលអភ័ព្វយ៉ាងណាខ្លះដែលប៉ារីសបានទទួលក្នុងរឿងនេះ ។ ស្រីពីរនាក់អាចរុកគួនរករឿងឲ្យរំខានវេទនាខ្លាំងណាស់, ក៏ប៉ុន្តែបើមានស្រីតែម្នាក់វិញ... យើងក៏មិនដែលបានសប្បាយគ្រប់គ្រាន់នោះដែរ ... ដូច្នេះមធ្យោបាយដោះស្រាយ ត្រូវតែយកទាំងបី » ។

អារីសទីពក៏បានផាំស្រីទាំងបីនាក់រហូតដល់ក្នុងល្វែងផ្ទះរបស់គាត់ ... ហើយក៏បញ្ជូននាងឲ្យត្រឡប់ទៅលំនៅឋានរបស់ពួកគេវិញទាំងអស់គ្នា ។

★ មានពេលម្តងទៀត, ដេនីសបានពោលចំពោះគាត់ដូច្នេះថា ៖ « ហេតុអ្វីបានជាគេឃើញពួកទស្សនវិទូមិនចេះស្វាង នៅក្នុងផ្ទះអស់លោកអ្នកធំ និងលោកម្ចាស់ក៏ប៉ុន្តែគេពុំដែលឃើញពួកលោកម្ចាស់ ទៅនៅផ្ទះទស្សនវិទូវិញម្តងណាសោះ? » ។

« នេះគឺមកពី, អារីសទីពពោលឆ្លើយតប , ពួកទស្សនវិទូរមានចំណេះដឹងអំពីរឿងរ៉ាវសព្វបែបយ៉ាងដែលគេត្រូវការចង់ដឹង, ចំណែកពួកអស់លោកម្ចាស់វិញពុំមានដឹងរឿងអស់ទាំងនេះទេ » ។

មនុស្សខ្លះបានចោទសំនួរគាត់របៀបដដែល ប៉ុន្តែនៅក្នុងពេលមួយផ្សេងទៀត។ ពេលនោះ, អារីសទីពបានឆ្លើយតបដូច្នេះវិញថា ៖ « គេតែងតែឃើញពួកពេទ្យហូទៅនៅក្នុងផ្ទះអ្នកជំងឺជាធម្មតា..ក៏ប៉ុន្តែទោះដូច្នេះក៏ដោយ..នរណាៗក៏តែងតែចង់ព្យាបាលជំងឺរបស់អ្នកដទៃ...ហើយក៏មិនចង់ឈឺខ្លួនឯងនោះដែរ។ » ។

★ អារីសទីពតែងតែពោលថា ...គឺជាការមួយល្អពន់ពេកណាស់ដែលមនុស្សយើងចេះបន្ថយតណ្ហារបស់ខ្លួន... ក៏ប៉ុន្តែគេមិនត្រូវដកសេចក្តីសប្បាយទាំងនេះឲ្យរបូតដាច់អស់ទាំងឫសពីក្នុងខ្លួនឯងនោះទេ ។ គឺមិនមែនជាឧក្រិដ្ឋកម្មនោះទេដែលមនុស្សយើងត្រូវចេះត្រេកត្រអាលក្នុងសេចក្តីស្រើបស្រាលខ្លះៗ... កុំឲ្យតែយើងក្លាយទៅជាខ្ញុំកញ្ជះនៃតណ្ហាទាំងនោះ ។ ...ហើយគឺបណ្តាលមកពីចំណុចនេះឯង ដែលគេបានពេបជ្រាយឲ្យគាត់.. អំពីទំនាក់ទំនងមេត្រីដែលគាត់មានជាមួយនឹងនាងស្រីស្នំជាន់ខ្ពស់ម្នាក់ឈ្មោះនាងឡាអ៊ីស ( កកន ៖ Courtisanee : ស្រីស្នំជាន់ខ្ពស់ គឺស្រីដែលលក់សម្រស់ឲ្យពួកអ្នកធំនិងពួកលោកម្ចាស់ ) ។ ក្នុងរឿងនេះគាត់បានពោលតបថា ៖

« ជាការពិត ដែលនាងឡាអ៊ីសជាកម្មសិទ្ធរបស់ខ្ញុំ, ក៏ប៉ុន្តែខ្លួនខ្ញុំវិញ ពុំមែនជាកម្មសិទ្ធរបស់នាងឡាអ៊ីសនោះទេ » ។

នៅក្នុងសម័យថ្ងៃមួយ, នៅពេលដែលគាត់ដើរចូលក្នុងគេហដ្ឋានរបស់ស្រីស្នំជាន់ខ្ពស់ម្នាក់នេះ, សាវ័ករបស់គាត់ម្នាក់មានការអៀនខ្មាស់យ៉ាងខ្លាំង ។ អារីសទីពឃើញជននេះ មុខឡើងក្រហម, គាត់ពោលថា ៖ « នែហ!សម្លាញ់, ពុំមែនរឿងចូលផ្ទះនេះទេ ដែលគេគួរខ្មាស់អៀននោះ... ការដែលគួរខ្មាស់អៀន គឺការដែលចេញមកវិញមិនរួចតែប៉ុណ្ណោះ។ » ។

★ ថ្ងៃមួយ ទស្សនវិទូរ ប៉ូលិចសែនបានមកជួបនឹងអារីសទីព ។ ពេលចូលមកដល់ផ្ទះគាត់ កាលណា បុគ្គលនេះបានឃើញគេរៀបចំការជប់លៀងមួយដ៏សម្បើមដោយមានស្រីៗស្អាតៗស្លៀកពាក់ប្រកបដោយសម្រស់ឆើតឆាយ ។ ប៉ូលិចសែនក៏មានកំហឹងជាយ៉ាងខ្លាំងភ្លាមមួយរំពេជ ហើយក៏ចាប់ផ្តើមនិយាយប៉ះទង្គិចនឹងជីវិតរស់នៅដ៏ស្តុកស្តម្ភបែបនេះ ។ អារីសទីពក៏សួរទៅគាត់ដោយសុច្ចរិតវិញថា តើគាត់មានចង់ចូលរួមជាមួយនឹងការស្រស់ស្រូបភោជនាហារនេះទេ ។

– ខ្ញុំថ្វីក៏មិនចង់, ប៉ូលិចសែនឆ្លើយតប

– យីម្តេចក៏អីចឹង ? ... បើដូច្នេះ ម្តេចក៏ចាំបាច់ស្រែកឡូឡាខ្លាំងម្ល៉េះ ? អារីសទីពពោលសួរតបវិញ ។ ក្រែងឯងដាក់ទោសកំហុសទៅលើម្ហូបឆ្ងាញ់និងពួកក្រុមអ្នកជប់លាងទាំងអស់គ្នានេះឬ ?

– ទេ! មិនមែនដូច្នេះទេ... គឺអញដាក់ទោសទៅលើការចាយវាយដោយឥតបើ

គិត ។

★ ..អារីសទីត កាលពីយូរយារណាស់មកហើយ ធ្លាប់មានការទាស់ទែងខ្វែងសំដីគ្នាជាមួយនឹងអេសគីន ។ អ្នកទាំងពីរមានការអាក់អន់ចិត្តនឹងគ្នាយ៉ាងខ្លាំង ហើយមិនដែលបានជួបមុខគ្នារហូតតាំងពីពេលនោះមក ។

សម័យថ្ងៃមួយ អារីសទីពក៏បានធ្វើដំណើរឆ្លងកាត់ទៅជួបអេសគីនមុន ហើយក៏ពោលថា ៖

– យ៉ាងម៉េច ? យើងគិតតែពីទាស់ទែងគ្នាតែរហូតយ៉ាងនេះទៅឬ ? តើឯងចាំឲ្យពួកគេទាំងអស់គ្នាសើចចំអកដាក់យើងទាំងពីរនាក់ទាល់តែរយះមាត់ទៅឬ ? ឯងចង់ឲ្យពួកបញ្ចើក្អែក ( ពួកបារ៉ាស៍យ ) ដែលដើរទៅស៊ីបាយផ្ទះគេនោះ ... និយាយដើមចំអកពីយើង នៅមុខតុម្ហូបអាហារនោះមែនទេ ?

– អើមែន! គ្នាសប្បាយចិត្តណាស់, អេសគីនឆ្លើយតបវិញ, ហើយគ្នាក៏យល់ព្រមត្រូវរូវជាមួយឯងវិញយ៉ាងអស់ពីក្នុងចិត្ត...

– ចូរឯងកុំភ្លេចថា ... គឺអញទេហ្នា ដែលបានបបួលឯងមុន, អារីសទីពពោលបន្ត, ថ្វីបើអញមានអាយុច្រើនជាងឯងក្តី ...

★ ..ថ្ងៃមួយ ដេនីសបានធ្វើការជប់លៀងមួយយ៉ាងអធឹកអធ៍ម, ហើយនៅទីចុងបំផុត ស្តេចនេះក៏មានគោលបំណងចង់ឲ្យជនម្នាក់ៗ ស្លៀកសំពត់វែងព៌ណក្រហម ព្រមទាំងឲ្យរាំរែកនៅកណ្តាលសាលភោជនាហារ ។ ប្លាតុងដែលនៅទីនោះដែរមិនព្រមធ្វើតាមបញ្ជារបស់ស្តេចទេ ។ គាត់បានពោលថាគាត់ជាបុរស ហើយសំពត់វែងរបៀបស្រីដូច្នេះមិនសមសក្តិនឹងរូបគាត់ទេ ។ ក៏ប៉ុន្តែអារីសទីពមិនសូវខ្វល់ខ្វាយច្រើននៅក្នុងរឿងនេះឡើយ ។ គាត់នេះក៏ចាប់ផ្តើមស្លៀកសំពត់វែងហើយរាំរែកឡកឲ្យអ្នកផងមើល... ហើយក៏ពោលឲ្យឃោបល់របៀបសប្បាយយ៉ាងស្វាហាប់ដូច្នេះថា ៖ « យើងធ្លាប់ធ្វើខ្លាំងជាងនេះទៅទៀត នៅពេលបុណ្យទានថ្វាយព្រះបាក់គុស ( កកន ៖ Bacchus, ព្រះឥសូរ ឬព្រះសេវៈនៃជនជាតិក្រិក ) ...ហើយក៏មិនដែលឃើញមាននរណាខូចកាចភ្លាត់ស្នៀតបាត់បង់ព្រហ្មចារីយអ្វីទៅ? មនុស្សឃើងកាលណាវាមិនខូចក៏នៅតែវាមិនខូចអីចឹងឯង... ទោះស្លៀកពាក់អ្វីក៏ដោយ » ។

★ នៅពេលមួយទៀត អារីសទីពបានពោលអង្វរករចំពោះដេនីសឲ្យជួយយកអាសារមិត្តសំឡាញ់ដ៏ប្រសើររបស់គាត់ម្នាក់ ។ ដេនីសបានរុញច្រានគាត់ចេញ, ដោយធ្វើថ្លង់ធ្វើគរ មិនព្រមអនុញ្ញាត្តតាមសេចក្តីសុំរបស់អារីសទីពសោះ ។ គាត់នេះក៏លុតជង្គង់ឱនក្បាលក្រាបរហូតដល់ថើបជើងរបស់ស្តេច ។ មានអ្នកខ្លះបានយល់ឃើញថាឫកពារអាកប្បកិរិយាបែបនេះ ជាអំពើមួយដ៏គួរអាមាស់ថោកទាបខ្លាំងណាស់។ អារីសទីព ក៏បានឆ្លើយតបវិញថា ៖ « រឿងនេះមានខុសពីខ្ញុំឯណា ?

... ទាំងនេះជាកំហុសរបស់ដេនីស ... ពីព្រោះស្តេចមានត្រចៀកនៅត្រង់ជើង »។

★ ថ្ងៃមួយដែលគាត់នៅស្រុកស៊ីរ៉ាគុស , នាយស៊ីមុស ព្រីយៀង ដែលមានថានៈជាមេឃ្លាំងរបស់ស្តេចដេនីស បាននាំគាត់ទៅឲ្យមើលវាំងដ៏សម្បើមរបស់ខ្លួន , ហើយនៅពេលដែលនាយនាំគាត់ចុះឡើងពីឆ្វេងទៅស្តាំ ដើម្បីឲ្យគាត់មៀងមើលគ្រឿងសិល្បៈដ៏ល្អៗ , អារីសទីពក៏ធ្វើជាក្អកកណ្តាស់ រួចហើយក៏ស្តោះទឹកមាត់ផែតទៅលើមុខរបស់ស៊ីមុស ។ នៅពេលដែលនាយស៊ីមុសបែបចង់រកខឹងសម្បារ , អារីសទីពក៏បានពោលឡើងថា ៖ « នែហ! សំឡាញ់... ខ្ញុំរកកន្លែងដែលក្រខ្វក់ជាងនេះដើម្បីស្តោះទឹកមាត់វាមិនបានទេ ...» ។ មានអ្នកខ្លះបានអះអាងថាព្រឹត្តិការណ៍នេះ , ឬដែលប្រព្រិត្តទៅរបៀបគ្នានេះ ... គឺជាឌីយ៉ូសែន-ឡឺស៊ីនីកទេ ដែលជាអ្នកបានបង្កើត ។ ... ប៉ុន្តែ អ្នកទាំងពីរនេះអាចប្រព្រិត្តរឿងដូច្នេះបានតែទាំងពីរនាក់ ។

★ ក្នុងសម័យថ្ងៃមួយ មានបុរសម្នាក់បានជេរត្មះតិះដៀលគាត់ជាខ្លាំង ។ អារីសទីពក៏សម្រេចដើរចាកចេញពីទីនោះ ។ បុគ្គលជម្លើយនោះក៏ដើរតាមគាត់ទៅ ។

★ នៅពេលមួយទៀត អារីសទីពបានសុំប្រាក់មួយតម្លឹងពីដេនីស ។ ដេនីសក៏និយាយទៅគាត់ថា ៖

– ក្រែងកាលពីដើម ឯងនិយាយប្រាប់អញថា ពួកបញ្ញាជនមិនដែលត្រូវការប្រាក់កាសទេឬអ្វី ?

– ចាំលោកឲ្យប្រាក់ខ្ញុំសិនមក ... រួចសិមយើងពិនិត្យមើលរឿងនេះទាំងអស់គ្នាឡើងវិញ , អារីសទីពឆ្លើយ..

ដេនីសក៏ប្រគល់ប្រាក់ឲ្យគាត់...

– ឃើញទេ, អារីសទីពនិយាយបន្តមកទៀត, លោកឃើញស្រាប់ហើយថា នៅក្នុងពេលនេះ ខ្ញុំឥតមានត្រូវការលុយអ្វីទៀតទេ មែនទេ ?

★ នៅពេលដែលមនុស្សម្នាក់ បានស្តីបន្ទោសឲ្យគាត់យ៉ាងខ្លាំងថា គាត់នេះបានបោះបង់ចោលសូក្រាត ដើម្បីទៅបម្រើដេនីសវិញ, គាត់ក៏បានឆ្លើយថា ៖ កាលណាខ្ញុំត្រូវការបញ្ញា ហើយនិងចំណេះដឹង, ខ្ញុំបានទៅផ្ទះសូក្រាត ។ នៅពេលនេះ ដែលខ្ញុំត្រូវការលុយ ខ្ញុំស្វែងទៅផ្ទះដេនីស ។

★ ក្នុងសម័យថ្ងៃមួយ គាត់បានឃើញយុវជនម្នាក់ ដែលសប្បាយហ៊ឹកហ៉ាក់ខ្លាំងពេកណាស់ ព្រោះតែគេចេះហែលទឹក ៖ « ឯងមិនចេះខ្មាស់អៀនទេឬ, អារីសទីពពោល , បានជាមកអួតអាងក្នុងបើសព្វអារឿងកំទេចកំទីប៉ុណ្ណឹងៗ ។ សត្វត្រីដូហ្វាំង ( ដុលហ្វីន ) ...ហែលពូកែជាងឯងទៅទៀត » ។

★ នៅពេលដែលគេសួរគាត់ថា តើគាត់បានទាញផលចំណេញអ្វីខ្លះដែរទៅពីទស្សនវិជ្ជា ៖ « គឺ, គាត់ពោល, សមត្ថភាពក្នុងការនិយាយស្តីដោយសេរីនិងស្មើភាគ

ជាមួយគ្រប់មនុស្សទាំងអស់ » ។ មានមនុស្សម្នាក់ទៀតបានសួរគាត់ថា ៖ «ពួកអស់លោកទស្សនវិទូរ, តើអស់លោកមានអ្វីប្រសើរជាងអ្នកដទៃត្រង់កន្លែងណាទៅ ? » ។

« គឺថា , អារីសទីពឆ្លើយតប, បើទោះជានៅក្នុងពេលណាដែលគ្មានច្បាប់ទម្លាប់អ្វីសោះក៏ដោយ, ក៏ពួកយើងនៅតែអាចរស់តាមរបៀបដដែល ...» ។

ពួកស៊ីរ៉េណាអ៊ីក យកចិត្តទុកដាក់តែទៅលើសីលធម៌តែប៉ុណ្ណោះ, ហើយមិនសូវចាប់អារម្មណ៍មកលើស្បង់ឬវិទ្យាសាស្ត្រផ្នែកខាងវិនិច្ឆ័យនោះប៉ុន្មានទេ។ ពួកគេមិនបានរវីរវល់ទាល់តែសោះនឹងវិទ្យាសាស្ត្រពិសាធន៍ ...ពីព្រោះគេស្មានថាមុខវិជ្ជានេះរៀនមិនចេះ ។

ពួកគេយល់ថា គោលបំណងធំបំផុតរបស់ជីវិត គឺសេចក្តីសប្បាយ... មិនមែនសេចក្តីសប្បាយទទេប្រហោងក្នុង ដែលគ្រាន់ជាអវត្តមាននៃទុក្ខកង្វល់តែប៉ុណ្ណោះទេ...ក៏ប៉ុន្តែគឺជាសេចក្តីត្រេកត្រអាលពិតប្រាកដ, មែនទែន, ជាក់លាក់ដែលស្ថិតនៅក្នុងសកម្មភាព ។ ពួកគេតែងយល់ថា មានចលនាពីរយ៉ាងនៅក្នុងអារម្មណ៍ ៖ ចលនាមួយស្លូតបូតស្រគត់ស្រគំ ដែលនាំឲ្យមានសេចក្តីសុខ; ចលនាមួយទៀតមានសភាពគំហុក ដែលបណ្តាលឲ្យកើតសេចក្តីឈឺចាប់ ។ ដោយអ្នកផងច្រើនចូលចិត្តចលនាទី១ ..ហើយតែងតែគេចចៀសវាងពីចលនាទី២, គឺបានសេចក្តីថា សេចក្តីសុខសប្បាយគឺជាគោលបំណងធំបំផុតរបស់មនុស្សទូទៅ ។ ពួកគេយល់ថាសេចក្តីខ្ជិលច្រអូស មានលំនាំដូចជាសភាពការណ៍នៃមនុស្សដេកលក់ ដែលគេមិនត្រូវយកទៅដាក់បញ្ចូលនៅក្នុងការសប្បាយ ឬក៏នៅក្នុងសេចក្តីឈឺចាប់នោះឡើយ ។ ... ពួកគេយល់ថាសីលធម៌មានប្រយោជន៍ តែក្នុងលក្ខណៈណាដែលរបស់នេះ ជួយឲ្យមានការត្រេកត្រអាលសប្បាយរីករាយ, ប្រៀបបាននឹងថ្នាំពេទ្យដែលជួយមនុស្សម្នាក់ៗឲ្យមានសុខភាពអឺចឹងឯង ។ ពួកគេយល់ថា ការសម្រេចទៅតាមសេចក្តីប្រាថ្នា វាខុសគ្នាពីសុភមង្គល ។ គឺដោយហេតុថាគោលប្រាថ្នានៅទីបំផុតនៃសកម្មភាពអ្វីមួយគឺការទទួលលទ្ធផលសប្បាយអ្វីមួយជាពិសេស, ចំណែកសុភមង្គលវិញគឺជាកម្រងនៃសេចក្តីសុខ, នៃសេចក្តីត្រេកត្រអាលគ្រប់បែបយ៉ាង ។ ពួកគេយល់ថាសេចក្តីសប្បាយផ្នែករូបកាយ វាមានលក្ខណៈដ៏ប្រសើរ គួរឲ្យត្រេកត្រអាលច្រើនជាងការរំភើបសប្បាយក្នុងផ្លូវអារម្មណ៍...ម្ល៉ោះហើយ ពួកស៊ីរ៉េណាអ៊ីកយកចិត្តទុកដាក់ថែទាំតែចំពោះរូបកាយ, ហើយមិនសូវជារវីរវល់នឹងព្រលឹងវិញ្ញាណសោះឡើយ ។

⋆ ពួកគេបានចាត់ទុកជាទស្សនៈចំបង នូវការខំប្រឹងប្រែងចងមិត្តភក្តិ ដោយហេតុថាមនុស្សយើងតែងតែត្រូវការពឹងពាក់ជានិច្ចចំពោះមិត្តសំឡាញ់, ដូចគេយកចិត្តទុកដាក់នឹងអវៈយវៈនៃអង្គកាយ (ដៃ-ជើង ) ...ដោយហេតុថារបស់នេះ វាមាន

ប្រយោជន៍សំរាប់ប្រើប្រាស់ ។

★ ពួកគេយល់ថាគ្មានអ្វីជាយុត្តិធ៌ម ឬក៏ជាអយុត្តិធ៌ម, ជាសេចក្តីសុចរិត ឬក៏ជាអំពើទុចរិតនោះទេនៅលើលោកយើងនេះ, រឿងអស់ទាំងនេះ វាមានការទាក់ទងត្រឹមតែជាមួយច្បាប់ទម្លាប់នៃស្រុកទេសតែប៉ុណ្ណោះ ។ អ្នកប្រាជ្ញមិនត្រូវធ្វើអ្វីដែលខុសទំនងនោះឡើយ, ពីព្រោះគេត្រូវខ្លាចរអែងនឹងគ្រោះថ្នាក់ដែលអាចកើតមានឡើងជាយថាហេតុ ។ បញ្ញាជនត្រូវចេះរស់នៅស្របតាមច្បាប់ នៅក្នុងស្រុកដែលគេសំណាក់នៅ, ជានិច្ចជាកាល, ហើយត្រូវចៀសវាងកុំឲ្យមានការខូចឈ្មោះកេរ្តិ៍ឈ្មោះ ។

★ ពួកគេនិយាយទៀតថា វាគ្មានអ្វីល្អ ឬអាក្រក់, ដែលស្រួលឬក៏ពិបាក ពីខ្លួនវានោះឡើយ។ តម្លៃនៃការវិនិច្ឆ័យទាំងអស់នេះ វាអាស្រ័យទៅលើម៉ូដ ឬរបៀបរស់នៅថ្មី, ទៅលើភាពសំបូរសប្បាយ, ឬទៅលើកាលៈទេសៈផ្សេងៗ ដែលធ្វើឲ្យរបស់ខាងលើក្លាយទៅជាមានតម្លៃល្អឬអាក្រក់ ។

★ គេមិនអាចរស់នៅដោយប្រមូលសេចក្តីសប្បាយពេញលេញ ឬក៏សុភមង្គ-លឥតខ្ចោះនៅលើលោកនេះឡើយ, ដោយហេតុថាមនុស្សយើងម្នាក់ៗតែងតែមានពិការភាពមួយពាន់យ៉ាង, ឬមានតណ្ហាមួយពាន់បែប ដែលបណ្តាលឲ្យយើងអាក់ខានក្នុងសេចក្តីសប្បាយនោះ ឬក៏មកឃាត់ឃាំងរាំងរារូបយើងមិនឲ្យទទួលសភាពឆ្ងាញ់ពិសារពេញទំហឹង ។

★ ពុំមែនសេរីភាព ឬក៏ទាសភាព, ការសម្បូរណ៍សប្បាយ ឬក៏សេចក្តីក្រខ្សត់ទុរគត, សេចក្តីថ្លៃថ្នូរឬក៏សេចក្តីថោកទាបពីកំណើតនោះទេ, ដែលជាកត្តាអាចឃាត់ឃាំងរាំងរាសេចក្តីសប្បាយបាន ។ មនុស្សយើងអាចស្គាល់លក្ខណៈនៃសេចក្តីស-ប្បាយ ទោះជានៅក្នុងឋានៈឬវណ្ណៈណាក៏ដោយ ។

★ អ្នកប្រាជ្ញមិនត្រូវស្អប់ជនណាម្នាក់ឡើយ, ប៉ុន្តែត្រូវតែបង្ហាត់បង្រៀនអ្នកផងគ្រប់ៗគ្នា ។ បញ្ញាជនត្រូវគិតថាអ្វីៗដែលគេធ្វើ គឺអាស្រ័យនៅលើរូបគេទាំងអស់, ពីព្រោះគ្មាននរណាម្នាក់ដែលសមស័ក្តិឲ្យលើសពីខ្លួនគេក្នុងការទទួលបុព្វសិទ្ធគ្រប់បែបយ៉ាង, មិនត្រឹមតែប៉ុណ្ណោះ ខ្លួនគេវាបិតនៅខ្ពស់ហួសសេចក្តីអធិប្បាយលើអំពីអ្វីៗដែលបិតមាននៅក្នុងលោកនេះរួចទៅហើយ ។ ទាំងនេះ គឺជាអារម្មណ៍របស់អារីសទីពនិងរបស់ពួកស៊ីរ៉េណាអ៊ីក ។

❑

អារីសទីពមានកូនស្រីម្នាក់ឈ្មោះអារ៉េតា, ដែលគាត់បានខំប្រឹងប្រែងថែទាំអប់រម្យឲ្យបិតនៅក្នុងវិន័យរបស់គាត់ ។ នាងក៏បានក្លាយទៅស្រីម្នាក់មានបញ្ញាខ្ពង់ខ្ពស់នៅក្នុងក្រុមរបស់ពួកស៊ីរ៉េណាអ៊ីក ។ នាងបានបង្ហាត់បង្រៀនកូនប្រុសរបស់នាង

( ដែលមានឈ្មោះថាអារីសទីពដូចជីតា ) ដោយខ្លួននាង ។ កូនប្រុសនោះ មានរហស្សនាមថា មេត្រូឌីដាក់ ដែលថ្ងៃក្រោយទៅបានក្លាយទៅជាគ្រូបង្រៀនរបស់ជនឥតជំនឿលើព្រះម្ចាក់ ឈ្មោះតេអូឌរ ។ បុគ្គលក្រោយនេះ ក្រៅតែពីគោលជំហររបស់ក្រុមស៊ីរ៉េណាអ៊ីក បានបង្ហាត់បង្រៀនក្នុងទីសាធារណៈ ដោយអះអាងថា ពុំមានព្រះឬទេព្តា ឬព្រះឥន្ទព្រះអង្គអ្វីទាំងអស់ ។ ជននេះបានអះអាងថែមទៀតថា មិត្តភាពគឺគ្រាន់តែជាគ្រឿងបញ្ឆោតតែប៉ុណ្ណោះឯង ។ គឺ..វាមិនអាចមានមិត្តភាពទៅកើតនៅក្នុងហ្វូងមនុស្សឆ្កួតនោះឡើយ ។ អ្នកប្រាជ្ញមានតែខ្លួនឯងម្នាក់គឺគ្រប់គ្រាន់ណាស់ទៅហើយ, ម្ល៉ោះហើយបញ្ញាជនមិនចាំបាច់មានមិត្តភក្តិសោះឡើយ ។ អ្នកប្រាជ្ញជាមនុស្សម្នាក់ដែលគ្មានប្រទេសជាតិ... ក្រៅតែពីពិភពលោកទាំងមូល ។ ម្ល៉ោះហើយ គេមិនត្រូវយកអ្នកប្រាជ្ញទៅ ឲ្យរងគ្រោះថ្នាក់ស្លាប់សម្រាប់ហ្វូងមនុស្សឆ្កួតនោះឡើយ... ពីព្រោះពុំមែនជាអំពើមួយប្រកបដោយយុត្តិធម៌សោះ ។ ម្យ៉ាងវិញទៀតអ្នកប្រាជ្ញអាចលួចរបស់ប្រើប្រាស់បន្តិចបន្តួចបាន, អាចប្រមាថទីអាសនៈរបស់ព្រះក៏បាន, អាចលួចប្រពន្ធគេបានតាមចិត្ត ...ប្រសិនបើឱកាសអនុញ្ញាតឲ្យរូបគេប្រព្រឹត្តធ្វើទៅដោយគ្មានទោសពៃរ៍, ពីព្រោះរឿងទាំងអស់នេះមានលក្ខណៈជាបទឧក្រិដ្ឋតែក្នុងក្នុងអារម្មណ៍របស់មនុស្សល្ងង់ខ្លៅ និងក្នុងមតិរបស់ប្រជាពលរដ្ឋសាមញ្ញធម្មតាតែប៉ុណ្ណោះ ។ តាមការពិតអំពើអស់ទាំងនេះ ពុំមែនជាអំពើអាក្រក់ទាល់តែសោះ ។ ទាំងនេះជាយោបល់របស់តេអូឌរ...សិស្សចៅរបស់អារីសទីព ។

★ បុគ្គលនេះយល់ថា គេអាចធ្វើអ្វីៗនៅក្នុងទីសាធារណៈ នូវអ្វីៗគ្រប់យ៉ាងដែលមតិមហាជនយល់ថាជារឿងអាក្រក់អាក្រី ដ៏គួរអាមាស់ថោកទាបជាទីបំផុត ។

★ ថ្ងៃមួយគាត់ត្រូវបានគេបញ្ឆោតឲ្យទៅចូលតុលាការនៅទីក្រុងអាតែ្មន ( សាលាកាត់ក្តីនោះឈ្មោះថាអារ៉េអូប៉ា ឋិតនៅលើកំពូលភ្នំអារ៉េស) ...ក៏ប៉ុន្តែ មានឈ្មោះដេម៉េទ្រីយុស នៅផាលែរ ដែលបានជួយគាត់ឲ្យរួចខ្លួន ។ គាត់បានទៅសំណាក់នៅអស់មួយរយៈពេលនៅស៊ីរ៉ែន ...ដែលនៅទីនោះ ម៉ារីយុសបានទទួលគាត់ឲ្យរស់នៅដោយកិត្តិយសធំដុំ ។ ក៏ប៉ុន្តែពួកស៊ីរ៉ែនក៏បាននិរទេសគាត់ឲ្យត្រឡប់ទៅវិញ ។ នៅពេលដែលគាត់ថយខ្លួនគាត់បានពោលទៅកាន់អ្នកទាំងនោះថា ៖ « ពួកអ្នកឯងឥតដឹងថា ពួកខ្លួនកំពុងធ្វើអ្វីទេ ដែលបានបណ្តេញខ្ញុំឲ្យចេញពីលីប៊ី ឲ្យទៅរស់នៅក្នុងភាពនិរទេសឯប្រទេសក្រិក » ។ ផ្តូឡេម៉េ-ឡាគុស, ដែលបានទទួលរូបគាត់ឲ្យសំណាក់នៅ ក៏បានបញ្ជូនរូបគាត់ក្នុងឋានៈជារដ្ឋទូតទៅនៅជាមួយស្តេចលីស៊ីម៉ាគុស ។ គាត់ក៏បាននិយាយរបៀបព្រហើនកាងកាចខ្លាំងពេកជាមួយនឹងស្តេច ... រហូតដល់មេឃ្លាំងរបស់ស្តេចលីស៊ីម៉ាគុសកំពុងឈរនៅទីនោះដែរ បានពោលថា ៖ « យើងយល់ថា តេអូឌរឯង ជឿថាឥតមានព្រះឥន្ទព្រះអង្គ... ហើយក៏ឥតមានស្តេចផងដែរ

មែនទេ ...» ។

អំហ្វីក្រាតបានធ្វើរបាយការណ៍ថា ទស្សនវិទូម្នាក់នេះ នៅទីបញ្ចប់ក៏បានត្រូវគេយកទៅកាត់ទោសប្រហារជីវិត ដោយបង្ខំឲ្យផឹកថ្នាំពុល ។៚

❏ ❏

❏

# ជីវិតរបស់អារីសតូត
## ARISTOTE

កើតនៅក្នុងឆ្នាំទី-១នៃអូឡាំព្យ៉ាដទី ៩៩ ។ ស្លាប់ទៅវិញនៅឆ្នាំទី ៣ នៃអូឡាំព្យ៉ាដទី១១៤, ក្នុងជន្មាយុ ៦៣ឆ្នាំ ។

អារីសតូតបានឋិតនៅក្នុងចំណោមទស្សនវិទូដ៏មានកេរ្តិ៍ឈ្មោះល្បីជាទីបំផុតនៅក្នុងបុរាណកាល ៖ ឈ្មោះគាត់សព្វថ្ងៃនៅតែមានសភាពរន្ទឺរសុះសាយនៅគ្រប់សាលារៀន ។ គាត់ត្រូវជាកូនប្រុសរបស់នីកូម៉ាគុស, លោកគ្រូពេទ្យម្នាក់ដែលត្រូវជាមិត្តភក្តិរបស់អាមីនតាស, ស្តេចនៅម៉ាសេឌ្វាន់ ។ គាត់មានសែស្រឡាយចុះមកពីម៉ាកាអុង ដែលត្រូវជាចៅរបស់អេសគូឡាព ។ គាត់មានកំណើតកើតនៅស្តាយៀរនៅក្នុងទីក្រុងម៉ាសេឌ្វាន់, នៅក្នុងឆ្នាំទី១ នៃអូឡាំព្យ៉ាដទី៩៩ ។ គាត់បានត្រូវធ្លាក់ខ្លួនកំព្រាបាត់បង់ឱពុកម្តាយតាំងពីនៅក្នុងវ័យកុមារភាពមកម្ល៉េះ ។ អ្នកដែលមានភារៈទទួលខុសត្រូវ នៅក្នុងការអប់រំរបស់គាត់បានបោះបង់រូបគាត់ចោល ។ ម្ល៉ោះហើយអារីសតូត ពេលចូលវ័យជំទង់ក៏បានធ្លាក់ខ្លួនទៅក្នុងអបាយមុខផ្សេងៗ... ទៅក្នុងការសប្បាយស្រើបស្រាលពាសវាលពាសកាលដែលបានបណ្តាលឲ្យគាត់បាត់បង់ទ្រព្យធនអស់រលីង ។

ជាដំបូងគាត់បានចុះឈ្មោះជាយុទ្ធជនស្ម័គ្រចិត្តចូលធ្វើសឹកសង្គ្រាម, ក៏ប៉ុន្តែដោយមុខរបរនេះ មិនសមស្របនឹងជំនោរចិត្តរបស់គាត់ពីកំណើត, គាត់ក៏បានឆ្លៀតទៅសួរហោរានៅភ្នំដេលហ្វ, ដើម្បីគ្រាន់តែចង់ដឹងថា គាត់នឹងត្រូវធ្វើអ្វីសម្រាប់តទៅថ្ងៃមុខទៀត។ ហោរាបានបញ្ជារឲ្យគាត់ធ្វើដំណើរទៅក្រុងអាតែ្មន, ព្រមទាំងឲ្យខំប្រឹងហ្វឹកហ្វឺនខាងផ្នែកវិន័យទស្សនវិជ្ជា ។ នៅពេលនោះ គាត់បានចូលក្នុងអាយុ១៨ឆ្នាំរួចទៅហើយ ។ គាត់បានខំប្រឹងប្រែងរៀនសូត្រអស់រយៈពេល២០ឆ្នាំ នៅអាកាដេមីក្រោមការដឹកនាំរបស់ប្លាតុង, ហើយដោយគាត់បានចាយវាយបំផ្លាញទ្រព្យសម្បត្តិរបស់គាត់ខ្ទេចខ្ទីអស់រលីងរួចទៅហើយ, គាត់ក៏មានកាតព្វកិច្ចដើម្បីរកកម្រៃចិញ្ចឹមជីវិតយកថ្នាំទៅលក់...ថ្នាំខ្លះគាត់ធ្វើដោយដៃខ្លួនឯង, នៅទីក្រុងអាតែ្មន ។

អារីសតូតមានទម្លាប់បរិភោគតែបន្តិចបន្តួចប៉ុណ្ណោះ, ហើយនិទ្រាក៏រិតតែតិចតួចណាស់ទៅទៀត ។ ដោយគាត់ស្រឡាញ់ការសិក្សាស្រាវជ្រាវពេកទៅ, ដើម្បីទប់ទ-

ល់នឹងការងងុយដេក, គាត់បានយកចាំងស្ពាន់មួយដាក់ក្បែរគ្រែដំណេករបស់គាត់ ស្រណុកនៅពេលចូលទំរេតគាត់លាតសន្ធឹងដៃរបស់គាត់ម្ខាងរហូតដល់ចាំងស្ពាន់, ដោយនៅក្នុងកណ្ដាប់ដៃមានកាន់ដុំដែកមួយផង ។ នៅពេលដែលគាត់លង់លក់ស៊ប់ក្នុងអារម្មណ៍ ដុំដែកក៏របូតធ្លាក់ទៅក្នុងចាំងស្ពាន់បណ្ដាលឲ្យលាន់ឮសម្លេងយ៉ាងខ្លាំង ធ្វើឲ្យគាត់ភ្ញាក់ក្រញាងឡើងវិញមួយរំពេច ។ ឡាអ៊ែរកបានធ្វើរបាយការណ៍ថាគាត់មានសម្លេងស្រួយ (ញ៉ៀវៗ) , ភ្នែកតូចៗ, ហើយជើងក៏តូចទៀត ហើយថាគាត់ចូលចិត្តស្លៀកពាក់ស្អាតបាតផូរផង់ ។

អារីសតូតមានបញ្ញាស្មារតីវាងវៃណាស់ ហើយអាចយល់ចំណោទដ៏លំបាកៗនោះយ៉ាងឆាប់រហ័សជាទីបំផុត ។ មិនយូរប៉ុន្មានគាត់ក៏ចាប់ផ្ដើមមានទេពកោសល្យខ្ពង់ខ្ពស់នៅក្នុងសាលារបស់ប្លាតុង, ព្រមទាំងមានកេរ្តិ៍ឈ្មោះខ្ពស់ល្បីពីលើពួកបណ្ឌិតសភាឯទៀតៗទាំងអស់ ។ នៅក្នុងអាកាដេមី (បណ្ឌិតសភា) គេពុំហ៊ានសម្រេចអ្វីទាំងអស់ បើកាលណាហើយគេមិនបានទទួលយោបល់របស់អារីសតូត, ថ្វីត្បិតតែយោបល់នេះ ជួនកាលមិនសូវសមស្របជាមួយគោលជំហររបស់ប្លាតុងក៏ដោយ ។ ពួកសាវ័កឯទៀតៗបានសម្លឹងមើលមកអារីសតូត, ដោយចាត់ទុកថាជាអ្នកប្រាជ្ញម្នាក់ដ៏ខ្ពង់ខ្ពស់សម្បើមអស្ចារ្យណាស់ ។ មានអ្នកខ្លះអនុលោមតាមយោបល់របស់អារីសតូតដោយទៅទទឹងជាមួយនឹងយោបល់របស់លោកគ្រូធំថែមទៀតផង ៖ គឺប្លាតុង ។ អារីសតូតក៏បានដកខ្លួនថយចេញពីបណ្ឌិតសភា ដែលជាហេតុបណ្ដាលឲ្យប្លាតុងមានការអាក់អន់ស្រពន់ចិត្តជាខ្លាំង ។ លោកគ្រូធំបានចាត់ទុកថាអារីសតូតជាសាវ័កម្នាក់បះបោរ ហើយតែងតែថ្លែងថាបុគ្គលចេះតែប្រឆាំងនឹងរូបគាត់, ដូចជាកូនសេះមួយ ដែលប្រឆាំងនឹងមាតារបស់ខ្លួនឯង ។

ពួកអ្នកទីក្រុងអាតែ្ហនបានជ្រើសរើសយកអារីសតូតបញ្ជូនទៅធ្វើជារដ្ឋទូតតំណាងទីក្រុងរបស់ពួកខ្លួននៅក្នុងវាំងស្ដេចហ្វីលីព, ឪពុករបស់អាឡេចសង់-ឡឺក្រង់ (Alexandre-le-Grand ) ។ អារីសតូតក៏បានសំណាក់អស់មួយរយៈពេលនៅម៉ាសេ-ឌ្វាន់ ដើម្បីបំពេញកិច្ចការទូតឲ្យពួកទីក្រុងអាតែ្ហន ។ នៅពេលដែលគាត់ត្រឡប់មកវិញ គាត់បានសង្កេតឃើញថា ទស្សនវិទូសេណូក្រាតបានត្រូវគេជ្រើសរើសឲ្យបង្ហាត់បង្រៀននៅក្នុងអាកាដេមី ។ នៅពេលដែលអារីសតូតបានសង្កេតឃើញថាកន្លែងនេះត្រូវគេយកបាត់ទៅហើយ, គាត់ក៏បានពោលថា គួរឲ្យអៀនខ្មាស់ណាស់ដែលអារីសតូតត្រូវតែបិទមាត់នៅស្ងៀម នៅពេលដែលសេណូក្រាតមានអំណាចនិយាយ។ គាត់ក៏បានបង្កើតក្រុមបក្សមួយទៀត ហើយក៏បានបង្ហាត់បង្ហាញចំណេះវិជ្ជាមួយផ្សេង ពីអ្វីៗដែលគាត់បានរៀនសូត្រអំពីលោកគ្រូធំរបស់គាត់ គឺប្លាតុង ។

កេរ្តិ៍ឈ្មោះល្បីល្បាញរបស់អារីសតូតដែលអ្នកផងយល់ថាចេះពូកែស្ទើរគ្រប់មុខនូវមុខវិជ្ជានិងវិទ្យាសាស្ត្រច្រើនយ៉ាងហើយ ជាពិសេសនៅក្នុងទស្សនវិជ្ជានិងន-យោបាយ, បានណែនាំចិត្តស្តេចហ្វីល្លីព ឲ្យជ្រើសរើសយករូបគាត់ទៅឲ្យបង្ហាត់បង្ហាញកូនប្រុសរបស់ទ្រង់ ។ នៅពេលនោះ អាឡេចសង់ទើបនឹងមានអាយុ១៤ឆ្នាំ។ អារីសតូតបានទទួលយកមុខងារថ្មីនេះ, ហើយក៏បានសំណាក់នៅចំនួន៤ឆ្នាំ ជាមួយនឹងអាឡេចសង់, ដើម្បីជួយអប់រម្យដល់កូនស្តេចនេះ នូវមុខវិជ្ជាពិសេសៗ , ហើយបើយោងតាមរបាយការណ៍ថ្ងៃក្រោយមករបស់ពួតាក, ដែលគាត់បានលាក់មិនបង្ហាញនរណាម្នាក់ទៀតទាំងអស់ ។ ចំណេះដឹងខាងផ្នែកទស្សនវិជ្ជា មិនបានធ្វើឲ្យគាត់មានវិន័យតឹងរ៉ឹងប៉ុន្មានទេ ។ ផ្ទុយទៅវិញគាត់ខំប្រឹងប្រែងធ្វើការរកស៊ីមានបាន, ហើយមានការលោយឡំនៅក្នុងបញ្ហានយោបាយជាច្រើនកាលក្នុងសម័យគាត់នៅក្នុងវាំងរបស់ស្តេចម៉ាសេឌ្វាន់ ។ ស្តេចហ្វីល្លីពក៏ខំលើកស្ទួយកិត្តិយសរបស់គាត់ដោ-យកសាងស្រុកស្តាយៀរឡើងវិញ ដែលជាស្រុកកំណើតរបស់អាសរីតូត , ហើយដែលធ្លាប់បានទទួលការហិនហោចដោយសារសឹកសង្គ្រាម។ ស្តេចទ្រង់បានបញ្ជូនអ្នកស្រុកដើមនៅស្តាយៀរឲ្យទៅរស់នៅទីនោះឡើងវិញទាំងអស់ដោយសុខសាន្ត, គឺដោយហេតុថាប្រជាជនមួយភាគនៅទីនោះធ្លាប់បានបាត់បង់សេរីភាព, ហើយមួយភាគទៀតក៏បានរត់ចាកចោលទីកន្លែង ។

អារីសតូតបន្ទាប់ពីបានចាកចេញពីវាំងអាឡេចសង់កាលណាមក, ក៏ត្រឡប់មករស់នៅក្នុងទីក្រុងអាតែ្មនវិញ ដែលនៅទីនោះគេបានផ្តល់កិត្តិយសឲ្យគាត់គ្រប់ៗគ្នា។ គឺដោយសារតែស្តេចហ្វីល្លីព ដើម្បីជារង្វាន់លើកទឹកចិត្តដល់អារីសតូតបានកសាងអំពើល្អជាច្រើនចំពោះអ្នកទីក្រុងអាតែ្មន ។ អារីសតូតក៏បានជ្រើសរើសយកទីកន្លែងមួយនៅក្នុងតំបន់លីសេ ( កកន ÷ Lycée ដែលថ្ងៃក្រោយមកមានឈ្មោះថាវិទ្យា-ល័យ, គឺជាស្រុកមួយនៅប្រទេសក្រិក ដែលអារីសតូតបានជ្រើសរើសយកធ្វើជាទីកន្លែងសាលារៀន ) ...យកទីកន្លែងមួយដែលមានដំាព្រៃឈើជាជួរដើម្បីបង្កើតសាលាថ្មីរបស់គាត់ ។ នៅក្នុងពេលប្រក្រតីធម្មតា គាត់តែងបង្ហាត់បង្ហាញពួកសាវ័ករបស់គាត់ ដោយដើរលេងកំសាន្តនៅទីនោះ, ម៉្លោះហើយអ្នកផងក៏នាំគ្នាហៅអ្នកបង្កើតក្រុមបរិស័ទថ្មីនេះថាជាពួកក្រុមប៉េរីប៉ាតេទីស្យាង ( Péripatéticiens ) ។ មិនយូរប៉ុន្មានវិទ្យាល័យរបស់អារីសតូតក៏ចាប់ផ្តើមមានកេរ្តិ៍ឈ្មោះរន្ទឺរល្បី, ដោយហេតុថាមានមនុស្សម្នារខ្លាន់ខ្លាប់ស្វែងមកពីគ្រប់ទិសទី ដើម្បីគ្រាន់តែបានមកស្តាប់អារីសតូត, ដែលកិត្តិនាមបានត្រូវផ្សព្វផ្សាយនៅពេញពាសប្រទេសក្រិក ។

❑

អាឡេចសង់បានស្នើរសុំឲ្យអារីសតូតធ្វើការស្រាវជ្រាវជាពិសេសនៅក្នុងមុខវិជ្ជាវិទ្យាសាស្ត្រពិសោធន៍ ៖ ទ្រង់បានបញ្ជូនពួកអ្នកប្រមាញ់និងពួកអ្នកនេសាទជាច្រើនរូប ដូចកងទ័ពមួយ ដើម្បីជួយផ្ដល់ព័ត៌មានអំពីធម្មជាតិគ្រប់ទីកន្លែងដែលអារីសតូតត្រូវការចង់ដឹង... មិនត្រឹមតែប៉ុណ្ណោះថែមទាំងបានបញ្ជូនប្រាក់៨០០តម្លឹង ដើម្បីឲ្យគាត់មានលទ្ធភាពចាយវាយធ្វើការសិក្សាស្រាវជ្រាវទៀតផង ។

អារីសតូតក៏បានបោះពុម្ពផ្សាយសៀវភៅរបស់គាត់ទាក់ទងនឹងបរម័ត្ថវិជ្ជា ( Métaphysique ) ហើយនិងវិទ្យាសាស្ត្រពិសោធន៍ ( Physique ) ។ ស្ដេចអាឡេចសង់បានទទួលដំណឹងនេះនៅចំពេលដែលទ្រង់កំពុងជាប់ច្បាំងនៅទ្វីបអាស៊ី។ ស្ដេចអង្គនេះដែលមានមហិច្ឆិតាធំធេង ហើយដែលមានគោលប្រាថ្នាធ្វើជាមនុស្សទី១នៅក្នុងលោក នៅក្នុងគ្រប់មុខវិជ្ជា, ក៏មានការក្រេវក្រោធយ៉ាងខ្លាំង ដែលចំណេះដឹងនិងវិទ្យាសាស្ត្ររបស់អារីសតូតទាំងប៉ុន្មាន បានត្រូវយកទៅចែកចាយដល់មនុស្សសាមញ្ញ ។ ទ្រង់បានសំដែងនូវទោមនស្សនេះ ដោយបានសរសេរលិខិតផ្ញើមកអារីសតូតមានសេចក្ដីដូច្នេះថា ៖

« ពីអាឡេចសង់មកអារីសតូត,...លោកគ្រូមិនគួរបោះពុម្ពផ្សាយសៀវភៅរបស់លោកគ្រូដែលទាក់ទងនឹងវិទ្យាសាស្ត្រពិសោធន៍នោះទាល់តែសោះ, គឺពីព្រោះថាយើងច្បាស់ជាគ្មានស្ថានភាពឧត្តុង្គឧត្តមអ្វីនៅពីលើអ្នកដទៃនោះតទៅទៀតទេ, ប្រសិនបើអ្វីៗដែលលោកគ្រូបានបង្ហាត់បង្រៀនយើងខ្ញុំ ជាពិសេសនោះត្រូវយកទៅផ្សព្វផ្សាយពាសវាលពាសកាលដល់មនុស្សគ្រប់ប្រភេទ ។ ខ្ញុំសូមជំរាបលោកគ្រូតាមត្រង់ទៅចុះថា ខ្ញុំត្រូវការមានចំណេះដឹងខ្ពង់ខ្ពស់លើសពីអ្នកដទៃទាំងអស់, ជាជាងមានមហិទ្ធឫទ្ធខ្លាំងពូកែនោះទៅទៀត » ។

អារីសតូតដើម្បីសម្រាលកំហឹងរបស់ស្ដេចអង្គនេះក៏បានឆ្លើយតបថា គាត់បានបង្កើតទ្រឹស្ដីអស់ទាំងនេះឲ្យឃើញពន្លឺថ្ងៃ ទៅតាមបែបបទមួយដែលទ្រឹស្ដីអស់ទាំងនេះមិនអាចឃើញពន្លឺថ្ងៃសោះឡើយ។ គឺគាត់ចង់និយាយថាគាត់បានបង្វែងដាន...ដាក់សម្ងៀកបំពាក់បញ្ច្រាស់នៅក្នុងទ្រឹស្ដីរបស់គាត់ រហូតដល់គ្មាននរណាម្នាក់អាចយល់បានឡើយ ។

អារីសតូតមិនសូវបានជាធ្វើឲ្យស្ដេចអាឡេចសង់សព្វហឫទ័យប៉ុន្មានទេ ។ ស្ដេចមានរឿងទាស់ចិត្តជាមួយគាត់ជាខ្លាំងពីព្រោះគាត់បានកាន់ជើងទស្សនវិទូកាលីសតែនដោយចំហខ្លាំងពេក ។ កាលីសតែននេះត្រូវជាចៅក្មួយរបស់អារីសតូត, ពោលគឺជាកូនប្រុសរបស់ក្មួយស្រីរបស់គាត់ ។

ក្នុងអតិតកាល, អារីសតូតធ្លាប់បានយកក្មេងម្នាក់នេះទៅចិញ្ចឹមនៅផ្ទះគាត់,

ធ្លាប់បានផ្តល់នូវការអប់រម្យគ្រប់យ៉ាង ។ នៅពេលដែលគាត់បានចាកចេញពីអាឡេ-ចសង់ទៅគាត់បានប្រគល់ចៅក្លួយនេះ ឲ្យទៅស្តេចដើម្បីឲ្យដើរតាមទ្រង់ទៅធ្វើសឹកសង្គ្រាម... ដោយបានផ្តាំផ្ញើជាមួយនឹងទ្រង់យ៉ាងពិសេសពិសាលទៀតផង ។ កាលីសតែននិយាយស្តីមិនសូវគិតក្រែងជាមួយនឹងស្តេច, ហើយមាននិស្ស័យមិនសូវចុះសម្រុងជាមួយនឹងទ្រង់ទេ ។ គឺបុគ្គលនេះឯងដែលបានឃាត់ឃាំងប្រជាជនម៉ាសេឌ្វាន់កុំឲ្យលើកដំកើងស្តេចដូចជាព្រះអាទិទេព , របៀបប្រជាជនពែរ្ស ។

អាឡេចសង់ដែលស្អប់ខ្ពើមកាលីសតែនជាខ្លាំង ពីព្រោះតែជននេះមានក្បាលរឹងពន់ពេក ...ក៏បានឆ្លៀតរកឃើញឱកាសកំចាត់ជននេះចោល ។ ស្តេចបានចោទកាលីសតែនថាមានប្រឡាក់ប្រឡូសជាមួយនឹងអំពើឃុបឃិត របស់សាវ័ករបស់ខ្លួនគឺអ៊ែរម្មូឡាអ៊ុស, ហើយទ្រង់ក៏មិនអនុញ្ញាតឲ្យជនជាប់ចោទការពារខ្លួនដែរ ។ អាឡេច-សង់ក៏បញ្ជារឲ្យចាប់កាលីសតែនទៅបោះជាចំណីសត្វសឹង្ហ ។ អ្នកខ្លះបានពោលថាទ្រង់ឲ្យយកទៅព្យួរក ។ អ្នកខ្លះទៀតបានអះអាងថាកាលីសតែនបានត្រូវស្លាប់នៅក្រោមអំពើទារុណកម្ម, វាយដំច្រំធាក់ ។

តាំងពីមានការដាក់ទោសកាលីសតែនកាលណាមក អារីសតូតក៏មានកើតចិត្តគំនុំយ៉ាងខ្លាំងជាមួយនឹងអាឡេចសង់ ។ ចំណែកអាឡេចសង់វិញក៏ឆ្លៀតឱកាសរកមធ្យោបាយគ្រប់យ៉ាងដើម្បីព្យាបាទអារីសតូត ។ ស្តេចបានលើកដំកើងកិត្តិយសរបស់សេណូក្រាតហួសចន្លោល ព្រមទាំងបានផ្ញើអំណោយយ៉ាងច្រើនឥតគណនាចំ-ពោះទស្សវិទូរក្រោយនេះ ។ អារីសតូត កើតសេចក្តីច្រណែននិន្ទារយ៉ាងខ្លាំង ។ អ្នកខ្លះបានចោទថែមទៀតផងថាអារីសតូតនេះហើយ ដែលបានឃុបឃិតជាមួយនឹងអង់ទីប៉ាទែរ ដោយឲ្យរូបមន្តទៅជនក្រោយនេះលាយថ្នាំបំពុល ដែលគេសង្ស័យថាបានត្រូវបញ្ជូនទៅឲ្យធ្វើគត់ស្តេចអាឡេចសង់ ។

អារីសតូត បើទោះជាមានអាកប្បកិរិយារឹងប៉ឹងយ៉ាងណាក៏ដោយ ក៏បានបង្ហាញនូវលក្ខណៈទន់ខ្សោយជាច្រើនផងដែរ ។ បន្តិចក្រោយពីពេលដែលគាត់បានលាចាកបណ្ឌិតសភារបស់ប្លាតុង, គាត់បានថយខ្លួនទៅរស់នៅជាមួយនឹងអ៊ែរមីញ៉ាសដែលជាស្តេចផ្តាច់ការនៅអារតាន ។ គេមិនបានដឹងដោយច្បាស់លាស់ទេថាមានមន្តស្នេហ៍អ្វី ដែលបានប្រទាញចិត្តគាត់ឲ្យទៅនៅទីនោះ ។ ក៏ប៉ុន្តែមានអ្នកខ្លះបានពោលថា អារីសតូតបានធ្វើដំណើរទៅទីនោះ ដើម្បីត្រេកត្រអាលក្នុងការប្រព្រិត្តអំពើអបា-យមុខតែប៉ុណ្ណោះ ។

អ្នកខ្លះបានពោលថាអារីសតូតបានរៀបអាពាហ៍ពិពាហ៍ជាមួយនឹងប្អូនស្រី, ខ្លះទៀតថាជាមួយនឹងប្រពន្ធចុងរបស់ស្តេចផ្តាច់ការអែរមីញ៉ាស ។ ទោះជាយ៉ាងណាក្តីគាត់បានសំដែងបង្ហាញនូវតណ្ហាក្រឡាប់ផែនដីជាមួយនឹងស្រីម្នាក់នេះ, ដែលជា

ហេតុបណ្ដាលឲ្យគាត់ធ្វើពិធីពលិកម្មសាក្ការៈបូជាចំពោះនាង ដូចដែលអ្នកទីក្រុងអា-ត្មែនធ្លាប់ធ្វើចំពោះព្រះស្រី សេរ៉េស-អេឡឺស៊ីនដូច្នោះដែរ ។ មិនត្រឹមតែប៉ុណ្ណោះ , គាត់ថែមទាំងបានសរសេរកំណាព្យជាកិត្តិយសចំពោះស្ដេចអែរមីញ៉ាស ដែលបានអនុញ្ញាត្តឲ្យគាត់រៀបការជាមួយស្រីម្នាក់នេះ ។

❑

អារីសតូតបានចែកទស្សនវិជ្ជា ជាទ្រិស្ដីនិងជាកិច្ចការអនុវត្តន៍ ។ ទស្សនវិជ្ជាអនុវត្តន៍ គឺជាវិន័យដែលបង្រៀនយើង អំពីសេចក្ដីពិតទាំងឡាយដែលអនុញ្ញាត្តឲ្យយើងយកមកធ្វើកិច្ចប្រតិបត្តលើសតិស្មារតីរបស់យើង, ដូចជាវិទ្យា-វិនិច្ឆ័យ (Logique) ដែលផ្ដល់ឲ្យយើងនូវសុភាសិត សម្រាប់ឲ្យយើងរស់សុខស្រួលក្នុងជីវិតនៃសង្គម, ដែលផ្ដល់សីលធ៌ម និងលទ្ធិនយោបាយឲ្យយើងជាដើម ។

ទស្សនវិជ្ជាក្នុងថានៈជាទ្រិស្ដីអនុញ្ញាត្តយើងរកឃើញសេចក្ដីពិតសំរាប់វែកញែកអធិប្បាយ ដូចជាបរម័ត្ថវិជ្ជា ( Métaphysique ) និងរូបវិទ្យា ( Physique ) ។ យោងតាមយោបល់គាត់, វាមានគោលជំហរបីយ៉ាង ដែលទាញបានមកពីក្បួនវិជ្ជាពីធម្មជាតិ ៖ គឺកង្វះ, វត្ថុធាតុដើម, និងរូបរាងទ្រង់ទ្រាយ ។

ដើម្បីបង្ហាញថា «កង្វះ» ក៏ត្រូវចាត់ទុកជាគោលជំហរផងដែរ, គាត់បានពោលថា វត្ថុធាតុដើមដែលកសាងឆ្លាក់ឆ្លៃគ្រឿងរបស់ប្រើប្រាស់អ្វីមួយ ត្រូវមាន «កង្វះ» នៃគ្រឿងរបស់នោះ ។ ជាឧទាហរណ៍, គេត្រូវចាត់ទុកថាវត្ថុធាតុដើមដែលកសាងតុការិយាល័យ, វាត្រូវតែមានកង្វះ នៃរូបរាងទ្រង់ទ្រាយរបស់តុ-ការិយាល័យ, ពោលមុននឹងកសាងឆ្លាក់ឆ្លៃតុការិយាល័យមួយ, វាទាល់តែវត្ថុធាតុដើម ពុំមានរូបរាងទ្រង់ទ្រាយជាតុ-ការិយាល័យនោះទេ ។

អារីសតូតមិនបានចាត់ទុកកង្វះ ជាគោលជំហរសម្រាប់សាងសង់រូបកាយនោះឡើយ, ក៏ប៉ុន្តែជាគោលជំហរនៃទិដ្ឋភាពខាងក្រៅដើម្បីផលិតកម្ម, ក្នុងលក្ខណៈដែ-លថាផលិតកម្មគឺជាការប្រែប្រួលពីសភាពការណ៍មួយ ដែលវត្ថុធាតុដើមមិនទាន់មានរូប ទៅសភាពការណ៍មួយទៀតដែលវត្ថុធាតុមានរូប ៖ ជាឧទាហរណ៍ឈើក្តារដែលមិនទាន់មានរូប ដែលក្លាយទៅជាតុ ។

អារីសតូតបានផ្ដល់នូវនិយមន័យពីរខុសគ្នាអំពីវត្ថុធាតុ ។ និយមន័យទី១ មានលក្ខណៈជាអវិជ្ជមាន ( Caractère négatif ) ។ វត្ថុធាតុដើម, គាត់ពោល, គឺពុំមែនជាធាតុ, ឬជាសភាពលាតសន្ធឹង, ឬជាគុណសម្បត្តិ គឺពុំមានលក្ខណៈអ្វីទាំងអស់ ។ ដូច្នេះបើយោងតាមយោបល់គាត់, ធាតុដើមរបស់ឈើ គឺពុំមែនជាទំហំរបស់វា, ពុំមែនជារូបរាងទ្រង់ទ្រាយ, ពុំមែនជាព៌ណសំបុរ, ពុំមែនជាសភាពរឹង, ពុំមែនជាលក

ណៈស្ងួតហែង ឬក៏ជាសភាពសើមស្អិត, ពុំមែនជាក្លិន, ពោលពុំមែនអ្វីៗទាំងអស់ជាគ្រោះថ្នាក់ចរាចរដែលមាននៅក្នុងសាច់ឈើនោះឡើយ ។

និយមន័យមួយទៀតមានលក្ខណៈជាវិជ្ជមាន, ( Caractère positif ), ហើយក៏ពុំមានចំណុះនូវគុណភាពផងដែរ, ដូចតែនិយមន័យទី១ដូច្នោះឯង ។ គាត់បានពោលថា វត្ថុធាតុដើម គឺជាប្រធាន ( sujet ) ដែលរបស់ប្រើប្រាស់អ្វីនិមួយៗ ត្រូវសាងសង់ឡើង យោងតាមឥទ្ធិពលនៃប្រធាននោះ ។ គេនៅតែចង់ដឹងថាតើអ្វីទៅជាប្រធានទី១ដែលមានឥទ្ធិពលសាងសង់ឆ្លាក់ឆ្លៃគ្រឿងរបស់ប្រើប្រាស់ទាំងឡាយ ។

ទស្សនវិទូរដដែលបានបង្ហាត់បង្រៀនថា ដើម្បីសាងសង់រូបកាយមួយនៅក្នុងធម្មជាតិ, វាត្រូវមានលើសពីវត្ថុធាតុដើម, គឺគេត្រូវមានគោលជំហរមួយទៀត ដែលគេហៅថារូបរាងទ្រង់ទ្រាយ ។ អ្នកខ្លះបានយល់ថា រូបរាងទ្រង់ទ្រាយនេះ គឺគ្មានអ្វីផ្សេងពីសភាពខាំគ្នានៃភាគីផ្សេងៗតែប៉ុណ្ណោះ នៅក្នុងរូបមន្តនៃធម្មជាតិ ។ អ្នកខ្លះបានអះអាងថា វាត្រូវតែមានគុណសម្បត្តិសំខាន់អ្វីមួយ ដែលមានលក្ខណៈខុសពីវត្ថុធាតុដើម ,ដែលបណ្តាលឲ្យពេលណាដែលគេកិនស្រូវសាឡីទៅ វាក្លាយទៅជារូបរាងឬសភាពការណ៍សំខាន់មួយទៀត ដែលធ្វើឲ្យស្រូវសាឡីក្លាយទៅជាម្សៅ ។ រួចបន្ទាប់ពីបានយកមកលាយទឹក, ម្សៅដែលគេបានច្របាច់ច្របល់បញ្ចូលគ្នានោះ ក៏បានក្លាយទៅជាដុំប៉ាតេ ( បាយអរ ) ... នៅទីបំផុត នៅពេលដែលគេយកដុំប៉ាតេនោះទៅចំអិន ក៏វាក្លាយទៅជារូបរាងឬសភាពការណ៍មួយថ្មីផ្សេងមួយទៀត ដែលបណ្តាលឲ្យម្សៅប៉ាតេក្លាយទៅជានំបុ័ង ។

អ្នកទាំងអស់គ្នានៅខាងលើបានទទួលស្គាល់ថាមានការប្រែក្លាយសភាពការណ៍ ឬរូបរាងសំខាន់នេះ នៅគ្រប់រូបកាយឯទៀតៗទាំងអស់នៅក្នុងធម្មជាតិ ។ ឧទាហរណ៍ដូចជានៅក្នុងរូបកាយរបស់សត្វសេះ, ក្រៅតែពីឆ្អឹង, សាច់, សរសៃប្រសាទ, ខួរក្បាល, ឈាមដែលហូរតាមសរសៃធំៗទៅចិញ្ចឹមគ្រប់ទីកន្លែងនៃគ្រឿងសារពាង្គ; ហើយក្រៅពីវិញ្ញាណរបស់សត្វដែលជាគោលជំហរញ៉ាំងឲ្យមានកើតចលនា, អ្នកទាំងអស់គ្នានៅខាងលើ (ក្រុមវិនិច្ឆ័យនៅក្នុងសាលារបស់អារីសតូត) បានចាត់ទុកថាមានរូបរាងសំខាន់មួយទៀតរបស់សត្វដែលគេហៅថាព្រលឹង។ អ្នកទាំងអស់គ្នាបានចាត់ទុកថា សភាពការណ៍ឬរូបរាងបែបថ្មីក្រោយនេះ ពុំបានទាញចេញពីវត្ថុធាតុដើមនោះទេ, ក៏ប៉ុន្តែបានទាញចេញពីមហិទ្ធិឫទ្ធ ឬឥទ្ធិពលនៃវត្ថុធាតុដើម របៀបជាអវតាររបស់ព្រះ។ គឺជាសភាពការណ៍សំខាន់ដែលមានអាការៈដាច់ឡែកមែនទែនពីវត្ថុធាតុដើម (គ្មានអ្វីទាក់ទងគ្នាទេ)...គឺពុំមែនជាការប្រែក្លាយ, ប្តូរទ្រង់ទ្រាយអ្វី, ឬពុំមែនជាការប្រែកាឡាពីវត្ថុធាតុដើមនោះផង ។

❑

អារីសតូតបានចាត់ទុកថារូបកាយអ្វីៗក៏ដោយដែលស្ថិតមាននៅលើផែនដីនេះត្រូវប្រគុំឡើងដោយធាតុ៤យ៉ាង ៖ គឺដី, ទឹក, ខ្យល់, ភ្លើង ។ ដីហើយនិងទឹកមានទម្ងន់ធ្ងន់ពីព្រោះមានជំនោរទៅរកមជ្ឈមណ្ឌល(ទីកន្លែងកណ្តាល) នៃពិភពលោក។ ផ្ទុយទៅវិញ ទឹកនិងខ្យល់ចេះតែរសាត់ទៅឆ្ងាយពីមជ្ឈមណ្ឌល...ទៅតាមអំពើដែលវាអាចធ្វើបាន ។ ពីព្រោះរបស់ក្រោយនេះជារបស់ធុនស្រាល ។

ក្រៅពីធាតុទាំង៤នេះ, អារីសតូតបានទទួលស្គាល់ថាមានធាតុទី-៥ មួយទៀត, ដែលប្រគុំឡើងដោយគ្រឿងផ្ទៃអំពរ (មេឃ), ហើយដែលមានចលនាវិលជុំវិញជារង្វង់មូលជានិច្ច។ គាត់បានយល់ថានៅពីលើខ្យល់, ហើយនៅពីក្រោមផ្នែកមួយដែ-លជាសភាពកោងនៃថានព្រះច័ន្ទ, មានថានអគ្គីមួយដ៏ធំធេង ដែលធាតុភ្លើងចេះតែហោះឡើងទៅរក...ប្រហែលគ្នានឹងធាតុទឹកដែលចេះតែហូរទៅរកទីឋានសមុទ្រដូ-ច្នោះឯង ។

⋆- ...អារីសតូតបានបញ្ជាក់ថា វត្ថុធាតុដើមអាចបែងចែកឥតចេះចប់ ហើយថាវត្ថុធាតុទាំងនេះមានសម្បូរពាសពេញសកលលោកយើងទាំងមូល, ហើយគាត់បានបន្ថែមថាគ្មានសភាពអ្វីជាទំនេរ ឬប្រហោងក្នុងទទេនៅក្នុងធម្មជាតិសោះឡើយ ។ គាត់ថាច័ក្រវាលនេះ មានកំណើតជានិច្ចនិរន្តរ៍ ។ ចំណែកថ្ងៃធ្លាប់តែវិលដូច្នេះឯងតាំងពីដើមរៀងមក, ហើយតទៅថ្ងៃមុខទៀត ថ្ងៃនៅតែវិលតាមរបៀបតែមួយ ដោយគ្មានឈប់ឈរ។ រីឯកំណើតរបស់មនុស្សមួយជំនាន់ៗធ្លាប់តែប្រព្រឹត្តកើតឡើងបន្តបន្ទាប់គ្នាតាមរបៀបនេះឯង ដោយគ្មានការចាប់ផ្តើមឡើងពីដំបូងនោះទេ ។ ប្រសិនបើមានមនុស្សខ្លួនមួយតែម្នាក់ឯងពីដំបូងទីពិតមែននោះ, គាត់ពោល, ... បុរសនោះនឹងច្បាស់ជាកើតឡើងដោយគ្មានម៉ែគ្មានឪ; ដែលជារឿងមួយគួរឲ្យអាក្រក់មើលណាស់ ។ គាត់បានធ្វើការវិនិច្ឆ័យត្រិះរិះរបៀបដូច្នេះដែរទៅលើសត្វបក្សា-បក្សី ។ វាមិនអាចមានស៊ុតមួយជាដំបូងដែលឲ្យកំណើតទៅបក្សី, ហើយវាមិនអាចមានបក្សីតែមួយជាដំបូងដែលផ្តល់កំណើតទៅដល់ស៊ុត; ពីព្រោះបក្សីវាចេញពីស៊ុត ចំណែកស៊ុតវិញវាចេញពីបក្សី ។ ហើយគេអាចវិនិច្ឆ័យដោះស្រាយរបៀបដូច្នេះតែដដែលដោយខំប្រឹងឡើងបន្តទៅលើ...ដោយគ្មានគិតរឿងចាប់ផ្តើមនៅពេលណាមួយទេ ។ គាត់ធ្វើការត្រិះរិះតាមរបៀបដដែលនេះ ជាមួយនឹងពូជសត្វផ្សេងៗដែលមាននៅក្នុ-ងច័ក្រវាលនេះ ។

⋆- ... គាត់បានអះអាងថា ផ្ទៃមេឃពុំស្គាល់សភាពពុករលួយទេ ... ហើយថ្វីបើភាគនៅខាងក្រោមព្រះច័ន្ទ ប៉ុន្តែដែលឋិតនៅពីលើផែនដី ( choses sublunaires ៖ អ្វីៗដែលនៅចន្លោះព្រះច័ន្ទនិងផែនដី ) ...អាចស្គាល់សភាពពុករលួយខ្លះៗ ក៏ប៉ុ

ផ្ទៃរបស់អស់ទាំងនេះមិនអាចសាបសូន្យបានឡើយ របស់អស់ទាំងនេះគ្រាន់តែបានផ្លាស់ប្តូរទីកន្លែងតែប៉ុណ្ណោះ ។ កំទេចនៃវត្ថុធាតុអ្វីមួយ វាអាចក្លាយទៅជាវត្ថុធាតុអ្វីមួយផ្សេងទៀត ។ ម្ល៉ោះហើយវត្ថុធាតុ ដែលប្រគុំចក្រវាលទាំងមូល មានឯកភាព ឬនៅមានសភាពតែដដែលជានិច្ចជាកាល ។ អារីសតូតបានអះអាងថា... អ្វីៗដែលមានពាសដោយទឹកសមុទ្រសព្វថ្ងៃ កាលពីដើមគឺជាដីគោក, ... ហើយអ្វីៗដែលមានរូបរាងជាដីគោកសព្វថ្ងៃ កាលពីដើមមានពាសដោយទឹកសមុទ្រ ។ បុព្វហេតុចំបងនៃរឿងនេះ ...គឺបណ្តាលមកពីទឹកជ្រោះ, អូរ, ព្រែកទន្លេ តែងតែហូរនាំយកដីខ្សាច់និងល្បប់ទៅជាមួយ...ម្ល៉ោះហើយឆ្នេរសមុទ្រចេះតែខិតទៅមុខបន្តិចម្តងៗ, ចំណែកទឹកសមុទ្រវិញ ក៏ចេះតែខើចទៅៗផងដែរ ហើយដោយពេលវេលា ចេះតែហូរទៅៗឥតអាក់ដោយគ្មានខ្វះខាត, ការលាតអណ្តាតរបស់ដីចូលក្នុងទឹក ឬក៏ការលាតអណ្តាតរបស់ទឹកចូលក្នុងដីនេះ អាចប្រព្រឹត្តទៅក្នុងរយៈពេលរាប់រយពាន់ឆ្នាំ ។ គាត់បានបន្ថែមថា នៅទីកន្លែងជាច្រើនដែលទឹកសមុទ្រ កាលពីដើមធ្លាប់ខិតទៅលើដី, ដោយមានទីកន្លែងខ្លះមានកំពស់ខ្ពស់ទាល់តែមែនទែន នៅពេលដែលទឹកនេះបានដកថយទៅវិញបានបន្សល់សំបកខ្យងខ្ចៅហូរហែរពាសពេញ មិនត្រឹមតែប៉ុណ្ណោះសោត, ប្រសិនបើគេជីកជំរៅទៅក្នុងដីថែមទៀត ជួនកាលគេអាចរកឃើញយុថ្កានិងគ្រឿងប្រដាប់ខ្លះរបស់នាវាទៀតផង ។ អូវីដ ( Ovide ) បានចាត់ទុកថាការវិនិច្ឆ័យបែបនេះ ជាផែនគំនិតបស់ ពីតាគ័រ ។

ក៏ប៉ុន្តែអារីសតូតបានអះអាងថា , ការប្រែក្លាយរូប ពីទឹកសមុទ្រទៅជាដីគោក ... ហើយពីដីគោកទៅជាទឹកសមុទ្រ បានប្រព្រឹត្តទៅជាច្រើនពាន់ឆ្នាំ, ម្ល៉ោះហើយបានជាវិញ្ញាណរបស់មនុស្សជាតិ មិនបានចងចាំអំពីសភាពការណ៍នៃអតិតកាលអស់ទាំងនេះទេ ។ គាត់បានបន្ថែមលើសពីនេះទៅទៀតថា វាមានគ្រោះថ្នាក់ចៃដន្យខ្លះ ដែលនាំបណ្តាលឲ្យបាត់បង់រហូតទាំងវត្ថុសិល្បៈបុរាណថែមទៀត ដែលមនុស្សបានខំឆ្លាក់ឆ្លៃ ៖ បុព្វហេតុទាំងអស់នេះ គឺជំងឺប៉េស្ត ( ពិស ) , សង្គ្រាម, ការដាច់ពូជ, សភាពរង្គើរផែនដី, អគ្គីភ័យ, ...ឬក៏... សភាពហិនហោចខ្លោចផ្សាអណ្តូរកប្បដ៏ធំសម្បើមមែនទែនដែលធ្វើឲ្យមនុស្សក្នុងដំបន់មួយវិនាសផុតពូជ, ឬពុំនោះសោតទេ មាននៅសល់ប្អូន-ដប់នាក់ ដែលរត់ភៀសខ្លួនទៅរស់នៅក្នុងវាលរហោដ្ឋាន, របៀបជាមនុស្សព្រៃ ។ ហើយក្រុមពួកគេ ក៏បានផ្តល់កំណើតទៅពពួកមនុស្សមួយក្រុមផ្សេងទៀត, ដែលនៅពេលវេលាក្រោយមកក៏បានចាប់ផ្តើមដាំដំណាំធ្វើស្រែចំការ, បង្កើតសិល្បៈថ្មីៗ ឬក៏រកឃើញសិល្បៈចាស់ៗ ។ ម្ល៉ោះហើយ មតិដដែលៗរបស់មនុស្សជាតិក៏បានវិលត្រឡប់មកវិញ, វិលវល់ៗ, ជាច្រើនលើកច្រើនសាររាប់អសង្ខ័យ ( រាប់មិនអស់ ) ។ ដូច្នេះហើយបានជាថាដោយមិនបាច់គិតអំពីសភាពផ្លាស់ប្តូរត្រឡប់ចុះឡើ

ង... និងបដិវត្តន៍រលំរលាយត្រឡប់ធាតុអស់ទាំងនេះទេ, ម៉ាស៊ីននៃចក្រវាលទាំងមូលនៅតែដដែល ឥតមានស្គាល់សភាពពុករលួយ ។

❑

អារីសតូតបានសង្កេតពិចារណាយ៉ាងល្អិតល្អន់ អំពីអ្វីៗដែលអាចបង្កើតឲ្យមានសុភមង្គលចំពោះមនុស្សនៅលើផែនដីនេះ ។ គាត់បានបដិសេធជាទី១ នូវទស្សនៈរបស់ពពួកអ្នកត្រេកត្រអាលក្នុងសេចក្ដីសម្រើបនឹងកាមតណ្ហា ... នឹងសភាពឆ្ងាញ់គ្រប់យ៉ាងនៅក្នុងជីវិត ។ មតិរបស់អ្នកទាំងនោះបានចាត់ទុកថា សុភមង្គលឋិតនៅក្នុងសេចក្ដីសប្បាយនៃខ្លួនប្រាណ ។ អារីសតូតក៏បានផ្ទុញផ្ទាល់ឲ្យអ្នកទាំងនោះវិញថា សេចក្ដីសប្បាយបែបនេះ ពុំឋិតថេរបានយូរឡើយ ... ពីព្រោះការស្រៀវស្រើបវាតែងបង្កើតឲ្យមានការខ្ពើមរអើម ... មិនត្រឹមតែប៉ុណ្ណោះ វាបណ្ដាលឲ្យអង្គកាយទន់ខ្សោយ ... វាបង្កើតឲ្យមានការវង្វេងវង្វាន់នៅក្នុងសតិស្មារតី ... ( កកន ៖ ទ្រឹស្ដីរបស់អារីសតូតនេះចេញពីលទ្ធិព្រះពុទ្ធសាសនា ដែលថ្ងៃក្រោយទៅ នៅសតវត្សរ៍ទី១៩ ទស្សនវិទូអាល្លឺម៉ង់ Schopenhauer បានយកទៅបកស្រាយយ៉ាងពិស្ដារនៅក្នុងសៀវភៅដ៏ល្បីរបស់គាត់ ៖ « The World as Will and Idea ..ពិភពនៃចំណង់របស់សត្វលោក យោងតាមឆន្ទៈនិងគំនិត » )។

⋆ – អារីសតូតក៏បានទាត់ចោលផងដែរ នូវទស្សនៈរបស់ពួកអ្នកលោភលន់និងរបស់ពួកអ្នកមានមហិច្ឆិតា ...ដែលបានកសាងសុភមង្គលនៅពីលើកិត្តិយស ហើយដែលបានប្រើវិធីដ៏អយុត្តិធម៌គ្រប់បែបយ៉ាង ដើម្បីឲ្យតែបានសម្រេចទៅដល់គោលដៅនេះ ។

⋆ – គាត់បានពោលថា កិត្តិយសវាតែងតែឋិតនៅក្នុងតម្លៃអ្វីៗដែលផ្ដល់កិត្តិយស ។ គាត់បានបន្ថែមថា ពួកមនុស្សលោភលន់តែសង្ឃឹមថា នឹងបានទទួលកិត្តិយស ដោយព្រោះតែគុណធម៌ឬគុណសម្បត្តិខ្លះៗ ( ឧទាហរណ៍ ដូចជាសេចក្ដីក្លាហាន, ចំណេះដឹង, សេចក្ដីស្នេហាជាតិ ) ...ដែលពួកគេបង្ខំឲ្យអ្នកផងជឿថាពួកគេមាននៅក្នុងខ្លួន ។ ដូច្នេះបើយោងតាមទស្សនៈរបស់ពួកមនុស្សលោភលន់, សុភមង្គលតែងមានវត្តមាននៅក្នុងគុណធម៌ទៅវិញទេតើ ? ពុំមែននៅក្នុងកិត្តិយសនោះទេ ។ ទោះជាយ៉ាងណាក្ដី ..របស់អស់ទាំងនេះ សុទ្ធសឹងតែនៅខាងក្រៅខ្លួនយើង ។

⋆– នៅទីបំផុត, គាត់បានបដិសេធមតិរបស់ជនកំណាញ់ក្រៅតម្រា...ដែលបានចាត់ទុកថាសេចក្ដីសប្បាយតែងតែមាននៅក្នុងទ្រព្យធន ។ គាត់បានពោលថាទ្រព្យសម្បត្តិមិនមែនជារបស់ល្អពីខ្លួនវានោះឡើយ... ពីព្រោះវាតែងតែធ្វើឲ្យអ្នកត្បិតត្បៀតរក្សាទុកទ្រព្យសម្បត្តិនេះកើតមានសេចក្ដីទុក្ខ ... ហើយចេះតែធ្វើឲ្យព្រួយបារម្ភជា

និច្ចជាកាលមិនហ៊ានយកវាទៅប្រើប្រាស់ ។ ដើម្បីឲ្យទ្រព្យសម្បត្តិមានប្រយោជន៍ គេត្រូវយកវាទៅប្រើប្រាស់, ត្រូវយកទៅចែកចាយដល់គេឯងឲ្យរបូតចេញពីដៃរបស់ខ្លួនយើង ...ចំណែកសុភមង្គលវិញជារបស់នឹងន៎... ដែលគេត្រូវតែខំប្រឹងរក្សាវាទុកឲ្យគង់វង់ ។

☆ – នៅចុងចប់ទៅ, ទស្សនៈផ្ទាល់របស់អារីសតូតបានចាត់ទុកថា សុភមង្គលឋិតនៅក្នុងសកម្មភាព ដែលសមស្របជាទីបំផុតជាមួយនឹងវិចារណញ្ញាណរបស់យើង... ហើយនិងការប្រព្រឹត្តអ្វីៗឲ្យត្រូវនឹងគោលជំហរនៃគុណធ៌ម ។ គាត់បានអះអាងថាសកម្មភាពថ្លៃថ្នូរជាទីបំផុតនៃវិចារណញ្ញាណរបស់យើង គឺស្ថិតនៅក្នុងការស្រាវជ្រាវនិងសកម្មភាពបែកប្រាជ្ញានៅក្នុងរឿងធម្មជាតិ, រឿងមេឃ, រឿងផ្កាយ, រឿងអ្វីៗដែលនៅក្នុងធម្មជាតិទាំងមូលហើយជាពិសេស គឺវត្ថុសក្តិសិទ្ធដែលជាកំណើតដំបូងនៃធម្មជាតិ ។ ទោះជាយ៉ាងនេះក្តី ...គាត់បានសង្កេតឃើញថា មនុស្សយើងមិនអាចមានសេចក្តីសប្បាយពេញលេញសោះឡើយ... បើយើងពុំមានទ្រព្យធនគ្រប់គ្រាន់សំរាប់ថានៈរបស់យើង, ពីព្រោះថាបើគ្មានទ្រព្យសម្បត្តិទាំងនេះទេ ...គេមិនមានលទ្ធភាពធ្វើអ្វីៗដែលគេចូលចិត្ត, ព្រមទាំងមិនអាចអនុវត្តន៍អ្វីៗទៅតាមគោលជំហរនៃសីលធ៌មបានឡើយ ។ ជាឧទាហរណ៍ គេមិនអាចធ្វើឲ្យមិត្តភ័ក្តិរបស់គេមានសេចក្តីសប្បាយរីករាយក្នុងចិត្តបានសោះឡើយ ...ឧបមាបើគេជាមនុស្សក្រីក្ររហេមរហាមរស់នៅក្នុងសេចក្តីខ្វះខាត ...ពីព្រោះថានៅលើលោកនេះ សេចក្តីសប្បាយរីករាយក្នុងជីវិត គឺលទ្ធភាពធ្វើអំពើល្អចំពោះមនុស្សដែលយើងស្រឡាញ់, ម្ល៉ោះហើយសុភមង្គលត្រូវមានវត្ថុបីយ៉ាងជាមូលដ្ឋាន ៖ គុណសម្បត្តិនៃសតិស្មារតីដូចជាបញ្ញាញាណ និងការចេះប្រុងប្រយ័ត្ន ; គុណសម្បត្តិនៅក្នុងរូបកាយ ដូចជាសោភ័ណភាព, រូបសម្រស់, កម្លាំងកំហែង, សុខភាព ; គុណសម្បតិនៅក្នុងភព្វវាសនា ដូចជាទ្រព្យសម្បត្តិហើយនិងបុណ្យសក្តិ ។ គាត់យល់ថា សីលធ៌មជារបស់មិនគ្រប់គ្រាន់ដើម្បីធ្វើឲ្យមនុស្សមានសុភមង្គលនោះឡើយ ៖ គេត្រូវការដាច់ខាតមានគុណសម្បត្តិក្នុងអង្គកាយ ហើយនិងទ្រព្យសម្បត្តិក្រៅខ្លួន, ហើយបើទោះជាអ្នកប្រាជ្ញក៏ត្រូវមានទុក្ខដែរ ...បើគេខ្វះទ្រព្យសម្បត្តិអស់ទាំងនេះ ។ ក៏ប៉ុន្តែគាត់បានបញ្ជាក់ថា ជីវិតអបាយមុខតែងតែនាំឲ្យមនុស្សមានទុក្ខទោសដោយចៀសមិនរួច... ហើយបើទោះជាមនុស្សម្នាក់រស់នៅក្នុងសភាពសម្បូរណ៍សប្បាយយ៉ាងណាក្តី, មនុស្សនេះមិនអាចស្គាល់សុភមង្គលសោះឡើយ... ប្រសិនបើខ្លួនគេបណ្តោយឲ្យធ្លាក់ខ្លួនចូលក្នុងជីវិតអបាយមុខ ។ អ្នកប្រាជ្ញក៏មិនអាចចៀសវាងរួចពីជីវិតស្រើបស្រាលបានដែរ គ្រាន់តែអ្នកប្រាជ្ញអាចចេះទប់ខ្លួនបានមួយភាគ ។ ទោះជាយ៉ាងណាក្តី, អបាយមុខហើយនិងគុណធ៌មមិនមែនជារបស់ពីរដែលមិនអាចចុះសម្រុងនឹងគ្នា

បាននោះទេ ។ គាត់ពោលជាឧទាហរណ៍ថា មនុស្សតែម្នាក់... អាចជាមនុស្សមានយុត្តិធម៌ផង... អាចចេះទប់ខ្លួនប្រាណ, ចេះប្រុងប្រយ័ត្នផង.. ក៏ប៉ុន្តែជាមនុស្សដែលអាចមានសេចក្តីស្រើបស្រាលយ៉ាងខ្លាំងផងដែរ។

⋆– គាត់បានទទួលស្គាល់ថា មានមិត្តភាពបីសណ្ឋាន ៖ មិត្តភាពទី១ ដែលបានមកដោយសារតែការជាប់សាច់ឈាម; មិត្តភាពទី២ ... គឺមានដើមកំណើតពីសេចក្តីស្រឡាញ់; មិត្តភាពទី៣... គឺបានមកពីសេចក្តីស្វាគមន៍និងសភាពរាក់ទាក់ទទួលភ្ញៀវ ។

⋆– គាត់មានជំនឿថា អក្សរសាស្ត្រជាមធ្យោបាយជួយមនុស្សជាតិឲ្យប្រឹងប្រែងឱបក្រសោបយកគុណធម៌ ។ គាត់បានបញ្ជាក់ថាអក្សរសាស្ត្រគឺជាវត្ថុសក្តិសិទ្ធជាងគេ ដែលជួយលួងលោមមនុស្សនៅក្នុងវ័យចាស់ជរា ។

⋆– គាត់បានទទួលស្គាល់ដូចជាប្លាតុងផងដែរ ... ថាមានវត្ថុមាននៃវត្ថុសក្តិសិទ្ធិទី១ ...ជាដើមចមដែលបង្កើតឡើងឲ្យមានវាលវដ្តសង្សារនិងព្រេងវាសនារបស់មនុស្សជាតិ ។

⋆– គាត់ជឿថា គំនិតនិងមនោសញ្ចេតនារបស់មនុស្សយើងទាំងអស់ គឺតែងកើតចេញឡើងពីវិញ្ញាណ ...យ៉ាងណាមិញមនុស្សដែលខ្វាក់ពីកំណើត... មិនអាចស្គាល់រូបរាងទ្រង់ទ្រាយនៃពិភពលោកបានទេ, ចំណែកមនុស្សថ្លង់ពីកំណើត ក៏មិនអាចដឹងពីភិនភាគនៃសម្លេងយ៉ាងដូចម្តេចដែរ ។

⋆– គាត់បានទទួលស្គាល់ថា នៅក្នុងបញ្ហានយោបាយរបស់រដ្ឋ, របៀបគ្រប់គ្រងជារាជានិយម ជារដ្ឋាភិបាលដ៏ល្អប្រសើរជាងគេបំផុត, គឺដោយហេតុថា នៅក្នុងការគ្រប់គ្រងតាមរបៀបផ្សេងៗទៀត, មានមនុស្សច្រើនពេក ដែលតណ្តើមគ្នាធ្វើជាអ្នកគ្រប់គ្រង ។ ក្នុងរឿងនេះ ក៏ដូចក្នុងកងទ័ព ដែលដឹកនាំដោយមេដ៏ល្អតែម្នាក់ ច្រើនតែមានជោគជ័យជាងកងទ័ព ដែទទួលបញ្ជារពីមេកើយច្រើនគ្នា, ហើយក្នុងការដឹកនាំរដ្ឋក៏មានលំនាំដូច្នេះដែរ ។ នៅក្នុងពេលដែលពួកតំណាងរាស្ត្រនិងពួកមនុស្សសំខាន់ៗនៅក្នុងសាធារណរដ្ឋ តែងតែធ្វើការរួមប្រជុំគ្នាដើម្បីសម្រេចសេចក្តី, ក្នុងពេលលនោះស្តេចតែមួយអង្គបានវាតយកទីកន្លែងអស់រួចស្រេចទៅហើយ ៗ កំពុងតែរៀបចំប្រុងប្រៀបអនុវត្តន៍គំរោងការណ៍របស់ទ្រង់ ។ ពួកអ្នកគ្រប់គ្រងសា–ធារណរដ្ឋមិនបានរវីរវល់ក្នុងការបំផ្លិចបំផ្លាញរដ្ឋរបស់ខ្លួនឯងនោះទេ នៅពេលណាដែលពួកគេបានទទួលសេចក្តីចម្រុងចម្រើនមានបានដោយខ្លួនឯង ។ ពួកគេច្រើនតែមានមនោសញ្ចេតនាច្រណែននិន្ទាគ្នាឯងទៅវិញទៅមក ...ម្ល៉ោះហើយរឿងនេះក៏បង្កើតឲ្យមានការបែកបាក់ ... ហើយនៅទីបំផុតទៅ សាធារណរដ្ឋក៏ចៀសមិនរួចពីគេផ្តួលព្រលំបាន ។ ចំណែកនៅក្នុងរបបរាជានិយមវិញ, ស្តេចពុំមានផលប្រយោ–

ជន៍អ្វីក្រៅតែពីផលប្រយោជន៍នៃរដ្ឋរបស់ទ្រង់ ៖ ម៉្លោះហើយរដ្ឋរបស់ទ្រង់តែងតែមានការចម្រុងចម្រើនល្អតលាស់ទៅមុខជានិច្ច។

⋆- ថ្ងៃមួយ គេបានសួរអារីសតូតថា តើពួកមនុស្សភរភូតបានចំណេញអ្វីទៅ ។ គាត់បានឆ្លើយថា ៖ « ពួកនេះចំណេញត្រង់ថ្ងៃណាមួយអ្នកផងលែងជឿពួកគេប៉ុ-ណ្ណោះ... បើទោះជានៅក្នុងកាលៈទេសៈមួយដែលគេនិយាយការពិតក៏ដោយ » ។

⋆- មានជនម្នាក់បានបន្ទោសដល់គាត់ថា គាត់បានដាក់ទានដល់មនុស្សម្នាក់ដែលជាបុគ្គលកំណាចមានចិត្តអាក្រក់ ។ អារីសតូតបានឆ្លើយថា ៖ « ខ្ញុំមិនមែនមានការអាណិតពីព្រោះជននេះ ជាមនុស្សចិត្តអាក្រក់នោះទេ...ខ្ញុំមានការអាណិតអាសូរពីព្រោះវាជាមនុស្ស ។

⋆- គាត់តែងនិយាយជាធម្មតាដល់មិត្តភក្តិ និងដល់ពួកសាវ័ករបស់គាត់ថាវិទ្យាសាស្ត្រមាននាទីសំរាប់ព្រលឹងមនុស្ស ក៏ដូចជាពន្លឺសម្រាប់កែវភ្នែកដូច្នោះដែរ.. ហើយប្រសិនបើខាងឫសគល់មានជាតិល្វីង ...ក៏ប៉ុន្តែលទ្ធផលផ្លែផ្កាខាងចុង ជារង្វាន់មានរសជាតិផ្អែមល្អណាស់ ។

⋆- មានពេលខ្លះ, គាត់មានកំហឹងយ៉ាងខ្លាំង និងពួកជនជាតិអាត្វែន ... ។ គាត់បានស្តីបន្ទោសឲ្យពួកនេះថា...ពួកគេបានរកឃើញស្រូវសាលី ហើយនិងច្បាប់ ... ក៏ប៉ុន្តែគេប្រើប្រាស់តែស្រូវសាលី ...មិនបានប្រើប្រាស់ច្បាប់ទេ ។

⋆- ថ្ងៃមួយគេបានសួរគាត់ថា តើអ្វីទៅដែលអាចរលប់រលាយទៅវិញឆាប់ជាងគេ ? គឺសេចក្តីដឹងគុណ, គាត់បានឆ្លើយ ។

⋆- តើអ្វីទៅជាសេចក្តីសង្ឃឹម ? គឺជាការយល់សប្តិយល់សូងរបស់មនុស្សម្នាក់ដែលមិនដេក, គាត់ពោល ។

⋆- ថ្ងៃមួយ ឌីយ៉ូហ្សែនបានបង្ហាញផ្លែជ្រៃមួយដល់អារីសតូត ។ ដោយយល់ឃើញថា បើគាត់មិនទទួលយកផ្លែជ្រៃទេ...ឌីយ៉ូហ្សែនច្បាស់ជាមានរឿងសើចចំអកឲ្យគាត់ជាមិនខាន គាត់ក៏ទទួលយកផ្លែជ្រៃ ព្រមទាំងពោលដោយសើចផងថា ៖ « ឌីយ៉ូហ្សែន បានបាត់បង់ផ្លែជ្រៃ ...ព្រមទាំងបានបាត់បង់គំរោងការណ៍ដែលគាត់ចង់អនុវត្តន៍ជាមួយផ្លែជ្រៃ » ។

⋆- អារីសតូតបានពោលថា មានការចំបាច់សំខាន់បីយ៉ាងសម្រាប់ក្មេង គឺការហ្វឹកហ្វឺនប្រាជ្ញា, ការហាត់ប្រាណហើយនិងវិន័យ ។

⋆- នៅពេលដែលគេសួរគាត់ថា តើមានរឿងអ្វីខុសគ្នាទៅ រវាងអ្នកប្រាជ្ញហើយនិងជនល្ងង់ខ្លៅ ។ គាត់បានឆ្លើយថា ..ខុសគ្នាដូចតែពួកមនុស្សរស់ហើយនិងពួកមនុស្សស្លាប់ ។

⋆- គាត់បានពោលថា វិទ្យាសាស្ត្រ គឺជាគ្រឿងលំអសម្រាប់សភាពសម្បូរសប្បា

យ ..និងជាទីជម្រកសម្រាប់ជីវិតដែលជួបប្រទះនឹងសេចក្តីអភ័ព្វ ។ គាត់បានបន្ថែមថា ជនណាដែលបានផ្តល់ការអប់រំដល់ក្មេង ..ត្រូវចាត់ទុកថាជាឪពុករបស់ក្មេងនោះជាងជនដែលជាអ្នកបានបង្កើតវា„ ពីព្រោះជនក្រោយនេះ គ្រាន់តែបានផ្តល់ត្រឹមជីវិតប៉ុណ្ណោះ... ចំណែកអ្នកដែលបានបង្ហាត់បង្រៀនវា... គឺបានផ្តល់ក្បួនរស់នៅដោយសុខសប្បាយចំពោះរូបវា ។

⋆- សម្រស់ឬសោភ័ណភាពរូបកាយ ..មានលក្ខណៈសំខាន់ជាងលិខិតផ្តាំផ្ញើអ្វីៗទាំងអស់ ។

⋆- ថ្ងៃមួយ ជនម្នាក់បានសួរគាត់ថា តើក្រុមពួកសាវ័ករបស់គាត់ត្រូវធ្វើយ៉ាងណា ដើម្បីទាញយកភោគផលចំណេញឲ្យបានច្រើនជាទីបំផុត ។ ពួកគេត្រូវតែ, គាត់ពោល , ខំប្រឹងប្រែងដើរឲ្យបានទាន់ពួកអ្នកនៅជួរមុខគេ , មិនមែននៅរង់ចាំឲ្យពួកជួរខាងក្រោយមកទាន់ខ្លួនគេនោះឡើយ ។

⋆- បុរសម្នាក់បានអួតអាងថា ខ្លួនគេមានសញ្ជាតិជាពលរដ្ឋនៃទីក្រុងដ៏ធំជាងគេទាំងអស់ ។

« រឿងនេះមិនសំខាន់ទេ, អារីសតូតបានឆ្លើយតបទៅជននេះវិញ, ត្រូវគិតថាតើឯងបានធ្វើអ្វីខ្លះ ដើម្បីឲ្យបានសមសក្តិធ្វើជាសមាជិកនៃមាតុភូមិដ៏ល្បីល្បាញខ្ទរខ្ទារនោះ » ។ ( កកន ៖ គឺពាក្យឃ្លាចុងក្រោយនេះហើយ ដែលលោកប្រធានាធិបតីកេណ្ណឺឌីបានយកទៅសម្រួចសម្រាំងរូបមន្ត-សុភាសិតរបស់លោកដូច្នេះថា ៖ « ចូរឯងកុំសួរថា តើប្រជាជាតិរបស់ឯងបានធ្វើអ្វីខ្លះចំពោះឯង ... ចូរឯងសួរថា តើឯងបានធ្វើអ្វីខ្លះចំពោះប្រជាជាតិរបស់ឯង ! » ) ។

⋆- នៅពេលដែលគាត់ត្រិះរិះពិចារណា អំពីជីវិតសត្វលោក, គាត់តែងតែនិយាយដូច្នេះថា ៖ « វាមានពួកមនុស្សខ្លះដែលខំកើបប្រមូលទ្រព្យសម្បត្តិជាខ្លាំងហាក់ដូចជាពួកគេនោះអាចរស់នៅជានិច្ចនិរន្តរ៍ជាអមតៈ, ចំណែកពួកអ្នកខ្លះទៀតចេះតែពីចាយវាយទ្រព្យសម្បត្តិដោយឥតបើគិត.. ហាក់ដូចជាគេរស់បានត្រឹមតែដល់ថ្ងៃស្អែកតែប៉ុណ្ណោះឯង ។

⋆- នៅពេលដែលគេសួរគាត់ថា តើអ្វីទៅជាមិត្តភ័ក្តិ, គាត់បានឆ្លើយថា ៖ « គឺជាព្រលឹងតែមួយ,តែនៅក្នុងរូបកាយខុសគ្នា » ។

⋆- ថ្ងៃមួយបុរសម្នាក់បានពោលមកកាន់គាត់ដូច្នេះថា ៖ « តើយើងត្រូវមានអាកប្បកិរិយាបែបណាចំពោះមិត្តភ័ក្តិរបស់យើង ។ « គឺ, អារីសតូតឆ្លើយ, ទៅតាមបែបបទមួយដែលយើងចង់ឲ្យគេធ្វើមកចំពោះយើងវិញដូច្នោះដែរ » ។

⋆- គាត់បានស្រែកឧទានជាញឹកញាប់យ៉ាងដូច្នេះថា ៖ « ឱ! មិត្តសម្លាញ់ទាំងឡាយអើយ ! នៅលើលោកនេះ គ្មានទេមិត្តសំឡាញ់ » ។

⋆- ជនម្នាក់បានសួរគាត់ថា ហេតុអ្វីបានជាយើងចូលចិត្តស្រឡាញ់ស្រីរូបស្អាត ... ចំណែកស្រីរូបអាក្រក់យើងមិនដែលស្រឡាញ់សោះឡើយ ។ អារីសតូតបានឆ្លើយតបវិញថា ៖ « ឯងកំពុងតែចោទសួរ នូវសំនួររបស់មនុស្សខ្វាក់ » ។

⋆- នៅពេលដែលគេសួរគាត់ថា តើគាត់បានទាញផលចំណេញអ្វីខ្លះទៅអំពីទស្សនវិជ្ជារបស់គាត់ ៖ « គឺ, អារីសតូតពោល, លទ្ធភាពដែលខ្ញុំអាចធ្វើអ្វីៗពីចិត្តខ្លួនឯង នៅពេលដែលអ្នកឯទៀតៗធ្វើដោយសារតែការកោតក្រែងនៃច្បាប់ » ។

.. គេបាននិយាយថា នៅពេលដែលគាត់បានសំណាក់នៅក្នុងទីក្រុងអាតែ្មន, គាត់មានការទាក់ទងយ៉ាងជិតដឹតជាមួយនឹងមនុស្សប៉ិនប្រសប់ម្នាក់ ចេះមន្តស្នេហ៍មកពីយូដេ , ហើយដែលបានបង្ហាត់បង្រៀនគាត់ដល់ទីជម្រៅអំពីវិទ្យាសាស្រ្ត និងសាសនារបស់ពួកជនជាតិអេយីព្ទ , ជាពិសេសអំពីចំណោះដឹងទាំងឡាយដែលកាលសម័យនោះ អ្នកផងតែធ្វើដំណើរត្រេចចរដោយខ្លួនឯងទៅឱបក្រសោបយកពីក្នុងទឹកដីនៃប្រទេសអេយីព្ទដោយផ្ទាល់ ។

អារីសតូត បន្ទាប់ពីបានបង្ហាត់បង្រៀនចំនួន១៣ឆ្នាំ នៅក្នុងវិទ្យាល័យរបស់គាត់ ... ហើយនៅក្នុងពេលដែលគាត់កំពុងតែបានទទួលកេរ្តិ៍ឈ្មោះ ដ៏ល្បីសុះសាយជាទីបំផុត ក៏ស្រាប់តែបាត្រូវទទួលការចោទប្រកាន់ផងដែរថាជាជនមិនជឿព្រះ (ទមិឡឥតសាសនា ) ពីសំណាក់អេរីមើដុង ដែលជាព្រះសង្ឃម្នាក់របស់ព្រះសេរ៉េស ។

ការនឹករឭកឃើញអំពីទុក្ខទោសទណ្ឌកម្មរបស់សូក្រាត បានធ្វើឲ្យគាត់មានសេចក្តីភិតភ័យតក្កម្មារហូតដល់គាត់បានសម្រេចរត់ចេញយ៉ាងប្រញាប់ពីទីក្រុងអាតែ្មន។ គាត់ក៏បានថយខ្លួនទៅរស់នៅម្តុំ កាល់ស៊ី-ដឺបេ ( Chalcis d'Eubée ) ។ ពួកក្រុមមនុស្សមួយភាគបានពោលថា អារីសតូតបានទទួលសេចក្តីស្លាប់ ដោយហេតុតែសេចក្តីតូចចិត្តហួរហួងពីព្រោះគាត់មើលអាថ៌កំបាំងមិនធ្លុះអំពីទឹកជោរ និងទឹកនាចនៃសមុទ្រអឺរីព ។ អ្នកខ្លះទៀតបានពោលថា គាត់បានលោតសំយុងខ្លួនទៅក្នុងសមុទ្រនេះ, ហើយនៅពេលដែលគាត់កំពុងតែធ្លាក់ទៅ គាត់បានស្រែកថា ៖ « សូមឲ្យអឺរីពស្រូបយករូបខ្ញុំទៅចុះ, ពីព្រោះខ្ញុំមិនអាចយល់បានអំពីជំរៅអាថ៌កំបាំងនៃមហាគង្ហារនេះឡើយ ។ នៅទីបំផុត, មនុស្សខ្លះទៀតបានបញ្ជាក់ថាគាត់បានស្លាប់ទៅដោយសារជម្ងឺចុកពោះ, នៅក្នុងជន្មាយុ៦៣ឆ្នាំ, គឺពីរឆ្នាំបន្ទាប់ពីមរណៈភាពរបស់ស្តេចអាឡេចសង់ ដែលត្រូវជាសាវ័ករបស់គាត់ ។

ប្រជាជននៅស្រុកស្តាយៀរបានសង់ទីកន្លែងអាសនៈបង់ស្រន់ សំរាប់រូបគាត់ ... ហាក់ដូចជាគាត់នោះជាព្រះអាទិទេព ។

អារីសតូតបានទុកសេចក្តីបណ្តាំមួយ ដែលមានឈ្មោះអង់ទីប៉ាទែរ ជាអ្នកអនុវត្តឆន្ទៈចុងក្រោយរបស់គាត់ ។

គាត់បានបន្សល់បុត្រម្នាក់ឈ្មោះនីកូម៉ាគុស, និងបុត្រីម្នាក់ទៀតដែលបានទទួលរៀបអាពាហ៍ពិពាហ៍ ជាមួយនឹងចៅរបស់ដេម៉ារ៉ាទុស, ស្តេចនៅឡាសេដេម៉ូន ៕

❑ ❑

❑

# ជីវិតរបស់ប៊ីយ៉ុង
## BION

* – គាត់ត្រូវជាសាវ័ករបស់តេអូហ្វាស្រ្ត ដែលបានបន្តកិច្ចការពីអារីសតូត នៅក្នុងសាលាប៉េរីប៉ាតេទីក, នៅក្នុងអូឡាំព្យ៉ាដទី១១៤ ។

❑

ទស្សនវិទូប៊ីយ៉ុងបានធ្វើការសិក្សាអស់រយៈពេលវេលាដ៏យូរ នៅក្នុងបណ្ឌិតសភាដែលជាមរតកវប្បធ៌មរបស់ប្លាតុង ។ សាលានេះបានធ្វើឲ្យគាត់ទាស់ចិត្តជាខ្លាំង ។ គាត់មាក់ងាយពួកអ្នកស្វែងរកបុណ្យសក្តិនិងកិត្តិយសនៅទីនោះ... ម៉្លោះហើយគាត់តែងធ្វើការចំអកដល់ពួកអ្នកទាំងនេះជារៀងរាល់ថ្ងៃ ។ ថ្ងៃមួយ, គាត់ក៏បានចាកចេញពីសាលានេះតែម្តង ។ គាត់បានយកជាប់ជាមួយនឹងខ្លួននូវអាវម៉ង់តូមួយ, ដំបងមួយនិងថង់យាមមួយហើយក៏បានសម្រេចទៅចូលក្នុងបក្សសីនីកវិញ ។ ក៏ប៉ុន្តែនៅទីនោះក៏គាត់មិនបានសមប្រកបមួយនឹងនរណាដែរ ... ។ នៅក្នុងសាលាថ្មីដ៏តឹងរ៉ឹងនេះ, គាត់បានប្រលោមជីវភាពរស់នៅរបស់គាត់ដោយយកទ្រឹស្តីរបស់តេអូឌរដែលត្រូវជាសាវ័ករបស់អារីសទីព នៃសាលាសីរេណាអ៊ីកមកអនុវត្តបន្ធូរបន្ថយសភាពល្វីងជូរចត់ ។ នៅទីបំផុតគាត់ក៏បានស្វែងទៅសិក្សានៅក្រោមការដឹកនាំរបស់តេអូហ្វាស្រ្ត ។

ប៊ីយ៉ុងមានបញ្ញាឈ្លាសវៃពន់ពេកណាស់, គាត់ជាអ្នកប៉ិនប្រសប់ខាងដោះស្រាយបញ្ហាចំណោទ្យគ្រប់យ៉ាង ។ គាត់ពូកែខាងសរសេរកំណាព្យ ហើយនិងលេងភ្លេង, ហើយមានទេព្យកោសល្យដ៏កម្រកបានខាងផ្នែកវិជ្ជារេខាគណិត។ គាត់ចូលចិត្តបរិភោគម្ហូបឆ្ងាញ់ ហើយមានជីវភាពរស់នៅលង់ខ្លួនយ៉ាងជ្រៅទៅក្នុងអំពើអបាយមុខ ។ គាត់មិនដែលសំណាក់នៅទីកន្លែងណាមួយបានយូរអង្វែងទេ, គាត់ច្រើនតែដើរផ្សងពីភូមិមួយទៅភូមិមួយព្រមទាំងបានចូលទៅរួមនៅគ្រប់ទីកន្លែងទាំងអស់ណាដែលមានពិធីរជប់លាង ។ នៅទីនោះ, គាត់មានភារកិច្ចធ្វើឲ្យអ្នកផងសើចសប្បាយ និងធ្វើឲ្យពួកគេស្ងើចសរសើរអំពីបញ្ញាញាណវាងវៃរបស់គាត់ ។ ដោយគាត់មាននិស្ស័យគួរឲ្យគេចូលចិត្ត...មនុស្សម្នាក់ៗតែងតែមានការត្រេកត្រអាលក្នុងការស្តាប់ពាក្យសំដីរបស់គាត់ ហើយតែងប្រុងប្រៀប

ផ្តល់អាហារភោក្តាដល់គាត់ជានិច្ចជាកាល ។

ថ្ងៃមួយ, ប៊ីយ៉ុងបានដឹងថាមានមនុស្សដែលជាសត្រូវរបស់គាត់បានទៅទូលស្តេចអង់ទីគ្នោនុស្សអំពីដើមកំណើតដ៏ថោកទាបរបស់គាត់ ។ គាត់មិនបានយកចិត្តទុកដាក់អំពីរឿងនេះទេ... មិនត្រឹមតែប៉ុណ្ណោះគាត់មានឫកពារហាក់ដូចជាមិនបានដឹងមិនបានឮពីអ្វីទាំងអស់ ។ ស្តេចអង់ទីគ្នោនុស្សក៏បានបញ្ជូនមនុស្សឲ្យទៅកោះហៅប៊ីយ៉ុងឲ្យមកចូលគាល់ ដោយនឹកស្មានថាមានឱកាសធ្វើឲ្យជននេះបានទទួលសេចក្តីអាមាស់ ។ នៅពេលដែលប៊ីយ៉ុងមកដល់ ស្តេចក៏មានបន្ទូលថា ៖

– តើឯងអធិប្បាយប្រាប់អញបន្តិចមើល, ឯងឈ្មោះអី ? មកពីស្រុកណា ? តើដើមកំណើតរបស់ឯងមានលក្ខណៈយ៉ាងដូចម្តេចខ្លះដែរ ? តើឪពុកម្តាយរបស់ឯងបានប្រកបមុខរបរអ្វីខ្លះ ?

ប៊ីយ៉ុងពុំមានសេចក្តីភ្ញាក់ផ្អើលសោះឡើយនៅក្នុងរឿងសំនួរនេះ ។

– ឪពុករបស់ខ្ញុំ, គាត់ពោល, បានត្រូវលោះពីថានៈខ្ញុំកញ្ជះគេ, រួចបន្ទាប់មកគាត់បានប្រកបជីវភាពលក់ខ្លាញ់និងបើរប្រៃ ។ ខ្ញុំមិនបានដឹងថាគាត់មានរូបរាងស្អាតបាតឬក៏អាក្រក់អាក្រីបែបណាទេកាលពីដើម, ពីព្រោះមុខមាត់របស់គាត់បានត្រូវកំពៀចវៀចវ៉ៃ ដោយសារតែចៅហ្វាយនាយរបស់គាត់បានវាយដំច្រំផាក់ ។ គាត់មានសញ្ជាតិជាស៊ីត ហើយមានដើមកំណើតនៅមាត់សមុទ្របូរីសត្ថែន ។ គាត់បានជួបម្តាយខ្ញុំនៅទីកន្លែងសាធារណៈមួយ ...។ គឺនៅទីនោះហើយដែលអ្នកទាំងពីរបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ។ នៅទីបញ្ចប់, ខ្ញុំពុំបានដឹងថាឪពុកខ្ញុំបានប្រព្រឹត្តអំពើឧក្រិដ្ឋអ្វីមួយទេ... ដែលជាហេតុបណ្តាលឲ្យគេយកគាត់ទៅលក់ជាមួយនឹងប្រពន្ធកូនទាំងអស់គ្នា ។ ខ្ញុំនៅចាំថាកាលនោះខ្ញុំជាកុមារម្នាក់មានរូបរាងស្រស់ស្អាតបាត ហើយវាគ្មិនម្នាក់ក៏បានទិញយករូបខ្ញុំទៅ... គាត់នេះបានទុកសម្បត្តិទ្រព្យឲ្យខ្ញុំទាំងអស់មុននឹងគាត់ស្លាប់ទៅ ។ ខ្ញុំក៏បានហែកសំបុត្រផ្ទេរមរតករបស់គាត់ចោលទៅក្នុងភ្លើងទាំងអស់... ហើយបានថយមករស់នៅទីក្រុងអាត្ហែន...ដែលនៅទីនោះខ្ញុំបានខំប្រឹងរៀនសូត្រអំពីទស្សនវិជ្ជា ។ ក្នុងពេលនេះ, អ្នកឯងបានដឹងច្បាស់ប្រាកដរួចហើយអំពីឈ្មោះខ្ញុំ, ប្រទេសរបស់ខ្ញុំ, ឪពុករបស់ខ្ញុំ, ហើយនិងអំពីដើមកំណើតរបស់ខ្ញុំទាំងមូល... គឺដឹងប្រហែលតែនឹងខ្ញុំដែរ ។ រឿងដែលខ្ញុំមានសមត្ថភាពដឹងពីខ្លួនឯងមានតែប៉ុណ្ណោះទេ ។ ពែរសេហើយនិងហ្វីឡូនីដ ...ក៏មិនបាច់ខាតពេលធ្វើការថែមថយឲ្យអ្នកបានសប្បាយចិត្តនោះផងដែរ ។

សម័យថ្ងៃមួយគេបានសួរទៅប៊ីយ៉ុងថា តើមនុស្សប្រភេទណាដែលមានសេចក្តីទុក្ខវេទនារលើសអំពីអ្នកផង ។

– គឺ, គាត់ពោលឆ្លើយតបវិញ, ជនដែលមានគោលប្រាថ្នាដ៏ខ្លាំងក្លាជាទីបំផុត រស់នៅឲ្យបានសប្បាយ ក្នុងជីវិតមួយដ៏សុខស្រួលគ្មានផលរមាស់អ្វីទាំងអស់ ។

គាត់បានពោលថាជរាភាពជាកំពង់ផែនៃសេចក្ដីទុក្ខលំបាក, គឺនៅទីនោះហើយ ដែលរឿងអភ័ព្វចេះតែធ្លាក់មកដល់ផ្ទួនៗគ្នា ។ គេត្រូវរាប់ឆ្នាំនៃជីវិតរបស់គេ តែចំពោះខែឆ្នាំណាដែលទាក់ទងនឹងសេចក្ដីរុងរឿងដែលគេបានកសាងនៅលើពិភពលោកនេះ ។ សោភ័ណភាពជារបស់មួយឯករាជ្យពីខ្លួនយើង ...ពោលជាអ្វីៗដែលមិនទាក់ទងជាមួយខ្លួនយើងទេ, ចំណែកទ្រព្យសម្បត្តិវិញគឺជាចំណាងល័ក្ខណ្ឌចាំបាច់សម្រាប់កិច្ចការធំៗទាំងអស់... ដោយហេតុថាបើឥតទ្រព្យសម្បត្តិហើយ គ្មាននរណាធ្វើអ្វីកើតទេ បើទោះជាគេមានទេពកោសល្យយ៉ាងណាក៏ដោយ ។

ថ្ងៃមួយ, គាត់បានជួបប្រទះយុវជនម្នាក់ដែលបានចាយវាយបំផ្លិចបំផ្លាញទ្រព្យសម្បត្តិរបស់ខ្លួនអស់រលីង ។ គាត់ក៏បានពោលទៅកាន់យុវជនម្នាក់នេះថា ៖ « ព្រះធរណីបានស្រូបយកជនឈ្មោះអម់ហ្វីយ៉ារ៉ូស ...ចំណែករូបឯងវិញ, ឯងបានស្រូបលេបព្រះធរណីយកទៅបាត់ ! » ។

ជនសង្ការម្នាក់ដែលមានសំដីខ្ពស់និងបុកពារក្រអឺតក្រទម បានពោលប្រាប់គាត់ថា ខ្លួនគេមានគោលបំណងសុំឲ្យគាត់បំពេញកិច្ចការអ្វីមួយ ៖ « អញនឹងធ្វើអ្វីៗទាំងអស់តាមគោលប្រាថ្នារបស់ឯង, ប៉ីយ៉ុងពោលតបវិញ, ឲ្យតែឯងបញ្ជូនមនុស្សមកប្រាប់អញថាតើឯងចង់បានអ្វី... ប៉ុន្តែចូរឯងកុំមកដោយខ្លួនឯងឲ្យសោះ » ។

នៅក្នុងពេលមួយទៀត, គាត់បានបិតនៅក្នុងនាវាមួយនៅចំកណ្ដាលចំណោមពួកក្រុមចោរ ។ នាវានោះក៏ត្រូវចាប់បានដោយកងរក្សាសមុទ្រ ។ ពួកជនទុច្ចរិតក៏និយាយកាន់គ្នាទៅវិញទៅមកថា ៖ « ពួកយើងដល់ថ្ងៃអន្សារហើយ ...បើកាលណាមានគេស្គាល់រូបយើង » ។ « ចំណែកខ្ញុំវិញ, ប៉ីយ៉ុងពោល, ខ្លួនខ្ញុំមកដល់ថ្ងៃអន្សារហើយ បើកាលណាពុំមានគេស្គាល់រូបខ្ញុំទេ » ។

❑

*– ថ្ងៃមួយ, គាត់ឃើញជនច្រណែនគេម្នាក់ដើរសរសៀរមកក្នុងសភាពអាការៈក្រៀមក្រំពន់ប្រមាន ។ « តើមានរឿងអភ័ព្វអ្វីកើតឡើងដល់រូបឯង, គាត់ពោលទៅកាន់ជននេះ, ឬមួយក៏មានរឿងសប្បាយមួយ ដែលធ្លាក់ទៅលើរូបអ្នកដទៃ ? » ។

*– នៅពេលដែលគាត់ឃើញជនកំណាញ់ក្រៀតម្រាម្នាក់ដើរមកដល់, គាត់ពោលថា ៖ « ឯងមិនមែនជាម្ចាស់ទ្រព្យសម្បត្តិរបស់ឯងនោះទេ ...គឺទ្រព្យសម្បត្តិ

របស់ឯងទៅវិញទេ ដែលជាចៅហ្វាយម្ចាស់របស់ឯង » ។

*- គាត់តែងពោលថា ជនកំណាញ់យកចិត្តទុកដាក់នឹងទ្រព្យសម្បត្តិរបស់ខ្លួនខ្លាំងណាស់ ...ធ្វើដូចជាទ្រព្យសម្បត្តិនេះជាកម្មសិទ្ធរបស់ខ្លួនពិតមែន ។ ...ក៏ប៉ុន្តែក្នុងការចាយវាយវិញ គេមានការភ័យខ្លាចតក់ស្លុតហាក់ដូចជាទ្រព្យសម្បត្តិនេះជារបស់អ្នកដទៃ ។

*- គាត់យល់ថា សេចក្តីទុក្ខដ៏ធំបំផុត គឺការមិនចេះអត់ទ្រាំនឹងសេចក្តីទុក្ខ ។

*- គេមិនត្រូវដាក់ទោសអំពីជរាភាពទៅលើរូបនរណាម្នាក់ឡើយ ( កុំឲ្យមើលងាយមនុស្សចាស់ ) ...ពីព្រោះជាសភាពការណ៍មួយ ដែលមនុស្សម្នាក់ៗតែងចង់បាន ។

*- សូវឲ្យបាត់បង់ទ្រព្យសម្បត្តិខ្លួនធ្លាក់ទៅក្នុងកណ្តាប់ដៃអ្នកដទៃទៅចុះ... ពីព្រោះមនុស្សយើងអាចរស់នៅសប្បាយ ថ្វីបើត្រូវថមថយទ្រព្យរបស់ខ្លួន ។ ចំណែកជនដែលរស់នៅដោយមានចំណង់ចង់បានរបស់គេវិញ ...តែងមានសេចក្តីអផ្សុខ្លាំងណាស់ គ្មានឱសថដោះស្រាយទេ ។

*- ពេលខ្លះសេចក្តីក្លាហានហួសព្រំដែនវាសមរម្យនឹងយុវវ័យ ...ក៏ប៉ុន្តែមនុស្សយើងកាលណាចូលដល់វ័យចាស់ជរាហើយ គួរតែធ្វើអ្វីដោយប្រយ័ត្នប្រយែង ។

* - កាលណាគេមានឱកាសបង្កើតបានមិត្តភ័ក្តិរួចហើយ គេគួររក្សាមិត្តភ័ក្តទាំងនេះតទៅទៀតនៅក្នុងសភាពដដែលដូចដើម ...ទោះជាអ្នកទាំងនេះ មាន-ចារិកលក្ខណៈយ៉ាងណាក៏ដោយ, ចៀសវាងកុំឲ្យគេចោទថាយើងបានសេពគប់ជាមួយនឹងចោរ ...ឬក៏ថាយើងបានផ្តាច់មេត្រីភាពជាមួយនឹងមនុស្សល្អបរិសុទ្ធ ។

*- គាត់បានប្រាប់មិត្តភ័ក្តិទាំងអស់ឲ្យបានដឹងថា សញ្ញានៃការចម្រុងចម្រើនលូតលាស់ខាងផ្នែកទស្សនវិជ្ជាដល់កំពូល គឺនៅពេលដែលយើងគ្មានការរំភើបញាប់ញ័រដល់តិចតួច.. បើទោះជាអ្នកក្រៅនិយាយប្រមាថកាតទៀនយើងក្តី ឬក៏សរសើររូបយើងក្តី ។

*- គាត់បានពោលថា ការប្រុងប្រយ័ត្នមានលក្ខណៈខ្ពង់ខ្ពស់ជាងសីលធម៌ដទៃទៀតទាំងអស់...ក៏ដូចជាចក្ខុប្បសាទដែលមានលក្ខណៈខ្ពង់ខ្ពស់ជាងវិញ្ញាណដទៃទៀតទាំងអស់ដែរ ។

*- អំពើអសិលធម៌ពុំមែនជាមិត្តភ័ក្តិល្អ ក្នុងការរួបរួមដំណើរជាមួយនឹងសម្បជញ្ញៈនោះទេ, គឺដោយហេតុថាជាការលំបាកណាស់ចំពោះមនុស្សម្នាក់ៗក្នុងការហ៊ាននិយាយស្តីឲ្យបានពេញមាត់ បើកាលណាសម្បជញ្ញៈរបស់គេបានស្តីបន្ទោសអំពីរឿងអ្វីមួយហើយ... ម៉្លោះហើយជននោះតែងយល់ថា មានព្រះឬទេព្តា

ណាមួយកំពុងអាក់អន់ចិត្តនឹងរូបគេនៅក្នុងរឿងនេះ ។

*- ផ្លូវដែលនាំចូលទៅឋាននរកជាផ្លូវងាយស្រួលពេកណាស់... ពីព្រោះគេចំណាំតែដើរចូលទៅដោយបិទភ្នែក ។

*- ជនណាដែលធ្វើការសិក្សាឡើងទៅមិនដល់កម្រិតទស្សនវិជ្ជា...ហើយឱបក្រសោបបានត្រឹមតែវិទ្យាសាស្ត្រដទៃទៀតរបស់មនុស្សជាតិ ក៏ប្រៀបធៀបបានទៅនឹងក្រុមបុរសដែលតាមស្នេហាស្មោះស្ម័គ្រជាមួយអ្នកស្រីប៉េណេឡុប គឺពួកគេបានត្រឹមតែរួមរស់ជាមួយនឹងឈ្នួលស្រីបម្រើ ...ក៏ប៉ុន្តែមិនបានទៅរួមរស់ភ្លក្សរសជាតិជាមួយនឹងម្ចាស់ផ្ទះនោះឡើយ ។

*- ថ្ងៃមួយ, នៅពេលដែលប៊ីយ៉ុងបិតនៅស្រុករ៉ូដ , គាត់បានឃើញពួកអ្នកស្រុកអាត្មែនដែលមករស់នៅក្នុងកោះនេះគិតតែពីរៀនវិជ្ជាខាងផ្នែកវោហាសាស្ត្រ គឺពោលវាចាឲ្យបានសមពិរោះដូចនៅក្នុងសិល្បៈល្ខោន ...។ គាត់ក៏បានចាប់ផ្ដើមបង្រៀនពីទស្សនវិជ្ជា ។ នៅពេលដែលគេស្ដីបន្ទោសឲ្យគាត់ថាហេតុអ្វីបានជាគាត់មិនធ្វើដូចជាអ្នកដទៃ, គាត់បានឆ្លើយតបវិញដូច្នេះថា ៖ « អញបានយកម្សៅសាលីមកជាប់នឹងខ្លួន ... ហេតុអ្វីបានជាឯងចង់ឲ្យអញលក់ម្សៅដំបែរទៅវិញ ? ។

*- នៅពេលដែលគេរៀបរាប់អាណិតអាសូរអំពីសេចក្ដីទុក្ខវេទនារបស់ក្រុមនារីឋានប្រេតដាណៃយ៉ាដ ដែលមានកាតព្វកិច្ចយកកញ្ជើធ្លុះទៅដងទឹកមិនចេះចប់មិនចេះហើយ, គាត់ក៏បានពោលតបថា ៖ « ខ្ញុំយល់ដូច្នេះទៅវិញទេថា ...បើសិនជាពួកនាងដួសទឹកជាមួយនឹងកញ្ជើដែលមិនធ្លុះវិញ ...ពួកនាងរិតតែគួរឲ្យអាណិតថែមលើសពីនេះទៅទៀត » ។

❑

នៅទីបំផុត, បន្ទាប់ពីបានរស់នៅក្នុងជីវភាពមួយដែលមានមូលដ្ឋាននៅក្នុងអំពើឧក្រិដ្ឋ, គាត់ក៏បានធ្លាក់ឈឺរ៉ាំរ៉ៃជាយូរខែថ្ងៃនៅស្រុកចាល់ស៊ី ។ ដោយគាត់ជាជនម្នាក់ក្រីក្រជាបំផុត, គ្មានសោហ៊ុយដើម្បីចាយវាយទៅលើមនុស្សសម្រាប់ថែទាំព្យាបាលរូបគាត់... ស្ដេចអង់ទីគ្មោនុស្សក៏បានបញ្ជូនឈ្នួលបម្រើពីរនាក់ទៅជួយមើលគាត់ ព្រមទាំងបានប្រទានអំណោយនូវកៅអីមួយផងជូនគាត់, ដើម្បីស្រណុកតាមឃ្លាំមើលគាត់នៅពេលណាដែលទ្រង់សព្វព្រះហឫទ័យ ។

គេបាននិយាយថាប៊ីយ៉ុង, នៅពេលកើតជម្ងឺរ៉ាំរ៉ៃនេះ, មានការស្ដាយក្រោយជាខ្លាំង ដោយគាត់ធ្លាប់បានប្រមាថព្រះនិងទេព្តា។ គាត់ក៏បានបន់ស្រន់ព្រះឥន្ទ, ព្រះព្រហ្មនិងទេព្តាដើម្បីជួយរូបគាត់ឲ្យបានចាកចេញពីសភាពវេទនារខ្លោចផ្សារបែ-

បនេះ ។ គាត់បានសុខចិត្តទៅហិតក្លិនសាច់ខ្មោចដែលគេបានថ្វាយជាសក្ការៈបូជាដល់ទេព្តា ៖ គាត់បានធ្វើសេចក្តីសារភាពអំពីបទឧក្រិដ្ឋរបស់គាត់...ព្រមទាំងមានការវង្វេងវង្វាន់រហូតដល់ប្រគល់ខ្លួនគាត់ទៅឲ្យស្រីមេធ្មប់ដាក់អំពើម្នាក់។ គាត់បានហុចក និងដៃរបស់គាត់ទៅឲ្យស្រីមេធ្មប់នេះ ចងខ្សែគាថាដាក់មន្តស្នេហ៍។ គាត់បានធ្លាក់ចូលទៅក្នុងជំនឿដ៏មហាស្ចារ្យ ...គឺគាត់បានតែងតាំងទ្វាររបស់គាត់នូវកម្រងផ្ការផ្សេងៗ ...ហើយសុខចិត្តធ្វើអ្វីៗគ្រប់យ៉ាងដើម្បីរក្សាជីវិតរបស់គាត់ ។ ប៉ុន្តែ ការខំប្រឹងប្រែងអស់ទាំងនេះជាការឥតអំពើ ។ ជនកំសត់ឈ្មោះប៊ីយ៉ុងក៏បានទទួលមរណភាពទៅ នៅក្នុងការស្រែកដង្ហោយឈឺចាប់វេទនាយ៉ាងខ្លាំងដែលបណ្តាលមកពីអបាយមុខដែលគាត់បានប្រព្រិត្តពីក្នុងអតីតកាល ។៚

❑ ❑

❑

# ជីវិតរបស់ស្ទីឡុង
# CHILON

គាត់បានចូលក្នុងវ័យលូតលាស់នៅក្នុងអូឡាំព្យ៉ាដទី៥២ ។ ម្ល៉ោះហើយគេអាចសន្និដ្ឋានបានថា អាយុរបស់គាត់ទំនងដូចជាប្រហាក់ប្រហែលគ្នានឹងអាយុរបស់ពីតាគុសដែរ ។

*　　*
*

ស្ទីឡុងមានកេរ្តិ៍ឈ្មោះលូតលាស់នៅឡាសេដេម៉ូននៅក្នុងកំឡុងអូឡាំព្យ៉ាដទី៥២ ។ គឺជាបុរសម្នាក់ដែលមានស្មារតីរឹងប៉ឹងនិងចិត្តអង់អាច, ដែលមានអាការៈនឹងនរ ព្រងើយកន្តើយ មិនខ្វល់ខ្វាយជានិច្ចជាកាល នៅចំពោះសេចក្តីទុក្ខលំបាកវេទនាក៏ដូចតែនៅក្នុងសេចក្តីសុខសប្បាយ ពោរពេញទៅដោយភោគទ្រព្យ ។ គាត់បានថយខ្លួនទៅរស់នៅក្នុងគេហដ្ឋានគាត់ ដោយគ្មានមហិច្ឆិតា ហើយបានយល់ថាពេលវេលាដែលគេប្រើប្រាស់ដោយឥតប្រយោជន៍ជាទីបំផុត គឺពេលវេលាដែលគេបានធ្វើដំណើរទៅឆ្ងាយយូរខែយូរថ្ងៃ ។ ជីវិតរបស់គាត់ជាគំរូមួយប្រកបដោយសីលធម៌ត្រឹមត្រូវឥតខ្ចោះ ។ គាត់តែងបានអនុវត្តនូវអ្វីទាំងអស់ដែលគាត់បាននិយាយ ។ សេចក្តីស្ងៀមស្ងាត់ព្រមទាំងលក្ខណៈសុភាពរាបសាររបស់គាត់បានធ្វើឲ្យអ្នកផងមានចិត្តស្ងើចសរសើររូបគាត់គ្រប់គ្នា ។ គាត់បានគ្រប់គ្រងជីវិតរបស់គាត់ស្របតាមតាមភាសិតមួយដែលគាត់បាននិពន្ធដោយខ្លួនឯងផ្ទាល់គឺ ៖ « ក្នុងរឿងអ្វីៗក៏ដោយ គេត្រូវប្រឹងរត់ទៅមុខដោយយឺតៗ » ។ នៅក្នុងកំឡុងអូឡាំព្យ៉ាដទី៥៥ គេបានលើកដំកើងលោកឲ្យមានឋានន្តរស័ក្តិជាអេហ្វ័រ ( Éphore : ថានៈជាចៅក្រមទី១នៅស្ប៉ាតិ៍) មានអនុភាពប្រហែលគ្នានឹងស្តេចគ្រប់គ្រង ។ បងប្រុសរបស់គាត់ ដែលចង់បានកន្លែងនេះដែរ ក៏កើតមានចិត្តច្រណែននិន្ទារយ៉ាងខ្លាំង ។ បងម្នាក់នេះ ក៏បានសំដែងនូវគំនុំគុំគួនដ៏ល្វីងជូរចត់ចំពោះគាត់ ។ គាត់ក៏បានឆ្លើយតបចំពោះចំពោះបងប្រុសវិញ យ៉ាងរបៀបត្រជាក់ថា ៖ « គេបានជ្រើសរើសយករូបខ្ញុំ ពីព្រោះពួកគេយល់ថាគេអាចទំខានឬធ្វើទុក្ខបុកម្នេញមកលើរូបខ្ញុំច្រើនជាងបងក្នុងការប្រទាញប្រទង់រូបខ្ញុំឲ្យចេញផុតពីរង្វង់នៃសេចក្តីសុខសាន្តនៃការសំរាកកាយនិងចិត្តគំនិត ដើម្បីយករូបខ្ញុំទៅលត់ដំនៅក្នុងបញ្ហានយោបាយ ព្រមទាំងធ្វើរូបខ្ញុំឲ្យក្លាយទៅជាទាសកម្មករ ។

គាត់បានយល់ថាគេមិនត្រូវបោះបង់ចោលទាំងស្រុង នូវច្បាប់ក្បួននៃការទស្សន៍ទាយនោះទេ ហើយមនុស្សយើងដោយសារកម្លាំងនៃគំនិតបញ្ញា អាចមើលឃើញនិងដឹងបាននូវរឿងជាច្រើន ដែលកើតឡើងនៅថ្ងៃមុខ ។

ថ្ងៃមួយអ៊ីប៉ូក្រាត ( Hippocrate : ជនដែលបានបង្កើតវិទ្យាសាស្ត្រពេទ្យទំនើបក្នុងពិភពក្រិក ហើយដែលមានឥទ្ធិពលទៅលើវេជ្ជសាស្ត្រនៃគ្រប់ប្រទេសរហូតមកទល់សព្វថ្ងៃ ) បានធ្វើពិធីបូជាយញ្ញមួយ នៅចំពេលកីឡាអ៊ីឡាំពីក ។ នៅពេលដែលគេបានយកសាច់ឈាមនៃជនរងគ្រោះដាក់ក្នុងឆ្នាំងដែកមួយដ៏ធំ ដែលពោរពេញទៅដោយទឹកត្រជាក់, ក៏ស្រាប់តែគេឃើញទឹកនេះពុះឡើងមួយរំពេច ជាហេតុឲ្យទឹកហៀរចេញពីមាត់ឆ្នាំងដ៏សម្បើមនោះ ។ ស្ទីឡុងដែលមានវត្តមានទីនោះដែរ បានសង្កេតពិចារណាយ៉ាងពិនិត្យពិច័យទៅលើអព្ភូតហេតុនេះ ។ គាត់ក៏បានទូន្មានដល់អ៊ីប៉ូក្រាតថា កុំឲ្យគាត់នេះយកប្រពន្ធឲ្យសោះ... ចៀសវាងដាច់ខាតកុំឲ្យរៀបអាពាហ៍ពិពាហ៍ ហើយប្រសិនណាបើជាគ្រោះអភ័ព្វ គាត់ជ្រួលជាមានប្រពន្ធកូនទៅហើយនោះក៏គាត់ត្រូវតែប្រញាប់លែងប្រពន្ធចោលមួយរំពេច ហើយសម្លាប់កូនទាំងអស់ដែលគាត់មានពីស្រីម្នាក់នេះដែរ ។ អ៊ីប៉ូក្រាតបានសើចចំអកនឹងយោបល់បែបនេះ។ ទោះជាយ៉ាងណាក្តី ការទូន្មានបែបនេះ មិនបានហាមឃាត់រូបគាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍នោះទេ, ហើយគាត់មានកូនម្នាក់ជាមួយប្រពន្ធគាត់ ដែលគ្មាននរណាក្រៅពីវាជាផ្តាច់ការពីស៊ីត្រាត ដែលបានដណ្តើមយកអធិបតេយ្យភាពនៃទីក្រុងអាត្ថែនមាតុភូមិរបស់គាត់ ។

មានពេលមួយ ស្ទីឡុង ដោយបានសង្កេតពិចារណាពីគុណភាពទឹកដី អំពីជីវជាតិនិងស្ថានភាពភូមិសាស្ត្រនៃកោះស៊ីត្ថែរ ( Cythère ) ក៏បានស្រែកប្រកាសនៅមុខអ្នកផងថា ៖ « ឱព្រះជាម្ចាស់!... សូមកុំឲ្យមានកោះនេះវិញល្អជាជាង, ឬពុំនោះសោត សូមឲ្យសមុទ្រលេបត្របាក់វាឲ្យបាត់ទៅ នៅពេលដែលវាងើបផុសចេញឡើង... ពីព្រោះខ្ញុំអាចមើលជាមុនថា ដីនេះនឹងបង្កើតការហិនហោចដល់ប្រជាជននៅសេដេម៉ូនជាពុំខាន ។ ត្រង់ចំណុចនេះ ស្ទីឡុងមិនបានយល់ច្រឡំទេ ។ កោះនេះបន្តិចក្រោយមកក៏ត្រូវពួកអ្នកក្រុងអាត្ថែនតណ្តើមយកបាន ដែលបានប្រើប្រាស់កោះនេះ ដើម្បីកំចាត់ស្រុកឡាសេដេម៉ូន ។

ស្ទីឡុងបានពោលថា តាមធម្មតានៅក្នុងជីវិត មានរឿងពិបាកបីយ៉ាងដែលមនុស្សយើងពិបាកយកជ័យជំនះ៖ លាក់ការសម្ងាត់, ទ្រាំនឹងការប្រមាថ, ហើយនិងប្រើប្រាស់វេលាយ៉ាងល្អប្រសើរ ។

សុន្ទរកថារបស់ស្ទីឡុងតែងតែមានពាក្យឃ្លាខ្លី ប្រកបដោយន័យទូលំទូលាយ ។ ការនិយាយស្តីរបស់គាត់ ក៏បានក្លាយទៅជាសុភាសិត ។

★ គាត់បានពោលថា គេមិនត្រូវប្រើការកំហែងគំរាមចំពោះជនណាម្នាក់ទេ ពីព្រោះការកំហែងជាលក្ខណៈទន់ខ្សោយរបស់ស្រីភេទ ។

★ វិចារណញាណដ៏សំខាន់បំផុត គឺការចេះទប់អណ្ដាតខ្លួនឯង ជាពិសេសនៅពេលជប់លៀង ។

★ គេមិនត្រូវនិយាយអាក្រក់ពីនរណាទាំងអស់... បើពុំនោះសោតទេ គេបានត្រឹមតែបង្កើតសត្រូវសម្លាប់ខ្លួនឯង ឬក៏បានត្រឹមតែពាក្យមិនល្អ ដែលត្រឡប់បញ្ច្រាស់មកវិញ ។

★ គេគួរតែទៅលេងមិត្តភក្ដិ នៅពេលដែលអ្នកទាំងនេះធ្លាក់បុណ្យ... ចៀសវាងកុំទៅលេងនៅពេលដែលគេកំពុងឡើងបុណ្យ ។

★ ការបង់ខាតជាការល្អប្រសើរ ជាងការចំណេញដោយអយុត្តិធម៌និងដោយទុច្ចរិត ។

★ គេមិនត្រូវសរសើរជនណាម្នាក់ អំពីភ័ព្វវាសនាអាក្រក់ដែលជននេះកំពុងតែឆ្លងកាត់នោះទេ ។

★ បុរសដែលមានចិត្តក្លាហាន តែងតែមានអាកប្បកិរិយាត្រជាក់ជានិច្ច ។ សូវធ្វើឲ្យគេគោរព ជាជាងធ្វើឲ្យគេខ្លាច ។

★ នយោបាយដ៏ល្អប្រសើរបំផុតក្នុងរដ្ឋនិមួយៗ គឺការបង្រៀនពលរដ្ឋឲ្យចេះអប់រំគ្រួសាររបស់ខ្លួនឯងផ្ទាល់ ។

★ គេគួរតែយកប្រពន្ធជាស្ត្រីសាមញ្ញធម្មតាជាជាងធ្វើការបង្ខើនបង្ខោចខ្លួនឯងក្នុងការរៀបចំអាពាហ៍ពិពាហ៍ជាន់ខ្ពស់ ។

★ គេអាចសាកល្បងដឹងពីមាសឬប្រាក់ដោយសារថ្មវិភាគ (Pierre de touche) ប៉ុន្តែមាសនិងប្រាក់គេអាចយកទៅសាកល្បង ដើម្បីដឹងសំគាល់ពីទឹកចិត្តមនុស្ស ។

★ អ្វីៗក៏ដោយគេត្រូវចេះប្រើដោយសន្សំសំចៃ ដើម្បីចៀសវាងកុំឲ្យមានសេចក្ដីឈឺចាប់ខ្លាំងពេក នៅពេលដែលគេខ្វះខាតរបស់អស់ទាំងនេះទៅ ។

★ សេចក្ដីស្នេហាក្ដី, ការស្អប់ខ្ពើមក្ដី ពុំមែនស្ថិតស្ថេរចិរកាលនោះទេ ។ គេត្រូវស្រឡាញ់ដោយបំរុងក្នុងចិត្តថា ថ្ងៃមួយគេត្រូវស្អប់វិញ ។ គេត្រូវស្អប់ដោយបំរុងក្នុងចិត្តថាថ្ងៃមួយគេត្រូវស្រឡាញ់វិញ ។

គាត់បានឲ្យគេឆ្លាក់ឆ្លែជាអក្សរមាស នៅក្នុងព្រះវិហារអាប៉ូឡុងនៅភ្នំដេល្ហ នូវសុភាសិតដូច្នេះថា ៖ « គេមិនត្រូវប្រាថ្នាចង់បានអ្វីៗ ដែលនៅខ្ពស់ហួសឆ្ងាយពីលើរូបខ្លួនឯងពេលនោះទេ, ហើយជនណាក៏ដោយដែលតបឆ្លើយចំពោះអ្នកម្នាក់ទៀតច្បាស់ជាត្រូវបង់ខាតដោយចៀសមិនរួច » ។

ប៉េរីយ៉ង់ដ្រឺបានខំប្រឹងប្រែងប្រទាញយកស្ទីឡុង ឲ្យទៅរស់នៅជាមួយគាត់នៅកូរាំងថឺ ដើម្បីយកទៅធ្វើជាសមាជិកក្រុមប្រឹក្សារបស់គាត់ ក្នុងការបន្ដរបបរាជានិ-

យមផ្ដាច់ការ ដែលគាត់តណ្ដើមយកបាន ។ ស្ទីឡុងក៏បានឆ្លើយតបទៅគាត់វិញដោយសេចក្ដីដូច្នេះថា ៖ « លោកបានចង់ណែនាំខ្ញុំឲ្យចូលក្នុងវិបត្តិនៃសង្គ្រាម, ចង់និរទេសរូបខ្ញុំឲ្យនៅឆ្ងាយពីស្រុកខ្ញុំ ហាក់ដូចជាធ្វើដូច្នេះទៅ លោកនឹងអាចរស់នៅក្នុងសេចក្ដីសុខនិងសុវត្ថិភាព។ សូមលោកដឹងថា គ្មានអ្វីដែលមិននឹងនរឬផលផាលជាងអំណាចរបស់ស្ដេចនោះទេ, ហើយរាជាផ្ដាច់ការដែលមានភ័ព្វសំណាងជាទីបំផុតគឺជនណាម្នាក់ដែលមានសុភមង្គលក្នុងការស្លាប់នៅលើគ្រែដេករបស់ខ្លួន » ។

ស្ទីឡុងបានដឹងថា ជីវិតរបស់គាត់បានមកដល់ក្បែរចុងចប់ ក៏បានប្រមែប្រមូលមិត្តភក្ដិរបស់គាត់ទាំងប៉ុន្មានឲ្យមកអង្គុយជុំវិញគាត់ រួចគាត់ពោលដូច្នេះថា ៖ «មិត្តទាំងអស់គ្នា, មិត្តបានដឹងរួចស្រេចហើយថា ខ្ញុំបាននិយាយស្ដីនិងបានប្រព្រឹត្តអំពើជាច្រើនណាស់ តាំងពីយូរយារណាស់មកហើយ បន្ទាប់ពីខ្ញុំបានចាប់កំណើតក្នុងជាតិនេះមក ។ ខ្ញុំបានពិនិត្យសើរើឡើងវិញទាំងអស់អំពីកិច្ចការដែលខ្ញុំបានធ្វើ ហើយខ្ញុំបានខំប្រឹងរកមើលមិនឃើញនូវរឿងណាមួយ ដែលខ្ញុំមានការសោកស្ដាយជាក្រោយ ក្រៅអំពីរឿងនេះមួយ ដែលខ្ញុំកំពុងតែលើកយកមកជូនមិត្តទាំងអស់គ្នាជួយអារកាត់ គឺគ្រាន់តែដើម្បីដឹងថាតើខ្ញុំបានធ្វើត្រូវឬធ្វើខុស៖ ថ្ងៃមួយក្នុងឋានៈជាចៅក្រម ខ្ញុំបានត្រូវគេចាត់ ជាជនទី៣ ឲ្យកាត់ទោសមនុស្សម្នាក់ ដែលត្រូវប្រហារជីវិតស្របតាមច្បាប់ជាធរមាន ហើយដែលត្រូវជាមិត្តភក្ដិដ៏ល្អរបស់ខ្ញុំម្នាក់ដែរ ។ ខ្ញុំមានការទើសទាល់ជាខ្លាំង ៖ វាមានផ្លូវតែ២យ៉ាងប៉ុណ្ណោះជាការចាំបាច់, ឬមួយខ្ញុំត្រូវបំពានច្បាប់, ឬមួយខ្ញុំត្រូវសម្លាប់មិត្តភក្ដិរបស់ខ្ញុំ។ បន្ទាប់ពីបានធ្វើការស្រមើស្រមៃតែពីសតែពាសអស់មួយខណៈ ខ្ញុំក៏បានរកឃើញស្នៀតនេះម៉្យាង ៖ ខ្ញុំបានលើកយកមកសំដែងបង្ហាញ, ដោយការប៉ិនប្រសប់ក្រៃលែង, នូវគុណធម៌និងលក្ខណៈសម្បត្តិជាច្រើនរបស់ជនជាប់ចោទ, រហូតដល់សហសេវិករបស់ខ្ញុំទាំងប៉ុន្មាន គ្មានការលំបាកអ្វីនឹងលើកលែងទោសឲ្យជននេះទាល់តែសោះ ហើយក្នុងពេលជាមួយគ្នានោះខ្ញុំក៏បានសំរេចកាត់ទោសប្រហារជីវិត ដោយគ្មានការវែកញែកអ្វីទាំងអស់ ៖ តាមបែបផែនដូច្នេះ ខ្ញុំក៏បានបំពើឧត្ដមគតិរបស់ខ្ញុំជាចៅក្រមផង និងជាមិត្តសំឡាញ់ផង ។ ក៏ប៉ុន្តែខ្ញុំហាក់ដូចជាមានអ្វីមួយនៅស្ទះក្នុងសម្បជញ្ញៈរបស់ខ្ញុំ ដែលធ្វើឲ្យខ្ញុំនឹកសង្ស័យថា យោបល់របស់ខ្ញុំមានទំនោរឧក្រិដ្ឋកម្ម ។

ស្ទីឡុង ដោយមានវ័យចាស់ជរាពេកណាស់ទៅហើយ ក៏បានទទួលមរណភាពនៅពីសឺ ( Pise ), ដោយត្រេកសប្បាយហួសហេតុ ដោយឱបកូនរបស់គាត់ម្នាក់ដែលទើបតែបានទទួលរង្វាន់លេខ១នៅក្នុងកីឡាអូឡាំពីក ។

អ្នកស្រុកឡាសេដេម៉ូនបានកសាងរូបសំណាកមួយជូនគាត់ ក្រោយពីពេលដែលគាត់ស្លាប់ ។៚

# ជីវិតរបស់ក្លេអូប៊ុល
# CLÉOBULE

ជាអ្នករស់ក្នុងជំនាន់សូឡុង ។ អាយុរបស់គាត់ក៏មានទំនងប្រហាក់ប្រហែលគ្នានឹងសូឡុងដែរ ។ ពោលជីវភាពរបស់គាត់ បានលាតសន្ធឹងរវាងចន្លោះអូឡាំព្យ៉ាដទី ៣៥ និង ទី៥៥ ។

* *

*

ក្លេអូប៊ុលបានត្រូវចាត់ទុកជាអ្នកប្រាជ្ញម្នាក់ ដ៏មិនសូវសម្បើមប៉ុន្មានទេ ក្នុងចំ-ណោមអ្នកប្រាជ្ញទាំងឡាយ... ក៏ប៉ុន្តែចាត់ទុកថាគាត់ជាបុគ្គលដែលមានសុភមង្គលជាងគេបំផុត ។ គាត់ត្រូវជាកូនប្រុសរបស់អេវ៉ាគោរ៉ាស ដែលបន្តពូជមកពីអ៊ែរគុល ( Hercule) ។ គាត់មានកំណើតនៅក្នុងសមុទ្រឡាំងដីនៃកោះរ៉ូដ, ដែលនៅទីនោះគាត់បានចំរើនអាយុនៅក្នុងសម័យសក់រាជ្យរបស់ក្រេស៊ុស, ស្តេចនៃប្រទេសលីឌី ។ តាំងពីក្មេងមកម្ល៉េះ គាត់បានបង្ហាញនូវបញ្ញានិងវិចារណញ្ញាណដ៏ជ្រាលជ្រៅ ។ គាត់មានទឹកមុខស្រស់ស្អាតបាតណាស់ ។ មានមាឌធំខ្ពស់ ប្រកបដោយកម្លាំងកាយបរិបូរណ៍អស្ចារ្យ ដែលគេកំរជួបប្រទះ ។ កាលគាត់នៅក្នុងយុវវ័យ គាត់បានចំណាយពេលធ្វើដំណើរទៅប្រទេសអេយីព្ទ ដើម្បីទៅសិក្សាទស្សនវិជ្ជា ស្របតាមទំនៀមទំលាប់សម័យនោះ ។ នៅពេលគាត់ត្រឡប់មកវិញ គាត់បានរៀបអាពាហ៍ពិពាហ៍ជាមួយស្រីគ្រប់លក្ខណម្នាក់ ហើយគាត់បានរស់នៅយ៉ាងស្ងាត់ស្ងៀម នៅកណ្តាលចំណោមគ្រួសាររបស់គាត់ ។ គឺដោយសារតែអាពាហ៍ពិពាហ៍នេះទើបគាត់បានផ្តល់កំណើតដល់កូនស្រីម្នាក់ប្រកបដោយកិត្តិនាមល្បីល្បាញ។ នាងឈ្មោះក្លេអូប៊ូលីន។ នារីនេះមានកេរ្តិ៍ឈ្មោះរន្ទឺសុះសាយ ក៏ដោយសារតែនាងអនុវត្តមេរៀនដ៏ប្រកបដោយភោគផលរបស់ឪពុកនាង ជាហេតុបណ្តាលឲ្យមានការភ័ន្តភាំងដល់ទស្សនវិទូដ៏ពូកែៗជាច្រើននៅក្នុងសម័យនោះ ជាពិសេសដោយសារនាងមានទេពកោសល្យក្នុងការចោទសំនួរ ដែលមានលក្ខណ:ជាប្រស្នា ។ នាងមានសច្ចភាពពន់ពេកព្រមទាំងជានារីប្រកបដោយគុណធម៌ រហូតដល់នាងសុខចិត្តដាក់ខ្លួនលាងជើងដោយមធ្យ័តចំពោះមិត្តភក្តិនិងភ្ញៀវបរទេស ដែលបានមកធ្វើពិធីជប់លៀងនៅផ្ទះឪពុករបស់នាង ។

ក្លេអូប៊ុលជាបុគ្គលដែលគេជ្រើសរើស ដើម្បីឲ្យគ្រប់គ្រងរដ្ឋឡាំងដីដ៏តូចមួយ។

គាត់បានបំពេញករណិយកិច្ចនេះដោយធូរស្រួលពន់ពេក ហាក់ដូចជាគាត់បានត្រួតត្រាកាន់កាប់គ្រួសារតែមួយប៉ុណ្ណោះ។ គាត់បានបញ្ចៀសនូវគ្រប់កត្តាដែលអាចបង្កើតឲ្យមានសង្គ្រាម ហើយបានបង្កើតបរិយាកាសនៃសេចក្ដីសុខសប្បាយ និងសភាពត្រូវរ៉ូវគ្នា រវាងពលរដ្ឋគ្នាឯងផង ក៏ដូចជាមួយគ្នានឹងជនបរទេសផងដែរ ។ ស្នាដៃដ៏សំខាន់របស់គាត់នៅខាងផ្នែកអក្សរសាស្ត្រ គឺការចេះពន្យល់ណែនាំនិងដាក់ចំណោទប្រស្នាយ៉ាងប៉ិនប្រសប់ក្រៃលែង ។ គឺគាត់នេះហើយដែលបង្កើតឲ្យមានរបៀបចោទសំនួរប្រៀបផ្ទៀបក្នុងអាថ៌កំបាំង ដែលបានទទួលការរាប់អានពីគ្រប់ប្រជាជាតិក្រិក គឺវិធីដាក់ចំណោទប្រស្នារដែលគេបានរៀនសូត្រមកពីប្រទេសអេយីព្ទ ។ គឺគាត់នេះដដែល ដែលជាអ្នកនិពន្ធនៃប្រស្នារមួយដែលមានសេចក្ដីដូចតទៅនេះ ៖

« ខ្លួនខ្ញុំជាបិតាម្នាក់ដែលមានបុត្រា១២នាក់, បុត្រម្នាក់ៗមានបុត្រី៣០ ។ នាងខ្លះមានមុខស នាងខ្លះមានមុខខ្មៅទាល់តែមែនទែន ។ បុត្រីទាំងអស់នេះ មានលក្ខណ:ជាអមត:មិនចេះស្លាប់, ក៏ប៉ុន្តែនាងចេះតែស្លាប់រៀងរាល់ថ្ងៃ » ។

ប្រស្នានេះមានន័យថា « ឆ្នាំ » ។

គឺក្លេអូប៊ុលនេះឯងដែលជាអ្នកនិពន្ធអក្ខរាលើផ្នូររបស់ស្ដេចមីដាស...។ នៅក្នុងចំណារអត្ថបទនោះ គាត់បានថ្លែងសរសើរយ៉ាងខ្លាំង ចំពោះរាជាដែលបានសុគតទៅ ។ មានជនខ្លះបានយល់ច្រឡំតែផ្ដាសថា អូម៉ែរ ( Homère ) ជាអ្នកបានសរសេរចំណារអត្ថបទសរសើរ... ក៏ប៉ុន្តែអ្នកផងបានដឹងថា អូម៉ែរបានកើតមុនស្ដេចមីដាសនោះជាយូរអង្វែងឆ្នាំផុតរួចទៅហើយ ។

ក្លេអូប៊ុលបានកសាងគោលជំហរនៃសីលធម៌របស់គាត់ ក្នុងការកំចាត់បង់នូវអយុត្តិធម៌និងបាបកម្មដទៃៗទៀត ។ គឺនៅក្នុងមនោសញ្ចេតនាបែបនេះហើយ ដែលហូរ៉ាស្ស ( Horace ) បានសរសេរថា ៖

**Virtue est vitium fugere, et sapienta prima stultitià caruisse...**

★ ក្លេអូប៊ុលធ្លាប់បានពោលជារឿយៗធម្មតាថា...គេត្រូវតែរក្សាឲ្យមានសណ្ដាប់ធ្នាប់ កិរិតពេលវេលានិងរង្វាស់រង្វាល់សមរម្យ ទោះនៅក្នុងរឿងអ្វីៗក៏ដោយ ។

★ ដើម្បីបំបាត់អំពើឆ្គួតលីលា ដែលមានពាសពេញនៅក្នុងរដ្ឋ គេត្រូវបង្ខំពលរដ្ឋម្នាក់ៗឲ្យចេះរស់នៅទៅតាមសមត្ថភាពរបស់ខ្លួន ។

★ នៅក្នុងលោកនេះ គ្មានអ្វីដែលសាមញ្ញទូទៅជាងអំពើល្ងង់ខ្លៅ ហើយនិងមនុស្សដែលនិយាយរអ៊ូតអាងច្រើននោះទេ ។

★ ត្រូវតែខំប្រឹងប្រែងឲ្យមានមនោសញ្ចេតនាខ្ពស់, គាត់ពោល, ហើយចៀសវាងកុំឲ្យកើតចិត្តរមិលគុណនិងវៀចវេរ ។ ចូរធ្វើអំពើល្អជាមួយមិត្តភក្តិរបស់អ្នក ក៏ដូចតែជាមួយនឹងសត្រូវរបស់អ្នកផងដែរ ។ ធ្វើដូច្នេះទៅ លោកអ្នកនឹងអាចរក្សាមិត្តភក្តិ

ហើយធ្វើឲ្យសត្រូវប្រែក្លាយទៅជាមិត្តវិញ ។

★ មុននឹងចាកចេញពីលំនៅដ្ឋានរបស់អ្នកទៅ...ត្រូវអ្នកគិតជាស្រេចថា អ្នកបំរុងនឹងធ្វើអ្វីខ្លះ។ លុះដល់ពេលវិលត្រឡប់មកវិញ, អ្នកត្រូវគិតពិចារណាសម្លឹងមើលមកខ្លួនឯង ត្រូវសើរើឡើងវិញក្នុងចិត្តគំនិតរបស់អ្នក នូវអ្វីៗទាំងអស់ដែលអ្នកបានប្រព្រឹត្ត ។

★ និយាយឲ្យតិច, ហើយស្តាប់ឲ្យបានច្រើន ។

★ កុំនិយាយអាក្រក់ពីជនណាទាំងអស់ ។

★ ត្រូវផ្តល់ជំបូន្មានចំពោះអ្នកដទៃ នូវអ្វីៗដែលអ្នកយល់ថា ជាការសមរម្យជាទីបំផុត ។

★ កុំបណ្តោយខ្លួនឲ្យរសាត់អណ្តែតទៅតាមសេចក្តីសប្បាយ ។

★ ត្រូវសម្របសម្រួលជាមួយសត្រូវរបស់អ្នក ប្រសិនបើលោកអ្នកមាន ។ កុំធ្វើអំពើអ្វីដោយកំហែងកំហល់ឲ្យសោះ ។

★ ត្រូវខំប្រឹងអប់រំកូនរបស់លោកអ្នក ឲ្យបានក្លាយទៅជាមនុស្សល្អ ។

★ កុំសើចចំអកចំពោះជនអភ័ព្វណាម្នាក់ឲ្យសោះ ។

★ បើកាលណាភ័ព្វព្រេងវាសនាសើចញញឹមមករកអ្នក, ចូរអ្នកកុំអាលត្រេកអរសប្បាយបំប៉ោងខ្លួន ។ ក៏ប៉ុន្តែបើភ័ព្វវាសនាបែរខ្នងដាក់រូបអ្នកវិញ... ក៏គួរតែអ្នកកុំអាលកើតទុក្ខ ។

★ ចូរអ្នករើសគូស្រករយោងទៅតាមឋានៈរបស់រូបខ្លួនឯង ។ ពីព្រោះបើអ្នករៀបការជាមួយនឹងភរិយាដែលមានឋានៈខ្ពស់លើរូបអ្នកខ្លាំងពេក... អ្នកនឹងមានចៅហ្វាយនាយនៅគ្រប់រូបបងប្អូនដែលនាងមាន ។

★ គេត្រូវចេះថែរក្សានិងអប់រំបុត្រីជាពិសេស ។ គេមិនត្រូវបណ្តោយឲ្យនាងរៀបការ ដោយសារតែនាងមានអាយុពេញវ័យតែប៉ុណ្ណោះទេ... ប៉ុន្តែដោយសារនាងបានក្លាយជារូបស្រីដែលមានចិត្តគំនិត និងឫកពារជាមនុស្សធំរួចស្រេច ។

★ បុរសមិនត្រូវលើកសរសើរដំកើង ឬក៏រករឿងឈ្លោះជាមួយនឹងភរិយាខ្លួនឯង នៅនឹងមុខភ្ញៀវនោះទេ ។ ក្នុងប្រការទី១ ជាសេចក្តីទន់ខ្សោយ, ក្នុងប្រការទី២ ជាអំពើឆ្កួតលីលា...

*　　　*

*

នៅពេលដែលក្លេអូប៉ុលបានដឹងថាសូឡុង បានបោះបង់ចោលប្រទេសជាតិរបស់ខ្លួន លែងវិលត្រឡប់ គាត់បានចាត់វិធានការគ្រប់យ៉ាង ដើម្បីទាក់ទាញរដ្ឋបុរសនេះមកលំនៅដ្ឋានរបស់គាត់។ គាត់បានផ្ញើលិខិតមួយទៅសូឡុង ដែលមានសេចក្តី

ដូច្នេះថា ៖

« លោកមានមិត្តភក្តិជាច្រើន ដែលសុទ្ធសឹងតែមានផ្ទះសំរាប់ទទួលលោកឲ្យសំណាក់ ៖ ប៉ុន្តែខ្ញុំជឿជាក់ថា លោកមិនអាចរស់នៅទីណាឲ្យបានប្រកបជាងនៅឡាំងដីនេះទេ ។ គឺជាទីក្រុងនៃកោះសមុទ្រមួយ ដែលមានសេរីភាពពេញលេញគ្រប់យ៉ាង ៖ លោកឥតមានត្រូវការភ័យខ្លាចអ្វីជាមួយពីស៊ីត្រាតនោះទេ ចំណែកមិត្តភក្តិរបស់លោកទាំងអស់អាចធ្វើដំណើរមកលេងលោកនៅទីនេះដោយសុវត្ថិភាព » ។

ក្លេអូប៊ុលបានចេះបង្កើតឲ្យមានសេចក្តីសុខសប្បាយ និងសុភមង្គលក្នុងការរស់នៅ ដោយមានសម្ភារៈបន្តិចបន្តួចនៅក្នុងជីវិតមួយ ដែលប្រាសចាកការរំខាននៃពិភពលោក ។ គាត់ជាស្វាមីម្នាក់ដ៏ល្អ, ជាឪពុកម្នាក់ដ៏ប្រសើរ, ជាពលរដ្ឋគំរូ, ជាទស្សនវិទូដែលប្រកបដោយសេចក្តីសុខ... ហើយនៅទីបញ្ចប់, គាត់បានទទួលមរណភាពទៅនៅក្នុងអាយុ៧០ឆ្នាំ បន្ទាប់ពីអ្នកផងបានលើកដំកើងកិត្តិយសរបស់គាត់ ពេញមួយជីវិតរបស់គាត់ ។ ពួកអ្នកស្រុកឡាំងដី បានសំដែងនូវសេចក្តីសោកស្តាយពន់ប្រមាននៅពេលដែលគាត់ស្លាប់ទៅ ។ ពួកគេបានកសាងផ្នូរមួយយ៉ាងល្អ ដែលនៅទីនោះគេបានសរសេរចំណារអត្ថបទដ៏ល្អប្រសើរ ដើម្បីរំឭកចំពោះគុណូបការៈរបស់គាត់ ។៚

❑ ❑

❑

# ជីវិតរបស់ក្រាតែស
# CRATÈS

* គឺជាទស្សនវិទូរមួយរូបនៅក្នុងជំនាន់ប៉ូឡេម៉ុង, ( ដែលជាអ្នកបន្តដំណែងពីសេណូក្រាតនៅក្នុងបណ្ឌិតសភារបស់ប្លាតុង) ។ ក្រាតែសបានស្គាល់សេចក្ដីរុងរឿងនៅក្នុងសម័យអូឡាំព្យ៉ាដទី-១១៣ ។

❑

ក្រាតែស-ឡឺស៊ីនីក (មានន័យថាក្រាតែសនៃបក្សឥតខ្វល់ខ្វាយឬបក្សស្នូម), គឺជាសាវ័កម្នាក់របស់ជនល្បីឈ្មោះឌីយ៉ូសែននោះឯង។ ក្រាតែសជាកូនប្រុសរបស់អាសកុងឌុសដែលជាបូរីជនម្នាក់នៃទីក្រុងថែបចេញពីគ្រួសារមួយដ៏រុងរឿងថ្កុំថ្កើងស្មុះសាយសម្បើមណាស់ ...ពីព្រោះជាពូជពង្សវង់ត្រកូលមហាសេដ្ឋីមួយមានទ្រព្យសម្បត្តិក្រាស់ក្រៃលមហិមា។

ថ្ងៃមួយ, ក្នុងពេលដែលក្រាតែសបានទៅទស្សនាសោកនាដកម្ម, គាត់បានសង្កេតឃើញថាតេឡេភុសបានបោះបង់ធនធានរបស់ខ្លួនទាំងប៉ុន្មានដើម្បីរត់ទៅចូលបក្សស្នូមរបស់ឌីយ៉ូសែន ។ គាត់ក៏មានកើតសេចក្ដីរំភើបក្នុងចិត្តជាខ្លាំង, ម៉្លោះ ហើយគាត់ក៏បានសម្រេចចិត្តថាយកគំរូតាមតេឡេភុសដោយគ្មានបង្អែរបង្អង់ ។ គាត់ក៏សម្រេចលក់សម្បត្តិកេរ្តិ៍អាករបស់គាត់ទាំងអស់បានប្រាក់ពីររយតម្លឹង ( មួយតម្លឹង ឬមួយថ្លឹង- Talent -សម័យនោះ, គឺច្រើនណាស់ ...ពីព្រោះមួយតម្លឹងក្រិកជំនាន់ដើមមានទម្ងន់ជាប្រាក់ ឬជាមាសពី២០ទៅ២៧គីឡូ ) ។ គាត់បានយកប្រាក់នេះទៅប្រគល់ឲ្យម្ចាស់ធនាគារម្នាក់ដោយផ្ដែផ្ដាំថា ឲ្យប្រគល់ទៅកូនរបស់គាត់ល្គឹកណាបើវាមានសតិស្មារតីមិនគ្រប់គ្រាន់ក្នុងការកសាងខ្លួនឲ្យក្លាយទៅជាទស្សនវិទូ ។ ក៏ប៉ុន្តែបើពួកវាមានបញ្ញាខ្ពង់ខ្ពស់ដើម្បី ឡើងថានៈជាទស្សនវិទូរួចហើយគាត់នឹងអនុញ្ញាត្តឲ្យយកប្រាក់ទាំងនេះ ទៅចែកចាយដល់ប្រជាពលរដ្ឋនៅទីក្រុងថែនវិញ ពីព្រោះដោយហេតុថាពួកទស្សនវិទូ ឥតមានត្រូវការអ្វីទេ ។ ថ្ងៃមួយ, ឪពុកម្ដាយរបស់គាត់បានមកអង្វរកគាត់ឲ្យបោះ បង់គំនិតនេះចោលទៅវិញ ហើយឲ្យបង្កើតគំរោងការណ៍រកស៊ីចិញ្ចឹមជីវិតទៅតាមរបៀបផ្សេង ។ គាត់បានដេញមាតាបិតារបស់គាត់ឲ្យចេញពីផ្ទះគាត់...មិនត្រឹមតែប៉ុណ្ណោះបានយកដំបងព្រនង់តាមវាយសំពងពួកអ្នកមានគុណថែមទៀត ។

នៅក្នុងខែក្ដៅក្រាតែសតែងពាក់អាវម៉ង់តូយ៉ាងក្រាស់ឃ្មឹក, ក៏ប៉ុន្តែនៅខែរងារវិញគាត់ស្លៀកពាក់យ៉ាងស្ដើងរយារ ដើម្បីទម្លាប់ខ្លួនគាត់ឲ្យចេះអត់ទ្រាំនឹងសេចក្ដីទុក្ខលំបាក ។ គាត់តែងដើរចូលរបៀបព្រហើនទៅក្នុងផ្ទះរបស់អ្នកដទៃគ្រប់គ្នាដើម្បីទៅស្ដីបន្ទោសឲ្យគេអំពីរឿងហេតុអ្វីៗដែលធ្វើឲ្យទាស់ភ្នែកត្រចៀករបស់គាត់ ។ គាត់តែងស្វែងដេញតាម ពួកអ្នករស់នៅក្នុងអំពើពាលា ដើម្បីទៅនិយាយប្រមាថប្រាស់ឆ្អេះឲ្យអ្នកទាំងនេះ, ក្នុងគោលបំណងឲ្យពួកអ្នកក្រោយនេះស្ដីជេរត្រឡប់ឲ្យគាត់វិញ, ហើយដោយមានទម្លាប់ធ្វើដូច្នេះទៅ ...គាត់នឹងអាចអត់ទ្រាំជាមួយនឹងពួកគេនៅក្នុងកាលៈទេសៈផ្សេងទៀត ។ គាត់រស់នៅយ៉ាងរបៀបតឹងរឹងជាបំផុត ហើយផឹកតែទឹក, ដូចតែមនុស្សឯទៀតទាំងអស់នៅក្នុងបក្សស៊ីនីក ។

វាគ្មិនម្នាក់ឈ្មោះម៉េត្រូកមិនហ៊ានដើរចេញទៅកន្លែងសាធារណៈទេ, ពីព្រោះគាត់នេះអត់ទ្រាំមិនបានចេះតែលេចផោមនៅកណ្ដាលវាល, រៀងរាល់ពេលណាដែលគាត់និយាយស្ដី សម្លេងខ្យល់ដែលចេញពីខ្លួនគាត់បានធ្វើឲ្យគាត់កើតសេចក្ដីអៀនខ្មាស់ជាខ្លាំង ។ ម្ល៉ោះហើយគាត់បានបិទទ្វារសម្ងំនៅតែក្នុងផ្ទះ ព្រមទាំងបានសម្រេចថានឹងនៅលាក់ខ្លួនពួនអាត្មាទីនេះរហូតដល់ជីវិតរបស់គាត់ចប់ ។ ដោយបានឮគេនិយាយពីរឿងនេះ ក្រាតែសក៏បានហូបផ្លែល្ងបុំាង ( មានឥទ្ធិពលដូចជាគ្រាប់ខ្ទុរដុត) ដើម្បីឲ្យពោះរបស់គាត់មានខ្យល់ចូលពេញ ...រួចគាត់ក៏ដើរសំដៅឆ្ពោះទៅផ្ទះមេត្រូក ។ គាត់ក៏បានពោលពាក្យសំដីផ្អែមពិរោះជាច្រើនដល់មេត្រូកដើម្បីបង្ហាញឲ្យជននេះឃើញថា គេមិនត្រូវមានសេចក្ដីអៀនខ្មាសសោះឡើយក្នុងករណីដែលគេមិនបានធ្វើអំពើអ្វី ជាតំណាងនៃសេចក្ដីអាក្រក់ ។ រឿងទាំងអស់នេះទៀតសោតវាអាចកើតដល់មនុស្សគ្រប់ៗគ្នា, ជាពិសេសវាក៏អាចកើតមានឡើងចំពោះរូបគាត់ផងដែរ ។

នៅពេលដែលគាត់កំពុងនិយាយដូច្នេះ សម្លេងខ្យល់បណ្ដាលមកពីគ្រាប់ល្ហុបុំាងនោះក៏បានបញ្ចេញឥទ្ធិពលរបស់វា ។ គំរូដ៏ល្អរបស់ក្រាតែសបានលើកទឹកចិត្តរបស់មេត្រូកជាខ្លាំង រហូតដល់បណ្ដាលឲ្យគាត់នេះទទួលស្គាល់នូវសេចក្ដីទន់ខ្សោយរបស់គាត់ ។ ពេលនោះមេត្រូកក៏លែងរវីរវល់នឹងសេចក្ដីគួរសមឬក្បួនសុជីវធ៌មអ្វីៗទាំងប៉ុន្មាន, មិនត្រឹមតែប៉ុណ្ណោះគាត់បានដុតចោលសៀវភៅទាំងអស់របស់តេអូប្រាស្តដែលគាត់ធ្លាប់បានព្យាយាមសិក្សាដល់ទីជម្រៅ, ហើយក៏បានដើរតាមក្រាតែសដែលបានញុំាងរូបគាត់ឲ្យក្លាយទៅជាសមាជិកនៃបក្សស៊ីនីកម្នាក់ដ៏ល្អប្រសើរ ។ បន្ទាប់ពីនោះមកមេត្រូកក៏បានក្លាយទៅជាទស្សនវិទូប្រកបដោយកេរ្តិ៍ឈ្មោះខ្ទរខ្ទារនៅក្នុងបក្សព្រមទាំងមានសាវ័ករបស់ខ្លួនជាច្រើនដែលសុទ្ធសឹងតែមានកេរ្តិ៍ឈ្មោះល្បីផងដែរនៅថ្ងៃក្រោយមក ។ ក៏ប៉ុន្តែនៅទីបំផុត,

ដោយគាត់មានវ័យចាស់ជរាទ្រុឌទ្រោមដោយពិការភាព, សេចក្ដីស្ងប់ខ្ពើមនៃជីវិតក៏បានមកសណ្ឋិតនៅក្នុងរូបគាត់ឡើងវិញសារជាថ្មី ៖ គាត់ក៏បានច្របាច់កខ្លួនឯងស្លាប់តែម្ដងទៅ ។

ក្រាតែសមានរូបអាក្រក់ពន់ពេកណាស់... ហើយដើម្បីឲ្យគេមើលមកឃើញគាត់កាន់តែអាក្រក់អស្ចារ្យឡើងថែមទៀត គាត់បានដេរស្បែកចៀមពីលើអាវម៉ង់តូរបស់គាត់ ... ដូច្នេះទៅពេលគេសម្លឹងមើលមកគាត់ គេក៏មិនអាចដឹងច្បាស់ថាតើជាមនុស្សឬក៏ជាសត្វចម្លែកអ្វីទេ ។ ម្យ៉ាងវិញទៀត, ដោយគាត់ជាមនុស្សប៉ិនប្រសប់ខាងមុខល្បែងកីឡាច្រើនយ៉ាង, នៅពេលណាដែលគាត់ត្រូវសំដែងជូនមតិមហាជនទស្សនានូវក្បួនចំបាប់ ឬការប្រយុទ្ធគ្នាបែបផ្សេងទៀត, ពួកអ្នកឈរនៅទីនោះចេះតែសើចនឹងគាត់ ដោយហេតុមកពីមុខមាត់ចម្លែកនិងសម្លៀកបំពាក់ដ៏អស្ចារ្យរបស់គាត់ ។ ក្រាតែសមិនមានការភ្ញាក់ផ្អើលក្នុងរឿងនេះទេ ។ គាត់លើកដៃទាំងពីរឡើងលើហើយស្រែកថា ៖ « ឱ! ក្រាតែសចូរឯងខំប្រឹងរក្សាសេចក្ដីអត់ធ្មត់ ...បន្តិចទៀតពួកនរណាសើចនឹងឯងត្រូវយំវិញម្ដង, ហើយឯងនឹង-មានការសប្បាយចិត្តដោយឃើញពួកជនទាំងនេះស្រឡាញ់រូបឯងវិញ ហើយចាត់រូបឯងថាជាមនុស្សមានភ័ព្វសំណាង ...ដោយពួកគេនឹងស្ដីបន្ទោសអំពីសភាពកំសាកញើរបស់ខ្លួនគេ ។

ថ្ងៃមួយ, គាត់បានទៅអង្វរករលោកគ្រូម្នាក់ឲ្យមានចិត្តសណ្ដោសប្រណីចំពោះសាវ័ករបស់គាត់ម្នាក់ ។ ក៏ប៉ុន្តែគាត់មិនឱបជើងថើបក្បាលជង្គង់របស់គ្រូម្នាក់នេះបែរជាថើបភ្លៅរបស់គាត់ទៅវិញ ដែលជាហេតុបណ្ដាលឲ្យលោកគ្រូរកកលខឹងសម្បារនឹងអាកប្បកិរិយាដ៏ចម្លែកនេះ ។

– មានជាការទាស់ខុសអ្វី, ក្រាតែសពោលទៅកាន់លោកគ្រូ, តើភ្លៅរបស់ឯងមិនមែនជាសម្បត្តិទ្រព្យរបស់ឯងដូចតែក្បាលជង្គង់ដែរទេឬ ?

គាត់បានពោលថាគឺជាការលំបាកណាស់ ឬជាការមិនអាចទៅរួចក្នុងការរកឲ្យឃើញមនុស្សណាម្នាក់ដែលមិនបានប្រព្រឹត្តកំហុស ។ ក៏ប៉ុន្តែផ្លែទទឹមនៅតែល្អជានិច្ចបើទោះជាមានគ្រាប់រលួយពីរបីគ្រាប់ក៏ដោយ ។

ក្រាតែសចង់ឲ្យសាវ័ករបស់គាត់ ដកចិត្តថ្លើមចេញពីសម្បត្តិទ្រព្យទាំងអស់នៅលើផែនដីនេះ ។ «សម្បត្តិទ្រព្យរបស់ខ្ញុំគឺមានតែអ្វីៗ ដែលខ្ញុំបានរៀនសូត្រតែប៉ុ-ណ្ណោះឯង, គាត់ពោល, អ្វីៗដែលនៅសល់ក្រៅពីនេះខ្ញុំបានទុកឲ្យពួកអ្នកស្វែងរកសេចក្ដីរុងរឿងទៅចុះ» ។ គាត់បានដាស់តឿនសាវ័កទាំងនេះជាពិសេសឲ្យចៀសវាងជីវិតនៃសេចក្ដីសប្បាយ ពីព្រោះថាវាគ្មានអ្វីសមរម្យសំរាប់ទស្សនវិទូ ជាងទម្លាប់រស់នៅក្នុងសេរីភាពនោះទេ ហើយក៏គ្មានចៅហ្វាយម្ចាស់ឯណាដែលមានលក្ខណៈ

ផ្ដាច់ការនិយមសង្កត់សង្កិនជាងជីវភាពឈ្លក់វង្វេងនៅក្នុងតណ្ហាក្រាស់នោះដែរ ។

– សចក្ដីអត់ឃ្លាន, គាត់ពោល, តែងតែធ្វើឲ្យស៊ះស្បើយរោគស្នេហា ។ បើឧសថប៉ុណ្ណោះមិនគ្រប់គ្រាន់នោះទេ ...ពេលវេលាដែលរសាត់ទៅតែងតែធ្វើឲ្យមនុស្សបំភ្លេចទុក្ខអ្វីៗទាំងអស់ ។ បើពុំនោះសោតទេ, គេគួរតែរកខ្សែមួយចង្វាយមកចងកខ្លួនឯងស្លាប់ឲ្យហើយទៅ !

កាលណាគាត់នឹកទៅដល់ទំនៀមទម្លាប់ពុករលួយ នៃសតវត្សរ៍របស់គាត់ គាត់តែងតែស្ដីបន្ទោសទៅលើអំពើឆ្កួតលីលារបស់មនុស្ស ដែលសុខចិត្តចាយប្រាក់ទាំងពំនូកដើម្បីបម្រើតណ្ហារបស់ខ្លួន ក៏ប៉ុន្តែដែលនឹកស្ដាយស្រណោះចំពោះប្រាក់ពីរបីសេនដែលខ្លួនចាយនៅក្នុងរឿងសុច្ចរិត ហើយនិងបានផលប្រយោជន៍ ( ក.ក.ន.៖ ដូចជាជនឆ្កួតល្បែងក្នុងសម័យឥឡូវ ដែលចាយប្រាក់រាប់ម៉ឺនដុល្លារក្នុងកាស៊ីណូមិនស្ដាយ បែរជាស្ដាយប្រាក់៩-១០សេនក្នុងការទិញពងមាន់មួយយកមកស្ងោរលិទ្ធ ...) ។

គឺក្រាតែសនេះឯង ដែលបានសរសេរកំណាត់បញ្ហាមួយដ៏ល្បីល្បាញរហូតមកទល់សព្វថ្ងៃនេះ ៖ « គេគួរតែឲ្យទៅអ្នកធ្វើបាយនិងពេទ្យហ្មរនូវប្រាក់មួយកាក់ ។ គេគួរតែឲ្យ៥ដម្លឹងទៅជនឡែបឡប, ឲ្យតែផ្សែងពពកទៅទីប្រឹក្សាម្នាក់ដ៏ល្អប្រសើរ។ គេគួរតែឲ្យមួយតម្លឹងដល់ស្រីពេស្យា ហើយឲ្យតែមួយសេនទៅដល់ទស្សនវិទូ» ។

នៅពេលដែលគេសួរគាត់ថា តើទស្សនវិជ្ជារបស់គាត់បានផ្ដល់ផលប្រយោជន៍អ្វីខ្លះទៅ ?

– គឺបានផ្ដល់ផលប្រយោជន៍ឲ្យខ្ញុំចេះរស់នៅដោយគ្រាន់តែហូបបន្លែប៉ុណ្ណោះក៏ខ្ញុំសប្បាយចិត្តណាស់ទៅហើយ, គាត់ពោលតបវិញ, គឺឲ្យចេះរស់ដោយឥតមានការថ្នាក់ថ្នមថែទាំ ហើយដោយគ្មានរឿងកង្វល់កង្វាយអ្វីទាំងអស់ ។

ថ្ងៃមួយដេម៉េទ្រីយុសនៅហ្វាលែរបានផ្ញើនំបុ័ងហើយនិងស្រាក្រហមមកជូនគាត់ពិសារ ។ ក្រាតែសមានសេចក្ដីទាស់ចិត្តជាខ្លាំងដែលដេម៉េទ្រីយុសនឹកស្មានថា

ថ្ងៃមួយដេម៉េទ្រីយុសនៅហ្វាលែរបានផ្ញើនំបុ័ងហើយនិងស្រាក្រហមមកជូនគាត់ពិសារ ។ ក្រាតែសមានសេចក្ដីទាស់ចិត្តជាខ្លាំងដែលដេម៉េទ្រីយុសនឹកស្មានថាទស្សនវិទូរក៏ត្រូវការផឹកស្រាក្រហមផងដែរ ៖ គាត់ក៏បានបញ្ជូនដបស្រាទំពាំងបាយជូរត្រឡប់ទៅវិញដោយមានទឹកមុខក្រមូវ ៖ « ឱ! ព្រះជាម្ចាស់, គាត់ឧទានឡើងយ៉ាងខ្លាំងៗ, សូមឲ្យមានម៉ាស៊ីនមួយដូចម៉ាស៊ីនទឹកដែលបញ្ចេញតែនំបុ័ងមកបានហើយ » ។

អាកប្បកិរិយាដ៏រំភើយរបស់ក្រាតែសបានធ្វើឲ្យនាងហ៊ីប៉ាឆា, ប្អូនស្រីរបស់មេត្រូកចាប់ចិត្តស្រឡាញ់យ៉ាងខ្លាំង ម៉្លោះហើយនាងឥតមានវីរវល់ចង់ដឹងអំពី

មនុស្សជាច្រើននាក់ទៀតប្រកបដោយថានៈឧត្ដុងឧត្ដមដែលតាមចែចង់ស្រឡាញ់នាងនោះឡើយ ។ នាងបានគំរាមកំហែងឪពុកម្ដាយនាងថាបើនាងពុំបានក្រាតែសជាស្វាមីនោះទេ, នាងនឹងប្រហារជីវិតរបស់ខ្លួនឯងចោល ។ ឪពុកម្ដាយពួដូច្នេះ, ក៏បានខំប្រឹងប្រែងប្រើមធ្យោបាយគ្រប់យ៉ាង ដើម្បីដកគំនិតនេះចេញពីក្បាលនាង, ក៏ប៉ុន្តែគឺជាការឥតអំពើ ។ នៅទីបំផុត, លោកទាំងពីរក៏បានរត់ទៅអង្វរក្រាតែសដោយផ្ទាល់តែម្ដងឲ្យជួយពង្វាងនាងហ៊ីប៉ាឆាអំពីគោលប្រាថ្នារបស់នាង ។ ដោយនៅទីបំផុតគាត់ក៏មិនអាចដោះស្រាយបញ្ហានេះបាន, គាត់ក៏ងើបឡើងហើយដោះសម្លៀកបំពាក់ចោលចេញទាំងអស់ចំពោះមុខនាង ដើម្បីបង្ហាញឲ្យនាងបានឃើញខ្នងគម និងរូបកាយក្រញឹងក្រង់ក្រៀចក្រវិច ប្រាសចាកនូវសោភ័ណភាពរបស់គាត់ ។ គាត់ក៏គ្រវែងចោលទៅខាងម្ខាងនូវអាវម៉ង់តូ, ថង់យាមហើយនិងដំបងរបស់គាត់ ( កកន ៖ គួរកត់សំគាល់ថាប័ក្សសីនីករបស់ពួកក្រិក ហើយនិងប័ក្សស្ទូមរបស់ចិនមានលក្ខណៈ ដូចគ្នាត្រង់ការប្រើដំបងឈើច្រត់ជានិមិត្តរូប ) ។

– ដើម្បីឲ្យនាងមើលឃើញឲ្យច្បាស់, គាត់ពោលទៅកាន់នាងហ៊ីប៉ាឆា, និងកុំភ័ន្តច្រឡំឲ្យសោះថានេះហើយជាអីវ៉ែអីវ៉ាន់ទាំងប៉ុន្មាន ដែលប្ដីរបស់នាងមាន ។ សូមក្រឡេកមើលក្នុងពេលនេះដើម្បីដឹងថានាងចង់បានអី ? ប្រសិនបើនាង សុខចិត្តរៀបការជាមួយរូបខ្ញុំៗមិនហ៊ានអួតអាងថា ខ្ញុំមានទ្រព្យសម្បត្តិអ្វីផ្សេងក្រៅពីនេះទេ ។

នាងហ៊ីប៉ាឆាមិនបានរេរាសោះឡើយ ។ នាងសម្រេចជ្រើសរើសយកក្រាតែសហើយលះបង់ចោលអ្វីៗទាំងអស់ដែលនាងធ្លាប់មាន ...ពោលគឺរូបក្រាតែសមានតម្លៃលើសពីអ្វីៗទាំងអស់ដែនាងធ្លាប់សង្ឃឹម ។ តាំងពីថ្ងៃនោះមក, នាងមិនដែលបានបោះបង់ចោលប្ដីនាងសោះឡើយ ។ នាងបានដើរតាមប្ដីនាងរហូត ហើយបានចូលគ្រប់ទីប្រជុំឯណាដែលមានប្ដីនាងនៅក្នុងទីនោះ ។

ថ្ងៃមួយនៅពេល ដែលអ្នកទាំងពីរបានចូលទៅរួមក្នុងពិធីជប់លៀងនៅផ្ទះរបស់លីស៊ីម៉ាគុស, នាងហ៊ីប៉ាឆាបានបញ្ចេញទ្រឹស្ដីសូហ្វីស្ដមួយ ( របៀបនិយាយស្ដីវែកញែកដោយគ្មានមូលដ្ឋានត្រឹមត្រូវ ) អនុវត្តន៍ទៅលើជនឥតជឿព្រះម្នាក់ឈ្មោះតេអូឌរ ...ដោយពោលពាក្យដូច្នេះថា ៖ « ប្រសិនបើជាតេអូឌរ បានប្រព្រឹត្តអំពើអ្វីមួយហើយមិនបានទទួលទោសកំហុស, ហ៊ីប៉ារឆាដែលប្រព្រិត្តអំពើដូចគ្នាដោយក៏ឥតត្រូវទទួលទោសកំហុសផងដែរ, ម្ល៉ោះហើយពេល ដែលតេអូឌរវាយខ្លួនឯង, ច្បាស់ជាគ្មាននរណាស្ដីបន្ទោសឲ្យគាត់ទេ ដោយពោលដូច្នេះនាងក៏ទះកំភ្លៀងតេអូឌរមួយដៃ, បើហ៊ីប៉ាឆាវាយតេអូឌរក៏មិនត្រូវមាននរណាស្ដីបន្ទោសឲ្យដូចគ្នាដែរ » ។

ក្នុងពេលភ្លាមៗនោះ តេអូឌរមិនបាននិយាយតបតសោះឡើយ ។ ប៉ុន្តែបន្តិច

ក្រោយមកជននេះក៏ចាប់កន្ត្រាក់អាវម៉ង់តូចេញពីស្មារបស់ហ៊ីប៉ាឆាដែលពុំបាន សំដែងនូវការភ្ញាក់ផ្អើលអ្វីទាំងអស់ ។

– មើលហ្ន៎ ! តេអូឌរពោល, នេះហើយជាស្រីម្នាក់ដែលបានឃ្លាតចាកពីក្រ-ណាត់ទ្រាប់និងសំបុកពីពាងរបស់ខ្លួន ។

– ការនេះជាការពិត, ហ៊ីប៉ាឆាពោល, ក៏ប៉ុន្តែតើគាត់ឯងយល់ថាខ្ញុំបានធ្វើអំពើអាក្រក់ណាស់ណាទៅឬ ដោយបានជ្រើសរើសយកទស្សនវិជ្ជា និងដោយបានទម្លាក់ចោលមុខរបររបស់ស្ត្រី ?

លទ្ធផលនៃអាពាហពិពាហ៍ដ៏ខ្ពង់ខ្ពស់រវាងហ៊ីប៉ាឆាហើយនិងក្រាតែស គឺការឲ្យកំណើតទៅបុត្រម្នាក់ឈ្មោះប៉ាស៊ីក្លែស ដែលទាំងឪពុកនិងទាំងម្ដាយបានបង្ហាត់បង្រៀនឲ្យក្លាយទៅជាទស្សនវិទូរស៊ីនីកម្នាក់ដ៏ល្អប្រសើរ ។

ថ្ងៃមួយស្ដេចអាឡេចសង់បានស្នើរដល់ក្រាតែសនូវពាក្យដូច្នេះថា ៖

– គួរតែឯងរៀបចំកសាងប្រទេសជាតិរបស់ឯងឡើងវិញ ... (ទីក្រុងថែប) ...

– តើបានប្រយោជន៍អ្វីទៅ, ក្រាតែសពោលតបវិញ, ពីព្រោះនឹងមានស្ដេចអា-ឡេចសង់មួយអង្គទៀតមកបំផ្លាញខ្ទេចខ្ទីអស់តែដដែល ។

គាត់បានពោលថាគាត់គ្មានប្រទេសជាតិអ្វីក្រៅតែពីសេចក្ដីក្រីក្រ ហើយនិងការមាក់ងាយសេចក្ដីថ្កុំថ្កើងរុងរឿងតែប៉ុណ្ណោះទេ ។ គាត់ជាពលរដ្ឋម្នាក់របស់ឌីយ៉ូសែនម៉្លោះហើយគាត់គ្មានចំណង់ចង់បានអ្វីទាំងអស់ ។

គាត់បានពោលថា សម្បត្តិទ្រព្យរបស់ពួកអម្ចាស់ក៏ដូចតែដើមឈើធំៗ ខ្ពស់ៗទាំងឡាយដែលដុះនៅលើកំពូលភ្នំក្រមថ្មស្រួចៗដែលគ្មានរណាឡើងទៅបាន...។ មានតែ សត្វត្មាតនិងសត្វក្អែកតែប៉ុណ្ណោះដែលអាចបរិភោគផលផ្លែនៃដើមឈើទាំ-ងនេះ។ យ៉ាងណាមិញ, គឺមានតែស្រីពេស្យាហើយនិងពួកជនឡែបឡប់តែប៉ុណ្ណោះដែលអាចពឹងពាក់អាស្រ័យហូបទ្រព្យសម្បត្តិរបស់ពួកអម្ចាស់ ។ គាត់បានពោលបន្ថែមទៀតថា ជនអ្នកមានម្នាក់ដែលមានជនឡែបឡប់នៅជុំវិញខ្លួន ក៏ហាក់ដូចជាកូនគោមួយដែលរស់នៅកណ្ដាលចំណោមឆ្កែចចក ។

នៅពេលដែលគេសួរគាត់ថា តើគេត្រូវអនុវត្តទ្រឹស្ដីទស្សនវិជ្ជារហូតដល់ពេលណាដែរទៅ ?

– គឺ, គាត់ពោល, រហូតដល់ពេលមួយដែលគេទទួលស្គាល់ថា ពួកជនដែលគេតម្រូវឲ្យដឹកនាំនិងបញ្ជាត្រួតត្រាមនុស្ស តាមពិតគឺសមសក្ដិតែដឹកនាំហ្វូងសត្វលាទៅវិញទេ ។

ក្រាតែសក៏ដូចតែទស្សនវិទូរឯទៀតៗក្នុងបក្សស៊ីនីក គឺមិនបានយកចិត្តទុកដាក់នឹងវិទ្យាសាស្ត្រដទៃទៀតទាំងអស់ក្រៅតែពីសីលធម៌ ។ គាត់បានរស់រានមាន

ជីវិតជាយូរអង្វែងឆ្នាំពេកណាស់ ៖ គាត់ក៏បានក្លាយទៅជាមនុស្សចាស់ជរាមានខ្នងកោងយ៉ាងខ្លាំង នៅក្នុងប៉ុន្មានឆ្នាំចុងក្រោយនៃជីវិតរបស់គាត់ ។ នៅពេលដែលគាត់ដឹងខ្លួនថា ពេលចប់របស់គាត់បានជិតមកដល់ហើយ ...គាត់ក៏បានគិតពិចារណាលើរូបខ្លួនឯងដោយពោលថា ៖ « ឱ បុរសគមដ៏កំសត់អើយ, ឆ្នាំអាយុវែងអន្លាយរបស់ឯង កំពុងរៀបចំយករូបឯងទៅដាក់នៅក្នុងផ្នូរពេលនេះហើយ; បន្តិចទៀត ឯងនឹងអាចឃើញមាត់ទ្វារប្រាសាទនៃឋាននរកដ៏ពិតប្រាកដ » ។

ក្រាតែសបានទទួលការល្បីឈ្មោះខ្លាំងនៅក្នុងអូឡាំព្យ៉ាដទី-១១៣ ។ ជាពិសេសកេរ្តិ៍ឈ្មោះរបស់គាត់បានលេចឮរន្ទឺរសុះសាយនៅទីក្រុងថែប... ដែលជាហេតុបណ្ដាលឲ្យឈ្មោះអ្នកដទៃទៀត ចុះថមថយជាខ្លាំងនៅក្នុងជំនាន់យុគសម័យរបស់គាត់ ។ គឺគាត់នេះហើយដែលជាគ្រូធំរបស់សេណុង... ដែលជាមេដឹកនាំបក្សស្តូអ៊ីកដ៏ល្បីល្បាញនៅពេលជាបន្ទាប់មក (កកន ៖ បក្សពួកអ្នកទទួលទ្រាំវាសនាយថាកម្មដោយមិនមានត្អូញត្អែរមួយម៉ាត់ ) ។

❑ ❑

❑

# ជីវិតរបស់ដេម៉ូគ្រីត
# DÉMOCRITE

★ កើតនៅឆ្នាំទី៣នៃអូឡាំពីយ៉ាដទី៧៧, ស្លាប់ទៅនៅឆ្នាំទី៤នៃអូឡាំពីយ៉ាដទី១០៥ ។ គាត់បានរស់នៅអស់រយៈពេល១០៩ឆ្នាំ ។

*　　　　*

*

មតិរបស់អ្នកផងបានយល់ថា ទស្សនវិទូដេម៉ូគ្រីតមានកំណើតនៅអាប់ឌែរ, ប៉ុន្តែមានអ្នកខ្លះទៀតបានយល់ថា គាត់មកពីមីឡេត៍... ហើយមូលហេតុដែលគេយល់ថា គាត់មកពីអាប់ឌែរ គឺមកពីគាត់បានដកថយខ្លួនទៅរស់នៅទីនោះ ។ ជាដំបូងគាត់បានចាប់ផ្ដើមរៀនសូត្រជាមួយពួកម៉ាស៊ី (ពួកអ្នកប្រាជ្ញនៅអៀរ៉ង់ដែលប្រើមន្តអាគមគាថា) និងពួកកាល់ដេ ដែលព្រះចៅស៊ែរក្សេ បានទុកឲ្យបំរើឪពុកគាត់, ដោយហេតុថាស្ដេចអង្គនេះ បានមកជ្រកនៅក្នុងលំនៅឋានរបស់ឪពុកគាត់ នៅពេលដែលទ្រង់បានចូលមកបង្កើតចំបាំងវាំងជល់ជាមួយពួកក្រិក ។ គឺដោយសារពួកអ្នកទាំងនេះហើយ ដែលដេម៉ូគ្រីតបានចេះអំពីទ្រឹស្ដីសាសនារបស់ព្រះ ហើយនិងតារាសាស្ត្រ ។ បន្ទាប់មកគាត់បានជាប់ចិត្តជាមួយនឹងទស្សនវិទូឡឺស៊ីព ដែលបានបង្ហាត់បង្រៀនគាត់ពីវិទ្យាសាស្ត្រពិសោធន៍ហ្វីស៊ិក ។ គាត់មានចំណូលចិត្តខាងក្រេបជញ្ជក់ចំណេះវិជ្ជាខ្លាំងពេកទៅ រហូតដល់គាត់បានសម្ងំតែម្នាក់ឯងរៀនរាល់ថ្ងៃ នៅក្នុងខ្ទមដែលសង់ឡើងកណ្ដាលសួនច្បារមួយ ។

ថ្ងៃមួយឪពុករបស់គាត់បាននាំសត្វគោមួយដើម្បីយកទៅបូជាយ័ញ្ញន៍ ហើយគាត់ក៏បានយកគោនោះ ទៅចងជាប់នឹងខ្ទមដែលកូនរបស់គាត់កំពុងសិក្សា ។ ដោយជាប់អាល័យនឹងការរៀនសូត្រខ្លាំងពេក ដេម៉ូគ្រីតមិនបានទាំងឮឪពុករបស់គាត់និយាយស្ដីថាម្ដេចផង ហើយគាត់មិនទាំងដឹងទៀតផងថា មានគេយកគោមួយមកចងនៅក្បែររូបគាត់ រហូតដល់ពេលឪពុកគាត់វិលត្រឡប់មកវិញជាលើកទី២ ហើយដាស់សតិអារម្មណ៍របស់គាត់ឲ្យចេញផុតពីការស្មឹងស្មាធិ ដោយប្រាប់គាត់ថា មានគោមួយនៅក្បែរនោះដែលត្រូវយកទៅធ្វើពិធីបូជាថ្វាយព្រះ ។

ដេម៉ូគ្រីត បន្ទាប់ពីបានសិក្សាស្វាធ្យាយន៍ដ៏យូរលង់ ក្រោមការដឹកនាំរបស់ឡឺស៊ីព ក៏បានសំរេចចិត្តធ្វើដំណើរទៅប្រទេសផ្សេងៗ ដើម្បីជជែកពិភាក្សាជាមួយនឹង

អ្នកប្រាជ្ញ ហើយនិងដើម្បីឲ្យបានជ្រួតជ្រាបក្នុងបញ្ញាញាណ នូវចំណេះវិជ្ជាដ៏ល្អៗគ្រប់បែបយ៉ាង ។ គាត់បានចែកសម្បត្តិកេរ្តិ៍មរតករបស់ឪពុក ជាមួយនឹងបងប្អូនប្រុសៗរបស់គាត់ទាំងអស់ដោយទទួលយកសំរាប់ខ្លួនគាត់ នូវចំណែកដែលមានជាប្រាក់ថ្វីបើជាចំណែកតិចតួចជាងគេក៏ដោយ ពីព្រោះចំណែកនេះបានជួយសំរួលយ៉ាងច្រើនដល់កិច្ចការពិសោធន៍ទស្សនវិជ្ជារបស់គាត់ និងក្នុងសោហ៊ុយធ្វើដំណើរ ។ គាត់បានត្រេចចរទៅដល់ប្រទេសអេយីព្ទ ដែលនៅទីនោះគាត់បានរៀនសូត្រអំពីរេខាគណិត (Géométrie) ។ តពីនោះទៅទៀត គាត់បានឆ្លងទៅប្រទេសអេត្យូពី, រួចឆ្លងទៅប្រទេសពែរ្ស, រួចចូលទៅក្នុងប្រទេសកាល់ដេ ។ នៅទីបំផុត ដោយហេតុតែមានការចង់ចេះចង់ដឹងខ្លាំងពេក គាត់ក៏បានធ្វើដំណើររហូតដល់ប្រទេសឥណ្ឌា ដើម្បីទៅក្រេបជញ្ជក់ចម្លងយកវិទ្យាសាស្ត្ររបស់ពួកតាឥសី (Le science des Gymno-sophistes ) ។ គាត់ចង់ដឹងចង់ស្គាល់អំពីអ្នកប្រាជ្ញនិងអ្នកប៉ិនប្រសប់ទាំងឡាយ ក៏ប៉ុន្តែចំពោះខ្លួនគាត់ផ្ទាល់ គាត់មិនចង់ឲ្យអ្នកណាដឹងឮពីរូបគាត់ទេ ។ គាត់បាននិយាយថា គាត់បានមករស់នៅ៤-១០ថ្ងៃនៅទីក្រុងអាតែ្ហន ដែលនៅទីនោះគាត់បានឃើញសូក្រាត តែមិនបានឲ្យសូក្រាតស្គាល់រូបគាត់វិញទេ ។ គឺជានិស្ស័យធម្មជាតិរបស់គាត់ ដែលចូលចិត្តរស់នៅលាក់ខ្លួនពួនអាត្មា ៖ មានពេលខ្លះគាត់បានស្វែងទៅជ្រកនៅក្នុងគុហារនិងក្នុងម៉ុងខ្មោច ក្នុងគោលបំណងកុំឲ្យនរណាម្នាក់រកគាត់ឃើញ ។ ទោះជាយ៉ាងនេះក្តី គាត់បានបង្ហាញខ្លួនម្តងនៅក្នុងវាំងរបស់ស្តេចដារីយុស... ហើយថ្ងៃមួយដែលក្សត្រអង្គនេះមានវិតក្កក្នុងព្រះទ័យជាអតិបរិមាដោយស្រីដែលទ្រង់បានស្រឡាញ់ជាងគេបំផុត នៅក្នុងចំណោមហ្វូងស្រីស្នំទាំងឡាយរបស់ទ្រង់នោះទើបនឹងបានស្លាប់ទៅ ដេម៉ូគ្រីតដើម្បីលួងលោមព្រះអង្គ ក៏បានសន្យានឹងទ្រង់ថានឹងធ្វើឲ្យនាងរស់ឡើងវិញ ល្គិកណាបើស្តេចដារីយុសអាចរកឲ្យគាត់បាន នៅគ្រប់រដ្ឋដែលគាត់កាន់កាប់ នូវមនុស្សបីនាក់ដែលមិនដែលជួបប្រទះនូវរឿងហេតុអ្វីដ៏គួរឲ្យទាស់ចិត្តសោះក្នុងមួយជីវិត ដើម្បីយកឈ្មោះពួកនោះមកចារលើផ្នូរខ្មោចរបស់ស្តេចស្រី ។ លទ្ធផលបានឲ្យដឹងថា នៅពាសពេញផ្ទៃដីអាស៊ីទាំងមូល គេមិនអាចរកបានសូម្បីមនុស្សតែម្នាក់ ដែលមានកិត្តិយសរស់នៅក្នុងសុភមង្គលឥតខ្ចោះ ដូចដែលបានចែងដេម៉ូគ្រីតនោះផងទេ។ ទស្សនវិទូរូបនេះក៏ឆ្លៀតឱកាសប្រាប់ដល់ស្តេចថា ជាកំហុសមួយធ្ងន់ណាស់ ដែលទ្រង់បានបណ្តោយខ្លួនឲ្យលិចលង់កប់ខ្លួនទៅក្នុងសេចក្តីអស់សង្ឃឹម ពីព្រោះគ្មានមនុស្សណាម្នាក់នៅលើភពផែនដីនេះ ដែលអាចចៀសវាងសេចក្តីទុក្ខលំបាកវេទនាបាននោះឡើយ ។

នៅពេលដែលដេម៉ូគ្រីតបានវិលត្រឡប់មករស់នៅក្នុងស្រុកអាប់ឌែរវិញ, គាត់បានរស់នៅឆ្ងាយពីគេពីឯងក្នុងសភាពក្រីក្រមែនទែន គឺដោយហេតុថា គាត់បានចា

យវាយទ្រព្យធនរបស់គាត់នោះខ្ទេចខ្ទីអស់រលីងទៅហើយ ។ ប្អូនប្រុសរបស់គាត់ឈ្មោះដាម៉ាសគុសក៏មានកាតព្វកិច្ចត្រូវផ្តល់របស់របរឲ្យគាត់ខ្លះៗ ដើម្បីជួយឲ្យគាត់មានលទ្ធភាពរស់នៅតទៅទៀត ។ មានច្បាប់ចែងមួយនៅក្នុងសម័យនោះ ដែលដាក់ទណ្ឌកម្មចំពោះជនដែលបានបំផ្លាញទ្រព្យសម្បត្តិរបស់ខ្លួន ដោយហាមប្រាមមិនឲ្យយកសពរបស់ជនប្រភេទនេះទៅកប់នៅក្បែរផ្នូរខ្មោចឪពុកម្តាយខ្លួនឡើយ ។ ដេម៉ូគ្រីតដែលស្ថិតនៅក្នុងលក្ខណៈបែបនេះ ហើយដែលមិនចង់ឲ្យក្រុមសត្រូវរបស់ខ្លួនអាចនិយាយថាអីថាវ៉ាន់បាន, ក៏បានសូត្រនៅចំពោះមុខប្រជាជន នូវស្នាដៃរបស់ខ្លួនមួយឈ្មោះថា Diacosme ។ អ្នកផងបានយល់ឃើញថា សៀវភៅនេះមានថ្វីដៃនឹងទេពកោសល្យជាពន់ពេក ទើបលើកលែងឲ្យគាត់រួចខ្លួនពីទម្ងន់ច្បាប់នៅខាងលើ ។ មិនត្រឹមតែប៉ុណ្ណោះ គេបានធ្វើអំណោយជាប្រាក់ដល់គាត់៥០០តម្លឹង ព្រមទាំងបានសង់រូបសំណាករបស់គាត់នៅទីសាធារណៈផ្សេងៗទៀតផង ។

* *
*

ដេម៉ូគ្រីតចេះតែពីសើចក្អាកក្អាយឥតមានឈប់ឈរ ។ សំណើចដែលពុំមានឈប់សំរាកនេះ គឺកើតឡើងដោយសារតែការសញ្ជឹងគិតដ៏ជ្រាលជ្រៅ និងសេចក្តីមេត្តាករុណាធម៌ ដែលគាត់មានចំពោះភាពទន់ខ្សោយ និងអំនួតរបស់មនុស្សលោក ដែលនាំគ្នាបង្កើតគំរោងការណ៍ចម្លែកៗច្រូងច្រាងរាប់រយរាប់ពាន់នៅក្នុងតំបន់មួយ ដែលគាត់យល់ថាអ្វីៗ ក៏ត្រូវពឹងពាក់ទៅលើការផ្សងសំណាង និងការជួបប្រទះគ្នាដោយចៃដន្យនៃអាតូម ។ យូវេណាល់ (អ្នកកវីក្រិក) ដែលបានធ្វើអត្ថាធិប្បាយពីទីក្រុងអាប់ឌែរបានពោលថា ៖ ខ្យល់អាកាសនៅទីនោះមានសភាពក្រាស់ឃ្មឹក ពិបាកដកដង្ហើមជាពន់ពេក, ចំណែកឯមនុស្សវិញមានលក្ខណៈឆ្កួតៗភ្លីភ្លើ ម្ល៉ោះហើយអ្នកនិពន្ធរូបនេះក៏បានទាញយោបល់ថា ហេតុដែលដេម៉ូគ្រីតបានកើតនៅក្នុងតំបន់នោះ គឺមកពីមនុស្សធំៗមានបញ្ញាខ្ពស់ខ្លះអាចមានលទ្ធភាពចេញមកពីទីកន្លែងដែលមានប្រជាជនរស់នៅដ៏សាមាន្យនិងក្រអឺតក្រទមជាទីបំផុត ។ អ្នកកវីដដែលបានពោលថា ដេម៉ូគ្រីតបានផ្ទុះសំណើចស្មើគ្នាទាំងអស់ ចំពោះសេចក្តីទុក្ខព្រួយ ក៏ដូចចំពោះសេចក្តីសប្បាយរបស់មនុស្សលោក ។ អ្នកកវីបានចាត់ទុកទស្សនវិទូរូបនេះ ជាដួងព្រលឹងមួយដ៏រឹងប៉ឹងមុតមាំ ដែលគ្មានអ្វីអាចធ្វើឲ្យរង្គោះរង្គើបាន... មិនត្រឹមតែប៉ុណ្ណោះបានចាត់ទុកថាជាមនុស្សម្នាក់ ដែលបានយកព្រេងវាសនាមកចងជាប់នឹងជើងខ្លួនឯងមិនឲ្យរះពីរទៅណារួច ។

ពួកអ្នកស្រុកអាប់ឌែរ លុះបានឃើញគាត់សើចគ្រប់ពេលវេលាដូច្នេះ ក៏នឹកស្មា

នថាគាត់ជាមនុស្សឆ្កួត ។ ពួកគេក៏បានបញ្ជូនមនុស្សឲ្យទៅរកលោកគ្រូពេទ្យអ៊ីប៉ូក្រាត ដើម្បីឲ្យមកព្យាបាលរោគរបស់គាត់ ។ អ៊ីប៉ូក្រាតក៏បានមកដល់ទីក្រុងអាប់ឌែរ ដោយបានយកថ្នាំសង្កូវរបស់គាត់មកជាមួយផង ។ ជាដំបូងគាត់បានយកទឹកដោះឲ្យដេម៉ូគ្រីតផឹក ។ ដេម៉ូគ្រីតសញ្ជប់សញ្ជឹងមើលទឹកដោះរួចពោលថា ៖ « នេះគឺជាទឹកដោះរបស់ពពែខ្មៅ ដែលទើបនឹងកើតកូនបានម្តង » ។ អ៊ីប៉ូក្រាតមានការភ្ញាក់ផ្អើលស្រទ្បាំងកាំង... គាត់ងឿងឆ្ងល់ថាហេតុអ្វីជននេះអាចដឹងពីការពិតលាក់កំបាំងនោះបាន ។ លោកគ្រូពេទ្យក៏បានពិភាក្សាជាមួយនឹងទស្សនវិទូ ។ គាត់មានការស្ងើចសរសើរចំពោះបញ្ញាញាណនិងចំណេះដឹងដ៏ជ្រាលជ្រៅរបស់ដេម៉ូគ្រីត ។ គាត់បានពោលថា គឺពួកអ្នកស្រុកអាប់ឌែរទៅវិញទេ ដែលត្រូវការថ្នាំសង្កូវ... គឺមិនមែនទស្សនវិទូដែលគាត់មានភារៈមកព្យាបាលនោះឡើយ ។ អ៊ីប៉ូក្រាតបានវិលត្រឡប់ទៅវិញដោយមានការវង្វេងវង្វាន់ស្មារតី ។

★ ដេម៉ូគ្រីត, ជាមួយនិងលោកគ្រូរបស់គាត់គឺស៊ីព បានយល់ថា ទ្រឹស្តីដំបូងនៃវត្ថុធាតុទាំងអស់ គឺហ្វូងអាតូម ហើយនិងសភាពលំហទទេ ។

★ អ្វីៗក៏ដោយមិនអាចចេញរូបរាងមកពីទទេ... ហើយអ្វីៗក៏ដោយក៏មិនអាចវិលត្រឡប់ទៅជាទទេវិញនោះបានដែរ ។

★ ចំពោះអាតូមវិញ គឺជាធតុទីចុងប៉ូចបំផុត ដែលមិនអាចបែងចែក ឬទទួលនូវសភាពពុករលួយបាន ហើយក៏មិនអាចប្រែរូបទៅជារបស់ផ្សេង... ពីព្រោះសភាពរឹងប៉ឹងស័ក្តិសិទ្ធិនៃធាតុអាតូម ដែលមានអ្វីអាចកាច់បំបាក់បានៗការពាររបស់នេះមិនឲ្យប្រែក្លាយរូប ។

★ គាត់បានអះអាងថា ដោយសារហ្វូងអាតូមទាំងនេះហើយ ទើបវត្ថុធាតុហើយនិងពិភពផ្សេងៗ បានត្រូវឧប្បត្តិកឡើង ហើយអាចរស់បានមួយរយៈពេល ៖ ក៏ប៉ុន្តែសំណល់នៃវត្ថុទាំងនោះ ក៏បានកកើតឡើងជាវត្ថុផ្សេងថ្មីៗទៀត ។

★ សូម្បីតែព្រលឹងមនុស្ស ត្រូវបានគាត់ចាត់ទុកជាបញ្ញាញាណនោះ ក៏បានត្រូវបង្កបង្កើតឡើងដោយសារហ្វូងអាតូមទាំងនេះដែរ... ក៏ដូចគ្នានឹងព្រះអាទិត្យ, ព្រះច័ន្ទ និងតារាទាំងឡាយដែរ ។

★ ហ្វូងអាតូមទាំងនេះចេះតែមានចលនាវិលចុះឡើងជានិច្ចជាកាល... ជាហេតុបណ្តាលឲ្យអ្វីៗដែលមានកំណើតក្នុងលោកនេះ ចេះតែបន្តកំណើតដល់គ្នាយ៉ាងរពុយ ។ ហើយដោយសារតែចលនាវិលចុះឡើងនេះជាចលនាដដែលៗ... គឺជាប្រធានសាច់រឿងមួយដែលដេម៉ូគ្រីតយល់ថាមកពីដំណើព្រហ្មលិខិត ហើយដែលប្រទាញឲ្យគាត់យល់ថា វត្ថុសព្វយ៉ាងដែលកើតមានឡើងក្នុងលោកនេះ គឺមានដោយសារតែការចាំបាច់ ។

អេពីគួរ ( ទស្សនវិទូក្រិកម្នាក់ទៀត ) ដែលបានបង្កើតទ្រឹស្តីរបស់គាត់ ដោយពឹងផ្អែកទៅលើមូលដ្ឋានគំនិតប្រូដេម៉ូគ្រីតផងដែរហើយដែលមិនបានទទួលស្គាល់ថា ការចាំបាច់ជាច្បាប់ចាត់ចែងត្រួតត្រាពិភពលោក ក៏មានកាតព្វកិច្ចត្រូវបង្កើតចលនាបែកឃ្លាតរបស់អាតូម (Mouvement de déclination) ដែលត្រូវយកទៅបកស្រាយពេញមួយជីវិតរបស់គាត់ ។

★ ដេម៉ូគ្រីតបានបញ្ជាក់ថា ធាតុនៃព្រលឹងបានត្រូវរាយប៉ាយពេញពាសទីកន្លែងរបស់រាងកាយផង គឺហេតុដូច្នេះហើយបានជាយើងចេះតែមានមនោសញ្ចេតនានៅគ្រប់ទីកន្លែងនៃរូបកាយរបស់យើង ពីព្រោះអាតូមនិមួយៗនៃព្រលឹង វាត្រូវទាក់ទងជាប់គ្នាជាមួយនឹងអាតូមនៃរូបកាយនិមួយៗផងដែរ ។

★ អំពីហ្វូងតារាវិញ ដេម៉ូគ្រីតបានយល់ថា ផ្កាយទាំងឡាយនោះ មានចលនានៅក្នុងវាលហើយមហាអាកាស ដែលពោរពេញដោយសេរីភាពបរិបូណ៌... ដូច្នេះទៅគឺគ្មានជុំមូលហើយរឹង ដែលចងពួកគេឲ្យជាប់ជាចំណងនោះទេ ។ មានចលនាតែមួយមុខគត់ គឺចលនាឆ្ពោះទៅទិសខាងលិច ។ តារាទាំងអស់នោះត្រូវប៉ើងទៅជាមួយនឹងខ្យល់គួច ហើយដែលមានផែនដីជាមជ្ឈមណ្ឌល ។ ហើយផ្កាយនិមួយៗ មានចលនាកាន់តែយឺតៗទៅ បើគេចូលមកដល់ជិតផែនដី ពីព្រោះកម្លាំងវិលជុំវិញផែនដីនោះ កាន់តែមានលក្ខណៈទន់ខ្សោយទៅ បើកាលណាគំនួចនេះខិតមកដល់ក្បែរមជ្ឈមណ្ឌល ។ ដូច្នេះទៅពួកក្រុមផ្កាយឯណា ដែលមានលំនាំធ្វើដំណើរទៅទិសខាងកើត, តាមពិតកំពុងតែធ្វើដំណើរដោយយឺតៗឆ្ពោះទៅទិសខាងលិច, រីឯចំណែកផ្កាយដែលមានលំនាំដូចជានឹងថ្កល់នោះ តាមពិតមានល្បឿនលឿនលើសឆ្ងាយពីពួកអ្នកដទៃ គឺអាចធ្វើដំណើរវិលមួយជុំរបស់ខ្លួនបានក្នុងរយៈពេល២៤ម៉ោង ។ ថ្ងៃដែលត្រូវមានដំណើរយឺតយ៉ាវបន្តិច ក៏បានសំរេចការត្រេចចរវិលមួយជុំរបស់ខ្លួនអស់រយៈ២៤ម៉ោងនិង៤-១០នាទី ។ រីឯព្រះច័ន្ទវិញដែលមានដំណើរយឺតជាងតារាឯទៀតៗទាំងអស់ ក៏បានសំរេចដំណើររបស់ខ្លួនរហូតដល់២៥ម៉ោង ÷ ម្ល៉ោះហើយព្រះច័ន្ទហាក់ដូចជាគ្មានកំរើករំពើកដោយចលនាខ្លួនឆ្ពោះទៅរកផ្កាយនៅទិសខាងកើតនោះទេ... ប៉ុន្តែព្រះច័ន្ទត្រូវឃ្លាតឆ្ងាយដោយផ្កាយខាងលិច ដែលវិលបានមួយជុំមកទាន់ដំណើរអ្នកក្រោយគេនេះ ក្នុងរយៈពេល៣០ថ្ងៃក្រោយមក ។

* * *

គេបានពោលថា ចំណូលចិត្តដ៏ខ្លាំងហួសនិស្ស័យក្នុងការសិក្សាស្វាធ្យាយន៍បានបណ្តាលឲ្យដេម៉ូគ្រីត ក្លាយទៅជាខ្វាក់ភ្នែកទាំងសង្ខាងនៅពេលចុងចប់ទៅ ។

ម៉្លោះហើយគាត់ក៏អស់មានសមត្ថភាពក្នុងការពិសោធន៍មុខវិជ្ជាអ្វីផ្សេងៗទៀត ។ គាត់បានយកថាសស្ពាន់មួយបញ្ចាំងពន្លឺថ្ងៃចូលក្នុងភ្នែករបស់គាត់... ដូច្នេះហើយកំដៅនេះក៏បានបណ្តាលឲ្យគាត់មើលអ្វីលែងឃើញទាំងអស់ ។

ដោយដេម៉ូគ្រីតដឹងថា ខ្លួនគាត់ចូលវ័យចាស់ជរាទន់ខ្សោយរខេករខាកមកដល់ក្បែរសេចក្តីស្លាប់រួចកាលណាហើយ គាត់ក៏បានដឹងពីសេចក្តីបារម្ភរបស់ប្អូនស្រីរបស់គាត់ ដែលមានការភ័យព្រួយខ្លាចគាត់ត្រូវស្លាប់មុនពេលបុណ្យសេរ៉េះ ហើយខ្លាចក្រែងមរណៈទុក្ខនោះ នឹងធ្វើឲ្យពួកគេខកខានមិនបានបំពេញកម្មវិធីថ្វាយព្រះស្រីក្រិក ។ ដេម៉ូគ្រីតក៏បានឲ្យគេយកនំបុ័ងក្តៅមកដាក់រុំជុំវិញខ្លួនគាត់... ពីព្រោះក្លិននំបុ័ងធ្វើឲ្យគាត់បានសុខស្រួលដល់កាយ ហើយជួយធាតុកំដៅធម្មជាតិរបស់គាត់ឲ្យមានដំណើរបន្តទៅទៀត ។ នៅពេលពិធីបុណ្យបីថ្ងៃបានចប់សព្វគ្រប់កាលណា ដេម៉ូគ្រីតក៏បានឲ្យគេដោះនំបុ័ងចេញ ហើយគាត់ក៏បានត្រូវដាច់ខ្យល់ភ្លាមមួយរំពេច ។ នៅពេលនោះ គាត់បានចូលក្នុងអាយុ១០៩ឆ្នាំទៅហើយ យោងតាមមតិរបស់ប្រជាជនទូទៅ ៕

❏ ❏

❏

# ជីវិតរបស់ឌីយ៉ូសែន
# DIOGÈNE

បានទទួលមរណភាពនៅក្នុងឆ្នាំទី-១ នៃអូឡាំព្យ៉ាដ ទី១១៤, ក្នុងជន្មាយុ ៩០ឆ្នាំ ។ ដូច្នេះគាត់មានកំណើតនៅក្នុងឆ្នាំទី៣នៃអូឡាំព្យ៉ាដទី៩១ ។

ឌីយ៉ូសែន នៅក្នុងក្រុមបក្សស៊ីនីក ( ក.ក.ន ៖ Diogène le Cynique ៖ អាចចាត់ទុកបានថា ជាឌីយ៉ូសែននៃក្រុមបក្សស្នូម, សូមកុំឲ្យច្រឡំជាមួយនឹងឌីយ៉ូសែន-ឡាអ៊ែរត ), ជាកូនប្រុសរបស់ អ៊ីស៊ីស៊ីយូស, មានកំណើតនៅស៊ីណូព ដែលជាទីក្រុងរបស់ប៉ាប្លាហ្គោនី, ក្នុងកម្លុងអូឡាំព្យ៉ាដទី៩១ ។ ឌីយ៉ូសែនបានត្រូវគេចោទថា បានលួចធ្វើប្រាក់ក្លែងក្លាយជាមួយនឹងឪពុករបស់ខ្លួន ។ អ៊ីស៊ីស៊ីយូសបានត្រូវគេចាប់ខ្លួនបញ្ចូលឃុំឃាំងនៅក្នុងគុក... ហើយគាត់ក៏បានទទួលសេចក្ដីស្លាប់នៅទីនោះប-ណ្ដោយទៅ ៖ ឌីយ៉ូសែនមានការភ័យតក់ស្លុតជាខ្លាំង ក៏បានបោលរត់ចេញឥតងាកក្រោយឆ្ពោះទៅទីក្រុងអាតែ្កន ។ នៅពេលដែលគាត់បានមកដល់ទីក្រុងនេះភ្លាមកា-លណា ក៏បានស្ទាត់ទៅជួបទស្សនវិទូអង់ទីសតែន ដែលបានបណ្ដេញគាត់ឲ្យត្រឡប់ទៅវិញយ៉ាងស្វាហាប់, ពេលបានរុញច្រានគាត់នឹងដំបង, គឺដោយហេតុថា អង់ទីតែនបានសម្រេចថាមិនទទួលយកសាវ័កណាម្នាក់ថែមទៀតឡើយ តទៅអនាគត។ ក៏ប៉ុន្តែឌីយ៉ូសែនគ្មានសេចក្ដីតក់ស្លុតសោះឡើយ នៅក្នុងរឿងនេះ ។ គាត់បានឱនក្បាលហើយពោលទៅកាន់អង់ទីសតែនថា ៖ «វាយមក, វាយមក, លោកគ្រូមិនអាចរកដំបងឯណាឲ្យរឹងល្មមសមគួរដែរអាចបញ្ចៀសខ្ញុំ ឲ្យចេញឆ្ងាយពីលោកគ្រូបានទេ ...បើដរាបណាលោកគ្រូនៅតែនិយាយ...» ។ អង់ទីសតែន ដោយទន់ចិត្តចំពោះការរឹងរូសមានះរបស់ឌីយ៉ូសែន ក៏បានសុខចិត្តទទួលយល់ព្រមយកជននេះធ្វើជាសិ-ស្សរបស់គាត់ទៅហោង ។

ឌីយ៉ូសែនមានកាតព្វកិច្ចត្រូវរស់នៅក្នុងសេចក្ដីក្រីក្រលំបាកតោកយ៉ាកជាខ្លាំង, ដូចជាមនុស្សម្នាក់ដែលគេបានបណ្ដេញចេញពីស្រុករបស់ខ្លួន, ហើយដែលមិនបានទទួលជំនួយអ្វីសោះពីគ្រប់ទីកន្លែង ។
ថ្ងៃមួយ, គាត់បានសង្កេតឃើញសត្វកណ្ដុរតូចមួយដែលរត់សប្បាយពីឆ្វេងទៅស្ដាំ, ដោយគ្មានព្រួយបារម្ភនឹងរាត្រីដែលធ្លាក់មកដល់... ដោយគ្មានចំបាច់ត្រូវរកការ

បន្ទប់សម្រាប់ដេកពួន, ដោយគ្មានលំបាកខ្វល់ខ្វាយនឹងត្រូវរកចំណីបរិភោគថែមទៀតផង ។ ទិដ្ឋភាពនេះក៏បានលួងលោមចិត្តរបស់គាត់មានសេចក្ដីធូរស្រាលចំពោះទុគ្គតភាពរបស់ខ្លួនឯង ។ គាត់ក៏បានសម្រេចថាពីថ្ងៃនោះតទៅនឹងរស់នៅក្នុងសេចក្ដីស្ងប់ស្ងៀម គ្មានការបង្ខំចិត្តខ្លួនឯង, ដោយលែងត្រូវការរបស់អ្វីៗទាំងអស់នៅក្នុងលោកនេះ លើកលែងតែរបស់ណាដែលជាគ្រឿងចាំបាច់ ដើម្បីកុំឲ្យស្លាប់តែប៉ុណ្ណោះ ។ គាត់ក៏បានដេរអាវម៉ង់តូឱុបរបស់គាត់... ដើម្បីលូនចូលតណ្ដប់ឲ្យបានកក់ក្ដៅ ធ្វើជាភួយផង ធ្វើជាគ្រែដេកផង ។ សម្បត្តិទ្រព្យធនធានរបស់គាត់ទាំងប៉ុន្មានបូករួមទៅឃើញមានតែដំបងឈើច្រត់មួយ, ថង់យាមមួយ, ហើយនិងត្រឡោកមួយសម្រាប់ផឹកទឹកតែប៉ុណ្ណោះ ។ គាត់មិនដែលដើរទៅណាមកណា ដោយភ្លេចសណ្ដោងយកគ្រឿងសំខាន់អស់ទាំងនេះទៅតាមជាប់ជាមួយនឹងខ្លួនគាត់ទេ ។ ក៏ប៉ុន្តែគាត់តែងប្រើប្រាស់ដំបងតែក្នុងពេលណាដែលគាត់ត្រូវដើរឆ្លងកាត់ស្រែចំការ... ឬក៏នៅក្នុងពេលណាដែលគាត់ត្រូវទទួលការរំខាន ។ គាត់បានពោលថា ពួកជនពិការពិតប្រាកដ មិនមែនជាពួកថ្លង់ឬខ្វាក់នោះទេ ក៏ប៉ុន្តែគឺជាពួកដែលខ្វះថង់យាមឯណោះទេវិញ ។ គាត់តែងដើរជើងទទេ ហើយមិនដែលពាក់ស្បែកជើងសង្រែក ឬស្បែកជើងផ្ទាត់អ្វីម្ដងណានឹងគេទេ, បើទោះជាក្នុងពេលនោះ មានធ្លាក់ទឹកកកពាសពេញដីក៏ដោយ ។ គាត់បានខំប្រឹងប្រែងបរិភោគសាច់ឆៅផងដែរ...ក៏ប៉ុន្តែមិនបានសម្រេចក្នុងកិច្ចការនេះឡើយ ។

ឌីយ៉ូសែនបានស្នើរអង្វរករដល់ជនម្នាក់ដែលគាត់បានស្គាល់ ឲ្យចែកទីកន្លែងកៀនកោះតូចមួយនៅក្នុងគេហដ្ឋានរបស់ខ្លួនគេ... ដើម្បីស្រណុកគាត់ថយខ្លួនចូលមកសម្រាកម្ដងម្កាល, ក៏ប៉ុន្តែដោយជននេះមានការយឺតយ៉ាវពេក ក្នុងការតបឆ្លើយចំពោះគាត់ជាវិជ្ជមាន (ដោយពោលថា អ៊ឺ-អើ) គាត់ក៏បានសម្រេចយកធុងមួយធ្វើជាទីលំនៅ, គឺជាធុងមួយដែលគាត់បានព្រមៀលរហូតនៅពីមុខគាត់, ហើយគាត់មិនដែលមានភូមិឋានផ្ទះសំបែងអ្វីទៀតក្រៅពីធុងនេះទេ ។

នៅចំពេញរដូវក្ដៅ, ក្នុងខណៈដែលព្រះសុរិយាបាចសាចកម្មរស្មីបរិបូរណ៍ទៅលើវាលស្រែហាក់ដូចជាគេដុត, ឌីយ៉ូសែនបែរជាទៅដេកប្រាស់នទាលនៅក្នុងដីខ្សាច់ដ៏ក្ដៅគគុក, ផ្ទុយទៅវិញនៅចំកណ្ដាលរដូវត្រជាក់ គាត់បានទៅឱបក្រសោបរូបចម្លាក់ពោរពាសដោយទឹកកក...ដើម្បីទម្លាប់ខ្លួនគាត់ឲ្យទទួលសេចក្ដីឈឺចាប់វេទនាអំពីធាតុក្ដៅ និងធាតុត្រជាក់ដូចគ្នា ។

គាត់តែងមើលងាយមនុស្សផងទាំងឡាយដោយគ្មានរើសមុខ ។ គាត់បានចាត

ទុកប្លាតុងនិងក្រុមសាវ័កនៃទស្សនិទូរម្នាក់នេះថា ជាពួកជនចាយវាយបំផ្លិចបំផ្លាញ ដោយឥតបើគិត... ជាពួកចូលចិត្តម្ហូបឆ្ងាញ់ ។ គាត់តែងចាត់ទុកថា ពួកវាគ្មិន ឬពួកអ្នកប្រសប់ថ្លែងវាចា ...ថាសុទ្ធសឹងតែជាពួកខ្ញុំកញ្ជះនៃប្រជាពលរដ្ឋ ។

គាត់បានពោលថាម្កុដរបស់ស្តេច ជាសញ្ញានៃកិត្តិយសនិងកិត្តិនាម ដែលមានលក្ខណៈទន់ខ្សោយឬស្រួយប្រហែលគ្នានឹងពងឬពពុះទឹក...ដែលគ្រាន់តែចេញសញ្ញារូបរាងឡើងកាលណាក៏ផ្ទុះបែកទៅវិញទៅហើយ ។ ចំណែកការសំដែងល្ខោននិងសិល្បៈរបាំសម្រាប់កំដរអារម្មណ៍ទាំងប៉ុន្មាន គឺសុទ្ធតែជាអំពើអស្ចារ្យឬជាអព្ភូតហេតុរបស់ពួកមនុស្សឆ្កួត ។ ហើយនៅទីបំផុតទៅ អ្វីៗក៏មិនអាចគេចចៀសផុតបានពីបញ្ញាញាណនៃការរិះគន់ពេបជ្រាយរបស់គាត់ ។

... ថ្ងៃមួយ ពេលដែលឌីយ៉ូសែនដើរឆ្លងកាត់តាមស្រុកអ៊ីស៊ីន, គាត់បានត្រូវពួកចោរចាប់នាំខ្លួនយកទៅលក់នៅទីផ្សារសាធារណៈនៅស្រុកក្រែត។ គាត់ហាក់ដូចជាគ្មានវិវរល់ខ្វល់ខ្វាយនៅក្នុងរឿងនេះសោះ ។ មិនត្រឹមតែប៉ុណ្ណោះ គាត់បញ្ចេញឫកពាររំភើយគឺមិនបានប្រឹងប្រែងរំដោះខ្លួនអំពីសភាពការណ៍ទាល់ច្រក នេះថែមទៀតផង ។ គាត់ឃើញជនម្នាក់ឈ្មោះសេនីញ៉ាដដែលមានរូបរាងធំធាត់ ស្លៀកពាក់ស្អាតបាតដើរឆ្លងកាត់តាមទីនោះ, គាត់ក៏ពោលឡើងថា ៖

– ត្រូវតែលក់ខ្ញុំទៅឲ្យជនម្នាក់នេះ, ពីព្រោះបើតាមខ្ញុំមើលទៅ ជននេះទំនងដូចជាត្រូវការរកចៅហ្វាយម្នាក់ ។

នៅពេលដែលសេនីញ៉ាដដើរចូលមកជិត ដើម្បីតថ្លៃរូបគាត់, គាត់ក៏ពោលទៅកាន់ជននេះថា ៖

– មក, អាកូន, មកតថ្លៃ ទិញយកមនុស្សម្នាក់ពិត ។

នៅពេលដែលគេសួរគាត់ថា តើគាត់ចេះធ្វើអ្វីខ្លះ, គាត់បានឆ្លើយថា គាត់មានទេពកោសល្យខាងបង្គាប់បញ្ជារ ។ នែហ៍ហេរ៉ូត៍ ! (កកន ៖ ហេរ៉ូត៍ ជាជនឃោសនាសម្រាប់ផ្សាយព័តមានជាសាធារណៈ) ចូរផ្សព្វផ្សាយដំណឹងឲ្យអ្នកផងដឹងថា បើនរណាម្នាក់ត្រូវការចង់បានចៅហ្វាយនាយ ...ត្រូវឲ្យមកទិញរូបខ្ញុំចុះ ។

ជនដែលមានភារៈលក់រូបគាត់បានហាមប្រាមគាត់មិនឲ្យអង្គុយ ៖

– យ៉ាងម៉េចក៏បានដែរ, ឌីយ៉ូសែនថ្លែងវាចា, នៅពេលដែលគេទិញសត្វត្រីតើមាននរណាដែលខ្វល់ខ្វាយនឹងវាឈរ ឬអង្គុយឬទេ ? ហើយខ្ញុំឆ្ងល់ខ្លាំងណាស់ គ្មាននរណាម្នាក់ដែលទិញគំរបឆ្នាំងណាមួយ ដោយមិនបានយកទៅគោះផ្ទៀងផ្ទាត់យ៉ាងល្អិតល្អន់មើលថាតើដែកវាល្អឬមិនល្អផងទេ, ប៉ុន្តែដល់គេទិញរហូតដល់

មនុស្សក៏ស្រាប់ តែគេបែរជាឈរមើលទៅវិញ? ចម្លែកមែនៗ !

នៅពេលដែលគេបានតថ្លៃគ្នាត្រូវរូវរួចអស់ហើយ គាត់ក៏បានពោលទៅកាន់សេនីញ៉ោដដូច្នេះថា ៖

– បើទោះជាខ្លួនអញនៅពេលនេះជាខ្ញុំកញ្ជះរបស់ឯងក៏ដោយចុះ, ឯងត្រូវរៀបចំខ្លួនឲ្យហើយជាស្រេច ដើម្បីធ្វើអ្វីៗឲ្យស្របតាមគោលបំណងរបស់អញ ។ ពីព្រោះថា បើទោះជាអញបម្រើឯង ក្នុងនាមជាពេទ្យហ្មរក្តី ឬក៏ជាភូឈ្មួយរបស់ឯងក្តី ក្នុងប្រភេទណាក៏ដោយ ក្នុងថានៈរបស់អញជាខ្ញុំកញ្ជះក៏ដោយ ឬជាមនុស្សសេរីក៏ដោយ, ឯងត្រូវតែស្តាប់បង្គាប់បញ្ជារបស់អញ...។

សេនីញ៉ោដក៏បានប្រគល់កូនរបស់ខ្លួនច្រើនគ្នាឲ្យឱយ៉ូសែនបង្ហាត់បង្រៀន ។ ឱយ៉ូសែនបានខំប្រឹងយកចិត្តទុកដាក់ក្នុងកិច្ចការនេះជាខ្លាំង ។ គាត់បានបង្ហាត់បង្រៀនក្មេងទាំងនេះ ឲ្យទន្ទេញចាំមាត់នូវភាគល្អៗរបស់អ្នកកវីចម្រុះ, និងសេចក្តីបំព្រួញទស្សនវិជ្ជាដែលគាត់បានតុបតែងផ្ទាល់ដៃ សម្រាប់ពួកក្មេងៗទាំងនេះ ។ គាត់បានបង្ហាត់បង្រៀនក្មេងទាំងនេះ ឲ្យហ្វឹកហ្វឺនក្នុងការបោកចំបាប់, ក្នុងការបរបាញ់, ក្នុងការជិះសេះ, ឲ្យថ្វឹកជំនាញក្នុងការបាញ់ព្រួញ និងឈើពាម ។ គាត់ទម្លាប់ក្មេងទាំងនេះឲ្យរស់នៅក្នុងសភាពធម្មតាជាទីបំផុត, ឲ្យផឹកតែទឹក នៅក្នុងពេលបរិភោគម្ហូបអាហារជាប្រក្រតី ។ គាត់បានស្នើរសុំឲ្យគេកោរក្មេងទាំងនេះរហូតដល់ស្បែក ។ គាត់នាំក្មេងទាំងនេះ ដើរតាមថ្នល់ជាមួយគាត់, ដោយឲ្យពួកវាស្លៀកពាក់របៀបអន់ខ្សោយជាទីបំផុត ជួនកាលឥតមានអាវព្រមទាំងគ្មានស្បែកជើងផងទេ ។ ចំណែកពួកក្មេងទាំងនេះវិញ មានសេចក្តីស្រឡាញ់ពេញចិត្តនឹងឱយ៉ូសែនខ្លាំងណាស់... ហើយតែងតែពោលពាក្យសរសើរអំពីឱយ៉ូសែន ប្រាប់ឪពុកម្តាយរបស់វាជានិច្ចជាកាល ។ ( កកន ៖ ថ្ងៃក្រោយទៅ អ្នកនិពន្ធបារាំងម្នាក់ដ៏ល្បីល្បាញនៅសតវត្សរ៍ទី១៨ សង់-សាក់-រូស្សូ ( Jean-Jacques Rousseau ) ... ដែលមានឥទ្ធិពលយ៉ាងខ្លាំងជាងគេទៅលើបដិវត្តន៍បារាំងនៃឆ្នាំ១៧៨៩ បានសរសេរសៀវភៅអប់រំក្មេងមួយមានឈ្មោះថា «អេមីល», ដែលបានចម្លងយកមូលដ្ឋានអប់រំរបស់ឱយ៉ូសែនទាំងស្រុង ។ នៅក្នុងជីវិតសង់-សាក់រូស្សូផ្ទាល់ ក៏មានចម្លងរបៀបរស់នៅមួយភាគធំអំពីអ្នកប្រាជ្ញឱយ៉ូសែនផងដែរ ... ជាពិសេសនៅពេលដែលរូស្សូគាត់បែកប្រាជ្ញាសរសេរសៀវភៅមានកេរ្តិ៍ឈ្មោះ ខួរខ្មារនៅក្នុងផ្ទៃអឺរុប ។ ក៏ប៉ុន្តែនៅក្នុងសៀវភៅដែលមានចំណងជើងថា ៖ «សេចក្តីសារភាព» រូស្សូបានសរសេរដូច្នេះថា ៖ «ខ្ញុំនឹងបំពេញកិច្ចការមួយ ដែលពុំដែលមាននរណាម្នាក់ធ្លាប់ធ្វើដូច្នេះព្រមទាំងការអនុវត្តន៍ទ្រិស្តីរបស់ខ្ញុំ ក៏នឹងពុំមាននរណាម្នាក់ទៀតធ្វើដូចខ្ញុំឡើយ, ខ្ញុំតែម្នាក់គត់, ខ្ញុំយល់ចិត្តខ្លួនឯង... ហើយខ្ញុំស្គាល់មនុស្សផងទាំងឡាយដទៃទៀត ។ ខ្ញុំចង់

បង្ហាញមនុស្សម្នាក់ដ៏ពិត ប្រាកដចេញពីពុម្ពធម្មជាតិជាក់ស្តែងតែម្តង ហើយមនុស្សម្នាក់នោះ គឺខ្លួនខ្ញុំនេះឯង... Je forme une entreprise qui n'a pas d'exemples et dont l'exécution n'aura point d'imitateurs. Moi seul, je sens mon coeur et je connais les hommes . Je veux mon-trer un homme dans la vérité de la nature. Et cet homme, ce sera moi .- » ។ ហេតុអ្វីបានជាវរជនដ៏មានកេរ្តិ៍ឈ្មោះ ឬអ្នកប្រាជ្ញល្បីៗមិនសូវដែលបានសារភាពថា ខ្លួនឯងបានទទួលតម្រេះពីអ្នកដទៃ ? ពីព្រោះមនុស្សអ្នកធំ, ឬអ្នកមានកេរ្តិ៍ឈ្មោះល្បីដូចរូសូច្រើនតែស្រវឹងបុណ្យចង់ធ្វើព្រះ ... កើតមកចេះឯង, គ្មានគ្រូបាអាចារ្យឯណាប្រដៅប្រដៅ ហើយក៏គ្មានឪពុកថែមទៀតផង...) ។

...នៅពេលដែលឱយ៉ូសែនកំពុងតែធ្លាក់ខ្លួនទៅក្នុងទាសភាពបែបនេះ មានមិត្តភ័ក្តិមួយក្រុមបានរៀបចំគំរោងការណ៍រំដោះគាត់ឲ្យមានសេរីភាពមកវិញ ។« ពួកអ្នកឯងកំពុងតែឆ្កួតឡប់ៗទេដឹង ? គាត់បានពោលទៅកាន់អ្នកទាំងនេះ ។ តើអស់លោកចំអកឲ្យខ្ញុំ ឬក៏យ៉ាងណា ៖ ចូរដឹងថាសត្វរាជសីហ៍ វាមិនដែលធ្វើខ្ញុំកញ្ជះរបស់ពួកអ្នកណាដែលចិញ្ចឹមវានោះទេ ? ផ្ទុយទៅវិញ គឺពួកអ្នកចិញ្ចឹមនោះទៅវិញទេ ដែលជាខ្ញុំកញ្ជះរបស់វា » ។

❑❑❑

⭑✍ ថ្ងៃមួយ, ឱយ៉ូសែនបានឮជនឃោសនាម្នាក់ដែលប្រកាសផ្សព្វផ្សាយដំណឹង ថាជនឈ្មោះឱយ៉ូស៊ីពបានទទួលជ័យជំនះទៅលើមនុស្សដទៃទៀតនៅក្នុងការប្រកួតកីឡាអូឡាំពិក។

– នែហ៍សំឡាញ់, ឱយ៉ូសែនពោលទៅកាន់ជនឃោសនា, ចូរឯងនិយាយថាជាពួកជនកញ្ជះគេ និងជាពួកជនអភ័ព្វវិញទើបត្រូវ ។ គឺអញឯណោះទៅវិញទេ ដែលមានជោគជ័យទៅលើមនុស្សម្នាផងទាំងឡាយ ។

⭑✍ នៅពេលដែលគេនិយាយទៅកាន់គាត់ថា ៖ « អ្នកឯងចាស់ហើយ, ល្មមដល់ពេលឈប់សម្រាកហើយទេដឹង?», គាត់ក៏បានឆ្លើយតបវិញថា ៖ «យ៉ាងម៉េច, បើខ្ញុំជាអ្នករត់ប្រណាំងម្នាក់, តើត្រូវបោះបង់ខ្ញុំចោលនៅពេលចុងចប់នៃការប្រកួតរបស់ខ្ញុំ ឬ ? តើលោកអ្នកមិនយល់ថា ខ្ញុំគួរតែខំប្រឹងប្រែងឲ្យបានចប់ចុងចប់ដើមឬទេ ឬក៏យ៉ាងណា ? » ។

⭑✍ ក្នុងពេលដែលគាត់កំពុងតែដើរលេងកំសាន្តតាមផ្លូវថ្នល់, គាត់បាន

សង្កេតឃើញបុរសម្នាក់ដែលបានធ្វើឲ្យធ្លាក់នំប៉័ង ហើយជននេះមានសេក្ដីអៀនខ្មាស់ជាខ្លាំងក្នុងការឈោងរើសយករបស់នេះមកវិញ ។ ឱយ៉ូសែនក៏បានរើសអំបែងដបមួយយកមកចងបណ្ដើរអាក្រោសពេញពាសទីក្រុង ដើម្បីបង្ហាញឲ្យឃើញថាគេមិនត្រូវមានសេចក្ដីអៀនខ្មាស់សោះឡើយក្នុងការដែល គេខំប្រឹងប្រែងកុំឲ្យបង់ខាតអ្វីទាំងអស់ ។

– ខ្ញុំក៏ដូចជាអ្នកលេងភ្លេងដ៏ប្រសើរម្នាក់, ខ្ញុំបោះបង់ចោលសម្លេងដ៏ពិរោះ ដើម្បីឲ្យវាធ្លាក់ទៅជាសម្បត្តិទ្រព្យរបស់អ្នកដទៃ...

☆✍ ថ្ងៃមួយ, បុរសម្នាក់បានមកស្នើរសុំធ្វើជាសាវ័ករបស់គាត់ ។ ឱយ៉ូសែនក៏បានប្រគល់សាច់សំបុងមួយដុំ (សាច់ភ្លៅជ្រូកហាលផ្សែង) ឲ្យបុរសនេះកាន់ព្រមទាំងប្រាប់ជននេះឲ្យដើរតាមគាត់ ។ បុរសនេះមានសេចក្ដីអាមាស់ក្រៃលែង ក្នុងការកាន់សាច់ជ្រូកដើរយូរតាមផ្លូវថ្នល់ ម្ល៉ោះហើយគេក៏គ្រវែងសាច់មួយដុំនេះចោលបាត់ទៅ ។ បីបួនថ្ងៃក្រោយមក ឱយ៉ូសែនបានជួបប្រទះជនដដែលនេះ ហើយគាត់ក៏បានពោលថា ៖ « យ៉ាងម៉េច, សាច់សំបុងមួយដុំអាចធ្វើឲ្យខូចមិត្តភាពរបស់យើងបានដែរហ្ន៎ ? គួរដែរ ! គួរដែរ ! » ។

☆✍ នៅពេលដែលគាត់កំពុងដើរលំហែកាយ ដើម្បីយកខ្យល់អាកាស គាត់បានឃើញស្រីម្នាក់កំពុងតែស្លុងខ្លួនយ៉ាងខ្លាំងក្នុងការថ្វាយបង្គំព្រះ រហូតដល់លេចគូទចេញនៅកណ្ដាលវាល ។ ឱយ៉ូសែនក៏ស្ទុះហេរទៅជិតស្រីម្នាក់នោះព្រមទាំងពោលថា ៖ « នែហ៍ ! នាងស្រីកំសត់... នាងត្រូវដឹងថា ព្រះនៅពីខាងមុខនាងឯង ក៏ដូចតែនៅពីខាងក្រោយផងដែរ, ប្រយ័ត្នព្រះឃើញរូបឯងកំពុងស្ថិតនៅក្នុងសភាពការណ៍ចំតិតចំតូងឥតមេត្តាធ៌មដូច្នេះហ្ន៎ ! » ។

☆✍ នៅពេលដែលឱយ៉ូសែន កំពុងសញ្ជឹងគិតពិចារណាទៅលើក្បួនជីវិតរបស់គាត់ គាត់បានពោលព្រមទាំងសើចផងថា អ្វីៗដែលជាពាក្យប្រទេចផ្ដាសារនៅក្នុងល្ខោនសោកនាដកម្មជាធម្មតា បានធ្លាក់មកលើរូបគាត់តែទាំងអស់ ៖ គាត់ជាមនុស្សម្នាក់គ្មានទីលំនៅ, គ្មានទីក្រុង, គ្មានស្រុកទេស, គ្មានមាតុភូមិ, រស់មួយថ្ងៃ ហូបមួយថ្ងៃ ក៏ប៉ុន្តែគាត់បានយកចិត្តមានៈរបស់គាត់ទៅទប់ទល់នឹងព្រេងវាសនា, យកធម្មជាតិទៅទប់ទល់នឹងទំនៀមទម្លាប់ប្រពៃណី, យកគោលគំនិតទៅទប់ទល់នឹងការភ្លើតភ្លើននៃដួងព្រលឹង ។

☆✍ ថ្ងៃមួយបុរសម្នាក់បានមកស្នើរសួរគាត់ ដើម្បីគ្រាន់ចង់ដឹងថា តើនៅពេលណា ជាការគួរសមក្នុងការបរិភោគអាហារ ។

– បើឯងជាអ្នកមាន, គាត់ពោល, ឯងចង់ហូបពេលណាក៏បាន ស្រេចនឹងចិត្តឯង ។ ក៏ប៉ុន្តែបើឯងជាអ្នកក្រវិញ ឯងឆីនៅពេលណាដែលអាចធ្វើបាន...

☆✍ ពួកអ្នកទីក្រុងអាត្វែនខ្លះ បានស្នើរសុំឲ្យគាត់ចូលទៅរៀនវិជ្ជាអាថ៌កំបាំងរបស់ពួកគេ, ដោយអះអាងថា ពួកជនណាដែលចេះវិជ្ជានេះ ច្បាស់ជានឹងបានឡើងបុណ្យស័ក្តិយសខ្ពស់បំផុតនៅពេលទៅកាន់បរលោក ។ ឌីយ៉ូសែនក៏បានឆ្លើយតបទៅអ្នកទាំងនេះវិញថា ៖ « ជារឿងមួយគួរឲ្យអស់សំណើចខ្លាំងណាស់ ដែលអាយេស៊ីឡោសនិងអេប៉ាមីណុងដាស ត្រូវរស់នៅក្នុងភក់ នៅពេលដែលពួកអ្នកឯទៀតដែលបានចូលរៀនក្បួនវិជ្ជារបស់ពួកអ្នកឯង ដែលសុទ្ធសឹងតែជាជនអភ័ព្វសោះ បែរជាបានឡើងទៅរស់នៅលើឋានសួគ៌ទៅវិញ ! » ។

☆✍ ឌីយ៉ូសែនតែងមានទម្លាប់យកទឹកអប់ទៅលាបនៅជើងរបស់គាត់ ។ នៅពេលដែលគេសួរគាត់ថា ហេតុអ្វីបានជាគាត់ធ្វើដូច្នេះ, គាត់បានឆ្លើយថាក្លិនទឹកអប់ បើកាលណាគេយកទៅលាបលើក្បាលវាច្បាស់ជានឹងហើរឡើងទៅលើអស់ទៅហើយ... ក៏ប៉ុន្តែបើកាលណាគេយកទៅលាបជើងវិញ វាច្បាស់ជានឹងហើរចូលច្រមុះជាមិនខាន។

☆✍ ព្រឹទ្ធាចារ្យក្រៀវម្នាក់ ( កកន ៖ បើនៅក្នុងភាពយន្តចិន គេហៅថាកុង-កុង, ជនដែលគេក្រៀវពីក្មេង ហើយមានភារៈយាមគ្រែរបស់ស្រីៗនៅក្នុងវាំងស្តេច ) –ដ៏មានចិត្តអាក្រក់សាមាន្យបានសរសេរនៅមាត់ទ្វារចូលផ្ទៃគេហដ្ឋានរបស់ខ្លួនថា ៖ « មិនត្រូវមានអ្វីដែលជាអាក្រក់សាមាន្យចូលតាមទ្វារនេះឡើយ » ។ ឌីយ៉ូសែនក៏ពោលថា ៖ «ចុះម្ចាស់ផ្ទះនោះ... តើខ្លួនគេត្រូវចូលតាមច្រកណាទៅវិញដែរ ? »។

☆✍ ថ្ងៃមួយ មានទស្សនវិទូមួយចំនួនចង់បង្ហាញឲ្យឌីយ៉ូសែនយល់ថានៅលើភពផែនដីនេះ គ្មានចលនាសោះទេ ។ ឌីយ៉ូសែនក៏ងើបឈរឡើង ហើយដើរទៅវិញទៅមក ។ «តើលោកកំពុងធ្វើអ្វីហ្នឹង ?», ទស្សនវិទូម្នាក់បានចោទសំនួរ ចំ-ពោះគាត់ ។ « អញកំពុងតែបដិសេធទ្រឹស្តីរបស់ឯងហ្នឹង », ឌីយ៉ូសែនឆ្លើយ ។

☆✍ ជនម្នាក់បានពោលរៀបរាប់ប្រាប់គាត់អំពីតារាវិទ្យា, គាត់ក៏បានសួរទៅវិញដូច្នេះថា ៖ « តើឯងធ្លាប់បានចុះពីលើមេឃមកវិញជាយូរយារណាស់មកហើយ

ពិតមែនឬ ?» ។

⋆✍ ប្ដូតុងបានឲ្យនិយមន័យទៅដល់មនុស្សថាជាសត្វមានជើងពីរ តែពុំមានស្លាប ។ ឌីយ៉ូសែនក៏ចាប់មាន់គកមួយមកបោចស្លាបអស់រលីង ហើយយកទៅលាក់ក្នុងអាវម៉ង់តូរបស់គាត់, រួចគាត់ដើរឆ្ពោះទៅបណ្ឌិតសភារបស់ប្ដូតុង ។ ទៅដល់ទីនោះភ្លាម គាត់ក៏ទាញយកមាន់ពីក្នុងអាវម៉ង់តូរបស់គាត់ ហើយពោលដោយបោះមាន់ទៅកណ្ដាលចំណោមសាវ័ករបស់ប្ដូតុងថា ៖ « នេះហើយ គឺជាមនុស្សរបស់ប្ដូតុង » ។ ប្ដូតុងក៏មានកាតព្វកិច្ចត្រូវដូរនិយមន័យរបស់គាត់ ដោយបន្ថែមថា, សត្វនោះមានក្រចករីកធំទូលំទូលាយ ។

⋆✍ ឌីយ៉ូសែន ដោយធ្វើដំណើរកាត់តាមស្រុកមេក្ការ បានសង្កេតឃើញថាក្មេងៗនៅទីនោះមានសភាពអាក្រាតនននលគក ចំណែកហ្វូងសត្វចៀមនៅទីនោះវិញមានរោមក្រាស់ (ខ្សៀន) ពាសពេញខ្លួនវា ។ « នៅទីនេះ, ឌីយ៉ូសែន ពោល, មានថាន:ជាសត្វចៀម វាគ្រាន់បើជាងមានថាន:ជាកូនក្មេង » ។

⋆✍ ថ្ងៃមួយ នៅពេលដែលគាត់កំពុងអង្គុយបរិភោគ, ឌីយ៉ូសែនបានសង្កេតឃើញមានសត្វកណ្ដុរមួយចំនួនដែលមកអង្អៀមស៊ីចំណិតនំបុ័ងរបស់គាត់នៅក្រោមតុ ។ « យី អើ ! គាត់លាន់មាត់, ឌីយ៉ូសែនក៏ចិញ្ចឹមពួកប៉ារាស៍យមួយចំនួនផងដែរហ្ន៎ ? » ។

❑

⋆✍ ដោយនៅពេលនោះ, ឌីយ៉ូសែនគាត់ទើបតែចេញពីកន្លែងមុជទឹក, មានគេសួរគាត់ថា តើមានមនុស្សច្រើនគ្នាមកស្រង់ទឹកនៅទីកន្លែងនោះឬដែរ... គាត់បានឆ្លើយថាឥតមានមនុស្សទេ។ ក៏ប៉ុន្តែ, គេសួរតបគាត់វិញ, ក្រែងទីកន្លែងនោះមានសភាពអ៊ូអរណាស់មែនទេ ? – អ៊ូអរសម្បើមមែនទែន, គាត់ឆ្លើយ។

⋆✍ ថ្ងៃមួយ, គេបានសុំអញ្ជើញគាត់ឲ្យចូលរួមក្នុងពិធីជប់លៀងមួយ ។ គាត់បានបដិសេធសំណើរនេះ ដោយសំអាងថា, កាលពីថ្ងៃម្សិលគេបានអញ្ជើញគាត់ម្ដងរួចទៅហើយៗក៏គ្មាននរណាម្នាក់បានសំដែងអំណរគុណចំពោះគាត់ទាល់តែសោះក្នុងរឿងនេះ។

☆✍ សម័យថ្ងៃមួយ បុរសម្នាក់សែងឈើផ្ដានទៅលើស្មាបានដើរទៅទង្គិចរូបគាត់, ព្រមទាំងពោលថា ៖ « ចូរឯងប្រយ័ត្ន!» ។ « យ៉ាងម៉េច, ឌីយ៉ូសែនពោលតប, ឯងចង់បុកអញម្ដងទៀតឬយ៉ាងណា?» ។ បីបួនថ្ងៃក្រោយមក រឿងដូច្នេះក៏បានកើតមានឡើងម្ដងទៀត ។ ឌីយ៉ូសែនបានយកដំបងឈើច្រត់ របស់គាត់វាយសំពងជនដែលបានប៉ះទង្គិចគាត់ដោយពោលថា ៖ « ឯងត្រូវប្រយ័ត្នខ្លួនឯងទៅ ! » ។

☆✍ ថ្ងៃមួយ គាត់បានត្រូវទទឹកទឹកភ្លៀងយ៉ាងជោគជាំ... ដោយមានដំណក់ទឹកហូរជ្រួតជ្រាបពាសពេញនៅគ្រប់ទីកន្លែងអាវម៉ង់តូរបស់គាត់ ។ ពួកអ្នកដែលឈរមើលគាត់មានចិត្តអាណិតអាសូរចំពោះគាត់ជាខ្លាំង ។ ប្លាតុងដែលឈរនៅទីនោះដោយចៃដន្យ បាននិយាយទៅកាន់អ្នកទាំងនេះថា ៖ « បើអស់លោកអ្នកចង់ឲ្យគាត់នេះ មានសេចក្ដីទុក្ខវេទនាពិតប្រាកដ, សូមដើរចាកចេញឆ្ងាយពីទីនេះទៅ...កុំក្រឡេកមើលរូបគាត់ឲ្យសោះ ។

☆✍ ថ្ងៃមួយមនុស្សម្នាក់បានទះកំភ្លៀងគាត់។ ឌីយ៉ូសែនក៏ពោលថា ៖
- ខ្ញុំមិនដឹងសោះថា ខ្ញុំត្រូវដើរតាមផ្លូវដោយមានក្បាលពាក់អាវុធ។
ក្នុងពេលម្ដងទៀត គេបានសួរគាត់ថា តើអ្នកដែលបានទះកំភ្លៀងគាត់នោះគេចង់បានអ្វីដែរ ?
- ចង់បានមួកដែក, គាត់ឆ្លើយតបវិញ ។

☆✍ មីឌីយ៉ាស, កាលថ្ងៃមួយ, បានដាល់គាត់ជាច្រើនដៃហើយពោលថា ៖
- ទៅ ..ទៅ ! ចូរអញ្ជើញទៅប្ដឹងទៅ... គេនឹងតម្រូវឲ្យឯងបង់ផាកពិន័យជាប្រាក់បីពាន់លីវ្រ ។ ថ្ងៃស្អែកឡើងឌីយ៉ូសែនកាន់ស្លាប់ដៃមួយធ្វើពីដែក ហើយ ,ព្រលែងមួយដៃចំក្បាលមីឌីយ៉ាស ព្រមទាំងពោលថា ៖
- ទៅ ! ទៅប្ដឹងខ្លួនឯងទៅ ឯងនឹងត្រូវបង់ផាកពិន័យដូចគ្នា !

☆ ✍ លីស៊ីយ៉ាស, ជនលក់ថ្នាំម្នាក់បានសួរគាត់ថា តើគាត់មានជំនឿថាមានព្រះនៅលើមេឃពិតមែនឬទេ ?
- រកឯណាមិនជឿ, ឌីយ៉ូសែនពោលតបវិញ, ពីព្រោះអញដឹងថាគ្មាននរណាជាសត្រូវធំបំផុតរបស់ទេព្ដា និងរបស់ព្រះឲ្យលើសពីរូបឯងនេះទេ !

☆✍ ថ្ងៃមួយឌីយ៉ូសែនបានឃើញបុរសម្នាក់កំពុងជ្រមុជខ្លួនទៅក្នុងទឹក ដោយ

នឹកសង្ស័យថា ខ្លួនគេនឹងជម្រះសំអាតខ្លួនឲ្យបានស្អាតបរិសុទ្ធ រួចផុតពីអំពើបាប និងសេចក្ដីសៅហ្មងនានា ។ « ឱ! ជនអភ័ព្វ, ឱយ៉ូសែនពោលទៅកាន់ជននេះ, ឯងមានដឹងទេថា ទោះជាឯងជម្រះខ្លួនរហូតដល់ទៅថ្ងៃស្អែកទៀតផង...ក៏ឯងនៅតែរៀនមិនចេះវេយ្យាករណ៍... ហើយឯងនៅតែចៀសមិនផុតអំពីទុក្ខទណ្ឌកម្មនៃអំពើឧក្រិដ្ឋរបស់ឯង» ។

⭐✍ ថ្ងៃមួយ គាត់បានឃើញក្មេងម្នាក់ស្ថិតនៅក្នុងស្ថានភាពច្រហេងច្រហោងមិនសមរម្យ ។ គាត់បានស្ទុះទៅជួបគ្រូរបស់ក្មេងម្នាក់នេះ ហើយសំពងជននេះមួយដំបងដោយពោលថា ៖ « ម្ដេចបានជាឯងបង្រៀនវាឲ្យមានអាកប្បកិរិយាអាក្រក់អាក្រីច្រឡើសបើសយ៉ាងហ្នឹង ?»។

⭐✍ ថ្ងៃមួយ, បុរសម្នាក់ចង់បង្ហាញដល់ឱយ៉ូសែនអំពីក្បួនហោរាសាស្ត្រដែលខ្លួនទើបបានរៀបចំតុបតែងឲ្យមានរូបរាងឡើង ។ ឱយ៉ូសែនក៏លាន់មាត់ថា ៖ «នេះបានចំជាស្នាដៃមួយលប្រសើរមែន... ក៏ប៉ុន្តែតាមការពិតគឺដើម្បីកុំឲ្យយើងដាច់ពោះស្លាប់តែប៉ុណ្ណោះ » ។

⭐✍ គាត់បានទម្លាក់ទោសធ្ងន់ធ្ងរទៅលើពួកជនដែលតែងពោលត្អូញត្អែរនឹងកម្មវាសនា ។ មនុស្សម្នារទាំងឡាយ, គាត់ពោល, តែងតែស្វែងសុំអំពីព្រេងវាសនានូវអ្វីៗដែលមានទំនងត្រឹមតែជាសម្បត្តិទ្រព្យល្អ ...ក៏ប៉ុន្តែមិនដែលបានសុំរបស់អ្វីៗដែលជារបស់ទ្រព្យដ៏ល្អពិតប្រាកដនោះសោះ ។

⭐✍ ឱយ៉ូសែនបានដឹងយ៉ាងច្បាស់លាស់ ថាមានមនុស្សច្រើនគ្នាណាស់ដែលបានគាំទ្ររបៀបរស់នៅរបស់គាត់... ក៏ប៉ុន្តែដោយនៅក្នុងការអនុវត្តន៍វិញមានមនុស្សតិចគ្នាណាស់សុខចិត្តប្រព្រឹត្តតាមវិន័យរបស់គាត់, គាត់បានពោលថា , ខ្លួនគាត់ជាឆ្កែមួយដែលមានគេស្រឡាញ់រាប់អានក្រៃលែង... ក៏ប៉ុន្តែគ្មាននរណាម្នាក់ដែលបានស្ទើចសរសើរូបគាត់ដាច់ចិត្ត ទៅធ្វើការបរបាញ់ជាមួយនឹងគាត់ឡើយ ។

⭐✍ គាត់បានស្ដីបន្ទោសដល់ជនជំពូកខ្លះដែលមានសេចក្ដីតក់ស្លុតព្រួយបារម្ភតែនឹងការយល់សប្ដិយល់សូងរបស់ខ្លួន ។ ពួកជនទាំងនេះមិនដែលបានយកចិត្តទុកដាក់ខ្វល់ខ្វាយនឹងបញ្ហាអ្វីៗ ដែលបានចោទឡើងក្នុងខួរក្បាលរបស់គេ

នៅពេលដែលគេមានភ្នែកភ្លឺនោះទេ ក៏ប៉ុន្តែគេបែរជាត្រិះរិះពិចារណាដោយអបិយជំនឿ និងដោយសុបសៅ ចំពោះអ្វីៗដែលបានហើរចូលក្នុងអារម្មណ៍នៃការស្រមើស្រមៃរបស់គេ នៅពេលដែលគេកំពុងតែដេកនោះទេវិញ ។

☆✍ សម័យថ្ងៃមួយ, នៅពេលដែលគាត់កំពុងដើរលេងកំសាន្ត, គាត់បានសង្កេតឃើញស្រីម្នាក់ដេកចំខែងនៅក្នុងគ្រែមួយ ។ គាត់ពោលថា ៖

– ទ្រូងបែបនេះមិនមែនធ្វើឡើងសម្រាប់ដាក់សត្វពន្លាត់អ្វីដ៏អាក្រក់ម្លឹងៗ ។

☆✍ ពួកជនជាតិអាត្តែនមានសេចក្ដីស្រឡាញ់ពេញចិត្តនឹងដីយ៉ូសែនជាខ្លាំងព្រមទាំងមានសេចក្ដីកោតគោរពទៀតផង ។ ពួកគេបានចាប់យុវជនម្នាក់ចងវាយនឹងខ្សែតីព្រោះតែជនម្នាក់នេះបានធ្វើឲ្យបែកធុងរបស់ឌីយ៉ូសែន ។ មិនត្រឹមតែប៉ុណ្ណោះ គេបានរកធុងថ្មីមួយទៅជូនគាត់ថែមទៀត ។

☆✍ មនុស្សគ្រប់គ្នាតែងតែបានថ្លែងសរសើរអំពីសុភមង្គលរបស់កាលីសតែន ដែលបានទទួលភ័ព្វសំណាងបាយទឹករាល់ថ្ងៃនៅតុរបស់ស្ដេចអាឡេចសង់ ។ « ក៏ប៉ុន្តែខ្ញុំ, ឌីយ៉ូសែនពោលតបវិញ, ខ្ញុំយល់ឃើញថាកាលីសតែនជាមនុស្សចុះនរកទៅវិញទេ... នៅក្នុងរឿងតែមួយគត់ដែលជននេះត្រូវតែបរិភោគរៀងរាល់ថ្ងៃព្រឹកល្ងាច ជាមួយនឹងអាឡេចសង់ ។

☆✍ ក្រាទែរបានប្រើមធ្យោបាយគ្រប់យ៉ាង ដើម្បីបញ្ចុះបញ្ចូលទាក់ទាញឌីយ៉ូសែនឲ្យទៅរស់នៅក្នុងប្រាង្គប្រាសាទរបស់ខ្លួន ។ ឌីយ៉ូសែនបានឆ្លើយតបទៅជននេះវិញថា គាត់សុខចិត្តរស់តែនឹងធំប៉ុងនៅទីក្រុងអាត្តែន ជាជាងទៅរស់នៅក្នុងសេចក្ដីរុងរឿងនៃវាំងប្រាសាទរបស់ក្រាទែរ ។

☆✍ ពែរឌីកាសបានធ្វើការគំរាមកំហែងទៅលើឌីយ៉ូសែន ថាខ្លួននឹងសម្លាប់គាត់ ប្រសិនបើឌីយ៉ូសែនមិនព្រមមកលេងពែរឌីកាសនោះទេ ។ «ឯងធ្វើដូច្នេះច្បាស់ជាមិនបានបំពេញស្នាដៃអ្វីមួយដ៏ធំដុំនោះទេ , ឌីយ៉ូសែនបានពោលតបវិញ, ពីព្រោះសត្វអសិរពិសដ៏តូចមួយក៏វាអាចធ្វើការនេះបានដែរ។ ហើយអញសូមប្រាប់ ឯងទៅចុះថា ឌីយ៉ូសែនមិនត្រូវការពែរឌីកាស ហើយនឹងជីវិតធំដុំរបស់ជននេះដើម្បីគ្រាន់តែរស់ដោយសប្បាយនោះទេ»។ ហើយគាត់ក៏លាន់មាត់ថា ៖ «អនិច្ចា! ព្រះហើយនិងទេព្ដាមានចិត្តល្អពន់ពេកណាស់ចំពោះមនុស្សដោយបាន

ផ្តល់ជីវិតឲ្យអ្នកទាំងនេះ , ក៏ប៉ុន្តែសោភ័ណភាពទាំងប៉ុន្មានដែលព្រះបានចងភ្ជាប់មកជាមួយនឹងជីវិត មិនត្រូវបានពួកបថុជ្ជនទាំងនេះទទួលស្គាល់សោះឡើយ។ ពួកគេពឹតតែពីស្វែងរកបរិភោគឆ្ងាញ់ ហើយនិងលាបទឹកអប់ ។

☆✍ ថ្ងៃមួយ, គាត់បានឃើញជនម្នាក់ដែលឲ្យខ្ញុំកញ្ជះដាច់ថ្លៃរបស់ខ្លួនពាក់ស្បែកជើងឲ្យ...។ « ឯងប្រហែលមិនសប្បាយចិត្តទេដឹង, គាត់ស្តីបន្ទោសឲ្យជននេះ, រហូតដល់ថ្ងៃណាមួយវាញើសឯងខ្វាតចេញដូចទឹកសំបោរ ? ចុះដៃឯងទាំងពីរនេះវិញ, ទុកវាធ្វើអ្វីដែរ ? » ។

☆✍ នៅពេលមួយទៀតដែលគាត់កំពុងតែដើរតាមផ្លូវ, គាត់បានឃើញពួកចៅក្រមបណ្តើរមនុស្សម្នាក់យកទៅធ្វើទុក្ខទោសទារុណកម្ម ដោយហេតុថាជននេះបានលួចកូនដបមួយនៅក្នុងឃ្លាំងសាធារណៈ ។ « មើលចុះ ! ឱយ៉ូសែនពោល, គឺសុទ្ធសឹងតែជាចោរធំៗដែលកំពុងបណ្តើរកូនចោរតូចមួយ ! » ។

☆✍ គាត់បានពោលថា ៖ មនុស្សអ្នកមានដែលជាជនល្ងង់ខ្លៅ ក៏ហាក់ដូចជាសត្វចៀមញីមួយដែលពោរពេញទៅដោយរោមមាស ។

☆✍ ថ្ងៃមួយ, ដោយគាត់បានដើរមកដល់កណ្តាលផ្សារ, គាត់ក៏ស្រាប់តែចាប់ផ្តើមអេះខ្លួនញាប់ស្ញែក ។ « ឱ ! ព្រះជាម្ចាស់, គាត់ពោល, ធ្វើម្តេចឲ្យបានអេះពោះដូច្នេះទៅ ខ្ញុំបាត់ឃ្លានបាយរាល់ពេលវេលា...តាមចំណង់ចិត្តរបស់ខ្ញុំ» ។

☆✍ នៅពេលដែលគាត់ចូលមុជទឹក, គាត់បានប្រទះឃើញយុវជនម្នាក់កំពុងប្រព្រិត្តអំពើកាយវិការម្យ៉ាងដ៏ប៉ិនប្រសប់, ក៏ប៉ុន្តែមិនទំនងជាសុច្ចរិតប៉ុន្មានទេ ។ «បើឯងធ្វើចលនាបែបនេះកាន់តែបានល្អ, គាត់ពោលទៅរកជននេះ, ចលនារបស់ឯង នឹងកាន់តែក្លាយទៅជាអំពើអាក្រក់ ។

☆✍ នៅពេលមួយទៀត, ក្នុងឱកាសដែលគាត់កំពុងឆ្លងផ្លូវមួយ គាត់ឃើញមានប្លាកសរសេរនៅលើផ្ទះជនម្នាក់ដែលជាអ្នកស៊ីផឹកចាយវាយខ្ជះខ្ជាយ ដែលបញ្ជាក់ថាគេហដ្ឋាននេះនឹងត្រូវលក់ ។ «ឃើញទេ ! ឱយ៉ូសែនពោល, សភាពប្រមឹកជោគជាំរបស់ម្ចាស់ឯងបានបង្ខំឲ្យគាត់នេះក្អួតចេញអីចឹងឯង ! » ។

☆✍ ថ្ងៃមួយ, បុរសម្នាក់បាននិយាយដៀលបង្អាប់ប្រមាថរូបគាត់អំពីថាន: របស់គាត់ជាជននិរទេសខ្លួន ។ « ឱ ! ជនអភ័ព្វអើយ, គាត់បានពោលតបវិញ, តាមពិតខ្លួនអញសប្បាយចិត្តទៅវិញទេតើក្នុងរឿងនេះ ៖ គឺមកពីរឿងនេះឯងហើយដែលបណ្ដាលឲ្យរូបអញក្លាយទៅជាទស្សនិទូរ ! » ។

☆✍ បន្តិចក្រោយមក, ជនម្នាក់ទៀតបាននិយាយមកកាន់គាត់ដោយពាក្យត្រគោះថា ពួកជនជាតិស៊ីណូពបានដាក់ទោសរូបគាត់ឲ្យរស់នៅក្រៅប្រទេសមួយជីវិត ។ « ចំណែករូបអញវិញ, អញដាក់ទោសទណ្ឌកម្មពួកអ្នកទាំងនេះឲ្យរស់មួយក្រវិចតែនៅក្នុងស្រុកអាក្រក់របស់ពួកខ្លួននៅតាមឆ្នេរនៃប៉ុង-ដឹកសាំង ។

☆✍ ពេលខ្លះ គាត់បានទៅបន់ស្រន់នៅចំពោះរូបសំណាករបស់ព្រះ ដើម្បីសុំទ្រង់ប្រទានពរឲ្យបានសម្រេចបំណងផ្សេងៗ ។ នៅពេលដែលគេសួរគាត់ថា ហេតុអ្វីបានជាគាត់ទៅបន់ព្រះទៅវិញ ?

– គឺដើម្បី, គាត់ពោល, ទម្លាប់ខ្លួនខ្ញុំឲ្យព្រះបដិសេធជានិច្ចជាកាល ។

☆✍ នៅពេលដែលសេចក្ដីក្រខ្សត់បង្ខំគាត់ឲ្យធ្វើការសុំទាន, គាត់ក៏និយាយទៅជនទី-១ ដែលគាត់ជួបប្រទះ ដោយពាក្យសំដីដូច្នេះថា ៖ « ប្រសិនបើជាឯងធ្លាប់បានធ្វើទានដល់ជនណាម្នាក់ហើយ, ក៏សូមឲ្យឯងដាក់ទានចំពោះអញ ដូច្នេះដែរ, ហើយបើជាឯងមិនធ្លាប់ដែលឲ្យអ្វីដល់នរណាម្នាក់សោះ ត្រូវឯងចាប់ផ្ដើមពីរូបអញនេះឡើងទៅ ! » ។

☆✍ គេបានសួរគាត់នៅក្នុងសម័យថ្ងៃមួយថា តើជីនីសស្ដេចផ្ដាច់ការធ្លាប់ប្រព្រឹត្តយ៉ាងណាខ្លះជាមួយនឹងមិត្តភក្តិរបស់ខ្លួន ? « គឺដូចជាគេប្រើប្រាស់ដបកាលណាវានៅពេញ, គាត់ពោល, ហើយដែលគេត្រវែងចោល កាលណាអស់មានអ្វីហើយ »។

☆✍ ថ្ងៃមួយគាត់បានសង្កេត, នៅក្នុងរង្គសាលមួយ, ឃើញជនផឹកស៊ីបំផ្លាញទ្រព្យសម្បត្តិម្នាក់ ដែលពីតតែពីហូបផ្លែអូលីវ ។

– ប្រសិនបើឯងធ្លាប់បរិភោគតែរបៀបនេះតាំងពីដើមរៀងមក..., គាត់ពោល, ប្រហែលជាម្ហូបអាហាររបស់ឯងនៅថ្ងៃនេះមិនបានធ្លាក់ដុនដាបអីចឹងពេកទេ ។

☆✍ គាត់តែងធ្លាប់និយាយថា ចំណង់អារត់អាវាយឥតព្រំដែនគឺជាប្រភព

នៃសេចក្ដីទុក្ខវេទនារដែលតែងសង្កត់យាយីទៅលើមនុស្សជាតិគ្រប់សណ្ឋាន...

– រីឯជនសុច្ចរិត គឺជារូបគំរូរបស់ព្រះនិងទេព្ដាជាប្រាកដ...

– ចំណែកពោះទឹក ( ក្រពះបាយ ) គឺជាជ្រោះបាតជាលនៃជីវិត

– អំពីសន្ទូរកថាមួយដែលគេបានសំអាតពាក្យឃ្លា គឺហាក់ដូច ជាទឹក ឃ្មុំមួយបន្ទះដូច្នោះដែរ, ហើយនៅទីបំផុត ចំពោះស្នេហាវិញ គឺជាកិច្ចការរបស់ពួកអ្នករស់នៅទំនេរ, ឬខ្ជិលច្រអូស ។

⋆✍ ថ្ងៃមួយគេបានសួរគាត់ថា តើនៅក្នុងសភាពការណ៍បែបណាដែលត្រូវចាត់ទុកជាលក្ខណៈអភ័ព្វជាទីបំផុត ?

– គឺ, គាត់ឆ្លើយតប, លក្ខណៈរបស់មនុស្សចាស់ដែលនៅក្នុងសភាពក្រីក្រ ។

មានពេលមួយទៀត –ថាតើមានអ្វីទៅដែលជាសម្បត្តិទ្រព្យល្អលើសគេ នៅក្នុងសកលលោកនេះ ៖ គាត់បានឆ្លើយថា គឺជាសេរីភាព !

⋆✍ ជនម្នាក់បែកគំនិតសួរគាត់ថា តើសត្វអ្វីដែលខាំយ៉ាងសាហាវជាងគេបំផុត ? « បើនៅក្នុងចំណោមជនព្រៃផ្សៃ, គាត់ពោលឆ្លើយតប, គឺជាពួកជននិយាយដើមគេ, ក៏ប៉ុន្តែបើនៅក្នុងចំណោមអ្នកចេះដឹងវិញ, គឺជាពួកជនអ្នកបញ្ចើចបញ្ចើរលើកជើង » ។

❑

ថ្ងៃមួយ, នៅពេលដែលគាត់កំពុងតែដើរកំសាន្ត, គាត់បានឃើញស្រីៗ ច្រើនគ្នាដែលត្រូវគេព្យួរកនៅមែកអូលីវ។ ឱយ៉ូសែនបានលាន់មាត់ថា ៖ « ឱ! ព្រះជាម្ចាស់ធ្វើម្ដេចទៅហ្ន៎ ឲ្យដើមឈើទាំងឡាយបានចេញផ្លែចេញផ្កាមករបៀបនេះ »។

បុរសម្នាក់បានមកជួបគាត់ហើយសួរគាត់ថា តើនៅក្នុងអាយុប៉ុន្មាន ដែលគេគួរតែរៀបអាពាហ៍ពិពាហ៍ ។

-កាលណាគេនៅក្មេង, ឱយ៉ូសែនឆ្លើយ, គឺវាមិនទាន់ដល់ពេលវេលាទេ ក៏ប៉ុន្តែដល់ពេលណាចាស់ គឺវាហួសពេលទៅហើយ ។

គេបានសួរគាត់ថា ហេតុអ្វីបានជាមាសមានព៌ណស្លាំងស្លេកអីចឹង ?

- ពីព្រោះមានពួកអ្នកប្រណែនវាច្រើនគ្នាពេក, ឱយ៉ូសែនឆ្លើយតប ។

ថ្ងៃមួយ, គេបានតឿនគាត់ឲ្យរត់ដេញតាមចាប់នាយម៉ាណែស, ឈ្លួលបម្រើម្នាក់ដែលបានរត់ចេញពីគាត់ទៅ...

- វាជាការអាក្រក់មើលណាស់, ឱយ៉ូសែនពោល, ដែលម៉ាណែសអាចរស់បានដោយឥតមានឱយ៉ូសែន, ចំណែកឯឱយ៉ូសែនវិញមិនអាចរស់បានដោយសារគ្មានម៉ាណែស ។

មានស្ដេចត្រាញ់ម្នាក់បានមកសួរគាត់ នៅក្នុងសម័យថ្ងៃមួយថា តើនៅទីកន្លែងណាទៅ ដែលគេអាចសាងសង់រូបចម្លាក់បានដ៏ល្អប្រសើរ ?

- គឺទីកន្លែងដែលគេបានសាងសង់រូបរបស់អារម៉ូឌីយុស និងអារីសតូជីតុង, ពីព្រោះអ្នកទាំងពីរនាក់នេះជាសត្រូវដ៏ធំរបស់ជនដែលកាន់អំណាចផ្ដាច់ការ ។

ថ្ងៃមួយប្លាតុងបានពន្យល់បកស្រាយអំពីគំនិតថ្មីៗរបស់គាត់ ហើយបាននិយាយពន្យល់ជាពិសេសអំពីរូបរាងទ្រង់ទ្រាយនៃតុមួយនិងកែវមួយ។ «អញអាចមើលឃើញ អំពីតុមួយនិងកែវមួយ, ឱយ៉ូសែនពោលទៅកាន់ប្លាតុង, ក៏ប៉ុន្តែអញមិនអាចដឹងបានថា អ្វីជារូបរាងនៃតុ ហើយនិងអ្វីទៅជារូបរាងនៃកែវនោះបានឡើយ ។

- ការនេះវាពិតដូចឯងថាមែន ប្លាតុងឆ្លើយតប, ពីព្រោះដើម្បីមើលឃើញតុនិងកែវគេអាចប្រើតែប្រស្រីភ្នែកវាគ្រប់គ្រាន់ហើយ ។ ក៏ប៉ុន្តែដើម្បីដឹងនិងបានស្គាល់រូបរាងនៃតុនិងកែវគេត្រូវតែមានបញ្ញា ។

មានពេលមួយ គេសួរដល់ឪយ៉ូសែនថា តើគាត់យល់យ៉ាងណាដែរអំពីសូក្រាត។ គាត់បានឆ្លើយតបវិញថាជននោះជាមនុស្សឆ្កួត ។

ថ្ងៃមួយ, គាត់បានឃើញយុវជនម្នាក់មុខក្រហមដោយសេចក្ដីអៀនខ្មាស់ ៖
– ចូរឯងខំប្រឹងឲ្យមានសេចក្ដីក្លាហានឡើងកូនប្រុស, ឪយ៉ូសែនពោលទៅកាន់ក្មេងម្នាក់នេះ, នេះហើយដែលគេហៅថាព៌ណសំបុរនៃសេចក្ដីសុច្ចរិត ។

ស្មាក្ដីនៃតុលាការពីរនាក់ដែលមានកើតជម្លោះទាស់ទែងគ្នាបានជ្រើសរើសយកឪយ៉ូសែនធ្វើជាអាជ្ញាកណ្ដាលនៃវិវាទរបស់ពួកខ្លួន ។ ឪយ៉ូសែនបានកាត់សេចក្ដីដាក់ទោសទណ្ឌកម្មអ្នកទាំងពីរដូចគ្នា... ជនទី-១ ពីព្រោះបានលួចទ្រព្យសម្បត្តិរបស់គេដូចពាក្យចោទពិតមែន, ជនទី-២ ពីព្រោះតែបានប្ដឹងប្ដល់ដោយចិត្តឥតថ្លាឈ្លានីស ពីព្រោះខ្លួនឯងវិញគ្មានបានបាត់បង់អ្វីសោះទេ ហើយក៏គ្មានទ្រព្យសម្បត្តិឯណាប្រចាំខ្លួនក្រៅតែពីការបានមកដោយលួចទ្រព្យសម្បត្តិរបស់ អ្នកដទៃតែប៉ុណ្ណោះឯង ។

គេបានសួរគាត់ក្នុងសម័យថ្ងៃមួយថា ហេតុអ្វីបានជាអ្នកផងចូលចិត្តដាក់ទានទៅឲ្យជនខ្វាក់ភ្នែកម្ខាងឬទៅជនកំបុតជើងម្ខាង ជាជាងដាក់ទានទៅឲ្យពួកទស្សនវិទូវិញ ?
– ពីព្រោះ, ឪយ៉ូសែនពោលតប, មនុស្សយើងរង់ចាំថានឹងក្លាយខ្លួនទៅជាជនខ្វាក់ និងជាជនកំបាក់កំបែក ជាជាងក្លាយទៅជាទស្សនវិទូ ។

មនុស្សម្នាក់បានសួរគាត់ថា តើគាត់មានឈ្នួលប្រុស ឈ្នួលស្រីសម្រាប់ប្រើនឹងគេទេ ?
– ឥតមានទេ, គាត់ពោលតប ។
– ចុះទៅថ្ងៃមុខបាននរណាកប់ខ្មោចរបស់លោកទៅ ?
– គឺនរណាដែលត្រូវការយកផ្ទះខ្ញុំ !។

បុរសម្នាក់បានស្ដីបន្ទោសឲ្យគាត់ថា កាលពីដើមគាត់បានលួចធ្វើប្រាក់ក្លែងក្លាយ ។
– ជាការពិត, ឪយ៉ូសែនឆ្លើយតប, វាមានពេលវេលាមួយដែលកាលនោះឯងមានលក្ខណៈដូចជារូបអញនៅក្នុងពេលឥឡូវនេះអីចឹង ។ ក៏ប៉ុន្តែតាំងពីថ្ងៃនេះ

តទៅរហូតទល់នឹងពេលឯងស្លាប់ ឯងគ្មានសង្ឃឹមថានឹងមានលក្ខណៈដូចរូបអញក្នុងពេលបច្ចុប្បន្ននេះទេ ។

ថ្ងៃមួយគាត់បានដើរចូលចូលទៅក្នុងសាលាដឹកនាំដោយលោកគ្រូម្នាក់ដែលមានកូនសិស្សតែបន្តិចបន្តួចប៉ុណ្ណោះ តែមានរូបចម្លាក់តុក្កតានិងរូបព្រះជាច្រើនអង្គ។ « ឯងនៅទីនេះ មានសាវ័កច្រើនណាស់, ឱយ៉ូសែនពោល, ប៉ុន្តែក៏ត្រូវរាប់រូបព្រះផងទើបបាន» ។

គេបានសួរគាត់ថាតើគាត់មកពីស្រុកណាដែរ ។ គាត់បានឆ្លើយថាគាត់ជាប្រជាពលរដ្ឋម្នាក់នៃពិភពលោក, ដោយគាត់ចង់បង្ហាញថាពួកអ្នកប្រាជ្ញមិនត្រូវជាប់ចិត្តនឹងប្រទេសណាមួយជាពិសេសនោះឡើយ ។

ថ្ងៃមួយ គាត់ឃើញមនុស្សម្នាក់ស៊ីចាយសប្បាយហ៊ឺហាដើរមក... គាត់ក៏សុំទានប្រាក់មួយមីនពីជននោះ ។ បុរសដែលចាយលុយខ្ជះខ្ជាយក៏សួរគាត់ថា ៖

ថ្ងៃមួយ គាត់ឃើញមនុស្សម្នាក់ស៊ីចាយសប្បាយហ៊ឺហាដើរមក... គាត់ក៏សុំទានប្រាក់មួយមីនពីជននោះ ។ បុរសដែលចាយលុយខ្ជះខ្ជាយក៏សួរគាត់ថា ៖

– ហេតុអ្វី បានជាឯងសុំអ្នកឯទៀតតែមួយអូបូល (មួយកាក់) ...ក៏ប៉ុន្តែចំពោះអញវិញឯងសុំរហូតដល់មួយមីន (មួយម៉ឺនអូបូល) ។

– គឺពីព្រោះអ្នកឯទៀត, ឱយ៉ូសែនពោល, នៅមានសមត្ថភាពចែកអំណោយមកអញទៅថ្ងៃក្រោយទៀត ...ក៏ប៉ុន្តែចំពោះឯងវិញអញមានជំនឿថាឯងនឹងគ្មានលទ្ធភាពធ្វើដូច្នេះឡើយ ។

គេបានសួរគាត់ថាតើសេចក្តីស្លាប់ជាការមួយដ៏អាក្រក់សាមាន្យពិតមែនឬទេ ? «តើម្តេចយើងអាចដឹងបាន, ឱយ៉ូសែនពោលតប, ដោយហេតុថាពេលសេចក្តីស្លាប់មកដល់ យើងមិនទាំងដឹងខ្លួនផងសោះ» ។

ថ្ងៃមួយឱយ៉ូសែនឃើញជនខ្ជះការប៉ិនប្រសប់ម្នាក់លើកអាវុធឡើងតម្រង់បាញ់ ។ ឱ-យ៉ូសែនក៏ប្រញាប់ទៅឈរនៅកន្លែងដែលជននោះតម្រង់សំដៅ ។ គេសួរគាត់ថា ហេតុអ្វីបានជាគាត់មានអាកប្បកិរិយាដូច្នេះ ? – គឺពីព្រោះ, គាត់ពោលតប, កុំឲ្យជននេះមានលទ្ធភាពបាញ់ខ្ញុំត្រូវ ។

នៅពេលដែលជនខ្លះនិយាយប្រាប់ឱយ៉ូសែនថា, មានមនុស្ស ច្រើនគ្នាណាស់ដែលសើចចំអកដាក់គាត់ ។

– មិនជាការអ្វីទេ,ឱយ៉ូសែនពោល, ឧបមាថាវាអីចឹងទៅចុះ! ។ ហើយចំពោះអ្នកទាំងនោះក៏សត្វលាវាសើចចំអកដាក់ដូចគ្នា, កាលណាសត្វនេះវាបើកមាត់សំញេញបញ្ចេញធ្មេញមានទំនងដូចជាចង់សើច។

– ក៏ប៉ុន្តែមាននរណាទៅរវល់ឈឺក្បាលនឹងពួកសត្វលានោះ, ពួកគេនិយាយទៅកាន់ឱយ៉ូសែនវិញ ។

– ចំណែកខ្ញុំ, ឱយ៉ូសែនពោលតប, ក៏គ្មានរវល់ឈឺក្បាលនឹងពួកម្ចាលអស់ទាំងនោះដែរ ។

គេបានសួរគាត់ថា ហេតុអ្វីបានជាអ្នកផងទុកគាត់ជាសត្វឆ្កែ ?

– ពីព្រោះ, គាត់ពោល, ខ្ញុំយកចិត្តពួកអ្នកណាដែលផ្តល់របស់របរមកឲ្យខ្ញុំ, ហើយខ្ញុំស្រែកព្រូសចំពោះនរណាដែលមិនឲ្យអ្វីខ្ញុំសោះ, ព្រមទាំងខ្ញុំដេញខាំពួកជនកំណាច ។

នៅពេលមួយទៀត, គេបានសួរគាត់ថាតើគាត់ឋិតនៅក្នុងប្រភេទជាសត្វឆ្កែបែបណាមួយដែរ ?

– កាលណាខ្ញុំឃ្លាន, គាត់ពោល, ខ្ញុំមានធម៌ជាតិជាសត្វឆ្កែឡេវ្រីយេ ( ឆ្កែស្គមខ្ពស់ៗដែលគេប្រើឲ្យដេញសត្វម្រឹគ ), ខ្ញុំយកចិត្តយកថ្លើមអ្នកផងដែលនៅជុំវិញខ្លួនខ្ញុំ, ក៏ប៉ុន្តែនៅពេលណាដែលខ្ញុំបានហូបឆ្អែតហើយ, ខ្ញុំមានធម៌មជាតិជាសត្វឆ្កែដូក ( ឆ្កែមានមាឌមាំក្រអាញ, មាត់ធំៗ ), ខ្ញុំពឹតតែពីប្រទះខាំទាំងអស់ចំពោះពួកណាដែលខ្ញុំបានជួប ។

នៅសម័យថ្ងៃមួយ គាត់បានឃើញវាគ្មិនអាណាក់ស៊ីម៉ែន, ដែលមានដុះក្បាលពោះយ៉ាងសម្បើម ។

– ចូរឯងប្រគល់ឲ្យក្បាលពោះរបស់ឯងមកអញខ្លះៗមក, គាត់ពោល, ធ្វើដូច្នេះទៅ ឯងនឹងបណ្តាលឲ្យរូបអញបានសប្បាយចិត្តនោះម្យ៉ាង, ហើយម្យ៉ាងទៀយ ឯងនឹងបានទម្លាក់ចោលនូវរបស់ឥតប្រយោជន៍ខ្លះនោះផងដែរ ។

នៅពេលដែលគេស្តីបន្ទោសឲ្យគាត់ថា ហេតុអ្វីបានជាគាត់ចូលចិត្តបរិភោគនៅកណ្តាលផ្លូវ ឬនៅកណ្តាលផ្សារទៅវិញ ។

– ពីព្រោះខ្ញុំចាប់ផ្តើមឃ្លាននៅទីនោះ, គាត់ពោល, ហើយទោះនៅទីណាក៏ដោយឲ្យតែឃ្លាន ខ្ញុំហូបតែទាំងអស់ ។

នៅពេលដែលគាត់ធ្វើដំណើរត្រឡប់ពីទីក្រុងឡាសេដេម៉ូន ទៅទីក្រុងអាត្នែន, មានគេសួរគាត់ថា តើគាត់មកពីណាដែរ ?

– ខ្ញុំបានដើរមកពីស្រុករបស់ពួកប្រុសៗ, គាត់ពោល, ហើយកំពុងតែវិលត្រឡប់ទៅរកស្រុករបស់ស្រីៗវិញ ។

❑

គាត់បានប្រៀបធៀបស្រីស្អំនិងស្រីកំសាន្តចិត្តដ៏ល្អៗ ទៅនឹងស្រាក្រហមដ៏ឆ្ងាញ់ពិសារក៏ប៉ុន្តែពោរពេញដោយជាតិពុល ។ គាត់តែងហៅស្រីទាំងនេះថាជារាជនីរបស់ស្តេច, ឬជាមហាក្សត្រិយានីរបស់មហាក្សត្រ, ពីព្រោះនាងតែងជំរិតយកបានពីស្តេចនូវរបស់គ្រប់បែបយ៉ាងដែលនាងត្រូវការ ។

មនុស្សម្នាក់បានស្ងើចសរសើរយ៉ាងខ្លាំងអំពីរបស់ជង្វាយយ៉ាងច្រើន ដែលគេបានប្រទះនៅក្នុងវិហារសាម៉ូត្រាស ។

– ប្រហែលជាមានច្រើនជាងនេះទៅទៀត, ឌីយ៉ូសែនពោល, ប្រសិនបើពួកអ្នកស្លាប់បានដាក់ជំនូនដល់ព្រះជំនួសពួកដែលបាននៅរស់រួចជីវិត ។

ថ្ងៃមួយ, នៅពេលដែលគាត់កំពុងតែបរិភោគនៅកណ្តាលថ្នល់ ស្រាប់តែមានមនុស្សមួយចំនួនមកអង្គុយជុំវិញរូបគាត់, មិនត្រឹមតែប៉ុណ្ណោះបានហៅគាត់ថាឆ្កែ ។

– គឺអ្នកទាំងអស់គ្នានេះហើយដែលជាសត្វឆ្កែ, គាត់ពោលទៅកាន់អ្នក ទាំងនេះ, ពីព្រោះពួកអ្នកទាំងអស់គ្នាមកអង្គុយសម្លឹងមើលមនុស្សម្នាក់កំពុងស៊ីបាយ ។

ថ្ងៃមួយនៅពេលដែលគាត់កំពុងដើរលេងកំសាន្ត គាត់បានសង្កេតឃើញកូនរបស់ស្រីស្អំម្នាក់យកដុំគ្រួសចោលទៅលើកងទ័ពច្រើនជើងមួយក្រុម ។

–នែហ៍កូនប្រុស, ឌីយ៉ូសែននិយាយទៅកាន់ក្មេងម្នាក់នេះ ឯងប្រយ័ត្នចោលចំទៅលើឪពុករបស់ឯង ។

មានកីឡាករដ៏កំសោយម្នាក់ ដែលខ្វះសម័ត្ថភាពក្នុងមុខវិជ្ជាជីវៈរបស់ខ្លួនក៏បានសម្រេចចិត្តធ្វើពេទ្យហ្មវិញម្តង ។ ថ្ងៃមួយ, ឌីយ៉ូសែនបានជួបប្រទះជននេះហើយពោលថា ៖ « ក្នុងពេលឥឡូវនេះ ឯងមានមធ្យោបាយមួយដ៏ល្អប្រសើរដើម្បីសងសឹកនឹងពួកជនណាដែលធ្លាប់ឈ្នះលើរូបឯងកាលពីដើម ។

មានពេលមួយ, បុរសម្នាក់បានទារយកអាវម៉ង់តូដែលឌីយ៉ូសែនកំពុងតែពាក់ជាប់នឹងខ្លួន ។

– ប្រសិនបើជាឯងបានឲ្យរបស់នេះមកអញ, ឌីយ៉ូសែនពោល, របស់នេះក៏ជារបស់អញទៅហើយ ។ ក៏ប៉ុន្តែប្រសិនបើជាឯងគ្រាន់តែបានឲ្យអញខ្ចីវិញ អញកំពុងតែប្រើប្រាស់របស់នេះ... ចាំអញលែងត្រូវការសឹមឯងមយកទៅវិញចុះ ។

នៅពេលដែលគេស្តីបន្ទោសឲ្យគាត់ថា គាត់ធ្លាប់បានផឹកស្រានៅក្នុងតូបរង្គសាលគាត់បានឆ្លើយតបវិញថា ៖ « ខ្ញុំក៏ធ្លាប់បានកោរពុកមាត់ នៅកន្លែងកាត់សក់ដូចគ្នាអីចឹងដែរ » ។

ថ្ងៃមួយ គាត់បានឮគេសរសើរជនម្នាក់ដែលបានដាក់ទានឲ្យគាត់ ៖

– គេត្រូវសរសើរខ្ញុំទៅវិញទេ, ឌីយ៉ូសែនពោល, ដែលជាអ្នកបានផ្តល់កិត្តិយសចំពោះជនណាដែលបានដាក់ទានឲ្យខ្ញុំ ។

នៅពេលដែលគេសួរគាត់ថា តើគាត់បានចំណេញអ្វីខ្លះទៅអំពីទស្សនវិជ្ជារបស់គាត់ ?

– បើសិនវិជ្ជានេះ, ឌីយ៉ូសែនពោល, គ្រាន់តែបានរៀបចំខ្លួនខ្ញុំឲ្យចេះទប់ទល់នឹងការឈឺចាប់វេទនាដែលប្រហែលជាមិនអាចធ្លាក់មកលើរូបខ្ញុំរហូតក្នុងមួយជីវិតនេះ, ក៏ខ្ញុំសប្បាយចិត្តគ្រប់គ្រាន់ពេកណាស់ទៅហើយ ។

នៅពេលដែលអ្នកស្រុកនៃទីក្រុងអាត្អែនបានលើកដម្កើងស្តេចអាឡេចសង់ជាព្រះបាគុស ( ក.ក.ន. ៖ Bacchus បាគូ–បាគង ព្រះឥស្សូរនៃជនជាតិក្រិក ) ... គាត់បានពោលក្នុងគោលបំណងចំអកឲ្យអ្នកទាំងនេះថា ៖

– ហេ! ម្តេចក៏គេមិនដំកើងខ្ញុំឲ្យទៅជាព្រះសេរ៉ាពីសនឹងគេផង ? ( Sérapis )

គេបានស្តីបន្ទោសដល់គាត់ថា គាត់បានរស់នៅក្នុងទីកន្លែងក្រខ្វក់ ៖

– ព្រះអាទិត្យ, គាត់ពោល, តែងជ្រៀតជ្រែកទៅដល់ទីកន្លែងស្មោកគ្រោកជាងនេះឆ្ងាយណាស់, ហើយម្តេចក៏គេមិនឃើញពន្លឺថ្ងៃខូចគុណភាពអ្វីផងទៅ ?

បុរសម្នាក់ដែលស្មានថាខ្លួនមានប្រាជ្ញាបានពោលទៅកាន់គាត់ដូច្នេះថា ៖

– ឯងដែលឥតចេះដឹងអ្វីសោះម្តេចក៏ហ៊ានតាំងខ្លួនធ្វើជាទស្សនវិទូផង ?

– បើអញធ្វើមិនបានអ្វី, គាត់ពោលតបវិញ,... ក្រៅតែពីការយកតម្រាប់តាមពួក

ពួកទស្សនវិទូនោះ...តែប៉ុណ្ណោះក៏វាគ្រប់គ្រាន់ណាស់ទៅហើយដើម្បីតាំងខ្លួនអញជាទស្សនវិទូវ ។

ថ្ងៃមួយ គេបានយកក្មេងម្នាក់មកបង្ហាញគាត់ ដើម្បីណែនាំវាឲ្យធ្វើជាសាវ័ករបស់គាត់ ។ គេបានលើកសរសើរអំពីគុណសម្បត្តិរបស់យុវជនម្នាក់នេះជាអតិបរិមាថាវាជាមនុស្សឆ្លាតមានបញ្ញា, មានទំនៀមទម្លាប់ល្អ, ជាក្មេងត្រឹមត្រូវហើយចេះដឹងគ្រប់មុខគ្រប់យ៉ាង ។ ឌីយ៉ូសែនអង្គុយស្ដាប់យ៉ាងស្ងៀមស្ងាត់ ។

– បើវាពូកែម្ល៉េះៗ, គាត់ពោល, តើវាមានត្រូវការអ្វីពីខ្ញុំ, ពួកអ្នកឯងនាំវាមកជួបខ្ញុំធ្វើអ្វី ?

នៅពេលដែលគាត់ដើរចូលក្នុងរោងល្ខោនមួយ ចំពេលដែលទស្សនិកជនទាំងឡាយកំពុងតែដើរចេញ, គេបានសួរគាត់ថាហេតុអ្វីបានជាគាត់មានអាកប្បកិរិយាបែបនេះ ? គាត់បានពោលថា គឺជារឿងទម្លាប់មួយដែលគាត់បានសម្រេចធ្វើពេញមួយជីវិតរបស់គាត់ទៅហើយ ។

❑

ស្ដេចផ្ដាច់ការ ដឺនីស-ឡឺទៀរ៉ង់, បន្ទាប់ពីត្រូវបានគេដេញចេញពីអាណាចក្ររបស់ខ្លួននៅស៊ីរ៉ាគុស, ក៏បានដកថយមករស់នៅក្នុងស្រុកកូរាំង, ដែលនៅទីនោះសភាពក្រីក្រលំបាកបានជំរុញឲ្យគាត់នេះបំពេញមុខរបរជាគ្រូបង្រៀនដល់ពួកយុវជនដើម្បីកុំឲ្យដាច់ពោះស្លាប់ ។ ថ្ងៃមួយ, ឌីយ៉ូសែនបានដើរចូលទៅក្នុងសាលារបស់ដឺនីស...ស្រាប់តែគាត់បាន ឮកូនក្មេងស្រែកយំ ។ ដឺនីសនឹកស្មានថាឌីយ៉ូសែនមកលួងលោមអំពីសេចក្ដីទុក្ខសោករបស់ខ្លួន ៖

– ឌីយ៉ូសែន, អតិតស្ដេចថ្លែងវាចា, យើងអរគុណឯងណាស់ ៖ អនិច្ចា ! ចូរឯងមើលចុះ... នេះបានគេហៅថាឃ្លោកលិចអំបែងអណ្ដែត ...

– ឱជនកំសត់, ឌីយ៉ូសែនពោលតប ...អញមានការភ្ញាក់ផ្អើលខ្លាំងណាស់ដោយឃើញឯងនៅរស់នៅឡើយ... ឯងដែលបានធ្លាប់ធ្វើទុក្ខបុកម្នេញយ៉ាងខ្លាំងដល់ប្រជារាស្ត្ររបស់ឯងនៅស៊ីរ៉ាគុស...។ ហើយអញសង្កេតឃើញថាឯង ឥឡូវនេះវិញ មិនមែនជាគ្រូដ៏គាប់ប្រសើរ ដូចតែកាលឯងធ្វើស្ដេចក៏មិនមែនជាស្ដេចដ៏ល្អប្រសើរ ។

ថ្ងៃមួយគាត់បានឃើញមនុស្សជាច្រើនធ្វើពលិកម្មថ្វាយព្រះនិងទេព្ដា ដើម្បីសុំ

កូនប្រុសមួយ ។

– ពួកអ្នកឯងចង់បានកូនប្រុស, គាត់ពោលទៅកាន់អ្នកទាំងនេះ, ជាជាងចង់បានក្លាយទៅជាមនុស្សសុច្ចរិត ? ។

នៅពេលដែលគាត់សង្កេតឃើញយុវជនម្នាក់និយាយស្តីដោយទុច្ចរិត គាត់ក៏បានពោលទៅកាន់ក្មេងម្នាក់នេះថា ៖

– ឯងគ្មានសេចក្តីអៀនខ្មាស់ទេឬ ដែលខំប្រឹងដកដាវសំណាចេញពីស្រោមធ្វើអំពីភ្លុក ?

គាត់បានពោលអំពីមនុស្សដែលតែងនិយាយល្អពីគុណធម៌ តែមិនដែលធ្វើតាមពាក្យសំដីដែលគេបានបង្ហាត់បង្រៀនអ្នកដទៃនោះ ថាមិនសូវខុសគ្នាប៉ុន្មានពីគ្រឿងភ្លេងដែលបញ្ចេញបានត្រឹមតែសម្លេងពិរោះ ក៏ប៉ុន្តែពុំមាននមនោសញ្ចេតនាសោះឡើយ ។

បុរសម្នាក់បានពោលប្រាប់គាត់ក្នុងសម័យថ្ងៃមួយថា រូបគេមិនមាននិស្ស័យជាមួយនឹងទស្សនវិជ្ជាទាល់តែសោះ ។

បើដូច្នេះ តើឯងរស់ធ្វើអ្វីដែរ, ឌីយ៉ូសែននិយាយតទៅកាន់បុគ្គលនេះវិញ, បើឯងគ្មានសង្ឃឹមទាល់តែសោះថានឹងរស់បានសុខស្រួលនៅថ្ងៃណាមួយ ។

ក្នុងកាលៈទេសៈមួយទៀត, គាត់បានឃើញយុវជនម្នាក់ប្រព្រឹត្តអំពើមួយ មិនសុច្ចរិត។

– ឯងមិនមានការអៀនខ្មាស់ទេឬ ? គាត់ស្តីបន្ទោសឲ្យវា, បានជាធ្វើឲ្យខូចប្រឡាក់ប្រទូសអស់រលីងនូវគុណសម្បត្តិទាំងប៉ុន្មានដែលធម្មជាតិបានផ្តល់ឲ្យឯង ។

គាត់តែងពោលថា មនុស្សយើងគ្រប់ៗគ្នាតែងតែរស់នៅក្នុងទាសភាព ៖ ពួកខ្ញុំបម្រើគេដើម្បីគោរពចៅហ្វាយនាយរបស់ខ្លួន, ចំណែកពួកចៅហ្វាយរបស់គេដើម្បីគោរពចំណង់តណ្ហារបស់ខ្លួន ។ អ្វីៗទាំងអស់មានលក្ខណៈសំខាន់យោងទៅតាមទំនៀមទម្លាប់ប្រពៃណី ។ មនុស្សដែលធ្លាប់រស់នៅក្នុងឋានសួគ៌នៃសេចក្តីស្រណុកសំបូរសប្បាយ ច្បាស់ជាដកថយខ្លួនចេញវិញមិនរួចឡើយ ។ ផ្ទុយទៅវិញ ការមាក់ងាយចំពោះជីវិតសុខស្រួលជាសុភមង្គលពិតប្រាកដរបស់ ពួកមនុស្សដែលធ្លាប់រស់នៅដោយរបៀបផ្សេង ។

នៅក្នុងអាកប្បកិរិយាចំអកពេបជ្រាយរបស់គាត់ ដែលមិនរវីរវល់នឹងនរណាសើចឃំ ...គាត់បានយល់ថាសេចក្តីអៀនខ្មាស់ជាលក្ខណៈទន់ខ្សោយមួយ ។ គាត់មិនដែលមានសេចក្តីអៀនខ្មាស់ នៅចំពោះមុខអ្នកផង ក្នុងការប្រព្រឹត្តអំពើអ្វីៗមិនសមរម្យដែលបញ្ឆាស់ទិសសង្គមទាំស្រុង ។ ប្រសិនបើការបរិភោគជាអំពើមួយល្អនោះ ហេតុអ្វីបានជាគេប្រព្រឹត្តអំពើនេះនៅកណ្តាលផ្សារមិនបាន, ចាំបាច់តែធ្វើនៅក្នុងបន្ទប់ ?

គេបានសួរគាត់ថា តើនៅកន្លែងណាដែលគេត្រូវយកខ្មោចគាត់ទៅកប់ នៅពេលដែលគាត់ចូលមរណភាពទៅ ? នៅកណ្តាលវាលស្រែ គាត់ឆ្លើយតប..

– យ៉ាងម៉េចអីចេះ ? មនុស្សម្នាក់ចង់ផ្តុញផ្តាល់ឲ្យគាត់, តើលោកមិនខ្លាចត្មាតចោះ ឬក៏ក្លាយទៅជាចំណីរបស់សត្វព្រៃទេឬ ?

– ខ្ញុំនឹងដាក់ដំបងមួយនៅក្បែរខ្លួនខ្ញុំ, ឌីយ៉ូសែនពោលតប, ដើម្បីនឹងអាចដេញវានៅពេលដែលវាមកក្បែររូបខ្ញុំ !

– ប៉ុន្តែនៅពេលនោះ , លោកឥតដឹងខ្លួនអ្វីផង ( គេចចេសួរគាត់)

– បើខ្ញុំមិនដឹងខ្លួនផង ចង់នរណាស៊ីរូបខ្ញុំក៏ស៊ីទៅ ...ចង់ចោះយ៉ាងម៉េចបានក៏ចោះទៅ, គាត់ពោល ។

❑

មតិនៃមនុស្សភាគខ្លះបានអះអាងថា នៅពេលដែលគាត់បានចូលក្នុងអាយុ ៩០ឆ្នាំ គាត់បានបរិភោគជើងគោឆៅមួយដុំ ដែលបណ្តាលឲ្យគាត់ចុកពោះរហូតដល់ស្លាប់ ។ ប៉ុន្តែក្រុមមនុស្សខ្លះទៀតបាននិយាយថានៅពេលដែលគាត់បានចូលដល់វ័យចាស់ជរាវេទនាពេក គាត់បានអត់ដង្ហើមឲ្យស្លាប់ខ្លួនឯង ។ នៅពេលព្រឹកស្អែកឡើង ពួកមិត្តភ័ក្តិរបស់គាត់បានមកលេងគាត់ ៖ គេបានឃើញគាត់គ្រលំគ្រវៀននៅក្នុងអាវម៉ង់តូរបស់គាត់ ៖ ពួកគេក៏នាំគ្នាលារូបគាត់ចេញឡើងពីព្រោះគេមិនជឿថាគាត់ដេកលក់ទេ ... ដោយព្រោះគាត់មានទម្លាប់ភ្ញាក់ដឹងខ្លួនជានិច្ចជាកាល ។ នៅពេលនោះទើបបានគេដឹងថាគាត់ស្លាប់រួចទៅហើយ ។ ក្នុងកាលទេសៈនោះ មានមនុស្សជាច្រើនដែលឈ្លោះប្រកែកគ្នាឈូឆរ ដើម្បីណែ្តមយករូបគាត់ទៅកប់ ។ ពួកគេទាំង អស់ហៀបតែនឹងប្រើដៃជើងប្រកាប់ប្រចាក់គ្នាទៅហើយ ទទួលនៅពេលនោះពួកក្រុមចៅក្រមនិងពួកចាស់ទុំនៅក្នុវាំងត្រូបានមកសម្រុះសម្រួលមហាជនកុំឲ្យឈ្លោះប្រកែកគ្នា ។ សពឌីយ៉ូសែនបានទទួលពីធិរឈាបនកិច្ចដ៏អធិកអធម... គេបានយកគាត់ទៅកប់នៅមាត់ទ្វារនៃក្បាលកោះ ។

នៅក្បែរផ្នូររបស់គាត់គេបានលើកសសរកន្លោងមួយ ដែលគេបានដាក់រូបឆ្លាក់មួយធ្វើពីថ្មើមថ្មនៃប៉ារ៉ូស ។ មរណភាពរបស់ទស្សនវិទូម្នាក់នេះបានមកដល់តំណាលគ្នានឹងសេចក្ដីស្លាប់របស់មហាស្ដេចអាឡេចសង់នៅទីក្រុងបា-ប៊ីឡោនផងដែរ, នៅក្នុងអូឡាំព្យ៉ាដទី១១៤ ។ ឱយ៉ូសែនបានទទួលកិត្តិយសសន្ធឹកសន្ធាប់ លើកដំកើងដោយសារសមិទ្ធិរូបសំណាកដែលពួកសាមញ្ញជនជាច្រើនផ្សេងៗគ្នាបានសាងសង់ឡើងដើម្បីរំឭករូបគាត់ ព្រមទាំងមានសិលាចារឹកថ្លែងសរសើរអំពីគុណសម្បត្តិរបស់គាត់មកជាមួយគ្នាថែមទៀតផង ។

❑ ❑

❑

# ជីវិតរបស់អំប៉េដូក
# EMPÉDOCLES

បានចំរើនលូតលាស់នៅក្នុងអូឡាំព្យ៉ាដទី៨៤

តាមយោបល់របស់អ្នកផង អំប៉េដូកធ្លាប់បានធ្វើជាសិស្សរបស់ពីតាគ្ករ ។ គាត់មានកំណើតនៅស្រុកអាគ្រីយ៉ង់ ក្នុងកោះស៊ីស៊ីល ដែលនៅទីនោះក្រុមគ្រួសាររបស់គាត់មានកេរ្តិ៍ឈ្មោះល្បីល្បាញអស្ចារ្យជាងគេទាំងអស់ ៖ គាត់មានចំណេះដឹងដ៏ជ្រៅជ្រះបំផុតក្នុងផ្នែកវេជ្ជសាស្ត្រ ។ គាត់មិនត្រឹមតែមានលក្ខណៈជាវាគ្មិនម្នាក់ប្រកបដោយសំនួនវោហារតែប៉ុណ្ណោះទេ គាត់ថែមទាំងមានការប៉ិនប្រសប់ខាងតាក់តែងកំណាព្យកាព្យឃ្លោងនិងក្នុងវេទនម្តនៃពិធីគោរពបូជាព្រះ។ ពួកអ្នកស្រុកនៅអាគ្រីយ៉ង់មានសេចក្តីគោរពកោតខ្លាចជាអតិបរិមា ចំពោះបុគ្គលិកភាពរបស់គាត់ ដោយទុករូបគាត់ខ្ពស់ហួសពីលើមនុស្សម្នាផងទាំងឡាយ ។ លូក្រែស ( អ្នកកវីឡាតាំង ) បន្ទាប់ពីបានរៀបរាប់រឿងដ៏អស្ចារ្យគួរស្ងើចសរសើរនៅក្នុងកោះស៊ីស៊ីលកាលណាមក បានបន្ថែមថាអ្នកស្រុកក្នុងប្រទេសនេះបានសន្មត់ថា គ្មានអ្វីដ៏ល្អប្រសើរនៅលើកោះរបស់ពួកគេជាជាងមានវត្តមានរបស់មនុស្សម្នាក់ដ៏មានតម្លៃដូច្នេះទេ ។ ពួកគេបានចាត់ទុកកំណាព្យកាព្យឃ្លោងរបស់គាត់ស្មើនឹងទំនាយរបស់ព្រះ ។

ការគោរពរបស់អ្នកផងចំពោះគាត់ ពុំមែនគ្មានមូលហេតុនោះទេ ។ មានព្រឹត្តិការណ៍ជាច្រើននៅក្នុងជីវិតរបស់គាត់ ដែលបានបណ្តាលឲ្យមានមនោសញ្ចេតនារបស់អ្នកស្រុកកើតការរំជើបរំជួល ។ អ្នកខ្លះមានមន្ទិលសង្ស័យថា គាត់បានប្រើមន្តអាគមអូមអាម ។ សាទីរុសបានធ្វើសេចក្តីតំណាលថា ឈ្មោះគរយ៉ាស-ឡេអុងតាំង ដែលត្រូវជាសាវ័ករបស់ទស្សនវិទូម្នាក់នេះ បានពោលថាខ្លួនធ្លាប់ជួយគាត់ឲ្យសេពពិធីមន្តអាគមនេះ ហើយជួនពេលខ្លះ អំប៉េដូកថែមទាំងបានសំដែងបង្ហាញថា គាត់ចេះក្បួនអូមអាមសម្ងាត់នេះខ្លះៗទៀតផង ពីព្រោះគាត់បានពោលប្រាប់គរយ៉ាសថា គាត់ចង់បង្រៀនតែមនុស្សនេះម្នាក់គាត់ អំពីក្បួនអាថ៌កំបាំងដែលគេត្រូវប្រើ ដើម្បីព្យាបាលមនុស្សសព្វយ៉ាង ៖ ធ្វើមនុស្សចាស់ឲ្យទៅជាមនុស្សក្មេង, បង្កើតកម្លាំងខ្យល់, បន្ធូរកំហឹងនៃខ្យល់ព្យុះ, បង្កើតឲ្យមានទឹកភ្លៀងនិងកំដៅ, នៅទីបំផុតប្តូរជីវិតចំពោះមនុស្សស្លាប់ពោលគឺធ្វើឲ្យមនុស្សនេះវិលត្រឡប់មកវិញពីឋានបរលោក។

សម័យថ្ងៃមួយ ខ្យល់ផាត់ពីខាងជើងនៃសមុទ្រមេឌីទែរ៉ាណេ បានបោកបាចសាចខ្លាំងពេកទៅ ធ្វើឲ្យផ្លែឈើទាំងឡាយនៅលើផែនដីនេះ ធ្លាក់វិនាសខ្ទាត់ខ្ទាយ

ដោយគ្មានឱសថអ្វីកែកុនបាន ។ អំប៉េដូកក៏បានឲ្យគេពន្លះស្បែកសត្វលា ហើយយកមកដេរជាថង់ដាក់ទឹក, រួចគាត់ក៏យកថង់នេះ ទៅដាក់វាយប៉ាយនៅលើកំពូលភ្នំ ។ គេបានពោលអះអាងថា នៅពេលនោះ ព្រះពាយផាយផាត់ពេញកម្លាំងទាំងប៉ុន្មានក៏ត្រូវស្ងប់ស្ងាត់រលត់បាត់សូន្យអស់ទៅវិញ ។

អំប៉េដូកបានផ្ដែកជំនឿទៅលើទ្រឹស្ដីរបស់ពីតាគ្គរដែលត្រូវជាគ្រូរបស់គាត់ ហើយដែលពួកក្រុមពីតាគ្គរទាំងប៉ុន្មាន តែងតែមានសេចក្ដីខ្ពើមរអើមចំពោះឈាមសត្វដែលគេបូជាថ្វាយព្រះ។ អំប៉េដូកថ្ងៃមួយដែលគាត់ចង់ធ្វើពិធីបូជាយញ្ញ ក៏បានសូន្យរូបគោពីទឹកឃ្មុំនិងម្សៅសាឡី រួចក៏បានធ្វើការពិឃាតរូបអស់ទាំងនេះថ្វាយពួកទេវតា ។

អាគ្រីយ៉ង់នៅក្នុងសម័យអំប៉េដូក ជាទីក្រុងមួយដ៏ធំធេង ។ គេបានធ្វើការរាប់ទៅមានមនុស្សចំនួន៨០០,០០០នាក់ ។ គេបានប្រសិទ្ធិនាមទីក្រុងនេះថា ជាទីក្រុងដ៏ធំនិងដ៏ល្អប្រសើរ ។ ទ្រព្យសម្បត្តិដ៏មានតម្លៃ ដែលផ្ដល់នូវសេចក្ដីសុខស្រួល និងការស្រើបស្រាលសប្បាយ គឺជាឧត្តមគិតនៃការរស់នៅក្នុងទីនោះ ។ កាលណាគាត់និយាយពីអ្នកស្រុកអាគ្រីយ៉ង់, អំប៉េដូកបានពោលថា ពួកអ្នកទាំងនេះគិតតែពីសប្បាយដាច់បង្ហៀរ ហាក់ដូចជាគេមានវាសនាត្រូវស្លាប់នៅក្នុងព្រឹកថ្ងៃស្អែក, ម៉្យាងវិញទៀត ពួកគេខំប្រឹងប្រែងកសាងវាំងប្រាសាទដ៏ល្អៗ ហាក់ដូចជាពួកគេមានវាសនារស់នៅទីនោះរហូតជានិច្ចជាកាល ។ គាត់មិនដែលបាននឹកភ្លកចង់កាន់មុខនាទីធំដុំក្នុងកិច្ចការសាធារណៈនោះឡើយ ។ ជាច្រើនដងច្រើនគ្រាណាស់ ដែលអ្នកផងចង់លើកគាត់ឲ្យមានមុខតំណែងជាព្រះចៅនៅរាជាណាចក្រអាគ្រីយ៉ង់ ក៏ប៉ុន្តែគាត់មិនដែលបានទទួលយល់ព្រមម្ដងណាឡើយ ។ គាត់ចូលចិត្តមានជីវិតផ្ទាល់ខ្លួនស្ងៀមស្ងាត់ ជាជាងមានកិត្តិយសថ្កុំថ្កើង... ហើយគាត់ចូលចិត្តនៅឆ្ងាយពីសភាពស្មុគស្មាញរបស់រដ្ឋាភិបាល ។ គាត់ជាអ្នកស្រឡាញ់សេរីភាពយ៉ាងមុតមាំ និងជាអ្នកគាំទ្ររដ្ឋាភិបាលប្រជាធិបតេយ្យ ។

ថ្ងៃមួយគាត់ត្រូវបានគេអញ្ជើញឲ្យទៅចូលរួមក្នុងពិធីជប់លៀងមួយ ៖ លុះដល់ម៉ោងវេលាដែលអ្នកផងត្រូវឡើងតុ, អំប៉េដូកដោយសង្កេតឃើញថា គ្មាននរណាម្នាក់លើកម្ហូបម្ហារមកសោះ ហើយក៏គ្មានឃើញនរណាម្នាក់ត្អូញត្អែរផងដែរ គាត់ក៏មានអាការៈទាស់ចិត្តយ៉ាងខ្លាំង ។ គាត់មានបំណងចង់ឲ្យគេបំរើគាត់ភ្លាមមួយរំពេច ។ អ្នកដែលបានអញ្ជើញគាត់មកទីនោះក៏ពោលថា ៖ « សុំអត់ទ្រាំបន្តិចសិនទៅ ខ្ញុំកំពុងតែចាំលោកធំម្នាក់មកពីព្រឹទ្ធសភា ដែលត្រូវមកចូលរួមក្នុងពិធីជប់លៀងរបស់យើង » ។ នៅពេលដែលចៅក្រមម្នាក់នេះមកដល់ ម្ចាស់ផ្ទះនិងពួកក្រុមភ្ញៀវទាំងប៉ុន្មានបានដើរថយក្រោយ ដើម្បីទុកកន្លែងកិត្តិយសដ៏ខ្ពង់ខ្ពស់បំផុត ជូនចំពោះបុគ្គល

នោះ ។ បន្តិចក្រោយមក ជននេះក៏បានត្រូវអ្នកផងជ្រើសរើសឲ្យធ្វើជាស្តេចនៃពិធីជប់លៀងថែមទៀត ៖ បុគ្គលនេះក៏បានសំដែងនូវសញ្ញាក្រអឺតក្រទម ចូលចិត្តបង្គាប់គេឯង និងមានឆន្ទៈសង្កត់សង្កិននៃរាជានិយមផ្តាច់ការ ។ គឺជននេះបានបង្គាប់បញ្ជាឲ្យភ្ញៀវទាំងអស់លើកស្រាក្រហមអកឡើងគ្មានប្រណី ព្រមទាំងឲ្យយកស្រានោះជះទៅលើមុខ ឲ្យចូលក្នុងច្រមុះនៃពួកដែលមិនព្រមលើកកែវស្រាឡើងផឹក ។ ភ្លាមៗនោះ អំប៉េដូកឥតមាននិយាយស្តីថាអ្វីទាំងអស់... ប៉ុន្តែថ្ងៃស្អែកបន្ទាប់មកគាត់ បានធ្វើការកោះប្រជុំហៅរាស្ត្រប្រជា ។ គាត់បានធ្វើការចោទប្រកាន់ជាឧឡារិកទាំងចំពោះអ្នកធ្វើសេចក្តីអញ្ជើញដល់គាត់ និងចំពោះអ្នកដែលមានអាកប្បកិរិយាកោងកាចឆ្មើងឆ្មៃនៅក្នុងពេលជប់លៀង ។ គាត់បានបង្ហាញដល់ភ្នែកអ្នកទាំងអស់គ្នាថា អំពើទាំងនេះគឺជាការចាប់ផ្តើមនៃរបបជិះជាន់ផ្តាច់ការនិយម ហើយថាអំពើពាលាកំហែងកំហល់បែបនេះ មានលក្ខណៈផ្ទុយស្រឡះនឹងច្បាប់ ព្រមទាំងសេរីភាពរបស់សាធារណជន ។ បន្ទាប់ពីមានការកាត់ទោសអ្នកទាំងពីរមក គាត់ក៏បានសម្លាប់អ្នកទាំងពីរភ្លាមមួយរំពេជ ។ គាត់មានកេរ្តិ៍ឈ្មោះល្បីត្រដរថា គាត់មានជោគជ័យទៅលើសភា «១០០០នាក់» (សភានៃចាស់ព្រឹទ្ធាចារ្យ) ...ហើយដោយគាត់តែងតែមានចិត្តលំអៀងទៅខាងប្រជាជន គាត់ក៏បានបញ្ជាឲ្យពួកចៅក្រមទាំងឡាយមានអាណត្តិត្រឹមតែបីឆ្នាំប៉ុណ្ណោះ បន្ទាប់មកត្រូវផ្លាស់ប្តូរដោយមនុស្សផ្សេង ដើម្បីឲ្យមនុស្សម្នា ក់ៗមានលទ្ធភាពអាចឡើងកាន់ការសាធារណៈបាននឹងគេដែរ ។

លោកគ្រូពេទ្យអាក្រុងបានស្នើរសុំដល់ព្រឹទ្ធសភា នូវទីកន្លែងដើម្បីសាងសង់វិមានមួយជាកិត្តិយសដល់ឪពុករបស់គាត់ ដែលធ្លាប់មានស្នាដៃអស្ចារ្យនៅក្នុងវិជ្ជាជីវៈរបស់គាត់, ពោលគឺគាត់ធ្លាប់ធ្វើជាគ្រូពេទ្យដ៏ពូកែលើសនរណាៗទាំងអស់គ្រប់កាលសម័យ ។ អំប៉េដូកក៏បានងើបឡើងនៅកណ្តាលសភា ហើយក៏បានបង្វែរឆន្ទៈរបស់ពួកប្រជាជនមិនឲ្យធ្វើតាមសេចក្តីស្នើរសុំនេះឡើយ ពីព្រោះគាត់បានយល់ថាទង្វើបែបនេះ វាមានលក្ខណៈផ្ទុយនឹងសមភាព ដែលអ្នកផងតែងតែសង្វាតចង់បាន, គឺដើម្បីចៀសវាងកុំឲ្យមនុស្សណាម្នាក់ងើបឡើងខ្ពស់ជាងអ្នកដទៃជាដាច់ខាត ។ គឺយុត្តិធម៌បែបនេះហើយ, យោងតាមយោបល់របស់គាត់, ដែលជាមូលដ្ឋាននៃសេរីភាពរបស់សាធារណជន ។

ជម្ងឺពិសបានមករាតត្បាតអស់មួយរយៈពេលនៅក្នុងស្រុកសេលីនុនដែលបានបណ្តាលឲ្យមានមនុស្សស្លាប់ជាច្រើននាក់។ មនុស្សម្នាក់ៗដែលនៅរស់កាន់តែទ្រុឌទ្រោមទៅ ។ មានស្រីៗមួយភាគ បានផ្តល់កំណើតដល់កូនមុនខែ ។ អំប៉េដូកបានយល់ថា ជម្ងឺនេះបានត្រូវបណ្តាលឡើងដោយទឹកស្អុយរលួយនៃទន្លេដែលហូរមកស្រោចស្រប់ទីក្រុងនេះ ។ គាត់ក៏បានបញ្ចៀសផ្លូវទឹកដោយមធ្យោបាយខ្លួនឯង នូវ

ដើមទឹកដែលហូរមកតាមដងអូរពីរ ដែលគាត់បានបង្វែរឲ្យធ្លាក់ទៅក្នុងទឹកស្ទឹងសេលីនុន ។ ទង្វើបានខារឃាំងរាំងរាទឹកមិនឲ្យមានពិសពុល... ឬធ្លាក់ទៅក្នុងសភាពពុករលួយ ជម្ងឺពិសក៏បានរលត់រលាយឯងៗទៅវិញបាត់មួយរំពេជ ។ ពួកអ្នកស្រុកនៅសេលីនុន ក៏បានរៀបចំការជប់លៀងសប្បាយយ៉ាងអធិកអធម។ អំប៉េដូកនៅពេលនោះ ក៏បានមកបង្ហាញខ្លួននៅសេលីនុនផងដែរ ៖ អ្នកផងបានធ្វើការរួមប្រជុំគ្នា ដើម្បីផ្តល់កិត្តិយសជូនគាត់ ។ ពួកគេបានធ្វើបូជាយ័ញ្ញ ជាសក្ការៈបូជាជូនចំពោះគាត់ហាក់ដូចរូបគាត់ជាព្រះជាម្ចាស់ ដែលធ្វើឲ្យគាត់មានការសប្បាយរីករាយក្នុងចិត្តជាពន់ពេក ។

* *

*

អំប៉េដូកបានសន្មត់នៅក្នុងទ្រឹស្តីចំបងរបស់គាត់នូវធាតុទាំងបួន ៖ ទឹក, ដី, ភ្លើង និងខ្យល់ ។

គាតចចេសថា នៅក្នុងរវាងធាតុទាំងបួននេះ វាតែងតែមានចំណងមេត្រី ដែលធ្វើឲ្យធាតុទាំងនេះរួមចូលគ្នា និងកត្តានៃការបែកបាក់ ដែលធ្វើឲ្យធាតុទាំងនេះបែកឃ្លាតចេញពីគ្នា ។ គាត់បានបន្ថែមទៀតថា ធាតុទាំងបួននេះឋិតនៅក្នុងសភាពផ្លាស់ប្តូររូប ឬពុករលួយ ( អនិច្ចាសញ្ញាមិនទៀង ) ជានិច្ចនិរន្ត... ប៉ុន្តែគ្មានអ្វីៗដែលត្រូវស្លាប់បាត់រូបនោះទេ ។ នេះជាច្បាប់ធម្មតាដែលតែងតែមានជានិច្ចជាកាលតាំងពីដើមរៀងមក ហើយដែលនឹងមានតទៅទៀតជារៀងដរាប នៅក្នុងអនាគតកាលឥតមានអាក់ខាន ។

- ⋆ ថ្ងៃគឺគ្រាន់ជាដុំភ្លើងមូលមួយដុំតែប៉ុណ្ណោះ ។
- ⋆ ព្រះច័ន្ទមានរាងសំប៉ែត មានលំនាំដូចជាថាស ។
- ⋆ ផ្ទៃមេឃធ្វើឡើងដោយវត្ថុធាតុម៉្យាង មានលំនាំដូចជាកែវ ។

រីឯចំណែកព្រលឹងមនុស្សវិញ គឺជាធាតុម៉្យាងដែលអាចរត់ចូលក្នុងគ្រប់រូបកាយ... ហើយគាត់ក៏បានបញ្ជាក់ថា កាត់នៅចាំបានថាកាលពីជាតិមុនៗ គាត់ធ្លាប់មានកំណើតជាកូនស្រី, បន្ទាប់មកជាសត្វត្រី, បន្តមកទៀតជាសត្វស្លាប... មិនត្រឹមតែប៉ុណ្ណោះ គាត់ក៏ធ្លាប់មានរូបរាងជារុក្ខជាតិថែមទៀតផង ។

សេចក្តីស្លាប់របស់ទស្សនវិទូរូបនេះ ត្រូវបានគេលើកយកមកបរិយាយដោយរបៀបផ្សេងៗគ្នា ។ មតិទូទៅបានយល់ថា ដោយគាត់មានចំណង់ចង់ក្លាយខ្លួនទៅជាព្រះខ្លាំងពេក ហើយដោយគាត់បានសម្លឹងឃើញថា មានមនុស្សច្រើនគ្នា ដែលចាំតែពឹងផ្អែកជំនឿលើរូបគាត់តែប៉ុណ្ណោះ... គាត់ក៏បានសំរេចក្លែងខ្លួនធ្វើជាព្រះរហូត

ដល់ចុងចប់នៃជីវិតរបស់គាត់ ។ គឺនៅក្នុងមូលហេតុដូច្នេះហើយ ដែលនៅពេលដែលគាត់ដឹងខ្លួនថា រូបកាយរបស់គាត់កំពុងតែមានសភាពទ្រុឌទ្រោមដោយជរាភាព គាត់ក៏បានចង់បញ្ចប់ជីវិតគាត់ ក្នុងសភាពជាក់ស្តែងអស្ចារ្យ ប្រហែលគ្នានឹងអព្ភូត-ហេតុមួយ ។

បន្ទាប់ពីបានព្យាបាលស្ត្រីម្នាក់នៅអាគ្រីយ៉ង់ឲ្យជាសះស្បើយរោគ... នាងស្ត្រីនោះឈ្មោះប៉ង់តេ ដែលបានត្រូវគ្រូពេទ្យច្រើនគ្នាបោះបង់ចោលទៅហើយ ហើយដែលបានធ្លាក់ចូលទៅក្នុងសភាពជិតដាច់ខ្យល់ទៅហើយដែរ គាត់ក៏បានរៀបចំពិធីបូជាយ័ញ្ញមួយដ៏មហាឱឡារិក ដែលនៅក្នុងឱកាសនោះ គាត់បានអញ្ជើញអ្នកមុខអ្នកការចំនួន៨០នាក់ ក្នុងគោលប្រាថ្នាឲ្យពួកគេជឿថា គាត់បានបាត់រូបទៅហើយ ៖ នៅពេលដែលពិធីជប់លៀងបានប្រព្រឹត្តទៅចប់សព្វគ្រប់កាលណា, ហើយនៅពេលដែលភ្ញៀវម្នាក់ៗថយខ្លួនទៅសំរាកនៅក្រោមដើមឈើ ឬក៏ទៅនៅកន្លែងផ្សេងទៀត... អំប៉េដូកដោយគ្មាននិយាយស្តីអ្វីទាំងអស់ក៏បានឡើងទៅលើកំពូលភ្នំ(ភ្លើង) អេតណា...ហើយក៏លោតចូលទៅកណ្តាលអណ្តាតភ្លើងតែម្តង ។ អូរ៉ាស (Horace) ដែលបានធ្វើអត្ថាធិប្បាយអំពីមរណភាពនេះបានសរសេរថា ៖

**Deus immortalis haberi Dùm cupit Empedocles, ardentem frigidus AErhnam Insiluit...**

អំប៉េដូកមានលក្ខណៈជាមនុស្សត្រឹមត្រូវណាស់ ។ គាត់តែងទុកសក់វែងធ្លាក់រំសាយ ហើយមានពាក់មកុដធ្វើពីស្លឹកឡូរីយេនៅលើក្បាល ។ គាត់មិនដែលដើរតាមផ្លូវថ្នល់ ដោយគ្មានមនុស្សច្រើនហែរហមគាត់នោះឡើយ ។ គាត់តែងតែញាំងឲ្យអ្នកផងដែលបានឃើញរូបគាត់ មានសេចក្តីកោតគោរពចំពោះគាត់គ្រប់ៗគ្នា ។ នៅគ្រប់ពេលវេលា គាត់ធ្លាប់តែពាក់ស្បែកជើងសង្រែកមួយ ដែលមានពាសស្ពាន់...។ នៅពេលដែលគាត់បានលោតចូលទៅក្នុងភ្លើងកាលណា ចំហាយភ្នំភ្លើងដែលជះមកយ៉ាងខ្លាំង បានធ្វើឲ្យស្បែកជើងរបស់គាត់របូតមួយចំហៀងចេញមកខាងក្រៅវិញ ហើយដែលត្រូវអ្នកផងបានរកឃើញ ។ គេក៏បានដឹងអំពីល្បិចកល្បក្រឡិចក្រឡុចរបស់គាត់ ។

ដូច្នេះទៅ បុរសកំសត់អំប៉េដូក ដោយមិនបានប្រុងប្រយ័ត្នជាមុន ក៏បានបណ្តាលឲ្យភ្លាត់ចំណាប់បែកការណ៍... គាត់មិនបានប្រែក្លាយទៅជាព្រះជាម្ចាស់ ក៏មានថានៈត្រឹមតែជាអ្នកឆរបោកទៅវិញ ។

ក៏ប៉ុន្តែ គាត់ធ្លាប់មានគុណសម្បត្តិច្រើន ៖ គាត់ធ្លាប់ធ្វើជាពលរដ្ឋម្នាក់ដ៏ល្អ ហើយមិនដែលចង់បានផលប្រយោជន៍ពីនរណាទេ ។ នៅពេលតែប៉េតុង ( រាជាផ្តាច់ការនៅអាគ្រីយ៉ង់ ) ឪពុករបស់គាត់បានស្លាប់ទៅ, អ្នកខ្លះចង់ធ្វើការបះបោរតណ្តើម

រាជ្យនៅអាគ្រីយ៉ង់ ។ អំប៉េដូកក៏បានធ្វើការរួមប្រជុំប្រជាពលរដ្ឋភ្លាមមួយរំពេច បានបន្សាបពិសនៃការបះបោរ ដោយមិនធ្វើឲ្យរឿងនេះផ្ទុះធ្លាយវែងឆ្ងាយ... ហើយដើម្បីចង់បង្ហាញថា គាត់គោរពនូវគោលគំនិតស្មើភាព, គាត់ក៏បានចែកទ្រព្យសម្បត្តិរបស់គាត់ ជាមួយជនតាំងឡាយណា ដែលមានការខ្វះខាតជាងរូបគាត់ ។

ទស្សនវិទូរូបនេះបានចំរើនលូតលាស់នៅក្នុងអូឡាំព្យាដទី៨៤ ។ ប្រជាជននៅអាគ្រីយ៉ង់បានសង់រូបសំណាកមួយឲ្យគាត់ ហើយបានរក្សាសេចក្ដីកោតគោរព និងស្រឡាញ់ចំពោះរូបគាត់ ទុកស្មើនឹងព្រះ ។

គាត់មានអាយុច្រើនណាស់ហើយ នៅពេលដែលគាត់ស្លាប់ទៅ ក៏ប៉ុន្តែគេមិនដឹងថា គាត់មានអាយុប៉ុន្មានដោយច្បាស់លាស់នោះទេ ។៚

❑ ❑

❑

# ជីវិតរបស់អេពីគួរ
# ÉPICURE

*– កើតនៅក្នុងឆ្នាំទី-៣ នៃអូឡាំព្យ៉ាដទី-១០៩ ។ ស្លាប់នៅ ឆ្នាំទី-២នៃអូឡាំព្យ៉ាដ ទី-១២៧ , នៅក្នុងជន្មាយុ ៧២ឆ្នាំ ។

អេពីគួរដែលជាមនុស្សម្នាក់នៅក្នុងត្រកូលរបស់ពួកហ្វីឡៃដ៍ មានកំណើតនៅទីក្រុងអាតែ្កនក្នុងកម្លុងអូឡាំព្យ៉ាដទី-១០៩។ នៅក្នុងអាយុ ១៤ឆ្នាំ, គាត់បានចាប់ផ្ដើមសិក្សាអំពីទស្សនវិជ្ជា ។ គាត់បានហាត់រៀនមួយរយៈពេលនៅសាម៉ូស, ក្រោមការដឹកនាំរបស់ប៉ម់ហ្វីល-ប្លាតូនីស្យាង, ក៏ប៉ុន្តែគាត់មិនសូវបានជាចូលចិត្តទ្រឹស្ដីមនោគមវិជ្ជារបស់បុគ្គលក្រោយនេះប៉ុន្មានទេ។ គាត់បានថយចេញពីសាលារបស់លោកគ្រូម្នាក់នេះទៅ, ហើយក៏មិនបានទទួលយកគ្រូឯណាថ្មីទៀតឡើយ ។ គេបានពោលថាគាត់ធ្លាប់បានបង្ហាត់បង្រៀនក្បួនវេយ្យាករណ៍ ...ក៏ប៉ុន្តែមិនយូរប៉ុន្មានគាត់ក៏មានសេចក្ដីធុញថប់នឹងមុខវិជ្ជានេះដែរ ។ គាត់ចូលចិត្តអានសៀវភៅរបស់ដេម៉ូគ្រីត... ដែលគាត់ដកស្រង់ទាញយកចំណុចសំខាន់ៗយកមកសរសេរជាប្រព័ន្ធវិជ្ជាផ្ទាល់របស់គាត់, នៅថ្ងៃក្រោយមក ។

នៅក្នុងអាយុ ៣២ ឆ្នាំ គាត់បានបង្ហាត់បង្រៀនទស្សនវិជ្ជានៅមេតឺឡាំង, បន្ទាប់មកទៀតនៅឡាំសាក ។ ប្រាំឆ្នាំក្រោយមកទៀត, គាត់ក៏បានត្រឡប់មកទីក្រុងអាតែ្កនវិញហើយបានបង្កើតបក្សថ្មីមួយនៅទីនោះ ។ គាត់បានទិញចំការមួយយ៉ាងល្អ ដែលគាត់ដាំដំណាំដោយផ្ទាល់ដៃខ្លួនឯង ។ គឺនៅទីនោះហើយដែលគាត់បានបង្កើតសាលារៀនរបស់គាត់។ គាត់មានជីវភាពរស់នៅសុខស្រួលសប្បាយជាមួយនឹងសាវ័ករបស់គាត់ដែលគាត់បង្ហាត់បង្រៀននៅកណ្ដាលចំការដោយដើរលេងកំសាន្តនៅក្នុងសួនផង និងធ្វើកិច្ចការច្បារដំណាំបណ្ដើរៗផងជាមួយគ្នា ។ គាត់បានឲ្យសិស្សទាំងឡាយទន្ទេញចាំមាត់នូវក្បួនសុភាសិត ដែលគាត់បានសរសេរដោយខ្លួនឯង ។ មនុស្សជាច្រើនណាស់បានមកពីគ្រប់ទិសទីនៃប្រទេសក្រិក, ដើម្បីគ្រាន់តែបានសប្បាយស្ដាប់ពាក្យប្រៀនប្រដៅរបស់គាត់... ហើយនិងពិចារណាអំពីវត្តមានរបស់គាត់នៅឆ្ងាយពីគេពីឯងកណ្ដាលវាលលំហនៃធម្មជាតិ។

អេពីគួរជាមនុស្សម្នាក់ ដែលតែងពោលសំដីស្មោះត្រង់ពីក្នុងដួងចិត្ត ។ គាត់

មានអាការៈស្លូតបូត, សុភាពរាបសារ ព្រមទាំងចេះគួរសមជាមួយនឹងមនុស្ស គ្រប់ៗគ្នា, គាត់មានចិត្តសប្បុរសជាមួយនឹងបងប្អូន និងក្រុមមិត្តភ័ក្តិរបស់គាត់ ជាពន់ពេកណាស់...រហូតដល់គាត់បានចំណាយពេលវេលារសប់គាត់ស្ទើរតែទាំង អស់ឲ្យពួកអ្នកទាំងនេះ, ហើយតែងផ្តល់ឲ្យពួកគេនូវអ្វីៗទាំងប៉ុន្មានដែលគាត់មាន នៅក្នុងខ្លួន ។ គាត់បានផ្តែផ្តាំជាពិសេសឲ្យ ពួកសាវ័ករបស់គាត់មានចិត្តមេត្តាករុណា ជាពិសេសជាមួយនឹងឈ្នួលបម្រើ ។ ខ្លួនគាត់វិញតែងមានសប្បុរសធម៌ជាមួយ នឹងឈ្នួលបម្រើរបស់គាត់លើសពីនរណាៗទាំងអស់ ។ គាត់អនុញ្ញាត្តឲ្យពួកអ្នក ទាំងនេះបានរៀនសូត្រទទួលចំណេះវិជ្ជា, ដោយខ្លួនគាត់យកចិត្តទុកដាក់ធ្វើជាគ្រូ ហាក់ដូចជាពួកគេជាសាវ័ករបស់គាត់ដូច្នោះដែរ ។

អេពីគួររស់នៅគ្រប់ពេលវេលា ដោយបរិភោគតែនំបុ័ងហើយនិងទឹកព្រម ទាំងបន្លែផ្លែឈើដែលមាននៅក្នុងសួនរបស់គាត់តែប៉ុណ្ណោះ ។ ជួនកាលគាត់ និយាយប្រាប់ទៅកូនចៅគាត់ដូច្នេះថា ៖ « ចូរយកទឹកដោះគោនិងហ្វ្រូម៉ាសឲ្យខ្ញុំខ្លះៗ ដើម្បីខ្ញុំអាចទទួលទានឆ្ងាញ់នៅពេលណាដែលខ្ញុំចង់» ។ នេះហើយ, ឡាអ៊ែរគំពោ-ល, ជាជីវិតរបស់មនុស្សម្នាក់ ដែលអ្នកផងតែងនឹកស្មានថាមានកម្មសិទ្ធក្រាស់ក្នុង កាមតណ្ហានិងក្នុងសភាពឆ្ងាញ់ ។

សីសេរ៉ុង, នៅក្នុងសៀវភៅរបស់គាត់ដែលមានចំណងជើងថា «ទុស្ស-គូឡាន» បានពោលថា ៖ « ឱ! អេពីគួរជាជនមួយរូបដែលចេះរស់នៅ ដោយសឹង តែគ្មានរបស់អ្វីទាំងអស់ ! » ។

ពួកសាវ័ករបស់អេពីគួរគ្រប់ៗរូប តែងតែរស់នៅដោយយកតម្រាប់តាម ការបរិភោគក្រៀមក្រោះនិងសីលធម៌អត់ធ្មត់ដទៃទៀតរបស់លោកគ្រូខ្លួន ។ ពួកគេ រស់នៅដោយសារតែបន្លែហើយនិងទឹកដោះដូចតែគាត់ដែរ ។ មានពួកអ្នកខ្លះ ក៏ទទួលទានស្រាក្រហមបន្តិចបន្តួចទៅ...ប៉ុន្តែពួកអ្នកឯទៀតទាំងអស់ផឹកតែទឹក ប៉ុណ្ណោះ ។ អេពីគួរមិនបានចង់ឲ្យពួកគេដាក់ប្រាក់រួមជាមួយគ្នាឲ្យដូចជាពួកសាវ័ក របស់ពីតាគ្ក័រនោះឡើយ.. ពីព្រោះគាត់យល់ថាអំពើនេះគ្រាន់តែជាការមិនទុក ចិត្តគ្នាឯងតែប៉ុណ្ណោះ គឺពុំមែនជាការរួបរួមដោយស្មោះសរជាមួយគ្នានោះឡើយ ។

គាត់មានជំនឿថាគ្មានអ្វីដែលថ្លៃថ្នូរខ្ពង់ខ្ពស់ជាងការរៀនសូត្រអំពីទស្សនវិជ្ជា នោះទេ ។ ពួកយុវជនគួរតែហាត់រៀនពីក្មេងឲ្យហើយទៅ ...ចំណែកពួកមនុស្ស ចាស់វិញមិនត្រូវនឿយណាយនឹងមុខវិជ្ជានេះទាល់តែសោះ ...ដោយហេតុថា គោលបំណងធំរបស់មនុស្សទាំងអស់គ្នានៅលើផែនដីនេះ, គឺស្វែងរកសេចក្តីសុខ សប្បាយតែប៉ុណ្ណោះឯង ។ គឺទីដៅនេះហើយដែលមនុស្សត្រូវតែខំប្រឹងស្រវា ឈោង ។

សុភមង្គលដែលពួកទស្សនវិទូទាំងអស់ពោលអធិប្បាយ គឺជាសុភមង្គលដែលបានមកពីធម្មជាតិ... ពោលគឺជាសេចក្ដីសុខក្សេមក្សាន្តមួយដែលគេអាចរកបាននៅក្នុងជាតិនេះ ដោយសារតែការប្រើកម្លាំងឥទ្ធិពលពីធម្មជាតិទាំងស្រុង ។ សេចក្ដីសុខសប្បាយនៅក្នុងលោកិយនេះ, ចំពោះអេពីគួរ គឺពុំមែនឋិតនៅក្នុងអំពើស្រួលស្រណុកនៃកាមតណ្ហា ឬក៏ការផឹកស៊ីឆ្ងាញ់ពិសារនោះឡើយ ក៏ប៉ុន្តែឋិតនៅក្នុងអារម្មណ៍ស្ងប់ស្ងៀមគ្មានសេចក្ដីទុក្ខខ្វល់ខ្វាយហើយនិងសុខភាពនៅក្នុងអង្គប្រាណ ។ គាត់គ្មានគំនិតអ្វីទៀតទេក្នុងការស្វែងរកសម្បត្តិទ្រព្យដ៏កំពូល, ក្រៅតែពីការរកឲ្យបានរបស់ទាំងពីរខាងលើនេះនៅក្នុងពេលជាមួយគ្នា ។

គាត់បានបង្ហាត់បង្ហាញឲ្យឃើញថា សីលធម៌ជាឧបករណ៍មួយដ៏មានកម្លាំងសក្តិសិទ្ធជាទីបំផុតដើម្បីស្វែងរកសុភមង្គលឲ្យជីវិត គឺពីព្រោះដោយហេតុថាគ្មានអ្វីដែលធ្វើឲ្យមនុស្សរស់បានសុខសប្បាយជាងការរស់នៅដោយទៀងត្រង់នៅក្នុងសេចក្ដីសុច្ចរិតយុត្តិធម៌នោះទេ, ដោយគ្មានអ្វីត្រូវបន្ទោសខ្លួនឯង, ដោយគ្មានបានប្រព្រឹត្តអកុសលកម្មឬឧក្រិដ្ឋកម្ម, ដោយគ្មានបានបំផ្លិចបំផ្លាញផលប្រយោជន៍របស់អ្នកដទៃ, ដោយធ្វើអំពើល្អឲ្យបានយ៉ាងច្រើនបំផុតដែលគេអាច ធ្វើទៅបាន, ហើយនៅចុងចប់, ដោយចៀសវាងកុំខកខានក្នុងការបំពេញករណិយកិច្ចជានិច្ចជាកាលចំពោះជីវិតរស់នៅ ។ គាត់បានទាញសេចក្ដីសន្និដ្ឋានអំពីគំរោងទ្រឹស្ដីខាងលើនេះថា ៖ គឺមានតែជនដែលរស់នៅក្នុងសេចក្ដីសុច្ចរិតយុត្តិធម៌តែប៉ុណ្ណោះទេដែលអាចរស់នៅបានដោយសុខសប្បាយ, ដូច្នេះសីលធម៌ ឬ កុសលធម៌ជារបស់ចាំបាច់ត្រូវតែមាននៅក្នុងជីវិតមួយដែលប្រកបដោយសេចក្ដីសុខ ។

គាត់មិនដែលមានការហត់នឿយ ក្នុងការពោលថ្លែងសរសើរអំពីការចេះរស់នៅដោយសេចក្ដីអត់ធ្មត់ និងចេះតមចំពោះចំណីអាហារណាដែលឲ្យទុក្ខទោស, ដែលជាលក្ខណ្ឌមួយដ៏ប្រសើរ ធ្វើឲ្យមានមនុស្សមានអារម្មណ៍នឹងធ្ងន់អាចថែរក្សាសុខភាពល្អនៅក្នុងខ្លួន ...មិនត្រឹមតែប៉ុណ្ណោះសោតអាចកែខៃធ្វើឲ្យមានកម្លាំងកំហែងបរិបូរណ៍មកវិញទៀតផងនៅពេលណាដែលអង្គកាយធ្លាក់ចុះទន់ខ្សោយ ។ គេត្រូវចេះរស់នៅ, គាត់ពោល, ដោយមានរបស់របរតិចតួចបំផុតនៅក្នុងខ្លួន, នេះហើយជាទ្រព្យសម្បត្តិដ៏ធំបំផុត និងដ៏ល្អប្រសើរបំផុតដែលគេអាចរកបាន។ ដោយហេតុថាម្ហូបម្ហារធម្មតាបំផុតធ្វើឲ្យយើងបានទទួលសភាពឆ្ងាញ់ជាងម្ហូបដ៏អស្ចារ្យនោះទៅទៀត កាលណាយើងឃ្លាន ដូចពាក្យដែលថា «ឃ្លានឆ្ងាញ់ ស្រឡាញ់ល្អ»... គេក៏អាចមានសុខភាពដ៏ល្អប្រសើរផងដែរ កាលណាគេរស់នៅក្នុងសភាពធម្មតាជាទីបំផុត។ នៅពេលនោះ គេគ្មានខួរក្បាលវិវរវល់ខ្វល់ខ្វាយ, គេមានតែចិត្តថ្លើមបរិសុទ្ធ, ដួងព្រលឹងស្ងប់ស្ងៀម, គំនិតមានសេរី... ហើយគេអាចស្គាល់ការរីក

រាយសប្បាយក្នុងការប្រឹងប្រែងស្វែងរកការពិតថែមទៀត... ពោលគឺការស្វែងរកធ្វើអំពើណាដែលគួរធ្វើ ... ជាជាងការធ្វើអំពើណា ដែលប្រកបដោយអកុសលធម៌ ។ គាត់បានពោលបន្ថែមទៀតថា, ការជប់លៀងដែលគេធ្វើម្តងម្កាលតែងផ្តល់នូវការរីករាយសប្បាយជាងការស៊ីផឹកញឹកញាប់.. ហើយមនុស្សយើងតែងមានលទ្ធភាពចេះអត់ទ្រាំចំពោះសេចក្តីអភ័ព្វក្នុងវាសនា បើកាលណាគេចេះរស់នៅសប្បាយក្នុងសេចក្តីក្រទុរគត់, តែជាមួយរបស់របរបន្តិចបន្តួចដែលជាសេចក្តីត្រូវការចាំបាច់នៃធម្មជាតិ, ជាជាងកាលណាគេរស់នៅក្នុងសេចក្តីសំបូរហូរហៀរ និងក្នុងសេចក្តីអំនួតរង់រឿង ។

គេគួរតែប្រយ័ត្នប្រយែងមែនទែន, គាត់ពោលបន្ថែម, ចៀសវាងអំពើអបាយមុខដែលធ្វើឲ្យអង្គកាយធ្លាក់ខ្សោយ ហើយនិងធ្វើឲ្យស្មារតីភ្លេចភ្លាំងភាន់វង្វេង ។ ហើយបើទោះចំពោះសេចក្តីសប្បាយដ៏ប្រសើរឯណា ដែលមនុស្សគ្រប់គ្នាត្រេកត្រអាលចង់ស្រវាឱបក្តី, ក៏គេត្រូវចៀសវាងចេញឆ្ងាយ, កាលណាបើគេថ្លឹងសេចក្តីទុក្ខលំបាក ដែលជាលទ្ធផលវាមានសភាពធ្ងន់ធ្ងរហួសពេកជាងសភាពរីករាយដែលគេត្រូវបានទទួល ។ ផ្ទុយទៅវិញគេគួរតែចេះអត់ទ្រាំក្នុងការលំបាក បើកាលណាលទ្ធផល ដែលហុចមកវាមកជាមួយគ្នានឹងសេចក្តីសុខសប្បាយដ៏មហាប្រសើរ ហួសពីសេចក្តីទុក្ខវេទនាដែលគេបានឆ្លងកាត់ ។

ជំនឿរបស់គាត់មួយ ដែលមានសភាពផ្ទុយគ្នាពីជំនឿរបស់ពួកសេរីណាអ៊ីក... គឺសេចក្តីខ្វិលច្រអូស, ឬសភាពស្ពឹកស្ងោកងុយគឺជាសុភមង្គលជានិច្ចនិរន្តរ៍, ចំណែកសេចក្តីសប្បាយខាងផ្នែកបញ្ញាស្មារតី តែងតែមានន័យជ្រៅទូលំទូលាយជាងសេចក្តីសប្បាយខាងផ្នែកអង្គកាយ ។ គឺពីព្រោះថា, គាត់ពោល , អង្គកាយទទួលដឹងឮតែពីសេចក្តីឈឺចាប់បច្ចុប្បន្ន, រីឯបញ្ញាស្មារតីវិញ ទទួលដឹងឮអំពីសេចក្តីឈឺចាប់ដែលកើតមានឡើងក្នុងបច្ចុប្បន្នកាលផង, ក្នុងអតិតកាលផង, ក្នុងអនាគតកាលថែមទៀត ។ ( ក.ក.ន. ៖ ថ្ងៃក្រោយមក, នៅក្នុងសតវត្សរ៍ ទី-២០ អ្នកប្រាជ្ញអាល្លឺមង្គម្នាក់ឈ្មោះហៃដាក់គ្គើរ - Heidegger - បានសរសេរតាមទ្រិស្តីរបស់អេពីគួរថា ៖ មនុស្សយើងគឺជាសត្វលោកដែលរស់នៅក្នុងទីឋានឆ្ងាយៗ ពោលគឺរស់នៅក្នុងអតិតកាលផង, និងក្នុងអនាគតកាលផង... ក៏ប៉ុន្តែមិនសូវជាបានរស់នៅក្នុងបច្ចុប្បន្នកាលនេះទេ ... L'homme, c'est l'être des lointains - ) ។

អេពីគួរបានយល់ថាព្រលឹងរបស់យើងក៏មាននិស្ស័យនិងលក្ខណៈជាអង្គកាយផងដែរ គឺដោយហេតុថាព្រលឹងនេះឯងដែលបណ្តាលឲ្យអង្គកាយមានចលនា។ គឺថាព្រលឹងនេះឯងបានចូលរួបរួមជាមួយនឹងអង្គកាយក្នុងការសប្បាយក៏ដូចជាក្នុងសេចក្តីទុក្ខវេទនាខ្វះខាត ឬក្នុងពិការភាព ។ គឺព្រលឹងនេះឯងដែល

បានធ្វើឲ្យយើងភ្ញាក់ឡើងក្រញាងក្នុងនាទី ដែលយើងកំពុងនិទ្រាលក់ស្កប់ស្កល់ ។ នៅទីបំផុត, គឺព្រលឹងនេះហើយដែលបានញ៉ាំងឲ្យរូបយើងដូរពណ៌សំបុរយោងទៅតាមចលនាផ្សេងៗ ។ គាត់បានពោលបញ្ជាក់ថា ៖ បើសិនជាព្រលឹងពុំមានលក្ខណៈនិស្ស័យជាអង្គកាយនោះទេ... នោះច្បាស់ជាព្រលឹងគ្មានអ្វីទាក់ទងជាមួយនឹងខ្លួនប្រាណសោះឡើយ។

**Tangere enim ettangi, nisi corpus, nula potest res.**

គាត់បានសន្និដ្ឋានថាព្រលឹងគឺគ្មានអ្វីក្រៅតែអំពីវត្ថុធាតុម្យ៉ាងយ៉ាងស្ដើងហើយស្រាលដែលមានពាសពេញនៅក្នុងខ្លួនយើង...ហើយដែលមានថានៈជាអវយវៈរបស់យើងផងដែរប្រហែលគ្នានឹងដៃជើង ឬក៏ក្បាលរបស់យើង ។ ម្ល៉ោះហើយគាត់ក៏បានទាញសេចក្ដីថា ៖ កាលណាអង្គកាយរបស់យើងស្លាប់, ព្រលឹងក៏ត្រូវស្លាប់ជាមួយគ្នាដែរ ។ នៅពេលនោះ, ព្រលឹងនឹងត្រូវរលាយបាត់ដូចជាផ្សែងទឹកហើយក៏គ្មានមនោសញ្ចេតនាអ្វីបន្តិចបន្តួចសោះនៅក្នុងខ្លួនរបស់យើង ។ ដូច្នេះទៅសេចក្ដីស្លាប់មិនមែនជារបស់មួយដ៏អាក្រក់សាមាន្យនោះទេ ៖ ដោយហេតុ-ថាសេចក្ដីល្អនិងសេចក្ដីអាក្រក់ វាឋិតនៅក្នុងមនោសញ្ចេតនាតែប៉ុណ្ណោះឯង ។ ម្ល៉ោះហើយ, ដោយសេចក្ដីស្លាប់មានន័យថាជាការបាត់បង់នូវមនោសញ្ចេតនានៅពេលនោះ, សេចក្ដីស្លាប់ក៏គ្មានទំនាក់ទំនងអ្វីជាមួយនឹងរូបយើងផងទេ... ពីព្រោះយើងមិនដែលបានធ្វើអ្វីរួបរួមចូលគ្នា ជាមួយនឹងសេចក្ដីស្លាប់ម្ដងណាទេ ។ ពោល, កាលណាយើងនៅរស់, វាឥតនៅទីនោះទេ, ហើយកាលណាបើវាមកដល់វិញ, យើងក៏លែងនៅទីនោះទៅហើយ ។ តាមដោយសេចក្ដីពិត, តាំងពីយើងបានកើតមកនៅលើភពផែនដីនេះ... គឺជាការធម្មតាពេកណាស់ដែលយើងតែងតែចង់រស់នៅដោយទាញយកសេចក្ដីសុខសប្បាយឲ្យបានច្រើនជាទីបំផុត ។ ក៏ប៉ុន្ដែគេមិនត្រូវចចេសចង់នៅទីនោះទៀតទេ, ក៏ដូចតែមនុស្សម្នាក់ដែលបានបរិភោគឆ្ងាញ់រួចហើយក៏មិនត្រូវចចេសចង់អង្គុយនៅកន្លែងតុម្ហូបតទៅទៀតដែរ ។

( <u>កកន</u> ៖ ទ្រិស្ដីនៃសេចក្ដីស្លាប់របស់អេពីគួរត្រូវបានស្រង់យកចេញមកពីលទ្ធិព្រះពុទ្ធសាសនា ...ថ្វីបើទ្រិស្ដីទាំងពីរនេះមានសេចក្ដីអធិប្បាយខុសប្លែកគ្នាបន្តិចបន្តួចក៏ដោយ។ ព្រះពុទ្ធទ្រង់បានថ្លែងថាសេចក្ដីស្លាប់ជារបស់មួយដ៏ទៀងទាត់ ឬជាសេចក្ដីចាំបាច់...ចំណែកអេពីគួរបានពោលថាសេចក្ដីស្លាប់មិនមែនជារបស់មួយដ៏អាក្រក់នោះទេ ...។ ក៏ប៉ុន្ដែទ្រិស្ដីទាំងពីរបានអះអាងថា សេចក្ដីស្លាប់គឺជាការបាត់បង់នូវមនោសញ្ចេតនា។ សូមអានអំពីសេចក្ដីអធិប្បាយនៃសេចក្ដីស្លាប់នៅក្នុងធម៌ព្រះពុទ្ធ ៖ **អចិរំ វតយំកាយោ,** ឱ! កាយនេះមិនយូរសោះឡើយ , **បឋវិំ អធិសេស្សតិ,** នឹងដេកសង្កត់លើផែនដី, **ឆុឌ្ឌោ អបេតវិញ្ញាណោ ,** មានវិញ្ញាណ

ទៅប្រាសហើយបុគ្គលនឹងចោលនៅ , **និរត្ថំ ឧកលិង្គរំ ,** បីដូចជាអង្កត់ឱសរកប្រ-យោជន៍គ្មាន )។

❑

អេពីគួរបានពោលថា ៖ មនុស្សយើងដោយភាគតិចតួចណាស់ដែលចេះទាញយកប្រយោជន៍ពីជីវិត ។ ហើយគាត់ពោលថាមនុស្សគ្រប់ៗគ្នាតែងតែមើលស្រាលចំពោះស្ថានភាពបច្ចុប្បន្នដែលគេកំពុងតែរស់នៅ ។ ម្ល៉ោះហើយមនុស្សម្នាក់ៗចេះតែនឹកស្មានស្រមៃ ឬ មានគោលប្រាថ្នាថាគេនឹងបានរស់ក្សេមក្សាន្តទៅថ្ងៃមុខ , ក្នុងរំពេជនោះ, ក៏ស្រាប់តែសេចក្ដីស្លាប់បានមកដល់ ...នៅចំពេលមួយដែលគេមិនទាន់បានសម្រេចគោលបំណងអ្វីទាំងអស់, ដែលជាហេតុបណ្ដាលឲ្យជីវភាពរបស់មនុស្សជួបប្រទះនឹងសេចក្ដីអភ័ព្វដល់ម្ល៉េះ ។ ម្ល៉ោះហើយគ្មានអ្វីដ៏ត្រឹមត្រូវនិងដ៏មានប្រយោជន៍ជាងការរស់ឲ្យបានសប្បាយ នៅក្នុងពេលបច្ចុប្បន្ននេះទេ... ដោយមិនបាច់គិតពីអនាគតវែងឆ្ងាយ ។ ពោល, គេមិនត្រូវរាប់ពីសេចក្ដីសុខនៃជីវិតមួយដោយសារតែគេមានអាយុវែងនៅលើផែនដីនេះទេ... គឺត្រូវរាប់តាមអាការៈសប្បាយនិងរសជាតិឆ្ងាញ់ពិសារដែលយើងបានភ្លក្សនោះវិញ ។ ជីវិតមួយខ្លីដែលគេបានប្រទះការសប្បាយ, គាត់ពោល, វាប្រសើរជាងជីវិតមួយវែងដែលគេប្រទះនឹងសេចក្ដីធុញថប់។ គឺរសជាតិឆ្ងាញ់ពិសារនៅក្នុងម្ហូបអាហារដែលយើងតែងស្វែងរក... មិនមែនចំនួនសាច់ទាំងដុំៗដែលគេរៀបចំមិនបានល្អនោះទេ ។ បើយើងគិតថាបន្ទាប់ពីសេចក្ដីស្លាប់ទៅ, យើងនឹងបាត់បង់នូវអាការៈសប្បាយហើយនិងសភាពចំណោញទាំងប៉ុន្មាននៅក្នុងជីវិត, ជារៀងរហូតតទៅ... យើងក៏គួរតែគិតពិចារណាផងដែរថាកាលពីមុនពេលដែលយើងកើតមក, យើងក៏មិនបានប្រាថ្នាមកស្វែងរកសភាពឆ្ងាញ់អស់ទាំងនេះទេ... ម្ល៉ោះហើយនៅពេលដែលយើងស្លាប់ទៅ, យើងក៏ច្បាស់ជាគ្មានចំណង់សប្បាយក្នុងរឿងស៊ីចុកបុកទំពារបែបនេះតទៅទៀតដែរ ។

គឺជាសេចក្ដីទន់ខ្សោយមួយដ៏ធំដែលមនុស្សត្រូវខ្លាចអំពីអ្វីៗដែលគេនិយាយពីឋាននរក ។ រឿងទុក្ខវេទនារបស់តង់តាល, ស៊ីស៊ីហ្វ, ទីទី, និងពួកក្រុមនារីដាណៃយ៉ាដ, គឺសុទ្ធសឹងជារឿងព្រេងកំប្លែងដែលគេបង្កើតមកមួយសេរី, ដើម្បីធ្វើការបំភ័យនិងជំរុញឲ្យមនុស្សបានស្គាល់តណ្ហានិងសេចក្ដីរំភើបតក់ស្លុតដែលបណ្ដាលឲ្យពួកគេភាន់ភាំងវង្វេងស្មារតី និងឈឺចាប់វេទនានៅក្នុងជាតិនេះ ។ នៅទីបំផុត, មនុស្សយើងគួរតែរលាស់ចោលឲ្យអស់នូវជំនឿនិងសេចក្ដីតក់ស្លុតដូចខាងលើនេះដែលគ្មានលទ្ធផលអ្វី, ក្រៅតែពីបានធ្វើឲ្យប៉ះពាល់ដល់សេចក្ដី

សម្រាកនិងសភាពស្រណុកក្សេមក្សាន្តនៃជីវិតរបស់ពួកគេតែប៉ុណ្ណោះ ។

គាត់បានយល់ថាសេរីភាពរបស់មនុស្សគឺឋិតនៅទាំងស្រុងក្នុងការមិនរវីរវល់ខ្វល់ខ្វាយឬការគ្មានជំនឿ ។ គាត់បានទាត់ចោលនូវបញ្ញាវាសនាកម្ម។ គាត់បានពោលថារឿងទស្សន៍ទាយរបស់ហោរាជារឿងមួយដែលគ្មានប្រយោជន៍... ពីព្រោះគ្មាននរណាម្នាក់ដែលដឹងមុនអំពីអ្វីៗដែលត្រូវកើតឡើងនៅអនាគតនោះទេ, ពី-ព្រោះរឿងអនាគតកាលជារឿងជំពាក់ជំពិនជាមួយនឹងការរវើរវាយនិងចិត្តសាវារបស់មនុស្សជាតិ,ហើយរឿងអស់ទាំងនេះគ្មានបុព្វហេតុអ្វីដ៏ជាចាំបាច់នោះទេ ។

អេពីគួរតែងបានផ្តល់ភាពឧត្តុងឧត្តមជានិច្ចដល់ព្រះជាម្ចាស់ ។ គាត់តែងចង់ឲ្យអ្នកផងមានសេចក្តីគោរពកោតខ្លាចព្រះជាកំពូល ។ គាត់បានហាមប្រាមជាដាច់ខាតមិនឲ្យនរណាម្នាក់យល់ថា គាត់បានមាក់ងាយអំពីឋានសួគ៌ឋានសុខនិងសភាពអមតៈរបស់ព្រះជាម្ចាស់ ។ មនុស្សដែលមិនជឿព្រះ, គាត់ពោល, ពុំមែនជាជនណាដែលបានទាត់ចោលនូវព្រះនិងទេព្តា ដែលប្រជាពលរដ្ឋបានស្រឡាញ់ផ្កាប់មុខនោះឡើយ ។ មនុស្សដែលមិនជឿព្រះគឺជាជនណាដែលបានយកអំពើស្មោកគ្រោក និងលក្ខណៈទន់ខ្សោយរបស់ពួកខ្លួនយកទៅធ្វើយសសក្តិឲ្យព្រះនិងទេព្តាខ្ចីពាក់ធ្វើជាសម្លៀកបំពាក់ ។

គាត់បានយល់ថាព្រះជាម្ចាស់គួរតែឲ្យយើងគោរពកោតខ្លាច ដោយសារតែគុណធម៌និងធម្មជាតិដ៏ល្អរបស់ទ្រង់នោះក៏គ្រប់គ្រាន់ហើយ ។ ហើយយើងត្រូវសំដែងស្វាមីភក្តិចំពោះព្រះក៏ដោយសារបុព្វហេតុតែប៉ុណ្ណោះឯង, ពុំមែនដោយសារការខ្លាចទោសពិន័យ... ឬក៏ការចង់បានគាប់គួរឬបានប្រយោជន៍ពីព្រះនោះឡើយ ។ គាត់បានចោទប្រកាន់ជំនឿអកុសលដែលធ្វើឲ្យមនុស្សស្រវឹងវង្វេង...ហើយដែលជាធម្មតា គឺជាល្បិចកលប្បសម្រាប់ប្រព្រិត្តបទឧក្រិដ្ឋកម្មយ៉ាងសែនសាហាវនៅក្នុងអរិយធម៌របស់មនុស្សជាតិ ។

សាសនាដែលគាត់បានកើតមកជាមួយ ពុំបានលើកលែងឲ្យព្រះនូវទោសកំហុសនិងសេចក្តីទន់ខ្សោយរបស់មនុស្សនោះទេ ។ ចំពោះគាត់វិញ, គាត់តែងយល់ថាព្រះជាម្ចាស់គឺជាពួកអ្នកមានបុណ្យ ដែលមានវិមាននៅឋានដ៏ល្អប្រសើរ ។ ដែលនៅទីនោះ គេមិនដែលឃើញមានភ្លៀង, មានខ្យល់ព្យុះ, មានធ្លាក់ទឹកកកអ្វីឡើយ ... ពេលនៅជុំវិញព្រះមានតែខ្យល់រំភើយនិងពន្លឺភ្លឺថ្លៃសជាអចិន្ត្រៃ ហើយព្រះអង្គទ្រង់គិតតែពីក្រេបជញ្ជក់សេចក្តីសុខក្សេមក្សាន្ត និងសុភមង្គលគ្មានទីចប់របស់ទ្រង់តែប៉ុណ្ណោះ ។

គាត់តែងបានបញ្ចៀសពីព្រះនូវលក្ខណៈនៃសាមញ្ញជនធម្មតាដែលតែងតែធ្វើឲ្យមនុស្សយើងមានការឆ្គាំឆ្គងឬសេចក្តីអៀនខ្មាស់ ។ គាត់បានជឿថាព្រះគ្មាន

ការទាក់ទងជាមួយនឹងសុភមង្គលរបស់មនុស្សទេ, ទ្រង់ពុំមានលទ្ធភាពស្គាល់ពីសេចក្ដីរំភើបទាក់ទងជាមួយនឹងអំពើល្អ ឬក៏អំពើអាក្រក់របស់មនុស្សណាម្នាក់ដែរ ។ គាត់មានជំនឿថាប្រសិនបើព្រះសម្រេចចុះមកចាត់ចែងនៅក្នុងរឿងសេចក្ដីសុខទុក្ខរបស់មនុស្ស ឬក៏មករវីរវល់ក្នុងរឿងរដ្ឋាភិបាលនៃពិភពលោក ... នោះឋានសួគ៌និងឋានសុខរបស់ទ្រង់នឹងត្រូវចប់ត្រឹមណោះហើយ... ពោលឋានព្រះអង្គនឹងក្លាយទៅជាឋាននៃសេចក្ដីកង្វល់កង្វាយ ។

គាត់ក៏បានទាញសេចក្ដីបញ្ចប់អំពីគំហើញអស់ទាំងនេះថា ៖ រឿងបន់ព្រះសំពះទេព្តា, រឿងអធិដ្ឋាននិងរឿងធ្វើពលិកម្មសក្ការៈបូជា, ជារឿងឥតប្រយោជន៍ជាពន់ពេកកន្លង ។ គ្មានបុណ្យអ្វីដែលត្រូវស្នើរសុំពីព្រះ, គ្មានគួរអ្វីដែលគេត្រូវទៅលត់ជង្គង់ថ្វាយបង្គំនៅចំពោះរានទេព្តាឬអ្នកតា ទាក់ទងនឹងរឿងគ្រោះថ្នាក់ផ្សេងៗដែលធ្លាក់មកលើរូបយើងទាំងអស់គ្នានោះទេ ។ ក៏ប៉ុន្តែគេគួរតែសម្លឹងមើលអំពីបុព្វហេតុអស់ទាំងនេះដោយចិត្តស្ងប់ស្ងៀម, ប្រាស់ចាកនូវសេចក្ដីរំភើបភ្ញាក់ផ្អើលក្នុងអារម្មណ៍វិញល្អជាជាង ។

គាត់បានពោលបន្ថែមថាមិនមែនបញ្ញាញាណរបស់មនុស្សនោះទេ ដែលបានបង្កើតព្រះនិងទេព្តានៅក្នុងសតិអារម្មណ៍របស់ខ្លួន ក៏ប៉ុន្តែគឺការភ័យខ្លាចដែលមនុស្សគ្រប់រូបតែងមានចំពោះស្រមោលស្ងៀមស្ងាត់ទាំងនេះ នៅក្នុងការយល់សប្តិយល់សួងរបស់ខ្លួន ។ ពីព្រោះនៅក្នុងពេលសុបិន្ត, មនុស្សតែងឃើញខ្មោចដែលមានទំហំធំស្កឹមស្កៃមកយាយី ។ ខ្មោចព្រាយក្នុងអារម្មណ៍ទាំងនេះតែងធ្វើការគំរាមកំហែងមកលើរូបយើង ដោយមានរូបរាងអង់អាចនិងទឹកមុខកាចសាហាវអស្ចារ្យ ។ គេឃើញខ្មោចទាំងនេះមានយុទ្ធសិល្បបង្កើតអព្ភូតហេតុចម្លែកៗ, ហើយដោយគេឃើញខ្មោចទាំងនេះត្រឡប់មកវិញគ្រប់កាលសម័យ, មិនត្រឹមតែប៉ុណ្ណោះដោយមានហេតុភេទចម្លែកជាប់មកជាមួយផង, ដោយគេមិនបានដឹងថាបណ្ដាលមកពីរឿងអ្វី, ម្ល៉ោះហើយ, មនុស្សដែលមិនបានជាគិតពិចារណា លុះបានឃើញដំណើរដ៏ទៀងទាត់របស់ព្រះអាទិត្យនិងព្រះច័ន្ទនិងផ្កាយនានា ក៏បាននឹកម៉ៃថាខ្មោចព្រាយក្នុងការស្រមៃ អស់ទាំងនេះជាអ្នកមានបុណ្យអមតៈប្រកបដោយមហិទ្ធិឫទ្ធិដ៏មហិមា ។ ពួកគេក៏បានចាត់ទុកខ្មោចឬយក្សអស់ទាំងនេះថាជាព្រះនិងជាទេព្តា-ព្រះអង្គព្រះឥន្ទនៅចំកណ្ដាលមេឃតែម្ដង...ហើយគឺព្រះអង្គទាំងនេះឯងដែលបានបង្កើតឲ្យមានរន្ទះបាញ់, មានផ្លេកបន្ទោរ, ភ្លៀងផ្គរ, ខ្យល់, ព្រឹល, ទឹកកកធ្លាក់ ៖ ពួកគេក៏បានតែងតាំងព្រះទាំងឡាយឲ្យធ្វើជាអធិបតីនៃរដ្ឋាភិបាលដ៏មហាស្ចារ្យនៃចក្រភពតែម្ដង ។ អ្វីៗដែលជាអព្ភូតហេតុដ៏សម្បើមៗ ដែលគេមិនដឹងឫសគល់ក៏ពួកគេលើកថ្វាយព្រះទាំងអស់ ។ គឺមកពីបុព្វហេតុដូច្នេះហើយ,

បើយោងតាមយោបល់របស់អេពីគួរ, ដែលគេឃើញមានរានទេព្តា និងតួបរិហារសម្រាប់ថ្វាយបង្គំព្រះនៅគ្រប់ទីកន្លែង ។ គាត់បានយល់ថាពិធីរថ្វាយបង្គំព្រះគឺមានដើមកំណើតអំពីការភ័យតក់ស្លុតដោយខុសទំនងដូច្នេះឯង ។

អំពីឋានសួគ៌និងឋានសុខដែលព្រះអង្គ-ព្រះឥន្ទបានតាំងទីលំនៅដ្ឋាន, អ្នកនិពន្ធលូក្រែស ដែលបានយកមនោសញ្ចេតនារបស់អេពីគួរធ្វើជាគំរូបានពោលថាគេមិនត្រូវស្រមើស្រមៃអ្វីអំពីឋានប្រសិទ្ធិអស់ទាំងនេះថាមានទំនាក់ទំនងអ្វីជាមួយគ្នានឹងវាំងប្រាសាទដែលយើងបានឃើញនៅលើផែនដីនេះឡើយ ៖ គឺពីព្រោះថាព្រះជាវត្ថុធាតុម្យ៉ាងដ៏សែនស្រាល ដែលមិនអាចចូលមកលាយឡំជាមួយនឹងចូលជាមួយវិញ្ញាណរបស់យើងបានឡើយ... ពោលគឺយើងមិនអាចសម្លឹងមើលព្រះឃើញតាមដោយបញ្ញាស្មារតីរបស់យើងនោះផងទេ ។ ម្ល៉ោះហើយគឺជាការចាំបាច់, ឋានបរមសុខអស់ទាំងនេះបានសាងសង់ឡើងស៊ីដងស៊ីផ្ទៃតែជាមួយ នឹងធម្មជាតិរបស់ពួកបុគ្គល ដែលរស់នៅទីកន្លែងប្រសិទ្ធិនោះតែប៉ុណ្ណោះឯង ។

❑

ពួកទស្សនវិទូទាំងអស់មានមតិយល់ស្របជាមួយគ្នាថា ៖ បើយោងតាមដំណើរធម្មតាសុទ្ធសាធរបស់ធម្មជាតិ, វាគ្មានរបស់អ្វីមួយដែលថាមិនកើតចេញពីរបស់អ្វីមួយទៀតនោះទេ, ហើយអ្វីមួយដែលមានរូបរាងឡើងរួចហើយក៏មិនអាចរលត់រលាយបាត់សូន្យសោះធេងទាំងស្រុងទៅវិញដែរ ។ ការពិសោធន៍បានឲ្យយើងដឹងថា អង្គកាយអ្វីមួយតែងបានត្រូវសង់ឡើងដោយកំទេចនៃអង្គកាយផ្សេងៗដទៃទៀត, ម្ល៉ោះហើយជាលទ្ធផលចុងចប់ទៅ, អង្គកាយនានាទាំងអស់តែងតែមានប្រធានរួមជាមួយគ្នា... ដែលយើងច្រើនតែហៅថាវត្ថុធាតុដើម ។

វាមានការប៉ះទង្គិចមតិគ្នាជាច្រើនដើម្បីគ្រាន់តែចង់ដឹងថាអ្វីទៅ ដែលជាវត្ថុធាតុដើម ។ យោងតាមយោបល់របស់អេពីគួរ, វត្ថុធាតុដើមសុទ្ធសឹងតែជាអាតូមឬកំទេចតូចៗបំផុតដែលគេមិនអាចបំបែកបាន ហើយដែលអេពីគួរយល់ថាជាប្រភពដើមនៃគ្រប់អង្គកាយទាំងអស់...។ ពោលអ្វីៗទាំងអស់នៅក្នុងធម្មជាតិគឺត្រូវបានសាងសង់ឡើងដោយប្រព័ន្ធនៃអាតូម ។

ក្រៅតែពីអាតូម, គាត់បានសន្មត់ថាមានវត្តមាននៃរបស់មួយទៀតដែលគេហៅថាលំហ ។ តាមពិតលំហាពុំមែនជាវត្ថុធាតុដើម... ហើយក៏ពុំមែនជាប្រព័ន្ធនៃអង្គកាយនានានោះឡើយ ។ អេពីគួរគ្រាន់តែចាត់ទុកថាលំហាជាប្រភពដើមនៃចលនាតែប៉ុណ្ណោះឯង, គឺដោយហេតុថា, អេពីគួរពោល, បើគ្មានលំហាតូចៗ ឬស-

ភាពឃ្លាតគ្នារវាងអង្គកាយនិងអង្គកាយ នៅរាយហែរពាសពេញក្នុងធម្មជាតិនោះ ទេ , វាគ្មានអ្វីមួយដែលអាចរើបម្រាស់ឬក៏អាចបង្កើតជាចលនាបានឡើយ, ម្ល៉ោះហើយវត្ថុធាតុទាំងដុំនៃធម្មជាតិច្បាស់ជាមានសភាពគាំងស្ទេញគ្មានកម្រើកប្រៀបបានដូចគ្នាទៅនឹងផ្ទាំងថ្មមួយដុំ ។ ម្ល៉ោះហើយសភាពនឹងថ្កល់បែបនេះច្បាស់ជាពុំបានបង្កើតឲ្យមានផលិតកម្មអ្វីទាំងអស់ ។

គាត់បានសន្និដ្ឋានថា ក្រុមអាតូមទាំងអស់នេះមានវត្តមានឋិតថេរចីរកាល ( De toute éternité ) តាំងពីដើមទីនៃពិភពលោករៀងមក ។ ចំនួននៃអាតូមថ្វីបើមានព្រំដែនរបស់វា គឺជាចំនួនដែលហួសពីការស្មានឬការវិនិច្ឆ័យរបស់មនុស្ស ។ នៅក្នុងមុខឬបាត ឬក្នុងរូបនៃវត្ថុអ្វីនិមួយៗ ...វាមានចំនួនអាតូមរាប់អសង្ខ័យ ។ គាត់បានយល់ស្មានថា គឺទម្ងន់នៃអាតូមនេះហើយ ដែលបានបង្កើតឲ្យមាន-ចលនានៃក្រុមរបស់ពួកវាឡើង ។ ជួនកាលពួកវា ( គឺពួកអាតូម ) មានការប៉ះទង្គិចនឹងគ្នាឯង, ជួនកាលពួកវាមានការប្រតោងប្រទាមប្រខាំតែជាមួយនឹងពួកគ្នាវាទៅ ។ របៀបរួបរួមគ្នាវាធ្វើជាប្រព័ន្ធផ្សេងៗ, ដែលបានបញ្ចេញឥទ្ធិពលប្លែកៗខុសៗគ្នានៅក្នុងធម្មជាតិ... ដែលមានវត្តមានកើតឡើងដោយចៃដន្យសុទ្ធសាធ, ពោលគឺពុំបានគោរពតាមគំរោងច្បាប់គូសទុកជាមុន ដោយព្រហ្មលិខិតណាមួយ , ក្រុមប្រព័ន្ធនៃអាតូមផ្សេងៗទាំងនេះ ក៏បានបញ្ចេញជារូបរាងទ្រង់ទ្រាយនៃវត្ថុផ្សេងៗផងដែរ ។ គាត់បានប្រៀបធៀបប្រព័ន្ធនៃក្រុមអាតូមផ្សេងៗទាំងនេះ ទៅនឹងអក្សរសាស្ត្រ ។ ជាឧទាហរណ៍ពាក្យថា « Estre » និង « Reste » ជាពាក្យពីរមានន័យខុសគ្នាស្រឡះ ក៏ប៉ុន្តែត្រូវបានប្រគុំឡើងដោយព្យាង្គអក្សរតែមួយរបៀប ។ ( ក.ក.ន ÷ បើជាអក្សរខ្មែរវិញ, គេអាចទាញឧទាហរណ៍ពីពាក្យ «ព្រៃ» និង «ពៃរ»... ពីពាក្យ «ក្រ» និង «ករ » ...។ល។និង។ល។ ) ។

ដូច្នេះទៅ, យោងតាមអេពីគួរ, ក្រុមប្រព័ន្ធអាតូមដែលបានបង្កើតជាអង្គកាយមួយបែប, នឹងអាចបង្កើតទៅជាអង្គកាយមួយបែបទៀតឧបមាបើវាឋិតនៅក្នុងប្រព័ន្ធផ្សេង។ បើទោះជាយ៉ាងនេះក៏ដោយ, យោងតាមអេពីគួរ, ក្រុមអាតូមផ្សេងៗមិនមែនចេះតែអាចចូលទៅសាងសង់ក្នុងគ្រប់តែប្រព័ន្ធអង្គកាយនៃវត្ថុធាតុនានានៅលើពិភពលោកនេះបានទេ ។ ជាឧទាហរណ៍, តាមទំនងមើលទៅ, ក្រុមអាតូមដែលបានសាងសង់អំបោះឡែនមួយដុំគឺមិនមែនជាក្រុមអាតូមដែលបានសាងសង់ត្បូងពេជ្រនោះទេ ។ គឺដូចតែពាក្យពេជន៍ជាច្រើននៅក្នុងអក្សរសាស្ត្រ ...ដែលគ្មានព្យាង្គអក្សរអ្វីរួមជាមួយគ្នាទាំងអស់នោះដែរ ។

គាត់បានយល់ថាកំទេចតូចៗនៃអង្គកាយទាំងនេះ បានឋិតនៅក្នុងសភាពនៃចលនាជាអចិន្ត្រៃយ៍ ។ គឺហេតុដូច្នេះហើយ, បានជាគ្មានរបស់អ្វីមួយនៅក្នុងធម្មជាត

ដែលស្ថិតនៅក្នុងសភាពដដែលទាល់តែសោះ ។ វត្ថុខ្លះក៏មានការស្រុតចុះអន់ថយ ចំណែកវត្ថុខ្លះទៀតក៏កើនទំហំឡើង ដោយសារបានទទួលកំទេចនៃវត្ថុធាតុដទៃ ដែលកំពុងតែចុះថយ ។ របស់ខ្លះចេះតែទទួលសភាពចាស់ជរា ...ចំណែករបស់ខ្លះទៀតចេះតែបានទទួលកម្លាំងពលំថ្មីជារៀងរាល់ថ្ងៃ...។ ដូច្នេះទៅវត្ថុធាតុមិតនៅបានតែមួយរយៈពេលប៉ុណ្ណោះនៅក្នុងលោក ។ នៅពេលដែលរបស់មួយកំពុងទទួលអាការៈពុករលួយពេញទំហឹង ...ក្រុមអាតូមដែលកំពុងរត់ចេញទៅក៏បានទៅរួបរួមជាមួយនឹងក្រុមអាតូមផ្សេងទៀតដើម្បីសាងសង់ប្រព័ន្ធថ្មី ខុសប្លែកពីវត្ថុធាតុដែលកំពុងតែរលួយទៅ ។

ដូច្នេះទៅ, គ្មានអ្វីដែលសាបសូន្យនោះឡើយ ថ្វីបើរបស់អ្វីក៏ដោយនៅក្នុងលោកមានវត្តមានបានតែមួយរយៈពេល, ហើយថ្វីបើអ្វីក៏ដោយហាក់ដូចជាមានដំណើរសំដៅទៅរកការរលត់នៅចុងចប់ ...ហាក់ដូចជាមានរបស់ស័ក្តិសិទ្ធិអ្វីមួយមកធ្វើឲ្យវិនាសសាបសូន្យទាំងស្រុង ។

អេពីគួរបានស្រមៃឃើញថាវាមានពេលមួយ ដែលអាតូមទាំងអស់នៅដាច់ដោយឡែកពីគ្នា... ។ លុះដល់ក្រុមអាតូមបានជួបគ្នា, ការពាក់ព័ន្ធដោយចៃដន្យក៏បានបង្កើតឲ្យមានពិភពផ្សេងៗរាប់មិនអស់ ...ពីភពនិមួយៗ មានវត្តមានមួយរយៈពេលហើយក៏បានរលត់រលាយទៅវិញ ឬមួយដោយភ្លើងឆេះកល្ប, ប្រៀបបានដូចជាថ្ងៃចូលមកដល់ជិតក្បែរពេកទៅ, បណ្តាលឲ្យឆេះរលាយផែនដី, ឬមួយដោយសារមានការរង្គោះរង្គើរបោកទង្គិចជាយ៉ាងខ្លាំង បណ្តាលឲ្យអ្វីៗក៏ដួលបាក់រលំហិនហោចគ្មានសល់ ជាហេតុឲ្យមានការរលាយរលត់ម៉ាស៊ីនពិភពលោក ។ វាមានរបៀបច្រើនយ៉ាងណាស់ ដែលពិភពនិមួយៗអាចរលាយទៅវិញ ។ ក៏ប៉ុន្តែកំទេចដែលនៅសល់នោះ អាចផ្តុំគ្នាបង្កើតជាពួកសត្វបែបថ្មី ។ តាមដោយទំនង, ផែនដីដែលយើងរស់នៅសព្វថ្ងៃ គឺសុទ្ធសឹងជាសំណល់ពីការបាក់បែកបណ្តាលមកពីការរង្គោះរង្គើរដ៏មហស្ចារ្យពីបុរាណកាល ៖ ជាឧទាហរណ៍ជ្រោះជ្រលងក្រហេងក្រហូងគួរឲ្យព្រឺស្ញើបនៃសមុទ្រ, ជួរភ្នំដ៏ខ្ពស់ៗសម្បើម... ស្រទាប់ដុំថ្មដ៏វែងអន្លាយ, ថ្មខ្លះដុះច្រូងប្រាងទទឹងគ្នា, ខ្លះទៀតត្រួតលើគ្នាពីលើចុះក្រោម ...ថ្មខ្លះទៀតជាន់លើគ្នារបៀបស្លាយឆៀង ឬតាមជំរេ ។ ជាឧទាហរណ៍សភាពដុះដាលមិនស្មើគ្នានៅផ្ទែកផ្ទៃខាងក្នុងនៃផែនដី, ទឹកស្ទឹងទន្លេដែលហូរនៅក្រោមដី, ស្ទឹង, បឹងបួរ, រូងថ្ម ។ ជាឧទាហរណ៍មួយទៀតសភាពដីដុះមិនស្មើគ្នាលៀនជាអណ្តាតចូលទៅក្នុងទឹក, ដាច់ដោចរតេយរតាយដោយសារបឹងបួរឬ សមុទ្រ ដែលបានមកកាត់ឲ្យក្លាយទៅជាកោះ, ជ្រោយ ឬភ្នំ ។

អេពីគួរបានសន្មត់ថាចក្រវាលនេះគ្មានព្រំដែនទេ, របស់ទាំងមូលនេះគ្មានក-

ន្លែងត្រង់កណ្ដាល, គ្មានកន្លែងត្រង់ដើម, គ្មានកន្លែងត្រង់ចុង ។ បើទោះជាគេឈរនៅទីកន្លែងណាក៏ដោយនៅលើភពផែនដីនេះ ...គេនឹងប្រទះវាលលំហមួយដាច់កន្ទុយភ្នែកដែលគេមិនអាចឆ្លងកាត់បាន... ដែលគេមិនអាចរកឃើញដើមទី ឬក៏ចុងទីនោះទាល់តែសោះ ។

គាត់បានពោលថាមានតែមនុស្សឆ្កួតប៉ុណ្ណោះ ដែលបានសរសើរសំណាងខ្លួនដោយបានគិតថា ព្រះនិងទេព្តាបានបង្កើតផ្ទៃមេឃនិងចក្រវាលដោយសារតែមានចិត្តស្រឡាញ់ចំពោះពួកមនុស្សលោក ។ វាគ្មានអ្វីសមទំនងសោះដែលព្រះនិងទេព្តាដែលធ្លាប់តែបានរស់ដោយស្ងៀមស្ងាត់ តាំងពីយូរយារពេកណាស់មកហើយ ...រួចក៏ស្រាប់តែប្ដូរចិត្តមួយរំពេជ ដោយនឹកភ្ញាក់កែប្រែផ្លាស់ប្ដូរជីវិតបែបថ្មីវិញ ។ម្យ៉ាងវិញទៀត, គេស្រណុកធ្វើការវិនិច្ឆ័យពេកណាស់ក្នុងរឿងនេះ ៖ ដោយសង្កេតមើលឃើញកំហុសនិងអំពើឆ្គាំឆ្គងរបស់មនុស្ស, គេនឹងអាចវិនិច្ឆ័យបានថាភពផែនដីនេះមិនមែនជាស្នាដៃរបស់ព្រះទេ ។

គាត់បានយល់ឃើញថាផែនដីបានបង្កើតមនុស្សទាំងឡាយ ហើយនិងសត្វធាតុដទៃផ្សេងៗទៀត...ប្រហែលគ្នាតែនឹងបច្ចុប្បន្ននេះ ដែលព្រះធរណីកំពុងតែបង្កើតសត្វកណ្ដុរប្រែង, សត្វតួប ( Taupes ) , សត្វជង្កួវនិងសត្វល្អិតដទៃទៀតនៅឡើយដែរ ។ គាត់បានឧបមាឧបមេយ្យថា នៅពេលដំបូងទីនៃកំណើតរបស់ខ្លួនផែនដីនេះមានកម្រាលខាប់ដូចខ្លាញ់ក្រាស់ ព្រមទាំងជីរជាតិដែលគេហៅថា នីត្រាត, ហើយនៅពេលដែលព្រះអាទិត្យ បានផ្ដល់កំដៅយូរៗទៅក៏មានដុះចេញជាស្មៅ និងព្រៃព្រឹក្សាតូចៗ... បន្ទាប់មកទៀតក៏ចេញជាបូសដូចជាផ្សិត ។ មួយរយៈពេលក្រោយមក, លុះដល់បូសទាំងនេះវាទុំ ហើយសំបកវាខាងក្រៅក៏ផ្ទុះបែកធ្លាយព្រមទាំងបានបញ្ចេញសត្វមួយតូចដែលសណ្ដកខ្លួនចេញបន្តិចម្ដងៗ ពីកន្លែងទីកដែលបានផ្ដល់កំណើតឲ្យវា ។ វាក៏ចាប់ផ្ដើមដកដង្ហើមឡើង ។ ព្រះធរណីក៏បង្ហូរចេញពីទីកន្លែងនោះនូវទឹកដោះដែលចិញ្ចឹមពួកសត្វតូចៗទាំងនេះឲ្យរស់រានមានជីវិត ។

នៅក្នុងចំណោមហ្វូងសត្វគ្រប់មុខគ្រប់យ៉ាង ដែលបានកើតចេញមកពីធម្មជាតិវាមានសត្វខ្លះអាក្រក់គួរឲ្យស្ញើប ៖ សត្វខ្លះគ្មានជើងទេ, ហើយសត្វខ្លះទៀតគ្មានក្បាលទេ សត្វខ្លះទៀតមានអវយវៈជាប់ស្អិតនឹងដងខ្លួនតែម្ដង, ម៉្លោះហើយក៏មានសត្វមួយចំនួនធំដែលបានស្លាប់ទៅវិញ ដោយពួកវាមិនអាចមានលទ្ធភាពចិញ្ចឹមខ្លួន... ឬក៏គ្មានលទ្ធភាពបន្តពូជដោយធ្វើការរួមសង្វាសភេទជាមួយនឹងភេទ ។ នៅទីបំផុតពួកសត្វដែលនៅរស់ទាំងប៉ុន្មាន គឺពួកសត្វណាដែលមានអវយវៈសមសួននឹងគ្នា ហើយដែលអាចរួមប្រពៃណីនឹងគ្នា, គឺសត្វលោកទាំងអស់នេះឯងហើយ ដែលយើងបានឃើញនៅក្នុងពិភពលោកសព្វថ្ងៃនេះ ។

នៅក្នុងសភាពលក្ខណៈដំបូងនៃផែនដីនេះ, ធាតុត្រជាក់, កំដៅថ្ងៃ និងខ្យល់ព្យុះភ្លៀងផ្គរពាំទាន់មានសភាពលក្ខណៈកាចសាហាវ ឬកំបុតត្បូងដូចសព្វថ្ងៃនេះទេ... ពីព្រោះក្នុងពេលនោះ អ្វីៗក៏នៅមានសភាពថ្មីៗទាំងអស់នៅឡើយ ។

ពួកមនុស្សជាតិដែលទើបចេញដំបូងមកពីធាតុដី, មានលក្ខណៈមាំទាំនិងរឹងប៉ឹងជាងពួកមនុស្សយើងសព្វថ្ងៃនេះ ។ ពួកគេមានរោមដុះច្រូងច្រាងពេញខ្លួនទំនងដូចជារោមសត្វជ្រូកព្រៃ ៖ ពួកគេឥតមានការទើសទាល់ក្នុងការរស់នៅដោយសារតែចំណីមិនល្អ ឬដោយសារតែសភាពត្រជាក់ហួសពេក ឬក៏ក្ដៅជ្រុលនៃធាតុអាកាសប្រែប្រួលទៅតាមរដូវនោះទេ ។ ពួកគេមិនទាន់ស្គាល់គុណប្រយោជន៍នៃសម្លៀកបំពាក់នោះទេ ។ ពួកគេតែងដេកអាក្រាតនៅដោយដីនៅពេលណារាត្រីធ្លាក់មកដល់ ។ កាលណាមានទឹកភ្លៀងបង្អុរមក, ពួកគេតែងជ្រកនៅក្រោមដើមឈើតូចៗ ។ នៅពេលនោះមិនទាន់មានសង្គមមនុស្សជាតិនៅឡើយទេ ។ ម្នាក់ៗគិតតែពីខ្លួនឯងហើយតែងខំប្រឹងប្រវេប្រវាធ្វើការដើម្បីស្វែងរកសេចក្ដីស្រណុកផ្ទាល់ខ្លួនតែប៉ុណ្ណោះ ។ ព្រះធរណីក៏បានបង្កើតព្រៃឈើដែលដុះធំឡើងយ៉ាងក្រាស់រៀងរាល់ថ្ងៃ ។ ពួកមនុស្សក៏ចាប់ផ្ដើមរស់នៅដោយទទួលទានឫសឈើ, ក្ដួច, តម្លូង, ផល្លាផ្សេងៗ, ផ្លែប៉ោមព្រៃជាដើម។ ជាញឹកញយណាស់ពួកមនុស្សត្រូវដោះស្រាយទំនាស់របស់ពួកខ្លួន ជាមួយនឹងពួកសត្វជ្រូកព្រៃនិងពួកសត្វតោ។ ពួកគេបានព្រួតជួយគ្នាទៅវិញទៅមកដើម្បីទប់ទល់នឹងសត្វកាចសាហាវ ។ ពួកគេក៏បានសង់ខ្ទមតូចៗ, រួចបានប្រកបមុខរបរប្រមាញ់ព្រមទាំងបានយកស្បែកសត្វ ដែលគេសម្លាប់នោះមកធ្វើជាសម្លៀកបំពាក់ ។ បុគ្គលម្នាក់ៗក៏បានជ្រើសរើសយកប្រពន្ធរបស់ខ្លួន, ហើយក៏បានរស់នៅពិសេសជាមួយតែនឹងស្រីម្នាក់នោះ ៖ ដោយសារជីវភាពបែបនេះក៏មានក្មេងៗកើតឡើងដែលចេះថ្នាក់ថ្នមអង្អែលធ្វើឲ្យទន់ចិត្តរបស់ពួកឪពុកវា ដែលមានទម្លាប់ចិត្តជាមនុស្សព្រៃផ្សៃ។ ទាំងនេះហើយដែលជាការចាប់ផ្ដើមសង្គមនៃមនុស្សជាតិ ។ អ្នកជិតខាងក៏បានបង្កើតសេចក្ដីស្និទ្ធស្នាលនិងចំណងមិត្តភាពជាមួយអ្នកជិតខាង, ហើយក៏ឈប់ប្រព្រឹត្តអំពើបំផ្លិចបំផ្លាញរវាងគ្នាឯង ។ ជាដំបូងគេបានបង្ហាញដោយប្រើចង្អុលដៃនូវរបស់ដែលគេចង់បាន ។ គេបានបង្កើតដើម្បីសេចក្ដីត្រូវការរបស់ពួកគេ... ដោយចៃដន្យសុទ្ធសាធនូវឈ្មោះនាមនៃរបស់និមួយៗ ៖ នៅទីបំផុតពួកគេក៏បានបង្កើតភាសាមួយ ដែលគេបានប្រើប្រាស់សម្រាប់បញ្ចេញគំនិតប្រាប់គ្នីគ្នាទៅវិញទៅមក ។

ព្រះអាទិត្យបានណែនាំឲ្យគេចេះប្រើប្រាស់កំដៅមុនពេល ដែលគេបានរកឃើញភ្លើងនោះម៉្លេះ...។ ដោយសារតែចំហាយក្ដៅខ្លាំងនៃព្រះអាទិត្យនេះហើយ

ដែលគេចេះរបៀបចំអិនសាច់ដែលគេរកបានមក ដោយសារការប្រមាញ់ ។ សម័យថ្ងៃមួយរន្ទះក៏បានបាញ់មកត្រូវចំត្រង់កន្លែងមួយ ដែលបណ្តាលឲ្យមានភ្លើងឆេះឡើងត្រគោល ។ ក្នុងរំពេជនោះពពួកមនុស្ស ដែលបានយល់ពីគុណប្រយោជន៍របស់អគ្គីរួចហើយ, ក៏មិនបានជាស្ទះម្ទីម្ទារទៅពន្លត់ ..ហើយបែរជានាំគ្នាថែរក្សាភ្លើងទុកទៅវិញ ។ អ្នកខ្លះក៏យកភ្លើងទៅដល់ផ្ទះខ្ទមរបស់ខ្លួនថែមទៀតផង, ដើម្បីចំអិនសាច់របស់ពួកគេជាអាហារ ។

បន្ទាប់មកទៀតពួកគេក៏បានចាប់ផ្តើមកសាងស្ថាបនាទីក្រុង, ព្រមទាំងចែកដីធ្លីដល់គ្នីគ្នាផង ...ក៏ប៉ុន្តែពុំបានស្មើភាគគ្នាទេ ។ ពួកជនណាដែលមានកម្លាំងកំហែងនិងការប៉ិនប្រសប់ច្រើនជាងគេក៏បានយកដីធំៗនិងល្អៗជាងគេ ៖ ពួកគេក៏តាំងខ្លួនជាស្តេចផែនដីហើយបង្ខំអ្នកដទៃទៀតឲ្យគោរពកោតខ្លាច ។ ពួកគេក៏បានសាងសង់ប្រាសាទនិងបន្ទាយដើម្បីចៀសវាងការភ្ញាក់ផ្អើល បណ្តាលមកពីការឈ្លបឆ្មក់របស់អ្នកជិតខាង ។

ពួកមនុស្សកាលក្នុងសម័យនោះ, ពុំមានអ្វីការពារខ្លួនក្រៅតែពីដៃ, ក្រចក, ធ្មេញ, ដុំថ្ម, ឬដំបង ៖ ទាំងនេះហើយជាអាវុធដែលពួកគេបានប្រើប្រាស់ដើម្បីដោះស្រាយទំនាស់រវាងគ្នីគ្នា ។

បន្ទាប់ពីបានដុតព្រៃឈើជាច្រើនកន្លែង, ដោយប្រការផ្សេងៗ, ពួកគេក៏បានសង្កេតឃើញធាតុដែកហូរចេញពីស្រទាប់ដី ចូលទៅក្នុងថ្មក់ខ្លះហើយបណ្តាលទៅជាវត្ថុរឹង ។ ពន្លឺនៃលោហធាតុបានធ្វើឲ្យពួកគេកោតស្ញប់ស្ញែង ។ ពួកគេក៏បានយល់ថាដោយសារតែកំដៅភ្លើង, ពួកគេនឹងអាចដុតធ្វើវត្ថុអ្វីៗបានគ្រប់យ៉ាងទាំងអស់ ។ មុនដំបូងពួកគេនឹកឃើញចង់បានតែធ្វើគ្រឿងអាវុធតែប៉ុណ្ណោះទេ...។ គឺមកពីបុព្វហេតុនេះហើយបានជាកាលពីដំបូងទី, មនុស្សយើងរាប់អានស្ពាន់ជាងដុំមាស... ដោយសារតែអាវុធធ្វើពីមាសពុំសូវមុតសក្តិសិទ្ធិដូចជាគ្រឿងប្រដាប់ពីស្ពាន់នោះទេ ។ បន្ទាប់មកទៀត, ពួកគេក៏ដុតស្លលោហធាតុធ្វើប្រដាប់ឃ្លុំមាត់ សេះ, ផាលនង្គ័លសម្រាប់ភ្ជួរដី ហើយនិងវត្ថុជាច្រើនទៀតដែលពួកគេត្រូវការ ។

កាលពីមុនពេលដែលគេបង្កើតធាតុដែក, មនុស្សតែងធ្វើសម្លៀកបំពាក់ដោយយករបស់ផ្សេងៗមកចងប្រគុំគ្នា , ក៏ប៉ុន្តែតាំងពីមានគ្រឿងដែកដែលជារបស់ប្រើការបានគ្រប់មុខកាលណាមក ពួកគេក៏បានរកឃើញមធ្យោបាយធ្វើក្រណាត់ពីខ្សែនឬពីអំបោះ ដើម្បីឆ្លាក់ឆ្លែសម្លៀកបំពាក់បានតាមចំណង់ត្រូវការរបស់ពួកគេ ។

អំពីការសាបព្រួសគ្រាប់ពូជវិញ, គឺព្រះធរណីនេះឯងដែលបានបង្ហាត់បង្ហាញមនុស្សនូវវិជ្ជាកសិកម្ម ។ ពួកមនុស្សយើងបានសង្កេតឃើញតាំងពីដំបូងទីនៃ

ពិភពលោកមកថាគ្រាប់ជ្រៃ, កាលណាវាធ្លាក់មកដី, វានិងធ្វើឲ្យដុះដើមជ្រៃមួយទៀតស្រដៀងឬដូចគ្នានិងដើមជ្រៃមុន ៖ ម្ល៉ោះហើយ, បើមនុស្សចង់ដាំដើមជ្រៃនៅទីកន្លែងណាមួយ, គេគ្រាន់តែយកគ្រាប់មកបណ្ដុះក៏វាជាការស្រេចទៅហើយ ។ លទ្ធផលនៃការសង្កេតនេះ ក៏បានយកទៅអនុវត្តនៅគ្រប់ពូជរុក្ខជាតិដទៃទៀត ។ មនុស្សម្នាក់ៗក៏ចាប់ផ្ដើមសាបព្រួសគ្រាប់ធញ្ញជាតិ ដែលពួកគេអាចត្រូវការ ... ហើយដោយម្នាក់ៗបានសង្កេតឃើញថា គេតែងតែបានទទួលលទ្ធផលល្អប្រសើរបើកាលណាគេចេះថែទាំរក្សាច្បារដំណាំ ...ពួកគេក៏បានចាប់ផ្ដើមប្រកបមុខរបរកសិកម្មនេះឡើង ។

មកទល់ពេលនោះ, កម្លាំងហើយនិងទេពកោសល្យបានត្រូវចាត់ទុកថាជាគុណសម្បត្តិដើមចមនៃសង្គមជាតិ ។ ក៏ប៉ុន្តែនៅពេលដែលគេបានរកឃើញមាសរួចហើយកាលណាមក, ដោយសារការភ្ញាក់ផ្អើលបណ្ដាលមកពន្លឺនៃលោហធាតុនេះ, ម្នាក់ៗក៏គិតតែចង់ប្រមូលមាសយកមកធ្វើជាទ្រព្យសម្បត្តិ ។ ជនខ្លះក៏បានក្លាយទៅជាអ្នកមានធូរធារដ៏សម្បើមដោយសារតែកម្មវិធីនេះ ។ ចំណែកពួកប្រជាពលរដ្ឋក៏បានចាប់ផ្ដើមនាំគ្នារត់ចោលស្ដេចពីជំនាន់មុន ដែលគ្មានទ្រព្យសម្បត្តអ្វីក្រៅតែពីកម្លាំងនិងការប៉ិនប្រសប់ ។ មនុស្សម្នាក់ៗក៏រត់ទៅចោមរោមបម្រើតែអ្នកមានទ្រព្យសម្បត្តិ ។ ចំណែកពួកស្ដេចជំនាន់មុនក៏បានត្រូវគេពិឃាតចោលជាអសារបង់ ៖ តាំងពីថ្ងៃនោះមក, រដ្ឋាភិបាលក៏បានក្លាយទៅជារដ្ឋាភិបាលរបស់ប្រជាពលរដ្ឋ ។ គេក៏បានបង្កើតច្បាប់ឡើង ព្រមទាំងជ្រើសរើសយកចៅក្រមដើម្បីត្រួតពិនិត្យឲ្យអ្នកផងគោរពច្បាប់... និងដើម្បីទទួលភារកិច្ចនៃការបំពេញកិច្ចការសាធារណៈ ។

នៅពេលដែលមនុស្សជំនាន់ដើមទាំងនេះ បានបាត់បង់លក្ខណៈជាមនុស្សព្រៃបន្តិចម្ដងៗ, សង្គមជាតិក៏កាន់តែរីធំឡើងផងដែរ ។ មនុស្សម្នាទាំងឡាយក៏ចាប់ផ្ដើមចេះធ្វើការជប់លៀង, ម្ដងនៅផ្ទះអ្នកនេះ, ម្ដងនៅផ្ទះអ្នកនោះ ។ នៅពេលដែលគេបានបរិភោគឆ្អែតស្កប់ស្កល់កាលណាមក, ពួកគេតែងបានត្រេកត្រអាលក្នុងការស្ដាប់ចម្រៀងនៃសត្វបក្សី ៖ ម្ល៉ោះហើយពួកគេក៏បានខំប្រឹងចម្លងតាមសម្លេងព្រមទាំងប្រគំភ្លេងនិងចម្រៀង ទៅតាមបែបបទដែលពួកគេបានឮពីសត្វបក្សាបក្សី ។

ខ្យល់ផ្លូវបានបង្កើតបទសម្លេងមួយគួរស្រណោះ ។ ដោយបានដើរឆ្លងកាត់វាលត្រែងពួកគេក៏បានកាត់ដើមត្រែងយកមកធ្វើជាខ្លុយ ។ ម្យ៉ាងវិញទៀត, ការស្ទបស្ទង់អំពីអ្វីៗដែលគេបានឃើញនៅលើមេឃបានជំរុញឲ្យពួកគេខំប្រឹងប្រែងសិក្សាអំពីតារាសាស្ត្រ ។

សេចក្ដីកំណាញ់និងមហិច្ឆតា ក៏បានចូលមកលាយឡំក្នុងជីវិតរស់នៅ ។

ពួកគេក៏បានចាប់ផ្តើមធ្វើសង្គ្រាមជាមួយនឹងគ្នាឯង ...ពួកខាងម្ខាងខំប្រឹងបំផ្លិចបំផ្លាញទ្រព្យសម្បត្តិជាកម្មសិទ្ធរបស់ខាងម្ខាងទៀត ។ សឹកសង្គ្រាមទាំងនេះក៏បានបង្កើតឲ្យមានអ្នកវីដែលមានភារកិច្ចខាងរៀបរាប់អំពីសកម្មភាពដ៏អស្ចារ្យរបស់វិរជន, ហើយនិងអ្នកគំនូរដើម្បីសំដែងបង្ហាញឲ្យឃើញយ៉ាងប្រត្យ័ក្សអំពីរូបភាពនៃការប្រយុទ្ធគ្នា ។ បន្ទាប់មកដោយសារតែសភាពស្ងប់ស្ងៀម និងសភាពទំនេរដែលគេបានទទួលជាភាគចំណេញ, ពួកគេក៏បានសម្រាំងខ្លួនសប្បាយនៅក្នុងវង្វង់សិល្បៈដែលមានរួចហើយ ...ព្រមទាំងក្នុងសិល្បៈថ្មីៗដែលគេកំពុងបង្កើតតទៅទៀតដើម្បីជាសេចក្តីសុខសប្បាយ ក្នុងអារម្មណ៍របស់ពួកគេ ។

❑

នៅពេលដែលអ្នកខ្លះនិយាយតវ៉ាថា ព្រះធរណីសព្វថ្ងៃពុំឃើញមានបង្កើតមនុស្ស , សត្វតោ ឬក៏សត្វឆ្កែត្រង់ណាសោះ, អេពីគួរបានឆ្លើយថា ៖ « ព្រះម៉ែធរណីមានសេចក្តីហត់នឿយ ដូចតែស្រីម្នាក់ចាស់ជរាពុំអាចមានកូនដូច្នោះដែរ ។ ដីណាក៏ដោយ ដែលគេទើបបានដាំដំណាំជាដំបូង តែងតែផ្តល់ភោគផលបានច្រើនជាងនៅពេលបន្ទាប់មកទៀត ។ នៅទីបំផុតកាលណាគេដកព្រៃឈើនៅត្រង់ម្តុំណាចោលចេញ, នៅត្រង់កន្លែងក្រហូងដីនោះនឹងពុំអាចមានចេញព្រៃឈើឲ្យមានទំហំដូចមុនទៀតឡើយ... ពោលគឺចេញតែរុក្ខជាតិរួញក្រញ៉េះៗប្រកបដោយបន្លាចាក់ស្រែស ។ ហើយម្យ៉ាងវិញទៀត, គេអាចនិយាយបានថានៅក្នុងពេលសព្វថ្ងៃនេះ វាមានវត្តមាននៃសត្វទន្សាយ, សត្វកញ្ជ្រោង, សត្វជ្រូកព្រៃហើយនិងសត្វផ្សេងៗទៀតដែលចេញកំណើតពីដីសុទ្ធសាធ ។ ក៏ប៉ុន្តែដោយនៅទីកន្លែងនោះជាកន្លែងដាច់ឆ្ងាយស្រយាលពីកន្លែងមនុស្សរស់នៅ ...យើងក៏មិនបានដឹងឮហើយក៏មិនអាចជឿថារឿងដូច្នេះវាអាប្រព្រឹត្តទៅកើត ។ ម្យ៉ាងវិញទៀត ដោយយើងធ្លាប់តែបានឃើញសត្វកណ្តុរដែលវាកើតចេញមកតែពីសត្វកណ្តុរគ្នាវា យើងក៏មិនអាចជឿបានថាមានសត្វកណ្តុរឯទៀតដែលវាកើតចេញមកពីផែនដីនោះដែរ ។

ពួកទស្សនវិទូរជាច្រើនមានការបែកខ្ញែកគំនិតគ្នាក្នុងរឿងក្បួនតម្រា ដែលអនុញ្ញាតឲ្យយើងដឹងស្គាល់ពីការពិត ។ អេពីគួរបានបញ្ជាក់ថាគ្មានការពិតប្រាកដអ្វីនៅក្នុងចំណេះដឹងរបស់មនុស្សក្រៅ តែពីការពិតប្រាកដបានមកពីវិញ្ញាណតែប៉ុណ្ណោះទេ ។ យើងមានចំណេះដឹងដោយសារតែរបាយការណ៍ដែលយើងបានទទួលពីវិញ្ញាណ(ទាំង-៥) របស់យើងតែប៉ុណ្ណោះ, ហើយក៏វាគ្មានក្បួនតម្រាអ្វី

ផ្សេងទៀតដែលធ្វើឲ្យយើងដឹងពីសេចក្តីពិត ហើយនិងសេចក្តីមិនពិតនោះទេ ។

ចំពោះលទ្ធភាពនៃការយល់ឃើញនិងបញ្ញាញាណវិញ, គាត់បានអះអាងថា នៅពេលដំបូងទី មនុស្សយើងគ្មានគំនិតទាល់តែសោះ ។ នៅក្នុងអារម្មណ៍របស់មនុស្សយើងគឺដូចជាតុទទេស្អាតធេងគ្មានអ្វីទាំងអស់នៅពីលើ ។ នៅពេលដែលអវយវៈបានធំធាត់មានកម្លាំងមាំទាំហើយ ទើបបានចំណេះដឹងបានចូលមកដោយសារតែរបាយការណ៍របស់វិញ្ញាណ ។ មនុស្សយើងអាចមានគំនិតគិតទៅដល់របស់ដែលមិននៅនឹងមុខ ។ ម្ល៉ោះហើយខ្លួនគេអាចភ័ន្តច្រឡំ ដោយយល់ថារបស់ដែលជាអវត្តមាននោះថានៅនឹងមុខ... ឬក៏របស់ដែលមិនធ្លាប់ដែលមានទាល់តែសោះទៀតផងថាជាវត្តមាន ។ ផ្ទុយទៅវិញរបស់ដែលគេទទួលដឹងតាមវិញ្ញាណ... គឺជារបស់ណាដែលមានវត្តមានពិតប្រាកដមែន, យើងមិនអាចភ័ន្តច្រឡំទេ ( ដូចជារបស់គេមើលឃើញ ឬក៏ដើរប៉ះទង្គិច ) ។ ក្នុងប្រការនេះ ...មានតែមនុស្សឆ្កួតលីលាប៉ុណ្ណោះ ដែលមិនទាមទារយករបាយការណ៍នៃវិញ្ញាណ ដើម្បីឈោងទៅដល់កំពស់បញ្ញាញាណឬឈានជើងចូលទៅក្នុងការត្រិះរិះពិចារណា ។

វាមានរបៀបបែបបទច្រើនយ៉ាង ដែលពួកទស្សនវិទូរអាចពន្យល់អធិប្បាយអំពីគំហើញ ឬការមើលឃើញ ។ អេពីគួរបានយល់ថាពីគ្រប់អង្គកាយនានាទាំងអស់ដែលមានចំនួនរាប់អសង្ខ្យេយ្យនៅក្នុងចក្រវាលនេះ វាតែងមានខ្ចាតចេញនូវកំទេចលំហដូចៗគ្នានឹងអង្គកាយទាំងនោះដែរ ។ កំទេចលំហតូចៗទាំងនេះបិតនៅពាសពេញអាកាសដែលយើងកំពុងដកដង្ហើម, ហើយដោយសារមធ្យោបាយនេះឯងទើបវិញ្ញាណរបស់យើង អាចទទួលរបាយការណ៍ពីវត្ថុនៅខាងក្រៅរូបយើង ។

គាត់បានសន្និត់ថាក្លិននេះមួយ, សម្លេងនេះមួយ, កំដៅនេះមួយ, ពន្លឺនេះមួយព្រមទាំងគុនភាពដទៃទៀតដែលអាចញ៉ាំងវិញ្ញាណឲ្យទទួលយកឥទ្ធិពលស្មៀបរ-មាស់, ពុំមែនមានលក្ខណៈត្រឹមតែជាអព្ភូតហេតុ ដែលមាននៅក្នុងព្រលឹងវិញ្ញាណតែប៉ុណ្ណោះទេ ។ ពោលពុំមែនមានបិតនៅតែក្នុងការស្រមៃរបស់យើងនោះទេ...។ វាមានសភាពពិតប្រាកដជាក់ស្តែងរបស់វានៅខាងក្រៅខ្លួនយើងពិតមែន, ទៅតាមលក្ខណៈបែបបទដែលវិញ្ញាណយើងបានទទួល, ហើយវាមានលក្ខណៈអព្ភូត-ហេតុមួយចំនួនយោងទៅតាមបែបបទផ្សេងៗដែលជាក្លិនពិតមែន, ជាសម្លេងពិតមែន, ជាកំដៅពិតមែន, ជាពន្លឺពិតមែន, មិនចាំបាច់តែចំពោះមនុស្សនោះទេ តែចំពោះសព្វសត្វក៏ដូចគ្នាទាំងអស់ ។ ជាឧទាហរណ៍លំអងតូចៗដែលរសាត់ចេញពីផ្កាធ្លាក់ពាសពេញដីបានផ្សព្វផ្សាយក្លិនពិដោរក្រអូបឈ្ងុយឈ្ងប់, ដូចតែមនុស្សបានហិតក្លិននោះពិតមែន, ប្រសិនបើជាគេបានដើរទៅដល់កន្លែងទីផ្កាសួនច្បារទាំងនោះ។ នៅពេលដែលគេវាយរគាំងជាដើម, អាកាសធាតុដែលនៅជុំវិញ

ទីនោះ ត្រូវមានពោរពេញសភាពខ្វះខាតទ្រហឹង, ដូចតែសួរស័ព្ទសម្លេងដែលយើងបានឮនោះឯង។ ហើយនៅពេលដែលព្រះអាទិត្យចាប់ផ្ដើមរះចេញមក...វាតែងតែមាននៅក្នុងខ្យល់បរិដ្ឋាននូវអ្វីៗ ដែលភ្លឺផ្លេកដូចតែរស្មីដែលយើងបានឃើញនូវពេលនោះឯង ។ នៅទីបំផុត, ឧបមាថាវាមានរឿងតែមួយសោះក៏ប៉ុន្តែមានលក្ខណៈប្លែកគ្នាចំពោះសត្វពីរដែលមានលក្ខណៈខុសគ្នា, គឺមកតែពីធាតុផ្ទៃក្នុងរបស់សត្វទាំងពីរនោះវាមិនដូចគ្នាទេ ។ ពោល, ឧបមាថាស្លឹកសូល ( Saule ) វាមានជាតិល្វីងចំពោះមនុស្ស, ក៏ប៉ុន្តែវាមានរសជាតិផ្អែមពិសារចំពោះសត្វពពែ គឺមកពីមនុស្សហើយនិងពពែរពុំមានរចនាសម្ពន្ធផ្ទៃក្នុងដូចគ្នាសោះឡើយ ។

❑

ពួកក្រុមបក្សស្តូអ៊ីក, ដែលមានវិន័យតឹងរ៉ឹងក្នុងការរស់នៅនិងចេះអត់ទ្រាំ តាម-វាសនាកម្ម, ហើយដែលតាមពិតមានមោតនភាពនិងអំនួតដ៏ធំធេង ...ពោលសេចក្ដីស្ញៀមស្ងាត់របស់ពួកគេជាសេចក្ដីស្ញៀមស្ងាត់ដែលពោរពេញដោយសេចក្ដីក្រេវក្រោធឬស្យា, បែរជាមានសេចក្ដីច្រណែននិន្ទានិងការខឹងសម្បារយ៉ាងខ្លាំងចំ-ពោះអេពីគួរ ។ គឺដោយហេតុថាទស្សនវិទូម្នាក់នេះបានបង្រៀនទ្រឹស្ដីខុសប្លែកស្រ-ឡះពីពួកស្តូអ៊ីក ( ក.ក.ន ៖ គឺអេពីគួរបានបង្រៀនមនុស្សឲ្យចេះទទួលយកការស-ប្បាយខ្លះៗពីធម្មជាតិ កុំឲ្យតែការសប្បាយនោះមានបង្កប់ដោយជាតិពុល ...ឲ្យតែសមរម្យនឹងធាតុកំណើតរបស់ខ្លួន ព្រមទាំងកុំឲ្យខូចប្រយោជន៍ដល់អ្នកដទៃ ...ចំណែកពួកស្តូអ៊ីកវិញគឺបង្រៀនមនុស្សឲ្យទទួលបៀមយកតែសេចក្ដីទុក្ខតែម្យ៉ាង, ឲ្យចេះអត់ទ្រាំនឹងកម្មវាសនា ...ក៏ប៉ុន្តែមិនឲ្យត្រេកត្រអាលក្នុងការសប្បាយទាល់តែសោះ ...ទោះជាការសប្បាយនោះគ្រាន់តែជាការបាត់បង់នូវសេចក្ដីទុក្ខបណ្ដោះអាសន្នក៏ដោយ...) ។ ក៏ប៉ុន្តែមានក្រុមមិត្តភ័ក្តិ និងក្រុមសាវ័កជាច្រើន ដែលបានចោមរោមស្រឡាញ់គាត់ភ្លូកទឹកភ្លូកដី ។ ម្ល៉ោះហើយ, ពួកស្តូអ៊ីកក៏បានប្រើមធ្យោបាយគ្រប់យ៉ាងដើម្បីបន្ទុះបង្អាប់ទស្សនៈរបស់អេពីគួរ ។ មានពួកស្តូអ៊ីកខ្លះបានផ្សាយការមួលបង្កាច់ទៅលើអេពីគួរនៅក្នុងសៀវភៅ ដែលពួកខ្លួនបានបោះពុម្ពផ្សាយ ។ ដូច្នេះហើយបានជានៅក្នុងសម័យក្រោយមកមនុស្ស ច្រើនគ្នាណាស់បានស្គាល់អេពីគួរ តែតាមរយៈសៀវភៅរបស់ពួកស្តូអ៊ីកតែប៉ុណ្ណោះ... ពួកគេក៏នឹកស្មានថាបុព្វបុរសម្នាក់នេះ ដែលតែងរស់នៅក្នុងគតិធម៌ដោយចេះតមចំពោះការសប្បាយនិងសភាពឆ្ងាញ់គ្រប់បែបយ៉ាង, ថាជាមនុស្សដែលបានធ្លាក់ទៅក្នុងអបាយមុខដ៏គួរស្អប់ខ្ពើម ។

សាំង-ក្រេក្វារ ( សម្ដេចសង្ឃរាជកាតូលិកម្នាក់ ) បានពោលអំពីជីវិតបរិសុទ្ធនៃទស្សនវិទូអេពីគួរ ៖ « អេពីគួរបានពោលថា សេចក្ដីសុខសប្បាយជាគោលបំ-

ណាងរបស់មនុស្សគ្រប់ៗគ្នា... ក៏ប៉ុន្តែកុំឲ្យគេនឹកស្មានថាជាសេចក្ដីសុខសប្បាយក្នុងតម្រេកតណ្ហា ( ក.ក.ន.៖ ពេលកុំឲ្យគេនឹកស្មានថាមានតែប៉ុណ្ណឹង ) ។ បុគ្គលម្នាក់នេះបានរស់នៅ ដោយទៀងត្រង់និងត្រឹមត្រូវជាទីបំផុត ...ដោយអនុវត្តទ្រិស្ដីសីលធ៍មរបស់គាត់ឲ្យបានត្រូវស្របជាមួយនឹងជីវិតផ្ទាល់ខ្លួន » ។

អេពីគួរមិនដែលចង់រវីរវល់ ជាមួយនឹងរដ្ឋាភិបាលនៃសាធារណរដ្ឋទេ ។ គាត់តែងស្រឡាញ់ជីវិតស្ងៀមស្ងាត់ និងសេចក្ដីក្សេមក្សាន្តរបស់គាត់នៅឆ្ងាយពីសមាសភាពដឹកនាំ ។ រូបបដិមាករដែលពួកទីក្រុងអាត្តែនបានស្ថាបនាជូនគាត់គឺជាសក្ខីភាពនៃកិត្តិយស និងសេចក្ដីគោរពដ៏ធំធេង ដែលអ្នកស្រុកមានចំពោះរូបគាត់ ។ អ្នកដែលបានស្រឡាញ់អេពីគួរ មិនដែលបានបោះបង់ចោលគាត់ទេ, ក្រៅតែពីជនម្នាក់ឈ្មោះមេត្រូដូរុស ដែលបានរត់ចោលគាត់ដើម្បីទៅរៀនសូត្រនៅក្នុងបណ្ឌិតសភារបស់កានេយ៉ាដ ។ ក៏ប៉ុន្តែជនក្រោយនេះបានចាកចេញទៅតែ៦ខែប៉ុណ្ណោះ ក៏បានរត់ត្រឡប់មករកអេពីគួរវិញ ម្ដងនេះគឺនៅរហូតទល់ថ្ងៃស្លាប់ដែលកើតមានឡើងមុនមរណភាពរបស់អេពីគួរបន្តិចបន្តួចប៉ុណ្ណោះ ។ សាលារបស់គាត់ទៀតសោតបានរក្សាសេចក្ដីរុងរឿងជារហូតមក... ទោះជានៅពេលដែលសាលាដទៃទៀតបានធ្លាក់ចូលទៅក្នុងអនាមិកភាពក៏ដោយ ។

នៅក្នុងអាយុ៧២ឆ្នាំ គាត់ក៏បានធ្លាក់ខ្លួនឈឺនៅទីក្រុងអាត្តែន ៖ ក៏ប៉ុន្តែគាត់មិនបានបញ្ឈប់កិច្ចការបង្រៀនរបស់គាត់ទេ ។ រោគរបស់គាត់គឺជារោគទាស់នោមដែលបណ្ដាលឲ្យគាត់មានសេចក្ដីឈឺចាប់វេទនាដ៏ពន់ប្រមាណ ។ គាត់បានអត់ទ្រាំនឹងជម្ងឺនេះដោយសេចក្ដីស្ងៀមស្ងាត់ជាទីបំផុត ។ នៅពេលដែលគាត់ដឹងថាភាគចុងចប់នៃជីវិតគាត់បានធ្វើដំណើរជិតមកដល់ហើយ, គាត់ក៏បានដោះលែងខ្ញុំបម្រើរបស់គាត់មួយចំនួន, ចែកចាយទ្រព្យសម្បត្តិរបស់គាត់, បញ្ជាឲ្យគេធ្វើពីធីរំឭកថ្ងៃកំណើតរបស់គាត់ និងថ្ងៃកំណើតនៃឪពុកម្ដាយរបស់គាត់នៅថ្ងៃទី-១០នៃខែកាមេឡេអុង ( Gaméléon ) ។ គាត់បានប្រគល់សួនច្បារព្រមទាំងសៀវភៅរបស់គាត់ទាំងអស់ទៅឈ្មោះ ហែរម៉ាគុស ដឺម៉េតឺឡាំង ដែលត្រូវបន្តដំណែងពី គាត់, ក្នុងលក្ខ័ណដែលថាបុគ្គលម្ចាស់ការបច្ចុប្បន្ន ត្រូវតែប្រគល់ទ្រព្យសម្បត្តិទាំងនេះបន្តទៅទៀតទៅអ្នកមាននាទីកាន់កាប់ទីកន្លែងនេះនៅក្នុងអនាគតកាល ។ គាត់ក៏បានសរសេរលិខិតមួយទៅអ៊ីដូម៉េណោមានសេចក្ដីដូច្នេះថា ៖

« នៅទីបំផុត, ដោយសារតែគុណបុណ្យព្រះជាម្ចាស់, ខ្ញុំក៏បានរស់នៅដោយសេចក្ដីសុខសប្បាយរហូតដល់ថ្ងៃចុងចប់នៃជីវិតរបស់ខ្ញុំ ។ នៅក្នុងពេលនេះខ្ញុំមានសេចក្ដីទុក្ខកង្វល់យ៉ាងខ្លាំង ដោយសារតែរោគរបស់ខ្ញុំវាស៊ីរូងពោះវៀនហើយ និងក្រពះនោម ដែលបណ្ដាលឲ្យមានការឈឺផ្សារដែលគេមិនអាចនឹក

ស្ងានបាន ។ ទោះជាយ៉ាងនេះក្តី, នៅកណ្តាលសេចក្តីឈឺចាប់វេទនាររបស់ខ្ញុំ ខ្ញុំមានតែសេចក្តីត្រេកអរសប្បាយក្នុងបញ្ញាញាណ, ដោយនឹករឭកឃើញទៅដល់ការវែកញែកអធិប្បាយ និងគុណធ៌មរបស់ខ្ញុំដែលធ្វើឲ្យបានចម្រុងចម្រើនដល់ទស្សនវិជ្ជា ។ ខ្ញុំសូមឲ្យលោកជួយ, នៅក្នុងនាមនៃសេចក្តីស្រឡាញ់ដែលលោកតែងតែមានចំពោះខ្ញុំ, មើលថែរក្សាដល់កូនចៅរបស់មេត្រូដូរុសផង » ។

រយៈពេល១៨ថ្ងៃ ក្រោយមកបន្ទាប់ពីរោគរបស់គាត់បានចាប់ផ្តើមឡើង, អេពីគួរក៏បានចូលទៅជ្រមុជនៅក្នុងធុងទឹកក្តៅ ដែលគាត់បានឲ្យគេរៀបចំជាពិសេស ។ នៅពេលដែលគាត់ចូលដល់ក្នុងទឹកកាលណា, គាត់ក៏បានសុំស្រាក្រហមសុទ្ធមួយកែវ ។ គាត់បានផ្តែផ្តាំដល់កូនចៅគាត់នៅទីនោះឲ្យនឹករឭក ឃើញដល់គាត់ហើយនិងសុភាសិតរបស់គាត់ជានិច្ច, គាត់ក៏លើកស្រាអកឡើង រួចក៏ដាច់ខ្យល់មួយរំពេជ ។ សេចក្តីស្លាប់នេះបានមកដល់នៅក្នុងឆ្នាំទី១នៃអូ-ឡាំព្យ៉ាដ១២៧ ។ ពួកអ្នកស្រុកអាតែ្នបានសំដែងនូវសេចក្តីសោកស្តាយស្រណោះយ៉ាងខ្លាំងពន់ប្រមាណចំពោះរូបគាត់ ។៚

❑ ❑

❑

# ជីវិតរបស់អេពីមេនីឌ
# ÉPIMÉNIDES

បានមករស់នៅទីក្រុងអាតែ្មន នៅក្នុងសម័យនៃអូឡាំពៀដទី៤៥ ។ អ្នកខ្លះបាន អះអាងថា គាត់បានលង់លក់ក្នុងដំណេកស្កប់ស្កល់ អស់ចំនួន៥៧ឆ្នាំនៅក្នុងគុហារថ្មមួយ ។ ពួកជនជាតិក្រិកជាច្រើនបានពោលថា គាត់មានអាយុ១៥៤ឆ្នាំ, មានខ្លះនិយាយថា គាត់មានអាយុ១៥៧ឆ្នាំ... អ្នកខ្លះទៀតបញ្ជាក់ថា គាត់មានអាយុ ២៩៨ឆ្នាំ ។

* * *

អេពីមេនីឌ នៅង៉ូស្សិ, បានចំរើនវ័យនៅកោះក្រែត ក្នុងសម័យដែលសូឡុងកំពុងតែមានកេរ្តិ៍ឈ្មោះល្បីល្បាញនៅក្រុងអាតែ្មន ។ គឺជាបុរសកាន់ធម៌អាថ៌ម្នាក់ ដែលរស់នៅជារបៀបតាឥសី ៖ អ្នកផងមានជំនឿថា គាត់នេះត្រូវជាកូនប្រុសរបស់នាងមច្ឆានព បាល់តិ ( Balte ) ។ ពួកជនជាតិក្រិកទាំងឡាយមានជំនឿជឿជាក់ថា គាត់នេះមានព្រលឹងទេព្តាមកសណ្ឋិត... គឺដោយហេតុថា គាត់បានទទួលបន្ទូលផ្តែផ្តាំរបស់ព្រះនោះច្រើនណាស់ ។ ជីវភាពរបស់គាត់បានប្រព្រឹត្តទៅនៅក្នុងការតាក់តែងកំណាព្យ និងអ្វីៗដែលទាក់ទងនឹងពិធីពលិកម្មថ្វាយព្រះ ។ គឺគាត់នេះហើយដែលបានចាប់ផ្តើមធ្វើទីតាំងព្រះវិហារ ឲ្យទៅជាទីកន្លែងសក្ការៈបូជា... មិនត្រឹមតែប៉ុណ្ណោះ បានសំអាតឲ្យមានលក្ខណៈបរិសុទ្ធនៅស្រុកស្រែ នៅទីក្រុង និងតាមផ្ទះនិមួយៗផង ។ លោកគ្រូប៉ូល នៅក្នុងសំណេររបស់គាត់នៅទីត ( Tite )... បានលើកយកកំណាព្យរបស់គាត់មួយមកចុះផ្សាយ ដែលមានសេចក្តីទាក់ទងនឹងជនជាតិក្រិក ដែលថាពួកនេះ ជាពួកជនភូតភរ, ជាមនុស្សខ្ជិលច្រអូស ព្រមទាំងជាសត្វកាចសាហាវផង ។

ឪពុករបស់គាត់បានបញ្ជូនគាត់ឲ្យទៅរកកូនចៀមមួយនៅស្រែចំការ ៖ នៅពេលវិលត្រឡប់មកផ្ទះវិញ អេពីមីនីឌបានគេចចៀសពីផ្លូវធំ ហើយប្រមាណជានៅពេលថ្ងៃត្រង់ បានដើរតម្រង់ចូលក្នុងគុហារមួយ ក្នុងគោលប្រាថ្នាសំរាកកាយបានមួយរយៈ ទំរាំតែចំហាយក្តៅរសាត់ផុតទៅ ។ ក៏ប៉ុន្តែគាត់បែរជានិទ្រាស្កប់ស្កល់ទៅទីនោះអស់រយៈពេល៥៧ឆ្នាំ ។ នៅពេលដែលគាត់ភ្ញាក់ឡើងវិញកាលណា គាត់ស្មានតែ

ខ្លួនគាត់លង់លក់ក្នុងដំណេកមួយយូរតែប៉ុណ្ណោះ ។ គាត់ខំក្រឡេកមើលឆ្វេងស្តាំ
ដើម្បីរកកូនចៀមរបស់គាត់ ក៏ប៉ុន្តែគាត់រកមើលមិនឃើញសោះ ។ គាត់បានចេញពី
ក្នុងគុហារថ្មមក ហើយក៏មានការភ្ញាក់ផ្អើលស្រឡាំងកាំង ដោយបានឃើញថាទិដ្ឋភា
ពនៃផែនដីទាំងមូល បានផ្លាស់ប្តូរអស់រលីងទៅហើយ ។ គាត់បានរត់ដោយងឿងឆ្ង
ល់ជាខ្លាំង ទៅទីកន្លែងដែលគាត់បានយកកូនចៀមរបស់គាត់ ក៏ស្រាប់តែគាត់ឃើញ
ថា ផ្ទះនោះបានផ្លាស់ប្តូរម្ចាស់ទៅហើយ ហើយក៏គ្មាននរណាដឹងថា គាត់ចង់និយាយ
អំពីរឿងអ្វីផងទេ ។ ដោយភ័យតក់ស្លុតក្នុងចិត្ត គាត់ក៏បានវិលត្រឡប់ទៅង៉ូស្សវិញ
គាត់បានជួបនៅគ្រប់ទីកន្លែង ឃើញតែមុខមនុស្សដែលគាត់មិនដែលបានធ្លាប់ស្គា-
ល់ ។ សេចក្តីងឿងឆ្ងល់របស់គាត់កាន់តែមានទំហំរីកប៉ោងធំឡើងៗជាលំដាប់ ។

នៅពេលគាត់ដើរចូលក្នុងផ្ទះរបស់ឪពុកខ្លួនឯង ស្រាប់តែមានគេសួរគាត់ថា
តើគាត់នេះជានរណា ហើយសួរថែមទៀតថា តើគាត់ចង់បានអ្វី ? នៅទីបំផុតគាត់ក៏
បានត្រូវទទួលស្គាល់ដោយសេចក្តីលំបាកពីប្អូនប្រុសរបស់គាត់ ដែលធ្លាប់នៅជាកូ
នក្មេងសោះនៅឡើយ ពេលដែលគាត់ចាកចេញទៅ... ហើយស្រាប់តែនៅពេលគា
ត់វិលត្រឡប់មកវិញនេះ បានក្លាយទៅជាមនុស្សចាស់ជរាទៅហើយ ។ ការផ្សងព្រេ
ងដ៏មហស្ចារ្យបែបនេះ បានធ្វើឲ្យផ្អើលខ្ចរខ្ចាយពេញស្រុកទេស ។ មនុស្សគ្រប់ៗគ្នា
ចាប់ផ្តើមមើលឃើញថា អេពីមេនីឌនេះជាកូនសំណាប់របស់ព្រះ ។ ពួកអ្នកខ្លះដែល
មិនព្រមជឿថា អេពីមេនីឌបានដេកលក់ស្កប់ស្កល់ក្នុងដំណេកអស់រយៈពេលដ៏យូរ
ដល់ម្លឹង ក៏បែរជាមានជំនឿថា គាត់នេះបានចំណាយអាយុអស់៥៧ឆ្នាំ ដោយគ្មានឲ្យ
នរណាស្គាល់ នៅលើទឹកដីបរទេស ព្រមទាំងដើរស្វែងរាប់អានតែមនុស្សក្រីក្រតែ
ប៉ុណ្ណោះ ។

នៅពេលដែលមេក្លាក្លែសបានបញ្ជាឲ្យពិឃាតពួកក្រុមបក្សរបស់សូឡុងយ៉ាង
កាចសាហាវគឺបានតាមសម្លាប់ពួកនេះ រហូតដល់មាត់ជណ្តើរនៃព្រះវិហារទៀតផង,
ពួកអ្នកស្រុកអាត្តែនក៏កើតសេចក្តីភ័យភិតតក្កមា ដែលមានទំហំធំឡើងៗជារៀងរា-
ល់ថ្ងៃ ។ ក្រៅពីជម្ងឺពិសឧត្តប្បាទរាលដាលពេញផ្ទៃប្រទេស, ពួកគេបានយល់ថាខ្មោ
ចព្រាយបិសាចបានវិលត្រឡប់មកលងនៅពេញទីក្រុងរបស់គេហើយ ។ គេក៏បាន
សាកសួរពួកហោរាដែលអាចដឹងបាន, ដោយសារតែដង្វាយពលិកម្មថ្វាយព្រះ ថាពួ
កគេបានប្រព្រឹត្តអំពើអាក្រក់សាមាន្យមួយ ដែលជាហេតុធ្វើឲ្យទីក្រុងទាំងមូល បាន
ត្រូវទទួលអំពើចង្រៃឧបទ្រព ។ គេក៏បានបញ្ជូននីស្យ៉ាសទៅកោះក្រែត ៖ គេបានផ្ត
ល់នាវាឲ្យគាត់មួយ ដើម្បីទៅដឹកនាំយកអេពីមេនីឌ ដែលកំពុងតែមានកេរ្តិ៍ឈ្មោះ
ល្បីល្បាញពេញផ្ទៃប្រទេសក្រិក ។ នៅពេលដែលអេពីមេនីឌមកដល់ទីក្រុងអាត្តែន
កាលណា គាត់ក៏បានដឹកយកចៀមខ្មៅនិងចៀមស នាំជាមួយគ្នាយកទៅតុលាការ...

រួចបន្ទាប់មក គាត់ក៏បានបណ្ដោយឲ្យសត្វចៀមទាំងនោះ ដើរពាសវាលពាសកាល ស្រេចនឹងចិត្ត ។ គាត់បញ្ជាឲ្យគេដើរតាមសត្វចៀមទាំងអស់នេះ ហើយក៏បានផ្ដែផ្ដាំទៅពួកជនដែលគាត់បានជ្រើសរើសមកសំរាប់តែភារកិច្ចនេះ ឲ្យធ្វើបូជាយ័ញ្ញន៍នូវសត្វនិមួយៗ ដើម្បីជាដង្វាយដល់ព្រះណាមួយជាពិសេស នៅចំទីកន្លែងដែលសត្វទាំងនោះបានទទួលការសំរាក ។ គឺដោយវិធីដូច្នេះហើយ ទើបបានជាគេឃើញនៅជុំវិញទីក្រុងអាត្ហែន មានរានអ្នកតាជាច្រើនដែលគេបានសាងឡើងថ្វាយដល់ពួកទេព្ដាដែលគេមិនបានស្គាល់ឈ្មោះនាម ។ បង្គាប់បញ្ជាទាំងប៉ុន្មាន ត្រូវគេប្រតិបត្តិតាមដោយឥតមានខ្វោះ ៖ ជម្ងឺពិសក៏បានត្រូវរលត់មួយរំពេជ ចំណែកពួកខ្មោចព្រាយក៏លែងបានមកលងព្យាបាទជនណាម្នាក់ទាំងអស់ ។

អេពីមេនីឌ នៅពេលមកដល់ទីក្រុងអាត្ហែនរួចហើយ ក៏បានចងមិត្តភាពយ៉ាងរឹងមាំជាមួយនឹងសូឡុង ព្រមទាំងបានជួយស្នួយបុរសក្រោយនេះ ឲ្យតុបតែងច្បាប់របស់គាត់ផង ។ គាត់បានសំដែងបង្ហាញឲ្យឃើញ នូវសភាពអាសារឥតការនៃទំនៀមទំលាប់ព្រៃផ្សៃដែលបង្ខំឲ្យស្រីៗទៅរងពលិកម្មនៅក្នុងពិធីឈាបនកិច្ចនៃស្វាមីរបស់នាង ។ គាត់ក៏បានទម្លាប់ពួកទីក្រុងអាត្ហែនឲ្យចេះធ្វើពិធីបំណាន់ ( បន់ព្រះសំពះទេព្ដា) ព្រមទាំងបូជាយ័ញ្ញន៍, ហើយដោយសារតែកម្មវិធីទាំងអស់នេះ បានណែនាំពួកគេឲ្យរស់នៅក្នុងសេចក្ដីសុច្ចរិតយុត្តិធម៌ ចៀសវាងការបះបោរតទល់ពួកចៅក្រម ។

ថ្ងៃមួយ, បន្ទាប់ពីបានឃើញកំពង់ផែនៅមូនីស៊្វីភ្លាម គាត់ក៏បាននិយាយប្រាប់ពួកជនដែលនៅជុំវិញខ្លួនគាត់តាំងអស់ថា ៖ « មនុស្សផងទាំងឡាយកំពុងតែរស់នៅក្នុងសភាពងងឹតអន្ធការក្រាស់ឃ្មឹក ទាក់ទងនឹងរឿងរ៉ាវដែលត្រូវកើតមានឡើងនៅអនាគត ។ អនិច្ចា! ប្រសិនបើពួកទីក្រុងអាត្ហែនបានដឹងថា កំពង់ផែនេះនឹងនាំទុក្ខវេទនាដល់ពួកគេមិនចេះចប់មិនចេះហើយ, នោះពួកគេនឹងនាំគ្នាត្របាក់ស៊ីកំពង់ផែនេះ ដោយឆ្មាញ់មាត់ក្នុងពេលឥឡូវនេះជាមិនខាន » ។

នៅពេលដែលអេពីមេនីឌបានសំណាក់នៅអស់មួយរយៈពេលនៅអាត្ហែន គាត់ក៏បានប្រុងប្រៀបវិលត្រឡប់ទៅលំនៅវិញ ។ ពួកក្រុងអាត្ហែនបានរៀបចំផ្ដល់ជូនគាត់នូវនាវាមួយ និងប្រាក់មួយដម្លឹង (នៅក្នុងបុរាណកាលនៃប្រទេសក្រិក មួយដម្លឹងមានទម្ងន់២៧គីឡូក្រាម ) ។ អេពីមេនីឌក៏បានសំដែងនូវសេចក្ដីអំណរគុណចំពោះពួកគេដោយសច្ចធម៌ ពោលគឺគាត់មិនបានព្រមទទួលយកប្រាក់របស់គេឡើយ ។ គាត់គ្រាន់តែបានស្នើសុំរឹតចំណងមេត្រីភាពជាមួយពួកគេ ព្រមទាំងសុំឲ្យថែរក្សាទំនាក់ទំនងរវាងពួកអាត្ហែននិងពួកគ្នូំស្សិ ឲ្យបានយ៉ាងជិតស្និទ្ធខ្ជាប់ខ្ជួនជាទីបំផុត ។ មុននឹងចាកចេញទៅ គាត់បានឲ្យគេសាងព្រះវិហារមួយយ៉ាងល្អ សំរាប់ជាកិត្តិយសដល់ព្រះព្រះពាយផាយផាត់ ។

អេពីមេនីឌ បានខំប្រឹងបញ្ជាក់ប្រាប់ប្រជាពលរដ្ឋនៅស្រុករបស់គាត់ ថាគាត់នេះជាព្រះអេគុស ( Eacus ) ដែលរស់ឡើងវិញ ។ គេមិនដែលបានឃើញគាត់បរិភោគអ្វីទេ ។ គេបានពោលថា ពួកនាងមច្ឆាទេព្ភសមុទ្រជាអ្នកចិញ្ចឹមរូបគាត់, ហើយថាគាត់បានលាក់ទុកនៅក្នុងក្រចកគោមួយ នូវគ្រប់ឥវ៉ាន់អ្វីៗទាំងអស់ដែលគាត់ត្រូវការ ។ គេបានពោលបន្ថែមទៀតថា ម្ហូបម្ហាអ្វីៗក៏ដោយ ដែលគាត់បានស្រង់យកពីក្រចកគោនោះ នឹងក្លាយទៅជាធាតុផ្ទាល់របស់គាត់ ដោយគ្មានលាមកឯណាចេញពីអង្គកាយរបស់គាត់ឡើយ ។

គាត់បានធ្វើការទស្សន៍ទាយប្រាប់ពួកឡាសេដេម៉ូនជាមុន នូវសេចក្ដីទុក្ខវេទនា និងទាសភាពខ្លោចផ្សារ ដែលពួកគេត្រូវទទួលរងគ្រោះ ក្រោមការសង្កត់សង្កិនរបស់អាកាឌី ។

ថ្ងៃមួយ, នៅពេលដែលគាត់កំពុងកសាងព្រះវិហារមួយ ដែលគាត់បានសំរេចថា យកទៅធ្វើជាកន្លែងសក្ការៈសំរាប់នាងមច្ឆា... ក៏ស្រាប់តែគេឮសម្លេងមួយពីលើមេឃស្រែកប្រាប់គាត់ថា ៖ « ឱ! អេពីមេនីឌ កុំយកវិហារនេះទៅដាក់ដង្វាយឲ្យនាងមច្ឆា... ចូលយកទៅថ្វាយព្រះយូពីទើវិញ ។

នៅពេលដែលគាត់ដឹងថា សូឡុងបានដកខ្លួនថយចេញពីទីក្រុងអាត្មែន អេពី-មេនីឌក៏បានប្រញាប់សរសេរលិខិតមួយ ដើម្បីផ្ញើទៅលួងលោមបុរសនេះផង ហើយដើម្បីទៅណែនាំរូបគាត់ ឲ្យមករស់នៅកោះក្រែតនោះផង ។ នៅក្នុងសំបុត្រនោះមានសេចក្ដីដូច្នេះថា ៖

« ចូរកុំឲ្យអស់សង្ឃឹមឲ្យសោះណាមិត្តសំឡាញ់ ។ ប្រសិនបើពីស៊ីត្រាតបានសង្កត់សង្កិនទាល់តែរាបដូចកន្ទេល នូវពពួកជនដែលធ្លាប់តែរស់នៅក្នុងសភាពកញ្ជះគេ, ឬដែលមិនធ្លាប់រស់នៅក្រោមច្បាប់ទម្លាប់ល្អទាល់តែសោះ, នោះប្រហែលជាការជិះជាន់របស់គាត់នេះនឹងបានស្ថិតស្ថេរចីរកាលវែងឆ្ងាយ ។ ប៉ុន្តែនៅក្នុងរឿងនេះ ពីស៊ីសត្រាតត្រូវតទល់នឹងពពួកមនុស្សអ្នកជា, ពួកជនមានសេរី ដែលមិនខ្វះសេចក្ដីក្លាហានក្នុងការតស៊ូសោះឡើយ ។ មិនយូរមិនឆាប់ ពួកអ្នកទាំងនេះនឹងច្បាស់ជានឹករលឹកឃើញជាមិនខាន ដល់ពាក្យសុភាសិតនិងគោលជំហររបស់សូឡុង ។ ពួកគេនឹងច្បាស់ជាមានសេចក្ដីអៀនខ្មាស់ដោយពិតប្រាកដ នឹងលក្ខណៈរបស់ពួកគេជាជនជាប់ខ្សែច្រវាក់ ហើយពួកគេនឹងរើបំរះពីរាជផ្ដាច់ការម្នាក់ ដែលបានធ្វើឲ្យពួកគេដួលធ្លាក់ទៅក្នុងទាសភាព ។ នោទីបំផុត បើទោះបីជាពីស៊ីត្រាតអាចធ្វើជាចៅហ្វាយម្ចាស់ពេញមួយជីវិតរបស់គេក៏ដោយ ក៏រាជាណាចក្ររបស់គាត់មិនអាចធ្លាក់ទៅក្នុងកណ្ដាប់ដៃនៃកូនចៅរបស់គាត់ជាដាច់ខាត ។ ដោយហេតុថា គឺជាការមួយមិនអាចទៅរួច ដែលពពួកជនធ្លាប់រស់នៅក្នុងសេចក្ដីសុខសេរី និងក្រោមច្បាប់ក្រិត្យក្រមដ៏

ល្អអាចមកទ្រាំទ្រក្រោមការរស់នៅជានិច្ចនិរន្តរ៍ ក្នុងលក្ខណៈជាទាសកជន ។ ចំណែកចំពោះរូបលោកវិញ, ខ្ញុំសូមអង្វរកុំឲ្យលោកនៅមានឋានៈជាជនផ្សងព្រេងពីខាងណេះទៅខាងណោះ ៖ សូមលោកប្រញាប់អញ្ជើញមករស់នៅក្នុងកោះក្រែត, ដែលនៅទីនេះ គ្មានរាជាផ្ដាច់ការឯណាមកធ្វើធ្វើបាបជនណាទេ ។ ពីព្រោះខ្ញុំខ្លាចក្រែងតែមិត្តភក្តិរបស់ពីស្សីត្រាតជួបលោកនៅតាមផ្លូវដោយចៃដន្យ ហើយពួកគេនឹងធ្វើបាបរូបលោកជាយថាហេតុ »... ។

ជីវិតរបស់អេពីមេនីឌតាំងមូលមានដំណើរប្រព្រឹត្តទៅក្នុងការគោរពធម៌ព្រះ ។ ដោយគាត់នេះចូលចិត្តតាក់តែងកំណាព្យ, គាត់បានសរសេរសៀវភៅជាច្រើនជាកំណាព្យកាព្យឃ្លោង ។ ជាពិសេសគាត់បាននិពន្ធរឿងកំណាព្យមួយ ទាក់ទងនឹងយុគសម័យរបស់ពួកគួរ៉េត ( ពួកអ្នកស្រុកក្រែត ) និងពួកកូរីបង់ និងរឿងកំណាព្យមួយទៀត រៀបរាប់ពីដំណើរសង្គ្រាមរបស់ពួកកុលស្ហ ។ គាត់បានតាក់តែងសៀវភៅជាភាសាសំរាយមួយដែរ ទាក់ទងនឹងពលិកម្មនៅសាធារណរដ្ឋនៃកោះក្រែត ហើយនិងសៀវភៅមួយទៀត ដែលរៀបរាប់ពីសាច់រឿងរបស់មីណូសនិងរ៉ាដាម៉ង់ ។

អេពីមេនីឌបានទទួលអនិច្ចកម្មទៅនៅក្នុងជន្មាយុ១៥៧ឆ្នាំ ។ អ្នកខ្លះបានបន្ថែមទៀតថា គាត់មានអាយុរហូតដល់ទៅ២៩៨ឆ្នាំ ។ ដោយជីវិតរបស់អេពីមេនីឌមានអាថ៌កំបាំងដ៏ជ្រាលជ្រៅក្រៃលែង ពួកអ្នកខ្លះបានអះអាងថា គាត់បានទទួលអាយុបន្ថែមនៅពេលដែលគាត់បានដេកលង់លក់អស់ជាយូរអង្វែងឆ្នាំ ។ ពួកអ្នកស្រុកកោះក្រែតបានបូជាពលិកម្មជូនចំពោះរូបគាត់ ហាក់ដូចជាចំពោះទេវៈមួយអង្គ... ពួកគេហៅគាត់ដោយសេចក្ដីស្រឡាញ់ថា ជាគួរ៉េត ។ ពួកឡាសេដេម៉ូនបានយកខ្លួនគាត់ទៅរក្សាទុកដោយថ្នាក់ថ្នមជាទីបំផុត នៅក្នុងស្រុករបស់ពួកគេ... ដោយគោរពតាមទំនាយបុរាណមួយដែលបានទាយថា ពួកគេត្រូវតែធ្វើដូច្នេះ ។ ៙

❑ ❑

❑

# ជីវិតរបស់ហេរ៉ាគ្លីត

# HÉRACLITE

★ បានរីកចំរើននៅក្នុងអូឡាំព្យ៉ាដទី៦៩

------------

ហេរ៉ាគ្លិត នៅអេហ្វែស ជាកូនប្រុសរបស់ឈ្មោះ ប្លីសុង ។ គាត់បានរីកចំរើនធំធាត់នៅក្នុងចំណោះចេះដឹង នៅក្នុងអូឡាំព្យ៉ាដទី៦៩ ។ អ្នកផងច្រើនតែប្រសិទ្ធិនាមឲ្យគាត់ថា ជាទស្សនវិទូនៃទីងងឹត (ពិបាកយល់ )... ពីព្រោះគាត់ចូលចិត្តនិយាយអ្វីៗទៅតាមប្រស្នាតែប៉ុណ្ណោះ ។ ឡាអ៊ែរស្ស បានធ្វើសេចក្តីអត្ថាធិប្បាយថា ៖ ហេរ៉ាគ្លិតជាមនុស្សពោរពេញទៅដោយមោទនភាព ( អំនួត )... ហើយតែងមើលងាយមើលស្រាលជនដទៃទៀតគ្មានសល់នរណាម្នាក់ ។

ហេរ៉ាគ្លិតបានពោលថា ៖ អូបែរ ( អ្នកនិពន្ធសោកនាដកម្មក្រិកដ៏ល្បីល្បាញ ) ហើយនិងអាជិឡូគុស គួរតែត្រូវគេបណ្តេញចេញពីស្រុករបស់ខ្លួន ដោយអំពើកំហែងកំហាល់ ទះតប់ ទាត់ធាក់ផងទើបសម ។

គាត់មិនអាចអត់ឱនទោសឲ្យពួកអ្នកស្រុកអេហ្វែស ដែលបាននិរទេសមិត្តភក្តិរបស់គាត់ម្នាក់ឈ្មោះអ៊ែរម៉ូឌ្រុស។ គាត់បានសរសេរផ្សាយជាឱឡារិកថា មនុស្សទាំងអស់នៅក្នុងទីក្រុងនេះគួរតែស្លាប់... ចំណែកពួកកូនក្មេងនៅទីនោះវិញ គួរតែបណ្តេញចេញឲ្យអស់គ្មានសល់ម្នាក់ដើម្បីលប់លាងទោសកំហុសដែលពួកអ្នកស្រុកបានប្រព្រឹត្ត... គឺជាឧក្រិដ្ឋកម្មដ៏គួរអៀនខ្មាស់ ដោយបានបណ្តេញពលរដ្ឋដ៏ល្អប្រសើរជាងគេបំផុតនៅក្នុងសាធារណរដ្ឋ ។

ហេរ៉ាគ្លិតមិនដែលមានគ្រូអាចារ្យឯណាបង្ហាត់បង្រៀនគាត់សោះឡើយ ។ គឺដោយសារការស្ទឹងស្ទាធិដ៏ស្មៀមស្ងាត់របស់គាត់ ដែលអនុញ្ញាតឲ្យគាត់មានការប៉ិនប្រសប់និងបញ្ញាដ៏ជ្រាលជ្រៅ ។ គាត់មានតែអារម្មណ៍មាក់ងាយប៉ុណ្ណោះចំពោះអ្វីៗសព្វយ៉ាង ដែលមនុស្សទាំងឡាយបានធ្វើ ។ គាត់មានការចាប់អារម្មណ៍ជាតីបំផុតចំពោះការភ្លីភ្លើនិងការវង្វេងវង្វាន់របស់មនុស្ស ៖ ជាហេតុបណ្តាលឲ្យគាត់មានសេចក្តីទុក្ខធ្ងន់ធ្ងរ... គឺគាត់ពឹតតែយំសោកជានិច្ចជាកាល ។ យូវេណាល់ បានយកទស្សនវិទូម្នាក់នេះ ទៅធ្វើជារូបមន្តផ្ទុយនិងដេម៉ូគ្រិតវិញ ដែលគាត់នេះគិតតែពីសើចកាច់កកាច់សុរង់គ្រប់ពេលវេលា ។

យូវេណាល់បាននិយាយបន្ថែមទៀតថា ម្នាក់ៗអាចធ្វើការកាត់សេចក្តីឬផ្តន្ទាទោ

ស ដោយសើចចំអកយ៉ាងខ្លាំងមែនទែន ចំពោះអំពើអបាយមុខនិងអំពើឆ្កួតលីលា នៅក្នុងសតវត្សនោះ... ក៏ប៉ុន្តែគាត់ចេះតែមានសេចក្តីងឿងឆ្ងល់ថា តើមានចំនួនទឹកពីណាមកច្រើនម្ល៉េះ ដែលចេះតែហូរចេញមិនចេះចប់មិនចេះហើយ ពីភ្នែករបស់ញេរ៉ាគ្លិត ។

ហេរ៉ាគ្លិតក៏មិនដែលធ្លាប់មានមនោសញ្ចេតនានឹងនរនោះដែរ ៖ កាលនៅពីក្មេង គាត់ធ្លាប់និយាយថា ៖ គាត់ឥតមានដឹងអ្វីទាំងអស់... លុះដល់ពេលគាត់ចូលវ័យចាស់ គាត់បែរជានិយាយថា អ្វីៗក៏មិនកំបាំងនឹងភ្នែករបស់គាត់ដែរ... គឺគាត់ដឹងទាំងអស់ ។ មនុស្សណាក៏តែងតែធ្វើឲ្យគាត់ទាស់ចិត្តជាខ្លាំង គាត់តែងតែរត់គេចចេញពីហ្វូងមនុស្សទាំងឡាយ ហើយសំដែងការចូលចិត្តទៅលេងជាមួយឆ្អឹងមាន់ឆ្អឹងទា និងល្បែងបាយឡុកបាយឡផ្សេងៗទៀត នៅចំមុខវិហាររបស់ព្រះស្រីឌីយ៉ានជាមួយនឹងក្រុមក្មេងៗនៅក្នុងទីក្រុង ។ ពួកអ្នកស្រុកអេហ្វេស តែងតែមកឈររោមមើលគាត់គ្រប់ៗគ្នា ។

– ឱពួកជនអភ័ព្វអើយ, ហេរ៉ាគ្លិតពោលទៅកាន់អ្នកទាំងនោះ...ម្តេចក៏ពួកលោក–កអ្នកមកងឿងឆ្ងល់អ្វី នឹងឃើញខ្ញុំលេងសប្បាយជាមួយនឹងក្មេងៗទាំងនេះ ។ មិនគឺប្រសើរជាងការទៅចូលហ៊ុនជាមួយពួកអស់លោក ក្នុងការគ្រប់គ្រងដោយឥតសណ្តាប់ធ្នាប់និងអយុត្តិធម៌ នូវកិច្ចការផងទាំងឡាយរបស់សាធារណរដ្ឋទេឬ ?

ថ្ងៃមួយពួកអេហ្វេសបានអង្វរករលោកឲ្យសរសេរច្បាប់សំរាប់ទីក្រុងរបស់ពួកគេ ក៏ប៉ុន្តែហេរ៉ាគ្លិតមិនបានចង់ធ្វើដូច្នោះទេ ដោយគាត់យល់ថាទំនៀមទម្លាប់នៃប្រ–ជាជននៅស្រុកនោះមានលក្ខណៈពុករលួយជ្រុលពេកណាស់ទៅហើយ ជាហេតុឲ្យគាត់រកមើលមិនឃើញ នូវមធ្យោបាយបែបណាសំរាប់កែប្រែជីវិតរស់នៅរបស់ពួកអ្នកទាំងនេះទេ ។

គាត់បានពោលថា ប្រជាជាតិទាំងឡាយ គួរតែធ្វើការប្រយុទ្ធតស៊ូអង់អាចមែនទែន ដើម្បីការពារច្បាប់ទម្លាប់របស់ពួកគេ... គឺត្រូវធ្វើឲ្យលើសពីការការពារមហាកំពែងរបស់ពួកគេទៅទៀត ។

តាមយោបល់របស់គាត់ ប្រជាជននៃស្រុកនិមួយៗ គួរតែប្រញាប់ប្រញាល់ប–ន្ធូរបន្ថយកំហឹងនិងគំនុំគុំគួនដែលមាននៅក្នុងចិត្តមនុស្ស..ឲ្យលើសពីការខំប្រឹងប្រែងដើម្បីលត់ភ្លើងឆេះផ្ទះទៅទៀត... គឺដោយហេតុថា លទ្ធផលនៃគំនុំគុំគួនអាចមានគ្រោះថ្នាក់វែងឆ្ងាយមែនទែនជាងអគ្គីភ័យ ។ រឿងអគ្គីភ័យយ៉ាងច្រើនណាស់ អាចបំផ្លាញលំនៅដ្ឋានបានបួនដប់ខ្នងប៉ុណ្ណោះឯង... ចំណែកគំនុំដែលមានកប់នៅក្នុងចិត្តអាចបង្កើតជាចំបាំងរាំងជល់យ៉ាងសាហាវអស្ចារ្យ ជាហេតុបណ្តាលឲ្យមានការវិនាសហិនហោចដ៏ធំធេង ហើយជួនកាលបណ្តាលឲ្យរលាយរលត់បាត់ស្រមោលទាំង

ប្រជាជាតិទៀតផង ។

ថ្ងៃមួយមានកើតការបះបោរចលាចលរឹករវរនៅក្នុងបូរីអេហ្វែស ។ ពួកអ្នកស្រុកមួយចំនួនបានមកអង្វរករហេរ៉ាគ្លិត ឲ្យនិយាយផ្សព្វផ្សាយនៅចំពោះមុខហ្វូងប្រជាពលករ អំពីមធ្យោបាយយ៉ាងណា ដើម្បីចៀសវាងកុំឲ្យមានការបែកបាក់និងកលិយុគផ្ទៃក្នុង ( សព្វថ្ងៃហៅថាសង្គ្រាមស៊ីវិល ) ។ ហេរ៉ាគ្លិតក៏បានឡើងអង្គុយលើអាសនៈមួយដ៏ខ្ពស់ ។ គាត់បានសុំគេឲ្យយកកែវមួយមក ដែលគាត់បំពេញដោយទឹកត្រជាក់... រួចគាត់បានយកគ្រឿងបន្លែព្រៃយកមកលាយមួយទងពីរទង ។ បន្ទាប់មកគាត់ក៏បានលើកកែវ ដែលមានគ្រឿងផ្សំក្រសាំងម្ហូមរបស់គាត់ អកទាំងអស់គ្មានសល់... ទើបគាត់ចាកចេញពីទីនោះដោយគ្មាននិយាយស្តីអ្វីទាំងអស់ ។ គាត់ចង់បង្ហាញតាមក្បួននេះថា ដើម្បីចៀសវាងកុំឲ្យមានទំនាស់បែកបាក់នៅក្នុងសង្គម គេគួរតែកំចាត់សភាពរុងរឿង និងការរស់នៅដោយសប្បាយត្រេកត្រអាលឲ្យអស់រលីងពីក្នុងសាធារណរដ្ឋ... ហើយត្រូវបង្ហាត់បង្រៀនពួកប្រជាជន ឲ្យចេះរស់នៅក្នុងទ្រព្យធនបន្តិចបន្តួចដែលពួកគេមាន ។

* *

*

ហេរ៉ាគ្លិតបាននិពន្ធសៀវភៅមួយច្បាប់អំពីធម្មជាតិ រួចហើយគាត់បានយកស្នាដៃរបស់គាត់ទៅតម្កល់ទុកនៅក្នុងព្រះវិហារនៃព្រះស្រីឱយ៉ាន ( ធ្យាន ៖ ព្រះនាងកាលី ឬកល្យានីនៃជនជាតិក្រិក ) ។ សៀវភៅនេះបានត្រូវសរសេរឡើង តាមរបៀបអាថ៌កំបាំងដ៏សែនងងឹតក្រៃលែង...គឺធ្វើឡើងសំរាប់តែឲ្យអ្នកចេះដឹងប៉ិនប្រសប់អានយល់តែប៉ុណ្ណោះ ។ គាត់ភ័យណាស់ ខ្លាចតែប្រជារាស្ត្រធម្មតានាំគ្នារាប់អានសៀវភៅរបស់គាត់ វានឹងក្លាយទៅជាសមញ្ញហួសហេតុពេក នោះវានឹងបណ្តាលឲ្យអ្នកផងមើលស្រាលចំពោះរូបគាត់ ។ សៀវភៅនេះ ក៏មានកេរ្តិ៍ឈ្មោះល្បីល្បាញក្រៃលែង, ពីព្រោះបើយោងតាមយោបល់របស់លូក្រែស ( Lucrèce ) គ្មានជនណាម្នាក់អាចដឹងស្គាល់អំពីអត្ថន័យដ៏សែនជ្រៅនៃសៀវភៅដ៏អស្ចារ្យនោះឡើយ ។ ដារិយុសព្រះចៅនៃប្រទេសពែរ្ស ដោយទ្រង់បានឮអំពីសៀវភៅនោះ ក៏បានសរសេរលិខិតមកអ្នកនិពន្ធ ដើម្បីអញ្ជើញគាត់ឲ្យទៅរស់នៅស្រុកពែរ្ស, ព្រមទាំងស្នើឲ្យគាត់ជួយពន្យល់ណែនាំអំពីសៀវភៅរបស់គាត់ផង ។ ជាមួយគ្នានឹងសំណើរនេះ ស្តេចបានសន្យាផ្តល់រង្វាន់ដ៏សម្បើមចំពោះគាត់ ព្រមទាំងផ្តល់លំនៅដ្ឋាននៅក្នុងព្រះរាជវាំងរបស់ទ្រង់ផង... ក៏ប៉ុន្តែហេរ៉ាគ្លិតបានបដិសេធមិនព្រមទទួលសំណើររបស់ស្តេចនេះឡើយ ។

ទស្សនវិទូម្នាក់នេះសឹងតែបើកមាត់មិនរួច... សឹងតែមិនដែលនិយាយស្តីអ្វីសោះឡើយ ហើយនៅពេលដែលជនខ្លះសួរគាត់ថា ហេតុអ្វីបានជាគាត់នៅស្ងៀមស្ងាត់បែបនេះ... គាត់ឆ្លើយក្នុងលក្ខណៈទោម្នេញមកវិញថា ៖ « គឺដើម្បីស្តាប់អ្នកឯងនិយាយ » ។ គាត់មាក់ងាយពួកជនដែលរស់នៅក្នុងទីក្រុងអាតែ្មន ដែលមានសេចក្តីកោតសរសើរនិងគោរពកោតខ្លាចចំពោះកិត្តិនាមរបស់គាត់ ហើយចចេសរស់នៅក្នុងក្រុងហ្វែស ដែលនៅទីនោះនរណាៗក៏តែងតែមើលងាយមើលស្រាលរូបគាត់គ្រប់ៗគ្នា ។

គាត់មិនដែលសម្លឹងមើលនរណាម្នាក់ ដោយមិនយំសោកចំបែងក្រៀមក្រំចិត្តនោះឡើយ ព្រោះហេតុតែអាណិតអានាថចំពោះសេចក្តីទន់ខ្សោយរបស់មនុស្សទាំងឡាយ និងចំពោះសេចក្តីល្ងីងជូរចត់នៃជីវិត ដោយហេតុថាមនុស្សយើងមិនដែលមានការសប្បាយចិត្តនឹងរបស់ដែលខ្លួនឯងមាននោះទេ ។ មនោសញ្ចេតនាស្អប់ខ្ពើមចំពោះមនុស្សគ្រប់គ្នា ក៏បានធ្វើឲ្យគាត់ដាច់ចិត្តចាកចេញពីភូមិដ្ឋានដែលមានមនុ-ស្សនៅ ។ គាត់បានថយខ្លួនទៅរស់នៅក្នុងព្រៃភ្នំក្រំថ្មដ៏សែនជ្រៅ ដែលគាត់មិនអាចមើលឃើញមនុស្សណាម្នាក់ ៖ ជីវភាពរបស់គាត់បានប្រព្រឹត្តទៅក្នុងការស្រែកឈឺថ្ងូរ... ម៉្យាងទៀតគាត់បរិភោគតែស្មៅហើយនិងបន្លែបង្ការតែប៉ុណ្ណោះ ។

* *

*

★ ហេរ៉ាក្លីតបានយល់ថា ភ្លើងគឺជាធាតុដើមនៃវត្ថុធាតុសព្វយ៉ាង ។

គាត់បានយល់ថា ធាតុដើមដំបូងដ៏សំខាន់ជាងគេនេះ នៅពេលដែលប្រមូលផ្តុំគ្នាយ៉ាងក្រាស់ឃ្មឹកទៅ ក៏បានក្លាយទៅជាខ្យល់ ។ ចំណែកខ្យល់ នៅពេលដែលប្រ-មូលផ្តុំគ្នាទៅ ក៏ក្លាយទៅជាទឹក ។ នៅទីបំផុតទៅ ធាតុទឹកនៅពេលដែលប្រមូលផ្តុំគ្នាតាមរបៀបដដែល ក៏បានក្លាយទៅជាដី ។ នៅពេលដែលរំលាយខ្លួនទៅតាមរបៀបបញ្ច្រាស់ទៅវិញ... ដីក៏បានក្លាយជាទឹក, ទឹកក៏បានក្លាយទៅជាខ្យល់, ចំណែកខ្យល់ក៏បានក្លាយទៅជាភ្លើង ។ ដូច្នេះហើយអគ្គីជាធាតុដើមដំបូងបំផុតនៃធាតុទាំងឡាយ។

★ ចក្រវាលនេះមានព្រំដែនច្បាស់លាស់ ។ ពិភពលោកយើងនេះមានតែមួយទេ ។ ពិភពនេះបានចាប់ផ្តើមកំណើតឡើងដោយសារភ្លើង... ពិភពនេះក៏ត្រូវតែរលាយរលត់ទៅវិញដោយសារភ្លើងនោះដែរ ។

★ ចក្រភពនេះមានសំបូរពោរពេញដោយព្រលឹង, ដោយព្រាយ និងទេពរ័ក្សអ្នកតា ។

★ ព្រះទាំងឡាយពុំមានបុណ្យបារមីអ្វីទាំងអស់... អ្វីៗដែលកើតឡើងនៅក្នុង

ចក្រភពនេះ គឺទាក់ទងនឹងវាសនាចារនៅក្នុងព្រហ្មលិខិត ។

★ ព្រះអាទិត្យពុំមានទំហំអ្វីធំណាស់ណា លើសពីការដែលយើងមើលឃើញនោះទេ ។ នៅឯអាកាសព្ធជរនភាល័យ តែងតែមានទូកយ៉ាងច្រើន ដែលបង្ហាញផ្ទៃកកោងក្រហូងមករកយើងទាំងអស់គ្នា ។ គឺសំដៅឆ្ពោះទៅទីនោះឯង ដែលទឹកទាំងឡាយនៅលើផែនដីត្រូវហួតយកទៅ... ចំណែករបស់អ្វីៗទាំងប៉ុន្មានដែលយើងប្រសិទ្ធិនាមថាជាផ្កាយនោះ គឺគ្មានអ្វីទៀតក្រៅតែពីទូកតូចៗទាំងនេះ ដោលពោរពេញដោយផ្សែងទឹក ហើយដែលភ្លឺចាំងខ្លាំងឡើង បណ្តាលឲ្យយើងមើលឃើញពីចម្ងាយ ។ រីឯសុគ្រាសនិងរាហ៊ូចាប់ច័ន្ទ គឺគ្រាន់តែជាព្រឹត្តិហេតុមួយដែលកើតឡើង នៅពេលដែលទូកតូចៗទាំងនេះ បំបែរផ្នែកប៉ោងមូលក្រឡុមរបស់ខ្លួនមកខាងផែនដីវិញ... ចំណែកព្រឹត្តិហេតុដែលបណ្តាលឲ្យគេមើលឃើញព្រះច័ន្ទម្តងមួយចំណិតៗនោះ គឺមកពីទូកលោកខែបត់ខ្លួនបន្តិចម្តងៗ ។

★ ចំពោះរឿងអ្វីៗដែលទាក់ទងនឹងធាតុរបស់ព្រលឹង, គាត់បានពោលថា ការស្វែងរករបស់នេះ ជាការបង្ខាតពេលឥតប្រយោជន៍... ពីព្រោះរបស់នេះវាលាក់ខ្លួនខ្លាំងពេកណាស់ មនុស្សយើងគ្មានថ្ងៃណាមានលទ្ធភាពនឹងរកវាឃើញបានទេ ។

* *

*

ហេរ៉ាគ្លិតមានជីវភាពដ៏លំបាកពេកទៅ ជាហេតុបណ្តាលឲ្យគាត់កើតរោគមួយជាទម្ងន់ ៖ ខ្លួនគាត់ក៏ហើមពោរ ហើយចេញទឹករងៃមិនចេះចប់ ។ គាត់ក៏វិលត្រឡប់ទៅព្យាបាលខ្លួននៅអេហ្វែសវិញ... ជាពិសេសគាត់បានដើរស្វះស្វែងរកគ្រូពេទ្យ ក៏ប៉ុន្តែដោយគាត់ចេះនិយាយតែត្រឹមប្រស្នាអាថ៌កំបាំង គាត់ក៏បានពោលទៅកាន់ពួកគេថា ៖

« តើអស់លោកអាចកែប្រែទឹកភ្លៀងឲ្យក្លាយទៅជាធាតុអាកាសស្ងួតស្ងប់ស្ងៀមបានឬទេ ? » ។

ពេលគ្រូពេទ្យទាំងនោះពុំបានយល់នូវអត្ថន័យនៃពាក្យសំដីរបស់គាត់, ហេរ៉ាគ្លិតក៏បានដើរតម្រង់ចូលទៅក្នុងក្រោលគោមួយ ។ គាត់ក៏មុជបង្កប់ខ្លួនចូលទៅក្នុងរណ្តៅអាចម៍គោ... ក្នុងគោលបំណងធ្វើយ៉ាងណាឲ្យទឹករងៃចេញពីខ្លួនគាត់អស់ ៖ គាត់មុជយ៉ាងជ្រៅចូលក្នុងរណ្តៅ ជាហេតុបណ្តាលឲ្យគាត់ពើខ្លួនចេញមកវិញមិនរួច ។ មានពួកអ្នកខ្លះបាននិយាយថា ហ្វូងសត្វឆ្កែបានស៊ីត្របាក់រូបគាត់ នៅកណ្តាលពំនូកអាចម៍គោនោះហើយ ។ អ្នកខ្លះទៀតអះអាងថា គាត់ស្លាប់ទៅពីព្រោះតែពើខ្លួនមិនរួចចេញពីអាចម៍គោដ៏ក្រាស់ឃ្មឹក ។

ពេលនោះគាត់មានអាយុ៦៥ឆ្នាំ ។៚

# ជីវិតរបស់ពីតាគុ
# PITTACUS

★ រីកចំរើននៅក្នុងអូឡាំព្យ៉ាដទី៤២ ។ បានទទួលមរណភាពនៅក្នុងឆ្នាំទី៣នៃអូឡាំព្យ៉ាដទី៥២... ចូលក្នុងអាយុ៧០ឆ្នាំ ។

ពីតាគុស បុត្ររបស់អ៊ីរ៉ាឌីយុស ដែលមានកំណើតនៅត្រាស, បានប្រសូត្រឡើងនៅមីទីឡែន ទីក្រុងតូចមួយនៅកោះឡេប៊ូស ក្នុងកំឡុងអូឡាំព្យ៉ាដទី២៩ ។ បុគ្គលនេះ កាលនៅក្នុងយុវវ័យមានចិត្តអង់អាចក្លាហានជាយុទ្ធជនមោះមុត, ជាមេបញ្ជាការដ៏ល្បី និងជាប្រជាពលរដ្ឋម្នាក់ដ៏គួររាប់អាន ។ គាត់បានជ្រើសរើសយកបាវចនាមួយដែលថែងថា គេត្រូវតែសំរបសំរួលអាត្មាជាមួយនឹងពេលវេលា ហើយត្រូវតែឆ្លៀតឱកាសបំពេញគោលប្រាថ្នា ដែលគេអាចឆ្លៀតធ្វើទៅបាន ។

នៅក្នុងកិច្ចការដំបូងបំផុតរបស់គាត់ ពីតាគុសបានចងសម្ពន្ធមេត្រីជាមួយប្អូនរបស់អាល់សេរ ដើម្បីប្រឆាំងតទល់នឹងជនផ្តាច់ការនៅប៉េឡង់ត្រឺ ( ជនក្រោយនេះបានដណ្តើមយករាជ្យអំណាចស្តេចនៅលើកោះឡេប៊ូស ) នៅទីបំផុតក៏បានទទួលជោគជ័យក្នុងការកំចាត់ស្តេចត្រាញ់នេះរហូតដល់ខ្ចាត់ខ្ចាយទៅ ។ សកម្មភាពនេះបានធ្វើឲ្យពីតាគុសមានកេរ្តិ៍ឈ្មោះល្បីល្បាញជាអ្នកក្លាហាន ។

តាំងពីយូរយារណាស់មកហើយ វាមានសង្គ្រាមមួយដ៏កាចសាហាវឃោរឃៅរវាងពួកមីទីឡែននិងពួកទីក្រុងអាតែ្ទន ក្នុងប្រការដណ្តើមយកទឹកដីមួយឈ្មោះអាហ្ស៊ីសីទីឌ ។ ពួកមីទីឡែនបានជ្រើសរើសយកពីតាគុស ដើម្បីបញ្ជាកងទ័ពរបស់ក្រុមខ្លួន ។ នៅពេលដែលកងទ័ពទាំងពីរបានមកប្រឈមមុខគ្នាហើយ ព្រមទាំងសង្គ្រឹតដាក់គ្នាមុននឹងហក់លោតចូលប្រយុទ្ធ ពីតាគុសក៏បានស្នើសុំឲ្យសំរេចយកជោគជ័យក្នុងការប្រយុទ្ធមួយទល់នឹងមួយវិញ ។ គាត់បានសុំប្រយុទ្ធតែដួយជាមួយនឹងហ្វ្រីណុង ឧត្តមបញ្ជាការកងទ័ពខាងក្រុងអាតែ្ទន ដែលជាអ្នកល្បីល្បាញក្នុងការប្រយុទ្ធតទល់គ្នាគ្រប់ប្រភេទ ហើយដែលធ្លាប់បានទទួលរង្វាន់កិត្តិយសច្រើនដងនៅក្នុងកីឡាអូឡាំពិកទៀតផង ។

ហ្វ្រីណុងក៏បានទទួលយល់ព្រមធ្វើការប្រយុទ្ធ ។ គេបានសំរេចថា អ្នកឈ្នះត្រូវតែមានឈ្មោះដាច់ខាត ថាជាអ្នកតណ្តើមយកទឹកដីបាន ។ ឧត្តមសេនិយទាំង

ពីរក៏បានចូលមកក្នុងទីលានប្រកួត ដែលឋិតនៅចំចន្លោះកណ្តាលនៃកងទ័ពទាំងសង្ខាង ។ ពីតាគុសបានលាក់សំណាញ់មួយនៅក្នុងខែលរបស់ខ្លួន ។ គាត់រង់ចាំឱកាសយ៉ាងប៉ិនប្រសប់ជាទីបំផុត លុះពេលវេលាមកដល់ គាត់ក៏បានយកសំណាញ់រុំព័ទ្ធហ្វ្រីណុង ដែលពុំបានប្រុងប្រយ័ត្នខ្លួនជាមុនសោះ ហើយគាត់ក៏ស្រែកថា ៖ « ខ្ញុំមិនមែនចាប់បានមនុស្សម្នាក់ទេ, ខ្ញុំចាប់បានត្រីមួយ » ។ ពីតាគុសក៏សម្លាប់សត្រូវរបស់ខ្លួននៅក្រោមក្រសែភ្នែកកងទ័ពទាំងពីរ ហើយគាត់ក៏បានក្លាយទៅជាម្ចាស់ទឹកដី ( ដែលគេបានប្រជែងដណ្តើមគ្នា ) ។ គឺតាំងពីពេលនោះមក ដែលមានដើមកំណើតនៃសំណាញ់ ដែលគេយកមកសំដែងក្នុងឆាកល្ខោន ដើម្បីឲ្យពលរដ្ឋបានកំសាន្តចិត្ត ។

នៅពេលដែលអាយុគាត់កាន់តែបានចំរើន... ពីតាគុសក៏បានបន្ថយពលភាពរបស់គាត់វិញ ។ គាត់ក៏បានចាប់ផ្តើមក្រេបជញ្ជក់នូវគុណភាព និងសេចក្តីសុខក្សេមក្សាន្តនៃទស្សនវិជ្ជា ។ ពួកអ្នកស្រុកមីទីឡែន ដែលមានសេចក្តីគោរពកោតខ្លាចជាពិសេសចំពោះរូបគាត់ ក៏បានប្រគល់កៅអីចៅហ្វាយក្រុងឲ្យគាត់កាន់កាប់ ។ ការពិសោធន៍មួយដ៏វែងឆ្ងាយនិងដ៏លំបាក បានធ្វើឲ្យគាត់សម្លឹងមើលដោយគ្មានតក់ស្លុត នូវភាពវិលត្រឡប់ចុះឡើងនៃកង់វាសនា ។

បន្ទាប់ពីបានរៀបចំឲ្យមានសណ្តាប់ធ្នាប់នៅក្នុងសាធារណរដ្ឋ, គាត់ក៏បានលះបង់ចោលសាលាក្រុង ដែលគាត់បានកាន់កាប់ត្រួតត្រាចំនួន១២ឆ្នាំ ហើយខ្លួនគាត់ក៏បានដកថយចេញពីការច្របូកច្របល់នៃកិច្ចការរដ្ឋ ។

បន្ទាប់ពីបានស្វះស្វែងរកសម្បត្តិគ្រប់យ៉ាង ពីតាគុសក៏បានចាប់ផ្តើមមើលងាយមើលស្រាលរបស់ទ្រព្យទាំងនេះវិញ ។ ពួកអ្នកស្រុកមីទីឡែន ក្នុងការថ្លែងអំណរគុណចំពោះគាត់ក្នុងកិច្ចការសាធារណៈដែលគាត់បានបំពេញ ក៏បានប្រគល់ដីធ្លីមួយដ៏ល្អភិរម្យជូនចំពោះគាត់ គឺជាទីដីមួយល្វឹងល្វើយ មានទឹកជ្រោះឆ្លងកាត់ រុំព័ទ្ធដោយព្រៃឈើនិងចំការទំពាំងបាយជូរ មិនត្រឹមតែប៉ុណ្ណោះ មានកន្លែងគង្វាលចៀម ដែលអាចផ្តល់កំរៃគ្រប់គ្រាន់ អនុញ្ញាតឲ្យគាត់រស់បានស្រួលនៅពេលដែលគាត់ចូលនិវត្តន៍ ។ ពីតាគុសក៏លើកស្ទួររបស់គាត់ ហើយចាប់ផ្តើមចោលយ៉ាងឆ្ងាយជាទីបំផុតដែលគាត់អាចធ្វើទៅបាន ហើយគាត់សុខចិត្តយកត្រឹមតែផ្ទៃដីក្រឡាដែលបានពីចម្ងាយហោះហើរ ( ប្អូនជ្រុងស្មើ ) នៃស្ទួររបស់គាត់តែប៉ុណ្ណោះ ។ ពួកចៅក្រមទាំងឡាយក៏មានចម្ងល់និងសេចក្តីសុភាពរាបសារបែបនេះ ហើយក៏បានសុំឲ្យគាត់ពន្យល់ពីមូលហេតុ ។ គាត់ក៏បានឆ្លើយតបដោយគ្មានការពន្យល់វែងឆ្ងាយ ថា ៖ « បានតែមួយភាគ វាគ្រាន់បើជាងបានទាំងអស់ » ។

ថ្ងៃមួយស្តេចក្រេស៊ុសបានសរសេរលិខិតទៅអញ្ជើញគាត់ឲ្យមកមើលឃ្លាំង

សម្បត្តិរបស់ទ្រង់ ។ ពីតាគុសក៏បានសរសេរតបទៅស្តេចវិញ ដោយសេចក្តីដូ-ច្នេះថា ៖

« ទ្រង់ចង់ណែនាំខ្ញុំឲ្យទៅស្រុកសីឌី ដើម្បីទៅសម្លឹងមើលកំណប់ទ្រព្យរប-ស់ទ្រង់ ៖ ដោយពុំចាំបាច់ឃើញក៏បានដែរ ខ្ញុំក៏បានដឹងរួចស្រេចទៅហើយថា កូនប្រុសរបស់ហាលីយ៉ាត់ ជាស្តេចដ៏ពូកែរុងរឿងអស់លើទាំងស្តេច ។ ប៉ុន្តែបើទោះជាខ្ញុំមានរបស់របរទាំងអស់ដែលទ្រង់មានក៏ដោយ ក៏នៅតែខ្ញុំមិនអាចមានលើសពីសព្វថ្ងៃដែរ ។ ខ្ញុំមិនត្រូវការទ្រព្យធនអ្វីទេ ។ ខ្ញុំអាចរស់ដោយសប្បាយ នៅក្នុងរបស់បន្តិចបន្តួច ដែលខ្ញុំមានជាចាំបាច់សំរាប់ធ្វើឲ្យយើងរស់... គឺខ្លួនខ្ញុំជាមួយមិត្តភក្តិ២-៣នាក់របស់ខ្ញុំប៉ុណ្ណោះ ។ ប៉ុន្តែខ្ញុំអាចធ្វើដំណើរទៅលេងទ្រង់ក៏បាន គឺសំរាប់គ្រាន់ឲ្យទ្រង់សប្បាយចិត្តតែប៉ុណ្ណោះ... » ។

ក្រេស៊ុស បន្ទាប់ពីបានបង្ក្រាបជនជាតិក្រិកនៅអាស៊ីរួចមកកាលណា ក៏បានសំរេចចិត្តរៀបចំនាវា ដើម្បីធ្វើសង្គ្រាមជើងទឹកដណ្តើមយកកោះក្រិកទាំងឡាយ ។ ពីតាគុសនៅពេលនោះ ក៏បានធ្វើដំណើរមកសារឌី ក្រេស៊ុសក៏សួរគាត់ថា តើមានអ្វីប្លែកនៅស្រុកក្រិក ?

– អម្ចាស់, ពីតាគុសពោល, ពួកអ្នករស់នៅក្នុងកោះទាំងប៉ុន្មាន បានទិញសេះ ១០,០០០ក្បាល ពួកគេបំរុងធ្វើសង្គ្រាមតទល់ជាមួយនឹងទ្រង់ដល់ទីក្រុងសារឌីតែម្តង ។

ឮដូច្នេះ ក្រេស៊ុសក៏លើកយកបញ្ហានេះទៅគិតពិចារណាដោយមធ្យ័ត រួចទ្រង់ពោលថា ៖

–សូមបួងសួងអស់ពួកទេព្តា... ធ្វើយ៉ាងណាឲ្យពួករស់នៅក្នុងកោះទាំងនោះយកទ័ពសេះមកច្បាំងនឹងយើងចុះ ។

ពីតាគុសក៏ឆ្លើយតបទៅក្រេស៊ុសថា ៖

– ខ្ញុំមើលទៅទ្រង់ ហាក់ដូចជាបន់ស្រន់ឲ្យពួកនៅក្នុងកោះលើកទ័ពសេះ មកវាយទ្រង់នៅលើដីគោក ។ ទ្រង់គិតឃើញដូច្នេះត្រឹមត្រូវហើយ ប៉ុន្តែទ្រង់កុំអាលអរពេក... ទ្រង់ត្រូវតែគិតថា ពួកកោះនឹងសប្បាយសើចយ៉ាងណាទៅ នៅពេលដែលគេដឹងថា ទ្រង់កំពុងរៀបចំកងនាវាទៅច្បាំងនឹងពួកគេ ? ពួកគេរៀបចំជាស្រេចនឹងប្រយុទ្ធជាមួយទ្រង់ និងពួកសីឌីតាមជើងទឹក... ដើម្បីសងសឹកនឹងវាសនាអាក្រក់របស់ពួកក្រិកទាំងប៉ុន្មាន ដែលទ្រង់បានធ្វើឲ្យធ្លាក់ទៅក្នុងទាសភាព ។

ស្តេចក្រេស៊ុសនឹកស្មានថា ពីតាគុសដឹងពីគោលបំណងសម្ងាត់របស់ទ្រង់ ។ ទ្រង់ក៏លះបង់គំនិតនៃការរៀបចំកងទ័ពជើងទឹកនេះចោលចេញ ហើយបែរជាចងស្ពានមេត្រីជាមួយនឹងពួកជនជាតិក្រិកដែលរស់នៅក្នុងកោះទាំងឡាយនោះវិញ ។

ពីតាគុសមានទម្រង់មុខរៀចម្ខាង ។ គាត់ចេះតែមានជម្ងឺឈឺភ្នែកជានិច្ចជាកាល ។ គាត់មានរាងធាត់ដុះខ្លាញ់ ហើយមានសំលៀកបំពាក់មិនជាបើ ។ គាត់មានដំណើរដើរយ៉ាងលំបាក ដោយសារតែគាត់មានពិការភាពម៉្យាងនៅជើងទាំងពីរ ។ គាត់បានរៀបអាពាហ៍ពិពាហ៍ជាមួយកូនស្រីរបស់ជ្រាកុង អ្នកសរសេរច្បាប់ ។ គឺជាស្រីម្នាក់តែពោរពេញទៅដោយមោទនភាព និងមានឫកពាក្រអឺតក្រទមឆ្មើងឆ្មៃដែលគ្មាននរណាអាចទ្រាំទ្របាន ។ ភរិយារបស់គាត់នេះ បានត្រឹមតែចេះមើលងាយប្តីរបស់ខ្លួនឯង ពីព្រោះដោយគាត់មានរូបរាងមិនល្អ... ម៉្យាងវិញទៀតដោយសារតែអ្នកស្រីចេះតែនឹកថាខ្លួនឯង មានដើមកំណើតក្នុងពូជពង្សខ្ពង់ខ្ពស់ ។ ថ្ងៃមួយពីតាគុសបានអញ្ជើញពួកទស្សនវិទូ ដែលត្រូវជាក្រុមមិត្តភក្តិរបស់គាត់មកបរិភោគអាហារល្ងាច ៖ នៅពេលដែលម្ហូបអាហាររៀបចំរួចហើយ ប្រពន្ធគាត់ដែលចេះតែមួរម៉ៅមិនចេះចប់មិនចេះហើយក្នុងរឿងផ្សេងៗ... ក៏បានរុញតុរុញចានដែ-លមានសាច់ទាំងប៉ុន្មានឲ្យក្រឡាប់ធ្លាក់អស់ ។ ពីតាគុសគ្មានបានសំដែងនូវកំហឹងអ្វីទាំងអស់ គាត់គ្រាន់តែបាននិយាយទៅកាន់ភ្ញៀវទាំងឡាយថា ៖

– មីស្ទីគេហ្នឹងវាឆ្កួតទេ... សូមកុំប្រកាន់ខឹងធ្វើអ្វី...

ការទាស់ទែងខ្វែងគំនិតគ្នានេះ ដែលធ្លាប់កើតមានឡើងជាអចិន្ត្រៃយ៍ រវាងរូបគាត់និងភរិយាគាត់... បានបណ្តាលឲ្យគាត់មានការស្អប់ខ្ពើមជាខ្លាំងចំពោះអាពាហ៍ពិពាហ៍ទាំងឡាយណា ដែលមិនបានសំរេច ( គឺចំណងមេត្រីរវាងគូកម្ម ) ។ ថ្ងៃមួយបុរសម្នាក់បានមកសួរគាត់ថា តើស្ត្រីប្រភេទណាទៅ ដែលគេត្រូវសំរេចយកធ្វើប្រពន្ធ គឺដោយហេតុថា ខ្លួនគេត្រូវប្រឈមមុខនឹងស្ត្រីពីរប្រភេទដែលគេត្រូវជ្រើសរើស... ។

ថ្ងៃមួយបុរសម្នាក់បានមកសួរគាត់ថា តើស្ត្រីប្រភេទណាទៅ ដែលគេត្រូវសំរេចយកធ្វើប្រពន្ធ គឺដោយហេតុថា ខ្លួនគេត្រូវប្រឈមមុខនឹងស្ត្រីពីរប្រភេទ ដែលគេត្រូវជ្រើ សរើស ៖ ម្នាក់មានវណ្ណៈប្រហាក់ប្រហែលនឹងរូបគេ, ម្នាក់ទៀតជាកូនក្រមុំចេញពីត្រកូលខ្ពង់ខ្ពស់, សំបើមទាំងកិត្តិយស សំបើមទាំងទ្រព្យសម្បត្តិ ។ ពីតាគុសក៏លើកដំបងមួយដែលគាត់ឈរច្រត់ពីលើ រួចហើយគាត់ស្រែកយ៉ាងត្រគោះថា ៖

– ទៅឲ្យឆ្ងាយនុះន៎! នៅកាច់ជ្រុងផ្លូវថ្នល់ មានក្មេងមួយក្រុមវាកំពុងតែលេងប្រឡែងគ្នា... ចូរឯងទៅសាកសួរពួកវាទៅចុះ...

យុវជននោះក៏បានដើរតម្រង់ទៅរកក្មេងៗ ។ លុះបានដឹងរឿងនេះកាលណាពួកវាក៏នាំគ្នាសើចគិលឡើង សប្បាយអស់ពីដួងចិត្ត... នៅទីបំផុតវានិយាយទៅកាន់បុរសថា ៖

– ចូរពួឯងជ្រើសរើសយកនាងស្រីណា ដែលមានឋានៈស្មើនិងពួឯង ! ។

រឿងនេះ ក៏បានណែនាំឲ្យបុរសលែងនឹកនាដល់ស្ត្រីថ្នាក់លើខ្ពស់ឆ្ងាយពីវណ្ណៈខ្លួន... ហើយឲ្យជ្រើសរើសស្ត្រីដែលមានឋានៈស្មើនឹងខ្លួនវិញ ។

ពីតាគុសចូលចិត្តបរិភោគម្ហូបអាហារក្រៀមក្រោះ, គាត់ផឹកតែទឹកម៉ាស៊ីនស្ទើរតែគ្រប់ពេលវេលាទៅហើយ, ថ្វីបើនៅមីទីឡែនមានសំបូរដោយស្រាក្រហមដ៏ឆ្ងាញ់ពិសារយ៉ាងណាក៏ដោយ ។

★ ពីតាគុសបានផ្ដែផ្ដាំយ៉ាងសម្ងាត់ទៅឲ្យប៉េរីយ៉ង់ដ្រឺថា ឲ្យគាត់នេះឈប់ផឹកស្រាក្រហមទៅ ប្រសិនបើគាត់ចង់ធ្វើនាយថៅហ្វាយដោយជោគជ័យនៅស្រុកកូរាំងត្តឺ ហើយបើគាត់ចង់បន្តអំណាចផ្ដាច់ការរបស់គាត់តទៅទៀត ។

★ គាត់បានដាក់បទបញ្ជាថា មនុស្សណាដែលបានប្រព្រឹត្តខុស នៅពេលដែលខ្លួនស្រវឹងស្រា... ត្រូវទទួលទោសពិន័យពីរត្រួត ។

★ គាត់បាននិយាយជាប្រក្រតីថា ការចាំបាច់ជាកម្លាំងមួយដ៏ស័ក្តិសិទ្ធិពេកណាស់ សូម្បីតែពួកទេព្ដាក៏ត្រូវឱនខ្លួនលំទោនតាមផងដែរ ។

★ គាត់បាននិយាយថា ទាល់តែនៅក្នុងរដ្ឋាភិបាលនៃសាធារណរដ្ឋ ទើបមានមនុស្សម្នាក់ អាចបង្ហាញនូវការលាតសន្ធឹងនៃបញ្ញារបស់ខ្លួនបាន ។

★ ពួកមនុស្សមានបញ្ញាត្រូវចេះប្រុងប្រៀបទុកជាមុន នូវសេចក្ដីទុក្ខលំបាកដែលអាចធ្លាក់មកលើរូបគេជាយថាហេតុ, គឺធ្វើយ៉ាងណាឲ្យខ្លួនគេមានលទ្ធភាពការពារខ្លួន និងដើរវាងគ្រោះថ្នាក់បាន ។ ចំណែកពួកជនដែលមានចិត្តធម៌មេត្តា គួរតែជួយស្នួយដោយសេចក្ដីសប្បុរស ឲ្យពួកទាំងនេះមានការប្រឹងប្រែងតស៊ូទប់ទល់នៅពេលដែលសេចក្ដីទុក្ខវេទនា បានធ្លាក់មកដល់ពួកគេ ។

★ គឺជាការមួយលំបាកពន់ពេកណាស់ ក្នុងការធ្វើជាមនុស្សល្អ ។

★ គ្មានការអ្វីដែលល្អប្រសើរជាជាងកិច្ចការដែលគេកំពុងតែប្រឹងប្រែងបំពេញឲ្យបានគាប់ប្រសើរក្នុងពេលវេលានេះទេ...

★ ដើម្បីឲ្យបានទទួលជោគជ័យ គេត្រូវតែគិះត្រិះរិះពិចារណាឲ្យបានវែងឆ្ងាយរួចហើយចាប់ផ្ដើមអនុវត្តជាបន្ទាន់ នូវគំរោងការណ៍ដែលគេបានគិតថ្លឹងថ្លែងដល់ទីជំរៅ ។

★ ជោគជ័យដ៏ល្អប្រសើរបំផុត គឺជោគជ័យដែលគេយកបានដោយគ្មានការបង្ហូរឈាម ។ ហើយដើម្បីឲ្យមហារដ្ឋមួយមានការគ្រប់គ្រងល្អប្រសើរ គឺត្រូវតែព្រះរាជាអង្គនោះ ព្រមទាំងអ្នកកាន់កាប់ក្រសួងអំណាចធំៗទាំងឡាយ ចេះគោរពច្បាប់ហាក់ដូចជាប្រជាពលរដ្ឋតូចតាចផងដែរ ។

★ បើអស់លោកអ្នកមានគោលបំណងចង់បំពេញកិច្ចការអ្វីមួយ ( ពីតាគុសនិ

យាយទៅកាន់សាវ័ករបស់គាត់ ) ចូរកុំអួតអាងប្រាប់នរណាជាមុនឲ្យសោះ, ពីព្រោះថា បើក្នុងភ័ព្វវាសនាអាក្រក់ លោកអ្នកប្រែជាមិនបានសំរេចទៅវិញ នោះអ្នកផងនឹងសើចចំអកឲ្យលោកអ្នកជាមិនខាន ។

★ កុំស្តីបន្ទោសដល់ជនណាម្នាក់ នៅពេលដែលគាត់នេះកំពុងធ្លាក់ខ្លួនអភ័ព្វ.. ដើម្បីចៀសវាងកុំឲ្យគេស្តីបន្ទោសចំពោះរូបលោកអ្នកផងដែរ នៅពេលណាដែលវេនរបស់លោកអ្នកធ្លាក់មកដល់ ។

★ កុំនិយាយអាក្រក់ពីនរណាឲ្យសោះ បើទោះជាអំពីសត្រូវរបស់លោកអ្នកក៏ដោយ ។

★ ចូរថែរក្សាមិត្តភក្តិរបស់លោកអ្នកឲ្យបានស្រួលបួល ព្រមទាំងរស់នៅជាមួយអ្នកទាំងនេះ ដោយប្រយ័ត្នប្រយែងក្នុងប្រការដែលអ្នកទាំងនេះ អាចប្រែក្លាយក្នុងថ្ងៃណាមួយ ទៅជាគូបរបក្សដ៏ធំបំផុតរបស់អស់លោកអ្នក ។

★ ចូរស្រឡាញ់ភាពបរិសុទ្ធ ( ការមិនមានទាក់ទងតាមផ្លូវស្នេហា ), ការបរិភោគត្បិតត្បៀត ហើយនិងសេចក្តីពិត ។

★ ត្រូវគោរពកោតខ្លាចព្រះ និងទេព្តាទាំងឡាយ ។

★ ត្រូវសងរបស់បញ្ញើទៅដល់ម្ចាស់ដើមវិញ ឲ្យបានស្អាតនិងគ្មានខ្វះខាត ដូចដែលគេផ្ញើលោកអ្នក ។ មិនត្រូវទម្លាយការសម្ងាត់ណាមួយជាដាច់ខាត ។

★ គាត់បានសរសេរកំណាព្យមួយ ដែលគាត់បានអះអាងថា គេគួរតែស្រវារយកធ្នូនិងព្រួញរបស់គេ ដើម្បីស្វែងតាមបាញ់ប្រហារជនអាក្រក់ នៅទីកន្លែងណាដែលគេបានជួបប្រទះជននេះ ពីព្រោះដោយចិត្តរបស់មនុស្សអាក្រក់តែងមានពីរតម្រួត... មាត់របស់វាមិនដែលថ្លាថ្លែងអ្វីចេញមក ដែលគួរឲ្យទុកចិត្តបាននោះទេ ។

★ ក្រេស៊ុសបានបញ្ជូនប្រាក់មួយចំនួនធំ ទៅជូនពីតាគុស នៅពេលដែលគាត់ចូននិវត្តន៍ ។ គាត់មិនបានព្រមទទួលយកឡើយ ។ គាត់បានឆ្លើយដោយគ្មានរំភើបថា ៖ ខ្ញុំមានទ្រព្យសម្បត្តិច្រើនហួសពាក់កណ្តាលដែលខ្ញុំត្រូវការចង់បាននោះទៅហើយ... ពីព្រោះបងរបស់ខ្ញុំបានស្លាប់ទៅដោយគ្មានកូនចៅ ចំណែកកេរ្តិ៍មរតករបស់គាត់ បានធ្លាក់មកលើរូបខ្ញុំទាំងអស់ ។

* *

*

ពីតាគុសចេះប្រើសំដីឆ្លើយតបយ៉ាងរហ័ស ហើយប្រកបដោយវិចារណញ្ញាណ ។ គាត់មិនដែលស្ថិតនៅក្នុងសភាពទ័លច្រកម្តងណាឡើយ បើទោះជាគេចោទសំនួរទៅលើរូបគាត់ដោយរបៀបណាក៏ដោយ ។

ថ្ងៃមួយគេបានសួរគាត់ថា ៖ តើរបស់អ្វីដែលផ្លាស់ប្តូរញឹកញាប់ជាងគេបំផុត?

ទឹកទន្លេ, គាត់បានឆ្លើយ, ហើយនិងចិត្តរបស់ស្រីៗ ។ តើរបស់អ្វីដែលគេត្រូវពន្យឺតពេលវេលាឲ្យបានវែងឆ្ងាយជាទីបំផុត ដែលគេអាចធ្វើទៅបាន ? គឺហារមាត់ខ្ញីប្រាក់ចំពោះមិត្តសំឡាញ់របស់គេ ។

តើរបស់អ្វីដែលគេត្រូវធ្វើនៅគ្រប់ទីកន្លែង ? -ឆ្លៀតឱកាសយលផលចំណេញ ពីរឿងល្អក្តី បីរឿងអាក្រក់ក្តីដែលកាលៈទេសៈរុញមកដល់ ។

តើអ្វីដែលបង្កើតឲ្យមានការមនោរម្យជាទីបំផុត ? -គឺពេលវេលា ។ អ្វីដែលលាល់កំបាំងជាទីបំផុត ? -គឺអនាគត ។ អ្វីដែលស្មោះត្រង់ជាទីបំផុត ? -ព្រះធរ-ណី ។ អ្វីដែលគ្មានការស្មោះត្រង់ជាទីបំផុត ? -សមុទ្រ ។

ថ្ងៃមួយ ហ្វូកែយុស បាននិយាយប្រាប់គាត់ថា ៖ ខ្លួនគេចង់និយាយសារសងជាមួយនិងជនសុចរិតម្នាក់ ដើម្បីគ្រាន់ចង់ដឹងថា តើអ្នកស្មោះត្រង់មានអ្វីខ្លះនៅក្នុ-ងផៃនគំនិតរបស់គេ ។

- លោកចង់ស្វែងរកដល់ណាក៏បានដែរ, ពីតាគុសឆ្លើយតប, ក៏ប៉ុន្តែលោកច្បាស់ជាមិនអាចរកឃើញសោះឡើយ ។

ថ្ងៃមួយ ទៀរ៉េ, កូនប្រុសរបស់ពីតាគុស, បានទៅនៅក្នុងហាងកាត់សក់មួយនៅស្រុកគូម៉ីស ដែលពួកយុវជនច្រើនតែមកធ្វើការប្រជុំគ្នា ដើម្បីជជែកដោះស្រាយអំពីព្រឹត្តិការណ៍នានា, ស្រាប់តែកម្មករម្នាក់ ដោយមិនបានជាគិត បានចោលពូ-ថៅមួយហើរទៅពុះក្បាលទៀរ៉េជាពីរចំណែក ។

បួកអ្នកស្រុកគូម៉ីសក៏បានដេញតាមចាប់ឃាតករ ហើយនាំខ្លួនវាយកមកឲ្យឪពុករបស់អ្នករងគ្រោះ ។ ពីតាគុសបន្ទាប់ពីបានជ្រាបពីគ្រប់កាលៈទេសៈនៃឧប្បត្តិ-ហេតុនេះរួចកាលណាហើយ ក៏បានរកឃើញថា ពុំមែនជាកំហុសអ្វីរបស់ជនដែលបានប្រព្រឹត្តអំពើនេះទេ ។ គាត់ក៏បានលែងបុរសនេះឲ្យរួចខ្លួនទៅវិញ ពីព្រោះថា, គាត់ពោល, កំហុសអ្វីដែលបានប្រព្រឹត្តដោយគ្មានចេតនា គួរតែលើកលែងទោសឲ្យ, ចំណែកអ្នកដែលគិតសងសឹកក្នុងរឿងនេះ អាចក្លាយទៅជាអ្នកមានទោស ពីព្រោះតែបានដាក់ទណ្ឌកម្មដោយអយុត្តិធម៌ទៅលើជនម្នាក់ដែលគ្មានទោសពៃរ៍ ។

ជួនកាលពីតាគុសមានការកំសាន្តសប្បាយក្នុងការសរសេរកំណាព្យ ។ គាត់បាននិពន្ធច្បាប់របស់គាត់ ព្រមទាំងសៀវភៅរបស់គាត់ជាច្រើន ជាកំណាព្យ ។ ការហាត់ប្រាណដែលជាចំណូលចិត្តរបស់គាត់ជាប្រក្រតី គឺការបង្វិលត្បាល់ដើម្បីកិនស្រូវសាឡី ។ គឺគាត់នេះហើយ ដែលបានធ្វើជាគ្រូបង្ហាត់បង្រៀនដល់ជនឈ្មោះហ្វេរីស៊ីដ ដែលអ្នកផងបានចាត់ទុកថា ជាអ្នកចេះដឹងម្នាក់នៅក្នុងចំណោមអ្នកប្រាជ្ញនៃប្រទេសក្រិក ៖ សេចក្តីស្លាប់របស់ហ្វេរីស៊ីដ ជាព្រឹត្តិការណ៍មួយដ៏អស្ចារ្យខ្លាំងណាស់ ។

គេបានតំណាលថា ថ្ងៃមួយ នៅពេលដែលភ្លើងសង្គ្រាមឆេះសន្ធោរសន្ធៅរវាងពួកជនអេហ្វេសនិងពួកម៉ាណេស៊ី, ហ្វេរីស៊ីដដែលជាមនុស្សជាទីស្រឡាញ់របស់ពួកអេហ្វេស បានជួបប្រទះនឹងបុរសម្នាក់តាមផ្លូវដំណើររបស់គាត់ ។ លុះពេលគាត់បានដឹងថា ជននេះមកពីស្រុកអេហ្វេស គាត់ក៏ពោលឡើងថា ៖

- ចាប់ខ្ញុំអូសពីជើងទៅមុន... ហើយនាំខ្ញុំរហូតដល់ស្រុកម៉ាណេស៊ី... ហើយចូរត្រឡប់ទៅស្រុកអេហ្វេសវិញដើម្បីនិយាយរាយរាប់ប្រាប់ពួកអេហ្វេសពីរបៀបឃោរឃៅយ៉ាងណាដែលគេបានធ្វើបាបហ្វេរីស៊ីដ ៖ « ប្រាប់ពួកគេផង កុំភ្លេចយកខ្ញុំទៅកប់ នៅពេលដែលពួកគេទទួលជ័យជំនះរួចហើយ ។ អ្នកដំណើរក៏អូសយកហ្វេរីស៊ីដឆ្ពោះទៅគោលដៅ... រួចហើយគេក៏ត្រឡប់ទៅរាយការណ៍ប្រាប់ពួកអេហ្វេស អំពីដំណើរការអាក្រក់ ដែលធ្លាក់ទៅដល់រូបគាត់ ។ ថ្ងៃស្អែកឡើង ពួកអេហ្វេសក៏បានធ្វើការវាយប្រយុទ្ធយ៉ាងខ្លាំងទៅលើពួកម៉ាណេស៊ី, ហើយក៏បានទទួលជោគជ័យយ៉ាងត្រចះត្រចង់ទៅលើពួកសត្រូវរបស់គេ ។ បន្ទាប់មកពួកគេក៏បានស្វះស្វែងជាប្រញាប់ទៅទីកន្លែងដែលគេបានទុកចោលហ្វេរីស៊ីដ ។ គេឃើញបុរសនេះស្លាប់នៅនឹងកន្លែង... ពួកគេក៏នាំយកសពទៅធ្វើបុណ្យឈាបនកិច្ចមួយគគ្រឹកគគ្រេងអធិកអធម ។

ពីតាគុសបានចូលមរណកាលនៅលើកោះឡេសបូស ក្នុងជន្មាយុ៧០ឆ្នាំ ។ គឺនៅក្នុងអូឡាំព្យ៉ាដទី៥២ ។៚

*    *

*

# ជីវិតរបស់ប្លតុង
# PLATON



( កើតនៅក្នុងឆ្នាំទី១ នៃអូឡាំព្យ៉ាដទី៨៨... ស្លាប់ទៅវិញនៅក្នុងឆ្នាំទី១ នៃអូឡាំព្យ៉ាដទី១០៨, នៅក្នុងជន្មាយុ ៨១ ឆ្នាំ ) ។

○

ប្លតុង ដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញ ដោយសារតែឧត្តមគតិ និងទ្រឹស្តីដ៏ខ្ពង់ខ្ពស់របស់គាត់បានត្រូវអ្នកផងចាត់ទុកថា ជាអ្នកជាប់និស្ស័យជាមួយព្រះ ឬជាអ្នកបានទទួលស្នាដៃអំពីព្រះ ។ គាត់បានកើតមកនៅក្នុងអូឡាំព្យ៉ាដទី៨៨ចេញពីវង់ត្រកូលមួយ ដែលឋិតនៅក្នុងចំណោមត្រកូលអ្នកធំដុំជាងគេនៅទីក្រុងអាតែ្មន ។ គាត់បានចុះពីត្រកូលកូដ្រុស តាមខ្សែឪពុករបស់គាត់ ដែលមានឈ្មោះថាជាអារីសតុង,និងពីត្រកូលសូឡុងតាមខ្សែរយៈម្តាយគាត់ ដែលមានឈ្មោះថា ប៉េរីចស្យូន ។ មុនដំបូងគេបានដាក់នាមឈ្មោះគាត់ថាជាអារីសតូកក៏ប៉ុន្តែដោយគាត់មានរូបរាងខ្ពស់ស្រឡះ

ធំធាត់ មានថ្ងាសទូលាយ ហើយមានស្មារីកទទឹងយ៉ាងក្រាស់ គេក៏បានប្រសិទ្ធិនាមគាត់ថាជាប្លាតុង ហើយរហស្សនាមនេះក៏បាននិត្យនៅជាមួយគាត់ជារាងរហូតមក ។

គេបាននិយាយថា កាលគាត់នៅជាកុមារក្នុងអង្រឹងនៅឡើយ... មានសត្វឃ្មុំជាច្រើនបានហើរមកបន្តក់ទឹកឃ្មុំរាយពាសនៅលើបបូរមាត់របស់គាត់ ។ ម្ល៉ោះហើយគេក៏បានឃើញនូវ សញ្ញានៃសារិកាលិនថោង ឬទេពកោសល្យខាងបញ្ចេញសំនួនវោហាររបស់ប្លាតុងដែលគ្មាននរណាម្នាក់ទៀតអាចប្រៀបប្រដូចបាននៅក្នុងចំណោមជនជាតិក្រិក ។

កាលនៅក្នុងសម័យយុវ័យប្លាតុង បានខិតខំរៀនសូត្រអំពីក្បួនវិជ្ជាកំណាព្យនិពន្ធ ។ គាត់បានសរសេរ បញ្ចេញកម្រងកំណាព្យ សំដែងអំពីមនោសញ្ចេតនាល្វឹងជូរចត់និងក្រអែមក្រអូបចំនួនពីរ និងរឿងល្ខោនសោកនាដកម្មពីរដែរ ...។ ក៏ប៉ុន្តែគាត់បានយកស្នាដៃអស់ទាំងនេះបោះចូលទៅក្នុងភ្លើង នៅពេលដែលគាត់បានសម្រេចចិត្តប្រគល់ខ្លួនគាត់ទាំងស្រុងទៅទស្សនវិជ្ជាវិញ ។ គាត់ទើបនឹងមានអាយុ២០ឆ្នាំ នៅពេលដែលឪពុកគាត់បាននាំខ្លួនគាត់ទៅសុំដល់សូក្រាត ឲ្យជួយង្ហាត់បង្ហាញផ្លូវ ។ កាលពេលរាត្រីដែលទើបកន្លងទៅសូក្រាតបានយល់សប្តិឃើញថាគាត់បានឱបកូនក្ងានមួយជាប់នឹងទ្រូង ដែលនៅពេលនោះវាទើបដុះស្លាបភ្លាមទៅ វាក៏ចាប់ផ្តើមទទះស្លាបហើរយ៉ាងខ្ពស់ត្រដែតកប់ពពកនៅលើមេឃ ដោយស្រែកច្រៀងពិរោះខ្ទរខ្ទារពេញនភាល័យ ។ ទស្សនវិទូរូបនោះ ក៏បានយល់ថាសុបិន្តរបស់គាត់គឺជាច្បាស់ជាបានសំដៅទៅប្លាតុងនោះឯង, ដែលគាត់បានធ្វើការសាកល្បងពិសោធន៍ជាមួយ, ហើយនោះហើយជាប្រផ្នូល ឬពិតមានដឹងជាមុន នូវកេរ្តិ៍ឈ្មោះរន្ទឺសុះសាយ ដែលសាវ័ករបស់គាត់នឹងត្រូវបានទទួលនៅក្នុងថ្ងៃណាមួយ ។

ប្លាតុងបាននៅបម្រើសូក្រាតយ៉ាងស្មោះត្រង់ជារៀងរហូតមកដរាបណាគាត់នេះនៅរស់ ក៏ប៉ុន្តែនៅពេលដែលសូក្រាតបានស្លាប់ទៅ ប្លាតុងក៏បានទៅភ្ជាប់ខ្លួនជាមួយនឹងក្រាទីល ដែលជាអ្នកស្មោះត្រង់នឹងគោលជំហររបស់ហេរ៉ាគ្លីត ...និងជាមួយអ៊ែរម៉ូសែនដែលដើរតាមជំហូន្មានរបស់ ប៉ារម៉េនីដ ។ នៅក្នុងអាយុ២៨ឆ្នាំ, ជាមួយនឹងសាវ័កឯទៀតៗរបស់សូក្រាតជាច្រើន, គាត់បានធ្វើដំណើរទៅមេក្ការ ដើម្បីស្វែងរកចំណេះដឹងផ្នែកវិទ្យាសាស្ត្រក្រោមការដឹកនាំរបស់អឺគ្លីឌ ។ ពីនោះទៅទៀត គាត់បានចាកចេញឆ្ពោះទៅស្រុកស៊ីរ៉ែន ដើម្បីទៅរៀនគណិតសាស្ត្រក្រោមការបង្ហាត់បង្ហាញរបស់តេអូឌរ។ បន្ទាប់មកទៀតគាត់បានឆ្លងកាត់មកអ៊ីតាលី ដើម្បីស្រង់យកចំណេះដឹងពីសាវ័កដ៏ល្បីល្បាញបីនាក់របស់ពីតាគ័រនៅក្នុងសម័យនោះគឺ ហ្វីឡូឡាយុស, អរជីតា ឌីតារ៉ង់, និងអឺរីទុស ។ ប៉ុណ្ណឹងហើយ គាត់មិនបានសប្បាយចិត្តនឹង

អ្វីៗដែលគាត់បានចេះដឹងអំពីអស់លោកគ្រូធំៗអស់ទាំងនេះទេ ។ គាត់បានចាកចេ-ញទៅប្រទេសអេយីព្ទថែមទៀតដើម្បីហាត់រៀនយកការពិសោធន៍ពីពួកបណ្ឌិតនិងពួកសម្តេចសង្ឃនៅទីនោះ ។ ហើយគាត់មានគោលប្រាថ្នាធ្វើដំណើរទៅប្រទេសឥណ្ឌាថែមទៀតដើម្បីទៅរៀនសូត្រពីពួកសេកមន្តអាគម (ពួកម៉ាឃី-ម៉ាឃា ៖ Ma-ges ) ...ក៏ប៉ុន្តែកាលនោះ មានសង្គ្រាមកើតឡើងនៅទ្វីបអាស៊ី... គាត់ក៏បានខកខានក្នុងគំរោងការណ៍ដំណើរចុងក្រោយនោះទៅ ។

បន្ទាប់ពីបានធ្វើដំណើរសព្វទីកន្លែងស្វែងរកចំណេះវិជ្ជាដូច្នេះហើយ, ប្លាតុងក៏បានវិលត្រឡប់មកក្រុងអាតែ្មនវិញ។ គាត់បានមកតាំងលំនៅក្នុងភូមិមួយដែលមានឈ្មោះថា អាកាដេមី ( កកន ៖ ដូច្នេះ ពាក្យថា Académie, ឬពាក្យ Academy ... មានដើមកំណើតពីឈ្មោះភូមិរបស់ប្លាតុងនោះឯង ) ។ ភូមិនោះ ជាទីកន្លែងមិនសូវស្អាត ដែលប្លាតុងបានជ្រើសរើសដោយគោលបំណង ពីព្រោះគាត់យល់ថា គឺជាទីកន្លែងចាំបាច់ដើម្បីកែរោគធាត់របស់គាត់ ដែលបណ្តាលឲ្យសុខភាពរបស់គាត់ធ្លាក់ទន់ខ្សោយ ។ របៀបកែរោគដូច្នេះមានប្រសិទ្ធភាពពិតមែន, ពីព្រោះនៅទីនោះ គាត់ត្រូវចាញ់ធាតុអាកាស ហើយក៏បានចាប់ផ្តើមកើតរោគគ្រុនសន្ធិអស់រយៈវេលាមួយឆ្នាំកន្លះ។ ក៏ប៉ុន្តែដោយសារគាត់ខំប្រឹងអត់ទ្រាំ តមម្ហូបចំណីយ៉ាងខ្ជាប់ខ្ជួនគាត់ក៏បានយកជ័យជំនះទៅលើរោគគ្រុនចាញ់នេះ ...ហើយសុខភាពរបស់គាត់ក៏មានសភាពរឹងប៉ឹងឡើងវិញជាអតិបរិមា ។

ប្លាតុង គាត់បានទៅធ្វើសឹកសង្គ្រាមបីដង ។ លើកទីមួយនៅតាណាក, លើកទីពីរនៅកូរ៉ាំង ( កូរិនថូស ), លើកទី៣ នៅដេឡូស , ហើយនៅក្នុងចំបាំងជាលើកចុងក្រោយនេះ, គណបក្សរបស់គាត់ក៏បានទទួលជោគជ័យ ។

គាត់បានធ្វើដំណើរបីដងទៅស្រុកស៊ីស៊ីលផងដែរ; នៅលើកទីមួយ គឺនៅក្នុងការចង់ដឹងចង់ស្គាល់តែប៉ុណ្ណោះ, ម្យ៉ាងវិញទៀតគឺគាត់ចង់ទៅឃើញទិដ្ឋភាពនៃភ្នំភ្លើងអេតណា ។ កាលសម័យនោះ, គាត់មានអាយុ៤០ឆ្នាំរួចទៅហើយ ៖ គាត់បានទៅលេងវាំងស្តេចមួយអង្គ ហៅថាកញ្ជាស់ដេនីស-ឡឺទីរ៉ង់ ដែលជាស្តេចផ្តាច់ការក៏ប៉ុន្តែដែលមានគោលប្រាថ្នាចង់ជួបលោកទស្សនវិទូ។ សេរីភាពដែលគាត់បានប្រើហួសពេកក្នុងការជជែកវែកញែកជាមួយនឹងស្តេចដេនីស អំពីអំណាចផ្តាច់ការ... ក៏បានបណ្តាលឲ្យស្តេចនេះមានសេចក្តីក្រេវក្រោធយ៉ាងខ្លាំងរហូតដល់ចង់យករូបគាត់ទៅប្រហារជីវិត ។ ជាសំណាងល្អ នៅពេលនោះមានឈ្មោះ ឌីយ៉ុង ហើយនិងអារីសតូម៉ែន បានជួយអង្វរករស្តេចឲ្យលើកលែងទោសរបស់គាត់ ។ កញ្ជាស់ដេនីសក៏បានលើកលែងជីវិតឲ្យប្លាតុង ក៏ប៉ុន្តែបានប្រគល់ខ្លួនគាត់ទៅក្នុងកណ្តាប់ដៃរបស់ប៉ូលីដ ដែលជាអគ្គរដ្ឋទូតនៃពួកឡាសេដេម៉ូនប្រចាំនៅក្នុងវាំងរបស់ស្តេចផ្តាច់

ការ, ទ្រង់ក៏បានបញ្ជាឲ្យជននេះយកប្លាតុងទៅលក់ដូចជាខ្ញុំកញ្ជះគេ ។ អគ្គរដ្ឋទូតរូបនេះ ក៏បាននាំយកប្លាតុងទៅអេយីន, ហើយក៏បានលក់រូបគាត់នៅទីនោះ ។ ពួកអ្នកស្រុកនៅអេយីនបានបង្កើតច្បាប់មួយដែលចែងថា ឲ្យតែមានអ្នកស្រុកអាតែ្ហនឯណាម្នាក់ចូលខ្លួនទៅក្នុងកោះនោះ នឹងត្រូវយកទៅប្រហារជីវិតចោល ។ គឺនៅក្រោមលេសនៃច្បាប់នេះហើយ, ដែលជនម្នាក់ឈ្មោះឆរម៉ង់ឌើរ បានទាមទារឲ្យដាក់ទោសពិន័យរូបគាត់ដោយត្រូវយកទៅសម្លាប់ ..ក៏ប៉ុន្តែនៅទីនោះមានពួកជនខ្លះបានអះអាងថាច្បាប់នេះ បានត្រូវបង្កើតឡើងសម្រាប់ដាក់ទោសមនុស្ស... ក៏ប៉ុន្តែមិនមែនសម្រាប់អនុវត្តន៍ទៅលើទស្សនវិទូរនោះឡើយ... អ្នកផងក៏សុខចិត្តយករូបគាត់ត្រឹមតែទៅលក់ដូរបន្តគ្នាតែប៉ុណ្ណោះ ។ ជាភ័ព្វល្អចំពោះគាត់ទៀត, ជនម្នាក់ឈ្មោះអាណេស៊ីរី មកពីស៊ីរ៉ែនបាននៅក្នុងស្រុកនោះដែរ ។ ក្នុងពេលនោះ, គាត់ក៏បានទិញប្លាតុងដោយចេញថ្លៃ២០មីន ( ពីរពាន់ប្រាក់លុយក្រីកជំនាន់ដើម បើគិតជាទម្ងន់ប្រាក់ប្រមាណ៧០០ក្រាម ) រួចក៏បានបញ្ជូនគាត់ទៅឲ្យមិត្តភ័ក្តិគាត់វិញនៅទីក្រុងអាតែ្ហន ។ ចំពោះប៉ូលីដ, អគ្គរដ្ឋទូតមកពីឡាសេដេម៉ូនដែលបានលក់ប្លាតុងមុនគេ, ជននេះក៏បានត្រូវច្បាំងចាញ់កាប្រ៊ីយ៉ា, ហើយក៏បានត្រូវវិនាសស្លាប់នៅក្នុងទឹក ជាទណ្ឌកម្មដែលគាត់ត្រូវបានទទួលដោយសារតែបានធ្វើបាបដល់ទស្សនវិទូឈ្មោះប្លាតុង, ដូចដែលអារក្សបញ្ចូលរូបបានប្រាប់ជននេះជាមុន យោងតាមសំដីអ្នកផង។ ស្តេចកញ្ចាស់ឈ្មោះដេនីស ដោយដឹងថាទស្សនវិទូររូបនេះ បានវិលត្រឡប់ទៅក្រុងអា-តែ្ហនវិញហើយ, ក៏មានសេចក្តីភ័យខ្លាចគាត់សងសឹកដោយបកកេរ្តិ៍ស្តេច ។ ស្តេចផ្តាច់ការក៏បានសរសេរលិខិតមួយថែមទៀតផងដើម្បីទៅសុំខមាទោសពីគាត់ ។ ប្លាតុងបានសរសេរតបទៅវិញថាកុំឲ្យស្តេចព្រួយបារម្ភពីរឿងនេះឲ្យសោះ ដោយហេតុថាគាត់មានកិច្ចរវីរវល់ជាមួយនឹងទស្សនវិជ្ជាច្រើនពេកណាស់គ្មាន ពេលឯ-ណាទៅរវីរវល់ជាមួយនឹងស្តេចនោះទេ ។ មានមិត្តភ័ក្តិខ្លះបាននិយាយចំអកឲ្យគាត់ថា គាត់បានត្រូវស្តេចដេនីសបោះបង់ចោល ប៉ុន្តែប្លាតុងបានឆ្លើយតបវិញថា ៖ « មិនមែនដេនីសទេ ដែលបានបោះបង់ចោលប្លាតុង, គឺប្លាតុងទៅវិញទេ ដែលបានបោះបង់ចោលដេនីស » ។

○

គាត់បានធ្វើដំណើរជាលើកទី២ ទៅស៊ីស៊ីល, នៅក្នុងសម័យរាជ្យអំណាចរបស់ដេនីសស្តេចក្មេង, ដែលត្រូវជាកូនរបស់ស្តេចមុន ដោយសង្ឃឹមថានឹងបានណែនាំឲ្យជនផ្តាច់ការនេះមានចិត្តអាណិតអាសូរ ដោយផ្តល់សេរីភាពទៅដល់ប្រជានុរាស្ត្រ, បើពុំនោះសោតទេដោយជំរុញឲ្យជននេះ ធ្វើការគ្រប់គ្រងដោយសេចក្តីស្លូតបូតនិង

មេត្តាករុណា, ក៏ប៉ុន្តែបន្ទាប់ពីបានសំណាក់នៅទីនោះ៩ខែ, គាត់ក៏បានសង្កេតឃើញថា ជនផ្តាច់ការម្នាក់នេះនៅមានឫកពារតែដដែល ពុំមានការផ្លាស់ប្តូរសោះឡើយ, ពោលគឺមិនបានទទួលមេរៀនពីរូបគាត់ វាបែរជាបាននិរទេសឪយ៉ុងឲ្យទៅរស់នៅក្នុងភាពខ្វាត់ព្រាត់ ។ មិនត្រឹមតែប៉ុណ្ណោះ ជនផ្តាច់ការជំនាន់ក្រោយនេះ បានបន្តការជិះជាន់ប្រហែលគ្នានឹងឪពុករបស់ខ្លួនដែរ ប្លាតុងក៏បានវិលត្រឡប់ទៅទីក្រុងអាតែ្មនវិញបើទោះជាមានការអង្វរករពីជនផ្តាច់ការយ៉ាងណាក៏ដោយ ។ ដេនីសស្តេចក្មេងបានចាត់វិធានការណ៍គ្រប់បែបយ៉ាងដើម្បីប្រទាញចិត្តទស្សនវិទូឲ្យរស់នៅទីនោះ។

ប្លាតុងបានធ្វើដំណើរជាលើកទី៣ ទៅស៊ីស៊ីល ដើម្បីស្នើរសុំដល់ជនផ្តាច់ការអនុញ្ញាត្តឲ្យឪយ៉ុងវិលត្រឡប់មករស់នៅទីនោះវិញ, មិនត្រឹមតែប៉ុណ្ណោះដើម្បីសុំឲ្យស្តេចក្មេងម្នាក់នេះ លះបង់លក្ខណៈរបស់ខ្លួនជាស្តេចថែមទៀតផង ។ ក៏ប៉ុន្តែដេនីសស្តេចក្មេងដែលបានសន្យាជាមួយប្លាតុងរួចហើយថានឹងធ្វើដូច្នោះ មិនបានគោរពសំដីរបស់ខ្លួនវិញ ជាហេតុឲ្យប្លាតុងស្តីបន្ទោសយ៉ាងខ្លាំងដល់ស្តេច ថាមិនបានគោរពពាក្យសច្ចៈ ។ ដេនីសស្តេចក្មេង ក៏ខ្វាល់ក្រេវក្រោធយ៉ាងខ្លាំង ហើយប្លា-តុងប្រហែលជានឹងត្រូវអស់ជីវិតទៀតផង, ប្រសិនបើអរជិតាជីតាវ៉ង់មិនបានបញ្ជូនរដ្ឋទូតម្នាក់ទៅតវ៉ាក្នុងរឿងនេះ...ព្រមជាមួយគ្នានិងនាវាមួយទៀតផងដើម្បីដឹកយកប្លាតុងត្រឡប់មកវិញ ។

ដោយសារតែសេចក្តីអង្វរកររបស់អរជីតាជីតាវ៉ង់ ដេនីសមិនត្រឹមតែបានលើ-កលែងទោសឲ្យប្លាតុងប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងបានជួយផ្តល់នូវគ្រឿងចាំបាច់សព្វយ៉ាងក្នុងការធ្វើដំណើរថែមទៀតផង ។ ប្លាតុងក៏បានថយខ្លួនមករស់នៅក្រុងអាតែ្មនវិញ ... ដោយគ្មានពេលណាចាកចេញពីទីនោះម្តងទៀតឡើយ ។...

នៅអាតែ្មន, ប្លាតុងត្រូវបានគេទទួលដោយកិត្តិយសដ៏មហាលើសលប់ ។ ក៏ប៉ុន្តែថ្វីបើអ្នកផងបានជំរុញគាត់ពីគ្រប់ទិសឲ្យចូលរួបរួមយកកន្លែងកៅអីក្នុងរដ្ឋាភិបាលក្តីគាត់ក៏បានបដិសេធ ដោយគាត់យល់ឃើញថា គាត់ច្បាស់ជា នឹង ពុំបានចំណេញអ្វីទេ នៅកណ្តាលសភាពអាណាធិបតេយ្យនិងអំពើពុករលួយនៃសង្គមរបស់គាត់នាសម័យនោះ ។ ក៏ប៉ុន្តែគ្មានសញ្ញាអ្វី ដែលធ្វើឲ្យគេដឹងអំពីសេចក្តីស្រឡាញ់ ដែលប្លាតុងបានទទួលអំពីមហាជននៅក្នុងផ្ទៃនៃប្រទេសក្រិកទាំងមូល ជាជាងព្រឹត្តិការណ៍ដែលកើតមានឡើង នៅពេលដែលគាត់បានទៅធ្វើទស្សនកិច្ចនៅទីកន្លែងដែលកំពុងតែមានការប្រកួតកីឡាអូឡាំពិកនោះទេ។ នៅពេលនោះ គាត់បានត្រូវអ្នកផងទទួ-ល ដូចព្រះជាម្ចាស់ដែលច្បុតចុះពីលើមេឃដូច្នោះឯង ។ ចំណែកមនុស្សនានាមានលាយឡំគ្នាច្រើនសាសន៍ ច្រើនសញ្ជាតិ មកពីគ្រប់ទិសទីនៃប្រទេសក្រិកដែលចូលចិត្តសប្បាយទស្សនារបាំមហោរី, ហើយដែលបានមកកាន់ទីនោះ ដោយសារតែ

ការសំដែងអស្ចារ្យនៃកិឡាអូឡាំពីក ...ក៏ស្រាប់តែបានបោះបង់ចោលទិដ្ឋភាពនៃការសំដែងការប្រណាំងសេះ, និងការប្រយុទ្ធគ្នារវាងកីឡាករទាំងឡាយ ហើយបែរជាមកសប្បាយ នឹងទិដ្ឋភាពមនុស្សម្នាក់ ដែលគេបាននិយាយពីលក្ខណៈល្អប្រសើរគ្រប់យ៉ាង ។

ប្លាតុងបានរស់នៅលើវពេញមួយជីវិតរបស់គាត់ ។ ហើយគាត់បានគោរពក្បួនតំណាមដ៏តឹងរ៉ឹងជាទីបំផុតទាក់ទងនឹងជីវិតស្រើបស្រាល ម្យ៉ាងវិញទៀតគាត់បរិភោគតែម្ហូបក្រៀមក្រោះ ដែលខ្វះខាតនូវសភាពឆ្ងាញ់ជាទីបំផុត។ គាត់មានសេចក្ដីអត់ធ្មត់មិនចេះច្រឡោតតោតតួងហើយសូម្បីតែពីកាលគាត់នៅអាយុក្មេងខ្ចីក្ដី, គេមិនដែលបានឃើញគាត់សប្បាយសើចក្អាកក្អាយពេញទំហឹងដល់ម្ដងណាឡើយ។ គាត់ចេះទប់ខ្លួនមិនឲ្យមនោសញ្ចេតនាដឹកនាំគាត់ និងចេះគ្រប់សង្កត់តណ្ហារបស់គាត់ជានិច្ច ... រហូតដល់គាត់មិនដែលបានសំដែងបង្ហាញកំហឹងដល់ម្ដងណាឡើយ ។ ដូច្នេះហើយ បានជាគេនិយាយថា មានយុវជនម្នាក់ដែលបានទៅរស់ជាមួយគាត់ជាយូរឆ្នាំ ហើយដែលបានវិលត្រឡប់ មករស់នៅជាមួយឪពុកម្ដាយខ្លួនវិញ, ក៏មានការភ្ញាក់ផ្អើលជាខ្លាំងនៅពេលដែលឃើញឪពុកខ្លួនមានកំហឹង...រហូតដល់យុវជនេះបានលាន់មាត់ថា ខ្លួនមិនដែលឃើញប្លាតុងមានអាកប្បកិរិយាបែបនេះ សូម្បីតែម្ដងក៏គ្មានដែរ ។ មានម្ដងប៉ុណ្ណោះដែលគាត់ហាក់ដូចជាមានការរសាប់រសល់ខ្លះៗ គឺនៅពេលដែលខ្ញុំបម្រើគាត់ម្នាក់បានប្រព្រឹត្តកំហុសមួយដ៏ធ្ងន់ធ្ងរមែនទែន ។ គាត់ក៏បានបញ្ជាឲ្យដាក់ទោសជននេះ តាមរយៈជនម្នាក់ទៀត ...ដោយគាត់ពោលថា គាត់មានកំហឹងខ្លះៗនៅក្នុងខ្លួនដែលជាហេតុមិនអនុញ្ញាត្តឲ្យគាត់មានសមត្ថភាពដាក់ទោសជននេះដោយខ្លួនគាត់បានឡើយ ។ ថ្វីបើគាត់មានជំនោរពីធម្មជាតិជាមនុស្សមានលក្ខណៈក្រៀមក្រំ ហើយចូលចិត្តគិតពិចារណាវែងឆ្ងាយ, ដូចដែលបានកត់សំគាល់អារីសតូត, ប៉ុន្តែគាត់មានលក្ខណៈទន់ភ្លន់ ហើយមានការសប្បាយត្រេកត្រអាលដុះចេញពីចិត្តខ្លួនឯង, មិនត្រឹមតែប៉ុណ្ណោះសោត គាត់ចូលចិត្តនិយាយលេងចំអន់ដែលមិនមានធ្វើឲ្យខូចខាតដល់នរណា ៖ ដូចជាមានពេលខ្លះ គាត់បានផ្ដល់យោបល់ឲ្យសេណូក្រាតនិងឌីយ៉ុង ដែលមានលក្ខណៈជាមនុស្សកាចរញ៉េរញ៉ៃខ្លាំងពេក ឲ្យធ្វើបុណ្យទានទៅ ...ដើម្បីឲ្យព្រះប្រទានបុកពរស្រួលបួលស្លូតបូតជាងនេះបន្តិច ។

ប្លាតុងមានសាវ័កជាច្រើន ៖ ពួកដែលមានស្នាដៃជាងគេ គឺស្ពើស៊ីប, ដែលត្រូវជាក្មួយបង្កើតរបស់គាត់, ជាកូនប្អូនស្រីរបស់គាត់ឈ្មោះប៉ូតូន ដែលបានរៀបការជាមួយឈ្មោះអឺរីម៉ីដុង; សេណូក្រាត ជនដែលមកពីកាល់សេដូនី ហើយនិងអ្នកប្រាជអារីសតូតដ៏ល្បីល្បាញ ។ គេបាននិយាយថា តេអូប្រ្យាស្ដក៏បានឋិតនៅក្នុងចំណោមសិស្សរបស់គាត់ដែរ ចំណែកដេម៉ូសតែនវិញបានទុករូបគាត់ជាគ្រូបាធ្យាយន៍ជានិច្ច

ជាកាល ។ តាមពិតជនក្រោយនេះ, ក្នុងសម័យថ្ងៃមួយបានរត់គេចវេសពីកណ្ដាប់ដៃឈ្មោះអង់ទីប៉ាទើរ ...។ ដោយខ្មាំងសត្រូវឈ្មោះ អាឆាស-អង់ទីប៉ាៈទើរនោះបានបញ្ជូនមនុស្សឲ្យទៅចាប់ខ្លួនដេម៉ូសតែន ដោយសន្យានឹងគាត់នេះថា នឹងឲ្យគាត់នេះរួចជីវិតឲ្យតែចេញពីទីកន្លែងលាក់ខ្លួនមក, ដេម៉ូសតែនក៏បានឆ្លើយតបវិញដូច្នេះថា៖ « សូមព្រះធ្វើជាសាក្សីចុះ, បន្ទាប់ពីបានស្ដាប់សេណូក្រាត និងប្លាតុងរាយរាប់អំពីសភាពអមតៈនៃដួងព្រលឹងរួចហើយ...ខ្ញុំលែងចង់បានជីវិតមួយ ដែលរស់នៅក្នុងការអៀនខ្មាស់ ហើយសុខចិត្តទទួលយកសេចក្ដីស្លាប់មួយដ៏សុច្ចរិតវិញ! » ។ គេអាចរាប់បានថាមាន ស្រីពីរនាក់ក៏បានទទួលថានៈជាសាវ័ករបស់ប្លាតុងផងដែរ ៖ ស្រីម្នាក់ឈ្មោះឡាសតេនី ដឺម៉ង់ទីណេ ... ស្រីម្នាក់ទៀតឈ្មោះ អាស្យូតេ ដឺព្លីយ៉ា-ស៊ី, ស្រីទាំងពីរនាក់នេះមានទម្លាប់ស្លៀកពាក់ដូចជាមនុស្សប្រុស... ពីព្រោះកាលពីសម័យ នោះសម្លៀកបំពាក់ដូច្នេះ វាសមសក្ដិនឹងទស្សនវិជ្ជាដែលស្រីទាំងពីរបានឱបក្រសោបយកធ្វើជាវិជ្ជាជីវៈ ។ ប្លាតុងបានផ្ដល់តម្លៃដ៏ខ្ពង់ខ្ពស់ជាទីបំផុតដល់វិជ្ជានៃរេខាគណិត ( Géométrie ) ដោយគាត់បានយល់ថា ជាវិជ្ជាមែកធាងមួយសំខាន់ចាំបាច់របស់ទស្សនវិជ្ជា, ម្ល៉ោះហើយគាត់ក៏បានឲ្យឆ្លាក់អក្សរនៅត្រង់ផ្លូវចូល បណ្ឌិតសភារបស់គាត់ ( Académie ) ថា ៖ « ជនណាដែលមិនចេះវិជ្ជារេខាគណិត មិនបាច់ចូលមក្នុងទីនេះទេ » ។

ស្នាដៃនៃសំណេរទាំងអស់របស់ប្លាតុង, ដោយមិនគិតពីកំរងលិខិតរបស់គាត់ដែលមានចំនួន១២, មានលក្ខណៈជាការជជែកពិភាក្សាគ្នា ។ គេអាចចែកសៀវភៅនៃកិច្ចពិភាក្សាទាំងនេះជាបីចំណែក ។ នៅក្នុងផ្នែកទី១- ប្លាតុងបានធ្វើការប្រឆាំងនឹងពួកសូហ្វីស្ត... នៅក្នុងផ្នែកទី២ គាត់បានសាកល្បងធ្វើការអប់រំឲ្យពួកយុវជន, នៅក្នុងផ្នែកទី៣ សំណេររបស់គាត់សំដៅទៅរកពពួកមនុស្សចាស់ទុំ ដែលមានការពិចារណាជ្រៅជ្រះរួចមកហើយ ។ គេត្រូវវែកញែកកិច្ចភិភាក្សាខាងលើនេះជាពីរសណ្ឋានថែមទៀត ៖ ទី១-សំណេរអ្វីៗដែលប្លាតុងបានដាក់ឈ្មោះខ្លួនឯង នៅក្នុងកម្រងលិខិតរបស់គាត់ក្ដី, នៅក្នុងសៀវភៅច្បាប់របស់គាត់ក្ដី ឬនៅក្នុងសៀវភៅ Epinomis របស់គាត់, គឺគាត់បានតាក់តែងឡើងជាទ្រឹស្ដីផ្ទាល់របស់គាត់។ ក៏ប៉ុន្តែចំពោះសៀវភៅឯទៀតៗដែលគាត់បានដាក់ឈ្មោះរបស់អ្នកដទៃ. ដូចជាឈ្មោះសូ-ក្រាត, ទីម៉េ, ប៉ារម៉េនីឌ ឬសេណុង នោះគាត់បានចាត់ទុកថាជាទ្រិស្ដីមិនទាន់ប្រាកដប្រជា...ដែលគាត់មិនបានទទួលខុសត្រូវសោះឡើយ ។ ថ្វីបើប្លាតុងបាននិយាយល្អពីសូក្រាតយ៉ាងណាក្ដី, នៅក្នុងកិច្ចពិភាក្សារបស់ទស្សនវិទូម្នាក់នេះដែលសមទំនងនឹងរបៀបគរុវិជ្ជាដេញដោលគ្នាកាលសម័យនោះ, ពុំមែនបានន័យថាសំណេររបស់ប្លាតុងទាក់ទងនឹងសូក្រាតទាំងអស់នោះ បានលាតត្រដាងមនោសញ្ចេតនាពិតប្រា-

កដំរបស់សូក្រាតនោះឡើយ ពីព្រោះមានម្តងទស្សនវិទូក្រោយនេះកាលពីសម័យដែលគាត់នៅរស់.. បន្ទាប់ពីបានអានកិច្ចពិភាក្សាមួយនិពន្ធដោយប្លាតុង មានចំណងជើងថា ៖ « លីស៊ីស, អំពីមិត្តភាព » , គាត់បានស្រែក ដង្ហោយទៅលើផ្ទៃមេឃថា

« ឱ! ព្រះជាម្ចាស់ដ៏មានបារមីអើយ ! ... យុវជនម្នាក់នេះចេះតែនិយាយជំនួសខ្ញុំ... ខ្ញុំមិនដែលបានគិតពីរឿងទាំងនេះផង » ...។

○

ក្បួនសិល្បៈនិពន្ធរបស់ប្លាតុង, បើយោងតាមការកត់សំគាល់របស់អារីសតូត ដែលត្រូវជាសាវ័ករបស់គាត់, មានកំពស់កំពរដែលឋិតនៅត្រង់ចន្លោះសិល្បៈកំណាព្យ និងការសរសេររបៀបសំរាយ។ សីសេរុងបានឃើញទឹកដៃដ៏ខ្ពង់ខ្ពស់អស្ចារ្យរបស់ប្លាតុង ក៏គ្មានការលំបាកអ្វីសោះ ក្នុងការអះអាងថា ប្រសិនបើព្រះយូពីទើរបានសម្រេចប្រើប្រាស់ភាសារបស់មនុស្ស... នោះទ្រង់នឹងសរសេរឬនិយាយស្តីរបៀបគ្នានឹងប្លាតុង ។

ប៉ានេសីយុសមានទម្លាប់ហៅប្លាតុង ថាជាអូមែរ នៃទស្សនវិទូ ( Homère ៖ អ្នកកវីនៃជនជាតិក្រិកដ៏ល្បីល្បាញជាងគេ ) ។ ម្ល៉ោះហើយយោបល់បែបនេះក៏ស្របគ្នាជាមួយនឹងការយល់ឃើញរបស់កាំងទីលីយ៉ាងដែលបានបញ្ជាក់ថាប្លាតុងមានទេព្យកោសល្យខាងសំនួនវោហាប្រហែលគ្នានឹងទេព្តាផង និងអូមែរផងដែរ ។ ទ្រឹស្តីរបស់ប្លាតុងត្រូវបានប្រគុំឡើងដោយដកស្រង់ចេញពីគំនិតរបស់ទស្សនវិទូបីនាក់ ។ គាត់មានជំនឿតាមអេរ៉ាគ្លីត ក្នុងរឿងអ្វីៗដែលទាក់ទងនឹងរូបវិទ្យា ( Physique ) និងអ្វីៗដែលឋិតនៅក្រោមការដឹកនាំរបស់គ្រឿងវិញ្ញាណ ។ គាត់គោរពតាមពីតាគ័រក្នុងទ្រឹស្តីបរម័ត្ថវិជ្ជា ( បរម+អត្ថៈ+ វិជ្ជា = Métaphysique ) ...។ ចំពោះអ្វីៗដែលទាក់ទងនឹងនយោបាយហើយនឹងសីលធ៌ម, ប្លាតុងបានទុកសូក្រាតនៅកំពូលលើគេទាំងអស់...ហើយសម្របសម្រួលតាមទ្រិស្តីរបស់សូក្រាតទាំងស្រុង ។

យោងតាមសំណេររបស់ប្លូតារគ, នៅក្នុងសៀវភៅទី១ នៃផែនគំនិតរបស់ទស្សនវិទូរ, ជំពូកទី៣ប្លាតុងបានទទួលស្គាល់គោលជំហរបីយ៉ាងនៃសេចក្តីពិត ៖ ព្រះ, វត្ថុធាតុ ហើយនិងគំនិត ។ ព្រះ គឺជាបញ្ញាញាណទូទៅនៅក្នុងចក្រវាល; វត្ថុធាតុគឺធាតុដើម ដែលអនុញ្ញាត្តឲ្យមានកំណើត និងសេចក្តីពុករលួយ ( សេចក្តីស្លាប់ ) ; គំនិតគឺវត្ថុអរូបិយ ឬធាតុឥតរូប ដែលមាននៅក្នុងបញ្ញាញាណរបស់ព្រះ ។ ប្លាតុង, តាមដោយពិត, បានទទួលស្គាល់ថាពិភពលោកជាស្នាដៃដែលព្រះបានបង្កើតឡើង ក៏ប៉ុន្តែគាត់បានសន្មត់ថាការបង្កើតនេះ ពុំមែនជាការបង្កើតលោកដោយពិតប្រាកដ

នោះទេ ៖ ពីព្រោះគាត់បានយល់ថាព្រះអាទិទេពគ្រាន់តែបានសាងសង់តែប៉ុណ្ណោះទៅលើវត្ថុធាតុដើមដែលមានមករួចស្រេចគ្រប់កាល ឬមិនដឹងជាពីកាលណាមកផងទេ ។ ម្ល៉ោះហើយតាមយោបល់របស់ប្លាតុង, ព្រះជាម្ចាស់ដែលបានបង្កើតភពផែនដីនេះ... គឺគ្រាន់តែបានត្រួសត្រាយបំបាត់សភាពអានាធិបតេយ្យ, ដោយបានផ្តល់រូបរាងទៅដល់វត្ថុធាតុដើមដែលមានទៅនោះស្រាប់, ដូចជាស្ថាបត្យករនិងជាងសំណង់, ដែលកាត់ឬចាំងជុំថ្មដើម្បីផ្តល់រូបរាងឲ្យគេហដ្ឋានដូច្នោះដែរ ។

អ្នកខ្លះបានយល់ថា ប្លាតុងច្បាស់ជាបានជួបព្រះពិត, តាមខ្សែរយៈនៃបញ្ញាញាណរបស់គាត់, ឬដោយសារតែគាត់បានអានសៀវភៅរបស់ពួកអេប្រឺ ( អ៊ីស្រាអែល ) ។ ក៏ប៉ុន្តែគេគួរទទួលស្គាល់ថាប្លាតុងបានឋិតនៅក្នុងចំណោមនៃពួកមនុស្ស ដែលសាំង-ប៉ូល ( Saint - Paul ) បានរាប់ថាបានស្គាល់ព្រះរួចស្រេចក៏ពិតមែន ក៏ប៉ុន្តែមិនបានលើកតម្កើងទ្រង់ពិតប្រាកដ, បែរជាវង្វេងវិលវល់នៅក្នុងអំនួតនៃមនោសញ្ចេតនារបស់ខ្លួនឯងទៅវិញ ។ តាមដោយពិត, នៅក្នុងសំណេរ Epinomis របស់គាត់, ប្លាតុងបានចែកវណ្ណៈព្រះជាបីសណ្ឋាន ៖ ព្រះជាន់ខ្ពស់, ព្រះធុនទាប និងព្រះថ្នាក់កណ្តាល។ ព្រះជាន់ខ្ពស់, បើយោងតាមប្លាតុង, ជាពួកព្រះដែលរស់នៅក្នុងផ្ទៃមេឃខ្ពស់ឆ្ងាយសែនសល់ពីលើក្បាលមនុស្ស... ជាព្រះដ៏ឧត្តុង្គឧត្តម ដោយសារតែទ្រង់មានលក្ខណៈ អស្ចារ្យ និងទីកន្លែងល្អប្រសើរដែលទ្រង់គង់នៅ, ចំណែកពពួកមនុស្សលោកវិញអាចទាក់ទងនឹងព្រះឋានលើទាំងនេះ ដោយសារតែខ្សែរយៈនៃព្រះថ្នាក់កណ្តាលដែលរស់នៅក្នុងខ្យល់ហើយ ដែលអ្នកផងហៅថាព្រាយបិសាច ។ ព្រះជាន់ក្រោយនេះសម្រាប់មនុស្សលោកក៏ហាក់ដូចជារដ្ឋមន្ត្រីរបស់ព្រះជាន់ខ្ពស់។ ព្រះធុនកណ្តាលនេះ នាំយកបញ្ជារពីខាងលើមកឲ្យមនុស្ស ..ហើយនាំយកដង្វាយនិងការបន់ស្រន់របស់មនុស្សទៅថ្វាយព្រះខាងលើវិញ ។ ព្រះនិមួយៗគ្រប់គ្រងពិភពលោកទៅតាមក្រសួងរបស់ខ្លួន, ជាប្រធាននៃពាក្យទំនាយនិងការត្រាស់ដឹង (ទ្រង់ញាណ) , ជាអ្នកតុបតែងឲ្យមានអព្ភូតហេតុគ្រប់យ៉ាង និងអំពើអស្ចារ្យដែលកើតឡើងនៅលើផែនដី ។ គេអាចសន្និដ្ឋានបានថា ប្លាតុងទំនងដូចជាបានស្រមៃអំពីលក្ខណៈរបស់ព្រះធុនកណ្តាលនេះ... ដោយបានដកស្រង់យកគំនិតអំពីរឿងទេព្តាដែលមានសរសេរនៅក្នុងគម្ពីរ (សញ្ញាចាស់ ), ដែលទំនងដូចជាគាត់ធ្លាប់បានអានដឹងរឿងខ្លះៗជាមុន ។ គាត់បានអនុម័តថាមានជំពូកព្រះទីបី... ដែលនៅក្រោមជាន់ថ្នាក់នៃព្រះជំពូកទី២ ៖ គាត់បានចាត់ទុកថាព្រះជំពូកក្រោយនេះបានរស់នៅតែតាមទឹកស្ទឹង,ទន្លេបឹងបួរ...។ តាមយោបល់ប្លាតុង, គឺជាពួកអារក្សអ្នកតាដែលមានលក្ខណៈត្រឹមតែជាព្រះពាក់កណ្តាលតែប៉ុណ្ណោះ ដែលមានតេជៈអាចផ្តល់សុបិន្តចំពោះមនុស្សលោក... ហើយដែលអាចបង្កើតហេតុភេទអស្ចារ្យជាច្រើនទៀតដូចជា

ព្រះធុនកណ្តាលផងដែរ ។ គាត់ថែមទាំងបានអះអាងទៀតថា... នៅក្នុងធាតុទឹក-ដី-ភ្លើងខ្យល់... និងនៅគ្រប់ទីឋាននៃផែនដីនេះ...តែងតែមានព្រះពាក់កណ្តាលសំណាក់នៅពាសពេញ, ជួនកាលក៏ឲ្យពួកយើង (មនុស្ស) មើលឃើញទៅ ... ជួនកាលក៏គេចទៅបាត់មិនឲ្យពួកយើងឃើញសោះឡើយ ។ គឺទំនងជាដូច្នេះហើយបានជាមានបញ្ជាក់អំពីអ្នកតាទឹក, អ្នកតាខ្យល់, ពួកអាបធ្មប់, ពួកម្រេញគង្វាល ដែលមាននិទាននៅក្នុងកាបាល ( ច្បាប់តម្រាជំនាន់ដើមបំផុតរបស់អ៊ីស្រាអែល )។

○

ប្លាតុងបានបង្ហាត់បង្រៀនអំពីវិជ្ជានៃការចាប់ជាតិកំណើត (La Métempsychose) ដែលគាត់បានដកស្រង់យកពី ពីតាគ្គរ... ហើយដែលគាត់បានយកទៅក្រឡៃតាមបែបបទរបស់គាត់, ដូចដែលគេបានអាននៅក្នុងសៀវភៅកិច្ចភិភាក្សារបស់គាត់ដែលមានចំណងជើងថា ហ្វែដ្រ, ហ្វេដុង, ទីម៉េ...និងសៀវភៅដទៃៗផ្សេងទៀត ។ ថ្វីបើប្លាតុងបាននិពន្ធអត្ថបទនៃកិច្ចភិភាក្សាមួយដ៏ល្អប្រណិតទាក់ទងនឹងសភាពអមតៈនៃដួងព្រលឹង ក៏ប៉ុន្តែគាត់មានការភ័ន្តច្រឡំដ៏ធ្ងន់ធ្ងរអំពីរឿងនេះ។ ទី១-ទាក់ទងនឹងដួងព្រលឹង, គាត់បានយល់ថារបស់នេះមានប្រគុំជាពីរចំណែក, មួយចំណែកមានធាតុជាអាត្មន មួយផ្នែកទៀតមានធាតុជារូបកាយ ។ ទី២-ទាក់ទងនឹងដើមកំណើតនៃព្រលឹងដដែល, គាត់បានអះអាងថារបស់នេះ តែងកើតមានមុនរូបកាយ ...គឺជាឥន្ទ្រីយ៍អារម្មណ៍ដែលច្យុតពីលើមេឃដើម្បីផ្តល់ជីវិតដល់រូបកាយ... ម្ល៉ោះហើយរបស់នេះតែងតែវិលត្រឡប់ទៅលើមេឃវិញនៅពេលណាដែលរបស់នេះបានប្រែក្លាយទៅជាធាតុបរិសុទ្ធឡើងវិញ ( លាងចេញអស់ពីគ្រឿងមិនបរិសុទ្ធនៃរូបកាយ ) ។ ដូច្នេះហើយ បានជានៅក្នុងរយៈពេលជាច្រើនឆ្នាំ ដួងព្រលឹងបានត្រូវប្រើប្រាស់ដើម្បីផ្តល់ជីវិតដល់រូបកាយផ្សេងៗជាបន្តបន្ទាប់គ្នា... ដូច្នេះទៅ គឺជាដំណើរវិលវល់មិនចេះចប់មិនចេះហើយ ( កកន ៖ គឺជាទ្រឹស្តីដកស្រង់ចេញពីពុទ្ធនិយម ) ... ពីភាពប្រឡាក់ប្រឡូសទៅសភាពបរិសុទ្ធ, ពីសភាពបរិសុទ្ធទៅសភាពប្រឡាក់ប្រឡូស... ពីផែនដីមកផ្ទៃមេឃ និងពីផ្ទៃមេឃមកផែនដីសារជាថ្មីដើម្បីចូលមកសណ្ឋិតនៅក្នុងរូបកាយថ្មីស្រឡាងមួយទៀតដែលគេផ្តល់ជីវិតនិងសកម្មភាព ។ ដោយគាត់បានយល់ថាដួងព្រលឹងទាំងនេះពុំបានភ្លេចនូវអ្វីៗទាំងប៉ុន្មានដែលជាជីវិតពិសោធន៍នៅក្នុងរូបកាយផ្សេងៗដែលគេធ្លាប់បានសណ្ឋិតរួចមកហើយ, ប្លាតុងក៏បានអះអាងថាចំណេះដឹងដែលដួងព្រលឹងបានប្រមែប្រមូលទាំងនេះ ពុំមែនជាចំណេះដឹងថ្មី

ថ្ងៃនោះទេ...ក៏ប៉ុន្តែជាការនឹករឭកឃើញដោយស្រពេចស្រពិល Réminiscences អំពីរឿងចាស់នៅក្នុងជីវិតអតីតតែប៉ុណ្ណោះឯង ។ ម៉្លោះហើយដោយសារតែការចាំជាតិកំណើតទាំងនេះ ប្លាតុងក៏បានអះអាងថា ... ដួងព្រលឹងតែងតែមានកំណើតមុនរូបកាយ ...។

ក៏ប៉ុន្តែដោយមិនបាច់លាតសន្ធឹងវែងឆ្ងាយ ទៅលើទ្រឹស្តីរបស់ទស្សនវិទូម្នាក់នេះ ទោះជាយ៉ាងណាក្តីគាត់បានអធិប្បាយរៀបរាប់អំពីរឿងចាំជាតិនេះដោយត្រួសៗតែប៉ុណ្ណោះ, អ្នកផងអាចបញ្ជាក់ថាគំនិតរបស់គាត់ ... ទាក់ទងនឹងចំណុចផ្សេងៗដទៃទៀត មានលក្ខណះថ្មីទំនើបនិងខ្ពង់ខ្ពស់មែនទែន... រហូតដល់គេបានចាត់ទុកថាទេពកោសល្យរបស់គាត់គឺជានិស្ស័យរបស់ព្រះសុទ្ធសាធ។ ម៉្លោះហើយនៅពេលដែលគាត់បានស្លាប់ទៅ អ្នកផងបានគោរពរូបគាត់សឹងតែស្មើនឹងព្រះមួយអង្គដែលបានច្យុតចុះពីលើផ្ទៃមេឃមកដូច្នោះដែរ ។

ប្លាតុងបានទទួលមរណៈភាព នៅឆ្នាំទី១ នៃអូឡាំព្យ៉ាដទី១០៨, នៅក្នុងអាយុ ៨១ ឆ្នាំ ... នៅចំថ្ងៃដដែលដូចគ្នានឹងថ្ងៃកំណើតរបស់គាត់ ។៚

# ជីវិតពៀរ៉ុង
# PYRRHON

*– បានរស់នៅក្នុងជំនាន់សម័យមុនទស្សនវិទូរអេពីគួរបន្តិច នៅក្នុងអូឡាំព្យ៉ាដទី-១២០

ជាបុគ្គលដែលបានបង្កើតក្រុមបក្សមួយហៅថា ៖ បក្សពៀរ៉ូនីញ៉ាង ឬ ពួកសិបទីក ( គឺជាពួកជនសង្ស័យទៅលើការពិតគ្រប់យ៉ាង ) ។ គាត់ត្រូវជាកូនប្រុសរបស់បូរីជនម្នាក់ (ពលរដ្ឋនៃទីក្រុងស្រុកក្រិក) ឈ្មោះព្លីសតាកនៅក្នុងទីក្រុងអេឡេក្នុងដំបន់ប៉េឡូប៉ូណែស ។ មុនដំបូងគាត់បានខំប្រឹងរៀនគំនូរផាត់ពណ៌ ។ បន្ទាប់មកគាត់ក៏បានក្លាយទៅជាសាវ័ករបស់ ឌ្រីសុង ហើយផុតពីនោះមកទៀតរបស់ទស្សនវិទូរអាណាសាគុស ។ ពៀរ៉ុងបានជាប់ចិត្តស្រឡាញ់លោកគ្រូចុងក្រោយនេះខ្លាំងពេកណាស់... រហូតតាមគាត់ដល់ស្រុកឥណ្ឌា ។ នៅក្នុងឱកាសនៃដំណើរវែងឆ្ងាយនេះ ពៀរ៉ុងបានឆ្លៀតឱកាស ធ្វើការពិភាក្សាជាមួយពួកម៉ាឃី ( **Mages** ...ពួកក្រុមបក្សសេគមន្តអាគម ៖ ម៉ាឃី-មាយា ) , ជាមួយពួកឃីមណូ-សូហ្វីស្ត( **Les Gymnosophistes** ៖ ពួកឥសីស្រុកក្លីង្គ... ឥតមានស្លៀកពាក់ខោអាវហើយធ្វើពលិកម្ម នៅលើសេរីរាងកាយ ), ព្រមទាំងជាមួយពួកទស្សនវិទូទាំងអស់នៅពិភពខាងកើត ។ បន្ទាប់ពីបានប្រមែប្រមូលមតិរបស់អ្នកប្រាជ្ញអស់ទាំងនេះគ្រប់ៗគ្នាយកមកធ្វើការសិក្សាវែកញែកដល់ទីជម្រៅ, ពៀរ៉ុងក៏ពុំបានរកឃើញការពិតអ្វីសោះដែលអាចធ្វើឲ្យគាត់មានការស្កប់ស្កល់ក្នុងចិត្ត ។ គឺហាក់ដូចជាទស្សនៈឬទ្រិស្តីទាំងអស់នេះមានរចនាសម្ពន្ធស្មុគ្រស្មាញក្រៃពេក ដែលមិនអាចឲ្យគាត់រមិលយល់បាន ។ គឺហាក់ដូចជាការពិតនៃអ្វីៗទាំងអស់នៅលើភពផែនដីនេះបិតនៅឯបាតដាលដ៏មហាសែនជ្រៅ... ហើយអំពើសមរម្យដែលគាត់មានលទ្ធភាពអាចធ្វើបាន គឺមានតែការសង្ស័យទៅលើអ្វីៗទាំងអស់..។ ម្ល៉ោះ ហើយគាត់ក៏ពុំបានសម្រេចធ្វើអ្វីទាំងអស់ផងដែរ ។

គាត់បានពោលថា មនុស្សយើងមានអាកប្បកិរិយានិងទម្លាប់គំនិតរស់នៅស្របតែតាមគេនិយាយប៉ុណ្ណោះ, ម្នាក់ៗធ្វើអ្វីៗតែតាមទម្លាប់ , ម្នាក់ៗមើលឃើញតែច្បាប់និងទំនៀមទម្លាប់របស់ស្រុកខ្លួនឯង ...ក៏ប៉ុន្តែមិនដែលដឹងថាច្បាប់ឬ

ទំនៀម ទម្លាប់នោះត្រូវឬក៏ខុស...ល្អឬក៏អាក្រក់នោះទេ ។

កាលពីដើមដំបូង ពៀរ៉ុងជាជនអ្នកក្រីក្រម្នាក់ ដែលពុំសូវមាននរណាស្គាល់ទេ។ គាត់ប្រកបតែមុខរបរជាជាងគំនូរផាត់ពណ៌តែប៉ុណ្ណោះ , ហើយគេបានរក្សាទុកនៅទីក្រុងអេឡេនូវស្នាដៃរបស់គាត់ ដែលបង្ហាញឲ្យឃើញថាគាត់ជាអ្នកមានទេពកោសល្យពិតប្រាកដក្នុងវិជ្ជាជីវៈនេះ ។ គាត់រស់នៅក្នុងសេចក្ដីស្ងៀមស្ងាត់តែឯកឯងក្នុងទីរហោដ្ឋាន, ហើយមិនដែលបានទៅចូលរួមប្រជុំជាមួយក្រុមណាទេ។ គាត់បានធ្វើដំណើរជាញឹកញាប់ ដោយមិនដែលបានប្រាប់នរណាម្នាក់អំពីទីកន្លែងដែលគាត់ទៅ ។ អ្វីៗក៏គាត់ទ្រាំបានទាំងអស់នៅក្នុងជីវិតនេះដោយគាត់មិនដែលបានពោលនូវពាក្យត្អូញត្អែ ឬសំដែងនូវការពិបាកចិត្តអ្វីទាំងអស់ ។ គាត់លែងជឿបញ្ញានិងវិញ្ញាណរបស់ខ្លួនគាត់ផ្ទាល់ រហូតដល់គាត់លែងរវីរវល់នឹងដើរចៀសឧបសគ្គទាំងឡាយ, បើទោះជាជុំថ្មក្ដី, ទឹកជ្រោះក្ដី, ឬក៏គ្រោះថ្នាក់ផ្សេងៗទៀតក្ដី ។ គាត់សុខចិត្តឲ្យរទេះដែលគាត់បានជួបប្រទះបរមកកិនរូបគាត់ជាជាងគាត់ដើរងាកចេញ ៖ វាមានមិត្តភក្ដិរបស់គាត់មួយចំនួនដែលតែងដើរតាមឃ្លាំមើលរូបគាត់ហើយនៅក្នុងកាលៈទេសៈខ្លះក៏បានជួសង្គ្រោះគាត់ដោយទាញគាត់ឲ្យចៀសចេញពីគ្រោះកាចផ្សេងៗ ។ គាត់គ្មានចិត្តស្ញើបរំភើបនឹងអ្វីៗទាំងអស់ គាត់ស្លៀកពាក់តែខោអាវមួយម៉ាកដដែលៗ ។ នៅពេលដែលគាត់និយាយស្ដីអធិប្បាយអំពីរឿងអ្វីមួយឲ្យគេស្ដាប់, បើទោះជាជនអ្នកស្ដាប់ដើរចាកចេញទៅបាត់ដោយប្រការណាមួយក្ដី ហើយបានទុករូបគាត់ឲ្យនៅតែម្នាក់ឯងក្ដី, ក៏គាត់នៅតែពោលម្នាក់ឯងតទៅទៀត រហូតដល់ចប់ចុងចប់ដើមនៃសេចក្ដីសុន្ទរកថារបស់គាត់ ។ ពោលគឺគាត់មានអាកប្បកិរិយាដដែលដូចគ្នាស្មើដើមចុង នៅពេលដែលមានមនុស្សស្ដាប់ ...ឬក៏គ្មានមនុស្សស្ដាប់ ។ ឫកពាររបស់គាត់គឺគ្មានកង្វល់ខ្វល់ខ្វាយជាមួយមនុស្សគ្រប់ៗគ្នា, ចំពោះនរណាក៏ដូចនរណា ។

កេរ្ដិ៍ឈ្មោះរបស់ពៀរ៉ុងបានបែកខ្ញរខ្ញាយទូទាំងប្រទេសក្រិក ។ មានមនុស្សច្រើនគ្នាណាស់ដែលបានសម្រេចចូលក្នុងបក្សរបស់គាត់ ។ ប្រជាជននៅអេឡេបន្ទាប់ពីបានស្គាល់គុណសម្បត្តិនិងចរិយាធម៌របស់គាត់រួចហើយ ក៏មានសេចក្ដីកោតខ្លាចគោរពប្រណិបត្តិរូបគាត់ទុកគាត់ដូចជាព្រះមហាក្សត្រជាទីសក្ការៈបូជានៃសាសនារបស់ពួកគេ ។ ពួកអាត្ទែនបានលើកគាត់ជាបូរីជននៃទីក្រុងរបស់ពួកគេ ។ ទស្សនវិទូអេពីគួរ ចូលចិត្តជជែកពិភាក្សាជាមួយរូបគាត់ពន់ពេកណាស់, ហើយតែងនឹកស្ញើសរសើរមិនចេះដាច់អំពីរបៀបរបបដែលគាត់រស់នៅ ។ អ្នកផងគ្រប់គ្នាបានសង្កេតឃើញថាគាត់ជាមនុស្សមានសេរីភាពពិតប្រាកដមែន, ប្រាសចាកពីសេចក្ដីទុក្ខលំបាករបស់ជនសាមញ្ញ, ពីអំនួតហើយនិងជំនឿអកុសលផ្សេងៗ ។

នៅទីបំផុតលោកទស្សនវិទូវទីម៉ុងបានបញ្ជាក់ថា រូបគាត់បានត្រូវគេគោរពដូចជាព្រះមួយអង្គនៅលើភពផែនដីនេះ ៖ គាត់រស់នៅយ៉ាងស្ងៀមស្ងាត់ជាមួយប្អូនស្រីរបស់គាត់ឈ្មោះហ្វ៊ីល្លីសដែលមានមុខរបររកស៊ីធ្វើជាឆ្មប ។ គាត់តែងតែទៅផ្សារដោយខ្លួនឯងយកសត្វបក្សាបក្សីតូចៗនិងកូនជ្រូកទៅលក់ ។ គាត់តែងបោសសំអាតផ្ទះដោយផ្ទាល់ដៃពីខ្លួនឯង ។

ថ្ងៃមួយ, ឆ្កែមួយបានលោតកញ្ជ្រោងមកលើរូបគាត់បម្រុងខាំ ។ ពៀរ៉ុងក៏យកដៃរុញឆ្កែនេះចេញ ៖ ជនម្នាក់ក៏បាននិយាយចំអកដាក់គាត់ដោយសួរថា ៖ អំពើនេះវាមិនផ្ទុយនឹងទស្សនៈ របស់គាត់ទេឬ ? ។

– ឱ! មែន, គាត់ឆ្លើយតបវិញ, គឺជាការមួយលំបាកពន់ពេកណាស់ដែលគេត្រូវលះបង់ចោលទំនៀមទម្លាប់របស់ខ្លួនឯងទាំងស្រុង... ម្ល៉ោះហើយគេមានការលំបាកណាស់ក្នុងការយកមនុស្សម្នាក់ទៅប្រស្រោតខោអាវទាំងអស់ឲ្យអស់រលីងពីខ្លួន ។ ក៏ប៉ុន្តែក្នុងកិច្ចការនេះ, គេត្រូវប្រឹងប្រែងឲ្យពេញសមត្ថភាពតទៅទៀត... គេត្រូវប្រើកម្លាំងបញ្ញាទាំងអស់ដើម្បីទប់ទល់នឹងកម្លាំងទំនៀមទម្លាប់។

ក្នុងកាលៈទេសៈមួយទៀត ...នៅពេលដែលគាត់កំពុងតែជិះនាវាតូចមួយឆ្លងកាត់សមុទ្រក៏ស្រាប់តែមានខ្យល់ព្យុះបក់បោកមកយ៉ាងខ្លាំង ៖ នាវាដ៏តូចក៏មានសភាពឃ្លោងឃ្លោងរកកលនឹងលិច ។ ពួកមនុស្សដែលនៅជុំវិញគាត់ក៏មានការភិតភ័យតក់ស្លុតតក្កម្មា ។ ពៀរ៉ុងមានលក្ខណៈស្ងប់ស្ងៀមនៅកណ្តាលខ្យល់ព្យុះបោកបាចនេះ ... គាត់ក៏បានបង្ហាញឲ្យអ្នកឯទៀតឃើញអំពីកូនសត្វជ្រូកមួយដែលកំពុងបរិភោគយ៉ាងសប្បាយក្សេមក្សាន្ត ហាក់ដូចជានាវាបានចូលកំពង់ផែរួចទៅហើយ ។ ហើយគាត់ក៏បានពោលបន្ថែមថា អ្នកប្រាជ្ញគួរតែយកតម្រាប់តាមសត្វដ៏តូចនេះ, ពោលគេគួរតែមានលក្ខណៈស្ងៀមស្ងាត់នៅគ្រប់ពេលវេលានិងកាលៈទេសៈទាំងអស់ ។

ថ្ងៃមួយ, ពៀរ៉ុងបានកើតរោគឈឺក្រពះ (ចុកពោះ) ។ អ្នកដែលបានព្យាបាលរូបគាត់ក៏បានសម្រេចវិធានការណ៍ដ៏សាហាវ ...គឺវះនិងកាត់សាច់របស់គាត់ ។ គាត់នៅស្ងៀមធ្វើព្រងើយ ...មិនទាំងបានជ្រួញចិញ្ចើមបន្តិចផង ហាក់ដូចជាគ្មានបានទទួលការឈឺចាប់អ្វីទាំងអស់ ។ ទស្សនវិទូរូបនេះបានយល់ថាចំណេះដឹងដ៏ខ្ពង់ខ្ពស់បំផុតដែលគេរកបាននៅក្នុងលោកនេះ គឺការមិនព្រមសម្រេចថាធ្វើអ្វីទាំងអស់ ។ ពួកក្រុមសាវ័ករបស់គាត់ទាំងប៉ុន្មានបានសន្មត់ព្រមព្រៀងគ្នាក្នុងរឿងមួយ ៖ គឺគេមិនអាចដឹងបានទាល់តែសោះថាមានអ្វីដែលមានលក្ខណៈប្រាកដប្រជានោះឡើយ ។ ក៏ប៉ុន្តែមានពួកអ្នកខ្លះបានស្វះស្វែងរកការពិតដោយមាន

សេចក្តីសង្ឃឹមថានឹងរកឃើញពន្លឺនៅថ្ងៃណាមួយ... ចំណែកពួកអ្នកខ្លះទៀតគ្មានសេចក្តីសង្ឃឹមសោះឡើយថាថ្ងៃណាមួយគេនឹងបានទៅដល់ទីប្រាថ្នារបស់ពួកគេ។ ពួកអ្នកខ្លះទៀតថែមទាំងបាននិយាយថា គេអាចបញ្ជាក់បានពីអ្វីមួយដ៏ច្បាស់លាស់ ៖ គឺគេពុំមានចេះដឹងអ្វីទាំងអស់ ...អ្នកដែលនៅសល់ទាំងប៉ុន្មានមិនទាំងបានដឹងថាពួកគេជាមនុស្សល្ងង់ខ្លៅដែលគ្មានដឹងអ្វីទាំងអស់នោះផង ។ គំនិតបែបខាងលើនេះសុទ្ធសឹងតែមានកំណើតឃើញពន្លឺថ្ងៃមុនពៀរ៉ុងម្ល៉េះ ...ក៏ប៉ុន្តែដោយគ្មាននរណាម្នាក់មកទល់នឹងពេលនោះ ធ្លាប់ដែលមានមុខបររកស៊ីខាងសង្ស័យទៅលើរបស់គ្រប់សព្វសារពើ, គេក៏បានចាត់ទុកថាពៀរ៉ុងជាស្ថាបនិក និងជាមេកើយរបស់ក្រុមបក្សសិបទីកទាំងអស់ ។

មូលដ្ឋានគំនិតដ៏ធំបំផុតដែលទស្សនវិទូនេះយល់ថា គេគួរតែផ្អាកការវិនិច្ឆ័យរបស់ខ្លួន... គឺមកពីរូបយើងទាំងអស់គ្នាដឹងតែពីទំនាក់ទំនងរវាងវត្ថុសព្វយ៉ាងតែប៉ុណ្ណោះ, ក៏ប៉ុន្តែយើងមិនអាចដឹងបានពីផ្ទៃក្នុងនិងពីធម្មជាតិពិតប្រាកដនៃវត្ថុអស់ទាំងនេះឡើយ ( កកន ៖ ថ្ងៃក្រោយមក អ្នកប្រាជ្ញអាល្លឺមង្គ់ អេមានុយអែលកន្ទ ...បានយកទ្រិស្តីរបស់ពៀរ៉ុងទៅធ្វើការវែកញែកពិភាក្សានៅក្នុងសៀវភៅមួយដែលមានឈ្មោះថា **Critiques de la Raison pure** ...នៅក្នុងនោះ **Emmanuel Kant** បានអធិប្បាយថា ... យើងបានដឹងពីពិភពលោកនេះត្រឹមតែសំបកក្រៅតែប៉ុណ្ណោះ **Le pour-soi** ...ក៏ប៉ុន្តែយើងមិនបានដឹងពីអ្វីៗពិតប្រាកដដែលនៅពីខាងក្នុងវត្ថុ ទាំងអស់នេះទេ...:**L'En-soi** ។

ស្លឹកសូល ( ស្លឹកព្រៃនៅស្រុកក្រិក) ជាឧទាហរណ៍ មានរសជាតិឆ្ងាញ់សម្រាប់សត្វពពែ ប៉ុន្តែមានជាតិល្វីងជូរចត់សម្រាប់មនុស្ស ។ ផ្លែស្លែងជាចំណីដែលធ្វើឲ្យសត្វគ្រួចធំធាត់ ក៏ប៉ុន្តែជាថ្នាំពុលដែលបណ្តាលឲ្យមនុស្សស្លាប់។ ដេម៉ូហ្វុងដែលជាអ្នករៀបចំបាយទឹកឲ្យស្តេចអាឡេចសង់, មានអាការៈក្តៅអន្ទះអន្ទែង, ដូចគេយកភ្លើងមកដុតកាលណានៅក្នុងទីម្លប់ ...ក៏ប៉ុន្តែនៅហាលថ្ងៃវិញបែរជាមានសភាពត្រជាក់ស្រេងក្នុងខ្លួនគាត់, ដូចទឹកកក ។ អង់ត្រុង-ដារកុសអាចដើរឆ្លងកាត់វាលខ្សាច់នៅប្រទេសលីប៊ី បានយ៉ាងស្រួលដោយមិនមានការចាំបាច់ត្រូវផឹកទឹកអ្វីទាំងអស់ ។

អ្វីៗដែលត្រឹមត្រូវក្នុងប្រទេសមួយ ក្លាយជារឿងអយុត្តិធ៌មក្នុងប្រទេសមួយទៀត ។ ហើយនៅក្នុងប្រការដូចគ្នានេះ អ្វីដែលជាគុណធ៌មនៅក្នុងប្រទេសខ្លះក៏បានក្លាយទៅជារឿងអបាយមុខនៅប្រទេសផ្សេង ( កកន ៖ អ្នកនិពន្ធបារាំង, **Montaigne**, បន្ទាប់មកទៀត **Pascal** បានយកទ្រិស្តីរបស់អេពីគួរនេះទៅពង្រីកដោយនិយាយដូច្នេះថា ៖ « ឱ!យុត្តិធ៌មដ៏គួរឲ្យអស់សំណើចដែលមានស្ទឹង

មួយខណ្ឌផ្លូវ។ សេចក្តីពិតដែលនៅខាងម្ខាងនៃភ្នំពៀរ៉េណេ ... ក្លាយទៅជាសេចក្តីមិនពិតនៅខាងម្ខាងទៀត – **Plaisante justice qu'une rivière borne. Vérités en deça des Pyrénées, erreurs au-delà** ») ។ នៅក្នុងប្រទេសពែរ្ស ឪពុកអាចរៀបការជាមួយ កូនស្រីរបស់ខ្លួនឯងបាន ក៏ប៉ុន្តែនៅក្នុងប្រទេសក្រិកគឺជាឧក្រិដ្ឋកម្មមួយដ៏ធ្ងន់ធ្ងរនិងអាក្រក់អាក្រីខ្លាំងណាស់ ។ ពួកម៉ាស្សាយែត ( **Massagettes** )មិនបានទទួលស្គាល់នូវឯកភាព ឬសភាពលក្ខណ:សក្ការបូជានៃអពាហ៍ពិពាហ៍នោះឡើយ ( ទស្សន:ដែលយល់ថាអាពាហពិពាហ៍ជាចំណងដៃរបស់ព្រះ ...គឺព្រះបានចងផ្តោបគ្នា មនុស្សប្រុសហើយនិងមនុស្សស្រីឲ្យទៅជាមនុស្សតែមួយ ) , ចំណែកប្រទេសដទៃផ្សេងទៀតទាំងអស់ប្រឆាំងនឹងទស្សនៈរបស់ពួកម៉ាស្សាយែត ។ ការលួចទ្រព្យសម្បត្តិអ្នកដទៃជាអំពើល្អ ដែលគួរបានបុណ្យបានទាន ឬគួរឲ្យកោតសរសើរនៅប្រទេសស៊ីលីស៊ី...ក៏ប៉ុន្តែនៅប្រទេសក្រិកគឺជាអំពើអាក្រក់មួយដែលត្រូវគេផ្តន្ទារ ។ អារីសទីពមានមតិយោបល់មួយបែបទៅស្តីអំពីសុភមង្គល ... ចំណែកអង់តីសតែនមានទស្សនៈមួយបែបផ្សេងក្នុងរឿងដដែលនេះ, ចំណែកអេពីគួរមានទ្រិស្តីមួយផ្សេងទៀត ឃ្លាតពីការយល់ឃើញរបស់អ្នកទាំងពីរខាងលើ។ ពួកអ្នកខ្លះមានជំនឿទៅលើព្រហ្មលិខិត, ពួកអ្នកខ្លះទៀតបានបដិសេធមិនព្រមជឿវាសនាកម្ម ។ ពួកជនជាតិអេឃីពតែងកប់ខ្មោចរបស់ពួកខ្លួន ចំណែកពួកឥណ្ឌាតែងតែយកសពទៅដុត, រីឯពួកប៉េអូនីវិញតែងយកខ្មោចទៅគ្រវែងចោលនៅកណ្តាលបឹងតែម្តង ។ អ្វីដែលប៉ះនឹងពន្លឺព្រះអាទិត្យចេញព៌ណម្យ៉ាង ...ដល់ប៉ះពន្លឺព្រះច័ន្ទ្របែរជាចេញព៌ណសំបុរផ្សេង...នៅទីបំផុតដល់ចាំងនឹងពន្លឺភ្លើងទៀនក៏បញ្ចេញព៌ណមួយបែបផ្សេងទៀត ។ បំពង់កនៃសត្វព្រៀបអាចមានព៌ណសំបុរច្រើនយ៉ាង ស៊ីសងនឹងជ្រុងជ្រោយដែលគេសម្លឹងមើលមក ។ ស្រាក្រហមបើគេផឹកតែបន្តិចបន្តួចអាចជាជំនួយកម្លាំងដល់បេះដូង ...ក៏ប៉ុន្តែបើកាលណាគេផឹកច្រើនពេកវាអាចធ្វើឲ្យស្ពឹកខួរ ហើយបណ្តាល ឲ្យវង្វេងវង្វាន់វិញ្ញាណស្មារតី ។ អ្វីៗដែលនៅខាងស្តាំនៃរបស់មួយ, វាបែរជាទៅនៅខាងឆ្វេងនៃរបស់មួយទៀត ។ ប្រទេសក្រិកដែលនៅខាងកើតនៃប្រទេសអ៊ីតាលី វាទៅនៅខាងលិចនៃប្រទេសពែរ្ស ។ អ្វីៗដែលគេចាត់ទុកថាជាអព្ភូតហេតុដ៏អស្ចារ្យនៅក្នុងកន្លែងមួយ, គឺគ្រាន់តែជារឿងធម្មតាបំផុតនៅក្នុងកន្លែងផ្សេង ។ មនុស្សតែម្នាក់មានឋាន:ជាឥពុករបស់មនុស្សមួយចំនួន ហើយមានលក្ខណ:ត្រឹមជាបងប្អូនរបស់មនុស្សមួយចំនួនទៀត ។ នៅទីបំផុតសភាពប្រឆាំងផ្ទុយគ្នាតែងតែមានសណ្ឋិតនៅសព្វវត្ថុធាតុទាំងអស់ ជាហេតុញ៉ាំងឲ្យពៀរ៉ុងនិងក្រុមសាវ័ករបស់គាត់មិនអាចលទ្ធភាពផ្តល់និយមន័យចំពោះអ្វីៗទាំងអស់ ដោយពួកគេយល

ថាគ្មានអ្វីមួយនៅក្នុងលោកនេះដែលគេអាចដឹងបានអំពីលក្ខណៈរបស់វាផ្ទាល់ដោយមិនបានយកទៅប្រៀបធៀបនឹងវត្ថុមាននៃរបស់មួយទៀត ។ ដោយគេមិនអាចដឹងពីការពិតអំពីអ្វីៗទាំងអស់ ពួកក្រុមគេក៏បានហាមប្រាមមិនឲ្យមានការវិភាគសំដែងអធិប្បាយវែងឆ្ងាយ ...។ ពីព្រោះ នៅគ្រប់ការវិភាគវែកញែក, វាត្រូវមានការពឹងផ្អែកទៅលើមូលដ្ឋាននៃសេចក្ដីពិតទាំងស្រុងដ៏ច្បាស់លាស់ដែលមិនចាំបាច់ត្រូវការឲ្យមានភស្តុតាងអ្វីទាំងអស់។ ក៏ប៉ុន្តែ, នៅលើលោកនេះវាគ្មានអ្វីពិតទាំងស្រុងដែលមិនមានការចាំបាច់ក្នុងការស្វែងរកភស្តុតាងនោះទេ, ពីព្រោះកាលណា មានរឿងអ្វីមួយលេចឡើងដែលមានទំនងសមរម្យថាជាការពិត, យើងក៏ត្រូវមានកាតព្វកិច្ចត្រូវវិភាគសំដែងវែងឆ្ងាយ អំពីមូលដ្ឋាននៃសេចក្ដីពិតដែលបណ្ដាលឲ្យយើងជឿតាមបែបដូចនេះ ។

ពៀរ៉ុង, រួចបន្ទាប់មកទៀតគឺហ្វូមែរ ( អ្នកកវីនិពន្ធផ្នែកខាងសោកនាដកម្ម ក្រិក) បានប្រៀបធៀបមនុស្សយើងទៅនឹងស្លឹកឈើដែលដុះបន្តគ្នាជារៀងរហូត, ក្នុងដំណើរមួយដែលស្លឹកឈើថ្មីតែងទៅជំនួសស្លឹកឈើចាស់ៗដែលចាកមែក។ គាត់បានរស់នៅដោយបានទទួលសេចក្ដីគោរពកោតខ្លាចពីអ្នកផងជារៀងរហូត, តាំងពីពេលដែលគាត់មានកេរ្តិ៍ឈ្មោះល្បីកាលណាមក ។ គាត់បានទទួលមរណភាពនៅក្នុងអាយុ៩០ឆ្នាំ ៕

❑ ❑

❑

# ជីវិតពីតាគ្ករ
# PYTHAGORE

( កកន ៖ ន័យដើមនៃឈ្មោះ « ពីតាគ្ករ » គឺ « ថ្មគិរី » ឬ « បិតាគិរី » ។ Old Persian : Pitar; Sanskrit : pitar; Greek : Pytha, Pater; Latin : pater; German : Vater; French : père; English : father, peter... )

បានចំរើនលូតលាស់នៅអូឡាំព្យ៉ាដទី៦០ ។ បានមករស់នៅស្រុកអ៊ីតាលី នៅអូឡាព្យ៉ាដទី៦២, ទទួលមរណភាពនៅឆ្នាំទី៤ នៃអូឡាំព្យ៉ាដទី៧០ ក្នុងជន្មាយុ៨០ ឬបើតាមសំដីអ្នកខ្លះទៀត ក្នុងអាយុ៩០ឆ្នាំ ។

*　　　　*

*

វាមានការបែងចែកមែកធាងយ៉ាងល្បីល្បាញផ្នែកខាងទស្សនវិជ្ជា, ម្ខាងជាពួកយ៉ូនីច ( យោនី )... មួយផ្នែកទៀតខាងពួកអ៊ីតាលិច ( អ៊ីតាលី ) ។ ត្វាលែសនៅមីឡេត៍ ជាពួកមេក្រុមដឹកនាំខាងយ៉ូនិច ចំណែកពីតាគ្ករខាងពួកអ៊ីតាលិច ។

អារីសទីពនៃក្រុមស៊ីរេណាអ៊ិចបានពោលថា ៖ ហេតុដែលគេដាក់ឈ្មោះទស្សនវិទូម្នាក់នេះថាជា « ពីតាគ្ករ » គឺមកពីសំដីសំដៅរបស់គាត់ទាំងប៉ុន្មាន ចេញមកពីក្រអូមមាត់ពេលណា តែងតែមានលក្ខណៈពិតប្រាកដ ប្រហែលគ្នានឹងការទស្សន៍ទាយរបស់ព្រះអាប៉ូឡុង-ពីធាន ។

គឺគាត់នេះហើយមុនគេទាំងអស់ ដែលមានចិត្តសុភាពរាបសារ មិនព្រមទទួលឋានៈជាអ្នកប្រាជ្ញ គ្រាន់តែទទួលឋានៈជាទស្សនវិទូប៉ុណ្ណោះ ។

តាមយោបល់អ្នកផង គេថាពីតាគ្ករមកពីស្រុកសាម៉ូស, ជាកូនប្រុសរបស់មនេសាក ដែលជាជាងចម្លាក់មួយរូប... ។ ថ្វីបើមានអ្នកខ្លះទៀតពោលថា គាត់ជាជនជាតិតុសកាន ហើយគាត់មានកំណើតនៅក្នុងកោះតូចមួយ ដែលពួកអ្នកក្រុងអាត្វែនតណ្តើមយកបាននៅក្នុងសមុទ្រធីរ៉ែន ។

ពីតាគ្ករ បានសិក្សាមុខរបរវិជ្ជាជីវៈរបស់ឪពុកខ្លួនយ៉ាងស្ទាត់ជំនាញ ។ គាត់បានសិតពែងប្រាក់ដោយដៃរបស់គាត់ផ្ទាល់ចំនួនបី រួចគាត់យកទៅប្រគេនព្រះសង្ឃជា

តិអេយីព្ទបីអង្គ ។ មុនដំបូង គាត់ត្រូវជាសាវ័ករបស់អ្នកប្រាជ្ញ ផេរេស៊ីដ ដែលគាត់បានគោរពប្រណិបតន៍យ៉ាងស្និតស្នាញ ។ ថ្ងៃមួយ, ពេលដែលផេរាស៊ីដមានជម្ងឺជាទម្ងន់ ដែលធ្វើឲ្យគាត់នឹកស្មានថា គាត់កំពុងរៀបចំស្លាប់, ពីតាគ្គរក៏ដើរតម្រង់ចូលក្នុងបន្ទប់របស់គាត់ ក្នុងគោលបំណងសួរសួរសុខទុក្ខអាការរោគរបស់លោកគ្រូ ។ ប៉ុន្តែផេរាស៊ីដ ដែលមានអារម្មណ៍ថា ជម្ងឺរបស់គាត់ជាជម្ងឺឆ្លង ក៏បានបិទទ្វារយ៉ាងប្រញាប់ព្រមទាំងបានស៊កម្រាមដៃមួយតាមប្រឡោះទ្វារផង ៖ « មើលនែ៎ ! គាត់ពោល, មើលម្រាមដៃរបស់អញឯណោះ ! ឯងឃើញទេ វារលាត់ស្បែកអស់រលីងហើយ... ចំណែករូបកាយរបស់អញក៏វាអីចឹងដែរ ! » ។

បន្ទាប់ពីផេរាស៊ីដបានទទួលមរណភាពទៅ, ពីតាគ្គរក៏បានធ្វើការសិក្សាអស់មួយរយៈពេលនៅសាម៉ូស ក្រោមការដឹកនាំរបស់ហែរម៉ូដាម៉ង់តេ ។ បន្ទាប់មកគាត់ក៏មានកើតចំណង់យ៉ាងខ្លាំងក្លា ដើម្បីរៀនសូត្រឲ្យបានវែងឆ្ងាយ និងក្រេបយកចំណេះវិជ្ជាអំពីទំនៀមទំលាប់បរទេស ។ គាត់ក៏បានបោះបង់ចោលស្រុកទេសរបស់គាត់ និងរបស់របរដែលគាត់មានទាំងប៉ុន្មាន ដើម្បីចំណាយក្នុងការធ្វើដំណើរ ។ គាត់បានទៅរស់នៅ ក្នុងរយៈពេលយ៉ាងយូរក្នុងប្រទេសអេយីព្ទ, ដើម្បីធ្វើកិច្ចពិភាក្សាប្តូរយោបល់គ្នា ជាមួយនិងព្រះសង្ឃនិងពួកព្រឹទ្ធាចារ្យនៅទីនោះ និងដើម្បីមុជចូលទៅក្នុងរឿងសម្ងាត់ទាំងឡាយ ដែលមានលាក់បង្កប់យ៉ាងជ្រៅ នៅក្នុងលទ្ធិសាសនាអេយីព្ទ ។

ប៉ូលីក្រាត បានសរសេរលិខិតមួយទៅ អាម៉ាស៊ីរ្ស ស្តេចនៃប្រទេសអេយីព្ទ ក្នុងលក្ខណៈជាសេចក្តីគាំទ្រចំពោះពីតាគ្គរ... ដើម្បីឲ្យគាត់នេះបានទទួលកិត្តិយសពីព្រះរាជាអេយីព្ទ ។ បន្ទាប់មក ពីតាគ្គរ ក៏បានឆ្លងកាត់ទៅប្រទេសកាល់ដេរ ដើម្បីសិក្សាអំពីវិទ្យាសាស្ត្រ ( វេទមន្ត ) របស់ពួកម៉ាយី ( Mages : ពួកហោរាទស្សន៍ទាយ ) ។ នៅទីបំផុត បន្ទាប់ពីបានធ្វើដំណើរស្រាវជ្រាវគ្រប់ទីកន្លែង ធ្វើឡើងដោយសារការចង់ចេះចង់ដឹងមិនចេះឆ្អែតនៅប្រទេសផ្សេងៗនាខាងកើត គាត់ក៏បានមកសំណាក់នៅកោះក្រែត ( Crète : ក្រអែត, ក្រអឹត... កោះសិរមាន់ ) ដែលនៅទីនោះ គាត់មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងអ្នកប្រាជ្ញ អេពីមេនីដ ។ ពីទីនោះមក គាត់ក៏បានត្រឡប់មករស់នៅក្នុងស្រុកសាម៉ូសវិញ ។ សេចក្តីព្រួយបារម្ភនិងលំបាកចិត្ត នៅពេលដែលគាត់ឃើញស្រុកកំណើតរបស់គាត់ បានទទួលការជិះជាន់ពីសំណាក់រាជាផ្តាច់ការប៉ូលីក្រាត ក៏បានធ្វើឲ្យគាត់សំរេចចិត្តទៅរស់នៅបរទេសសារជាថ្មី ។ គាត់ក៏បានឆ្លងចូលមករស់នៅក្នុងដែនដីអ៊ីតាលី, មកស្នាក់អាស្រ័យនៅក្នុងភូមិក្រូតូន ក្នុងផ្ទះរបស់មីឡុង ដែលនៅទីនោះ គាត់បានបង្រៀនផ្សព្វផ្សាយទស្សនវិជ្ជា (ច្បាប់ធម៌ ) ។ គឺនៅទីនោះហើយ ដែលគាត់បានបង្កើតនិកាយមួយហៅថា ពួកអ៊ីតាលិច ។

កេរ្តិ៍ឈ្មោះរបស់ពីតាគ្គរក៏បានរីកសុះសាយទៅពាសពេញដែនដីអ៊ីតាលី ។ គាត់មានសាវ័កចំនួនពាន់នាក់ ដែលមករួមប្រជុំគោរពប្រណិបត្តិគាត់យ៉ាងហ្មត់ហ្មង ហើយបក្សក្រុមរបស់គាត់ បានក្លាយទៅជាសាធារណរដ្ឋមួយដ៏តូច តែមានសណ្តាប់ធ្នាប់ត្រឹមត្រូវ ។ អ្នកនិពន្ធជាច្រើនបានសរសេរថា នូម៉ាក៏បានរស់នៅក្នុងចំណោមកូនសិស្សទាំងនោះដែរ...គឺបានរស់នៅយ៉ាងពិតប្រាកដនៅក្រូតូន ក្នុងផ្ទះរបស់ពីតាគ្គរ, នៅពេលដែលជននេះ បានត្រូវតែងតាំងឲ្យធ្វើជាស្តេចនៅក្រុងរ៉ូម ។ ក៏ប៉ុន្តែពួកប្រវត្តិវិទ្យាដ៏ល្បីៗជាច្រើនទៀតបានអះអាងថា រឿងស្តេចនូម៉ា ជាសាវ័ករបស់ពីតា-គ្គរ ជារឿងពុំពិតទេ... ហេតុដែលមានពាក្យដំណាលដូច្នេះកើតឡើង គឺមកពីពីតាគ្គរមានគំនិតប្រហាក់ប្រហែលគ្នានឹងស្តេចនូម៉ា ដែលបានកើតមុនសករាជពីតាគ្គរវែងអន្លាយឆ្ងាយអង្វែង ។

ពីតាគ្គរធ្លាប់បានពោលថា ៖ នៅក្នុងរវាងមិត្តភក្តិ អ្វីៗជារបស់រួមទាំងអស់...ហើយគឺមិត្តភាពនេះឯង ដែលបានធ្វើឲ្យមនុស្សទាំងឡាយមានសិទ្ធិស្មើគ្នា (កកន ៖ ជាលទ្ធិដែលចម្លងចេញមកពីលទ្ធិពុទ្ធសាសនា ដោយពេលនោះ អរិយានសាសនាបានធ្លាក់ដុនដាបទៅហើយ ) ។ ពួកសាវ័ករបស់គាត់ គ្មានរបស់របរអ្វីជាពិសេសនោះទេ។ ឥវ៉ាន់ឥវ៉ាន់ដែលគេមានទាំងប៉ុន្មាន ពួកគេប្រមែប្រមូលយកមកដាក់ចូលគ្នាទាំងអស់... ប្រាក់កាសដែលគេមានសំរាប់ចាយ គឺជាប្រាក់សំរាប់ចាយទាំងអស់គ្នា ។ ពួកគេបានចំណាយពេលវេលា៥ឆ្នាំ ដើម្បីមកស្តាប់ការប្រៀនប្រដៅរបស់លោកគ្រូធំ ដោយគ្មានឱកាសបើកមាត់និយាយពាក្យសំដី សូម្បីតែមួយម៉ាត់ក៏គ្មានផង ។ បន្ទាប់ពីរយៈពេលសិក្សាស្វាធ្យាយន៍ដុសដែកដុលដ៏តឹងរ៉ឹង និងដ៏យូរលង់បែបនេះ ទើបបានអ្នកផងមានសិទ្ធិអំណាច ចូលមកជួបពីតាគ្គរ ដើម្បីជជែកវែកញែកពិភាក្សាជាមួយនឹងគាត់ ។

* *

*

ពីតាគ្គរមានដំណើរសង្ហារ អាកប្បកិរិយាខ្ពង់ខ្ពស់ដូចព្រះរាជា ។ គាត់មានមាឌធំដំបង ហើយមានមុខមាត់ស្អាតបាតណាស់ ។ គាត់ស្លៀកពាក់គ្រប់ពេលវេលា ដោយដណ្តប់ខ្លួននឹងសំពត់ឡែនពណ៌ស ដែលគ្មានប្រឡាក់ប្រឡូស សូម្បីបន្តិចបន្តួចក៏គ្មានផង ។ គាត់មិនដែលបង្ហាញមហិច្ឆិតា ឬសំដែងកំហឹងកំហែងកំហាល់ទោសៈអ្វីឡើយ ។ គ្រប់ពេលវេលា គាត់តែងលាក់បង្កប់អាថ៌កំបាំងមួយយ៉ាងធំធេង ។

គ្មានអ្នកណាម្នាក់បានឃើញគាត់សើចនោះទេ ឬក៏បានធ្លាប់ឮគាត់និយាយកំប្លុកកំប្លែងនោះក៏ទេដែរ ។គាត់មិនដែលចង់ដាក់ទោសអ្នកណាម្នាក់ នៅពេលដែលគាត

មានកំហឹងក្នុងខ្លួន សូម្បីតែវាយឈ្នួលបំពីរតែមួយរំពាត់ក៏គ្មានផង ។ ពួកសាវ័ករបស់គាត់បានទុករូបគាត់ជាព្រះអាប៉ូឡូង ( អាប៉ូឡូងជាភាសាអង់គ្លេស ៖ គឺព្រះវិស្ណុ ) មនុស្សនៅគ្រប់ភូមិដ្ឋាន តែងធ្វើដំណើរទាំងហ្វូងទាំងហ្វាយ មកស្តាប់ពាក្យសំដីរបស់ពីតាគ្ករ ជាពិសេសមកមើលរូបគាត់ ដែលមានរូបរាងដូចព្រះបង្ហាត់បង្រៀនសាវ័ក ។ ក្នុងមួយឆ្នាំៗ មានមនុស្សប្រកបដោយចំណេះដឹងចំនួន៦០០នាក់ មកពីទីតំបន់ឆ្ងាយៗនៃប្រទេសផ្សេងៗ ដែលបានចូលមកស្រុកក្រូតូន ៖ ក្នុងសម័យនោះ គឺជាកិត្តិយសមួយធំណាស់ សំរាប់ជនណាក៏ដោយដែលមានភ័ព្វសំណាង បានពិភាក្សា ១០-២០នាទីជាមួយពីតាគ្ករ ។

ពីតាគ្ករបានសរសេរច្បាប់ក្រមសំរាប់ជាអំណោយចំពោះប្រជាជាតិជាច្រើន ដែលបានធ្វើសំណើរនេះចំពោះគាត់ ។ អ្នកផងមានសេចក្ដីកោតស្ញប់ស្ញែងចំពោះរូបគាត់គ្រប់ៗគ្នា... ម្ល៉ោះហើយគេមានការលំបាកក្នុងការបែងចែកឲ្យដាច់គ្នាស្រឡះ រវាងពាក្យសំដីរបស់គាត់និងពាក្យហោរានៅភ្នំដែលហ្វ ។ គាត់បានហាមប្រាមដាច់ណាត់មិនឲ្យធ្វើការស្បថស្បែ ព្រមទាំងមិនឲ្យយកព្រះធ្វើជាប្រធានសាក្សី ។ គាត់បានពោលថា មនុស្សយើងម្នាក់ៗ មែនទែនគួរតែកសាងសេចក្ដីសុចរិតឲ្យបានជិតដល់ដើម្បីញ៉ាំងឲ្យអ្នកផងគ្រាន់តែឮពាក្យសំដីរបស់យើងពេលណា ក៏គេអាចជឿបានស្រេចទៅហើយ ។

ពីតាគ្ករមានជំនឿថា ពិភពលោកដែលយើងរស់នៅ មានជីវិតនិងទំនាក់ទំនងផ្តែកបញ្ញាបាធីគ្រប់ទិសទីកន្លែង ។ គាត់បានយល់ថា ព្រលឹងនៃចក្រវាលទាំងមូលគឺជាឋានសួគ៌ដ៏ទន់ស្រាលនៅខាងលើមេឃ ដែលបញ្ជូនវិញ្ញាណមកមនុស្សនិងសត្វគ្រប់ៗគ្នា ។ គាត់ជឿថាព្រលឹងមិនចេះសាបសូន្យសោះឡើយ... ព្រលឹងតែងរសាត់អណ្តែតនៅតាមខ្យល់ ហើយតែងស្រវារយករូបកាយទី១ដែលគេបានជួបប្រទះ ។ ជាឧទាហរណ៍ ព្រលឹងមួយអាចចេញពីខ្លួនមនុស្សម្នាក់, ហើយចូលទៅក្នុងរូបកាយរបស់សត្វសេះ, សត្វឆ្កែចចក, សត្វលា, សត្វកណ្តុរ, សត្វពពែ, សត្វត្រី... ឬក៏សត្វណាមួយផ្សេងទៀត ដោយគ្មានត្រូវការជ្រើសរើសអ្វីទាំងអស់ ។ គឺមកពីហេតុដូច្នេះហើយ បានជាពីតាគ្ករបានហាមប្រាមយ៉ាងដាច់ខាត មិនឲ្យអ្នកផងបរិភោគសាច់សត្វជាអាហារ ។ គាត់មានសេចក្ដីជឿជាក់ថា គេអាចប្រព្រឹត្តអំពើឧក្រិដ្ឋកម្មធ្ងន់ធ្ងរដូចគ្នា ក្នុងការសម្លាប់សត្វរុយ, សត្វមមង់ ឬក៏សត្វស្អិតផ្សេងៗទៀត គឺមានទោសស្មើគ្នានឹងការសម្លាប់មនុស្សម្នាក់ ពីព្រោះនៅក្នុងរូបកាយរស់រវើកដូចគ្នានេះ សុទ្ធតែមានព្រលឹងដូចៗគ្នាទាំងអស់ ។

ពីតាគ្ករ ដើម្បីបញ្ជាក់ប្រាប់អ្នកផងអំពីទ្រឹស្តីនៃការចាប់ជាតិកំណើតរបស់គាត់ គាត់បានពោលអះអាងថា កាលពីដើមគាត់ធ្លាប់មានឋានៈជាអេថាលីដ ដែលត្រូវជា

រាជបុត្ររបស់ព្រះមែរគួរ ។ គឺហេតុដូច្នេះហើយបានជាមែរគួរបានប្រាប់គាត់ថា ឲ្យស្នើសុំអ្វីៗទាំងអស់ដែលគាត់ប៉ងប្រាថ្នាចង់បាន ក្រៅពីសភាពអមតៈ, ហើយចំណាងអ្វីៗដែលគាត់បានសុំ នឹងត្រូវបានបំពេញទាំងអស់ ។ ពីតាគួរក៏បានសុំចំពោះមែរ-គួរ នូវមហិទ្ធិឫទ្ធិនៃការនឹករឭកឃើញរឿងរ៉ាវទាំងឡាយ ដែលធ្លាប់កើតមានឡើងក្នុងពិភពអតិតកាល ពេលដែលគាត់កំពុងមានជីវិតរស់នៅ ក៏ដូចជានៅក្នុងពេលដែលគាត់ស្លាប់រួចទៅហើយ ហើយតាំងពីពេលនោះមក គាត់ក៏បានដឹងយ៉ាងច្បាស់លាស់ នូវរឿងហេតុអ្វីៗដែលធ្លាប់កើតមានឡើង ។ ដូចជាទាក់ទងនឹងរូបគាត់ផ្ទាល់ បន្ទាប់ពីបានកើតមកជាអេថាលីដ... គាត់ក៏បានក្លាយទៅជាអេហ្វ៊រប ។ គាត់ក៏បានចូលប្រយុទ្ធក្នុងសង្គ្រាមនៅទីក្រុងត្រួយ ដោយនៅពេលនោះ គាត់ក៏បានទទួលរបួសយ៉ាងធ្ងន់ពីមេណេឡាស ។ ជាបន្ទាប់មក ព្រលឹងរបស់គាត់ក៏បានរត់សំដៅចូលទៅក្នុងរូបរបស់អ៊ែរម៉ូទីមូស ។ ក្នុងខណៈនោះ ដើម្បីបញ្ជាក់ដល់អ្នកផងអំពីអំណោយបារមីដែលព្រះមែរគួរបានផ្ដល់ចំពោះគាត់ ៗក៏បានចាកចរទៅក្នុងប្រទេសនៃពួកប្រង់ស្ទីឌ ។ គាត់បានចូលទៅក្នុងវិហាររបស់អាប៉ូឡុង ហើយក៏បង្ហាញពីខែលកំពុកមួយរបស់គាត់ ដែលមេណេឡាសពេលវិលត្រឡប់មកពីទីក្រុងត្រួយវិញ បានយកមកថ្វាយព្រះអង្គនេះ ដើម្បីបញ្ជាក់ពីជោគជ័យរបស់សាមីខ្លួនគេផ្ទាល់ ។

បន្ទាប់ពីអ៊ែរម៉ូទីមូស គាត់ក៏បានក្លាយទៅជាអ្នកនេសាទពៀរុស ហើយនៅទីបំផុតក៏បានក្លាយមកជាទស្សនវិទូពីតាគួរ... ដោយមិនបានរៀបរាប់ផង ថាគាត់ក៏ធ្លាប់បានកើតជាសត្វមាន់គកនៅមីស៊ីល ព្រមធ្លាប់កើតជាសត្វក្អែក មិនដឹងជានៅប្រទេសណាផងទេ ។

គាត់បានបញ្ជាក់ថា នៅក្នុងរយៈពេលនៃការធ្វើដំណើរចុះទៅឋាននរក គាត់បានជួបប្រទះនឹងព្រលឹងរបស់អ្នកកវីហេស៊ីម៉ូដ ដែលកំពុងតែយំទួញស្រែកថ្ងូរជាខ្លាំង ព្រោះគេបានយកច្រវាក់ ចងគាត់ផ្ទោបនឹងសសរក្លោងមួយ ។ នៅក្នុងពេលជាមួយគ្នានោះ គាត់បានឃើញព្រលឹងរបស់អ្នកនិពន្ធអូមែរ ( Homère ) ដែលគេបានយកទៅចងព្យួរកនៅដើមឈើមួយពោរពេញដោយសត្វពស់...គឺពីព្រោះដោយហេតុថា កាលពេលគាត់នៅរស់ គាត់បាននិពន្ធរឿងភូតភរច្រើនណាស់ ដែលគាត់នេះបានបន្ទុកបណ្ដាក់ទៅលើព្រះ ។ ជាពិសេសគាត់បានសង្កេតឃើញនៅឋាននរកឯណោះថា ព្រលឹងប្ដីដែលបានធ្វើបាបប្រពន្ធជាខ្លាំង កាលពេលពួកគេនៅរស់នោះ ត្រូវយកមកធ្វើទុក្ខបុកម្នេញយ៉ាងសំបើមនៅទីនោះ ។

មានពេលមួយទៀត ពីតាគួរបានឲ្យគេសង់វិហារមួយយ៉ាងជ្រៅនៅក្នុងផ្ទះរបស់គាត់ ។ យោងតាមសំដីអ្នកផង ពីតាគួរគាត់បានស្នើសុំឲ្យម្ដាយគាត់សរសេរអំពីព្រឹត្តិហេតុគ្រប់យ៉ាង ដែលកើតមានឡើងនៅពេលដែលគាត់មិននៅ ៖ គាត់ក៏បានចូល

ទៅបួនសម្ងំនៅក្នុងគុហារនោះអស់រយៈពេលមួយឆ្នាំ ។ ពេលដែលគាត់ចេញមកវិញ គាត់មានរូបរាងកាយក្រខ្វក់ស្គមស្គាំងជគ្រើងគួរឲ្យភ័យខ្លាច ។ គាត់ក៏បានឲ្យគេប្រមូលអ្នកស្រុកអ្នកភូមិមកជុំវិញគាត់ហើយគាត់ក៏បានប្រាប់ពួកគេថា គាត់ទើបនឹងវិលត្រឡប់មកពីឋាននរក ។ ដើម្បីញ៉ាំងឲ្យមនុស្សទាំងឡាយជឿលើពាក្យសំដីរបស់គាត់ គាត់ក៏បានចាប់ផ្ដើមនិយាយអំពីរឿងហេតុទាំងប៉ុន្មានដែលកើតមានឡើងនៅពេលដែលគាត់មិននៅ ។ ហ្វូងប្រជាពលរដ្ឋក៏មានសេចក្ដីកោតស្ញប់ស្ញែងជាយ៉ាងខ្លាំង ។ ក្នុងរំពេជនោះ អ្នកខ្លះមានអារម្មណ៍ថា ពីតាគ្គរជាកូនរបស់ព្រះ ។ ម្នាក់ៗក៏បានចាប់ផ្ដើមយំទួញ ព្រមទាំងបញ្ចេញសំរែកយ៉ាងខ្លាំងស្ទើរដល់អាកាស ។ ពួកបុរសក៏បានស្នើរសុំឲ្យពីតាគ្គរជួយបង្ហាត់បង្រៀនភរិយារបស់ពួកគេផង ។ គឺចាប់តាំងពីពេលនោះមក ដែលពួកស្រីៗនៅក្រូតូន ត្រូវគេដាក់ងារថាជា ពីតាគ្គរីស្យែន ( សាវ័ករបស់ពីតាគ្គរ ) ។ ថ្ងៃមួយពីតាគ្គរបានចូលទៅក្នុងទីលានកីឡាសាធារណៈ គាត់ក៏បានហួចឆ្វេកស្រែកហៅសត្វឥន្ទ្រីយមួយ ដែលគាត់បានចាប់យកមកផ្សាំងដោយគ្មាននរណាដឹង ។ ពួកប្រជាជនទាំងឡាយ មានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ។ ពិតាគ្គរដើម្បីញ៉ាំងដំណើរឲ្យរឹតតែសមទំនង ក៏បានឲ្យអ្នកផងមើលឃើញភ្លៅមាសមួយចងជាប់នឹងជើងរបស់សត្វនោះ ។

ពីតាគ្គរតែងតែធ្វើពិធីបូជាថ្វាយព្រះ នូវនំប៉័ងនិងនំផ្សេងៗរបៀបៗគ្នានេះ ។ គាត់បានពោលថា ពួកព្រះនិងទេព្តាមិនសូវចូលចិត្តសត្វដែលគេប្រហារដោយឈាមកក្លាក់នោះទេ... ហើយរឿងនេះអាចណែនាំឲ្យព្រះចងកំហឹងទៅលើពួកជនដែលជាអ្នកផ្ដើមធ្វើពិធីបូជាយ័ញ្ញថ្វាយព្រះនោះទៀតផង ។

វាមានរឿងហេតុច្រើនយ៉ាងដែលពីតាហ្គរ, ដោយសារតែការជាស់តឿនខាងលើនេះ ចង់ឲ្យមនុស្សងាកចេញពីការបរិភោគឆ្អាញ់ ហើយទម្លាប់ពួកគេឲ្យមានការរស់នៅយ៉ាងរបៀបធម្មតាជាទីបំផុត... ពីព្រោះពួកគេច្បាស់ជាមានសុខភាពដ៏ល្អប្រសើរជាងមុន, ចំណែកបញ្ញារបស់គេនឹងមានលក្ខណៈសេរី ហើយនិងមានដំណើរប្រព្រឹត្តទៅមុខក្នុងកិច្ចការផ្សេងៗ ។ ដើម្បីផ្ដល់ឧទាហរណ៍ ខ្លួនគាត់ផ្ទាល់ផឹកតែទឹកហើយរស់នៅគ្រប់ពេលវេលា ដោយសារការបរិភោគនំប៉័ង, ទឹកឃ្មុំ, ផ្លែឈើ, បន្លែ.. លើកលែងតែសណ្ដែកគួរតែប៉ុណ្ណោះ ដែលធ្វើឲ្យអ្នកផងមានសេចក្ដីងឿងឆ្ងល់ថាហេតុអ្វីបានជាគាត់មានកាតព្វកិច្ច ត្រូវគោរពគ្រឿងបន្លែមួយមុខនេះ ។

ពីតាគ្គរបានប្រៀបធៀបជីវិតមនុស្សទៅនឹងបុណ្យហ្វ៊ែរ ( ផ្សារតាំងតុ-តាំងទំនិញ ) ៖ គឺដូចបុណ្យហ្វ៊ែរដូច្នោះឯង អ្នកខ្លះមកទីនោះដើម្បីហ្វឹកហ្វឺនក្នុងការប្រយុទ្ធ, អ្នកខ្លះទៀតមកធ្វើការតថ្លៃទិញដូរទំនិញ, អ្នកខ្លះទៀតមកគ្រាន់តែដើម្បីឈរមើល ។ ដូច្នេះនៅក្នុងជីវិត អ្នកខ្លះកើតមកជាប់ឃុំគ្រងក្នុងកិត្តិយស, អ្នកខ្លះទៀតអើខ្លួនមិន

រួចអំពីមហិច្ឆិតា, ចំណែកអ្នកខ្លះទៀតរង់ចាំចង់ដឹងតែអំពីសេចក្តីពិតតែប៉ុណ្ណោះ ។

គាត់មានឆន្ទៈចង់ឲ្យមនុស្សម្នាក់ៗកុំទាមទារអ្វីៗសំរាប់ខ្លួនឯងផ្ទាល់ឲ្យសោះ ពីព្រោះមនុស្សយើងម្នាក់ៗមិនដែលដឹងអំពីអ្វីដែលត្រឹមត្រូវសំរាប់ខ្លួនឯងនោះទេ ។

គាត់បានចែកជីវិតមនុស្សជាបួនចំណែក ៖ គាត់បាននិយាយថា មនុស្សនៅជាកូនក្មេងរហូតដល់អាយុ២០ឆ្នាំ, ជាយុវវ័យរហូតដល់អាយុ៤០ឆ្នាំ, ជាមនុស្សធំរហូតដល់អាយុ៦០ឆ្នាំ, ជាមនុស្សចាស់ជរារហូតដល់អាយុ៨០ឆ្នាំ ។ ហួសពីអាយុនេះ គាត់មិនរាប់មនុស្សណានៅក្នុងចំណោមមនុស្សរស់ទៀតទេ ។

គាត់ចូលចិត្តធរណីមាត្រ ( géométrie ) និងតារាសាស្ត្រពេកណាស់ ៖ គឺគាត់នេះហើយដែលបានរកឃើញផ្កាយព្រឹក ហើយនិងផ្កាយល្ងាច គឺជាផ្កាយតែមួយ... ហើយនៅក្នុងត្រីកោនដែលមានមុមត្រង់... ការគុណនឹងខ្លួនឯងនៃមុមកណ្តាលនឹងមានការេស្មើគ្នា នឹងការបូកនៃទំហំគុណនៃមុមទាំងសង្ខាងទៀត ( « Le carré de l'hypothènuse est égal à la somme des carrés des deux autres côtés - Théorème de Pythagore » ) ។

គេបាននិយាយថា ៖ ពីតាគ្គរមានសេចក្តីពេញចិត្តនិងរូបមន្តគណិតសាស្ត្រខាងលើនេះមែនទែន រហូតដល់គាត់យល់ថា គឺជាព្រះអាទិទេព ដែលបានផ្តល់បញ្ញានេះដល់រូបគាត់... ម្ល៉ោះហើយគាត់ក៏បានចង់សំដែងនូវសេចក្តីដឹងគុណជាមួយនឹងព្រះដោយការសម្លាប់រង្គាល... គឺដោយធ្វើពិធីបូជាសត្វគោចំនួន១០០ ។ រឿងនេះត្រូវបានគេលើកមកនិយាយគ្រប់ទីកន្លែង ថ្វីបើជារឿងមិនសូវសមស្របនឹងទ្រឹស្តីរបស់ពីតាគ្គរទាល់តែសោះ ។ ក៏ប៉ុន្តែគេអាចសន្និដ្ឋានបានថា សត្វគោទាំងនោះ ជាគោសូន្យមកពីទឹកឃ្មុំនិងម្សៅសាឡី... ដូចតែស្រីៗសាវ័ករបស់ពីតាគ្គរធ្លាប់ធ្វើដូច្នោះឯង ។ អ្នកខ្លះទៀតបាននិយាយថា ៖ ពីតាគ្គរមានសេចក្តីសប្បាយរីករាយនឹងទ្រឹស្តីរបស់គាត់ពេករហូតដល់ទទួលសេចក្តីស្លាប់...ក៏ប៉ុន្តែយោងតាមសំណេររបស់ឡាអែរស (Laërce)... រឿងនេះគ្មានមូលដ្ឋានអ្វីត្រឹមត្រូវទេ ។

ពីតាគ្គរមានគោលបំណងចង់ឲ្យមិត្តភាព និងទំនាក់ទំនងស្រុះស្រួលគ្នា មានជាអចិន្ត្រៃយ៍នៅរវាងពួកក្រុមសាវ័ករបស់គាត់ ។ ជាច្រើនលើកច្រើនគ្រាណាស់ ដោយបង្ហាត់បង្រៀនអ្នកទាំងនេះ គាត់តែងតែនិយាយនៅក្នុងប្រស្នារ ឬនៅក្នុងរបៀបជាការប្រៀបធៀប ។ ជាឧទាហរណ៍ គាត់បាននិយាយទៅកាន់កូនសិស្សគាត់ទាំងអស់ថា គេមិនត្រូវដើរកន្លងជញ្ជីងសោះឡើយ ៖ គឺដើម្បីបញ្ជាក់ប្រាប់អ្នកទាំងនោះថា គេមិនត្រូវដើរងាកចេញពីគន្លងយុត្តិធម៌ទាល់តែសោះ ។

គាត់បានបន្ថែមទៀតថា គេមិនត្រូវអង្គុយលើរបស់អ្វីៗ ដែលគេមានសំរាប់តែមួយថ្ងៃនោះទេ... គឺដើម្បីបញ្ជាក់ថា គេមិនត្រូវបញ្ឈប់ខ្លួនមកត្រឹមតែបច្ចុប្បន្នកាល

ប៉ុណ្ណោះទេ គឺត្រូវមានបង្កប់ស្មៀតខ្លះសំរាប់ដោះស្រាយរឿងអនាគតកាលផងដែរ។

គាត់បានណែនាំសាវ័ករបស់គាត់ឲ្យចំណាយពេលមួយរយៈរៀងរាល់ថ្ងៃ ដើម្បីចោទសួរខ្លួនឯងថា ៖ តើពេញមួយថ្ងៃ ឯងបានធ្វើអ្វីខ្លះ ? តើឯងបានទៅទីណាខ្លះ ? តើឯងបានធ្វើអ្វីខ្លះ ដែលមានលក្ខណៈសមរម្យ ? តើឯងបានធ្វើអ្វីខ្លះ ដែលទាស់ខុសនឹងកាលៈទេសៈ ? ។

គាត់បានផ្តែផ្តាំកូនសិស្សរបស់គាត់ទាំងអស់ថាឲ្យមានលក្ខណៈខាងក្រៅសុភាពរាបសារ, នឹងនរមិនច្រឡោតតោតតូង មិនអបអរសប្បាយឲ្យហួសហេតុ ហើយក៏មិនឲ្យធ្លាក់ខ្លួនស្រពាប់ស្រពោនហួសនិស្ស័យពេកដែរ ។ គេត្រូវមានសេចក្តីទន់ភ្លន់ចំពោះមាតាបិតាជានិច្ច... គេត្រូវតែគោរពចាស់ទុំ... គេត្រូវតែហាត់ប្រាណដើម្បីកុំឲ្យរូបកាយធំធាត់ដុះខ្លាញ់ហួសពេក... គេមិនត្រូវចំណាយពេលពេញមួយជីវិតរបស់គេសំរាប់តែធ្វើដំណើរនោះទេ ។

★ គេត្រូវតែប្រុងប្រយ័ត្នក្នុងការរៀបចំថ្វាយកិត្តិយសដល់ព្រះ ដោយសំអិតសំអាងពិធីសក្ការៈបូជាឲ្យបានល្អប្រសើរជាទីបំផុត ។

★ ជនជាតិស៊ីត សាម៉ូលស៊ីក ដែលមានឋានៈជាកូនឈ្នួលរបស់ពីតាគ្គរ បានសំដែងនូវការប៉ិនប្រសប់ក្រៃលែង ក្នុងការសំដែងទាញយកផលចំណេញ ពីសេចក្តីប្រៀនប្រដៅរបស់លោកគ្រូធំ រហូតដល់ពេលមួយដែលគាត់នេះបានត្រឡប់ទៅស្រុករបស់ខ្លួនវិញ ពួកស៊ីតក៏បានធ្វើពិធីថ្វាយសក្ការៈបូជាចំពោះគាត់ ហាក់ដូចជាកូនឈ្នួលរបស់ពីតាគ្គរ ស្ថិតនៅក្នុងចំណោមពួកព្រះរបស់ពួកគេ ។

* *
*

ពីតាគ្គរបានយល់ថា ទ្រឹស្តីធំបំផុតក្នុងទំនាក់ទំនងលោកិយវត្ថុធាតុនេះ គឺឯកភាព ។ គឺចាប់ផ្តើមពីឯកភាពនេះឡើង ដែលគេចាប់ផ្តើមរាប់ចំនួនលេខនពន្ធ ។ កាលណាមានចំនួនហើយ គេអាចរាប់ពិន្ទុ... កាលណាមានពិន្ទុហើយ គេអាចទាញជាខ្សែគំនូស... កាលណាមានខ្សែគំនូសរួចហើយ គេអាចលាតសន្ធឹងជាផ្ទៃក្រឡា...កាលណាមានផ្ទៃក្រឡារួចហើយគេអាចសាងសង់ជាដុំវត្ថុរឹង... កាលណាមានដុំវត្ថុរឹងរួចហើយ គេអាចរកឃើញនូវធាតុទាំងបួនក្នុងលោកិយគឺ ៖ ភ្លើង, ខ្យល់, ទឹក, ដី... ដែលជាធាតុសាងសង់រូបកាយ... កាឡាខ្លួនចូលគ្នាទៅវិញទៅមកជានិច្ចនិរន្តរ៍ ក៏ប៉ុន្តែគ្មានអ្វីៗដែលត្រូវរលាយរលត់នៅក្នុងចក្រវាលនេះទេ... អ្វីៗដែលកើតមានឡើង គឺគ្រាន់តែជាការផ្លាស់ប្តូររូបប៉ុណ្ណោះ ។

គាត់បាននិយាយថា ផែនដីមានរាងមូល ( កកន ៖ ដូច្នេះពីតាគ្គរបានរកឃើញថា ផែនដីមានរាងមូលចំនួន២ពាន់ឆ្នាំមុន Copernic និង Galilée ទៅទៀត... ក៏ប៉ុន្តែគួរកុំភ្លេចថាចំណេះវិជ្ជារបស់ពីតាគ្គរ ក៏ត្រូវដកស្រង់ចេញពីប្រទេសអេឃីព្ទដែរ ) ហើយផែនដីនេះ បានត្រូវយកមកតាំងនៅចំកណ្តាលទីចក្រវាលតែម្តង ។ គាត់បានអះអាងថា ផែនដីនេះមានមនុស្សរស់នៅគ្រប់ទិសទី... ដូច្នេះទៅវាគ្មានទិសផ្ទុយគ្នាដែលមានពពួកមនុស្ស ដើរបញ្ច្រាស់ជើងទល់គ្នា ជាមួយនិងពួកយើងនោះទេ ។

គាត់និយាយថា ខ្យល់ដែលនៅរុំជុំវិញផែនដី ជាគ្រឿងមិនស្អាត ព្រមទាំងមានថាន:ជារបស់មួយនៅនឹងថ្កល់មួយកន្លែង... គឺហេតុដូច្នោះហើយ បានជាសព្វសត្វទាំងឡាយដែលរស់នៅលើផែនដីនេះ មានវាសនាត្រូវស្លាប់ ព្រមទាំងមានលទ្ធភាពកើតជម្ងឺដែលបណ្តាលឲ្យមានសភាពពុករលួយដល់ខ្លួនប្រាណ ។ ផ្ទុយទៅវិញ ខ្យល់នៅលើផ្ទៃមេឃជាគ្រឿងស្អាតថ្លាឆ្វង់ ដែលរើបំរះផ្លាស់ប្តូរទីកន្លែងជាអចិន្ត្រៃយ៍.. ម្ល៉ោះហើយសព្វសត្វទាំងឡាយ ដែលរស់នៅលើផ្ទៃមេឃ ជាសត្វអមតៈ... អ្វីៗនៅខាងលើមានលក្ខណ:ជាព្រះ ជាទេព្តាទាំងអស់ ។ ដូច្នេះទៅ ថ្ងៃក្តី លោកខែក្តី ព្រមទាំងតារាទាំងឡាយ សុទ្ធសឹងតែជាព្រះអទិទេព ពីព្រោះពួកគេរស់នៅកណ្តាលគ្រឿងខ្យល់ល្អជានិច្ច បក់បោកមកជាមួយកំដៅសកម្ម ដែលជាប្រភពនៃជីវិតទាំងឡាយ ។

មានមតិច្រើនណាស់ដែលបានបកស្រាយអំពីសេចក្តីស្លាប់របស់ទស្សនវិទូពី-តាគ្គរ ។ អ្នកខ្លះពោលថា សាវ័ករបស់គាត់មួយចំនួន ដែលគាត់បានទទួលរាប់អាន ក៏កើតមានសេចក្តីក្តៅក្រហាយជាខ្លាំងនឹងសេចក្តីបដិសេធនេះ ម្ល៉ោះហើយបានយកភ្លើងទៅដុតផ្ទះនៅមីឡុង ដែលពីតាគ្គរកំពុងតែសំណាក់នៅ ។ អ្នកខ្លះទៀតបានអះអាងថា គឺពួកក្រុត្តូនីញ៉ាតដែលបានបង្កើតអគ្គីភ័យខាងលើនេះ ដោយព្រោះគេភ័-យខ្លាចពីតាគ្គរនឹងតាំងខ្លួនជាស្តេចនៅក្នុងស្រុករបស់គេ ។ ទោះជាយ៉ាងណាក្តី នៅពេលដែលពីតាគ្គរបានឃើញភ្លើងឆេះភូមិស្ថានរបស់គាត់អស់ហើយ គាត់ក៏បានដកថយចេញពីទីនោះ ជាមួយនឹងក្រុមសាវ័ករបស់គាត់ចំនួន៩០នាក់ ។ មតិខ្លះទៀតបានបញ្ជាក់ថា គាត់បានរត់ចូលព្រៃមុយសេនៅម៉េតាប៉ុង ដែលនៅទីនោះគាត់បានប-ណ្តោយខ្លួនឲ្យស្លាប់ដោយសារសេចក្តីអត់ឃ្លាន ។ មនុស្សមួយចំនួនបានផ្តល់យោបល់ថា គាត់បានដើរទៅប្រទះចំការសណ្តែកគួរ ដែលគាត់មិនបានដាច់ចិត្តនឹងដើរឆ្លងកាត់ ម្ល៉ោះហើយជាហេតុមិនអនុញ្ញាតឲ្យគាត់គេចចេញពីគ្រោះថ្នាក់បាន ។ « គួរតែ ស្លាប់នៅទីនេះចុះ, គាត់ពោល, ជាជាងដើរជាន់សណ្តែកទាំងនេះឲ្យខ្ទេចខ្ទីអស់ » គាត់ក៏អង្គុយរង់ចាំពួកក្រុត្តូនីញ៉ាតដោយស្ងប់ស្ងៀម ឲ្យពួកនេះមកប្រហាររូបគាត់និងក្រុមសាវ័ករបស់គាត់គ្មានសល់ ។ នៅទីបំផុតមានមនុស្សខ្លះបានយល់ថាមិនមែន

ពួកក្រួតូនីញ៉ាតនេះទេ ដែលបានប្រព្រឹត្តអំពើអកុសលទាំងនេះ ក៏ប៉ុន្តែបន្ទាប់ពីមានសង្គ្រាមកើតឡើងរវាងពួកអាត្រីយ៉ង់តាំងនិងពួកស៊ីរ៉ាគុស្សាំង, ពីតាគ្ករក៏បានរត់ទៅជួយយកអាសារពួកអាត្រីយ៉ង់តាំងដែលត្រូវជាសម្ពន្ធមិត្ត ។ ពួកអាក្រីយ៉ង់តាំងក៏បានត្រូវបាក់ទ័ពខ្ចាត់ខ្ចាយ ហើយនៅក្នុងពេលនោះ ពីតាគ្ករដែលកំពុងថយខ្លួន ក៏បានជួបប្រទះនឹងចំការសណ្តែកពិតមែនដែលគាត់មិនព្រមឆ្លងកាត់ បែរជាសុខចិត្តយកកទៅហុចឲ្យពួកស៊ីរ៉ាគុស្សាំងទៅវិញ។ ពួកនេះបានចាក់ទម្លុះទម្លាយខ្លួនគាត់ជាច្រើនដង ។ ពួកសាវ័ករបស់គាត់ដែលធ្វើដំណើរជាមួយគាត់នៅពេលនោះដែរ ក៏ត្រូវគេប្រហារស្ទើរតែទាំងអស់ ។ មានតិចគ្នាណាស់ដែលបានរួចជីវិតនៅពេលនោះ ។ នៅក្នុងចំណោមអ្នកដែលបានគេចផុតពីគ្រោះថ្នាក់ មានឈ្មោះអាជីតា នៅតារ៉ង់ត៍...ដែលបានក្លាយទៅជាអ្នកប្រាជ្ញផ្នែកខាងរេខាគណិតម្នាក់ដ៏សំខាន់ជាងគេក្នុងសម័យនោះ ។៚

❑ ❑

❑

# ជីវិតរបស់សូក្រាត
# SOCRATE



កើតនៅឆ្នាំទី៤ នៃអូឡាំព្យាដទី៧៧ ។ ស្លាប់នៅឆ្នាំទី១ នៃអូឡាំព្យាដទី៩៥ បន្ទាប់ពីបានរស់រានមានអាយុ៧០ឆ្នាំ ។

❑

សូក្រាត បើយោងតាមយោបល់របស់មនុស្សផងទាំងឡាយក្នុងបុរាណកាល គឺជាទស្សនវិទូម្នាក់ ប្រកបដោយបញ្ញាវាងវៃនិងភ្លឺស្វាង ព្រមទាំងមានជីវិតពោរពេញដោយសីលធម៌ជាងគេបំផុត នៅក្នុងយុគសម័យនៃពហុទេវា ( ពហុទេវា ឬទេព្តច្រើន គឺសម័យព្រហ្មញ្ញសាសនានៃជនជាតិក្រិក... **Paganisme** : បារកាន, ប្រកាន់, ព្រះកាន់, ព្រះខ័ន្ធ ) ។ គាត់ជាពលរដ្ឋនៃទីក្រុងអាតែ្មន, រស់នៅក្នុងសង្កាត់អាឡូប៉ែស ។ គាត់មានកំណើតនៅក្នុងឆ្នាំទី៤នៃអូឡាំព្យាដទី៧៧ មានឪពុកឈ្មោះ សូប្រូស៊ីន ដែលប្រកបមុខរបរជាជាងចម្លាក់លើថ្ម ហើយមានម្តាយឈ្មោះ ហ្វារ៉ាណែត ដែល

ប្រកបមុខរបរជាឆ្មប ។ គាត់បានសិក្សាទស្សនវិជ្ជា, ជាដំបូងនៅក្រោមការដឹកនាំរបស់អាណាសាគូរ៉ាបន្ទាប់មកទៀតនៅក្រោមអ្នកប្រាជ្ញផ្នែកខាងវិទ្យាសាស្ត្រពិសោធន៍ម្នាក់ឈ្មោះ អារកេឡាអ៊ុស ។ ក៏ប៉ុន្តែដោយយល់ឃើញថា ការសិក្សាទៅលើសភាពអាថ៌កំបាំងនៃធម្មជាតិនេះ គ្មានបាននាំមកនូវផលប្រយោជន៍អ្វីសោះ ជាពិសេសគឺមិនបានណែនាំទស្សនវិទូទាំងឡាយ ឲ្យបានក្លាយទៅជាមនុស្សល្អប្រសើរជាងមុន គាត់ក៏បានចាប់ផ្តើមរៀនសូត្រអំពីអ្វីៗដែលទាក់ទងជាមួយទំនៀមទំលាប់ ឬរបៀបរស់នៅ... ហើយទៅតាមមាត៌ាដូចខាងលើនេះ គាត់ក៏បានក្លាយទៅជាស្ថាបនិកជននៃទស្សនវិជ្ជាផ្នែកសិលធម៌មួយរូបក្នុងចំណោមពួកប្រជាជនក្រិក, យោងតាមសេចក្តីសង្កេតឃើញរបស់ស៊ីសេរ៉ុង ( Cicéron ) ក្នុងសៀវភៅទី៣នៃកម្រងសំនួរទូស្គូឡាន ( Questions Tusculanes ) ។

អ្នកនិពន្ធរ៉ូម៉ាំង ( ស៊ីសេរ៉ុង ៖ អ្នកនយោបាយរ៉ូម៉ាំង ដែលបានស្រាវជ្រាវពីវប្បធម៌ក្រិក ) ក៏បានបកស្រាយវែងឆ្ងាយ ហើយនិងជ្រៅជ្រះជាងនេះទៅទៀត នៅក្នុងសៀវភៅទី១របស់គាត់ ដែលគាត់បានធ្វើសេចក្តីអត្ថាធិប្បាយ តាមពាក្យឃ្លាដូចតទៅនេះ « ចំពោះខ្ញុំ, ក៏ដូចជាចំពោះយោបល់មនុស្សទូទៅផងដែរ, សូក្រាតគឺជាអ្នកប្រាជ្ញទី១ ដែលបានបង្វែរទស្សនវិជ្ជា ឲ្យឃ្លាតចេញពីក្របខ័ណ្ឌនៃការស្រាវជ្រាវអំពីទិដ្ឋភាពសម្ងាត់ដែលលាក់បង្កប់ក្នុងធម្មជាតិ... ដែលជាទំលាប់មុខនាទីកិច្ចការអចិន្ត្រៃយ៍របស់ទស្សនវិទូទាំងឡាយ ដែលបានរស់នៅមុនរូបគាត់ ។ គឺសូក្រាតនេះហើយដែលបានប្រទាញយកទស្សនវិជ្ជាមកពង្រឹកធ្វើជាវិន័យសំរាប់អនុមតិទៅលើគ្រប់ នាទីនិងករណិយកិច្ចនៃជីវិតរស់នៅក្នុងសង្គមមនុស្ស ។ ក្នុងប្រការនេះ គាត់បានធ្វើ ការពិចារណាស្រាវជ្រាវទៅលើអ្វីៗដែលជាគុណធម៌ ហើយនិងអំពើបាបឬទៅលើអំពើល្អ និងអំពើអាក្រក់តែប៉ុណ្ណោះ ដោយគាត់បានបញ្ជាក់អះអាងថា អ្វីៗដែលមាននៅលើមេឃនិងលើផ្កាយ វាទៅហួសឆ្ងាយពីសមត្ថភាពនិងបញ្ញាញាណរបស់យើងពន់ពេក, ហើយបើទោះបីយើងបានចូលទៅក្បែរចំណេះដឹងអស់ទាំងនេះក្តី ក៏វិជ្ជាទាំងនេះមិនបានជួយកែឆ្នៃអាកប្បកិរិយារបស់យើងឲ្យបានល្អប្រសើរផងដែរ » ។

ហេតុដូច្នេះ សូក្រាតក៏បានផ្តង់ធ្វើការរៀនសូត្រទៅលើបែបផែនទស្សនវិជ្ជា ដែលមានទំនាក់ទំនង តែទៅលើទំនៀមទំលាប់នៃការរស់នៅប៉ុណ្ណោះ... ដែលលាតសន្ធឹងទៅលើគ្រប់កាលសម័យ និងទៅលើរបៀបរស់នៅគ្រប់ប្រភេទ ។ ហើយការសិក្សាទស្សនវិជ្ជាតាមបែបខាងលើនេះ ត្រូវបានប្រជាជនក្រិកមានការស្រឡាញ់រាប់អានរីតតែខ្លាំងនៅពេលជាមួយគ្នាផងដែរ ដែលអ្នកបានបង្កើតទ្រឹស្តីនេះ ក៏បានធ្វើជាគំរូ នូវចរិយាប្រកបដោយគុណធម៌របស់គាត់ចំពោះភ្នែកអ្នកដទៃ ដោយបានខំប្រឹ

ងប្រែងយ៉ាងទៀងទាត់ជាទីបំផុត បំពេញករណីកិច្ចរបស់ប្រជាពលរដ្ឋដ៏គាប់ប្រសើរ ទោះនៅក្នុងពេលសន្តិភាពក្តី ទោះនៅក្នុងពេលចំបាំងក្តី ។

នៅក្នុងចំណោមទស្សវិទូទាំងអស់ ដែលធ្លាប់មានកេរ្តិ៍ឈ្មោះល្បីល្បាញ បើយោងតាមការសង្កេតរបស់ លូស៊ីយាង នៅក្នុងសៀវភៅគំហើញរបស់គាត់ដែលមានឈ្មោះថា ៖ « ការសន្ទនារបស់ជនប៉ារ៉ាស៊ីយ » ( **Dialogue du Parasite** ), សូក្រាតជាមនុស្សតែម្នាក់គត់ ដែលធ្លាប់បានចូលធ្វើសឹកសង្គ្រាម ។ គាត់បានចូលធ្វើសង្គ្រាមនៅក្នុងយុទ្ធនាការពីរដង ( **Campagnes** )... ហើយនៅគ្រប់ចំបាំងទាំងពីរលើកនេះ, ថ្វីបើបក្សពួករបស់គាត់បានទទួលបរាជ័យគ្រប់តែលើកក្តី គាត់មិនបានញញើតនឹងធ្វើពលិកម្មរូបខ្លួនឯង គឺប្តូរខ្លួនជាមួយនឹងសេចក្តីស្លាប់... ពោលគាត់បានបង្ហាញថា ខ្លួនគាត់ជាមនុស្សម្នាក់ ប្រកបដោយសេចក្តីក្លាហានដ៏កម្ររកបាន ។នៅ ក្នុងប្រការមួយ គាត់បានជួយស្រោចស្រង់ជីវិតរបស់ សេណូហ្វុង ( **Xénophon**) ។ ជនក្រោយនេះដែលបានត្រូវធ្លាក់ពីលើខ្នងសេះ នៅពេលដែលកងទ័ពរបស់ពួកខ្លួន កំពុងតែវាយដកថយ ប្រហែលជាត្រូវសត្រូវប្រហារជីវិតចោលបាត់ទៅហើយ ប្រសិនបើសូក្រាតមិនបានលើកគាត់នេះអូសចេញពីការប្រកួត ហើយដាកលើស្មាខ្លួនឯងព្រមទាំងរត់ចម្ងាយបានពីរបីស្រែ (ស្តាដ) រហូតដល់សេះដែលរត់រួចរួចទៅនោះ ត្រូវចាប់បានមកវិញ ។ គឺស្រ្តាបុង ដែលបានលើកយករឿងនេះមកផ្សាយក្នុងសាធារណជន ។ នៅក្នុងប្រការមួយទៀត... នៅពេលដែលពួកទីក្រុងអាតែ្មនត្រូវចាញ់គេ ហើយវាយដកថយរត់យកតែប្រាស់អាយ៉ូស... សូក្រាតគឺជាជនម្នាក់ដែលបានដកថយក្រោយគេបង្អស់ ។ គាត់បានបង្ហាញនូវចិត្តនឹងនរគ្មានសេចក្តីតក់ស្លុត សូម្បីតែពួកសត្រូវដែលបានដេញតាមប្រហារពួកជនភៀសខ្លួន ក៏មានសេចក្តីខ្លាចញញើតចំពោះរូបគាត់ផងដែរ ពីព្រោះពួកនេះដឹងថា គាត់ចាំតែបែរមុខមកតទល់វិញតែប៉ុណ្ណោះ... ម្ល៉ោះហើយពួកសត្រូវពុំមានសេចក្តីក្លាហាននឹងព្យាបាទរូបគាត់ឡើយ ។ រឿងនេះមានសាក្សីម្នាក់ឈ្មោះ អាត្គោណេ ជាអ្នកលើកយកមកបរិយាយ ។

ក្រៅតែពីរឿងសឹកសង្គ្រាមតាំងពីរលើកនេះចេញ សូក្រាតមិនដែលបានដាក់ជើងទៅក្រៅតីក្រុងអាតែ្មនម្តងណាទៀតឡើយ ។ អាកប្បកិរិយាបែបនេះមានលក្ខណ:ផ្ទុយពីចរិតនៃទស្សនវិទូឯទៀតៗ ដែលសុខសឹងតែបានធ្វើដំណើរ អស់មួយភាគនៃជីវិតរបស់ប្ចកគេ ដើម្បីព្យាយាមសន្សំយកនូវចំណេះដឹង ដែលពួកគេដកចេញបានមកពីការពិភាក្សា ជាមួយនឹងពួកក្រុមអ្នកប្រាជ្ញនៃគ្រប់ប្រទេស ។ ក៏ប៉ុន្តែរបៀបបែបបទនៃទស្សនវិជ្ជា ដែលសូក្រាតបានដាក់ព្រំសីមានោះ គឺគ្រាន់តែបានជំរុញមនុស្ស ឲ្យស្វែងរកត្រឹមតែចំណេះដឹងនៅក្នុងខ្លួនឯងតែប៉ុណ្ណោះ ( « *ចូរឯងដឹងអំពីអ្វីៗ ដែលនៅក្នុងខ្លួនរូបឯង...» សូក្រាត* ) ជាជាងស្វែងរកវិជ្ជានៅក្រៅខ្លួន ដែលគ្មាន

ប្រយោជន៍អ្វីទាល់តែសោះ  សំរាប់ដោះស្រាយបញ្ហាសីលធម៌នៃរបៀបរស់នៅក្នុង
សង្គមមនុស្ស ម្ល៉ោះហើយគាត់ក៏បាននឹកគិតថា គាត់គ្មានការចាំបាច់អ្វីក្នុងការធ្វើដំ-
ណើរទៅទីឆ្ងាយៗនោះឡើយ ដែលច្បាស់ជាគ្មានបានបង្ហាត់បង្ហាញ នូវអ្វីៗដែលគា
ត់ចង់ដឹង ឲ្យលើសពីនៅក្នុងទីក្រុងអាតែ្ននោះបានឡើយ ។ គាត់បានយល់ថា ការ
កែទម្រង់នៃសង្គមដែលគាត់រស់នៅ, នៅកណ្តាលចំណោមប្រជាពលរដ្ឋ ដែលជា
បងប្អូនរួមជាតិរបស់គាត់  ជាកិច្ចការចាំបាច់ដែលគាត់ត្រូវធ្វើមុនមុខនាទីអ្វីៗទៀតដែ
លគេត្រូវបំពេញនៅបរទេស ។ ម៉្យាងវិញទៀត ដោយទស្សនវិជ្ជាខាងផ្នែកសីលធម៌
របស់គាត់ជាវិទ្យាសាស្ត្រមួយ  ដែលតម្រូវឲ្យផ្តល់អំពើជាគំរូចំពោះអ្នកដទៃ  ជាជាង
ការធ្វើសង្កថាវែងអន្លាយ គាត់ក៏បានបង្កើតវិន័យមួយដ៏តឹងរ៉ឹងសំរាប់ខ្លួនឯងត្រូវគោ
រពប្រណិបតន៍ជារៀងរាល់ថ្ងៃ ៖ គឺប្រព្រឹត្តអ្វីៗតែតាមគន្លងសីលធម៌ និងវិចារណ-
ញ្ញាណ ដែលបានតម្រែតម្រង់រូបគាត់ប៉ុណ្ណោះ ។ គឺនៅក្នុងប្រការនៃការស្វះស្វែង
រកឧត្តមគតិបែបនេះហើយ ដែលនៅពេលមួយដែលគាត់បានត្រូវតែងតាំង ជាស-
មាជិកនៃព្រឹទ្ធសភានៃទីក្រុងអាតែ្ន, សូក្រាតតែងតែបានបដិសេធជានិច្ចជាកាល មិ
នព្រមគោរពតាមច្បាប់រដ្ឋពេលមិនព្រមគោរពតាមឆន្ទៈរបស់ប្រជាជន, ថ្វីបើគាត់បា
នប្រកាសស្បថស្បែថាគោរពច្បាប់ជាធរមានយ៉ាងណាក្តី... ពេលគឺគាត់មិនព្រមកា
ត់ទោសប្រហារជីវិតនាយទាហានមេបញ្ជាការ៩នាក់ ។ នៅក្នុងរឿងនេះ បើទោះជា
មានកំហឹងពីសំណាក់ប្រជាពលរដ្ឋយ៉ាងណាក្តី,  បើទោះជាមានការគំរាមកំហែងពី
សំណាក់រដ្ឋបុរស ដែលមានអំណាចពីលើគាត់យ៉ាងណាក្តី ក៏បុកពាររបស់គាត់នៅ
នឹងថ្កល់រឹងដូចថ្ម មិនព្រមធ្វើតាមការសម្អាធន៍របស់ជនណាម្នាក់ឡើយ ។

យើងមិនបានដឹងថា គាត់បានកាន់កិច្ចការសាធារណៈណាមួយទៀត ក្រៅតែពី
ការកាត់ទោសនាយទាហានបញ្ជាការទាំង៩នាក់នេះឡើយ ក៏ប៉ុន្តែក្នុងឋានៈជាបុគ្គល
សាមញ្ញមួយរូប សូក្រាតបានត្រូវទទួលការកោតគោរពកោតក្រែងពីអ្នកផង ដោយ
សារតែគតិយុត្តិធម៌ និងអំពើស្អាតស្អំរបស់គាត់ ជាងពួកក្រុមចៅក្រមដែលកាន់កាប់
ត្រួតត្រានៅទីក្រុងអាតែ្នទៅទៀត ។ ទាក់ទងនឹងបុគ្គលិកលក្ខណៈផ្ទាល់របស់គាត់
វិញ, គាត់ចូលចិត្តតាក់តែងខ្លួនល្មម, របៀបកណ្តាលនិយម, ដោយមានសំលៀកបំ
ពាក់ផ្ចិតផ្ចង់ ។ គាត់តែងតែស្តីបន្ទោសដល់មនុស្សខ្លះ ដែលមិនព្រមរវីរវល់នឹងរូបខ្លួ
នឯងសោះ ពេលដែលមានការស្លៀកពាក់មិនជាបើ ។ គាត់ចូលចិត្តស្លៀកពាក់ស្អា
តបាតសមសួន សមរម្យនឹងភ្នែកអ្នកផង មិនក្រខ្វក់ស្មោគគ្រោករបៀបសាមញ្ញជន
ខ្លាំងពេក ហើយក៏មិនសង្ហារខ្ពង់ខ្ពស់ដែលបង្ហាញនូវចរិតទន់ខ្សោយនោះផងដែរ ។
ថ្វីបើគាត់មិនបានទទួលភ័ព្វវាសនានៃទ្រព្យសម្បត្តិដ៏បរិបូរណ៍ក្តី ក៏ប៉ុន្តែគាត់មិនដែ-
លបានគិតពីផលប្រយោជន៍ផ្ទាល់ខ្លួនរបស់គាត់ទាល់តែសោះ ។ គាត់មិនដែលបាន

ទទួលជំនួនអ្វីៗពីអ្នកផងទាំងឡាយ ដែលស្ទុះស្វែងមកស្តាប់មេរៀនរបស់គាត់នោះឡើយ ម្ល៉ោះហើយអាកប្បកិរិយាបែបនេះ ក៏បណ្តាលឲ្យមានការប៉ះទង្គិចជាមួយនឹងទស្សនវិទូដទៃៗទៀត ដែលមានទំនៀមទំលាប់លក់ដូរមេរៀនរបស់ខ្លួន ដោយទាមទារយកសារគុណាពីកូនសិស្សរបស់ខ្លួន នូវកំរៃខ្ពស់ឬកំរៃទាបយោងទៅតាមកេរ្តិ៍ឈ្មោះ ដែលពួកខ្លួនមាននៅក្នុងចំណោមមហាជនតែប៉ុណ្ណោះ ។ ក្នុងប្រការនេះយោងតាមសេចក្តីរាយការណ៍របស់សេណូហ្វុង សូក្រាតមានទម្លាប់និយាយថា គាត់មិនអាចយល់បានទាល់តែសោះថា ហេតុអ្វីបានជាមនុស្សម្នាក់អាចនឹកឃើញអំពីការទាញយកកំរៃទៅកើតកាលណាបើខ្លួនគេមានវិជ្ជាជីវៈជាអ្នកបង្ហាត់បង្រៀនសីលធម៌ ធ្វើមើលតែការប្រទាញយកមនុស្សដ៏សុច្ចរិតម្នាក់មកធ្វើជាមិត្តសំឡាញ់ និងជាសាវ័ក មិនគឺជាកម្រៃដ៏ខ្ពង់ខ្ពស់ និងជាការចំណេញដ៏បរិបូរណ៍ខ្លាំងពេកណាស់ទៅហើយ ដែលគេអាចដកស្រង់បានពីការខំប្រឹងប្រែងរបស់គេទេឬ ? ។

គឺទាក់ទងនឹងរឿងមិនគិតផលប្រយោជន៍ផ្ទាល់ខ្លួននេះហើយ ដែលជនសូហ្វីស្តម្នាក់ ( កកន ៖ Sophiste : ជនដើរតួជាអ្នកប្រាជ្ញ, មាត់រឹង ហើយជជែកយកតែពីឈ្នះ ដោយគ្មានគិតពីបញ្ហាហេតុផល ) ...មានឈ្មោះថាអង់ទីហ្វុង ដែលមិនសូវសប្បាយចិត្តនឹងសីលធម៌មួយដែលគាត់មិនចង់ធ្វើតាម... បានពោលពាក្យត្រគោះក្នុងសម័យថ្ងៃមួយទៅកាន់សូក្រាតថា មានគំនិតត្រឹមត្រូវហើយ ដែលមិនចង់បានផលចំណេញអ្វីទាល់តែសោះ ពីពួកអ្នកដែលគាត់បានបង្ហាត់បង្រៀន... ហើយក្នុងការប្រកាន់យកអាកប្បកិរិយាបែបនេះ សូក្រាតបានបង្ហាញថា ខ្លួនគាត់ជាមនុស្សសុច្ចរិតយុត្តិធម៌ពិតមែន ។ គឺដោយហេតុថា, ជនសូហ្វីស្តបានពោលបន្តទៅទៀត, « ប្រសិនបើជាលោកត្រូវការលក់ផ្ទះសំបែង, លក់សំលៀកបំពាក់ ឬតុទូរបស់លោក... លោកច្បាស់ជាមិនឲ្យរបស់នេះទៅអ្នកដទៃទទេៗនោះឡើយ, ឬក៏មិនព្រមលក់ដោយតម្លៃថោកៗនោះដែរ គឺលោកច្បាស់ជាខំប្រឹងប្រែងទាញយកផលកំរៃឲ្យត្រឹមត្រូវតាមតម្លៃរបស់ខ្លួន លោកច្បាស់ជាលក់យកថ្លៃ ដោយមិនឲ្យខាតមួយសេនសោះឡើយ ។ ក៏ប៉ុន្តែនៅក្នុងពេលជាមួយគ្នា ដែលលោកមានជំនឿជឿជាក់ខ្លួនលោក ថាលោកគ្មានដឹងអ្វីទាល់តែសោះ... ( កកន ៖ ពាក្យឃ្លាដ៏ល្បីល្បាញបំផុតរបស់សូក្រាត ចងក្រងជាសុភាសិតនៅភ្នំដែល្ហ ហើយដែលអ្នកផងស្គាល់ជាងគេបំផុតគឺ : « ខ្ញុំដឹងតែរឿងមួយគត់ប៉ុណ្ណោះ... គឺខ្ញុំឥតដឹងរឿងអ្វីទាំងអស់ » )... ហើយដោយនៅក្នុងមូលហេតុនេះលោកក៏ពុំមានលទ្ធភាពបង្ហាត់បង្រៀនផ្តល់ចំណេះវិជ្ជាអ្វីទាំងអស់ដល់អ្នកដទៃដូច្នេះទៅលោកក៏មានអារម្មណ៍ឬមានសតិសម្បជញ្ញៈថា លោកមិនត្រូវទាញយកផលចំណេញអំពីអ្វីៗ ដែលលោកមិនអាចបង្ហាត់បង្រៀនដល់ក្រុមសិស្សរបស់លោកនោះផងដែរ ។ រឿងនេះគួរឲ្យសរសើរដល់គតិយុត្តិធម៌របស់លោក មិន

មែនជារឿងដែលបញ្ជាក់ថា លោកមិនស្រឡាញ់ផលប្រយោជន៍ផ្ទាល់ខ្លួននោះឡើយ » ។

ក៏ប៉ុន្តែសូក្រាតពុំមានការលំបាកអ្វីសោះក្នុងការធ្វើឲ្យជននេះភ័ន្តភាំងវង្វេងស្មារតី, គឺដោយគ្រាន់តែបង្ហាញឲ្យគាត់នេះឃើញថា វាមានរបស់ខ្លះដែលគេអាចយកទៅប្រើប្រាស់បានដោយគតិធម៌ផង និងដោយមិនសុចរិតផងដែរ ឧទាហរណ៍ ៖ ការយកផ្លែឈើមួយពីរ ដែលខ្លួនមាននៅក្នុងសួន យកទៅធ្វើអំណោយដល់មិត្តភក្តិម្នាក់ ឬក៏យកទៅលក់ដូរឲ្យជនដដែលនេះ គឺជារឿងពីរខុសគ្នាស្រឡះ ។ ម៉្យាងវិញទៀត គេមិនត្រូវនឹកស្មានថា សូក្រាតបានបង្កើតសាលា ដូចទស្សនវិទូដទៃឯទៀតៗ ដែលបានជ្រើសតាំងទីកន្លែងមួយប្រាកដប្រជា សំរាប់ជាកន្លែងប្រជុំរបស់ក្រុមសាវ័ក ហើយដែលបានផ្តល់មេរៀនទៅតាមម៉ោងពេលកំណត់ដ៏ទៀងទាត់នោះទេ ។ របៀបបង្ហាត់បង្ហាញទស្សនវិជ្ជារបស់សូក្រាត, គឺមានលំនាំជាការពិភាក្សាវែកញែក, ការជជែកប្តូលយោបល់គ្នាទៅវិញទៅមក សុទ្ធសាធជាមួយនឹងពពួកមនុស្សដែលមានវត្តមាននៅក្បែររូបគាត់, ដោយគ្មានចាំបាច់ជ្រើសរើសពេលវេលានិងទីកន្លែងណាមួយពិតប្រាកដនោះឡើយ ។ មូលហេតុដ៏សំខាន់បំផុត ដែល ម៉េលីទុស បានចាត់ទុកជាបទឧក្រិដ្ឋដែលសូក្រាតបានប្រព្រឹត្ត គឺការមិនព្រមទទួលស្គាល់ក្រុមជំពូកព្រះដែលអ្នកផងបានគោរពបូជានៅទីក្រុងអាតែ្មនរួចទៅហើយ, ហើយថាសូក្រាតគាត់បែរជាបញ្ចូលព្រះអាទិទេពថ្មីៗបន្ថែមមកទៀត ។ ក៏ប៉ុន្តែ ការចោទប្រកាន់នេះប្រកបដោយលក្ខណៈមួលបង្កាច់ហួសនិស្ស័យ និងខ្វះនូវសេចក្តីសំអាងលើមូលដ្ឋានពិត ដែលគេមិនធ្លាប់ដែលបានជួបប្រទះទាល់តែសោះ, ពីព្រោះថាសូក្រាតបានបង្កើតច្បាប់ទម្លាប់មួយដ៏សំខាន់សំរាប់ខ្លួនឯង, និងសម្រាប់អ្នកដទៃទៀត ដែលបានមកស្នើរយោបល់ចំពោះរូបគាត់, គឺការគោរពប្រណិបត្តន៍និងអនុលោមតាមពាក្យទំនាយរបស់ព្រះអាប៉ូឡុងនៅភ្នំដេល្វីទាំងស្រុង (ភ្នំទេព) ។ នៅពេលដែលគេសួរគាត់ថា តើគេត្រូវថ្វាយបង្គំព្រះសំពះទេព្តា ដោយរបៀបណា, គាត់បានឆ្លើយថា , ម្នាក់ៗត្រូវគោរពព្រះទៅតាមបែបបទពិធីទំនៀមទម្លាប់ ដែលមាននៅក្នុងស្រុករបស់ខ្លួន ។ គឺយោងទៅតាមរបៀបដូច្នេះឯងដែលសូក្រាតតែងធ្វើពិធីសក្ការៈបូជា គឺដាក់ដង្វាយថ្វាយព្រះទៅតាមសមត្ថភាពដែលគាត់មាន...។ ថ្វីបើអ្វីៗដែលគាត់បានដាក់ថ្វាយព្រះអង្គជារបស់តិចតួចស្តួចស្តើងយ៉ាងណាក្តី សូក្រាតតែងនឹកគិតថា គាត់ត្រូវបានភាគចំណែក(បុណ្យទាន) ពីព្រះ និងទេព្តាទាំងអស់, ស្មើគ្នានឹងពួកអ្នកមានសម្បត្តិទ្រព្យដែលបានចំណាយប្រាក់កាសដ៏សម្បើមធ្វើបុណ្យនោះដែរ, ដោយហេតុថាពួកអ្នកក្រោយនេះ គេអាចធ្វើដូច្នេះបាន ពីព្រោះគេមានអំណាច, ហើយគាត់មិនអាចនឹកស្មានយល់ទាល់តែសោះថា ព្រះជាម្ចាស់និងទេព្តានានា អាចមានអធ្យោគអធ្យា-

ស្រវ័យអាណិតអាសូរឃោគយល់ (ស៊ីសំណូក) ទៅលើពួកអ្នកធំនិងពួកគហបតីដែលបានដាក់ដង្វាយក្រាស់ក្រែលនោះ..ឲ្យលើសពីពលិកម្មរបស់ពួកអ្នកក្រីក្រនិងអ្នកតូចតាច ខ្សត់ខ្សោយនោះដែរ ។ ផ្ទុយទៅវិញ គាត់តែងតែបានយល់ថា ព្រះទាំងឡាយតែងតែមានសេចក្តីសោមនស្សរីករាយ នៅពេលដែលបានជ្រាបថាពួកជនសុច្ចរិត និងពពួកមនុស្សប្រកបដោយធម៌ បានធ្វើបុណ្យធ្វើទានថ្វាយទ្រង់ ។

គ្មានអ្វីដែលមានលក្ខណៈធម្មតាជាទីបំផុត ហើយនៅក្នុងពេលនោះឯងមានលក្ខណៈជាសក្ការៈផងដែរ ឲ្យលើសពីសេចក្តីអធិដ្ឋាន ( ឧទ្ទិសដ្ឋាន ) ឬការបន់ព្រះដែលសូក្រាតតែងតែប្រារព្ធធ្វើនោះទេ ។ គាត់មិនដែលបានសុំអ្វីពីព្រះដោយច្បាស់លាស់នោះទេ គាត់គ្រាន់តែបានឧទ្ទិសសូមឲ្យទ្រង់វិនិច្ឆ័យដោយព្រះអង្គឯង... ថាអ្វីជារបស់ល្អ ហើយនិងអ្វីជារបស់អាក្រក់សំរាប់រូបគាត់, ពីព្រោះថា, នេះគឺជាសំដីរបស់គាត់ផ្ទាល់, កាលណាហើយគេសុំសម្បត្តិទ្រព្យនិងកិត្តិយសពីព្រះ... ក៏គឺហាក់ដូចជាគេសុំលទ្ធភាពពីព្រះក្នុងការធ្វើសឹកសង្គ្រាម ឬទៅលេងល្បែងដូច្នោះ...ដោយគ្មានដឹងពីលទ្ធផលចុងចប់នៃសង្គ្រាមនោះ ឬក៏គ្មានដឹងពីជោគវាសនារបស់ខ្លួនឯងនៅក្នុងរឿងល្បែងនោះផង។

សូក្រាតមិនត្រឹមតែមិនមែននាំគេឯងឲ្យឃ្លាតចាកចេញពីព្រះ... គឺថែមទាំងបានណែនាំអ្នកផងដែលបាត់បង់ជំនឿទៅលើលទ្ធិសាសនាឲ្យវិលត្រឡប់មករកព្រះវិញនោះផង ។ សេណូហ្វុងបានរៀបរាប់អំពីរបៀប ដែលសូក្រាតគាត់បានប្រើ ដើម្បីបន្ទន់ចិត្តរបស់មនុស្សម្នាក់ ឈ្មោះអារីសតូដេមុស ដែលបានផ្តេជ្ញាចិត្តថាមិនព្រមធ្វើបុណ្យថ្វាយព្រះទាល់តែសោះ... មិនត្រឹមតែប៉ុណ្ណោះ ថែមទាំងបានឈរសើចចំអកចំពោះអ្នកដទៃដែលធ្វើបុណ្យសាងកុសលធម៌នោះថែមទៅទៀត ។ នៅពេលណាដែលគេបានអានអត្ថបទរបស់សេណូហ្វុង, អំពីអ្វីៗដែលសូក្រាតបាននិយាយបានថា អំពីសភាពអស្ចារ្យរបស់ព្រះជាម្ចាស់ទៅលើពពួកមនុស្ស, គេមានសេចក្តីងឿងឆ្ងល់ជាខ្លាំង អំពីទស្សនវិទូម្នាក់នេះ ដែលធ្លាប់តែរស់នៅ ក្រោមលទ្ធិនៃពហុទេវា, ថាគាត់ចេះអាចមានគំនិតត្រិមត្រូវ និងសមរម្យពន់ពេក ទាក់ទងនឹងអ្វីៗដែលមកពីព្រះអាទិទេព ។

○

គាត់មានសភាពក្រីក្រទូរគតជាពន់ពេកណាស់, ក៏ប៉ុន្តែគាត់ក៏សប្បាយចិត្តនឹងទូរគតភាពរបស់គាត់ផងដែរ ។ ប្រសិនបើគាត់មានគំនិតត្រឹមតែចង់មានចង់បានប៉ុណ្ណោះទេ...គាត់គ្រាន់តែព្រមហុចដៃទទួលអំណោយអំពីមិត្តភក្តិរបស់គាត់ ឬពីពួកសាវ័ករបស់គាត់ដែលតែងតែបង្ខំឲ្យគាត់ទទួលយល់ព្រមយកជំនួយពីពួកគេជារឿ

យៗ នោះក៏វាជាការស្រេចទៅហើយ ។ ក៏ប៉ុន្តែសូក្រាតចេះតែបញ្ជូនអំណោយទាំងនេះ ឲ្យវិលត្រឡប់ទៅម្ចាស់ដើមវិញ, ជាហេតុបណ្តាលឲ្យភរិយារបស់គាត់, ដែលមិនសូវជាមានគំនិតស្របតាមទស្សនវិជ្ជារបស់គាត់ប៉ុន្មានសោះ, មានការខកចិត្តយ៉ាងខ្លាំង ។ របៀបរស់នៅរបស់គាត់មានសភាពតឹងតែងចំពោះខ្លួនឯងពេកណាស់ ជាពិសេសទាក់ទងនឹងចំណីអាហារ និងសម្លៀកបំពាក់... រហូតដល់ជនសូហ្វីស្ត ( អ្នកនិយាយយកតែឈ្នះ ) ឈ្មោះអង់ទីហ្វុង ដែលយើងបានអធិប្បាយពីខាងលើរួចមកហើយ... បាននិយាយស្តីបន្ទោសឲ្យគាត់ថា ថាគ្មានឈ្នួលបម្រើគេ ដ៏ក្រីក្ររហេមរហាមឯណា ដែលធុនទ្រាំបានដូចគាត់ ឬដែលចង់រស់ដូចគាត់នោះទេ ។ « ពីព្រោះថា, ជននោះពោល, ម្ហូបម្ហាររបស់លោក វាស្គមស្គាំងជាងគេនៅលើផែនដីនេះ ។ ម្យ៉ាងវិញទៀត លោកមិនត្រឹមតែមានសម្លៀកបំពាក់ម្សីម្សារ មិនជាបើតែប៉ុណ្ណោះទេ... ប៉ុន្តែពេញរយៈវេលាមួយឆ្នាំ, លោកមានសម្លៀកបំពាក់តែមួយម៉ាកហ្នឹង... ខែក្តៅក៏ដូចតែខែត្រជាក់ ។ លើសពីនេះទៅទៀត, លោកដើរទៅណាមកណាតែជើងទទេ...គ្មានស្បែកជើងអ្វីពាក់នឹងគេទេ! »..។ ក៏ប៉ុន្តែសូក្រាតបានបង្ហាញដល់ជននេះថា គាត់នេះយល់ច្រឡំតែខ្លួនឯងតែប៉ុណ្ណោះ, ប្រសិនបើជាគាត់នេះយល់ថាសុភមង្គលបិតនៅលើសភាពសំបូរសប្បាយ និងសភាពឆ្ងាញ់ពិសារ ។ « ខ្ញុំយល់ឃើញថា, គាត់ពោល, ដោយកង្វះនៃសេចក្តីត្រូវការ គឺជាគុណសម្បត្តិរបស់ព្រះ... ដូច្នេះកាលណាមនុស្សយើងកាន់តែលែងមានចំណង់និងលែងមានសេចក្តីត្រូវការ... នោះគេកាន់តែធ្វើដំណើរឆ្ពោះទៅជិតព្រះជាមិនខានឡើយ » ។

គឺដោយបង្ហាញខ្លួនជាអ្នកមានសីលធ៌មដ៏បរិសុទ្ធបែបនេះ, ទើបសូក្រាតចៀសវាងមិនរួច ពីការជួបប្រទះនូវប្រជាប្រិយភាពដ៏ភ្លូកក្រឡាប់, ជនណាៗក៏មានការស្ងើចសរសើរចំពោះរូបគាត់ដែរ, ជាពិសេសនៅក្នុងទីក្រុងមួយដូចជា ទីក្រុងអាត្តែននេះ ដែលរបៀបរស់នៅរបស់សូក្រាតបានលេចឡើងជាគំរូមួយដ៏អស្ចារ្យ...។ ពោលសូម្បីតែអ្នកដែលគ្មានកម្លាំងនឹងរស់នៅក្នុងគន្លងធ៌មដូចសូក្រាត ក៏ត្រូវមានកាតព្វកិច្ចប្តូលយុត្តិធ៌មចំពោះពួកអ្នកដែលអាចរស់នៅបែបដូចនេះដែរ ។ ជីវិតរបស់សូក្រាតបានបណ្តាលឲ្យពួកប្រជាពលរដ្ឋដូចគ្នាស្ងើចសរសើរជាទូទៅ... ហើយបានណែនាំមនុស្សភ្លូកទឹកភ្លូកដី ឲ្យមកជួបគាត់គាត់...នូវសាវ័កទាំងចាស់ទាំងក្មេង, ដែលមានសេចក្តីរំភើបញាប់ញ័រក្នុងការស្តាប់ពាក្យសំដីទូន្មានរបស់គាត់ ជាជាងការបានទៅសប្បាយភ្លើតភ្លើនក្នុងល្បែងឆក់ទាញអារម្មណ៍គ្រប់បែបយ៉ាង ។ ឥទ្ធិពលឆក់ទាញរបស់សូក្រាត រិតតែមានកម្លាំងស្នេហ៍យ៉ាងខ្លាំងថែមទៅទៀត, នៅពេលដែលគាត់ដាក់ច្បាប់បន្តឹងបន្តែងតែចំពោះរូបគាត់ប៉ុណ្ណោះ... ក៏ប៉ុន្តែគាត់តែងតែមានការបន្ធូរបន្ថយជានិច្ចសំរាប់ជាការសំរួលជីវិតដល់អ្នកដទៃ ។ កាតព្វកិច្ចទី១ ដែលគាត់បាន

សាកល្បងឲ្យយុវជនដែលស្តាប់មេរៀនរបស់គាត់គោរពប្រណិប័តន៍, គឺការមានចិត្តសទ្ធាជ្រះថ្លាចំពោះព្រះ... ។ បន្ទាប់មក គាត់ក៏បានប្រើឥទ្ធិពលសីលធ៌មរបស់គាត់ដើម្បីជំរុញពួកអ្នកទាំងនេះ, ទៅតាមសម័ត្ថភាពដែលគាត់ធ្វើបាន, ឲ្យពួកអ្នកទាំងនេះចេះរស់នៅក្នុងសភាពអត់ធ្មត់នៅក្នុងជីវិតខ្វះខាត, ចៀសវាងជីវិតរុងរឿងសប្បាយនិងសេចក្តីសំរើប ពីព្រោះគ្រឿងភ្លើតភ្លើនបំប៉នអារម្មណ៍អស់ទាំងនេះ តែងនាំឲ្យពួកគេបាត់បង់នូវកំណាប់ទ្រព្យដ៏មានតម្លៃថ្លៃថ្លាជាទីបំផុតដែលគ្មានអ្វីប្រៀបផ្ទៀបបាន, ពោលគឺសេរីភាព ។ របៀបដែលលោកគ្រូធំបានបង្ហាត់បង្រៀនអំពីសីលធ៌មតែងមានស្នេហ៍ឆក់ទាញដ៏ពិតប្រាកដ ពីព្រោះមានសភាពជាការនិយាយគ្នាយ៉ាងធម្មតាការប្តូរយោបល់គ្នាទៅវិញទៅមក, ដោយថៃដន្យព្រមទាំងដោយគ្មានការចាត់តាំងកម្មវត្ថុអ្វីដ៏ពិតប្រាកដ ។ ជាដំបូងគាត់តែងផ្តើមការពិភាក្សាជាមួយនឹងជនទី១ ដែលបានគាត់បានជួបប្រទះ ដោយចោទជាសំនួរដូចជាមនុស្សម្នាក់ដែលមានការចង់ចេះចង់ដឹង...។ ជាបន្ទាប់មក, ដោយឆ្លៀតឱកាសអំពីជំហរខ្ពស់របស់គាត់ ទៅលើចំណុចខ្សោយនៃចម្លើយដែលគូសន្ទនាបានធ្វើមកចំពោះរូបគាត់ សូក្រាតក៏បានណែនាំអ្នកទាំងនោះ ឲ្យនិយាយប្រឆាំងនឹងខ្លួនឯង ( ឲ្យនិយាយជាន់កែងជើងខ្លួនឯង ) បើប្រៀបធៀបជាមួយមួយនឹងមតិដែលអ្នកទាំងនេះបានអះអាង តាំងពីដំបូងទីនៃការជជែកវែកញែក ។ គាត់តែងតែចំណាយពេលអស់កន្លះថ្ងៃ ទៅមួយថ្ងៃទៅក្នុងសន្និសិទ្ធនៃសីលធ៌មបែបនេះ, ដែលអ្នកផងតែងបានត្រូវទទួលស្វាគមន៍ជានិច្ច, ហើយដែលគ្មាននរណាម្នាក់បានចាកចេញទៅវិញ បើយោងតាមសេចក្តីអះអាងរបស់សេណូហ្វុង, ដោយគ្មានការរីកចម្រើនក្នុងឆន្ទៈនៃការប្រព្រឹត្តអំពើល្អនោះឡើយ...។

○

ថ្វីបើសូក្រាតពុំបានទុកសំណេរអត្ថបទអ្វី ដល់កូនចៅជំនាន់ក្រោយទាល់តែសោះ ក៏ប៉ុន្តែអ្នកផងអាចធ្វើការវិនិច្ឆ័យបានដោយងាយស្រួល ទៅលើមូលដ្ឋានសីលធ៌មរបស់គាត់, ហើយនិងរបៀបដែលគាត់បានអនុវត្តន៍ធម្មក្រិត្យរបស់គាត់, តាមរយៈសៀវភៅរបស់ប្លាតុង នឹងរបស់សេណូហ្វុង ។ សេចក្តីអធិប្បាយរបស់សាវ័កទាំងពីររបស់សូក្រាតនេះ, អំពីអ្វីៗដែលទាក់ទងនឹងការបង្ហាត់បង្រៀនរបស់គ្រូនៃពួកគេ ដែលមានលំនាំជាការឈ្លោះប្រកែកគ្នា (ការប៉ះទង្គិចគ្នាខាងផ្លូវគំនិត ឬ ការពិភាក្សា ) មិនដែលជាន់ជើងគ្នាឡើយ, គឺទៅសមស្របគ្នាជានិច្ច ដែលជាភស្តុតាងថាគរុកោសល្យ របស់សូក្រាតមានវត្តមានពិតមែននៅក្នុងប្រវត្តិសាស្រ្ត ។ ...ចំពោះអត្ថន័យវិញ, គេមិនអាចនិយាយបានថាប្លាតុងបាននិយាយរៀបរាប់នូវការពិតទាំងស្រុងរបស់គ្រូរបស់ខ្លួនឯងនោះឡើយ... ពីព្រោះសាវ័កម្នាក់នេះ នៅពេលខ្លះក៏បាន

បញ្ចេញបញ្ចូលជ្រៀតជ្រែកគំនិតរបស់ខ្លួនឯង,ដូចដែលសូក្រាតបានពោលនៅថ្ងៃមួយបន្ទាប់ពីបានអានការពិភាក្សាប្តូរ យោបល់របស់គាត់ជាមួយអ្នកដទៃនៅលីស៊ីស។ ក៏ប៉ុន្តែគួរកត់សំគាល់ថា នៅក្នុងរឿងនេះសេណូហ្វុងមានសេចក្តីស្មោះត្រង់ជាងប្លាតុង ពីព្រោះទាក់ទងនឹងកម្រងពាក្យសំដីដែលគាត់បានដកស្រង់ពីការប្តូរយោបល់គ្នារវាងសូក្រាត និងមនុស្សម្នាក់ផ្សេងទៀត សេណូហ្វុងតែងបានពោលថាគាត់បានធ្វើឡើងនៅក្នុងគោលបំណងគោរពប្រវត្តិវិទ្យា ...ពោលគឺគាត់រៀបរាប់ដាក់នៅលើក្រដាស់តែអ្វីៗ ដែលគាត់បានឮតែប៉ុណ្ណោះ... ដោយគ្មានឲ្យថ្លោះធ្លោយ ។

ទៅថ្ងៃមុខទៅ គេមានការលំបាកក្រៃពេកដើម្បីស្វែងរកយល់ថា ហេតុអ្វីបានជាមនុស្សម្នាក់ដែលបានណែនាំអ្នកផងឲ្យគោរពព្រះ, និងបានបង្ហាត់បង្រៀនដល់យុវជនឲ្យឃ្លាតចាកចេញឆ្ងាយពីអំពើបាបនិងជីវិតអបាយមុខ បែរជាត្រូវគេយកទៅកាត់ទោសប្រហារជីវិតទៅវិញដោយត្រូវជាប់ចោទជាអ្នកប្រមាថព្រះជាទីសក្ការៈបូជានៅទីក្រុងអាត្ថែន និងក្នុងឋានៈជាអ្នកបំពុលសាបព្រួសនូវអំពើពុករលួយក្នុងចំណោមពួកយុវជនសម័យនោះ?!។ ម្ល៉ោះហើយអ្នកផងបានអនុម័តថាអំពើអយុត្តិធម៌មដ៏មហាអស្ចារ្យនិងដ៏សែនចុកចាប់នេះ អាចប្រព្រឹត្តទៅបានតែនៅក្នុងស្រុក មួយដែលកើតកល្លិយុគពោរពេញដោយអនាធិបតេយ្យ ក្រោមរដ្ឋាភិបាលបែកបាក់ ដឹកនាំដោយជនកាន់អំណាចផ្តាច់ការ៣០នាក់ ។ ហើយតទៅនេះ គឺជាដើមហេតុចំបងដែលបានបង្កើតឲ្យមានអយុត្តិធម៌ដូចបែបខាងលើ ៖ គ្រីតចាស ជាបុរសម្នាក់ដែលមានអំណាចដ៏លើសលប់បំផុតនៅក្នុងចំណោមអ្នកកាន់អំណាចផ្តាច់ការទាំង៣០នាក់, កាលពីដើមគាត់នេះ ក៏មានឋានៈជាកូនសិស្សរបស់សូក្រាត ដោយស្មើភាពគ្នាជាមួយនឹងអាល់ស៊ីប្យ៉ាដផងដែរ ៖ ក៏ប៉ុន្តែអ្នកទាំងពីរក្រោយនេះ ដោយមានការធុញថប់នឹងទស្សនវិជ្ជាមួយ ដែលមានវិន័យនិងការប្រៀនប្រដៅមិនសូវសមស្របនឹងមហិច្ឆតានិងជីវិតស្រើបស្រាលរបស់ពួកគេ... ក៏បានបោះបង់ចោលគ្រូរបស់ខ្លួនឯងបណ្តោយទៅ ។ ចំពោះគ្រីតចាសពីឋានៈជាសាវ័ក... ជននេះក៏បានក្លាយទៅជាសត្រូវដ៏ធំបំផុតរបស់សូក្រាត, គឺដោយសារតែទស្សនវិទូរូបនេះបានដាក់ទោសយ៉ាងតឹងរ៉ឹងចំពោះរូបគេ... ដែលបានប្រព្រឹត្តអំពើបាបខាងផ្លែកតណ្ហាមួយដ៏គួរអាមាស់ថោកទាប មិនត្រឹមតែប៉ុណ្ណោះ សូក្រាតថែមទាំងបានមកឈរទទឹងផ្លូវនៃការលោភលន់របស់បុគ្គលនេះទៀតផង ។ គឺហេតុដូច្នេះហើយ បានជាគ្រីតចាសនៅក្នុងចំណោមជនផ្តាច់ការទាំង៣០នាក់... មានគំនុំគុំគួនជាមួយនឹងសូក្រាត ខ្លាំងជាងគេទាំងអស់... ហើយបានខំប្រឹងប្រែងធ្វើយ៉ាងណាធ្វើការបំផ្លិចបំផ្លាញសូក្រាតឲ្យត្រាតែរលាយរូបទើបបានអស់ចិត្ត ។

ចំណែកសូក្រាតវិញ ក៏មិនអាចទ្រាំទ្រចំពោះការជិះជាន់សង្កត់សង្កិនរបស់ជន

ផ្តាច់ការទាំង៣០នាក់នេះដែរ, ម៉្លោះហើយក៏បាននិយាយប្រឆាំងជាមួយនឹងពួកក្រុមទាំងនេះ ដោយគ្មានញញើតកោតក្រែង ។ គឺពីព្រោះថា ដោយបានឃើញពួកជនផ្តា-ច់ការបានបណ្តាលឲ្យមានការស្លាប់ដល់ប្រជារាស្ត្រកាន់តែខ្លាំងឡើងៗ រៀងរាល់ថ្ងៃ, ហើយសុទ្ធសឹងតែជាពលរដ្ឋសំខាន់ៗថែមទៅទៀត, សូក្រាតក៏បានប្រៀបធៀបពួកអ្នកទាំងនេះទៅនឹងក្រុមគង្វាលមួយ ដែលគេបានទុកចិត្តប្រគល់មេគោជាច្រើនឲ្យឃាម ក៏ប៉ុន្តែជារៀងរាល់ថ្ងៃបាននាំសត្វគោត្រឡប់មកវិញដោយមានសភាពកាន់តែស្គមស្គាំងទៅ និងដោយចំនួនកាន់តែតិចតួចស្តួចស្តើងទៅ...ម៉្លោះហើយអ្នកផងនឹងច្បាស់ជាភ្ញាក់ផ្អើលជាមិនខានបើក្រុមគង្វាលនេះ មិនព្រមទទួលខ្លួនថាពួកក្រុមខ្លួនជាក្រុមគង្វាលមួយដ៏សែនគម្រក់។ គ្រីតចាសហើយនិងចារីត ...ជនផ្តាច់ការពីរនាក់ដ៏សំខាន់ជាងគេក្នុងចំណោមអ្នកទាំង៣០នាក់...ដែលដឹងថាការនិយាយប្រៀបធៀបមានការតម្រង់ទៅលើរូបពួកគេ, ក៏បានចាប់ផ្តើមបង្កើតច្បាប់មួយ ដែលហាមប្រាមមនុស្សមិនឲ្យបង្ហាត់បង្រៀន អំពីសិល្បៈនៃសំនួនវោហារនៅទីក្រុងអាតែ្មន។ ថ្វីបើសូក្រាតមិនដែលបានទទួលស្គាល់ថាខ្លួនគាត់ជាគ្រូបង្រៀនផ្នែកខាងធ្វើសេចក្តីអត្ថាធិប្បាយក្តី... ក៏ប៉ុន្តែអ្នកផងបានដឹងថា ពួកអស់លោកអ្នកធំមានគំនុំទៅលើរូបគាត់ជាប្រាកដ ។ ពួកអ្នកដឹកនាំសម័យនោះ ចង់ចងឃ្លុំមាត់របស់គាត់ ដើម្បីកុំគាត់មានលទ្ធភាពពិភាក្សាអំពីចំណុចសីលធម៌, ដូចដែលសូក្រាតគាត់ធ្លាប់បានធ្វើមករៀងរាល់ពេលជាធម្មតា, ជាមួយនិងពួកមនុស្សដែលបានមកជួបមុខគាត់, ដើម្បីសួរសុខទុក្ខចំពោះរូបគាត់ ។

សូក្រាតក៏បានធ្វើដំណើរទៅជួបអ្នកមេច្បាប់ទាំងពីរនាក់នេះដោយផ្ទាល់... ដើ-ម្បីសាកសួរអំពីមូលហេតុនៃការបង្កើតច្បាប់ខាងលើនេះ ៖ ក៏ប៉ុន្តែដោយសំនួរដែ-លប្រកបដោយវិចារណញ្ញាណរបស់គាត់បានបណ្តាលឲ្យពួកនេះទើសទាល់ជាខ្លាំងជនផ្តាច់ការទាំងពីរនាក់នេះ ក៏បានហាមប្រាមចំពោះរូបគាត់មិនឲ្យ និយាយស្តីទៅកាន់ពួកយុវជនណាម្នាក់សោះឡើយ ។ នៅពេលដែលសូក្រាតសួរត្រឡប់ទៅវិញថា តើអ្នកទាំងពីរនាក់នេះ គិតរាប់ពីអាយុប៉ុន្មានទៅដែរ ដែលគេអាចចាត់ទុកបានថាជាយុវជនជនផ្តាច់ការក៏បានបញ្ជាក់ថា ពួកយុវជនត្រូវគិតរាប់ពីមនុស្សដែលមានអាយុ៣០ឆ្នាំចុះក្រោម ។ « ក៏ប៉ុន្តែ, សូក្រាតពោល, តើខ្ញុំត្រូវចៀសវាងមិនតបឆ្លើយឬយ៉ាងណា... ឧបមាបើមានគេសួរខ្ញុំថា តើចារីកនៅឯណា ?
តើគ្រីតចាសនៅឯណាដែរ? » ។ « អើ, ចារីកពោល, ឯងឥតត្រូវនិយាយស្តីអ្វីទាំងអស់ » ។ « ក៏ប៉ុន្តែ, គ្រីតចាសពោលបន្ថែម, គេហាមប្រាមរូបឯងមិនឲ្យនិយាយទៅកាន់ពួកសិល្បករមួយចំនួនធំ ដែលមានក្រដាសត្រចៀកធុញថប់ជាខ្លាំងមែនទែន ...មិនចង់ឲ្យឯងនិយាយតម្លង់ដោយសន្ទូរកថារបស់ឯងនោះទេ...» ។

«ចុះបើ,សូក្រាតពោលបន្ត, ..ចុះបើពួកគេមកសួរខ្ញុំអំពីសេចក្ដីមេត្តាករុណា ហើយ និងអំពីយុត្តិធម៌វិញ? »។« អើ, ចារីកពោលតបទៅសូក្រាត, ហើយអំពីរឿងពួកគង្វាលគោថែមទៀត, ហើយចូរឯងប្រុងប្រយ័ត្នឲ្យមែនទែន ប្រយ័ត្នគោញីរបស់ឯងហ្នឹង កាន់តែមានចំនួនតិចទៅៗជាមួយគ្នាផងដែរ។ »... ។ ការជជែកគ្នាមិនបានប្រព្រឹត្តទៅវែងឆ្ងាយលើសពីនេះឡើយ, ក៏សូក្រាតបានយល់រួចស្រេចទៅហើយអំពីគ្រោះថ្នាក់ដែលគាត់ត្រូវភ័យខ្លាចអំពីមេច្បាប់ទាំងពីររូបនេះ... គឺដោយហេតុថាការដែលគាត់បានប្រៀបធៀបពួកជនផ្ដាច់ការទៅនឹងពួកគង្វាលគោ... បានធ្វើឲ្យពួកនេះមានសេចក្ដីក្ដៅក្រហាយច្រឡោតខឹងពេលរាលយ៉ាងខ្លាំង ។

ក៏ប៉ុន្តែដោយកេរ្តិ៍ឈ្មោះរបស់សូក្រាត និងគោលជំហរសីលធម៌របស់គាត់មានសភាពរឹងប៉ឹងមាំក្រៃពេក, ពួកអ្នកកាន់អំណាចមិនហ៊ានឆ្លងកាត់ការស្ដុយកេរ្តិ៍ឈ្មោះដោយវាយប្រហាររូបគាត់យ៉ាងចំហរ ព្រមទាំងដោយអូសករូប គាត់មកឡើងតុលាការនោះឡើយ។ ម្ល៉ោះហើយ,គេក៏បានចាប់ផ្ដើមបំផ្លាញកេរ្តិ៍ឈ្មោះរបស់គាត់សិនតាមរយៈការសំដែងសិល្បៈល្ខោនកំប្លែង មានចំណងជើងថា « ហ្វូងពពក », ដោយអ្នកនិពន្ធដ៏មានទេពកោសល្យម្នាក់ឈ្មោះអារីសតូហ្វាន, ដែលមានការប៉ិនប្រសប់ក្នុងការបង្ហាញឲ្យឃើញថា សូក្រាតចេះច្នៃនភ្លែកធ្វើឲ្យអំពើសុច្ចរិតយុត្តិធម៌លេចឡើងជាអំពើអយុត្តិធម៌ ។ ល្ខោនកំប្លែងនេះ មានឥទ្ធិពលយ៉ាងខ្លាំងទៅលើមតិមហាជន, ដោយបាចសាចលក្ខណៈគួរឲ្យចង់សើចទៅលើរូបសូក្រាត ម្ល៉ោះហើយរដ្ឋអាជ្ញាម៉េ-លីទុស ក៏បង្ហាញខ្លួនឡើងដើម្បីចោទប្រកាន់សូក្រាតអំពីបទក្បត់ជាតិ, ក្បត់សាស-នា ៖ ដោយប្រការទី-១, សូក្រាតបានត្រូវចោទថាមិនបានទទួលស្គាល់ព្រះដែលអ្នកផងគោរពបូជានៅទីក្រុងអាតែ្ថន, មិនត្រឹមតែប៉ុណ្ណោះថែមទាំងបាននាំព្រះថ្មីយកមកបញ្ចូលជំនួសវិញ; ក្នុងប្រការទី២ គឺបានសាបព្រួសនូវអំពើពុករលួយក្នុងចំណោមពួកយុវជន ពោលគឺបានបង្ហាត់បង្ហាញពួកអ្នកទាំងនេះមិនឲ្យគោរពឪពុកម្ដាយរប-ស់ខ្លួនឯង និងពួកចៅក្រម ។ រដ្ឋអាជ្ញាខាងលើនេះ ក៏បានទាមទារនៅចំពោះមុខឧក្រិដ្ឋកម្មទាំងពីរបែប ឲ្យកាត់ទោសសូក្រាតដោយដាក់ទណ្ឌកម្មប្រហារជីវិត ។

បើទោះជាជនផ្ដាច់ការទាំង៣០នាក់, ជាពិសេសគ្រីតចាសនិងចារីក.. មានមោហ៍បាំងជញ្ជាំងចិទ យ៉ាងណាក្ដីចំពោះសូក្រាត ក៏ពួកគេមិនងាយយករូបគាត់ទៅកាត់ទោសបានដែរ, ល្គឹកណាបើសូក្រាតមិនជួយសំរួលការពួកអ្នកទាំងនេះផងដែរ ។ ក៏ប៉ុន្តែសេចក្ដីក្លាហានដ៏មោះមុតរបស់សូក្រាត ការមើលងាយសេចក្ដីស្លាប់ ...ជាពិ-សេសការមើលស្រាលពេបជ្រាយចំពោះពាក្យប្រមាថចោទប្រកាន់ទៅលើរូបគាត់, គឺគាត់មិនព្រមចេញប្រាក់បង់ផាកពិន័យណាមួយផង... ដោយយល់ឃើញថាបើគាត់យល់ព្រមធ្វើដូច្នេះទៅ គឺហាក់ដូចជាការទទួលខ្លួនខុស, មិនត្រឹមតែប៉ុណ្ណោះ

គោលជំហររឹងប៉ឹងរបស់គាត់តទល់នឹងពួកចៅក្រម... នៅពេលដែលពួកនេះបានកោះហៅរូបគាត់ទៅសួរថា តើគាត់ចង់ឲ្យគេកាត់ទោសតាមទម្ងន់បែបបទឧក្រិដ្ឋណាមួយ... គាត់បានឆ្លើយតបទៅពួកអ្នកទាំងនេះវិញយ៉ាងសង្ហារថា រូបគាត់គួរតែមានកិត្តិយសរស់នៅក្នុងសាលាក្រុងរបស់អាត្តែន ហើយគួរតែរដ្ឋផ្តល់សេចក្តីត្រូវការឲ្យគាត់ពេញមួយជីវិត ។ ពាក្យទាំងនេះ បានជំរុញឲ្យពួកជនផ្តាច់ការទាំង៣០នាក់មានកំហឹងពុះពោរ... ម្លោះហើយពួកគេក៏បានសម្រេចចិត្តកាត់ទោសផ្តាច់ជីវិតរូបគាត់បណ្តោយទៅ ។

○

ទស្សនវិទូម្នាក់ឈ្មោះ លីស៊ីយ៉ាសបាននិពន្ធនូវកម្រងពាក្យសរសើរដំកើងមួយ (កកន ៖ Une apologie ពាក្យបារាំងមានន័យថាជាពាក្យសរសើរដំកើង ឬពាក្យការពារ ចំណែកពាក្យអង់គ្លេសវិញ Apology មានន័យថាជាពាក្យសុំទោស ) ដើម្បីឲ្យគាត់យកទៅប្រើការការពារខ្លួន នៅពេលដែលគាត់ឡើងទៅបង្ហាញខ្លួននៅចំពោះមុខចៅក្រម ។ សូក្រាត បន្ទាប់ពីបានយកកម្រងពាក្យនោះមកអានរួចហើយ, ក៏បានពោលថាសំណេរការពារខ្លួននេះជាការល្អប្រសើរពន់ពេកណាស់។ ក៏ប៉ុន្តែគាត់បានប្រគល់អត្ថបទនេះទៅម្ចាស់ដើមវិញ ដោយពោលថាសំណុំសេចក្តីនេះមិនសមស្របជាមួយនឹងរូបគាត់ទេ ។ « ម្តេចក៏អីចឹងទៅវិញ, លីស៊ីយ៉ាសពោល, ហេតុអ្វីក៏ពាក្យការពារខ្លួនទាំងនេះមិនសមស្របនឹងរូបលោកទៅវិញ បើលោកបានពោលថាវាជាការល្អប្រសើរ ? » ។ « នែហ! មហាមិត្ត, សូក្រាតពោលតបវិញ, វាមានសម្លៀកបំពាក់ខ្លះនិងស្បែកជើងខ្លះវាល្អប្រសើរឆើតឆាយពិតមែន... ក៏ប៉ុន្តែវាមិនល្អប្រសើរជាមួយនឹងរូបខ្ញុំ ..» ។ ជាការពិត, ថ្វីបើពាក្យសរសើរដំកើងនោះ បានត្រូវនិពន្ធឡើងដោយប៉ិនប្រសប់, ដោយមានគោលជំហរនិងមូលហេតុត្រឹមត្រូវ, ក៏ប៉ុន្តែសំណុំពាក្យទាំងនេះ បានត្រូវរៀបចំឡើងដោយមិនសមស្របជាមួយនឹងបុគ្គលិកលក្ខណៈស្មោះត្រង់និងប្រកបដោយសច្ចភាពរបស់សូក្រាតនោះទេ។ ដោយត្រូវទទួលទោសពិន័យពីបទប្រហារជីវិត, សូក្រាតក៏បានត្រូវគេនាំទៅបញ្ចូលក្នុងគុក, ហើយពីរបីថ្ងៃជាបន្ទាប់មក, គាត់ក៏បានទទួលសេចក្តីស្លាប់ដោយបានលេបគ្រាប់ស្លែង ៖ គឺដោយរបៀបនេះហើយ ដែលគេបានសម្លាប់ពួកជនជាប់ទោសអំពីបទប្រហារជីវិតនៅទីក្រុងអាត្តែនកាលសម័យនោះ ។

ជនម្នាក់ឈ្មោះឌីយ៉ូសែន-ឡាអ៊ែរក្ស បានអះអាងថា សូក្រាតបានរៀបអាពាហ៍ពិពាហ៍ពីរដងក្នុងជីវិតរបស់គាត់ ។ ក៏ប៉ុន្តែនៅចំពោះមុខប្រវត្តិសាស្ត្រ ... នៅក្នុងចំណោមប្រពន្ធទាំងពីររបស់គាត់ ...មានតែអ្នកស្រីសន់ទិព , ដែលបានផ្តល់កូនប្រុស

មួយដល់សូក្រាតឈ្មោះ តម់ប្រូក, ដែលបានត្រូវអ្នកផងស្គាល់ជាងគេ... ពីព្រោះអ្នកស្រីល្បីថាកាចមួរម៉ងច្រើនហើយ បានធ្វើទុក្ខបុកម្នេញចំពោះសូក្រាតយ៉ាងច្រើនបំផុតក្នុងជីវិតរបស់គាត់...។ សូក្រាតបានពោលថា ដែលគាត់បានយកនាងសន់ទិពធ្វើប្រពន្ធ ពីព្រោះគាត់ដឹងច្បាស់ណាស់ថា បើគាត់អាចទប់ទល់ទ្រាំទ្រនឹងចរិតកាចឫស្យារបស់ភរិយាគាត់បាន...នោះគ្មានអ្វីៗទៀតនៅក្នុងជីវិត ដែលថាគាត់មិនអាចទ្រាំទ្របាននោះឡើយ ។

សូក្រាតបានអះអាងថាគាត់ជាមនុស្សដែលមានគ្រូកាន់,មានទេព្តាណែនាំផ្លូវ, ដោយធ្វើឲ្យគាត់ដឹងរឿងហេតុជាមុននៅក្នុងកាលៈទេសៈខ្លះ។ ប្លាតុង, សេណូហ្វុង... ហើយនិងអ្នកនិពន្ធដ៏ល្បីៗជាច្រើនទៀតនៅក្នុងបុរាណកាល ក៏បានបញ្ជាក់ពីរឿងនេះដែរ ។ ព្លូតារគ, អាពូឡេ, ហើយនិងម៉ាកស៊ីមដឺទៀរ, ម្នាក់ៗសុទ្ធសឹងតែបានសរសេរសៀវភៅ...អំពីទេព្តាសូក្រាត... ឬអារក្សសូក្រាត គ្រប់ៗគ្នា។ គាត់បានស្លាប់ទៅនៅឆ្នាំទី១ នៃអូឡាំព្យ៉ាដទី៩៥ នៅក្នុងជន្មាយុ៦៨ឆ្នាំ ។៚

○

( កកន ៖ សេចក្តីស្លាប់របស់សូក្រាតបានធ្វើឲ្យផ្អើលពិភពគុននៅក្នុងបុរាណសម័យហាក់ដូចជាមានការក្រឡាប់មេឃនិងផែនដី ។បន្ទាប់ពីមរណភាពរបស់សូក្រាត អ្នកផងក៏បានចាប់ផ្តើមស្រឡាញ់និងគោរពបូជារូបគាត់ដូចជាព្រះ ។ ដូច្នេះហើយបានជាក្រោយពេលដែលសូក្រាតស្លាប់ទៅ ពួកជនជាតិក្រិកបានចែកក្រុមទស្សនវិទូរជា២កាលសម័យ... គឺសម័យជំនាន់មុនសូក្រាត និងជំនាន់ក្រោយសូក្រាត ...។ មិនត្រឹមតែប៉ុណ្ណោះ បន្ទាប់ពីសូក្រាតស្លាប់ទៅ... ពិភពខាងលិចទាំងមូលដែលឋិតនៅក្រោមឥទ្ធិពលទស្សនវិជ្ជានិងចំណេះដឹងរបស់ពួកជនជាតិក្រិក បានចាត់ទុកទស្សនវិជ្ជាថាថាជា « ចំណេះដឹង ដែលរៀនពិសោធន៍អំពីសេចក្តីស្លាប់ » ( Philosopher, c'est apprendre à mourir ) ។ សេចក្តីស្លាប់របស់សូក្រាតបានត្រូវមនុស្សជាតិតំណក្រោយ ទទួលដឹងឮនិងលើកយកមកធ្វើការវិភាគគ្រប់ជ្រុងជ្រោយ ...ក៏ដោយសារតែសូក្រាតមានសាវ័កដ៏ឆ្នើមម្នាក់ឈ្មោះប្លាតុង... ដែលមានឋានៈជាទស្សនវិទូរផងនិងជាអ្នកកវីផង បានលើកយកសេចក្តីស្លាប់នៃគ្រូរបស់ខ្លួនមកអធិប្បាយចងក្រងជាសៀវភៅយ៉ាងគួរឲ្យរំភើបអស្ចារ្យ ។ ចំនួនពីរពាន់បួនរយឆ្នាំមកហើយ, ដែលពួកអ្នកអានជាច្រើនឥតគណនា ... ដែលកាលណាគេអានស្នាដៃដ៏ពោរពេញដោយទេព្យកោសល្យរបស់ប្លាតុង ទាក់ទងនឹងសេចក្តីស្លាប់ដ៏អណោចអធម៌នេះ... គឺមានតិចតួចណាស់ ដែលអាចគ្រប់សង្កត់មនោសញ្ចេតនាពុះកញ្ជ្រោលរបស់ខ្លួន

ព្រមទាំងអាចទប់ទល់ទឹកភ្នែករបស់ខ្លួនឯងបាន..។ តទៅនេះជាសេចក្ដីដកស្រង់នៃអត្ថបទរបស់ប្លាតុងស្ដីពីទិវាចុងក្រោយរបស់សូក្រាត ( ចុះនៅក្នុង Phaedo, section 116-118, traduction Jowett ដកស្រង់ចេញពីសៀវភៅ The Story of Philosophy , by Will Durant ) ៖

« គាត់បានងើបឡើង ហើយដើរចូលទៅក្នុងបន្ទប់ទឹកជាមួយនឹងគ្រីតូ, ដែលបានបង្គាប់ឲ្យពួកយើងរង់ចាំ។ យើងក៏បានរង់ចាំ ព្រមទាំងបានជជែកគ្នាពីនេះពីនោះដោយនឹកមមៃមិនចេះដាច់ទៅដល់ទម្ងន់ទុក្ខដ៏សែនសាហាវ ដែលកំពុងគ្របសង្កត់មកលើពួកយើង ។ ពីព្រោះរូបគាត់ហាក់ដូចជាឳពុករបស់យើងទាំងអស់គ្នា ដែលយើងនឹងត្រូវបាត់បង់, ហើយពួកយើងនឹងរៀបចំក្លាយទៅជាក្មេងកំព្រាតាំងតែពីថ្ងៃនេះតទៅហើយរហូតដល់ថ្ងៃជីវិតអវសាន ។ នៅពេលនោះ, នាទីនៃព្រះសូរិយាអស្ដង្គតបានខិតមកជិតដល់ទៅហើយ, ដោយហេតុថាពេលវេលាក៏បានកន្លងទៅអស់ច្រើនណាស់ទៅហើយដែរ តាំងតែពីយើងបានចូលមកក្នុងទីនោះ ។ ពេលគាត់ដើរចេញត្រឡប់មកវិញ... គាត់ក៏បានមកអង្គុយក្នុងចំណោមពួកយើងដដែល... ក៏ប៉ុន្តែពាក្យសំដីឆ្លងឆ្លើយគ្នាពុំសូវមានទៀតទេ ។ មិនយូរប៉ុន្មាន មេគុកក៏បានដើរចូលមកឈរនៅក្បែររូបគាត់,ហើយពោលថា ៖ « ចំពោះលោកគ្រូសូក្រាត, ដែលខ្ញុំធ្លាប់បានស្គាល់ថា ជាមនុស្សថ្លៃថ្នូរ, ជាមនុស្សដ៏សភាពរាបសារ, ជាមនុស្សដ៏ល្អប្រសើរជាទីបំផុត ក្នុងចំណោមពពួកមនុស្សដែលធ្លាប់បានមកកាន់ទីកន្លែងនេះ, ខ្ញុំជឿជាក់ថាលោកគ្រូពុំមាននមនោសញ្ចេតនាក្ដៅក្រហាយដូចពួកមនុស្សឯទៀតៗទេ, ដែលមានសេចក្ដីក្រេវក្រោធច្រឡោតខឹងព្រមទាំងប្រទេចផ្ដាសារមកលើរូបខ្ញុំ នៅពេលដែលខ្ញុំបានបញ្ជាឲ្យពួកគេផឹកថ្នាំពុលក្រោមសេចក្ដីសម្រេចរបស់រដ្ឋាភិបាល ។ ជាការពិតណាស់, ខ្ញុំដឹងថាលោកគ្រូច្បាស់ជាគ្មានកំហឹងចំពោះរូបខ្ញុំសោះឡើយ។ ពីព្រោះ ដូចលោកគ្រូក៏បានជ្រាបស្រាប់រួចហើយដែរ, គឺជាអ្នកដទៃទេពុំមែនរូបខ្ញុំទេ... ដែលជាដើមហេតុនៃរឿងនេះ ។ ដូច្នេះ ខ្ញុំសូមជូនពរឲ្យលោកគ្រូបានសុខសប្បាយហើយសូមឲ្យលោកគ្រូបានទទួលសេចក្ដីឈឺចាប់ដ៏តិចតួចជាទីបំផុត នៅក្នុងរឿងដ៏ជាចាំបាច់នេះ។ លោកគ្រូបានស្គាល់ដំណើរបេសកកម្មរបស់ខ្ញុំរួចហើយ » ។ រំពេជនោះស្រាប់តែគាត់នេះស្រែកទួញយំស្រក់ទឹកភ្នែករហាមរួចដើរចេញទៅក្រៅបាត់ ។

សូក្រាតតាមមើលគាត់នេះ ហើយពោលថា ៖ « ខ្ញុំក៏សូមជូនពរឲ្យលោកបានសុខសប្បាយផងដែរ ហើយនឹងធ្វើអ្វីៗតាមដែលលោកបានបង្គាប់បញ្ជា...» ។ បន្ទាប់មក, លោកគ្រូបែរមុខមករកពួកយើង ហើយពោលថា ៖ « មនុស្សម្នាក់នេះបានចំជាមាននិស្ស័យគួរឲ្យចូលចិត្តមែន។ តាំងតែពីថ្ងៃដែលខ្ញុំបានចូលមកក្នុងគុកនេះ គាត់តែងតែបានមកសួរសុខទុក្ខចំពោះខ្ញុំជារៀងរាល់ថ្ងៃ, ហើយឥឡូវ មើលចុះ

តើដោយធម៌មេត្តាករុណាបែបយ៉ាងណាដែរ ដែលគាត់កំពុងមានសេចក្ដីអាណិតអាសូរដល់រូបខ្ញុំនេះ ។ ក៏ប៉ុន្តែ យើងត្រូវតែធ្វើតាមគាត់ប្រាប់ គ្រីតូ ។ ចូរទៅយកកែវថ្នាំមក...បើឧបមាថាថ្នាំពុលរៀបចំរួចហើយ ។ បើពុំដូច្នោះទេ គួរតែឲ្យលោកមេគុករៀបចំផ្សំថ្នាំឲ្យហើយទៅ » ។

« កុំអាលសិន, គ្រីតូពោល ...ថ្ងៃទើបតែជ្រេគងភ្នំទេតើ ។ ហើយមានមនុស្សច្រើនគ្នាណាស់ពីមុនលោកគ្រូ ដែលបានពន្យឺតពេលវេលាដល់ដំណាក់ការចុងក្រោយបំផុតដើម្បីផឹកថ្នាំពុល ។ ហើយបន្ទាប់ពីត្រូវគេបានប្រកាសឲ្យស្លាប់ហើយ ...ពួកអ្នកទាំងនោះនៅឆ្លៀតស៊ីផឹក..ហើយបានត្រេកត្រអាលសប្បាយក្នុងអង្គកាយបានមួយសេរី ។ ម្ល៉ោះហើយសូមកុំប្រញាប់ខ្លាំងពេកព្រោះវានៅសល់ពេលវេលាខ្លះដែរ ។

« សូក្រាតពោល ៖ « អីចឹងហើយគ្រីតូ, ហើយពួកដែលលោកទើបបាននិយាយនេះ មានគំនិតត្រឹមត្រូវពិតមែនក្នុងការធ្វើដូច្នេះ, ពីព្រោះពួកគេយល់ថា គេបានចំណេញដោយសារតែការពន្យឺតពេលនៃសេចក្ដីស្លាប់។ ក៏ប៉ុន្តែចំពោះខ្លួនខ្ញុំៗក៏បានគិតត្រិមត្រូវដែរដោយសារតែមិនព្រមធ្វើតាមបែបនេះវិញ, ពីព្រោះខ្ញុំយល់ឃើញថាខ្ញុំគ្មានបានចំណេញអ្វីទេក្នុងការផឹកថ្នាំពុលក្រោយពេលវេលាបន្តិចបន្តួច ។ គួរអ្វីខ្ញុំត្រូវរក្សាការពារជីវិតមួយដែលបានរត់ចេញបាត់ទៅហើយនោះ ។ ធ្វើដូច្នេះទៅខ្ញុំគ្រាន់តែអាចផ្ទុះសំណើចដាក់លើរូបខ្លួនឯងតែប៉ុណ្ណោះ។ ដូច្នេះ ខ្ញុំសូមអង្វរ..សូមធ្វើតាមខ្ញុំប្រាប់... ហើយសូមកុំបដិសេធចំពោះរូបខ្ញុំឲ្យសោះ ! »

« ឮដូច្នោះ គ្រីតូក៏បានធ្វើសញ្ញាទៅឲ្យឈ្នួលបម្រើម្នាក់ ។ ហើយឈ្នួលបម្រើនោះ ក៏បានដើរចូលទៅក្នុងបាត់ខ្លួនមួយសន្ទុះធំ ។ ហើយនៅពេលត្រឡប់មកវិញគេដើរជាមួយនឹងមេឆ្មាំគុកដែលបានយកថ្នាំពុលមួយកែវមកផង ។ សូក្រាតក៏បានពោលថា ៖ «..ឱ! ប្រិយមិត្តរបស់ខ្ញុំ, លោកដែលជាអ្នកមានការពិសោធន៍នៅក្នុងរឿងនេះ, សូមប្រាប់ខ្ញុំផងអំពីរបៀបប្រើយ៉ាងណាដើម្បីឲ្យមានប្រសិទ្ធភាព..» ។ បុរសនោះក៏បានឆ្លើយថា ៖ «... លោកគ្រូគ្រាន់តែដើរចុះឡើង រហូតដល់ជើងលោកគ្រូឡើងស្ពឹក...រួចលោកគ្រូសណ្ដូកខ្លួនដេកទៅ ថ្នាំពុលក៏វានឹងចាប់ផ្ដើមធ្វើការជាស្រេច » ។ នៅក្នុងពេលជាមួយគ្នានោះ បុរសក៏បានហុចកែវទៅសូក្រាត, ដែលនៅក្នុងអាកប្បកិរិយាស្រួលបួលបែបរំភើយ ហើយនិងតាមរបៀបគួរសមជាទីបំផុត, ដោយគ្មានសំដែងការភ័យខ្លាចឬផ្លាស់ប្ដូរទឹកមុខតែបន្តិចបន្តួចក៏គ្មានផង, ហើយដោយសម្លឹងមើលចូលក្នុងក្រសែភ្នែករបស់បុរស, ដូចដែលគាត់បានធ្វើសព្វមួយដង, ក៏ទទួលយកកែវថ្នាំហើយពោលថា ៖ « តើលោកយល់យ៉ាងណាដែរ បើខ្ញុំប្រសិទ្ធពរជ័យនូវថ្នាំនេះ (ចាក់បន្តិច) ថ្វាយព្រះ ? តើខ្ញុំអាចធ្វើបាន ឬមិនបាន ? » ។ បុរសបានឆ្លើយថា ៖ «យើងគ្រាន់តែជាអ្នកផ្សំថ្នាំតែប៉ុណ្ណោះទេ, លោកគ្រូសូក្រាត, យើង

ចេះត្រឹមតែកិរិតវិនិច្ឆ័យយ៉ាងណាឲ្យបានគ្រប់គ្រាន់ប៉ុណ្ណោះឯង» ។ «ខ្ញុំយល់ហើយ, គាត់ពោល, ទោះយ៉ាងនេះក្តី ខ្ញុំសូមបន់ព្រះសំពះទេព្តា ដើម្បីជួយឲ្យកិច្ចការធ្វើដំណើររបស់ខ្ញុំ បានចំរុងចំរើន ពីពិភពនេះទៅកាន់ពិភពខាងមុខ- សូមព្រះប្រទានពរឲ្យសំណើររបស់ខ្ញុំនេះ បានសម្រេចដូចសេចក្តីប្រាថ្នាទៅហោង» ។ ថាដូច្នេះហើយ ដោយលើកកែវដល់ត្រឹមកំពស់បបូរមាត់របស់គាត់... ដោយមានសេចក្តីប្រុងប្រៀបមុនជាស្រេច និងដោយសេចក្តីសប្បាយពេកពន់ គាត់ក៏បានចាប់ផ្តើមផឹកថ្នាំពុលក្អឹកៗ...។

« ហើយមកទល់ពេលនេះ, ពួកយើងទាំងអស់គ្នានៅមានលទ្ធភាពអាចទប់ទល់នឹងទម្ងន់ទុក្ខព្រួយនិងសេចក្តីសោកសង្រេងបានខ្លះៗនៅឡើយ ។ ក៏ប៉ុន្តែនៅពេលដែលពួកយើងបានឃើញរូបគាត់ផឹកថ្នាំពុល មិនត្រឹមតែប៉ុណ្ណោះបានឃើញគាត់ផឹកអស់រលីងពីកែវទៀតផង, ពួកយើងក៏លែងទ្រាំទ្រនឹងទិដ្ឋភាពនេះបានតទៅទៀត, ចំណែកខ្លួនខ្ញុំផ្ទាល់ ( ប្លាតុង ) ...បើទោះជាខ្ញុំខំប្រឹងទប់ទល់យ៉ាងណាក៏ដោយក៏ទឹកភ្នែកហូរចេញមកខ្វាយដោយមិនដឹងខ្លួន។ ខ្ញុំក៏ខ្ទប់មុខស្រែកទួញយំតែម្តង ។ គឺមិនមែនខ្ញុំយំចំពោះសេចក្តីស្លាប់របស់គាត់នោះទេ..ក៏ប៉ុន្តែខ្ញុំយំស្រណោះអនិច្ចាវាសនាអភ័ព្វរបស់ខ្លួនឯងដែលត្រូវបាត់បង់ប្រិយមិត្តដ៏មហាប្រសើរបែបនេះ។ ហើយមិនមែនរូបខ្ញុំនោះទេ មនុស្សទី១ដែលយំនៅពេលនោះ ។ គ្រីតូ ដោយទប់ទឹកភ្នែកខ្លួនឯងមិនបាន ក៏ដើរចាកចេញឆ្ងាយពីទីនោះ ... ខ្លួនខ្ញុំក៏បានដើរតាមពីក្រោយគាត់នេះផងដែរ ។ ស្រាប់តែនៅក្នុងពេលនោះ អាប៉ូឡូដ៏រស់ ដែលយំពេបស្បែបអណ្តឹតអណ្តក់សឹងគ្រប់ពេលវេលាទៅហើយ... បានចាប់ផ្តើមស្រែកទ្រហោយំខ្លាំងមែនទែន បណ្តាលឲ្យពួកយើងទាំងអស់គ្នាព្រឺក្បាលសំពោងសំពាយ ។ មានតែសូក្រាតតែម្នាក់ឯងប៉ុណ្ណោះដែលរក្សាអាកប្បកិរិយានឹងថ្កល់នៅកណ្តាលសោកនាដកម្មនេះ ៖ «ម្តេចបានជាមានសម្រែកអ្វីដ៏ចម្លែកម្ល៉េះ, គាត់ពោល, ខ្ញុំបានបញ្ជូនស្រីៗឲ្យទៅផ្ទះដើម្បីមិនចង់ឲ្យមានការរំខានបែបនេះ, ដោយខ្ញុំធ្លាប់បានឮគេថាមនុស្សយើងគួរតែស្លាប់ដោយមានការស្ងប់ស្ងៀមនៅក្នុងអារម្មណ៍ ។ ដូច្នេះ សូមអស់លោករក្សាការស្ងៀមស្ងាត់បន្តិចផងទៅ សូមអស់លោកមេត្តាចេះអត់ទ្រាំបន្តិចផងទៅ ។ នៅពេលដែលយើងបានឮពាក្យទាំងនេះ ពួកយើងមានសេចក្តីអៀនខ្មាស់យ៉ាងខ្លាំងគ្រប់ៗគ្នាហើយខំទប់ទឹកភ្នែករៀងៗខ្លួន ។ រួចហើយ គាត់ក៏ដើរចុះឡើងរហូតដល់ពេលមួយ, ដូចតាម សំដីរបស់គាត់ផ្ទាល់, ថាគាត់កំពុងធ្លាក់ជើង ។ គាត់ក៏ដាក់ខ្លួនសណ្តូក ដេកនៅលើខ្នង... ដោយធ្វើតាមគេប្រាប់ ។ ហើយបុរសដែលបានផ្តល់ថ្នាំពុលចំពោះរូបគាត់នោះ ក៏សម្លឹងមើលទៅជើងនិងទៅភ្លៅរបស់គាត់។ ហើយបន្ទាប់ពីជននេះបានសង្កត់ទៅលើជើងរបស់គាត់យ៉ាងខ្លាំង ហើយសួរគាត់ថា តើគាត់មានដឹង (ឈឺ) ឬ

ទេ ? ហើយគាត់ក៏បានឆ្លើយថា«ទេ» ។ ជននោះ ក៏សង្កត់កំភួនជើងឡើងរហូតដល់ភ្លៅរបស់គាត់ហើយចេះតែសង្កត់ឡើងលើតទៅទៀត, ហើយជននោះ ក៏បានបង្ហាញដល់ពួកយើងថាអង្គកាយរបស់គាត់ឡើងត្រជាក់ ហើយមានអាការៈរឹងកំព្រឹស ។ បន្ទាប់មក សូក្រាតដែលនៅដឹងរឿងនេះពីខ្លួនគាត់បានពោលថា ៖ « ពេលណាថ្នាំពុលចូលដល់ក្នុងបេះដូងកាលណាពេលនោះសេចក្ដីចប់នឹងមកដល់ » ។ គាត់មានសភាពត្រជាក់នៅត្រង់កន្លែងចង្កេះ នៅពេលដែលគាត់ចាប់ផ្ដើមបើកកន្សែងដែលគ្របមុខរបស់គាត់ចេញ ( ពីព្រោះគាត់បានគ្រលំខ្លួនឯងនៅផ្នែកខាងលើ ) ហើយគាត់ពោលថា ៖ « គ្រីតូ, ខ្ញុំនៅជំពាក់មាន់គកមួយចំពោះអាសក្លេបព្យូស, សូមលោកកុំភ្លេចសងបំណុលរបស់ខ្ញុំផងបានទេ ? ».. «បំណុលនេះ នឹងត្រូវផាត់សង, គ្រីតូពោល... តើមាននៅសល់អ្វីទៀតទេ? »...។ គេពុំមានឮសម្លេងតបឆ្លើយអ្វីសោះចំពោះសំនួរចុងក្រោយនេះ ក៏ប៉ុន្តែចំនួនមួយនាទីក្រោយមក គេបានឮសម្លេងរើបំរះពីរដង។ មេគុកក៏បើកមុខគាត់មើល។ ភ្នែករបស់គាត់សម្លឹងគ្មានបប្រិចឡើងទៅលើទៅហើយ ។ គ្រីតូក៏បានបិទភ្នែកនិងមាត់របស់គាត់ទៅហោង ។

« នេះហើយ ជានាទីចប់នៃមហាមិត្តរបស់យើង , ដែលខ្ញុំអាចប្រសិទ្ធិនាមដោយពិតប្រាកដគ្មានភ័ន្តច្រឡំបានថាជាមនុស្សដ៏មានបញ្ញាខ្ពង់ខ្ពស់, មានវិចារណញ្ញាណដ៏ឧត្តុង្គឧត្តម, ជាមនុស្សប្រកបដោយគតិយុត្តិធ៌មជាមនុស្សដ៏មហាប្រសើរលើសលែងអស់ទាំងមនុស្សនានាដែលខ្ញុំធ្លាប់បានស្គាល់មកទល់ពេលនេះ... តាំងពីខ្ញុំមានកំណើតដឹងក្ដីកាលណាមកនៅលើភពផែនដី » ។

( « **Plato - The Story of Philosophy, by Will Durant, Pages 11, 12 & 13** »)...

○○○

# ជីវិតរបស់សូឡុង
# SOLON

មានកំណើតនៅឆ្នាំទី៣នៃអូឡាំព្យ៉ាដទី៣៥ ( អូឡាំព្យ៉ាដ ៖ រយៈវេលាបួនឆ្នាំដែលនៅចន្លោះកីឡាអឺឡាំពីក ) ។ ធ្លាប់ធ្វើការជាចៅក្រមនៅទីក្រុងអាតែ្មននៅឆ្នាំទី៣នៃអូឡាំព្យ៉ាដទី៤៥, បានទទួលមរណភាពនៅអូឡាំព្យ៉ាដទី៥៥ នៅក្នុងអាយុ៧៨ឆ្នាំ ។

សូឡុងដែលមានដើមកំណើតពូជអំបូរនៅទីក្រុងអាតែ្មន... បានកើតនៅសាឡាមីន នៅអូឡាំព្យ៉ាដទី៣៥ ។ ឪពុករបស់គាត់ជាចៅរបស់ស្តេចសូឌ្រុស ចំណែកម្តាយរបស់គាត់ជាបងជីដូនមួយ (ផ្នែកខាងម្តាយ) ជាមួយនឹងម្តាយរបស់ពីស៊ីសត្រាត ។ គាត់បានចំណាយពេលមួយភាគធំក្នុងយុវវ័យរបស់គាត់ ដើម្បីធ្វើដំណើរទៅប្រទេសអេយីព្ទ... ដោយហេតុថាក្នុងសម័យនោះ ប្រទេសនេះជាទីកន្លែងប្រជុំនៃអ្នកចេះដឹង ។ បន្ទាប់ពីបានរៀនសូត្រអំពីរបៀបគ្រប់គ្រងរដ្ឋាភិបាលច្រើនប្រភេទ... និងពីអ្វីៗទាំងអស់ដែលទាក់ទងនឹងច្បាប់ទម្លាប់នៃប្រទេសនេះ គាត់បានត្រឡប់មកក្រុងអាតែ្មនវិញ ដែលនៅទីនោះ ចំណេះវិជ្ជាដ៏ជ្រៅជ្រះរបស់គាត់ព្រមទាំងពូជអំបូរដ៏ខ្ពង់ខ្ពស់របស់គាត់បានធ្វើឲ្យគាត់ទទួលកាន់កាប់តំណែងដ៏សំខាន់ៗនៅក្នុងរដ្ឋាភិបាល ។

សូឡុងជាបុរសម្នាក់ប្រកបដោយបញ្ញាខ្ពង់ខ្ពស់, មានកម្លាំងកំហែងកាយសម្បទារឹងប៉ឹង, ឆន្ទៈមោះមុតនិងសេចក្តីស្មោះត្រង់ ។ គាត់ជាវាគ្មិនម្នាក់ដ៏ពូកែ, ជាអ្នកកវី, ជាអ្នកតែងច្បាប់ក្រមព្រមទាំងជាអ្នកធ្វើសិកសង្គ្រាមផង ។ ពេញមួយជីវិតរបស់គាត់ៗបានខំប្រឹងប្រែងខ្នះខ្នែងជួយរកសេរីភាពឲ្យប្រទេសជាតិរបស់គាត់ ។ សូឡុងជាខ្មាំងសត្រូវរបស់ពពួកជនល្មោភអំណាចផ្តាច់ការ... មិនត្រឹមតែប៉ុណ្ណោះមិនសូវរវីរវល់ក្នុងការស្វែងរកទ្រព្យសម្បត្តិ ដើម្បីពង្រីកពង្រឹងគ្រួសាររបស់គាត់នោះទេ ។ ដូចតាល្ហែសផងដែរ គាត់មិនដែលបានជាប់ចិត្តដើរតាមបំរើគ្រូបាធ្យាយន៍ណាម្នាក់ផងដែរ ។ គាត់មិនសូវបានយកចិត្តទុកដាក់និងរឿងអាថ៌កំបាំងរបស់ធម្មជាតិនោះឡើយ ប៉ុន្តែបានចាប់អារម្មណ៍តែក្នុងរឿងសីលធម៌ និងរឿងនយោបាយទៅវិញ ។ គឺគាត់នេះហើយដែលបាននិពន្ធសុភាសិតមួយដ៏ល្អប្រពៃ ៖ « នៅគ្រប់មុខវិជ្ជា គេត្រូវមានការចេះដឹងតែល្មមៗបានហើយ »...

ថ្ងៃមួយសូឡុងបានធ្វើដំណើរទៅមីឡេត៍ ដោយគាត់ត្រូវទាក់ទាញដោយកេរ្តិ៍ឈ្មោះល្បីរបស់តាល្លែស ហាក់ដូចជាមន្តស្នេហ៍ បន្ទាប់ពីមានការពិភាក្សាអស់មួយរយៈពេលជាមួយនឹងទស្សនវិទូក្រោយនេះ គាត់ក៏បាននិយាយទៅកាន់ត្ថាលែសថា ៖ « ឱ! ត្ថាលែស... ខ្ញុំមានសេចក្តីងឿងឆ្ងល់ខ្លាំងណាស់, ហេតុអ្វីបានជាលោកមិនព្រមរៀបការសោះ; ពីព្រោះពេលនោះលោកច្បាស់ជាមានកូនចៅ ដែលលោកមានការសប្បាយនឹងចិញ្ចឹមឲ្យធំធាត់... » ។

ក្នុងពេលភ្លាមនោះ ត្ថាលែសពុំបានឆ្លើយថាអ្វីទាំងអស់ ។ បីបួនថ្ងៃបន្ទាប់មកគាត់ក៏បានបញ្ជាឲ្យបុរសម្នាក់ក្លែងខ្លួនហាក់ដូចជាជនបរទេស ដែលមកលេងពួកគាត់ ។ ជននេះបានអះអាងថា ខ្លួនគេទើបនឹងធ្វើដំណើរមកពីទីក្រុងអាត្មែនថ្មីៗ ។

– នែ, សូឡុងសួរអ្នកដំណើរ, តើមានរឿងអ្វីប្លែកកើតឡើងឬទេ ?

– គ្មានរឿងអ្វីទេបើតាមខ្ញុំដឹង, បុរសចម្លែកបានពោល, ក្រៅតែពីសពយុវជនម្នាក់ ដែលមនុស្សទាំងឡាយនៅទីក្រុងអាត្មែន នាំគ្នាហែរយកទៅធ្វើបុណ្យ... គឺដោយហេតុថាយុវជននោះជាកូនអ្នកមានពូជអំបូរខ្ពស់ ។ គឺជាកូនប្រុសរបស់មនុស្សម្នាក់ ដែលគេនាំគ្នាស្រឡាញ់ពេញស្រុក ហើយគាប់ជួនអ្វីបុរសនោះក៏កំពុងតែនៅក្រៅក្រុងអាត្មែនថែមទៅទៀត អស់ចំនួនមួយរយៈពេលមកហើយ ។ ម៉្លោះហើយមិត្តភក្តិរបស់គាត់គ្រប់គ្នា ក៏បានសំរេចថាលាក់រឿងនេះមិនឲ្យគាត់ដឹង ដោយខ្លាចបារម្ភថា រឿងដ៏ខ្លោចផ្សារនេះអាចធ្វើឲ្យគាត់ឈឺស្លាប់...

– ឱ! ឪពុកអ្វីក៏អភ័ព្វម៉្លេះ... សូឡុងបានឧទានឡើងខ្លាំងៗ, តើគាត់នោះឈ្មោះអ្វីទៅ ? ។

– ខ្ញុំឮគេនិយាយឈ្មោះគាត់ដែរតែខ្ញុំមិនចាំ, ជនអ្នកធ្វើដំណើរបានឆ្លើយតប, ខ្ញុំគ្រាន់តែដឹងថា នេះបើយោងតាមសំដីអ្នកផង ថាជាបុរសម្នាក់មានប្រាជ្ញាខ្ពស់ខ្ពស់ណាស់...

សូឡុងដែលកាន់តែមានការថប់បារម្ភខ្លាំងឡើងៗ មានស្មារតីវង្វេងវង្វាន់អស់ទៅហើយ ។ ទ្រាំមិនបានគាត់ក៏លាន់មាត់ថា ប្រហែលជាសូឡុងទេដឹង ។ បុរសចម្លែកក៏ឆ្លើយតបភ្លាមមួយរំពេចថា ៖ « ហ្នឹងហើយគឺឈ្មោះគាត់នេះហើយ » ឮដូច្នោះភ្លាមសូឡុងក៏មានអាការៈឈឺចាប់ពន់ប្រមាណ រហូតដល់ហែកសំលៀកបំពាក់របស់គាត់ ។ គាត់បោចខ្ញាំសក់ និងវាយតប់ក្បាលរបស់ខ្លួនឯង ! ។

– ម្តេចបានជាយំហើយកើតទុក្ខអ្វីដ៏ម្លឹងៗ, ត្ថាលែសពោលទៅកាន់រូបគាត់, ចំពោះការខូចខាតមួយដែលទឹកភ្នែកមួយក្រោមមេឃនេះ មិនអាចជួយកែកុនបាន ។

– អនិច្ចា! ចម្លើយរបស់សូឡុង, មកពីហេតុដូច្នេះហើយដែលបណ្តាលឲ្យខ្ញុំយំ... ខ្ញុំយំសោកនឹងវិបត្តិមួយដែលគ្មានឱសថអ្វីអាចមើលជាបាន ។

នៅទីបញ្ចប់ ត្លាលែសក៏បានសើចពីអាកប្បកិរិយាសំដែងទុក្ខព្រួយទាំងប៉ុន្មានរបស់សូឡុង...

– ឱ! សូឡុង... មិត្តសំឡាញ់របស់ខ្ញុំ, ត្លាលែសពោល... គឺមកពីបុព្វហេតុនេះហើយដែលធ្វើឲ្យខ្ញុំភ័យខ្លាចរឿងរៀបអាពាហ៍ពិពាហ៍ដល់ម្ល៉េះ... ខ្ញុំខ្លាចនឹមនៃចំណងមេត្រីរវាងប្តីប្រពន្ធ ពីព្រោះខ្ញុំបានដឹងច្បាស់ណាស់ ពីសេចក្តីឈឺចាប់របស់បុរសម្នាក់ដ៏មានប្រាជ្ញាជាងគេ ក្នុងចំណោមបុរសទាំងឡាយថា... ទោះជាមនុស្សមានចិត្តរឹងប៉ឹងយ៉ាងណាក៏ដោយ ក៏មិនអាចទប់ទល់ជាប់នឹងសេចក្តីឈឺចាប់ដែលកើតឡើងមកពីសេចក្តីស្នេហា ហើយនិងពីការថែទាំរក្សាកូនចៅសាច់ឈាម ។ ចូរឯងឈប់ព្រួយបារម្ភពីរឿងនេះទៅ ពីព្រោះរឿងទាំងអស់ដែលគេបាននិយាយប្រាប់ឯង គឺជារឿងភរភូតដែលគេបានគ្រោងទុកសំរាប់សើចលេងតែប៉ុណ្ណោះ ។

★ ★

★

ជាយូរយារណាស់មកហើយ មានកើតសង្គ្រាមមួយយ៉ាងឃោរឃៅ រវាងពួកប្រជាជននៅទីក្រុងអាតែ្មន និងពួកអ្នកស្រុកមេក្ការី ដែលប្រកាប់ប្រចាក់គ្នាស្លាប់រស់តណ្តើមយកកោះសាឡាមីន ។ នៅចុងបញ្ចប់, បន្ទាប់ពីមានការវាយប្រហារស្លាប់ស្អេកស្កះនៅក្នុងក្រុមទាំងសង្ខាង... ពួកអ្នកទីក្រុងអាតែ្មន ដោយចាញ់ប្រៀបគេផង ដោយធុញថប់នឹងការបង្ហូរឈាមផង ក៏បានបង្គាប់បញ្ជាឲ្យផ្តន្ទាទោសដល់ស្លាប់ ចំពោះជនទី១ណាម្នាក់ដែលមានការព្រហើនហ៊ានស្នើរឲ្យបង្កើតសង្គ្រាមដណ្តើមយកកោះសាឡាមីន ដែលពួកប្រជាជនមេក្ការីកំពុងតែកាន់កាប់ ។ សូឡុងក៏មានការព្រួយបារម្ភថា ក្នុងរឿងនេះប្រសិនបើគាត់ហារមាត់និយាយ នឹងអាចនាំទុក្ខទោសដល់ខ្លួនឯង ក៏ប៉ុន្តែបើគាត់នៅស្ងៀមវិញ វានឹងអាចធ្វើឲ្យបង់ខាតដល់ប្រជាជាតិរបស់គាត់ ។ ម្ល៉ោះហើយគាត់ក៏បានសំរេចចិត្តក្លែងខ្លួនធ្វើជាមនុស្សឆ្កួត ដើម្បីអាចនិយាយស្តីថាយ៉ាងណាក៏បាន ព្រមទាំងប្រព្រឹត្តអាកប្បកិរិយាបែបណាក៏បានទាំងអស់ដោយគ្មានទោសពៃរ៍អ្វី ។ គាត់ក៏បានឲ្យគេផ្សាយពាសពេញទីក្រុងថាខ្លួនគាត់មានការឡប់សតិខូចស្មារតីអស់រលីងទៅហើយ ។ បន្ទាប់ពីបានតែងកំណាព្យដ៏កំសត់ ពោរពេញទៅដោយមនោសញ្ចេតនាអាណិតអានាថខ្លួនឯង ដែលគាត់បានទន្ទេញច្រើនដងរហូតដល់ចាំមាត់ គាត់ក៏បានដើរចេញពីផ្ទះ ដោយសំលៀកបំពាក់ក្រខ្វក់និងរហែករហុយ ។ គាត់មានខ្សែដែលគាត់ពាក់ព្យួរជាប់នឹងកខ្លួនឯង ព្រមទាំងពាក់មួកកំពូលស្រួចមួយដែលពោរពេញទៅដោយក្អែល ។ ពលរដ្ឋជាច្រើនរូបក៏បានប្រមូលផ្តុំគ្នាចោមរោមជុំវិញរូបគាត់ ។ សូឡុងក៏ឡើងឈរលើដុំថ្មមួយ ដែលតាមទម្លាប់គេប្រើសំរាប់ប្រកាសដំណឹងជាសាធារណៈ ហើយគាត់

ក៏ចាប់ផ្ដើមសូត្រកំណាព្យដែលជាការខុសប្លែកពីទម្លាប់ធម្មតារបស់គាត់ ៖

– គឺជាភ័ព្វអាក្រក់ណាស់សំរាប់រូបខ្ញុំ, សូឡុងបានស្រែកដង្ហោយនៅចំពោះមុខអ្នកផង, ដែលក្រុងអាតែ្ថនជាស្រុកកំណើតរបស់ខ្ញុំ... ឱ! ខ្ញុំគួរតែកើតនៅហ្វូឡេ-ក្លង់ដេ ឬនៅសីយ៉ែន ឬក៏នៅទីកន្លែងណាអាក្រក់សាមាន្យ ព្រៃផ្សៃយ៉ាងណាក៏បានដែរ ដូចម្ដេចក៏គ្រាន់បើជាងក្រុងអាតែ្ថន : ពីព្រោះខ្ញុំមិនចង់ឲ្យគេចង្អុលមុខខ្ញុំថាអាគាត់នេះជាជនជាតិអាតែ្ថនដែលបានរត់ប្រាស់អាយុ យ៉ាងគួរឲ្យអៀនខ្មាស់ពីសាឡាមីន ។ ពួកយើងត្រូវតែសងសឹកភ្លាមមួយរំពេជ ចំពោះការប្រមាថដែលយើងទើបនឹងបានទទួល... ហើយត្រូវកាន់កាប់កន្លែងសប្បាយក្សេមក្សាន្តមួយ ដែលពួកសត្រូវយើងបានដណ្ដើមយកទៅដោយអយុត្តិធម៌ ។

ពាក្យនេះបានបណ្ដាលឲ្យពួកអ្នកនៅទីក្រុងអាតែ្ថនមានសេចក្ដីរំភើបយ៉ាងខ្លាំង ។ ពួកគេក៏ភ្ញាក់រលឹកស្មារតី រួចនាំគ្នាកែប្រែក្រឹត្យបញ្ញត្តិរបស់ពួកគេ ។ ពួកគេនាំគ្នាកាន់អាវុធព្រមគ្នាឡើង ហើយបានសំរេចចិត្តយ៉ាងមុតមាំធ្វើសង្គ្រាមប្រឆាំងនឹងពួកមេហ្គារីឡើងវិញ ។

សូឡុងក៏បានត្រូវគេជ្រើសរើសធ្វើជាមេបញ្ជាការកងទ័ព ។ គាត់និងកូនចៅរបស់គាត់បានចុះធ្វើដំណើរក្នុងទូកនេសាទជាច្រើន... មានទូកសង្គ្រាមមួយដែលមានអ្នកចែវ៣៦នាក់មកតាមពីក្រោយ ។ គាត់មកឈប់សំកាំងមិនឆ្ងាយប៉ុន្មានពីសាឡាមីន ។ ពួកមេហ្គារី ( ជនជាតិស្ប៉ារតឺ... ដែលសុទ្ធសឹងជាពួកក្រិកដូចជាជនជាតិអាតែ្ថនផងដែរ ) ហាក់ដូចជាដឹងថាមានរឿងអ្វីកើតឡើង ក៏នាំគ្នារត់ព្រោងព្រាតក្នុងសភាពអារាត់អារាយទៅរកកាន់អាវុធរៀងខ្លួន ។ ពួកគេបានស្រាយនាវារបស់គេមួយ ហើយបញ្ជូនឲ្យទៅមើលដល់កន្លែងកើតហេតុ ដើម្បីគ្រាន់ដឹងឲ្យច្បាស់ថាតើមានរឿងអ្វីកើតឡើង ។ នាវានោះក៏បានខិតចូលទៅជិតក្បែរមែនទែន ជាហេតុបណ្ដាលឲ្យសូឡុងចាប់ឃាត់បាន ។

សូឡុងក៏បានបញ្ជាឲ្យចាប់ចង់ពួកមេហ្គារីដែលនៅក្នុងទូកនោះទាំងអស់ ។ គាត់ក៏បានយកអ្នកក្លាហាននៃទីក្រុងអាតែ្ថនជាច្រើននាក់ទៅដាក់បញ្ចូលជំនួស ហើ-យបង្គាប់បញ្ជាឲ្យពួកនេះបើកក្ដោងឆ្ពោះទៅសាឡាមីន ដោយលបលាក់ឲ្យបានយូរជាទីបំផុត ។ សូឡុងបាននាំទៅជាមួយគាត់ នូវពួកយុទ្ធជនដែលសេសសល់ ហើយបានចូលទៅក្នុងដីកោះតាមកន្លែងមួយផ្សេង ។

សូឡុងបានពើបប្រទះនឹងពួកមេហ្គារី ដែលលើកគ្នាមកប្រយុទ្ធយ៉ាងគឹកកង ក៏ប៉ុន្តែនៅពេលដែលពួកគេកំពុងតែជាប់ដៃគ្នា... ពួកក្រុមអ្នកក្លាហានដែលសូឡុងបានបញ្ជូនមួយនាវាតែឯកឯង ក៏បានមកដល់ដីកោះដែរ ហើយវាយដណ្ដើមយកបានទីក្រុងទាំងមូលជាចំណុះ ។ សូឡុងបន្ទាប់ពីបានទម្លាក់អាវុធពួកមេហ្គារីរួចហេ

ិយ ក៏បានបញ្ជូនពួកអ្នកទោសសង្គ្រាមឲ្យត្រឡប់ទៅស្រុកខ្លួនវិញ ដោយគ្មានទាមទារយកថ្លៃថ្នូរអ្វីទាំងអស់ ។ បន្ទាប់មក គាត់ក៏បានសង់វិហារនៃសង្គ្រាមមួយសំរាប់ថ្វាយព្រះអង្គារ ( ព្រះអាទិទេពនៃជនជាតិក្រិក, ជានិមិត្តរូបនៃសង្គ្រាម ) នៅចំត្រង់កន្លែងដែលគាត់បានទទួលជោគជ័យ...

ក្នុងរយៈវេលាបន្ទាប់មក ពួកក្រុមមេក្លារីដ៏រឹងរូសក៏បានសាកល្បងលើកទ័ពមកវាយតណ្ដើមយកកោះសាឡាមីនវិញ ក៏ប៉ុន្តែជាការឥតអំពើ នៅទីបំផុត ពួកក្រុមចំបាំងទាំងសង្ខាង បានសុខចិត្តលើកយករឿងជម្លោះរបស់ខ្លួនប្រគល់ទៅឲ្យពួកឡាសេដេម៉ូន ( Lacédémoniens ) ជាអ្នកកាត់សេចក្ដី ។ នៅពេលនោះ សូឡុងក៏បានបង្ហាញភស្តុតាងដ៏ជាក់ស្ដែងនៅចំពោះមុខក្រុមអ្នកតំណាងរាស្ត្រដែលមកពីស្ប៉ារតឺ ( Sparte ) ថាហ្វីលុសហើយនិងអឺរីហ្សាស ដែលជាកូនរបស់អាយ៉ាក្សស្ដេចនៅសាឡាមីន បានធ្លាប់មករស់នៅក្នុងក្រុងអាត្អែនកាលក្នុងអតិតកាល, ហើយអ្នកទាំងពីរក៏បានប្រគល់កោះនេះ មកឲ្យពួកអ្នករស់នៅទីក្រុងនេះរួចហើយ ។ គាត់ក៏បានបញ្ជាឲ្យគេបើកផ្នូរខ្មោចជាច្រើន ហើយបានបង្ហាញឲ្យឃើញថា ផ្នូរនៅស្រុកសាឡាមីនច្រើនតែបែរមុខទៅរកក្រុងអាត្អែន... ចំណែកផ្នូររបស់ពួកមេក្លារីវិញ ច្រើនតែបែរទៅរកទិសផ្សេង ។ មិនត្រឹមតែប៉ុណ្ណោះ ពួកសាឡាមីនច្រើនតែឆ្លាក់នាមត្រកូលនៃអ្នកស្លាប់នៅលើផ្នូរ ដែលជាទំនៀមទំលាប់ពេលនោះ របស់ពួកក្រុងអាត្អែនតែមួយប៉ុណ្ណោះ ។

ក៏ប៉ុន្តែមិនយូរប៉ុន្មាន ពួកមេក្លារីក៏បានឆ្លៀតឱកាសសងសឹកវិញ... គឺដោយហេតុថា នៅទីក្រុងអាត្អែនមានជម្លោះរវាងគ្រួសារពីរ គឺពួកក្រុមត្រកូលស៊ីឡុង និងក្រុមត្រកូលមេក្លាក្លែស ដែលបង្កើតឲ្យមានការសងសឹកព្យាបាទគ្នាយ៉ាងខ្លាំងពន់ប្រមាណទៅវិញទៅមក រហូតដល់ចង់បណ្ដាលឲ្យមានការរាលដាលស្លាប់មនុស្សពេញទីក្រុង ។ នៅក្នុងអតិតកាល ស៊ីឡុងមានគោលប្រាថ្នាចង់ឡើងធ្វើស្ដេចនៅទីក្រុងអាត្អែន ។ ការឃុបឃិតនេះក៏ត្រូវបានបែកការណ៍ ៖ ស៊ីឡុងក៏បានត្រូវពិឃាតជាមួយនឹងពួកក្រុមគូកនរបស់គាត់ជាច្រើននាក់ ។ ពពួកអ្នកដែលរត់រួច ក៏បានគេចទៅពួនអាត្មានៅក្នុងព្រះវិហារមីនែរវ ( Minerve ៖ អាទិទេពស្រីមួយទៀតនៃជនជាតិក្រិក ) ។ មេក្លាក្លែសដែលនៅពេលនោះមានឋានៈជាចៅក្រម បានធ្វើការល្បួងលួងលោមដោយសំដីផ្អែមល្ហែម ដើម្បីឲ្យពួកអ្នកទោសចេញមកបង្ហាញខ្លួននៅតុលាការ ដោយម្នាក់ៗកាន់ខ្សែមួយសរសៃឆ្មារចងជាប់នឹងរូបបដិមាកររបស់ព្រះស្រីនៅចុងខាងម្ខាង ដើម្បីកុំឲ្យបាត់បង់សេរីភាពរបស់ពួកគេដែលព្រះទើបប្រទានឲ្យ ។

នៅពេលដែលពួកនេះបានចាកចុះពីវិហារមកភ្លាមកាលណា ខ្សែចងរបស់ពួក

គេក៏ត្រូវរបូតដាច់ ។ មេក្លាក្លែសក៏បាននិយាយអះអាងថា នេះជាសញ្ញាច្បាស់លា-ស់ ដែលព្រះស្រីលែងទទួលគាំពារពួកអ្នកទាំងនេះទៀតហើយ ។ ភ្លាមក្នុងរំពេជនោះ មេក្លាក្លែសក៏បានបញ្ជាឲ្យចាប់ខ្លួនពួកអ្នកទាំងនោះច្រើនគ្នា ពួកគេក៏ត្រូវហ្វូងប្រជាពលករនៅក្បែរនោះគប់នឹងដុំថ្មស្លាប់អស់គ្មានសល់ ។ ពួកណាដែលរត់ទៅពួននៅកន្លែងព្រះបដិមាករ ក៏ត្រូវគេពិឃាតដោយគ្មានសេចក្តីអាណិតមេត្តា និងសេចក្តីគោរពចំពោះព្រះ ។ មានតែប្អូនដប់នាក់ប៉ុណ្ណោះដែលបានរត់រួចខ្លួន គឺដោយសារតែក្រុមភរិយារបស់ពួកចៅក្រមបានយកពួកសេសសល់ទាំងនេះ យកទៅប្រើប្រាស់ហើយដោះលែងឲ្យរួចខ្លួន...

អំពើអធម៌ខ្មៅក្រខ្វក់បែបនេះ បានបណ្តាលឲ្យអ្នកផងស្អប់ខ្ពើមពួកចៅក្រម តពូជរហូតដល់កូនចៅ ។ ជាយូរឆ្នាំក្រោយមក ពួកកូនចៅរបស់ស៊ីឡុង ក៏បានក្លាយជាមនុស្សមានឥទ្ធិពលដ៏មហិមា ។ គំនុំគុំគួនរវាងក្រុមទាំងពីរ ក៏ត្រូវផ្ទុះឆេះឆាបឡើងខ្លាំងឡើងៗរៀងរាល់ថ្ងៃ ។ សូឡុងដែលកាលពេលនោះមានឋានៈជាចៅក្រមទាំងពីរ មានការព្រួយបារម្ភថា ការបែកបាក់គ្នារវាងក្រុមទាំងពីរនេះ នឹងអាចមានលទ្ធភាពនាំឲ្យរលត់រលាយទីក្រុងទាំងមូល ។ គាត់ក៏បាននិយាយបញ្ចុះបញ្ចូលក្រុមទាំងសង្ខាងឲ្យរកចៅក្រមកាត់សេចក្តី រកការខុសត្រូវដល់ជម្លោះរបស់ពួកគេ ។ ពួកចៅក្រមក៏បានសំរេចសេចក្តីឲ្យពួកក្រុមត្រកូលស៊ីឡុងឈ្នះ ។ ពួកកូនចៅផៅសណ្តានរបស់ក្រុមមេក្លាក្លែសទាំងប៉ុន្មាន ក៏បានត្រូវគេបណ្តេញចេញពីទីក្រុងទាំងអស់គ្នា... សូម្បីតែឆ្អឹងរបស់ពួកអ្នកស្លាប់ទៅហើយ ក៏បានត្រូវគេគាស់កកាយយកចេញពីផ្នូរ ដើម្បីយកទៅគ្រវាត់ចោលនៅក្រៅក្រុងអាតែ្តន ។

ពួកមេក្លារី ដោយឆ្លៀតឱកាសដ៏ល្អរបស់ពួកគេក្នុងពេលនេះ ក៏បាននាំគ្នាលើកអាវុធមកច្បាំងពួកអាតែ្តនម្តងទៀត គឺនៅចំពេលដែលពួកខាងក្រោយនេះកំពុងតែបែកបាក់គ្នាពេញទំហឹង... ហើយពួកគេក៏បានសំរេចតណ្តើមយកកោះសាឡាមីនសារជាថ្មី ។

* *

*

នៅពេលដែលសង្គ្រាមស៊ីវិលមួយនៅក្រុងអាតែ្តន មិនទាន់បានផុតរលត់ទៅស្រួលបួលផងក៏ស្រាប់តែមានផ្ទុះវិបត្តិទំនាស់មួយទៀតដ៏ធ្ងន់ធ្ងរ ហើយដែលប្រ-កបដោយគ្រោះថ្នាក់ជាងមុនទៅទៀត ។ ពួកពលរដ្ឋក្រីក្រទាំងឡាយក៏ស្រាប់តែត្រូវជំពាក់គេវណ្ណក... ហើយក៏ត្រូវតុលាការនាំខ្លួនមកកាត់ទោសរៀងរាល់ថ្ងៃ ដាក់ទោសពិន័យឲ្យក្លាយទៅជាខ្ញុំកញ្ជះដាច់ថ្លៃរបស់ពួកក្រុមដែលគេជំពាក់ ។ ពួកក្រោ

យនេះក៏បាននាំយកពួកអ្នកងារទៅប្រើធ្វើការដូចគោក្របី ឬក៏យកទៅលក់ដូរតាមទំនើងចិត្ត ។ ពួកប្រជាជនក្រីក្រក៏បានប្រមូលផ្ដុំគ្នាឡើងស្វែងរកមេកើយ ដើម្បីឃាត់ដំណើរព្រឹត្តិការណ៍ ធ្វើយ៉ាងណាកុំឲ្យពួកគេត្រូវយកទៅលក់ដូរបន្តរទៅទៀត... ថ្វីបើពួកគេពុំមានសោហ៊ុយសងប្រាក់បំណុលដោយទាន់ពេលវេលាក្ដី ។ មិនត្រឹមតែប៉ុណ្ណោះ ពួកគេថែមទាំងបានបង្ខំឲ្យពួកចៅក្រមទាំងអស់ប្រមូលទ្រព្យសម្បត្តិខ្លួនយកមកចែកចាយឲ្យស្មើភាគគ្នាជាមួយអ្នកក្រីក្រ... ដូចជាលីក្ហួកបានធ្វើនៅស្ប៉ារតឺ ។ សភាពរំជើបរំជួលបែបនេះក៏បានរីកទំហំដុះដាលកាន់តែខ្លាំងទៅៗ, ទំនាស់បាក់បែកនៅក្នុងសង្គម ( រវាងពួកអ្នកក្រនិងអ្នកមាន )... ក៏កាន់តែមានកំស្ទួលពិសធ្ងន់ធ្ងររហូតដល់គេមិនអាចស្វែងរកឱសថមកព្យាបាលវិបត្តិនេះបាន ។

សូឡុងក៏បានត្រូវក្រុមជម្លោះទាំងសង្ខាងបោះឆ្នោតលើកឡើងឲ្យធ្វើជាអាជ្ញាកណ្ដាលដើម្បីផ្សះផ្សារនិងជួសជុលសភាពរហែកនៃសង្គម ! ។ មុនដំបូងគាត់មិនបានព្រមទទួលយកជាដាច់ខាតនូវបេសកកម្មមួយដ៏សែនស្មុគស្មាញបែបនេះ...ប៉ុន្តែបន្ទាប់មកទឹកចិត្តស្នេហាជាតិរបស់គាត់, ចំណង់ចង់បំរើប្រយោជន៍សាធារណៈក៏បានចំរុញឲ្យគាត់ពោលអះអាងកាលពីក្នុងអតិតកាលថា សមភាពនឹងអាចបញ្ឈប់ការតវ៉ានិងការកើតទុក្ខមិនសុខចិត្តគ្រប់បែបយ៉ាង ។ ម្នាក់ៗក៏បានបកស្រាយពាក្យឃ្លាទាំងនេះទៅតាមការយល់ឃើញនិងផលប្រយោជន៍របស់ពួកគេរៀងៗខ្លួន។ ពួកអ្នកក្រនឹកស្មានថា សូឡុងមានគោលបំណងចង់ឲ្យមនុស្សទាំងអស់មានភាពស្មើគ្នា... ចំណែកពួកអ្នកមានវិញនឹកស្មានថា គាត់មានគោលបំណងធ្វើវង្វាស់វង្វាល់នៃជីវិត ដោយយោងទៅតាមជាតិកំណើតពូជអំបូរនិងកិត្តិយសរបស់បុគ្គលម្នាក់ៗ ។ ដូច្នេះពាក្យពាក្យសំដីរបស់គាត់ បានធ្វើឲ្យមានការធូរស្រាល ដល់គ្រប់ត្រចៀកអ្នកស្ដាប់... រហូតដល់អ្នកផងបានមូលមតិគ្នាសុំឲ្យគាត់ឡើងធ្វើជាស្ដេច ។

មនុស្សច្រើនគ្នា ថ្វីបើគ្មានការទាក់ទងនឹងរឿងទំនាស់រវាងវណ្ណៈនិងវណ្ណៈនៅក្នុងទីក្រុងក៏ដោយ, ពុំអាចរកឱសថឯណាក្រៅទៀតបានដើម្បីទប់ទល់នឹងវិបត្តិនៃការបែកបាក់គ្នា... ម្ល៉ោះហើយក៏បានស្ម័គ្រចិត្តរួបរួមគ្នាស្វែងរកចៅហ្វាយម្នាក់ ដែលមានសណ្ដានចិត្តល្អ ហើយដែលអ្នកផងទទួលស្គាល់ថាជាមនុស្សមានបញ្ញាជាងគេនៅលើផែនដីនេះ ។ ប៉ុន្តែសូឡុងមិនបានព្រមទទួលយកដំណោះស្រាយដែលតម្រូវឲ្យរូបគាត់ធ្វើជាមេដឹកនាំនោះទេ... គាត់គេចខ្លួនចេញឆ្ងាយពីទីនោះ ហើយបានប្រកាសថា គាត់នឹងបដិសេធសំណើរបស់ពួកគេយ៉ាងដាច់អហង្កា ។

មិត្តភក្ដិដ៏ជិតដិតតាំងប៉ុន្មានរបស់គាត់ក៏បានស្ដីបន្ទោសដល់រូបគាត់គ្រប់ៗគ្នា។ អ្នកទាំងនោះបានពោលដោយសំដីពោរពេញដោយសេចក្ដីទោមនស្សដូច្នេះថា ៖

- ម្ដេចដូច្នេះសូឡុង ? គ្រាន់តែខ្លាចអ្នកផងតិះដៀលថាលោកជាអ្នកជិះជាន់...

លោកបែរជាមិនព្រមបង្កើតពូជពង្សវង់ត្រកូលមហាក្សត្រមួយ ដែលថ្ងៃក្រោយទៅគង់តែមានលក្ខណៈត្រឹមត្រូវតាមច្បាប់ជាក្រោយមិនខាន... ហើយគត់តែអ្នកផងកោតគោរពគ្រប់ៗគ្នា ? លោកមើលទីម៉ូដាស កាលពីដើមគាត់មិនបានតែងតាំងខ្លួនឯងជាស្ដេចនៅអឺបេទេឬ ? ចំណែកពីតាកវិញ គឺគាត់មិនកំពុងតែសោយរាជ្យនៅមីទីឡែននោះទេឬសព្វថ្ងៃ ? ការពិតមិនអីចឹង ? ។

ប៉ុន្តែទោះជាគេនិយាយបញ្ចុះបញ្ចូលវែងឆ្ងាយយ៉ាងណា ក៏សូឡុងមិនព្រមស្ដាប់ពាក្យសំដីបែបនេះដែរ ។ « រាជវាំងរបស់ស្ដេច ហើយនិងអំណាចផ្ដាច់ការ » សូឡុងឆ្លើយតប « ...តាមពិតគឺជាទីកន្លែងដ៏ល្អប្រសើរមែនទែន, ក៏ប៉ុន្តែទីនោះត្រូវខណ្ឌរុំព័ទ្ធជុំវិញដោយជ្រោះជ្រលង, កាលណាគេបានចូលទៅហើយ គេរកច្រកចេញវិញមិនរួចទេ...» ។ ដូច្នេះទៅ... ទោះជាមានមនុស្សច្រើនគ្នាបានទទូចសុំអង្វរយ៉ាងណាក៏ដោយ ក៏សូឡុងមិនបានព្រមទទួលយកមុខងារដ៏ថ្កុំថ្កើងរុងរឿងមួយដែលអ្នកផងលើកជូនគាត់ដោយសុទ្ធចិត្តនេះដែរ ។ មិត្តភក្តិរបស់គាត់បានចាត់ទុករូបគាត់ថាជាមនុស្សឆ្កួត...។

សូឡុងបានខំប្រឹងស្វះស្វែងដោយសុទ្ធចិត្ត រកដំណោះស្រាយដើម្បីឲ្យធូរស្រាលដល់វិបត្តិ ដែលធ្វើឲ្យក្រុងអាតែ្មនជ្រួលច្របល់វឹកវរ ។ គាត់ក៏បានចាប់ផ្ដើមចេញកំណាត់បញ្ញាមួយដែលចែងថា ការជំពាក់វាក់វិនទាំងអម្បាលមាណរបស់បុគ្គលម្នាក់ៗ នឹងត្រូវលើកលែងចោលទាំងអស់... ម្ល៉ោះហើយពួកជនណាដែលមានគេជំពាក់ប្រាក់នោះ ក៏ពុំអាចទៅទារយកបំណុលវិញបានឡើយ ។ មិនត្រឹមតែប៉ុណ្ណោះ ដើម្បីធ្វើជាគំរូចំពោះអ្នកដទៃទាំងអស់គ្នា គាត់ក៏បានយកមាស៧ដំឡឹងដែលគាត់ត្រូវបានទទួលជាមរតកពីឪពុករបស់គាត់ យកទៅបង្វិលត្រឡប់ទៅឲ្យគេវិញ ។ គាត់បានប្រកាសថែមទៀតថា កិច្ចជំពាក់ដែលនឹងកើតមានឡើងនៅថ្ងៃមុខដែលមានលក្ខណៈយករូបកាយទៅធានា នឹងត្រូវទុកជាមោឃៈតទៅទៀត ដើម្បីចៀសវាងកុំឲ្យមានវិបត្តិសង្គមដដែលកើតឡើងសារជាថ្មីម្ដងទៀត ។ បក្សទាំងសង្ខាង មុនដំបូងមិនសូវជាសប្បាយចិត្តនឹងការកាត់សេចក្ដីបែបនេះសោះ ៖ ពួកអ្នកមានៗការទាស់ចិត្តយ៉ាងខ្លាំង ដោយហេតុថាពួកគេត្រូវខូចខាតដោយសារតែមិនបានទារបំណុលមកវិញ... ចំណែកពួកអ្នកក្រីក្រវិញ ក៏កើតមានសេចក្ដីទោមនស្សព្រោះតែពួកគេមិនបានចំណែកទ្រព្យសម្បត្តិចែកឲ្យស្មើភាគគ្នា ។ ក៏ប៉ុន្តែពួកអ្នកខាងណាក៏ដោយ ថ្ងៃក្រោយមកក៏មានជំនឿជឿជាក់នៅក្នុងចិត្តថា ដំណោះស្រាយបែបសូឡុងមានផលប្រយោជន៍ពិតប្រាកដមែន ហើយជាដំណោះស្រាយពោរពេញដោយសុភនិច្ឆ័យ ។ ម្ល៉ោះហើយពួកគេក៏បានជ្រើសរើសសារជាថ្មីយករូបគាត់ឲ្យធ្វើជាអាជ្ញាធរ ដើម្បីបន្សាបការជ្រួលច្របល់វឹកវរ បង្កើតឡើងដោយពួក

ក្រុមគណបក្សបី ដែលយកទីក្រុងអាតែ្ននមកហែកចែកគ្នា ។ ពោល... ពួកគេក៏បានប្រគល់អំណាចពេញលេញទៅសូឡុង ដើម្បីឲ្យគាត់មានលទ្ធភាពកែប្រែច្បាប់តាមទំនើងចិត្តរបស់គាត់ ព្រមទាំងតែងតាំងរដ្ឋាភិបាលយោងទៅតាមចំណង់របស់គាត់ ។

ពួកអ្នកស្រុកភ្នំកាលណោះ ( បដិវត្តន៍បារាំងនៃឆ្នាំ១៧៨៩បានយកគំរូតាមរឿងជីវប្រវត្តិរបស់សូឡុងដែរ... ពីព្រោះក្នុងសម័យបដិវត្តន៍នេះ មាន«ពួកអ្នកស្រុកភ្នំ»បានឡើងមកធ្វើជាអ្នកតំណាងក្នុងសភាបដិវត្តន៍នៃសាធារណរដ្ឋបារាំង ) មានគោលប្រាថ្នាចង់ឲ្យប្រជាពលរដ្ឋ ឡើងមកកាន់កាប់កិច្ចការរបស់រដ្ឋនៅគ្រប់ទីកន្លែង ។ ពួកដែលរស់នៅលើផ្ទៃរាបមានយោបល់ថា មានតែពួកអ្នកចេះដឹងបន្តិចបន្តួចប៉ុណ្ណោះ ដែលត្រូវទទួលកាន់កិច្ចការសាធារណៈ ។ ចំណែកពួកនៅក្នុងកងនាវីវិញបានយល់ថា ពួកចៅក្រមត្រូវតែដកស្រង់ចេញមកពីវណ្ណៈទាំងពីរ ។

សូឡុងដែលគេជ្រើសរើសយកធ្វើជាអាជ្ញាកណ្ដាលកំពូល មានអំណាចដូចមហាក្សត្រ ក៏បានចាប់ផ្ដើមលប់បំបាត់ចោលទាំងអស់ នូវច្បាប់របស់ដ្រាកុង, អ្នកដែលបានកាន់កិច្ចការកំពូលមុនរូបគាត់... ដោយហេតុច្បាប់ទាំងនោះមានលក្ខណៈតឹងរ៉ឹងហួសនិស្ស័យពេក ។ ទោសកំហុសដ៏ស្រាលបំផុតក៏ត្រូវទទួលទណ្ឌកម្មដោយការពិឃាត ប្រហែលគ្នានឹងទោសកំហុសដ៏ធ្ងន់ធ្ងរបំផុតផងដែរ ។ រួមសេចក្ដីមក អ្នកដែលមានកំហុសដូចជាសេចក្ដីខ្ជិលច្រអូស ឬបានលួចផ្លែឈើ ឬស្មៅមួយចំនួន ត្រូវមានទុក្ខទោសស្មើគ្នានឹងអ្នកដែលបានប្រមាថព្រះ ឬប្រមាថវត្ថុស័ក្តិ-សិទ្ធិជាទីសក្ការៈ, មានឃាតកម្មជាដើមឬអ្វីៗទៀត ដែលគេបានចាត់ទុកថា ជាអំពើដ៏ខ្មៅក្រខ្វក់ជាទីបំផុត ។ ម្ល៉ោះហើយ អ្នកផងបានយល់ថា ច្បាប់ទាំងអស់នេះ បានត្រូវសរសេរឡើងដោយលោហិត ។

ថ្ងៃមួយគេបានសាកសួរទៅដ្រាកុងថា ៖ ហេតុអ្វីបានជាគាត់បង្គាប់បញ្ជា ឲ្យកាត់ទោសប្រហាជីវិត ចំពោះបទឧក្រិដ្ឋឬមជ្ឈឹមតែទាំងអស់ ដោយគ្មានពេលនឹងរិះរវល់ចំពោះបទណាស្រាលឬបទណាធ្ងន់នោះ? ។ ដ្រាកុងក៏បានឆ្លើយថា គឺពីព្រោះបទកំហុសដ៏ស្រាលបំផុតត្រូវទទួលពិន័យដោយដកហូតជីវិតទៅហើយ... ម្ល៉ោះហើយគាត់មិនដឹងរករបៀបពិន័យឯណាឲ្យតឹងរ៉ឹងជាងការពិឃាតទៅទៀត ចំពោះអំពើអាក្រក់ដ៏ធំៗមែនទែន ។

សូឡុងបានចែកវណ្ណៈប្រជាពលរដ្ឋក្នុងសម័យនោះជាបីប្រភេទ យោងតាមទ្រព្យសម្បត្តិដែលបុគ្គលម្នាក់ៗមានជាកម្មសិទ្ធិ ។ គាត់បានអនុញ្ញាតឲ្យបើកទ្វារនៃកិច្ចការសាធារណៈចំពោះប្រជាពលរដ្ឋទូទៅ... លើកលែងតែពួកសិប្បករតែប៉ុ-ណ្ណោះ ដែលរស់នៅដោយកិច្ចការស្នាដៃរបស់ខ្លួនឯង ។ ពួកអ្នកចុងក្រោយនេះ

ដោយពុំបានទទួលមុខតំណែងអ្វីទាំងអស់ ម្ល៉ោះហើយក៏មិនត្រូវបានទទួលបុព្វសិទ្ធិអ្វីដូចអ្នកដទៃផងដែរ ។

★ សូឡុងបានបង្គាប់បញ្ជាឲ្យមានការជ្រើសរើសជានិច្ចនិរន្តរ៍ នូវក្រុមចៅក្រមដ៏សំខាន់ៗទាំងឡាយ តែនៅក្នុងចំណោមពួកអ្នកចេះដឹងដ៏ខ្ពង់ខ្ពស់បំផុត...

★ ប្រសិនណាបើមានការបះបោរមួយកើតឡើង នរណាដែលមិនបានចូលក្នុងបក្សខាងណានោះ នឹងត្រូវចាត់ទុកថាជាអ្នកបានប្រព្រឹត្តអំពើខ្មៅក្រខ្វក់បំផុត...

★ នៅក្នុងលក្ខណៈណាដែលបុរសម្នាក់បានរៀបអាពាហ៍ពិពាហ៍ជាមួយស្រ្តីអ្នកមាន... ហើយបើបុរសនោះមានប្រដាប់បន្តពូជស្លាប់ស្លុក... ស្រ្តីនោះមានសិទ្ធិនឹងរួមដំណេកជាមួយនឹងបងប្អូនដ៏ជិតដិតបំផុតរបស់ប្តីនាង ដែលនាងបានជ្រើសរើស ។

★ សូឡុងបានកំរិតឲ្យស្រីៗយកសម្បត្តិទ្រព្យឲ្យប្តី មានចំនួនត្រឹមតែសំពត់បីនិងគ្រឿងរបស់របរក្នុងផ្ទះបន្តិចបន្តួចដែលគ្មានតម្លៃ ។

★ គេអាចសម្លាប់មនុស្សកំផិត (ប្តីឬប្រពន្ធរបស់ខ្លួន) បើគេទាន់មនុស្សនេះកំពុងប្រព្រឹត្តអាការសាហាយស្មន់ជាក់ស្តែង ( ត្រង់កន្លែងនេះ ច្បាប់បារាំងហើយនិងច្បាប់ខ្មែរបុរាណបានអនុវត្ត ដោយយកគំរូតាមសូឡុង ) ។

★ គាត់បានត្បិតត្បៀតការចំណាយរបស់ស្រីៗ ព្រមទាំងបានលប់បំបាត់ចោលនូវពិធីបុណ្យជាច្រើនយ៉ាង ដែលអស់អ្នកស្រីៗនិងលោកជំទាវច្រើនតែប្រារព្ធ ។

★ គាត់បានហាមប្រាមមិនឲ្យនិយាយអាក្រក់ ពីអ្នកដែលបានទទួលមរណភាពរួចទៅហើយ ។

★ គាត់បានបើកច្បាប់អនុញ្ញាត ឲ្យពួកអ្នកដែលមានកូនចៅ ជ្រើសរើសយកជនណាក៏បានដែរ ដើម្បីទទួលយកមរតក ពោលគឺឲ្យតែនៅក្នុងលក្ខណៈណាដែ-លពួកអ្នកទាំងនោះនៅមានស្មារតីស្រួលបួលនៅឡើយ នៅពេលដែលពួកគេធ្វើកិច្ចបណ្តាំ ។

★ ជនណាដែលបានបំផ្លិចបំផ្លាញទ្រព្យសម្បត្តិខ្លួនឯង ត្រូវចាត់ទុកថា បានប្រព្រឹត្តអំពើថោកទាបដ៏ខ្មៅក្រខ្វក់, បុគ្គលនោះត្រូវបាត់បង់បុព្វសិទ្ធិទាំងឡាយដែលខ្លួនមាន ។ ម៉្យាងវិញទៀត ទោសឧក្រិដ្ឋបែបនេះនឹងធ្លាក់ទៅលើគ្រប់បុគ្គលណា ដែលមិនបានចិញ្ចឹមឪពុកម្តាយរបស់ខ្លួន នៅពេលដែលគាត់ចូលវ័យចាស់ជរា ។ កូនប្រុសមិនទទួលនាទីចិញ្ចឹមឪពុករបស់ខ្លួនឯងទេ ប្រសិនបើកាលពីនៅក្នុងយុវវ័យឪពុករបស់ខ្លួនមិនបានណែនាំកូនឲ្យរៀនចេះដឹងពីមុខរបរមួយសំរាប់ចិញ្ចឹមជីវិត។

★ ជនបរទេសណាក៏ដោយ មិនបានត្រូវទទួលឋានៈជាពលរដ្ឋនៅទីក្រុងអាតែ្ននោះទេ ប្រសិនបើជននេះមិនបានទទួលការនិរទេសអស់មួយជីវិត ពីសំណាក

ប្រទេសដើមរបស់គេផ្ទាល់ ឬក៏គេមិនបានសំរេចមករស់នៅជ្រកកោនក្នុងទីនោះជាមួយនិងក្រុមគ្រួសារគេទាំងអស់ ដើម្បីប្រកបរបររកស៊ីណាមួយ ។

★ គាត់បានបន្ថយចំនួនប្រាក់កំរៃដែលគេធ្លាប់បានផ្តល់ឲ្យពួកកីឡាករជារង្វាន់នោះ ។

★ គាត់បានបញ្ជាឲ្យរដ្ឋការចិញ្ចឹមពួកកូនរបស់ពួកអ្នក ដែលបានស្លាប់ក្នុងសង្គ្រាមដើម្បីស្រោចស្រង់ប្រទេសជាតិ ។

★ អ្នកដែលទទួលខុសត្រូវតាមផ្លូវច្បាប់ថែរក្សាក្មេងមិនគ្រប់អាយុ... មិនអាចរស់នៅជាមួយម្តាយនៃក្មេងនោះទេ... ចំណែកអ្នកទទួលមរតកយ៉ាងជិតបំផុតក៏មិនអាចដាច់ខាតត្រូវទទួលថានៈជាអ្នកអភិបាលដែរ ( អ្នកទទួលខុសត្រូវមើលក្មេង ) ។

★ ការលួចបំបាត់ត្រូវទទួលទោសពិន័យដល់ស្លាប់, ចំណែកជនណាដែលបានខ្វេះភ្នែកគេម្ខាង នឹងត្រូវទទួលទោសពិន័យ ដោយត្រូវគេខ្វេះភ្នែកវិញទាំងសង្ខាង

ច្បាប់របស់សូឡុងទាំងប៉ុន្មាន បានត្រូវគេឆ្លាក់នៅលើផ្ទាំងថ្ម ។ ពួកក្រុមជំនុំកុង្ស៊ីបានរួមប្រជុំគ្នាធ្វើសេចក្តីសច្ចាប្រណិធាន ថាគេនឹងគោរពច្បាប់ទាំងនេះពុំឲ្យមានខ្វោះ ហើយនិងញ៉ាំងឲ្យអ្នកដទៃគោរពតាម ។ ពួកអ្នកទទួលបន្ទុកថែរក្សាច្បាប់នេះ ក៏បានធ្វើការស្បថស្បែរជាឱឡារិកថា បើបុគ្គលណាម្នាក់មានការខ្វះខាតមិនគោរពច្បាប់ទាំងនេះជាថរមាន... បុគ្គលនោះនឹងត្រូវមានកាតព្វកិច្ចថ្វាយជាដង្វាយដល់ព្រះវិហារអាប៉ុឡុង នូវរូបចម្លាក់មួយធ្វើពីមាសសុទ្ធដែលមានទម្ងន់ស្មើគ្នានឹងរូបព្រះ ។

គេបានតែងតាំងក្រុមចៅក្រមរួចជាស្រេច ដើម្បីធ្វើការបកស្រាយច្បាប់, នៅក្នុងលក្ខណៈណាដែលមានទំនាស់ផ្សេងៗកើតឡើង ក្នុងចំណោមប្រជាពលរដ្ឋទាក់ទងនឹងច្បាប់នេះ ។

ថ្ងៃមួយនៅពេលដែលសូឡុងគាត់តែងនិពន្ធច្បាប់... ក៏ស្រាប់តែអាណាកាស៊ី (អ្នកប្រាជ្ញក្រិកម្នាក់ទៀត) បានសើចចំអកឡកឡឺយចំពោះគាត់ដូច្នេះថា ៖

- យើ! អាណាកាស៊ីពោល, លោកហ៊ានអះអាងថា គ្រាន់តែលោកបានរៀបចំពាក្យពីបីម៉ាត់នេះ លោកនឹកស្មានតែបានបង្ក្រាបអយុត្តិធម៌ និងតណ្ហារបស់មនុស្សលោកឬ (!?) ក្រិត្យក្រមខ្លះវាមានលក្ខណៈដូចតែសំបុកពីងពាងអីចឹងឯង គឺចាប់បានតែសត្វល្អិតៗប៉ុណ្ណោះ ។

- មនុស្សយើងតែងតែរក្សារបស់អ្វីៗ ដែលគេបានអនុម័តរួមគ្នា, សូឡុងឆ្លើយតប ។ ខ្ញុំនឹងធ្វើច្បាប់របស់ខ្ញុំឲ្យវាទៅតាមលំនាំមួយ ដែលធ្វើឲ្យប្រជាពលរដ្ឋគេអាចយល់ថាពួកគេនឹងទាញប្រយោជន៍ ក្នុងការគោរពបានច្រើនជាងក្នុងការបំពាន ។

អ្នកខ្លះបានសួរគាត់ថា ហេតុអ្វីបានជាគាត់មិនបានតុបតែងច្បាប់ សំរាប់ផ្តន្ទាពួកបិតុឃាត (ជនដែលសម្លាប់ឪពុកខ្លួនឯង) ។ គាត់បានឆ្លើយថា...« គឺពីព្រោះខ្ញុំមិនដែលជឿថា នៅក្នុងលោកនេះមានជនអភ័ព្វរហូតទៅដល់សម្លាប់ឪពុកម្តាយរបស់ខ្លួនឯងនោះឡើយ » ។

គាត់តែងតែនិយាយទៅកាន់មិត្តភក្តិរបស់គាត់ថា ៖ មនុស្សដែលមានអាយុ ៧០ឆ្នាំទៅហើយ មិនត្រូវខ្លាចស្លាប់ទៀតទេ ហើយក៏មិនត្រូវថ្ងូរត្អូញត្អែរអំពីរឿងជីវិតទៀតដែរ ។

★ គាត់បានពោលថា ពួកអ្នកបំរើវាំង មានប្រៀបហាក់ដូចជាលុយសេនដែលគេប្រើទុកសំរាប់រាប់ ។ ជនទាំងនេះជាតំណាងតិចក្តីច្រើនក្តី នូវឆន្ទៈភ្លើតភ្លើនរបស់ស្តេច...

★ នរណាហើយដែលបានចូលទៅជិតស្តេច មិនមែនត្រូវប្តូលំយោបល់ដែលធ្វើឲ្យស្តេចសប្បាយចិត្តនោះទេ... ប៉ុន្តែគួរថ្វាយដំបូន្មានណាដែលប្តូលំការចំណេះ-ញូដល់ទ្រង់...

★ យើងពុំមានអ្នកដឹកនាំឯណាដែលល្អប្រសើរជាងបញ្ញាញាណរបស់យើងទេ... ហើយមុននឹងប្រព្រឹត្តការយើងគួរតែសួរពិចារណាញាណរបស់យើងជាមុនសិន ។

★ គេគួរតែផ្តល់តម្លៃទៅលើសេចក្តីសុចរិត និងកិរិតសីលធម៌ខ្ពង់ខ្ពស់របស់បុគ្គលណាម្នាក់... ជាជាងមានសេចក្តីទុកចិត្តទៅលើសេចក្តីសច្ចាប្រណិធានរបស់មនុស្សម្នាក់នេះ ។

★ គេមិនគួរបង្កើតចំណងមិត្តភាព ដោយរាក់កំភែលនោះទេ... ក៏ប៉ុន្តែបើការចងមិត្តនេះបានប្រព្រឹត្តឡើងរួចទៅហើយ គឺជាការមួយប្រកបដោយគ្រោះថ្នាក់ជាទីបំផុត បើកាលណាគេត្រូវផ្តាច់ចំណងនោះទៅវិញ ។

★ មធ្យោបាយមួយដ៏សក្តិសិទ្ធិនិងដ៏រហ័សបំផុតដែលអនុញ្ញាតឲ្យគេមានលទ្ធភាពទប់ទល់នឹងការប្រមាថ... គឺការបំភ្លេចចោល ។

★ គេមិនត្រូវវាយឫកធ្វើជាអ្នកត្រួតត្រាបង្គាប់បញ្ជានោះទេ... បើខ្លួនឯងហើ-យមិនដែលបានរៀនស្តាប់បង្គាប់បញ្ជានរណាទាំងអស់នោះ...។

★ អ្នកផងទាំងពួងត្រូវតែស្អប់ខ្ពើមការភរភូត ។

★ នៅទីបញ្ចប់គេត្រូវតែលើកតម្កើងព្រះ, ត្រូវគោរពឪពុកម្តាយរបស់ខ្លួនឯង ហើយគ្មានត្រូវមានការទាក់ទងរកស៊ីជាមួយ និងមនុស្សអាក្រក់ទាល់តែសោះ ។

* *

*

សូឡុងបានសង្កេតឃើញថា ពីសីស្ត្រាតបានបង្កើតក្រុមបក្សមួយដ៏ធំសំបើមនៅទីក្រុងអាតែន, ហើយជននេះក៏បានចាត់វិធានការណ៍ចាំបាច់គ្រប់បែបយ៉ាង ដើម្បីតែងតាំងខ្លួនឯងជាស្តេច ។ ម្ល៉ោះហើយសូឡុងក៏បានប្រឹងប្រែងពេញសមត្ថភាព ដើម្បីប្រឆាំងទប់ទល់និងគោលប្រាថ្នារបស់ជននេះ ។ គាត់បានកោះហៅឲ្យមានការរួមប្រជុំមនុស្សជាច្រើននៅកណ្តាលទីសាធារណៈ ។ នោពេលនោះ សូឡុងមានពាក់គ្រឿងអាវុធពេញទាំងខ្លួនផង ហើយគាត់ក៏បានស្រែកប្រកាសវែកមុខពីកិច្ចការសម្ងាត់របស់ពីសីស្ត្រាត ៖

– ឱ ! ប្រជាជននៅទីក្រុងអាត្តែនទាំងឡាយ, គាត់ស្រែកពោលខ្លាំងៗ, ខ្ញុំជាបុគ្គលម្នាក់ដែលមានបញ្ញាញាណជ្រៅជ្រះជាងអ្នកទាំងឡាយ ដែលមិនបានដឹងពីគោលគំនិតអាក្រក់របស់ពីសីស្ត្រាត, ហើយក៏មានសេចក្តីក្លាហានជាងអ្នកទាំងអស់ដែលបានដឹងរឿងនេះហើយតែធ្វើអ្វីពុំកើត ព្រោះតែមានការខ្លាចរអារហើយខ្វះទឹកចិត្តក្នុងការប្រឆាំងនិងគោលបំណងនេះ ។ ខ្ញុំបានប្រុងប្រៀបខ្លួនជាស្រេច ដើម្បីដឹកនាំអ្នកទាំងអស់គ្នាធ្វើការប្រឆាំងតស៊ូយ៉ាងអង់អាច ដើម្បីការពារសេរីភាពរបស់ពួកយើង ។

កាលនោះពួកប្រជាពលរដ្ឋ ដែលគាំទ្រពីស៊ីស្ត្រាតក៏បានយល់ថា សូឡុងជាមនុស្សឆ្កួត ។ បីបួនថ្ងៃបន្ទាប់មក, ពីសីស្ត្រាតក៏បានបណ្តាលធ្វើឲ្យមានការរបួសលើខ្លួនឯង ហើយក៏បានបញ្ជាឲ្យគេលើកខ្លួនគាត់ ដែលប្រឡាក់ពោរពេញដោយឈាមដាក់ផ្តុកលើរទេះមួយបរទៅកណ្តាលទីសាធារណៈ ។ ពីសីស្ត្រាតក៏បានផ្សព្វផ្សាយដំណឹងថា ពួកសត្រូវរបស់ខ្លួនគាត់បានលួចវាយឆ្មក់ខ្លួនគាត់ពីក្រោយខ្នង ជាហេតុបណ្តាលធ្វើឲ្យខ្លួនគាត់ធ្លាក់ទៅក្នុងសភាពការណ៍អាណោចអធមបែបនេះ ។ ពួកហ្វូងប្រជាពលករទាំងប៉ុន្មានក៏មានការរំភើបញាប់ញ័រយ៉ាងខ្លាំង ពួកគេក៏ប្រុងប្រៀបរៀបចំខ្លួនជាស្រេច ដើម្បីងើបឡើងកាន់អាវុធការពារពីសីស្ត្រាត...

– ឱ! កូនប្រុសរបស់អ៊ីប៉ូក្រាសីអើយ! សូឡុងបានពោលឡើង, ឯងដើរតួរជាអ៊ុយសីស ( Ulysse, វិរៈបុរសក្រិក)បែបនេះ វាមិនទំនងសោះ...។ អ៊ុយលីសបានធ្វើឲ្យរលាត់ស្បែកខ្លួនឯងដើម្បីបញ្ឆោតខ្មាំង, ចំណែកខ្លួនឯងវិញ បានធ្វើឲ្យរបួសខ្លួនឯង ដើម្បីបញ្ឆោតប្រជាពលរដ្ឋខ្លួនឯង ។

ពេលនោះហ្វូងប្រជាពលករក៏បានធ្វើការប្រជុំគ្នាអ៊ូរអរឡើង ។ ពីសីស្ត្រាតក៏បានសុំឲ្យមានអង្គរក្សការពារខ្លួនគាត់ចំនួន៥០នាក់ ។ សូឡុងក៏បានធ្វើការព្រមានយ៉ាងខ្លាំងវែកញែកនៅចំពោះមុខអ្នកទាំងអស់គ្នា អំពីគ្រោះថ្នាក់ដែលបានកើតឡើងអំពីវិធានការណ៍បែបនេះ ។ ក៏ប៉ុន្តែគាត់មិនអាចនិយាយអ្វីបានសោះទៅលើ

ប្រជាពលករ ដែលកំពុងតែរំជើបរំជួលញាប់ញ័រនិងឃោរឃៅ... ហើយដែលអនុញ្ញាតឲ្យពីសីស្សត្រាតប្រមូលអង្គរក្សបានរហូត៥០០នាក់ ព្រមទាំងឲ្យប្រមូលកងទ័ពបានជាច្រើន រហូតដល់ខ្លួនគាត់បានក្លាយទៅជាចៅហ្វាយម្ចាស់នៃបន្ទាយនៅទីក្រុងអាត្លែន ។ អ្នកមុខអ្នកការនៅក្នុងទីក្រុងមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ម្នាក់ៗបំរុងថយចេញពីតួនាទីនិងសេចក្ដីទទួលខុសត្រូវទៅរកសេចក្ដីសុខរៀងៗខ្លួន ។

សូឡុងមិនអស់សង្ឃឹមឡើយ ។ គាត់ក៏បានស្ដីបន្ទោសដល់ពួកប្រជាពលរដ្ឋដំបីសេចក្ដីល្ងង់ខ្លៅនិងភាពកំសាករបស់ពួកគេ...។ គាត់បាននិយាយទៅកាន់អ្នកទាំងអស់គ្នាដូច្នេះថា ៖

– កាលពីមុន, សូឡុងពោល, វាជាការស្រួលពន់ពេកណាស់ចំពោះអ្នកទាំងអស់គ្នា ដើម្បីហាមឃាត់កុំឲ្យអំណាចផ្ដាច់ការនេះមានកំណើតឡើងបាន ។ ក៏ប៉ុន្ដែឥឡូវដែលវាចេញរូបរាងទៅហើយ... នោះក៏វាជាកិត្តិយសកាន់តែខ្ពង់ខ្ពស់ថែមទៀតចំពោះអស់លោកអ្នកដើម្បីកំចាត់ដំពើជិះជាន់មនុស្សបែបនេះ ឲ្យវាដាច់ឫសគល់តែម្ដង ! ។

ក៏ប៉ុន្ដែដោយប្រជាពលរដ្ឋទាំងឡាយកំពុងតែស្ថិតនៅក្នុងសភាពភ្លឹកភ្លាំងយ៉ាងខ្លាំង... សំដីសំដៅអ្វីៗទាំងប៉ុន្មានរបស់សូឡុង ហាក់ដូចជាគ្មានឥទ្ធិពលអ្វីទាល់តែសោះទៅលើពួកគេ ។ ឃើញដូច្នេះ, គាត់ក៏ដើរត្រឡប់មកផ្ទះរបស់គាត់វិញហើយបានប្រមូលយកគ្រឿងអាវុធរបស់គាត់ យកទៅដាក់តាំងនៅពីមុខព្រឹទ្ធសភារួចគាត់ក៏ចាប់ផ្ដើមស្រែកដង្ហោយឡើងយ៉ាងខ្លាំងៗដូច្នេះថា ៖

– ឱ! ប្រទេសជាតិមាតុភូមិរបស់ខ្ញុំ... ខ្ញុំបានជួយសង្គ្រោះអ្នក តែតាមពាក្យសំដីនិងឫទ្ធិពលនៃសំនួរវោហាររបស់ខ្ញុំតែប៉ុណ្ណោះ ។ ខ្ញុំសូមយកព្រះធ្វើជាប្រធានសាក្សីថា ខ្ញុំមិនដែលភ្លេចអំពីការរៀបចំការពារក្បួនច្បាប់ទម្លាប់ ហើយនិងសេរីភាពរបស់ប្រទេសជាតិខ្ញុំនោះឡើយ ។ ឱ! មាតុភូមិរបស់ខ្ញុំ ! ខ្ញុំចាកចេញទៅពេលនេះហើយ... ខ្ញុំឃ្លាតចេញពីរូបអ្នកដោយគ្មានវិលត្រឡប់, ពីព្រោះខ្ញុំជាបុគ្គលតែម្នាក់គត់ ដែលបានតាំងខ្លួនជាសត្រូវនឹងជនដែលកាន់អំណាចផ្ដាច់ការ ក្នុងពេលដែលពួកអ្នកឯទៀតៗទាំងអស់គ្នា កំពុងតែរៀបចំទទួលយកជននេះធ្វើជាចៅហ្វាយម្ចាស់ ។

សូឡុងមិនដែលបានសំរេចចិត្តថា នឹងអាចគោរពកោតខ្លាចពីសីស្សត្រាតនោះឡើយ ។ ដោយគាត់មានការភ័យខ្លាចបារម្ភថា ពួកជនដែលរស់នៅទីក្រុងអាត្លែននិងអាចបង្ខិតបង្ខំរូបគាត់ឲ្យកែប្រែច្បាប់ ដែលគាត់បានសច្ចាប្រណិធានថានឹងគោរពតាមដោយគ្មានចន្លោះរួចទៅហើយនោះ... គាត់ក៏បានជ្រើសរើសយកការនិរទេសដោយចេតនា ព្រមទាំងបានសំរេចស្វែងរកការត្រេកសប្បាយក្នុងការធ្វើដំណើរ

ដើម្បីស្គាល់ពិភពលោក ជាជាងរស់នៅដោយវេទនាក្នុងអារម្មណ៍នៅក្រុងអាតែ្ន ។ គាត់ក៏បានឆ្លងចូលទៅក្នុងប្រទេសអេយីព្ទ ដែលគាត់បានសំណាក់នៅមួយរយៈពេលក្នុងវាំងរបស់អាម៉ាស៊ីស ( Amasis ) ។ ពីស្សីសត្រាតដែលមានការគោរព និងស្រឡាញ់សូឡុងយ៉ាងខ្លាំង ក៏មានការរំជើបរំជួលក្នុងមនោសញ្ចេតនា ចំពោះការថយខ្លួនទៅចូលនិវត្តន៍របស់សូឡុង ។ ជនអ្នកកាន់អំណាចផ្តាច់ការម្នាក់នេះក៏បានសាកល្បងផ្ញើលិខិតមួយទៅលួងលោមចិត្តគាត់ឲ្យវិលត្រឡប់មកវិញ ដោយមានសេចក្តីដូចតទៅនេះ ៖

« ខ្លួនខ្ញុំមិនមែនជាជនជាតិក្រិកតែមួយនាក់ ដែលបានតណ្តើមយកអធិបតេយ្យភាព ( តួនាទីជារាជា ) នៃប្រទេសជាតិរបស់ខ្ញុំនោះទេ ។ ខ្ញុំពុំបានប្រព្រឹត្តអ្វីផ្ទាំផ្ទុងផ្ទុយនឹងច្បាប់ ឬដែលប្រឆាំងនឹងព្រះនោះក៏ទេដែរ, ពីព្រោះខ្ញុំជាកូនចៅតំណពូជពង្សពីស្តេចកូឌ្រូស... ចំណែកពួកអ្នកស្រុកនៅអាតែ្នក៏បានស្បថស្បែរថា នឹងរក្សាទុករាជអំណាចរបស់ទ្រង់ទៅឲ្យកូនចៅរបស់ផងទ្រង់ ។ ខ្ញុំមានការប្រុងប្រយ័ត្នជាអតិបរិមា ក្នុងការគោរពច្បាប់ក្រិត្យក្រមដែលលោកបានសរសេរនោះឲ្យបានត្រឹមត្រូវជាទីបំផុត... លើសពីពេលដែលរដ្ឋបានត្រូវគ្រប់គ្រងដោយពួកប្រជាពលករទៅទៀត ។ ហើយក្រៅពីកិត្តិយសខ្លះៗដែលត្រូវបានមកសមស័ក្តិនឹងតួនាទីរបស់ខ្ញុំ, ខ្ញុំគ្មានបានទទួលបុព្វសិទ្ធិអ្វីទៀតដែលមានការខុសប្លែកពីប្រជាពលរដ្ឋសាមញ្ញធម្មតានោះដែរ ។ ខ្ញុំគ្មានគំនុំគុំគួនអ្វីចំពោះរូបលោកដែលបានបើកកកាយនូវគំរោងការណ៍របស់ខ្ញុំនោះទេ ។ ខ្ញុំជឿជាក់ច្បាស់ណាស់ថា បុព្វហេតុដែលបានជំរុញឲ្យលោកធ្វើដូច្នេះ គឺបណ្តាលមកពីមនោសញ្ចេតនាស្រឡាញ់ប្រទេសជាតិ, មិនមែនមកពីការស្អប់រូបខ្ញុំនោះទេ... ពីព្រោះលោកពុំបានដឹងជាមុនទេថា ខ្ញុំនឹងមានអាកប្បកិរិយាបែបណាទៅថ្ងៃមុខ, ពុំនោះសោតទេ ប្រសិនបើលោកបានដឹងជាមុន នោះប្រហែលជាលោកពុំបានដាក់ទោសកំហុសមកលើវិធានការរបស់ខ្ញុំនោះឡើយ ។ សូមលោកវិលត្រឡប់មកវិញដោយគ្មានការព្រួយបារម្ភ, ហើយសូមជឿជាក់លើសំដីរបស់ខ្ញុំចុះថា សូឡុងគ្មានត្រូវការអ្វីខ្លាចនឹងពីស្សីសត្រាតនោះទាល់តែសោះ... ពីព្រោះថាខ្ញុំមិនទាំងដែលចង់ធ្វើបាបចំពោះជនណា ដែលធ្លាប់ជាសត្រូវរបស់ខ្ញុំគ្រប់ពេលវេលានោះផង ។ ខ្ញុំសូមចាត់ទុករូបលោកថា ជាមិត្តភក្តិដ៏ល្អបំផុតរបស់រូបខ្ញុំ ហើយលោកច្បាស់ជានឹងបានទទួលផលប្រយោជន៍ដ៏ល្អប្រសើរគ្រប់យ៉ាងពីរូបខ្ញុំ... គឺដោយហេតុថា បើតាមខ្ញុំស្គាល់រូបលោក ខ្ញុំមើលមិនឃើញ ថាលោកអាចមានមនោសញ្ចេតនាក្បត់ជាមួយជនណាម្នាក់នោះជាដាច់ខាត ។ ប្រសិនបើលោកមានមូលហេតុអ្វី ដែលរាំងរាជំណើររបស់លោកមិនឲ្យវិលត្រឡប់មកក្រុងអាតែ្នវិញនោះ... លោកអាចសំណាក់គ្រប់ទីកន្លែងណាឯទៀតបាន ក៏

ស្រេចតែរូបលោកចុះ ៖ ខ្ញុំនឹងមានសេចក្តីសប្បាយរីករាយជានិច្ច ធ្វើយ៉ាងណាកុំ
ឲ្យតែបុព្វហេតុនៃការនិរទេសខ្លួនរបស់លោក គឺជារូបខ្ញុំ ! » ។

សូឡុងក៏បានសរសេរលិខិតតបទៅពីស៊ីស្រ្តាតវិញដោយសេចក្តីដូច្នេះថា «
ខ្ញុំជឿច្បាស់ណាស់ថា លោកនឹងមិនធ្វើអ្វីអាក្រក់មកលើខ្ញុំទេ, ដោយហេតុថាកា
លពីដើមយើងជាមិត្តភក្តិនឹងគ្នា មុននឹងលោកក្លាយទៅជាជនកាន់អំណាចផ្តាច់ការ
ហើយខ្លួនខ្ញុំក៏ប្រហែលជាមិនបណ្តាលញ៉ាំងឲ្យរូបលោកស្អប់ខ្ពើម លើសពីពួកអ្នក
ឯទៀត ដែលស្អប់ខ្ពើមអំពើជិះជាន់មនុស្សនោះដែរ ។ ខ្ញុំទុកសេរីភាពឲ្យបុគ្គលម្នា
ក់ៗមានលទ្ធភាពវិនិច្ឆ័យទៅតាមគំនិតរបស់គេទៅចុះ... ថាតើវាមានផលប្រយោ-
ជន៍ពិតមែនឬទេ ចំពោះប្រជាជននៅអាតែ្ហន ដែលត្រូវគ្រប់គ្រងដោយជនកាន់អំ-
ណាចផ្តាច់ការតែម្នាក់ ជាជាងត្រូវទទួលអភិបាលដោយពួកក្រុមចៅក្រមជាច្រើន
នាក់ ។ ខ្ញុំត្រូវទទួលស្គាល់ថា លោកជាជនកាន់អំណាចផ្តាច់ការម្នាក់ដ៏ប្រសើរជាង
គេបំផុត ក៏ប៉ុន្តែខ្ញុំពុំមានជំនឿថា ខ្ញុំមានកាតព្វកិច្ចត្រូវវិលត្រឡប់មករស់នៅទីក្រុង
អាតែ្ហននេះវិញទេ ៖ គឺថា បន្ទាប់ពីបានបង្កើតរដ្ឋាភិបាលសេរីមួយរួចហើយ ៗបន្ទា
ប់ពីបានបដិសេធតួនាទីជាមេដឹកនាំ ដែលពួកគេបានប្រគល់មកឲ្យរូបខ្ញុំ គេអាចមា
នលទ្ធភាពនឹងស្តីបន្ទោសឲ្យរូបខ្ញុំមិនខាន ហើយពួកគេច្បាស់ជាជឿថា ខ្ញុំគាំទ្រស-
កម្មភាពរបស់លោក ប្រសិនបើគេឃើញខ្ញុំត្រឡប់វិលវិញ » ។

សូឡុងក៏បានសរសេរសំបុត្រមួយច្បាប់ទៀតទៅអេពីម៉េនីឌ ( Epiménides)
ដែលមានសេចក្តីដូច្នេះថា ៖

« ដោយច្បាប់របស់ខ្ញុំពុំបានហុចផលប្រយោជន៍អ្វីប៉ុន្មាន ដូច្នេះការវាយបំបាក់
ច្បាប់ទាំងនេះចោលទៅក៏ពុំបានជាបណ្តាលឲ្យខូចខាតប្រយោជន៍អ្វីប៉ុន្មានដែរចំ-
ពោះទីក្រុង ។ ទោះជាព្រះក្តី, ទោះជាអ្នកសរសេរច្បាប់ក្តី ពុំបានផ្តល់ផលប្រយោជ
ន៍អ្វីដល់ទីក្រុងឡើយ, ប៉ុន្តែបានហុចផលផ្លែផ្កាដល់ពួកក្រុមអ្នកដឹកនាំប្រជាពលរដ្ឋ
ឲ្យសមស្រេបនឹងគោលបំណងរបស់គេ, ក្នុងលក្ខណៈណាដែលពួកគេមានឆន្ទៈល្អ
៖ ច្បាប់របស់ខ្ញុំពុំមានប្រយោជន៍អ្វីទេ... ក៏ប៉ុន្តែពពួកអ្នកដែលបានបំពានច្បាប់ទាំង
នេះ បានធ្វើឲ្យប៉ះក្រឡាប់ស្ថាប័ននៃសាធារណរដ្ឋអស់រលីងតែម្តង... ដោយពុំបាន
ខាខាំងរាំងរាពីស៊ីស្រ្តាត កុំឲ្យដណ្តើមយកអធិបតេយ្យភាព ។ ខ្ញុំបានទាយទុកជា
មុនរួចហើយ ថាអ្វីៗដែលត្រូវមកដល់ ច្បាស់ជានឹងមកដល់ ៖ ក៏ប៉ុន្តែគ្មាននរណា
ម្នាក់ជឿខ្ញុំឡើយ ។ ពីស៊ីស្រ្តាតដែលខំយកចិត្តយកថ្លើម និងខំប្រឹងបញ្ឆោរពួក
ប្រជារាស្រ្តនៅក្នុងទីក្រុង ក៏បានលេចឡើងជាមនុស្សមានភក្តីភាពស្មោះត្រង់ជាង
រូបខ្ញុំ ដែលបានខំប្រឹងនិយាយការពិតទៅរកពួកគេ ។ ខ្ញុំបានស្នើរសុំដឹកនាំប្រជា-
ពលរដ្ឋធ្វើការប្រយុទ្ធតស៊ូ ដើម្បីរាំងរាសភាពអណោចអធ៌មនេះ កុំឲ្យកើតមានឡេ

ីងបាន… ក៏ស្រាប់តែពួកគេបានទុករូបខ្ញុំជាមនុស្សឆ្កួតទៅវិញ ។ គេបានអនុញ្ញាតឲ្យពីសីស្រ្តាតមានអង្គរក្សដ៏ច្រើនលើសលប់… ហើយបុគ្គលនេះក៏បានយកអង្គរក្សទៅប្រើប្រាស់ដើម្បីបង្ក្រាបទីក្រុងទាំងមូល ឲ្យធ្លាក់ចូលក្នុងទាសភាព, ចំណែកខ្លួនខ្ញុំវិញក៏បានសំរេចចិត្តដកថយខ្លួនចេញពីទីនោះតែម្តងទៅ » ។

*　　　*

*

ក្រេស៊ុស, ស្តេចនៃជនជាតិលីឌី មាននាទីជាអ្នកទទួលសួយសារអាករពីពួកជនជាតិក្រិកទាំងឡាយដែលរស់នៅខាងប៉ែកអាស៊ី ។ នៅក្នុងសតវត្សនោះ ពពួកជនជាតិក្រិកជាច្រើនដ៏មានទេពកោសល្យ បានលះបង់ប្រទេសរបស់ខ្លួន ដើម្បីទៅតាំងលំនៅនៅសារដឺ ដែលជារាជធានីរបស់ព្រះចៅអធិរាជក្រេស៊ុស ។ ទីក្រុងនោះ ជាទីក្រុងលួតលាស់សម្បើម សំបូរសប្បាយរុងរឿង ពោរពេញដោយមនុស្សមានកិត្តិយសនិងជនមានទ្រព្យសម្បត្តិ ។ នៅទីនោះ, អ្នកផងនិយាយល្បីតែពីសូឡុង ជាហេតុបណ្តាលឲ្យស្តេចក្រេស៊ុសមានចំណង់ចង់ជួបគាត់ជាខ្លាំង ។ ព្រះចៅក៏បញ្ជូនមនុស្សឲ្យទៅអញ្ជើញសូឡុងឲ្យមកសំណាក់នៅក្នុងរាជវាំងរបស់ទ្រង់ ។ សូឡុងក៏បានសរសេរលិខិតឆ្លើយតបទៅទ្រង់វិញដូច្នេះថា ៖

« ខ្ញុំសូមថ្លែងអំណរគុណជាអតិបរិមា ចំពោះមិត្តភាពដែលទ្រង់បានសំដែងបង្ហាញមកលើរូបខ្ញុំ ហើយខ្ញុំសូមយកព្រះធ្វើជាប្រធានសាក្សីអំពីទឹកចិត្តរបស់ខ្ញុំ ៖ ប្រសិនបើខ្ញុំបានសំរេចចិត្តតាំងពីយូរយារណាស់មកហើយថា រស់នៅក្នុងលក្ខណ:ជាមនុស្សមានសេរីនោះទេ, នោះខ្ញុំច្បាស់ជាសុខចិត្តរស់នៅក្នុងរាជធានីរបស់ទ្រង់… ជាជាងរស់នៅក្នុងទីក្រុងអាតែ្កន នៅចំពេលដែលពីសីស្រ្តាត កំពុងតែប្រើអំណាចជិះជាន់សង្កត់សង្កិន ។ ក៏ប៉ុន្តែពេលនេះខ្ញុំកំពុងតែរស់នៅដោយសែនសប្បាយ យោងទៅតាមលក្ខណ:ជីវិតមួយដែលខ្ញុំបានជ្រើសរើស នៅក្នុងតំបន់មួយដែលអ្វីៗមានភាពស្មើគ្នាទាំងអស់ ។ ទោះជាយ៉ាងណាក្តី ខ្ញុំនឹងធ្វើដំណើរទៅលេងទ្រង់ ដើម្បីស្រង់យកការត្រេកសប្បាយ ដោយបានរស់នៅក្បែរទ្រង់មួយរយ:ពេល » ។

សូឡុងក៏បានធ្វើដំណើរទៅទីក្រុងសារដឺ តាមសំណើររបស់ក្រេស៊ុសដែលមានសេចក្តីរំភើបញាប់ញ័រជាខ្លាំងចង់ជួបគាត់ ។ នៅពេលដែលគាត់បានឆ្លងកាត់ប្រទេសលីឌី សូឡុងបានសង្កេតឃើញថា មានវរជនធំៗដ៏ច្រើនសន្ធឹកសន្ធាប់ ដែលទៅណាមកណាមានក្បួនដំណើរហែរហមដ៏អធឹកអធ៏ម និងពោរពេញដោយ

គ្រឿងអលង្ការ ។ រាល់តែដង... គាត់តែងនឹកស្មានថាជាព្រះរាជាដែលកំពុងធ្វើដំ-ណើរយាត្រា ។ នៅទីបំផុត សូឡុងក៏បានត្រូវគេនាំទៅបង្ហាញខ្លួនចំពោះមុខក្រេ-ស៊ុសដែលកំពុងអង្គុយរង់ចាំគាត់នៅលើបល្ល័ង្ករបស់ទ្រង់ ។ នៅពេលនោះ ស្ដេចបានតុបតែងខ្លួនដោយសំលៀកបំពាក់ដ៏ឆើតឆាយបំផុត ប៉ុន្តែសូឡុងគាត់ហាក់ដូចជាពុំបានចាប់អារម្មណ៍ទៅលើរបស់ថ្លៃថ្នូរទាំងអស់នេះទេ ។ ក្រេស៊ុសក៏បាននិយាយទៅកាន់គាត់ថា ៖

– នែភ្ញៀវរបស់យើង... យើងបានទទួលដឹងឮពីបញ្ញានិងកេរ្តិ៍ឈ្មោះរបស់ឯងតាមសំដីរបស់អ្នកផង ។ យើងបានដំណឹងថា ឯងបានធ្វើដំណើរទៅកាន់ប្រទេសជាច្រើនណាស់... ប៉ុន្តែតើឯងមានដែលឃើញនរណាម្នាក់ដែលស្លៀកពាក់ដ៏ស-ម្បើមអស្ចារ្យជាងរូបយើងនេះទេ ? ។

– ខ្ញុំដែលបានឃើញ, សូឡុងឆ្លើយតប, គឺសត្វមាន់ព្រៃ, មាន់គកនិងសត្វក្ងោក... ពួកសត្វទាំងនេះមានសំលៀកបំពាក់ដ៏សម្បើមអស្ចារ្យជាងទ្រង់... ហើយអ្វីៗដែលវាមាន គឺបានមកពីធម្មជាតិសុទ្ធសាធ គឺពួកវាមិនដែលចាំបាច់ខំប្រឹងតែងខ្លួននោះផងទេ...

ចម្លើយដោយមិនបានព្រៀងទុកនេះ បានធ្វើឲ្យក្រេស៊ុសមានសេចក្ដីងឿងឆ្ង-ល់ជាខ្លាំង ។ ស្ដេចក៏បានបញ្ជាឲ្យពួកមនុស្សរបស់ទ្រង់បើកហិបមាសប្រាក់និងគ្រឿងអលង្ការរបស់ទ្រង់ ( ស្ដេចក្រេស៊ុសជាស្ដេចមហាសម្បត្តិក្នុងបុរាណកាលរបស់ក្រិក )... ទាំងប៉ុន្មានដើម្បីបង្ហាញដល់សូឡុង ។ រួចទ្រង់ក៏កោះហៅគាត់ជាលើកទី២ដើម្បីសួរថា ៖

– តើលោកមានដែលឃើញមនុស្សណាម្នាក់ដែលសប្បាយជាងរូបខ្ញុំនេះទេ?

– ប្រាកដជាមាន, សូឡុងឆ្លើយតប, គឺតែលុស្ស ( Tellus ), ពលរដ្ឋម្នាក់នៅទីក្រុងអាត្តែន ។ គឺជាបុរសម្នាក់ដែលបានរស់នៅក្នុងភាពសុចរិត នៅក្នុងសាធារណរដ្ឋមួយដែលមានសណ្ដាប់ធ្នាប់ល្អ ៖ គាត់បានបន្សល់កូនពីរនាក់ ដែលមានគេស្រឡាញ់រាប់អានច្រើនគ្នា ព្រមទាំងបានទុកសម្បត្តិទ្រព្យល្មមសមគួរ ដើម្បីឲ្យពួកគេរស់នៅបាន... មិនត្រឹមតែប៉ុណ្ណោះ គាត់បានទទួលសុភមង្គលធំផង ដោយបានទៅស្លាប់ដោយមានអាវុធនៅក្នុងដៃ, ដោយបានដណ្ដើមយកជ័យជំនះសំរាប់ប្រ-ជាជាតិខ្លួនឯង ។ ពួកអ្នកស្រុកនៅទីក្រុងអាត្តែន បានសង់ផ្នូរមួយយ៉ាងល្អនៅត្រង់ទីកន្លែងដែលគាត់បានបាត់បង់ជីវិត ព្រមទាំងបានផ្ដល់កិត្តិយសដ៏ធំដុំសម្បើមសំ-រាប់រូបគាត់ថែមទៀត ។

ក្រេស៊ុសរឹតតែមានការភ្ញាក់ផ្អើល លើសពីកាលលើកទីមួយទៅទៀត ។ ស្ដេចបានយល់ថា សូឡុងជាមនុស្សឡប់ស្មារតី...

– បើអីចឹង, ក្រេស៊ុសឧទានឡើង, តើជនណាទៅជាមនុស្សសប្បាយជាងគេបន្ទាប់ពីតែលុស ? ។

– កាលពីដើមមានបុរសពីរនាក់បងប្អូននិងគ្នា, សូឡុងឆ្លើយតប, ម្នាក់ឈ្មោះក្លេអូប៊ីស ម្នាក់ទៀតឈ្មោះប៊ិតុង ។ អ្នកទាំងពីរមានកម្លាំងរឹងប៉ឹង... ទៅទីកន្លែងណាតែងតែច្បាំងឈ្នះគេនៅទីកន្លែងនោះ ។ អ្នកទាំងពីរស្រឡាញ់គ្នាណាស់មិនដែលរស់នៅបែកពីគ្នាទេ ។ ថ្ងៃមួយជាថ្ងៃបុណ្យ, ដូនជីនៃព្រះវិហារហ៊្សីណុង ( Junon : ព្រះស្រីមួយអង្គនៃជនជាតិក្រិក ប្រហែលគ្នានឹងប្រាសាទនាងខ្មៅ ) ដែលត្រូវជាមាតានៃអ្នកទាំងពីរ ត្រូវការធ្វើពលិកម្មបូជាយញ្ញនៅព្រះវិហារ ។ ដោយគេក្រយកគោមកទឹមរទេះ... ក្លេអូប៊ីសហើយនិងប៊ិតុងក៏សុខចិត្តទៅទឹមនៅរទេះរបស់ម្ដាយខ្លួនទាំងពីរនាក់... ហើយពួកគេអូសគាត់រហូតដល់ទីកន្លែងដែលគាត់ចង់ទៅ ។ ប្រជាពលរដ្ឋទាំងឡាយក៏បានជូនពរដល់ពួកគេគ្រប់ៗគ្នា ។ ដូនជីជាមាតាមានសេចក្ដីសប្បាយរីករាយពន់ប្រមាណ ក៏បានធ្វើការបួងសួងដល់ព្រះហ៊្សីណុង សូមឲ្យទ្រង់ប្រទានអ្វីៗដ៏ល្អជាងគេបំផុតដល់ពួកគេ ។ នៅពេលដែលពិធីបូជាយញ្ញបានប្រព្រឹត្តរួចហើយ, ហើយនៅពេលដែលបងប្អូនទាំងពីរបានស្រស់ស្រូបអាហារឆ្អែតឆ្អន់យ៉ាងឆ្ងាញ់ពិសារ... ពួកគេក៏នាំគ្នាទៅនិទ្រាលក់ស្កប់ស្កល់ហើយក៏ទទួលមរណភាពទាំងពីរនាក់ក្នុងរាត្រីនោះទៅ...

ឮដូច្នេះ ស្ដេចក្រេស៊ុសមានសេចក្ដីក្រេវក្រោធយ៉ាងខ្លាំង ៖

– ម៉េចអីចេះ... ស្ដេចពោល, ឯងមិនព្រមចាត់ទុករូបអញក្នុងចំណោមមនុស្សដ៏សប្បាយជាងគេទេឬ ?

– ឱ! ព្រះចៅនៃស្រុកលីឌី, សូឡុងពោលតប, ទ្រង់មានសំបុកសម្បត្តិដ៏មហិមា, ទ្រង់ជាចៅហ្វាយម្ចាស់នៃប្រជាពលរដ្ឋដ៏ច្រើនរាប់មិនអស់...។ ប៉ុន្តែនៅក្នុងជីវិតតែងតែមានការប្រែប្រួលសំខាន់ៗ ដែលធ្វើឲ្យគេមិនហ៊ានសន្និដ្ឋានជាមុនបានអំពីសុភមង្គលរបស់មនុស្ស... ដរាបណាបើជននោះមិនទាន់បានទៅដល់ទីចប់នៃមុខរបររបស់ខ្លួននោះទេ ។ ពេលវេលាតែងតែបង្កើតនូវឧប្បត្តិហេតុថ្មីៗថែមមកទៀត ដែលគ្មាននរណាអាចស្មានទុកជាមុន ៖ ម្ល៉ោះហើយគេមិនអាចអួតអាងពីជោគជ័យបានទេ ដរាបណាបើសង្គ្រាមមិនទាន់ចប់ ។

ស្ដេចក្រេស៊ុសមានសេចក្ដីទោមនស្សយ៉ាងខ្លាំង ហើយក៏បញ្ជូនសូឡុងឲ្យត្រឡប់ទៅវិញ ។ តាំងពីពេលនោះមក ស្ដេចក៏លែងកោះហៅគាត់ឲ្យមកជួបសារជា ថ្មី ។

ជនម្នាក់ឈ្មោះអេសុបដែលបានធ្វើដំណើរក្នុងពេលនោះដែរ មកពីទីក្រុងសារដឺ ក្នុងតួនាទីជាអ្នកជួយកំសាន្តអារម្មណ៍ដល់ស្ដេចក្រេស៊ុស... មានការអាក់

អន់ចិត្តយ៉ាងខ្លាំងចំពោះស្ដេចដែលបានប្រព្រឹត្តអំពើមិនគប្បីចំពោះជនម្នាក់ ដែលមានកិត្តិនាមល្បីល្បាញដូចសូឡុង ។

– ឱសូឡុង, អេសុបបានពោលទៅគាត់, គេមិនត្រូវចូលទៅជិតពួកស្ដេចនោះទេ បើពុំនោះសោត គេត្រូវតែនិយាយពីកិច្ចការអ្វីៗ ដែលបណ្ដាលឲ្យទ្រង់សព្វព្រះហឫទ័យ...

– ផ្ទុយទៅវិញ, សូឡុងពោលតប, គេមិនត្រូវចូលទៅជិតស្ដេចនោះទេ...ប៉ុន្តែបើគេជ្រុលចូលទៅជិតហើយ... គេត្រូវតែនិយាយអ្វីៗដែលជាការពិត ។

ស្ដេចសីរុសបានចាប់អាស្ទារ្យ, ជីតាខាងម្ដាយរបស់ខ្លួនឯងទៅធ្វើជាឈ្លើងសង្គ្រាម មិនត្រឹមតែប៉ុណ្ណោះបានដកហូតមុខតំណែងនិងរង្វជាច្រើនដែលអាស្ទារ្យជាអ្នកកាន់កាប់ ។ លុះបានទទួលដំណឹងនេះ, ស្ដេចក្រេស៊ុសក៏មានកំហឹងក្រេវក្រោធយ៉ាងខ្លាំង ៖ ទ្រង់ប្រកាន់យកបក្សខាងអាស្ទារ្យ ហើយក៏បានធ្វើសឹកសង្គ្រាមទៅលើពួកពែរ្ស ( អ៊ីរ៉ង់សព្វថ្ងៃ ) ។ ដោយស្ដេចនេះមានសំបុកសម្បត្តិដ៏មហាអស្ចារ្យ មិនត្រឹមតែប៉ុណ្ណោះជាមេទ័ពនៃប្រជាជាតិមួយ ដែលល្បីថាជាពូជអ្នកចំបាំងខ្លាំងក្លាជាងគេនៅលើផែនដីទៅទៀត... ទ្រង់ក៏បាននឹកថា គ្មានអ្វីដែលទ្រង់ធ្វើមិនបាននោះទេ ។ ជាការអភ័ព្វស្ដេចនេះក៏បានត្រូវទទួលបរាជ័យទៅវិញ..., ទ្រង់ក៏បានថ-យខ្លួនមកពួនសម្ងំនៅទីក្រុងសារដឹ ។ ប៉ុន្តែមិនយូរប៉ុន្មាន ទ្រង់ក៏បានត្រូវពួកខ្មាំងតាមមកឡោមព័ទ្ធ ហើយចាប់យកទៅធ្វើជាឈ្លើយ បន្ទាប់ពីមានការប្រយុទ្ធតស៊ូគ្នាចំនួន១៤ថ្ងៃ ។ គេចាប់អូសយកទ្រង់ទៅបង្ហាញខ្លួននៅពីមុខស្ដេចសីរុស ដែលបានបញ្ជាឲ្យគេដាក់ច្រវាក់ទ្រង់ ។ គេនាំទ្រង់យកទៅចងនៅលើគំនរអុសមួយយ៉ាងខ្ពស់ នៅកណ្ដាលចំណោមក្មេងៗនៃជនជាតិលីឌី១៤នាក់... ដើម្បីដុតជាចំណីអគ្គីនៅចំពោះមុខស្ដេចសីរុសនិងមហាជនជាតិពែរ្ស ។ នៅពេលដែលគេយកភ្លើងមកដុត, ក្រេស៊ុសដែលបានធ្លាក់ទៅក្នុងសភាពដ៏សែនអាណោចអធមទៅហើយក៏បាននឹកឃើញទៅដល់ពាក្យសំដីប្រៀនប្រដៅរបស់សូឡុង ។ ស្ដេចជាប់ទោសក៏ស្រែកថ្ងូរថា ៖ « ឱ! សូឡុង! សូឡុង! សូឡុង! » ។ អាការៈបើកមាត់ម្ដុបៗបែបនេះ ក៏បានធ្វើឲ្យសីរុសមានសេចក្ដីងឿងឆ្ងល់យ៉ាងខ្លាំង... ទ្រង់ក៏បានចាត់មនុស្សឲ្យទៅសាកសួរថា តើជាឈ្មោះព្រះណាមួយដែលជននេះស្រែកដង្ហោយហៅនៅពេលដែលខ្លួនមានទុក្ខ ។ ក្រេស៊ុសពុំបានឆ្លើយតបមួយម៉ាត់ ។ ប៉ុន្តែនៅពេលដែលគេបង្ខំឲ្យនិយាយ គាត់ក៏បានសុខចិត្តឆ្លើយ ដោយថ្លែងវាចាពោរពេញដោយទុក្ខសោក...

– ឱ! ខ្ញុំទើបបានបញ្ចេញឈ្មោះមនុស្សម្នាក់ ដែលពួកស្ដេចទាំងឡាយគួរតែនាំគ្នាយកមករស់នៅក្បែរខ្លួន... ហើយដែលត្រូវគេចាត់ទុកថា សំដីរបស់គាត់មាន

តម្លៃថ្លៃថ្នូរជាងសម្បត្តិមាសពេជ្រកែវកងដែលស្តេចមានទៅទៀត ។ គេក៏បង្ខំឲ្យក្រេស៊ុសនិយាយបានច្រើនជាងនេះ...

– គឺជាអ្នកប្រាជ្ញម្នាក់នៅប្រទេសក្រិក, ជននេះពោលបន្ត, ដែលខ្ញុំបានកោះហៅឲ្យមកក្បែររូបខ្ញុំដើម្បីញ៉ាំងឲ្យគេកោតស្ញប់ស្ញែងអំពីសេចក្តីរុងរឿងរបស់ខ្ញុំ ។ ប៉ុន្តែគាត់នេះបាននិយាយមកកាន់ខ្ញុំបែបព្រងើយ, ហាក់ដូចជាចង់បង្ហាញឲ្យខ្ញុំឃើញថា រឿងទាំងអស់នេះគ្រាន់តែជាអំនួតប៉ុណ្ណោះ... ថាចាំឲ្យជីវិតរបស់ខ្ញុំចប់សិន, ហើយថាគេមិនត្រូវឲ្យតម្លៃហួសហេតុទៅលើសុភមង្គលមួយ ដែលជាដើមកំណើតនៃសេចក្តីទុក្ខវេទនា និងរឿងអភ័ព្វរាប់មិនអស់នោះទេ ។ នៅពេលនេះ ទើបបានខ្ញុំទទួលស្គាល់នូវលក្ខណៈពិតនៃសេចក្តីរៀបរាប់របស់គាត់ទាំងប៉ុន្មាន ដែលគាត់បានទូន្មានខ្ញុំ...

នៅពេលដែលក្រេស៊ុសកំពុងតែនិយាយ, ភ្នក់ភ្លើងក៏ឆេះឡើងពីខាងក្រោម ចំណែកអណ្តាតភ្លើងក៏កាន់តែលិទ្ធនិងខិតឡើងទៅខាងលើជាលំដាប់ ។ ស៊ីរុសមានសេចក្តីរំភើបញាប់ញ័រយ៉ាងខ្លាំងចំពោះពាក្យសំដីរបស់ក្រេស៊ុស ។ សភាពហិនហោចអាណោចអធមរបស់ស្តេចម្នាក់ ដែលធ្លាប់តែមានឫទ្ធិអំណាច ធ្វើឲ្យបុគ្គលម្នាក់នេះមានការភ្ញាក់រឮកពីរូបខ្លួនឯង ។ ស៊ីរុសក៏នឹកថប់បារម្ភថា សេចក្តីអភ័ព្វបែបនេះ ក៏អាចធ្លាក់មកលើរូបខ្លួនឯងដែរទៅអនាគត ។ ទ្រង់ក៏បានបញ្ជាឲ្យគេពន្លត់ភ្លើងមួយរំពេច... ព្រមទាំងឲ្យយកច្រវាក់ចេញពីខ្លួនក្រេស៊ុស ។ ស្តេចបានផ្តល់កិត្តិយសជាច្រើនទៅឲ្យអ្នកទោសរបស់ទ្រង់ មិនត្រឹមតែប៉ុណ្ណោះ ទ្រង់យកជននេះមកប្រើប្រាស់ជាទីប្រឹក្សាផ្ទាល់នៅក្នុងគណរដ្ឋមន្ត្រីរបស់ទ្រង់ ដើម្បីពិភាក្សាពីរឿងសំខាន់ៗក្នុងនគរ ។

* *

*

សូឡុងបន្ទាប់ពីឃ្លាតចាកពីក្រេស៊ុសទៅ, ក៏បានថយខ្លួនទៅនៅស៊ីលីស៊ី ដែលនៅទីនោះ គាត់បានបង្កើតទីក្រុងមួយដាក់តាមឈ្មោះគាត់ហៅថា សូឡូស ។ គាត់បានទទួលដំណឹងថា របបពីស៊ីស្ត្រាត កាន់តែមានការរីកធំធាត់នៅក្នុងអំពើជិះជាន់សង្កត់សង្កិនអមនុស្សធម៌... ហើយថាពួកអ្នកស្រុកនៅទីក្រុងអាតែ្ទន កំពុងតែនឹកស្តាយក្រោយជាខ្លាំង ព្រោះតែពុំបានប្រឆាំងនឹងការប្លន់យកអំណាចរបស់បុគ្គលនេះកាលពីគ្រាដំបូង ។

សូឡុងបានសរសេរសំបុត្រមួយទៅកាន់អ្នកស្រុកអាតែ្ទនដោយសេចក្តីដូច្នេះថា ៖

« ...អស់លោកខុសហើយ ដែលបានដាក់ទោសទៅលើព្រះជាម្ចាស់ អំពីរឿងសេចក្ដីអភ័ព្វមួយ ដែលលោកបានបង្កើតដោយខ្លួនឯង ។ បើអស់លោកបានស្គាល់សេចក្ដីទុក្ខលំបាកវេទនានៅក្នុងពេលសព្វថ្ងៃនេះ ក៏ដោយសារតែអស់លោកមានអាកប្បកិរិយារាក់កំភែលនិងខ្វះនូវវិចារណញ្ញាណ គឺពុំបានចង់ស្ដាប់ពួកអ្នកដែលមានឆន្ទៈល្អចំពោះជាតិ បែរជាទៅជាចូលចិត្តស្ដាប់ពាក្យសំដីផ្អែមល្ហែម និងផ្ដេកផ្ដួលជំនឿទៅលើល្បិចកល្បរបស់មនុស្សម្នាក់ ដែលមានគោលបំណងត្រឹមតែបោកបញ្ឆោតតែប៉ុណ្ណោះ ។ ពួកអស់លោកបានអនុញ្ញាតឲ្យបុរសម្នាក់នេះ កេណ្ឌអង្គរក្សសន្ទឹកសន្ធាប់ ដែលមាននាទីសំរាប់តែយកមកបង្ក្រាបពួកអស់លោកឲ្យរស់នៅក្នុងទាសភាពអស់មួយជីវិត » ។

ឆប៉េរីយ៉ង់ដ្រ, អ្នកកាន់អំណាចផ្ដាច់ការម្នាក់ទៀតនៅកូរាំងថឺ បានរៀបរាប់ពីសភាពការណ៍នៃរដ្ឋរបស់ខ្លួនឲ្យសូឡុងស្ដាប់ ក្នុងគោលបំណងស្នើរសុំយោបល់ ។ សូឡុងក៏ឆ្លើយតបតាមលិខិតដោយសេចក្ដីដូច្នេះថា ៖

«លោកបានសរសេររៀបរាប់ប្រាប់ខ្ញុំអំពីមនុស្សជាច្រើន ដែលបានឃុបឃិតក្បត់ចំពោះរូបលោក ។ នៅពេលដែលលោកបានកំចាត់ខ្មាំងសត្រូវរបស់លោកអស់រលីងទៅ, ដោយយកពួកគេទៅពិឃាត លោកក៏គ្មានបានចំរើនអ្វីនៅក្នុងកិច្ចការរបស់លោកដែរ ។ ពួកមនុស្សខ្លះ ដែលលោកពុំបាននឹកស្មានសង្ស័យជាមុនបន្តិចសោះ ច្បាស់ជានឹងជីករណ្ដៅដើម្បីរង់ចាំស្ទាក់រូបលោក... ឬមួយគឺជាមនុស្សម្នាក់ដែលមានការភ័យខ្លាចពីជីវិតខ្លួនឯង... ឬមួយគឺជាមនុស្សម្នាក់ទៀត ដែលមិនបានចូលចិត្តអំពីអំពើឃោរឃៅរបស់លោក ឬក៏ជាមនុស្សផ្សេងម្នាក់ទៀតដែលចង់កសាងអំពើល្អមួយសំរាប់ប្រទេសជាតិរបស់ខ្លួន ។ បើចង់យកល្អ... លោកគួរតែឈប់ប្រើអំណាចជិះជាន់ផ្ដាច់ការឲ្យបានដាច់ស្រឡះតាំងពីពេលនេះទៅ ។ ក៏ប៉ុន្តែបើលោកធ្វើមិនបានទេ លោកត្រូវទៅនាំយកកងទ័ពបរទេសឲ្យបានច្រើនគ្រប់គ្រាន់ ដើម្បីបង្ក្រាបស្រុកលោកឲ្យបាក់ស្បាត ដើម្បីកុំឲ្យលោកភ័យខ្លាចរអែងពីរឿងអ្វីទាំងអស់ដែលអាចកើតឡើង និងដើម្បីឲ្យលោកមានកាតព្វកិច្ចចៀសវាងមិននិរទេសជាណាម្នាក់សោះ » ។

សូឡុងបានឆ្លងកាត់ទៅស៊ីព្រ ( Chypre ) ។ គាត់បានចងមិត្តភាពជាមួយនឹងហ្វីឡូស៊ីព្រ ដែលជាស្ដេចនៅអេពី ។ ក៏ប៉ុន្តែទីក្រុងនេះត្រូវបានសង់ឡើងនៅលើទីដីមួយស្ងួតហែងគ្មានជីវជាតិ ។ សូឡុងក៏បានជូនយោបល់ទៅដល់ហ្វីឡូស៊ីព្រថាគួរតែកសាងនគរនៅក្នុងតំបន់មួយដីល្អជាងនេះ ។ គាត់បានជ្រើសរើសទីវាលមួយដែលមានជីវជាតិល្អបានចាត់ចែងដឹកនាំឲ្យគេបំពេញវិធានការណ៍នេះដោយខ្លួនឯង... នៅទីបញ្ចប់គាត់ក៏បានទទួលលទ្ធផលយ៉ាងល្អប្រពៃ ។ ហ្វីឡូស៊ីព្រ ដោយ

មានអាការៈដឹងគុណចំពោះសូឡុង ក៏បានប្រសិទ្ធិនាមទីក្រុងនេះថា « សូឡេស»។

សូឡុងពុំមែនធ្លាប់ជាខ្មាំងសត្រូវជាមួយនឹងសេចក្តីសប្បាយពេញមួយជីវិតគាត់នោះដែរ ។ គាត់ធ្លាប់ចូលចិត្តម្ហូបឆ្ងាញ់ពិសារ, ធ្លាប់ចូលចិត្តស្តាប់ភ្លេង និងអ្វីៗដែលអាចញ៉ាំងឲ្យជីវិតមានរសជាតិ ។ ក៏ប៉ុន្តែគាត់ធ្លាប់ស្អប់ល្ខោន ដែលគាត់យល់ថាមានតែរឿងប្រឌិត សំរាប់នាំឲ្យអារម្មណ៍អណ្តែតភ្លើតភ្លើន ។ គាត់បានយល់ថាកិច្ចការដូច្នេះ បណ្តាលឲ្យមានការខូចខាតយ៉ាងខ្លាំងចំពោះសាធារណរដ្ឋ ពីព្រោះជាបុព្វហេតុធ្វើឲ្យកើតសភាពបះបោរគ្រប់យ៉ាង ។ កាលក្នុងពេលដែលគាត់ធ្លាប់ធ្វើជាទីប្រឹក្សាដែលមានគេស្តាប់បង្គាប់នៅទីក្រុងអាតែ្កន, តេសពីស ( Thepis ) បានចាប់ផ្តើមសំដែងឆាកសោកនាដកម្ម ដែលជននេះបាននិពន្ធដោយខ្លួនឯង ។ ល្ខោនសំដែងទាំងនេះបានធ្វើឲ្យប្រជាពលរដ្ឋផ្អើលមកទស្សនាយ៉ាងភ្លូកទឹកភ្លូកដី.. ពីព្រោះសាច់រឿងដែលគេបានសំដែងនោះ សុទ្ធសឹងតែជារឿងថ្មី ។ ថ្ងៃមួយសូឡុងក៏បានមកកំសាន្តអារម្មណ៍ក្នុងល្ខោនសំដែងនេះដែរ ។ លុះដល់ពេលល្ខោនបិទទ្វារ គាត់ក៏បានហៅតេសពីសមកស្តីបន្ទោស ៖

– ឯងមិនចេះខ្មាស់អៀនទេឬ, សូឡុងពោល, គឺគ្រាន់តែជារឿងសំរាប់សើចសប្បាយទេតើ !

សូឡុងក៏យកដំបងដែលគាត់កាន់នៅដៃវាយទៅលើធរណី...

– អឺចឹងហើយ, គាត់ពោលតប, បើកេគាំទ្រការភូតភរបៀបនេះ ដោយសើចលេងសប្បាយ... មិនយូរប៉ុន្មានទេ យើងគង់តែឃើញរឿងដូច្នេះឆ្លងចូលទៅក្នុងកិច្ចការសាធារណៈ និងចូលទៅក្នុងបញ្ហារដ្ឋដ៏សំខាន់ៗចៀសមិនផុត...

គឺហេតុដូច្នេះហើយ បានជានៅក្នុងពេលដែលពីស៊ីស្ស្រ្រាតបានបញ្ជាឲ្យគេសែងខ្លួនប្រឡាក់ពោរពេញទៅដោយឈាម ចូលមកកណ្តាលទីសាធារណៈ សូ-ឡុង ដោយបាននិយាយបីល្ខោនសំដែងខាងលើនេះក៏បានស្រែកថា ៖ « នេះហើយដើមកំណើតនៃការបោកប្រាស់ទាំងឡាយ » ។

អ្នកខ្លះយល់ថាសូឡុងជាអ្នកបានបង្កើតតុលាការក្រិកជំនាន់ដើម ( Aréopage ) ៖ គឺជាសមាគមអ្នកចេះដឹង និងអ្នកមានសមត្ថកិច្ច ដែលធ្លាប់បានកាន់ការគ្រប់ជាន់ថ្នាក់នៅទីក្រុងអាតែ្កន ។ ថ្ងៃមួយគេបានសួរទៅសូឡុងថា តើរដ្ឋណាមួយដែ-លមានសណ្តាប់ធ្នាប់ជាងគេ ? « គឺជារដ្ឋមួយ, សូឡុងឆ្លើយតប, ដែលពួករាស្ត្រប្រជា ដែលមិនបានត្រូវគេប្រមាថនោះ ខំប្រឹងប្រែងពេញទំហឹងតែខែអយុត្តិធម៌ដែលប្រព្រឹត្តទៅលើអ្នកដទៃនោះ... ហាក់ដូចជារឿងទាំងនោះត្រូវបានគេប្រព្រឹត្តមកលើខ្លួនឯង ។ នៅពេលចូលវ័យចាស់ជរាជិតស្លាប់ សូឡុងបានចាប់ផ្តើមសរ-សេរកំណាព្យអំពីកោះអាត្លង់ទីដ ( Atlantide )... កោះនៃការស្រមៃមួយដែលពួក

អ្នកស្រុកអេយីព្ទបានតំណាលប្រាប់គាត់ថា បិតនៅសែនឆ្ងាយដាច់ស្រយាលក្នុងមហាសមុទ្រដែលគេមិនទាន់បានទៅដល់ ។ កិច្ចការនិពន្ធនេះមិនទាន់បានចប់ផង គាត់ក៏បានទទួលមរណភាពទៅ ។ គឺនៅចំពេលអូឡាំព្យ៉ាដទី៥៥... ពេលដែលគាត់បានមកដល់អាយុ៨០ឆ្នាំ ។ គាត់បានធ្វើកិច្ចបណ្ដាំឲ្យគេយកឆ្អឹងរបស់គាត់ទៅកោះសាឡាមីនឲ្យដុតទៅជាផេះ ហើយឲ្យយកធាតុទៅគ្រវែងចោលតាមស្រែចំការ ។ បន្ទាប់ពីមរណភាពរបស់គាត់ទៅ អ្នកស្រុកនោទីក្រុងអាតែ្ហនបានសង់រូបសំណាក់របស់គាត់មួយធ្វើពីសំរឹទ្ធ ៖ គេឃើញសូឡុងកាន់សៀវភៅច្បាប់មួយនៅដៃ នៅក្នុងសំលៀកបំពាក់ជាមេដឹកនាំប្រជាពលរដ្ឋ ។ ឬកអ្នកស្រុកសាឡាមីនបានកសាងរូបសំណាកមួយទៀត បង្ហាញពីរូបគាត់ក្នុងឋានៈជាវាគ្មិន ដែលកំពុងតែនិយាយទៅកាន់សាធារណជន, ដៃលាក់បង្កប់នៅក្នុងផ្នត់សំពត់តុលាការរបស់គាត់ ។៚

❑ ❑

❑

# ជីវិតរបស់ថ្លាលែស
# THALÈS

[ កើតនៅឆ្នាំទី១នៃអូឡាំផ្យាដទី៣៥ ( កីឡាអូឡាំពីក )–ស្លាប់នៅក្នុងអូឡាំផ្យាដទី៥៨, មានអាយុ៩២ឆ្នាំ ]

ថ្លាតែល, ជនជាតិមីឡេស៊ីយាង, មានដើមកំណើតនៅប្រទេសហ្វេនីស៊ី, ជាកូនសែស្រឡាយរបស់កាដមុស្ស កូនប្រុសរបស់អាគ្គេនរ ។

ដោយឪពុកម្ដាយរបស់ថ្លាលែសមានការស្អប់ខ្ពើមជាខ្លាំង ចំពោះអ្នកកាន់អំណាចផ្ដាច់ការ ដែលធ្វើបាបជិះជាន់សង្កត់សង្កិនពួកប្រជាពលរដ្ឋដែលមានសន្ដានចិត្តល្អ, អ្នកទាំងនោះក៏ដាច់ចិត្តចាកចេញពីស្រុកមីឡេត៍, ពីទីក្រុងយ៉ូនី ដែលថ្លាលែសមានកំណើតកើតនៅក្នុងឆ្នាំទី១នៃអូឡាំផ្យាដទី៣៥ ។ បុគ្គលនេះជាបុគ្គលទី១ ដែលបានទទួលកិត្តិនាមជាអ្នកប្រាជ្ញ... ដោយគាត់បានបង្កើតទស្សនវិជ្ជាម៉្យាងឈ្មោះថា យ៉ូនីក... គឺឈ្មោះដកស្រង់ចេញពីទីក្រុងកំណើតរបស់គាត់ ។

បុគ្គលនេះបានចូលបំពេញកិច្ចការងារនៅក្នុងក្រសួងតុលាការអស់មួយរយៈពេល, ហើយបន្ទាប់ពីបានធ្វើការដោយមានកេរ្តិ៍ឈ្មោះល្អក្នុងនាទីសំខាន់ៗ នៅក្នុងក្រសួងនេះហើយ... គាត់ក៏បានចាកចេញស្វែងទៅរកសិក្សាស្វាធ្យាយន៍អាថ៌កំបាំងនៃធម្មជាតិវិញ... ដោយគាត់មិនចូលចិត្តជាប់ដៃជាប់ជើង និងសភាពតឹងតែងនៃកិច្ចការសាធារណៈនិងនយោបាយ ។ គាត់បានធ្វើដំណើរទៅប្រទេសអេយីព្ទ ដែលនៅទីនោះ វិទ្យាសាស្ត្រផ្សេងៗកំពុងតែលូតលាស់បែកផ្លែផ្កាពេញទំហឹង ៖ គាត់ក៏បានចំណាយពេលវេលាអស់ជាច្រើនឆ្នាំ ដើម្បីពិភាក្សាជាមួយនឹងពួកគ្រូអាចារ្យធំៗ ដែលសុទ្ធសឹងជាក្រុមបណ្ឌិតនៅក្នុងប្រទេសនេះ ។ គាត់បានសិក្សាស្រាវជ្រាវ ពីភិនភាគសម្ងាត់នៃសាសនារបស់ពួកគេ ហើយបានយកចិត្តទុកដាក់យ៉ាងខ្លាំងជាទីបំផុតខាងផ្នែកធរណីមាត្រ ( géométrie ) និងខាងផ្នែកតារាសាស្ត្រ ។ គាត់ពុំបានជាប់ចិត្តជាប់ថ្លើមបំរើលោកគ្រូធំណាម្នាក់ទេ...។ ក្រៅពីទំនាក់ទំនងដែលគាត់ធ្លាប់មានជាមួយនិងអ្នកប្រាជ្ញអេយីព្ទ... គាត់គ្មានការពិសោធន៍ឯណាទៀតទេ ក្រៅតែពីការពិសោធន៍ស្រាវជ្រាវរបស់ខ្លួនឯង ។ គឺការពិសោធន៍ពិចារណាដ៏ជ្រា–

លជ្រៅ និងចំណេះដឹងដែលគាត់បានប្រមែប្រមូលឱបក្រសោបដោយការសិក្សាផ្ទាល់ខ្លួនឯង... គាត់ក៏បានយកចំណេះដឹងទាំងនេះ មកពង្រីកចងក្រងជាទស្សន-វិជ្ជារបស់គាត់ ។

ត្អាលែសមានសម្បជ្ជញ្ញៈខ្ពង់ខ្ពស់ណាស់... និយាយតិច, តែគិតពិចារណាច្រើន ។ គាត់មិនដែលគិតអំពីប្រយោជន៍ផ្ទាល់ខ្លួនរបស់គាត់ទេ... គាត់មានការចាប់អារម្មណ៍យ៉ាងខ្លាំងតែទៅលើប្រយោជន៍នៃសាធារណរដ្ឋរបស់គាត់តែប៉ុណ្ណោះ ។

ជនម្នាក់ឈ្មោះយុវេណាល់... ពេលនិយាយពីមនុស្សខ្លះដែលជឿជាក់ថា ការសងសឹកជាទ្រព្យសម្បត្តិដ៏សំខាន់ជាងគេនៅក្នុងជាតិនេះ... បានពោលថា មនោ-សញ្ចេតនានៃការស្អប់គុំគួននិងសងសឹក ពុំមែនជាមនោសញ្ចេតនានៃពួកក្រុមគ្រូ-សារគ្រីស៊្សីព ( ឪពុកម្ដាយរបស់ត្អាលែស ) និងពុំមានឋិតនៅក្នុងលក្ខណៈទន់ភ្លន់របស់ត្អាលែសនោះទាល់តែសោះ ! ។

**At vindicta bonum vitâ jueundius ipsâ; Chrisippus non dicet idem, nec mite Thaletis Ingenium...**

នៅពេលដែលត្អាលែសត្រឡប់មករស់នៅស្រុកមីឡេត៍ បុគ្គលនេះរស់នៅក្នុងការស្ងប់ស្ងាត់តែម្នាក់ឯង ហើយគិតតែពីត្រិះរិះពិចារណាក្នុងរឿងអ្វីៗដែលទាក់ទងនឹងមេឃផ្កាយ ។ សេចក្ដីស្រឡាញ់ជាប់ចិត្ត និងបញ្ញា និងវិចារណញ្ញាណ បានណែនាំឲ្យគាត់ចូលចិត្តជីវិតរស់នៅជាមនុស្សទោលឥតប្រពន្ធ... គឺធ្វើឲ្យគាត់ចៀសចេញឆ្ងាយពីរឿងចំណងអាពាហ៍ពិពាហ៍ ។ នៅពេលនោះ គាត់ទើបមានអាយុ ២៣ឆ្នាំ ក៏ស្រាប់តែម្ដាយគាត់ អ្នកស្រីក្លេអូប៊ូលីនបានបង្ខំឲ្យគាត់រៀបការជាមួយកូនស្រីអ្នកមានម្នាក់ ។ ត្អាលែសក៏បានពោលថា ៖ « កាលណាគេនៅក្មេង... គឺមិនទាន់ដល់ពេលរៀបការទេ; កាលណាគេក្លាយទៅជាមនុស្សចាស់ជរា ក៏វាហួសពេលទៅហើយ ។ ចំណែកមនុស្សដែលឋិតនៅក្នុងចន្លោះនៃអាយុទាំងពីរនេះ គឺច្បាស់ជាពុំសូវមានពេលទំនេរគ្រប់គ្រាន់ដើម្បីស្វែងរកប្រពន្ធនោះទេ » ។ ប៉ុន្តែពាក្យអ្នកខ្លះបានពោលថា នៅពេលគាត់ចាស់ទៅ ត្អាលែសបានយកប្រពន្ធម្នាក់ជាស្រីជាតិអេហ្ស៊ីព្ទ ។ គឺជាស្រីម្នាក់ដែលចេះផលិតរបស់របរល្អៗច្រើនបែបច្រើនយ៉ាង ។

ថ្ងៃមួយ មានពួកបរទេសបានចូលមកក្នុងស្រុកម៉ាឡេត៍ ដោយឆ្លងកាត់តាមកោះកូ... ពួកជនទាំងនោះបានជួលអ្នកនេសាទឲ្យបង់សំណាញ់ចាប់ត្រីឲ្យពួកគេ ។ ពួកអ្នកនេសាទបានបង់សំណាញ់នៅក្នុងសមុទ្រ មិនចាប់បានត្រីបែរជាយកបានជើងតាំងមួយធ្វើពីមាសសុទ្ធដែលព្រះនាងអេឡែន ( Hélène ស្ដេចស្រីក្រិក ) នៅពេលត្រឡប់មកពីក្រុងត្រយវិញបានទម្លាក់ចោលនៅទីកន្លែងនោះ ។

ការបង់សំណាញ់បានជើងតាំងមានដូច្នេះ ក៏បានបង្កើតឲ្យមានជម្លោះជាខ្លាំង

រវាងពួកជនបរទេសនិងពួកអ្នកនេសាទ ដែលជជែកតវ៉ាគ្នាអ៊ឹងកងតណ្តើមគ្នាយករបស់មានតម្លៃ ។ បន្ទាប់មក ពួកអាជ្ញាក្រុងក៏បានចូលមកលាយឡំនៅក្នុងរឿងនេះ ដោយប្រកាន់យកត្រូវសំរាប់មនុស្សពួកគេរៀងៗខ្លួន ។ សង្គ្រាមមួយហៀបនឹងផ្ទុះឡើងរវាងទីក្រុងផ្សេងៗទៅហើយ ក៏ស្រាប់តែអ្នកខ្លះមានយោបល់ថា គួរតែយករឿងនេះទៅឲ្យហោរានៅភ្នំដេលហ្វជាអ្នកសំរេចវិញ ។ គេក៏បានបញ្ជូនបេសកជនទៅភ្នំដេលហ្វ; ហោរាបានឆ្លើយថា ត្រូវតែយកជើងតាំងមាសទៅប្រគល់ឲ្យអ្នកប្រាជ្ញទីមួយ ។ អ្នកផងក៏លើកយកជើងតាំងមាសនេះ ទៅប្រគល់ត្អាលែស ។ ត្អាលែសមិនព្រមទទួលយក ក៏បញ្ជូនរបស់នេះទៅឲ្យអ្នកចេះដឹងម្នាក់ទៀតឈ្មោះប៊ីយ៉ាស ។ ដោយសេចក្តីសុភាពរាបសារ ប៊ីយ៉ាសក៏បានបញ្ជូនតៗគ្នា រហូតធ្លាក់ទៅក្នុងកណ្តាប់ដៃរបស់សូឡុង ។ បុគ្គលក្រោយនេះក៏បានពោលថា គ្មានមនុស្សណាម្នាក់ដែលមានបញ្ញាញាណជាងព្រះនោះទេ ម្ល៉ោះហើយក៏បានបញ្ជូនរបស់នេះទៅថ្វាយតាំងជាគ្រឿងអាសនៈរបស់ព្រះអាប៉ូឡុង ( ព្រះពិស្ណុការរបស់ជនជាតិក្រិក ) នៅភ្នំដេលហ្វ ( គួរកត់សំគាល់ថា នៅសហរដ្ឋអាមេរិកសព្វថ្ងៃ មានទីក្រុងមួយឈ្មោះ « ហ្វីឡាដេលហ្វីយ៉ា » គឺមានន័យថា « សេចក្តីស្នេហាចំពោះភ្នំដេលហ្វ » ) ។

មានពួកយុវជនខ្លះនៅក្នុងក្រុងម៉ាឡេត៍ បានស្តីបន្ទោសឲ្យត្អាលែសថា មុខវិជ្ជាដែលគាត់ខំស្រាវជ្រាវ គ្មានបានផ្តល់ផលប្រយោជន៍អ្វីដល់គាត់ទេ... ពីព្រោះគេឃើញតែគាត់រស់នៅក្នុងសេចក្តីក្ររហេមរហាមរហូត ។ ត្អាលែសចង់បង្ហាញឲ្យពួកទាំងអស់នោះយល់ឃើញថា បើពួកក្រុមអ្នកប្រាជ្ញ មិនដែលប្រមែប្រមូលទ្រព្យបានទ្រព្យសម្បត្តិច្រើន គឺព្រោះដោយហេតុថា ពួកគេមើលងាយមើលស្រាលចំ-ពោះមាសពេជ្រកែវកង ដែលគេមិនដឹងយកទៅធ្វើអ្វី... ក៏ប៉ុន្តែបើពួកគេបានសំរេចថាធ្វើអ្នកមានអ្នកបាននោះវិញ ក៏គ្មានអ្វីជាការពិបាកចំពោះពួកគេដែរ ។

យោងតាមពាក្យសំដីរបស់ប្រជាពលរដ្ឋក្រិក ដែលនិយាយតៗគ្នាពីសម័យនោះ... គេថាត្អាលែសជាមនុស្សដែលចេះគន់គូរទុកជាមុនអំពីរឿងមេឃផ្កាយ ជាពិសេសបានទាយទុកពីផលិតផលល្អនៃកសិកម្មនៅក្នុងឆ្នាំដែលគេរស់នៅ ។ មុនរដូវមកដល់ គាត់បានទិញផ្លែអូលីវទាំងអស់នៅជុំវិញស្រុកម៉ាឡេត៍ ។ ផលិតផលក៏មានសំបូរដូចការទស្សន៍ទាយពិតមែន... ត្អាលែសក៏បានទទួលការចំណេញដ៏សន្ធឹកសន្ធាប់ ក៏ប៉ុន្តែដោយរូបគាត់ពុំមែនជាអ្នកគិតពីប្រយោជន៍... គាត់ក៏បានសុំឲ្យមានការរួមប្រជុំនៃពួកអ្នកជំនួញទាំងអស់នៅស្រុកម៉ាឡេត៍ ហើយគាត់ក៏បានចែកចាយការចំណេញរបស់គាត់ទាំងអស់ទៅពួកអ្នកជំនួញទាំងនោះ ។

ត្អាលែសធ្លាប់បានសំដែងសេចក្តីអំណរគុណចំពោះព្រះក្នុងរឿងបីយ៉ាង ÷ គឺបានកើតមកជាមនុស្សមានបញ្ញា មិនមែនជាមនុស្សភ្លីភ្លើ; បានកើតមកជាប្រុស មិ

នមែនជាស្រី; បានកើតមកជាជនជាតិក្រិក ពុំមែនកើតមកជាជនព្រៃផ្សៃ ។

ត្លាលែសមានទស្សនៈថា ពិភពលោកបានត្រូវរៀបចំឡើងដោយបញ្ញាខ្ពង់ខ្ពស់មួយ ដែលគ្មានការចាប់ផ្ដើមនិងគ្មានទីចប់ ។ គាត់ជាជនជាតិក្រិកទី១ដែលបានបង្ហាត់បង្រៀនថា ព្រលឹងវិញ្ញាណរបស់មនុស្ស (អាត្ម័ន)ជារបស់ដែលចេះស្លាប់ ។

ថ្ងៃមួយមានបុរសម្នាក់ដែលបានទៅសួរគាត់ថា តើមនុស្សយើងអាចលាក់បិទបាំងអំពើរបស់យើងចំពោះព្រះបានទេ ។ គាត់បានឆ្លើយតបថា ចិត្តគំនិតរបស់យើង ទោះជាមានលក្ខណៈជាអាថ៌កំបាំងនិងជាការសម្ងាត់យ៉ាងណាក៏ដោយ ក៏មិនអាចបិទជិតជាមួយនឹងព្រះបានដែរ ។

ត្លាលែសបានពោលថា របស់ដែលធំជាងគេនៅក្នុងលោក គឺទីកន្លែង ពីព្រោះទីកន្លែងមានចំណុះមនុស្សសត្វនិងធម្មជាតិទាំងអស់... របស់ដែលខ្លាំងជាងគេ គឺការចាំបាច់ ពីព្រោះការចាំបាច់នឹងនាំឲ្យឈ្នះនូវអ្វីៗគ្រប់យ៉ាង; របស់ដែលមានល្បឿនលឿនជាងគេ គឺចិត្តគំនិត... ពីព្រោះនៅក្នុងរយៈពេលតែមួយភ្លែតសោះ ចិត្តថ្លើមរបស់មនុស្សអាចឆ្លងកាត់រហូតដល់ចក្រវាល; របស់ដែលមានបញ្ញាជាងគេ គឺពេលវេលា ពីព្រោះពេលវេលានឹងអាចលាតត្រដាងនូវអាថ៌កំបាំងគ្រប់យ៉ាង; របស់ដែលគួរឲ្យសប្បាយនិងប្រកបដោយសុភមង្គលជាទីបំផុត គឺការធ្វើកិច្ចការអ្វីៗស្របតាមឆន្ទៈរបស់ខ្លួន ។

★ គាត់បានពោលអះអាងជាច្រើនដងថា ការនិយាយច្រើនពុំមែនជាសញ្ញានៃបញ្ញាញាណនោះទេ ។

★ គេត្រូវនឹកឃើញដល់មិត្តភក្តិស្មើគ្នា ទោះនៅជិតក្ដី ទោះនៅឆ្ងាយក្ដី ។

★ គេត្រូវជួយឧបត្ថម្ភដល់ឪពុកម្ដាយខ្លួន បើគេចង់ឲ្យកូនរបស់ខ្លួន ជួយឧបត្ថម្ភដល់ខ្លួនគេដែរ ។

★ គ្មានអ្វីលំបាកវេទនាជាងពួកជនកាន់អំណាចផ្ដាច់ការ ដែលមានភាពចាស់ជរានោះទេ ។

★ នៅក្នុងវាសនាអភ័ព្វ អ្វីៗដែលនាំយើងឲ្យបានស្គាល់សេចក្ដីស្ងប់ស្ងាត់ គឺការយល់ដឹងជាក់ច្បាស់ថា ពពួកជនដែលបានធ្វើទុក្ខបុកម្នេញមកលើរូបយើង ក៏ជាពពួកអ្នកមានវាសនាអភ័ព្វដូចរូបយើងដែរ ។

★ កុំចង់បានអ្វីៗដែលដណ្ដើមបានពីគេយកមកធ្វើជារបស់យើង ។

★ សុភមង្គលពិតប្រាកដ គឺតែងបានមកពីសុខភាពល្អ ពីទ្រព្យសម្បត្តិដ៏សមរម្យ ( មនុស្សសប្បាយចិត្តគឺតែងសប្បាយចិត្តនឹងរបស់បន្តិចបន្តួចដែលគេមាន ) និងបានពីជីវិតមួយ ដែលមិនមែនស្ថិតនៅក្នុងសេចក្ដីខ្ជិលច្រអូសនិងអវិជ្ជា...។

ត្អាលែសយល់ថា គ្មានរឿងអ្វីដែលលំបាកជាងការស្គាល់ខ្លួនឯងនោះទេ ៖ ហេតុដូច្នេះហើយទើបបានជាគាត់បង្កើតសុភាសិតមួយ ដែលគេបានឆ្លាក់ឆ្លៃនៅលើសន្លឹកមាស ព្រមទាំងបានថ្វាយទៅព្រះវិហារអាប៉ូឡុង ៖ « ចូរឯងស្គាល់ចិត្តគំនិតរបស់ខ្លួនឯង » ។

គាត់បានងះអាងថា ជីវិតហើយនិងសេចក្ដីស្លាប់គ្មានអ្វីខុសគ្នាត្រង់ណាសោះទេ ។ លុះដល់គេសួរដេញដោលគាត់ថា ហេតុអ្វីបានជាគាត់មិនព្រមស្លាប់តែម្ដងទៅ... គាត់បានឆ្លើយថា រស់និងស្លាប់ជារបស់តែមួយ... គ្មានអ្វីដែលអាចជំរុញឲ្យគាត់ជ្រើសរើសយករបស់មួយ ជាជាងរបស់មួយទៀតនោះឡើយ ។

គាត់តែងតែមានអារម្មណ៍សប្បាយរីករាយនៅក្នុងកំណាព្យកាព្យឃ្លោង ។ គេបាននិយាយថា គឺគាត់នេះហើយដែលបានបង្កើតក្បួនកំណាព្យពាក្យប្រាំបី...

ថ្ងៃមួយ បុរសម្នាក់ដែលត្រូវគេចោទថា បានលួចប្រពន្ធគេ បានមកជួបគាត់ដើម្បីសួរគាត់ថា តើខ្លួនគេគួរតែធ្វើសេចក្ដីសច្ចាប្រណិធានឬទេ ? ត្អាលែសបានឆ្លើយចំអកទៅជននោះវិញថា តើការភរភូតក្រោមសម្បថ ជាទោសមួយស្រាលជាងការលួចប្រពន្ធគេដែរឬទេ ? ។

នាយម៉ង់ទ្រៃតដីពីរ៉េន ដែលធ្លាប់ធ្វើការជាសារីករបស់គាត់ ថ្ងៃមួយបានមកជួបគាត់នៅមីឡេត៍ ហើយនិយាយទៅកាន់គាត់ថា ៖ « ឱ! ត្អាលែស តើមានរង្វាន់អ្វីដែលលោកចង់បានពីខ្ញុំ ដើម្បីបង្ហាញសេចក្ដីដឹងគុណរបស់ខ្ញុំចំពោះលោក ដែ-លបានណែនាំខ្ញុំឲ្យមានចំណេះដឹងនូវសុភាសិតដ៏ល្អទាំងឡាយ ដែលខ្ញុំជំពាក់រូបលោក ? » ។ « ប្រសិនបើលោកមានឱកាសបង្ហាត់បង្រៀនអ្នកដទៃ, នេះជាចម្លើ-យរបស់ត្អាលែស, ចូរលោកប្រាប់អ្នកទាំងនោះថា គឺខ្ញុំនេះហើយដែលបាននិពន្ធទ្រឹស្ដីទាំងនេះ ៖ ចំពោះរូបលោក គឺជាសេចក្ដីសុភាពរាបសារមួយគួរឲ្យកោតសរ-សើរ, រីឯចំពោះរូបខ្ញុំ គឺជារង្វាន់មួយដ៏មានតម្លៃរកអ្វីប្រៀបគ្មាន » ។

ត្អាលែស គឺជាជនជាតិក្រិកទី១ ដែលបានធ្វើការស្រាវជ្រាវក្នុងវិទ្យាសាស្ត្រពិ-សោធន៍ និងនៅក្នុងផ្នែកតារាសាស្ត្រ ។ គាត់បានយល់ថា ទឹកជាវត្ថុធាតុទី១ដែលជាដើមចមនៃវត្ថុធាតុគ្រប់យ៉ាង; គាត់បានយល់ថា ផែនដីគឺជាដុំទឹកខាប់ ចំណែកខ្យល់គឺជាទឹកដែលក្រខ្សត់ ។ របស់អ្វីៗក៏ដោយ តែងតែផ្លាស់ប្ដូរធាតុខ្លួនចូលគ្នាទៅវិញទៅមកជានិច្ចជាកាល ( <u>កំណត់អ្នកបកប្រែ</u> ៖ ក្នុងករណីនេះ យើងបានកត់សម្គាល់ឃើញថា ទ្រឹស្ដីដ៏ល្បីល្បាញរបស់អ្នកប្រាជ្ញគីមីបារាំងក្នុងសតវត្សទី១៨ម្នាក់ឈ្មោះ Lavoisier... តាមពិតគឺជាទ្រឹស្ដីរបស់ត្អាលែសសោះ ៖ « Rien ne se perd, rien ne se crée; tout se transforme » ) ។

ត្អាលែសបានយល់ថា អ្វីៗក៏ដោយនៅទីចុងចប់ទៅ ក៏បានក្លាយទៅជាធាតុទឹក

ទាំងអស់... ពិភពលោកទាំងមូល ត្រូវពោរពេញទៅដោយរូបសត្វដែលយើងមើ-លមិនឃើញ ហើយដែលហិចហើរចុះហើរឡើងពីគ្រប់ទិស ។ គាត់យល់ថាផែនដីវិលជុំវិញមជ្ឈមណ្ឌលរបស់ខ្លួនឯង ដែលជាមជ្ឈមណ្ឌលតែមួយរបស់ចក្រវា-ល រីឯទឹកសមុទ្រវិញដែលផែនដីនេះស្ថិតនៅពីបាន ជំរុញឲ្យមានការកំរើករញ្ជួយក្លាយទៅជាចលនារបស់ផែនដី ។

ឥទ្ធិពលស័ក្តិសិទ្ធិរបស់ដែកឆក់និងជាតិអង្គាំ ហើយនិងមហាមេត្រីរវាងអ្វីៗដែលមានធាតុដូចគ្នា បានណែនាំឲ្យត្លាលែសយល់ឃើញថា គ្មានអ្វីៗនៅក្នុងលោកនេះដែលគ្មានជីវិតនោះទេ ។

គាត់បានយល់ថា បុព្វហេតុដែលបណ្តាលឲ្យមានទឹកជំនន់នៅទន្លេនីល ( ប្រទេសអេយីព្ទ ) គឺមកពីខ្យល់ ( សមុទ្រ Méditerranée ) ដែលបក់ពីជើងមកត្បូងបានពន្យឺតចលនាទឹកទន្លេដែលហូរពីជើងទៅត្បូងវិញ ដែលជាហេតុបង្ខំឲ្យទឹកទ-ន្លេកំពប់ហូរហៀរបាចសាចចូលក្នុងស្រែចំការ ។

ត្លាលែសជាអ្នកប្រាជ្ញទី១ ដែលបានទស្សន៍ទាយអំពីចលនាសុគ្រាសនិងរាហ៊ូចាប់ចន្ទ... និងបានធ្វើការសង្កេតទៅលើចលនាផ្សេងៗនៃផ្កាយទាំងពីរនេះ ។ គាត់បានយល់ថា ព្រះអាទិត្យជាដុំផ្កាយដែលមានពន្លឺពីខ្លួនឯង ហើយដុំផ្កាយនោះមានទំហំ១២០ដងលើសព្រះច័ន្ទ ។ គាត់បានយល់ថា ព្រះច័ន្ទគឺជាដុំផ្កាយមួយដែលមានពន្លឺជ្រាបចូលមិនធ្លុះ ហើយដែលគ្រាន់តែមានលទ្ធភាពចាំងពន្លឺព្រះអាទិត្យត្រឡប់ទៅវិញ ដូចជាកញ្ចក់ប៉ុណ្ណោះ តាមរយៈផ្ទៃមួយចំហៀងរបស់ខ្លួនឯង ។ ហើយយោងតាមការសន្និដ្ឋានបែបនេះ គាត់ក៏បានពន្យល់ពីទំរង់ផ្សេងៗរបស់ព្រះច័ន្ទដែលបានលេចឡើងឲ្យយើងឃើញ ។

គឺគាត់នេះហើយ ជាអ្នកប្រាជ្ញទី១ដែលបានសិក្សាអំពីដើមកំណើតនៃព្រះពា-យ, អំពីធាតុនៃរន្ទះ, បុព្វហេតុនៃផ្លេកបន្ទោរ និងផ្គរលាន់ ។

ក្នុងសាវតាដែលកើតមានឡើងមុនរូបគាត់ ពុំមាននរណាម្នាក់មានសមត្ថភាពអាចវាស់វែងកំពស់នៃប៉មនិងបូរ៉ាមីឌ... ដោយយោងតាមស្រមោលដែលប៉មទាំងនេះជះទៅទិសខាងត្បូង នៅពេលដែលពន្លឺព្រះអាទិត្យកាត់ចំពាក់កណ្តាលផែនដី ( បណ្តាលឲ្យថ្ងៃនិងយប់មានក៏រិតវេលាស្មើគ្នា ៖ ក្នុងមួយឆ្នាំមានពីរថ្ងៃ ដែលយប់និងថ្ងៃមានក៏រិតវេលាស្មើគ្នា គឺថ្ងៃ២១មិនា និងថ្ងៃទី២២ឬ២៣កញ្ញា ) ។

ត្លាលែសបានក៏រិតឆ្នាំមកត្រឹម៣៦៥ថ្ងៃ ។ គាត់បានរៀបចំក្បួនច្បាប់នៃរដូវ ហើយបានក៏រិតខែមកត្រឹម៣០ថ្ងៃ ៖ កាលរយៈវេលា១២ខែបានកន្លងផុតទៅ គាត់តែងតែបន្ថែមប្រាំថ្ងៃ ដើម្បីគំរប់ដំណើរមួយជុំរបស់ឆ្នាំ ។ ក្បួនច្បាប់នេះគាត់បានរៀនចេះពីពួកជនជាតិអេយីព្ទ ។

គឺគាត់នេះហើយដែលបានផ្ដល់នូវចំណេះដឹងអំពីក្រុមផ្កាយដុះកន្ទុយដែលមានទិសដៅទៅផ្នែកខាងជើង ( La petite ourse ), ដែលពួកជនជាតិហ្វេនីស៊ីបានប្រើប្រាស់សំរាប់ក្បួននាវាចររបស់ពួកគេ ។

ថ្ងៃមួយ នៅពេលដែលគាត់ដើរចេញពីផ្ទះ ដើម្បីទៅសម្លឹងមើលមេឃផ្កាយ ក៏ស្រាប់តែគាត់ភ្លាត់ជើងធ្លាក់ចូលទៅក្នុងស្នាមភ្លោះ ។ ស្រីបំរើចាស់នៅក្នុងផ្ទះរបស់គាត់ម្នាក់ ក៏បានស្ទុះរលះរលាំងទៅជួយស្រង់យកគាត់ចេញពីអន្លង់មកវិញ ព្រមទាំងបានចំអកឲ្យគាត់ថា ៖

– យីអើត្លាលែស! លោកពូកែតែមើលទៅមេឃផ្កាយ ប៉ុន្តែលោកមើលមិនឃើញអ្វីៗដែលនៅជាប់នឹងជើងលោកសោះ ! ។

ពេញមួយជីវិតរបស់ត្លាលែស គាត់បានរស់នៅក្នុងសេចក្ដីកោតស្ញប់ស្ញែងរបស់អ្នកផង ។ គេបានមកសាកសួរគាត់ ក្នុងរឿងសំខាន់ៗគ្រប់យ៉ាង ។ ស្ដេចក្រេស៊ុស បន្ទាប់ពីបានធ្វើសង្គ្រាមជាមួយនឹងជនជាតិពែរ្ស ( អៀរ៉ង់ )... ក៏បានដឹកនាំកងទ័ពរបស់គាត់រហូតដល់មាត់ទន្លេហាលីស ។ ស្ដេចអង្គនេះ មានការអល់អែកយ៉ាងខ្លាំង ពីព្រោះមិនដឹងថាត្រូវឆ្លងទន្លេយ៉ាងណា ដោយទ្រង់ពុំមានស្ពាន ពុំមាននាវា ហើយទឹកទន្លេទៀតសោតក៏ជ្រៅ ។ ត្លាលែសដែលនៅពេលនោះ បានដើរមកជួបប្រទះជំរំរបស់ស្ដេច ក៏បានអះអាងទូលទ្រង់ថា គាត់មានមធ្យោបាយដើម្បីអនុញ្ញាតឲ្យកងទ័ពរបស់ទ្រង់ឆ្លងទន្លេបាន ដោយមិនបាច់ប្រើស្ពាននិងនាវា...។ ក្នុងរំពេជនោះ គាត់ក៏បានបញ្ជាឲ្យគេជីកប្រឡាយមានរាងជាចំណិតព្រះច័ន្ទ តាំងពីដើមជំរំរហូតទៅចុងជំរំ...។ ទន្លេក៏បែកផ្លូវជាពីរ ( ជំពាមព្រែក )... ហើយដៃទន្លេទាំងពីរត្រូវឆ្លងកាត់គ្រប់ទីកន្លែង ចំណែកកងទ័ពក៏បានឆ្លងត្រើយខាងម្ខាងដោយគ្មានការលំបាក ។

ត្លាលែសមិនបានអនុញ្ញាតក្នុងឱកាសនោះ ឲ្យជនជាតិមីឡេត៍ចងសម្ពន្ធយោធាជាមួយស្ដេចក្រេស៊ុសនោះឡើយ ថ្វីបើទ្រង់បានទទូចយ៉ាងណាក៏ដោយ ។ គឺការប្រុងប្រយ័ត្នរបៀបនេះហើយ ដែលបានធ្វើឲ្យប្រជាជាតិរបស់គាត់នៅគង់វង្ស ។ គឺដោយហេតុថាស្ដេចសៀរុស ដែលបានច្បាំងឈ្នះជនជាតិលីឌី ក៏បានកំទេចគ្រប់ទីក្រុងណាៗទាំងអស់ ដែលបានចូលដៃជាមួយពួកជនក្រោយនេះ... ក៏ប៉ុន្តែបានទុកស្រុកមីឡេត៍មួយឲ្យរួចខ្លួន... ពីព្រោះស្រុកនេះពុំមានការប្រាថ្នាអាក្រក់ទៅលើពួកគេទេ ។

ត្លាលែសនៅពេលចាស់ជរាពេកណាស់ទៅហើយ បានឲ្យគេសែងរូបគាត់ទៅលើដីទួល ដើម្បីទស្សនាការប្រយុទ្ធនៅក្នុងឆាកល្ខោនមួយ ។ ចំហាយក្ដៅយ៉ាងខ្លាំងនៅក្នុងពេលនោះ ក៏បានបណ្ដាលឲ្យសារពាង្គកាយរបស់គាត់ទទួលឥទ្ធិពលផ្លា

ស់ប្អូរ... គាត់ក៏បានទទួលសេចក្ដីស្លាប់មួយរំពេជ នៅចំត្រង់កន្លែងដែលគាត់កំពុងតែទស្សនាការប្រយុទ្ធ ។ គឺនៅក្នុងអូឡាំព្យាដទី៥៨ និងឆ្នាំ៩២នៃអាយុរបស់គាត់ ។ ជនជាតិមីឡេត៍ក៏បានរៀបចំឈាបនកិច្ចយ៉ាងអធិកអធមចំពោះរូបគាត់ ។

(កំណត់បន្ថែមរបស់អ្នកបកប្រែ៖ ត្លាលែសមានកំណើតតំណាលគ្នា និងយុគសម័យព្រះពុទ្ធសមណគោត្តម គឺ៦សតវត្សមុនគ្រីស្តសករាជ ។ គឺជាទស្សវិទូក្រិកនិងអ្នកប្រាជ្ញគណិតសាស្ត្រទី១ ដែលបានទុកទ្រឹស្តីថា ៖ « ខ្សែស្របពីរដែលសម ស្របជាមួយនឹងខ្សែទី៣ គឺសមស្របជាមួយគ្នាទាំងអស់ » ( **Deaux droites parallèles à une même troisième sont paralèlles entre elles** ) ។៚

□ □

□

# ជីវិតរបស់ត្ថាលែស
# THALÈS

[ កើតនៅឆ្នាំទី១នៃអូឡាំផ្យាដទី៣៥ ( កីឡាអូឡាំពីក )–ស្លាប់នៅក្នុងអូឡាំផ្យាដទី៥៨, មានអាយុ៩២ឆ្នាំ ]

ត្ថាតែល, ជនជាតិមីឡេស៊ីយាង, មានដើមកំណើតនៅប្រទេសហ្វេនីស៊ី, ជាកូនសែស្រឡាយរបស់កាដមុស្ស កូនប្រុសរបស់អាគ្តេនរ ។

ដោយឪពុកម្តាយរបស់ត្ថាលែសមានការស្អប់ខ្ពើមជាខ្លាំង ចំពោះអ្នកកាន់អំណាចផ្តាច់ការ ដែលធ្វើបាបជិះជាន់សង្កត់សង្កិនពួកប្រជាពលរដ្ឋដែលមានសន្តានចិត្តល្អ, អ្នកទាំងនោះក៏ដាច់ចិត្តចាកចេញពីស្រុកមីឡេត៍, ពីទីក្រុងយ៉ូនី ដែលត្ថាលែសមានកំណើតកើតនៅក្នុងឆ្នាំទី១នៃអូឡាំផ្យាដទី៣៥ ។ បុគ្គលនេះជាបុគ្គលទី១ ដែលបានទទួលកិត្តិនាមជាអ្នកប្រាជ្ញ... ដោយគាត់បានបង្កើតទស្សនវិជ្ជាម៉្យាងឈ្មោះថា យ៉ូនីក... គឺឈ្មោះដកស្រង់ចេញពីទីក្រុងកំណើតរបស់គាត់ ។

បុគ្គលនេះបានចូលបំពេញកិច្ចការងារនៅក្នុងក្រសួងតុលាការអស់មួយរយៈពេល, ហើយបន្ទាប់ពីបានធ្វើការដោយមានកេរ្តិ៍ឈ្មោះល្អក្នុងនាទីសំខាន់ៗ នៅក្នុងក្រសួងនេះហើយ... គាត់ក៏បានចាកចេញស្វែងទៅរកសិក្សាស្វាធ្យាយន៍អាថ៌កំបាំងនៃធម្មជាតិវិញ... ដោយគាត់មិនចូលចិត្តជាប់ដៃជាប់ជើង និងសភាពតឹងតែងនៃកិច្ចការសាធារណៈនិងនយោបាយ ។ គាត់បានធ្វើដំណើរទៅប្រទេសអេយីព្ទ ដែលនៅទីនោះ វិទ្យាសាស្ត្រផ្សេងៗកំពុងតែលូតលាស់បែកផ្លែផ្កាពេញទំហឹង ៖ គាត់ក៏បានចំណាយពេលវេលាអស់ជាច្រើនឆ្នាំ ដើម្បីពិភាក្សាជាមួយនឹងពួកគ្រូអាចារ្យធំៗ ដែលសុទ្ធសឹងជាក្រុមបណ្ឌិតនៅក្នុងប្រទេសនេះ ។ គាត់បានសិក្សាស្រាវជ្រាវ ពីភិនភាគសម្ងាត់នៃសាសនារបស់ពួកគេ ហើយបានយកចិត្តទុកដាក់យ៉ាងខ្លាំងជាទីបំផុតខាងផ្នែករេខាគណិត ( géométrie ) និងខាងផ្នែកតារាសាស្ត្រ ។ គាត់ពុំបានជាប់ចិត្តជាប់ថ្លើមបំរើលោកគ្រូធំណាម្នាក់ទេ...។ ក្រៅពីទំនាក់ទំនងដែលគាត់ធ្លាប់មានជាមួយនិងអ្នកប្រាជ្ញអេយីព្ទ... គាត់គ្មានការពិសោធន៍ឯណាទៀតទេក្រៅតែពីការពិសោធន៍ស្រាវជ្រាវរបស់ខ្លួនឯង ។ គឺការពិសោធន៍ពិចារណាដ៏ជ្រា–

លជ្រៅ និងចំណេះដឹងដែលគាត់បានប្រមែប្រមូលឱបក្រសោបដោយការសិក្សាផ្ទាល់ខ្លួនឯង... គាត់ក៏បានយកចំណេះដឹងទាំងនេះ មកពង្រីកចងក្រងជាទស្សន-វិជ្ជារបស់គាត់ ។

ត្លាលែសមានសម្បជ្ញញ្ញៈខ្ពង់ខ្ពស់ណាស់... និយាយតិច, តែគិតពិចារណាច្រើន ។ គាត់មិនដែលគិតអំពីប្រយោជន៍ផ្ទាល់ខ្លួនរបស់គាត់ទេ... គាត់មានការចាប់អារម្មណ៍យ៉ាងខ្លាំងតែទៅលើប្រយោជន៍នៃសាធារណរដ្ឋរបស់គាត់តែប៉ុណ្ណោះ ។

ជនម្នាក់ឈ្មោះយុវេណាល់... ពេលនិយាយពីមនុស្សខ្លះដែលជឿជាក់ថា ការសងសឹកជាទ្រព្យសម្បត្តិដ៏សំខាន់ជាងគេនៅក្នុងជាតិនេះ... បានពោលថា មនោ-សញ្ចេតនានៃការស្អប់គុំគួននិងសងសឹក ពុំមែនជាមនោសញ្ចេតនានៃពួកក្រុមគ្រូ-សារគ្រីស្ស៊ីព ( ឪពុកម្តាយរបស់ត្លាលែស ) និងពុំមានឋិតនៅក្នុងលក្ខណៈទន់ភ្លន់របស់ត្លាលែសនោះទាល់តែសោះ ! ។

**At vindicta bonum vitâ jueundius ipsâ; Chrisippus non dicet idem, nec mite Thaletis Ingenium...**

នៅពេលដែលត្លាលែសត្រឡប់មករស់នៅស្រុកមីឡេត៍ បុគ្គលនេះរស់នៅក្នុងការស្ងប់ស្ងាត់តែម្នាក់ឯង ហើយគិតតែពីត្រិះរិះពិចារណាក្នុងរឿងអ្វីៗដែលទាក់ទងនឹងមេឃផ្កាយ ។ សេចក្តីស្រឡាញ់ជាប់ចិត្ត និងបញ្ញា និងវិចារណញ្ញាណ បានណែនាំឲ្យគាត់ចូលចិត្តជីវិតរស់នៅជាមនុស្សទោលឥតប្រពន្ធ... គឺធ្វើឲ្យគាត់ចៀសចេញឆ្ងាយពីរឿងចំណងអាពាហ៍ពិពាហ៍ ។ នៅពេលនោះ គាត់ទើបមានអាយុ ២៣ឆ្នាំ ក៏ស្រាប់តែម្តាយគាត់ អ្នកស្រីក្លេអូប៊ូលីនបានបង្ខំឲ្យគាត់រៀបការជាមួយកូនស្រីអ្នកមានម្នាក់ ។ ត្លាលែសក៏បានពោលថា ៖ « កាលណាគេនៅក្មេង... គឺមិនទាន់ដល់ពេលរៀបការទេ; កាលណាគេក្លាយទៅជាមនុស្សចាស់ជរា ក៏វាហួសពេលទៅហើយ ។ ចំណែកមនុស្សដែលឋិតនៅក្នុងចន្លោះនៃអាយុទាំងពីរនេះ គឺច្បាស់ជាពុំសូវមានពេលទំនេរគ្រប់គ្រាន់ដើម្បីស្វែងរកប្រពន្ធនោះទេ » ។ ប៉ុន្តែពាក្យអ្នកខ្លះបានពោលថា នៅពេលគាត់ចាស់ទៅ ត្លាលែសបានយកប្រពន្ធម្នាក់ជាស្រីជាតិអេយីព្ទ ។ គឺជាស្រីម្នាក់ដែលចេះផលិតរបស់របរល្អៗច្រើនបែបច្រើនយ៉ាង ។

ថ្ងៃមួយ មានពួកបរទេសបានចូលមកក្នុងស្រុកម៉ាឡេត៍ ដោយឆ្លងកាត់តាមកោះកូ... ពួកជនទាំងនោះបានជួលអ្នកនេសាទឲ្យបង់សំណាញ់ចាប់ត្រីឲ្យពួកគេ ។ ពួកអ្នកនេសាទបានបង់សំណាញ់នៅក្នុងសមុទ្រ មិនចាប់បានត្រីបែរជាយកបានជើងតាំងមួយធ្វើពីមាសសុទ្ធដែលព្រះនាងអេឡែន ( Hélène ស្តេចស្រីក្រិក ) នៅពេលត្រឡប់មកពីក្រុងត្រូយវិញបានទម្លាក់ចោលនៅទីកន្លែងនោះ ។

ការបង់សំណាញ់បានជើងតាំងមានដូច្នេះ ក៏បានបង្កើតឲ្យមានជម្លោះជាខ្លាំង

រវាងពួកជនបរទេសនិងពួកអ្នកនេសាទ ដែលជជែកតវ៉ាគ្នាអ៊ឹងកងតណ្តើមគ្នាយករបស់មានតម្លៃ ។ បន្ទាប់មក ពួកអាជ្ញាក្រុងក៏បានចូលមកលាយឡំនៅក្នុងរឿងនេះដោយប្រកាន់យកត្រូវសំរាប់មនុស្សពួកគេរៀងៗខ្លួន ។ សង្គ្រាមមួយហៀបនឹងផ្ទុះឡើងរវាងទីក្រុងផ្សេងៗទៅហើយ ក៏ស្រាប់តែអ្នកខ្លះមានយោបល់ថា គួរតែយករឿងនេះទៅឲ្យហោរានៅភ្នំដេលហ្វជាអ្នកសំរេចវិញ ។ គេក៏បានបញ្ជូនបេសកជនទៅភ្នំដេលហ្វ; ហោរាបានឆ្លើយថា ត្រូវតែយកជើងតាំងមាសទៅប្រគល់ឲ្យអ្នកប្រាជ្ញទីមួយ ។ អ្នកផងក៏លើកយកជើងតាំងមាសនេះ ទៅប្រគល់ត្លាលែស ។ ត្លាលែសមិនព្រមទទួលយក ក៏បញ្ជូនរបស់នេះទៅឲ្យអ្នកចេះដឹងម្នាក់ទៀតឈ្មោះប៊ីយ៉ាស ។ ដោយសេចក្តីសុភាពរាបសារ ប៊ីយ៉ាសក៏បានបញ្ជូនតៗគ្នា រហូតធ្លាក់ទៅក្នុងកណ្តាប់ដៃរបស់សូឡុង ។ បុគ្គលក្រោយនេះក៏បានពោលថា គ្មានមនុស្សណាម្នាក់ដែលមានបញ្ញាញាណជាងព្រះនោះទេ ម្ល៉ោះហើយក៏បានបញ្ជូនរបស់នេះទៅថ្វាយតាំងជាគ្រឿងអាសនៈរបស់ព្រះអាប៉ូឡុង ( ព្រះពិស្ណុការរបស់ជនជាតិក្រិក ) នៅភ្នំដេលហ្វ ( គួរកត់សំគាល់ថា នៅសហរដ្ឋអាមេរិកសព្វថ្ងៃ មានទីក្រុងមួយឈ្មោះ « ហ្វីឡាដេលហ្វីយ៉ា » គឺមានន័យថា « សេចក្តីស្នេហាចំពោះភ្នំដេលហ្វ » ) ។

មានពួកយុវជនខ្លះនៅក្នុងក្រុងម៉ាឡេត៍ បានស្តីបន្ទោសឲ្យត្លាលែសថា មុខវិជ្ជាដែលគាត់ខំស្រាវជ្រាវ គ្មានបានផ្តល់ផលប្រយោជន៍អ្វីដល់គាត់ទេ... ពីព្រោះគេឃើញតែគាត់រស់នៅក្នុងសេចក្តីក្ររហេមរហាមរហូត ។ ត្លាលែសចង់បង្ហាញឲ្យពួកទាំងអស់នោះយល់ឃើញថា បើពួកក្រុមអ្នកប្រាជ្ញ មិនដែលប្រមែប្រមូលទ្រព្យបានទ្រព្យសម្បត្តិច្រើន គឺព្រោះដោយហេតុថា ពួកគេមើលងាយមើលស្រាលចំ–ពោះមាសពេជ្រកែវកង ដែលគេមិនដឹងយកទៅធ្វើអ្វី... ក៏ប៉ុន្តែបើពួកគេបានសំរេចថាធ្វើអ្នកមានអ្នកបាននោះវិញ ក៏គ្មានអ្វីជាការពិបាកចំពោះពួកគេដែរ ។

យោងតាមពាក្យសំដីរបស់ប្រជាពលរដ្ឋក្រិក ដែលនិយាយតៗគ្នាពីសម័យនោះ... គេថាត្លាលែសជាមនុស្សដែលចេះគន់គូរទុកជាមុនអំពីរឿងមេឃផ្កាយ ជាពិសេសបានទាយទុកពីផលិតផលល្អនៃកសិកម្មនៅក្នុងឆ្នាំដែលគេរស់នៅ ។ មុនរដូវមកដល់ គាត់បានទិញផ្លែអូលីវទាំងអស់នៅជុំវិញស្រុកម៉ាឡេត៍ ។ ផលិតផលក៏មានសំបូរដូចការទស្សន៍ទាយពិតមែន... ត្លាលែសក៏បានទទួលការចំណេញដ៏សន្ធឹកសន្ធាប់ ក៏ប៉ុន្តែដោយរូបគាត់ពុំមែនជាអ្នកគិតពីប្រយោជន៍... គាត់ក៏បានសុំឲ្យមានការរួមប្រជុំនៃពួកអ្នកជំនួញទាំងអស់នៅស្រុកម៉ាឡេត៍ ហើយគាត់ក៏បានចែកចាយការចំណេញរបស់គាត់ទាំងអស់ទៅពួកអ្នកជំនួញទាំងនោះ ។

ត្លាលែសធ្លាប់បានសំដែងសេចក្តីអំណរគុណចំពោះព្រះក្នុងរឿងបីយ៉ាង ៖ គឺបានកើតមកជាមនុស្សមានបញ្ញា មិនមែនជាមនុស្សភ្លីភ្លើ; បានកើតមកជាប្រុស មិ

នមែនជាស្រី; បានកើតមកជាជនជាតិក្រិក ពុំមែនកើតមកជាជនព្រៃផ្សៃ ។

ត្លាលែសមានទស្សនៈថា ពិភពលោកបានត្រូវរៀបចំឡើងដោយបញ្ញាខ្ពង់ខ្ពស់មួយ ដែលគ្មានការចាប់ផ្តើមនិងគ្មានទីចប់ ។ គាត់ជាជនជាតិក្រិកទី១ដែលបានបង្ហាត់បង្រៀនថា ព្រលឹងវិញ្ញាណរបស់មនុស្ស (អាត្ម័ន)ជារបស់ដែលចេះស្លាប់ ។

ថ្ងៃមួយមានបុរសម្នាក់ដែលបានទៅសួរគាត់ថា តើមនុស្សយើងអាចលាក់បីទបាំងអំពើរបស់យើងចំពោះព្រះបានទេ ។ គាត់បានឆ្លើយតបថា ចិត្តគំនិតរបស់យើង ទោះជាមានលក្ខណៈជាអាថ៌កំបាំងនិងជាការសម្ងាត់យ៉ាងណាក៏ដោយ ក៏មិនអាចបីទជិតជាមួយនឹងព្រះបានដែរ ។

ត្លាលែសបានពោលថា របស់ដែលធំជាងគេនៅក្នុងលោក គឺទីកន្លែង ពីព្រោះទីកន្លែងមានចំណុះមនុស្សសត្វនិងធម្មជាតិទាំងអស់... របស់ដែលខ្លាំងជាងគេ គឺការចាំបាច់ ពីព្រោះការចាំបាច់នឹងនាំឲ្យឈ្នះនូវអ្វីៗគ្រប់យ៉ាង; របស់ដែលមានល្បឿនលឿនជាងគេ គឺចិត្តគំនិត... ពីព្រោះនៅក្នុងរយៈពេលតែមួយភ្លែតសោះ ចិត្តថ្លើមរបស់មនុស្សអាចឆ្លងកាត់រហូតដល់ចក្រវាល; របស់ដែលមានបញ្ញាជាងគេ គឺពេលវេលា ពីព្រោះពេលវេលានឹងអាចលាតត្រដាងនូវអាថ៌កំបាំងគ្រប់យ៉ាង; របស់ដែលគួរឲ្យសប្បាយនិងប្រកបដោយសុភមង្គលជាទីបំផុត គឺការធ្វើកិច្ចការអ្វីៗស្របតាមឆន្ទៈរបស់ខ្លួន ។

★ គាត់បានពោលអះអាងជាច្រើនដងថា ការនិយាយច្រើនពុំមែនជាសញ្ញានៃបញ្ញាញាណនោះទេ ។

★ គេត្រូវនឹកឃើញដល់មិត្តភក្តិស្មើគ្នា ទោះនៅជិតក្តី ទោះនៅឆ្ងាយក្តី ។

★ គេត្រូវជួយឧបត្ថម្ភដល់ឪពុកម្តាយខ្លួន បើគេចង់ឲ្យកូនរបស់ខ្លួន ជួយឧបត្ថម្ភដល់ខ្លួនគេដែរ ។

★ គ្មានអ្វីលំបាកវេទនាជាងពួកជនកាន់អំណាចផ្តាច់ការ ដែលមានភាពចាស់ជរានោះទេ ។

★ នៅក្នុងវាសនាអភ័ព្វ អ្វីៗដែលនាំយើងឲ្យបានស្គាល់សេចក្តីស្ងប់ស្ងាត់ គឺការយល់ដឹងជាក់ច្បាស់ថា ពពួកជនដែលបានធ្វើទុក្ខបុកម្នេញមកលើរូបយើង ក៏ជាពពួកអ្នកមានវាសនាអភ័ព្វដូចរូបយើងដែរ ។

★ កុំចង់បានអ្វីៗដែលដណ្តើមបានពីគេយកមកធ្វើជារបស់យើង ។

★ សុភមង្គលពិតប្រាកដ គឺតែងបានមកពីសុខភាពល្អ ពីទ្រព្យសម្បត្តិដ៏សមរម្យ ( មនុស្សសប្បាយចិត្តគឺតែងសប្បាយចិត្តនឹងរបស់បន្តិចបន្តួចដែលគេមាន ) និងបានពីជីវិតមួយ ដែលមិនមែនស្ថិតនៅក្នុងសេចក្តីខ្ជិលច្រអូសនិងអវិជ្ជា...។

ត្លាលែសយល់ថា គ្មានរឿងអ្វីដែលលំបាកជាងការស្គាល់ខ្លួនឯងនោះទេ ៖ ហេតុដូច្នេះហើយទើបបានជាគាត់បង្កើតសុភាសិតមួយ ដែលគេបានឆ្លាក់ឆ្លៃនៅលើសន្លឹកមាស ព្រមទាំងបានថ្វាយទៅព្រះវិហារអាប៉ូឡុង ៖ « ចូរឯងស្គាល់ចិត្តគំនិតរបស់ខ្លួនឯង » ។

គាត់បានអះអាងថា ជីវិតហើយនិងសេចក្តីស្លាប់គ្មានអ្វីខុសគ្នាត្រង់ណាសោះទេ ។ លុះដល់គេសួរដេញដោលគាត់ថា ហេតុអ្វីបានជាគាត់មិនព្រមស្លាប់តែម្តងទៅ... គាត់បានឆ្លើយថា រស់និងស្លាប់ជារបស់តែមួយ... គ្មានអ្វីដែលអាចជំរុញឲ្យគាត់ជ្រើសរើសយករបស់មួយ ជាជាងរបស់មួយទៀតនោះឡើយ ។

គាត់តែងតែមានអារម្មណ៍សប្បាយរីករាយនៅក្នុងកំណាព្យកាព្យឃ្លោង ។ គេបាននិយាយថា គឺគាត់នេះហើយដែលបានបង្កើតក្បួនកំណាព្យពាក្យប្រាំបី...

ថ្ងៃមួយ បុរសម្នាក់ដែលត្រូវគេចោទថា បានលួចប្រពន្ធគេ បានមកជួបគាត់ដើម្បីសួរគាត់ថា តើខ្លួនគេគួរតែធ្វើសេចក្តីសច្ចាប្រណិធានឬទេ ? ត្លាលែសបានឆ្លើយចំអកទៅជននោះវិញថា តើការភរភូតក្រោមសម្បថ ជាទោសមួយស្រាលជាងការលួចប្រពន្ធគេដែរឬទេ ? ។

នាយម៉ង់ជ្រែតដឺពីរ៉េន ដែលធ្លាប់ធ្វើការជាសាវិករបស់គាត់ ថ្ងៃមួយបានមកជួបគាត់នៅមីឡេត៍ ហើយនិយាយទៅកាន់គាត់ថា ៖ « ឱ! ត្លាលែស តើមានរង្វាន់អ្វីដែលលោកចង់បានពីខ្ញុំ ដើម្បីបង្ហាញសេចក្តីដឹងគុណរបស់ខ្ញុំចំពោះលោក ដែលបានណែនាំខ្ញុំឲ្យមានចំណេះដឹងនូវសុភាសិតដ៏ល្អទាំងឡាយ ដែលខ្ញុំជំពាក់រូបលោក ? » ។ « ប្រសិនបើលោកមានឱកាសបង្ហាត់បង្រៀនអ្នកដទៃ, នេះជាចម្លើយរបស់ត្លាលែស, ចូរលោកប្រាប់អ្នកទាំងនោះថា គឺខ្ញុំនេះហើយដែលបាននិពន្ធទ្រឹស្តីទាំងនេះ ៖ ចំពោះរូបលោក គឺជាសេចក្តីសុភាពរាបសារមួយគួរឲ្យកោតសរសើរ, រីឯចំពោះរូបខ្ញុំ គឺជារង្វាន់មួយដ៏មានតម្លៃរកអ្វីប្រៀបគ្មាន » ។

ត្លាលែស គឺជាជនជាតិក្រិកទី១ ដែលបានធ្វើការស្រាវជ្រាវក្នុងវិទ្យាសាស្ត្រពិសោធន៍ និងនៅក្នុងផ្នែកតារាសាស្ត្រ ។ គាត់បានយល់ថា ទឹកជាវត្ថុធាតុទី១ដែលជាដើមចមនៃវត្ថុធាតុគ្រប់យ៉ាង; គាត់បានយល់ថា ផែនដីគឺជាដុំទឹកខាប់ ចំណែកខ្យល់គឺជាទឹកដែលក្រខ្សត់ ។ របស់អ្វីៗក៏ដោយ តែងតែផ្លាស់ប្តូរធាតុខ្លួនចូលគ្នាទៅវិញទៅមកជានិច្ចជាកាល ( <u>កំណត់អ្នកបកប្រែ</u> ៖ ក្នុងករណីនេះ យើងបានកត់សម្គាល់ឃើញថា ទ្រឹស្តីដ៏ល្បីល្បាញរបស់អ្នកប្រាជ្ញគីមីបារាំងក្នុងសតវត្សទី១៨ម្នាក់ឈ្មោះ Lavoisier... តាមពិតគឺជាទ្រឹស្តីរបស់ត្លាលែសសោះ ៖ « Rien ne se perd, rien ne se crée; tout se transforme » ) ។

ត្លាលែសបានយល់ថា អ្វីៗក៏ដោយនៅទីចុងចប់ទៅ ក៏បានក្លាយទៅជាធាតុទឹក

ទាំងអស់... ពិភពលោកទាំងមូល ត្រូវពោរពេញទៅដោយរូបសត្វដែលយើងមើលមិនឃើញ ហើយដែលហិចហើរចុះហើរឡើងពីគ្រប់ទិស ។ គាត់យល់ថាផែនដីវិលជុំវិញមជ្ឈមណ្ឌលរបស់ខ្លួនឯង ដែលជាមជ្ឈមណ្ឌលតែមួយរបស់ចក្រវាល រីឯទឹកសមុទ្រវិញដែលផែនដីនេះស្ថិតនៅពីបាន ជំរុញឲ្យមានការកំរើករញ្ជួយក្លាយទៅជាចលនារបស់ផែនដី ។

ឥទ្ធិពលស័ក្តិសិទ្ធិរបស់ដែកឆក់និងជាតិអង្កាំ ហើយនិងមហាមេត្រីរវាងអ្វីៗដែលមានធាតុដូចគ្នា បានណែនាំឲ្យត្លាលែសយល់ឃើញថា គ្មានអ្វីៗនៅក្នុងលោកនេះដែលគ្មានជីវិតនោះទេ ។

គាត់បានយល់ថា បុព្វហេតុដែលបណ្តាលឲ្យមានទឹកជំនន់នៅទន្លេនីល ( ប្រទេសអេយីព្ទ ) គឺមកពីខ្យល់ ( សមុទ្រ Méditerranée ) ដែលបក់ពីជើងមកត្បូងបានពន្យឺតចលនាទឹកទន្លេដែលហូរពីជើងទៅត្បូងវិញ ដែលជាហេតុបង្ខំឲ្យទឹកទន្លេកំពប់ហូរហៀរបាចសាចចូលក្នុងស្រែចំការ ។

ត្លាលែសជាអ្នកប្រាជ្ញទី១ ដែលបានទស្សន៍ទាយអំពីចលនាសុគ្រាសនិងរាហ៊ូចាប់ចន្ទ... និងបានធ្វើការសង្កេតទៅលើចលនាផ្សេងៗនៃផ្កាយទាំងពីរនេះ ។ គាត់បានយល់ថា ព្រះអាទិត្យជាដុំផ្កាយដែលមានពន្លឺពីខ្លួនឯង ហើយដុំផ្កាយនោះមានទំហំ១២០ដងលើសព្រះច័ន្ទ ។ គាត់បានយល់ថា ព្រះច័ន្ទគឺជាដុំផ្កាយមួយដែលមានពន្លឺជ្រាបចូលមិនធ្លុះ ហើយដែលគ្រាន់តែមានលទ្ធភាពចាំងពន្លឺព្រះអាទិត្យត្រឡប់ទៅវិញ ដូចជាកញ្ចក់ប៉ុណ្ណោះ តាមរយៈផ្ទៃមួយចំហៀងរបស់ខ្លួនឯង ។ ហើយយោងតាមការសន្និដ្ឋានបែបនេះ គាត់ក៏បានពន្យល់ពីទំរង់ផ្សេងៗរបស់ព្រះច័ន្ទដែលបានលេចឡើងឲ្យយើងឃើញ ។

គឺគាត់នេះហើយ ជាអ្នកប្រាជ្ញទី១ដែលបានសិក្សាអំពីដើមកំណើតនៃព្រះពាយ, អំពីធាតុនៃរន្ទះ, បុព្វហេតុនៃផ្គេកបន្ទោរ និងផ្គរលាន់ ។

ក្នុងសាវតាដែលកើតមានឡើងមុនរូបគាត់ ពុំមាននរណាម្នាក់មានសមត្ថភាពអាចវាស់វែងកំពស់នៃប៉មនិងបូរ៉ាមីឌ... ដោយយោងតាមស្រមោលដែលប៉មទាំងនេះជះទៅទិសខាងត្បូង នៅពេលដែលពន្លឺព្រះអាទិត្យកាត់ចំពាក់កណ្តាលផែនដី ( បណ្តាលឲ្យថ្ងៃនិងយប់មានកំរិតវេលាស្មើគ្នា ÷ ក្នុងមួយឆ្នាំមានពីរថ្ងៃ ដែលយប់និងថ្ងៃមានកំរិតវេលាស្មើគ្នា គឺថ្ងៃ២១មិនា និងថ្ងៃទី២២ឬ២៣កញ្ញា ) ។

ត្លាលែសបានកំរិតឆ្នាំមកត្រឹម៣៦៥ថ្ងៃ ។ គាត់បានរៀបចំក្បួនច្បាប់នៃរដូវ ហើយបានកំរិតខែមកត្រឹម៣០ថ្ងៃ ÷ កាលរយៈវេលា១២ខែបានកន្លងផុតទៅ គាត់តែងតែបន្ថែមប្រាំថ្ងៃ ដើម្បីគំរប់ដំណើរមួយជុំរបស់ឆ្នាំ ។ ក្បួនច្បាប់នេះគាត់បានរៀនចេះពីពួកជនជាតិអេយីព្ទ ។

គឺគាត់នេះហើយដែលបានផ្ដល់នូវចំណេះដឹងអំពីក្រុមផ្កាយដុះកន្ទុយដែលមានទិសដៅទៅផ្នែកខាងជើង ( La petite ourse ), ដែលពួកជនជាតិហ្វេនីស៊ីបានប្រើប្រាស់សំរាប់ក្បួននាវាចររបស់ពួកគេ ។

ថ្ងៃមួយ នៅពេលដែលគាត់ដើរចេញពីផ្ទះ ដើម្បីទៅសម្លឹងមើលមេឃផ្កាយ ក៏ស្រាប់តែគាត់ភ្លាត់ជើងធ្លាក់ចូលទៅក្នុងស្នាមភ្លោះ ។ ស្រីបំរើចាស់នៅក្នុងផ្ទះរបស់គាត់ម្នាក់ ក៏បានស្ទុះរលះរលាំងទៅជួយស្រង់យកគាត់ចេញពីអន្លង់មកវិញ ព្រមទាំងបានចំអកឲ្យគាត់ថា ៖

– យីអើត្ថាលែស! លោកពូកែតែមើលទៅមេឃផ្កាយ ប៉ុន្តែលោកមើលមិនឃើញអ្វីៗដែលនៅជាប់នឹងជើងលោកសោះ ! ។

ពេញមួយជីវិតរបស់ត្ថាលែស គាត់បានរស់នៅក្នុងសេចក្ដីកោតស្ញប់ស្ញែងរបស់អ្នកផង ។ គេបានមកសាកសួរគាត់ ក្នុងរឿងសំខាន់ៗគ្រប់យ៉ាង ។ ស្ដេចក្រេស៊ុស បន្ទាប់ពីបានធ្វើសង្គ្រាមជាមួយនឹងជនជាតិពែរ្ស ( អៀរ៉ង់ )... ក៏បានដឹកនាំកងទ័ពរបស់គាត់រហូតដល់មាត់ទន្លេហាលីស ។ ស្ដេចអង្គនេះ មានការអល់អែកយ៉ាងខ្លាំង ពីព្រោះមិនដឹងថាត្រូវឆ្លងទន្លេយ៉ាងណា ដោយទ្រង់ពុំមានស្ពាន ពុំមាននាវា ហើយទឹកទន្លេទៀតសោតក៏ជ្រៅ ។ ត្ថាលែសដែលនៅពេលនោះ បានដើរមកជួបប្រទះជំរំរបស់ស្ដេច ក៏បានអះអាងទូលទ្រង់ថា គាត់មានមធ្យោបាយដើម្បីអនុញ្ញាតឲ្យកងទ័ពរបស់ទ្រង់ឆ្លងទន្លេបាន ដោយមិនបាច់ប្រើស្ពាននិងនាវា...។ ក្នុងរំពេជនោះ គាត់ក៏បានបញ្ជាឲ្យគេជីកប្រឡាយមានរាងជាចំណិតព្រះច័ន្ទ តាំងពីដើមជំរំរហូតទៅចុងជំរំ...។ ទន្លេក៏បែកផ្លូវជាពីរ ( ជំពាមព្រែក )... ហើយដៃទន្លេទាំងពីរត្រូវឆ្លងកាត់គ្រប់ទីកន្លែង ចំណែកកងទ័ពក៏បានឆ្លងត្រើយខាងម្ខាងដោយគ្មានការលំបាក ។

ត្ថាលែសមិនបានអនុញ្ញាតក្នុងឱកាសនោះ ឲ្យជនជាតិមីឡេត៍ចងសម្ពន្ធយោធាជាមួយស្ដេចក្រេស៊ុសនោះឡើយ ថ្វីបើទ្រង់បានទទូចយ៉ាងណាក៏ដោយ ។ គឺការប្រុងប្រយ័ត្នរបៀបនេះហើយ ដែលបានធ្វើឲ្យប្រជាជាតិរបស់គាត់នៅគង់វង់ ។ គឺដោយហេតុថាស្ដេចសៀរុស ដែលបានច្បាំងឈ្នះជនជាតិលីឌី ក៏បានកំទេចគ្រប់ទីក្រុងណាៗទាំងអស់ ដែលបានចូលដៃជាមួយពួកជនក្រោយនេះ... ក៏ប៉ុន្តែបានទុកស្រុកមីឡេត៍មួយឲ្យរួចខ្លួន... ពីព្រោះស្រុកនេះពុំមានការប្រាថ្នាអាក្រក់ទៅលើពួកគេទេ ។

ត្ថាលែសនៅពេលចាស់ជរាពេកណាស់ទៅហើយ បានឲ្យគេសែងរូបគាត់ទៅលើដីទួល ដើម្បីទស្សនាការប្រយុទ្ធនៅក្នុងឆាកល្បែងមួយ ។ ចំហាយក្ដៅយ៉ាងខ្លាំងនៅក្នុងពេលនោះ ក៏បានបណ្ដាលឲ្យសារពាង្គកាយរបស់គាត់ទទួលឥទ្ធិពលផ្លា

ស់ប្ដូរ... គាត់ក៏បានទទួលសេចក្ដីស្លាប់មួយរំពេជ នៅចំត្រង់កន្លែងដែលគាត់កំពុងតែទស្សនាការប្រយុទ្ធ ។ គឺនៅក្នុងអូឡាំព្យាដទី៥៨ និងឆ្នាំ៩២នៃអាយុរបស់គាត់ ។ ជនជាតិមីឡេត៍ក៏បានរៀបចំឈាបនកិច្ចយ៉ាងអធិកអធមចំពោះរូបគាត់ ។

(កំណត់បន្ថែមរបស់អ្នកបកប្រែ៖ ត្លាលែសមានកំណើតតំណាលគ្នា និងយុគសម័យព្រះពុទ្ធសមណគោត្ដម គឺ៦សតវត្សមុនគ្រីស្ដសករាជ ។ គឺជាទស្សវិទូក្រិកនិងអ្នកប្រាជ្ញគណិតសាស្រ្ដទី១ ដែលបានទុកទ្រឹស្ដីថា ៖ « ខ្សែស្របពីរដែលសម ស្របជាមួយនឹងខ្សែទី៣ គឺសមស្របជាមួយគ្នាទាំងអស់ » ( **Deaux droites parallèles à une même troisième sont paralèlles entre elles** ) ។៚

□ □

□

# ជីវិតរបស់សេណុង
# ZENON

* – បានទទួលសេចក្ដីស្លាប់នៅក្នុងអូឡាំព្យ៉ាដទី១២៩ ។

○

សេណុងជាមេក្រុមបក្សនៃពួកស្តូអ៊ីក, មានកំណើតនៅក្នុងទីក្រុងស៊ីទី្ទ (Cittie) នៅក្នុងកោះស៊ី្ពប្រ៍ ។ មុននឹងសម្រេចចិត្តថាធ្វើអ្វីមួយ, គាត់បានទៅសាកល្បងសួរហោរាទស្សន៍ទាយ, ដើម្បីគ្រាន់តែចង់ដឹងថាតើគាត់ត្រូវចាត់វិធានការណ៍បែបណាដែរដើម្បីឲ្យបានជួបប្រទះនឹងសេចក្ដីសុខសប្បាយ ។ សម្លេងហោរាបានឆ្លើយប្រាប់ថាគាត់ត្រូវតែមានពណ៌សម្បុរឲ្យដូចជាពួកមនុស្សស្លាប់អ៊ីចឹង ។ សេណុងក៏បានកាត់យល់ថា ព្រះនិងទេព្តាចង់ផ្ដែផ្ដាំមកដល់គាត់ថា ឲ្យគាត់ខំប្រឹងរៀនសូត្រនៅក្នុងសៀវភៅរបស់ពួកចាស់ទុំពីបុរាណ ។ គាត់មានជំនឿទាំងស្រុងទៅលើព្រឹត្តិការណ៍នេះដែលគាត់ចាត់ទុកថា ជាអព្ភូតហេតុដ៏អស្ចារ្យ ។ គាត់ក៏ខំប្រឹងគោរពតាមបណ្ដាំនេះយ៉ាងត្រឹមត្រូវជាទីបំផុត ដោយខំប្រឹងស្វាធ្យាយន៍សិក្សានិងអនុវត្តនូវវិន័យគ្រប់យ៉ាង ដើម្បីឲ្យបានស្របជាមួយនឹងពាក្យរបស់ហោរា ។

សម័យថ្ងៃមួយ គាត់បានទៅជួញអង្កាំនៅប្រទេសហ្វេនីស៊ី ...នៅពេលត្រឡប់មកវិញកប៉ាល់របស់គាត់ក៏បានលិចនៅក្នុងផៃនៃពៀរ៉េ ។ ការខូចខាតទ្រព្យសម្បត្តិនេះបានបណ្ដាលឲ្យគាត់មានសេចក្ដីសៅហ្មងយ៉ាងខ្លាំង ។ នៅពេលគាត់វិលត្រ–ឡប់មកទីក្រុងអាតែ្ហនវិញ... គាត់បានចូលក្នុងបណ្ណាគារមួយ ហើយក៏ចាប់ផ្ដើមអានសៀវភៅរបស់សេណូហ្វុងដើម្បីរំងាប់ចិត្ត ។ គាត់មានសេចក្ដីត្រេកអរយ៉ាងខ្លាំងក្នុងការអានសៀវភៅ ដែលជាហេតុបណ្ដាលឲ្យគាត់ភ្លេចទុក្ខកង្វល់អស់រលីង ។ គាត់បានសួរទៅម្ចាស់បណ្ណាគារថា តើមនុស្សដូចដែលសេណូហ្វុងបាននិយាយនោះមាននៅទីណាខ្លះដែរ ? ។ គាប់ជួននៅពេលនោះ, ក្រាតែសនៃក្រុមប័ក្សស៊ីនីកបានដើរកាត់តាមទីនោះ, អ្នកម្ចាស់បណ្ណាគារក៏លើកដៃចង្អុលទៅក្រាតែសដោយប្រាប់សេណុងថា ៖ « ចូរដើរតាមមនុស្សម្នាក់នេះទៅ ! » ។ សេ–ណុងនៅពេលនោះមានអាយុ៣០ឆ្នាំ ។ គាត់ក៏បានដើរតាមក្រាតែស, ហើយតាំង

ពីថ្ងៃនោះមកបានក្លាយទៅជាសាវ័ករបស់លោកគ្រូម្នាក់នេះ ។ សេណុងជាមនុស្សចេះអៀនខ្មាស់ហើយគាត់មានទម្លាប់រស់នៅដោយលាក់ខ្លួន ។ គាត់មិនអាចទ្រាំទ្របាននឹងអាកប្បកិរិយាព្រហើនមុខក្រាស់ និងអាការរស់នៅឥតចេះលាក់លៀមរបស់ពួកស៊ីនីកនោះទេ ។ ក្រាតែសបានសង្កេតឃើញថាការនេះបានធ្វើឲ្យទាស់ចិត្តដល់សេណុងយ៉ាងខ្លាំង ។ គាត់ក៏មានគោលបំណងកែរោគទន់ខ្សោយរបស់សេណុងនេះឲ្យបានជាសះស្បើយ ៖ ថ្ងៃមួយគាត់បញ្ជារឲ្យសេណុងយួរឆ្នាំងមួយពេញដោយផ្លែឡង់ទីយ ( Lentilles ) ... ហើយឲ្យដើរឆ្លងកាត់តាមទីក្រុងសេរ៉ាមីក ។ សេណុងមានការអៀនខ្មាស់ជាពន់ពេកមុខឡើងក្រហម, គាត់រត់រកកន្លែងលាក់ខ្លួន ដើម្បីកុំឲ្យគេឃើញ ។ ក្រាតែសក៏បានពោលទៅកាន់សេណុងថា ៖ « អាចំកួត, ម្ដេចបានជាឯងរត់, តើឯងមានបានធ្វើអ្វីអាក្រក់មិនជាបើឬអ្វី? » ។

ទោះជាយ៉ាងនេះក្តី, សេណុងមានការពេញចិត្តនឹងរៀនទស្សនវិជ្ជាពេកណាស់។ គាត់តែងធ្លាប់អរគុណជារឿយៗដល់ព្រហ្មលិខិតដែលបានធ្វើឲ្យលត់រលាយទ្រព្យសម្បត្តិរបស់គាត់ទៅក្នុងទឹកសមុទ្រអស់ ។« ឱ! ទេព្តាព្រះអង្គព្រះឥន្ទ ! គាត់ពោល, ខ្យល់ព្យុះដែលបានបំផ្លិចបំផ្លាញឲ្យខ្ញុំលិចលង់ បែរជាបានជួយស្រោចស្រង់ខ្ញុំទៅវិញទេតើ ! » ។ គាត់បានរៀនសូត្រចំនួនដប់ឆ្នាំក្រោមការដឹកនាំរបស់ ក្រាតែស... ក៏ប៉ុន្តែគាត់នៅតែមិនចេះរស់នៅជាមួយនឹងអាកប្បកិរិយាច្រឡើស បើសរបស់ពួកស៊ីនីក ។ នៅទីបំផុតនៅពេលដែលគាត់មានបំណងចាកចេញ ពីក្រុមបក្សនេះ ដើម្បីទៅរៀនសូត្រក្រោមការដឹកនាំរបស់ស្ទីលប៉ុង-ដឹមេការ, ក្រាតែសបានចាប់ក្របួចអាវម៉ង់តូរបស់គាត់... ព្រមទាំងបានប្រើកម្លាំងដើម្បីឃាត់ គាត់ឲ្យនៅស្ងៀម ។

– ឱ! លោកគ្រូក្រាតែស, សេណុងពោល, គេមិនអាចឃាត់ទស្សនវិទូម្នាក់ដោយទាញតាមស្លឹកត្រចៀកនោះទេ ។ សូមលោកគ្រូពន្យល់ខ្ញុំមកថា តើទ្រឹស្តីរបស់លោកគ្រូល្អប្រសើរជាងរបស់ស្ទីលប៉ុងត្រង់ណា, បើពុំដូច្នោះទេ, លោកគ្រូឃាត់ខ្ញុំបានតែខ្លួនប៉ុណ្ណោះ, ប៉ុន្តែចិត្តរបស់ខ្ញុំបានហើរទៅខាងស្ទីលប៉ុងរួចបាត់ទៅហើយ ។

សេណុងបានចំណាយពេលដប់ឆ្នាំថែមទៀត ដើម្បីរៀនសូត្រជាមួយនឹងស្ទីលប៉ុង , សេណូក្រាតនិងប៉ូឡេម៉ុង ។ បន្ទាប់មកគាត់ក៏បានថយខ្លួនទៅបង្កើតក្រុមបក្សមួយថ្មី ។ មិនយូរប៉ុន្មានកេរ្តិ៍ឈ្មោះរបស់គាត់ក៏បានរីកខ្ទរខ្ទារល្បីសុះសាយពាសពេញប្រទេសក្រិក ។ ពោល, គាត់បានប្រែក្លាយយ៉ាងឆាប់រហ័សទៅជាទស្សនវិទូម្នាក់ដ៏សំខាន់ជាងគេនៅក្នុងប្រទេសនេះ ។ មានមនុស្សជាច្រើនគ្នាណាស់ដែលបានស្វែងមកពីគ្រប់ទិសទីដើម្បីមកបម្រើគាត់, មកសុំធ្វើជាសាវ័ករបស់គាត់។ ហើយដោយសារសេណុងមានទម្លាប់បង្ហាត់បង្រៀននៅក្នុងរោងក្រោលមួយគេ

ក៏បានហៅពួកគាត់ថាជាក្រុមបក្សស្តូអ៊ីក ។ ( ក.ក.ន.៖ ពាក្យស្តូអ៊ីកនៅក្នុងវចនានុក្រមឡឺពើទីរ៉ូប៊ែរត៍...មានន័យថាមានសេចក្តីក្លាហានតស៊ូនឹងសេចក្តីឈឺចាប់ដោយគ្មានស្រែកថ្ងូររំអែរំអួយ ... ដោយគ្មានឲ្យនរណាដឹងឮ ! ) ។

ពួកបូរីជននៅទីក្រុងអាត្មែនបានលើកិត្តិយសគាត់មែនទែនរហូតដល់បានប្រគល់កូនសោរនៃទីក្រុងឲ្យគាត់ទុកតម្កល់ ។ ពួកគេបានលើករូបសំណាកមួយរបស់គាត់ ព្រមទាំងបានធ្វើអំណោយនូវម្កុដមាសមួយដល់គាត់ទៀតផង ។ ស្តេចអង់ទីគ្មោនុស្សតែងមានការកោតសរសើរចំពោះទស្សនវិទូរម្នាក់នេះមិនចេះចប់មិនចេះហើយ ។ កាលណាស្តេចអង្គនេះធ្វើដំណើរមកទីក្រុងអាត្មែន, ទ្រង់មិនដែលខកខានមកស្តាប់មេរៀនរបស់សេណុងនោះទេ ។ ជាច្រើនលើកច្រើនគ្នាណាស់ដែលស្តេចទៅបរិភោគអាហារជាមួយនឹងសេណុង ។ មានពេលខ្លះទៀតទ្រង់យាងទៅរួមតុអាហារនៅផ្ទះសេណុងតែម្តង ឬបើពុំនោះទេទ្រង់នាំទស្សនវិទូទៅស្រស់ស្រូបនៅផ្ទះរបស់អារីសតូក្ល ដែលជាជនដេញពិនម្នាក់ដ៏ល្បីល្បាញ ។ ក៏ប៉ុន្តែសេណុងបានចៀសវាងនៅថ្ងៃក្រោយមក មិនចូលរួមក្នុងការជប់លៀងជាមួយនរណាទាំងអស់ ហើយក៏ចៀសវាងមិនចូលរួមប្រជុំជាមួយនរណាផងដែរ, ក្នុងគោលបំណងកុំឲ្យធ្លាប់ខ្លួនឬមានការស្និទ្ធស្នាលជា មួយជនអស់ទាំងនេះ ។ ស្តេចអង់ទីគ្មោនុស្សបានប្រើគ្រប់មធ្យោបាយ ដើម្បីឆក់ទាញទស្សនវិទូនេះឲ្យនៅក្បែរទ្រង់ ។ សេណុងបានសុំទោសដោយមិនអាច ធ្វើដំណើរនេះបាន, ហើយក៏បញ្ជូនពៃរសេអ៊ុសហើយនិងហ្វីឡូនីដទៅជំនួសវិញ។ ជាមួយគ្នានេះគាត់បានផ្តាំផ្ញើពាក្យទៅស្តេចដូច្នេះថាគាត់មានសេចក្តីរំភើបខ្លាំងណាស់ដែលស្តេចមានជំនោរអារម្មណ៍ចូលចិត្តចំណេះដឹងនិងវិទ្យាសាស្រ្ត ។ គឺគ្មានអ្វីអាចឲ្យទ្រង់ងាកចេញពីជីវិតស្រើបស្រាលព្រមទាំងឲ្យឱបក្រសោបយកកុសលធ៌ម បានជាជាងសេចក្តីស្នេហាចំពោះទស្សនវិជ្ជានោះឡើយ ។ « នៅទីបំផុត, គាត់បានបន្ថែម, បើកុំតែជីវិតចាស់ជរានិងកង្វះខ្វះខាតខាងផ្នែកសុខភាព បានឃាត់ឃាំងរាំងរារូបខ្ញុំមិនឲ្យដើរចេញក្រៅ, ម្ល៉េះសមប្រហែលជាខ្ញុំមិនខកខានទៅនៅជិតក្បែរទ្រង់ ដូចដែលទ្រង់ចង់បាននោះទេ។ ក៏ប៉ុន្តែដោយការនេះធ្វើមិនកើតទៅហើយ, ខ្ញុំក៏បានបញ្ជូនមិត្តភ័ក្តិពីរនាក់របស់ខ្ញុំ, ដែលបើគិតតាមកំពស់កំពរនៃគំនិតទ្រិស្តីនិងឧត្តមគតិ គឺមានជំហររឹងប៉ឹងជាងរូបខ្ញុំទៅទៀត ។ បើទ្រង់ពិភាក្សាជាមួយអ្នកទាំងពីរនាក់នេះដោយត្រឹមត្រូវ ហើយបើទ្រង់អនុវត្តតាមពាក្យសុភាសិតដែលពួកគេនឹងថ្វាយចំពោះទ្រង់ នោះទ្រង់ច្បាស់ជានឹង សង្កេតឃើញថាទ្រង់គ្មានខ្វះខាតអ្វីទៀតទេ ...ទាក់ទងនឹងសុភមង្គលដ៏កំពូលនៅលើភពផែនដីនេះ ។

សេណុងមានរាងខ្ពស់ស្គមហើយស្តើង ព្រមទាំងមានស្បែកខ្មៅឃ្លើកដែល

ជាហេតុបណ្ដាលឲ្យមនុស្សខ្លះហៅគាត់ថា ៖ « ដើមត្នោតនៅប្រទេសអេយីព្ទ » ។ គាត់មានក្បាលផ្អៀងទៅលើស្មាខាងម្ខាងរបស់គាត់ ។ ជើងរបស់គាត់ធំហើយពុំមានអនាម័យទេ ។ គាត់ស្លៀកពាក់ដោយក្រណាត់យ៉ាងស្តើងដែលមានតម្លៃដ៏ថោកបំផុតដែលគាត់អាចរកបាន ។ នៅគ្រប់ពេលវេលា, គាត់រស់ដោយសារតែបរិភោគនំបុ័ងបន្តិចបន្តួចជាមួយផ្លែហ្វីក ( Figues ) ហើយនិងទឹកឃ្មុំនិងដោយផឹកទឹកទំពាំងបាយជូរដែលពុំមានជាតិស្រា ។ គាត់មានអំណត់អត់ធុនហើយចេះតមខ្លាំងពេកទៅរហូតដល់គេពោលសរសើរអ្នកខ្លះដែលប្រកបដោយគុណសម្បត្តិទាំងនេះដោយធ្វើការប្រៀបធៀបដូច្នេះថា ៖ «គាត់នេះមានជីវិតបរិសុទ្ធជាងសេណុងទៅទៀត » ។

សេណុងមានដំណើរនឹងធ៌, ស្មារតីរហ័សរហួន, ទឹកមុខកាចម៉ាំទាំ ។ ពេលណាគាត់និយាយ, ថ្ពាសគាត់ឡើងជ្រួញ, មាត់គាត់ឡើងវៀច ។ ជួននៅពេលខ្លះ , ដែលគាត់ជាប់មាត់ធ្វើការឆ្លើយឆ្លងដោយសេចក្តីសប្បាយរីករាយ, គាត់អាចមានគំនិតកំប្លែងហើយចេះនាំអាទិឲ្យអ្នកផងសើចក្អាកក្អាយគ្រប់គ្នា ។ នៅពេលដែលគេសួរគាត់ថា ហេតុអ្វីបានជាមានការប្រែប្រួលដូច្នេះ, គាត់បានឆ្លើយថាផ្លែលូប៉ុង ( Lupin) វាមានជាតិល្វីង...ក៏ប៉ុន្តែបើកាលណាគេយកទៅត្រាំទឹកយូរៗទៅ វាបែរជាមានរសជាតិផ្អែមពិសារទៅវិញ ។

គាត់មានទម្លាប់ធ្វើសន្ទនរកថាខ្លីៗមែនទែន ។ នៅពេលដែលគេសួរគាត់អំពីបុព្វហេតុរឿងនេះ, គាត់បានឆ្លើយថាអ្នកប្រាជ្ញគួរតែប្រើពាក្យខ្លីៗជាទីបំផុត ដែលគេអាចធ្វើទៅបាន ។ នៅពេលដែលគាត់ចង់ស្តីបន្ទោសឲ្យជនណាម្នាក់, គាត់តែងនិយាយតែពាក្យពីរបីម៉ាត់ប៉ុណ្ណោះ... ហើយការនិយាយស្តីរបស់គាត់បានប្រើក្នុងការបញ្ជិតបញ្ជៀងរាល់លើក ។ ថ្ងៃមួយយុវជនម្នាក់បានតឿនបង្ខំគាត់ឲ្យពន្យល់រឿងមួយដែលបញ្ហារបស់វាឈោងមិនដល់សោះ ។ សេណុងបញ្ជាឲ្យយកកញ្ចក់មួយឲ្យយុវជននេះឆ្លុះមើលមុខខ្លួនឯង រួចគាត់ពោលប្រាប់វាថា ៖ « បញ្ហាអស់ទាំងនេះវាសមនឹងមុខឯងគិតគួរឬទេ? » ។

○

*- គាត់បានពោលថាសន្ទរកថាដ៏អាក្រក់ៗរបស់ពួកវាគ្មិនឥតឃោបាយមានរូបរាងដូចជាប្រាក់សេននៅក្រុងអាឡេចសង់ឌ្រីដូច្នោះឯង, គឺវាមានរូបល្អសមសួនតែនៅសំបកក្រៅក៏ប៉ុន្តែប្រកបដោយលោហធាតុដែលគ្មានតម្លៃសោះ ។

*- គាត់បានពោលថា កំហុសដ៏ធំនៅក្នុងការអប់រំមេឲ្យយុវជនសព្វថ្ងៃ គឺគេបានចិញ្ចឹមពួកនេះឲ្យរស់នៅក្នុងអំនួត ។ គេគួរតែបង្ហាត់បង្រៀនពួកនេះឲ្យស្គាល់ច្បាប់ស៊ីវិល័យហើយឲ្យធ្វើអ្វីៗតែក្នុងលក្ខណៈសមរម្យតែប៉ុណ្ណោះ ។ កាហ្វេសី-យុស, គាត់ពោលបន្ថែម, នៅពេលដែលឃើញសាវ័ករបស់គាត់ម្នាក់មានអាការៈពោរពេញដោយអំនួត គាត់ក៏បានទះកំភ្លៀងជននេះមួយដៃហើយពោលថា ៖«ពេលថ្ងៃណាគេលើកតាំងរូបឯងឲ្យធំខ្ពស់ជាងអ្នកដទៃ, ពុំមែនមានន័យថាឯងបានក្លាយខ្លួនទៅជាមនុស្សសុច្ចរិតនោះទេ ។ ក៏ប៉ុន្តែបើឯងជាមនុស្សសុច្ចរិតវិញ, ឯងនឹងត្រូវគេលើកតាំងឲ្យធ្វើធំខ្ពស់ពីលើអ្នកដទៃជាមិនខាន » ។

*- នៅពេលដែលគេសួរគាត់ថា តើអ្វីទៅដែលជាមិត្តភ័ក្តិរបស់គាត់នោះគាត់បានឆ្លើយថា៖ គឺជាខ្លួនខ្ញុំម្នាក់ទៀត ។ ( ក.ក.ន.៖ « ខ្លួនខ្ញុំម្នាក់ទៀត » ថ្ងៃក្រោយទៅបានក្លាយទៅជាភាសាឡាតាំងថា៖ Alter-Ego ) ។

*- ថ្ងៃមួយ, គាត់បានចូលរួមក្នុងពិធីរជប់លៀងដែលគេបានធ្វើឡើងជាកិត្តិយសដល់ពួកក្រុមប្រតិភូរបស់ស្តេចផ្តូឡេម៉េ, គាត់ពុំបាននិយាយស្តីអ្វីទាំងអស់នៅពេលបរិភោគ ។ ពួករដ្ឋទូតទាំងអស់មានសេចក្តីងឿងឆ្ងល់យ៉ាងខ្លាំង ហើយក៏បានសួរគាត់ថាតើគាត់មានចង់និយាយផ្តែផ្តាំអ្វីឬដែរទៅស្តេចផ្តូឡេម៉េ ? «ចូរអស់លោកអញ្ជើញទៅនិយាយប្រាប់ទ្រង់ផង, គាត់ឆ្លើយតបវិញ, ថានៅទីនេះមានជនម្នាក់ដែលចេះនៅស្ងៀមស្ងាត់ » ។

*-ពួកស្តូអ៊ីកបានអនុម័តថាគោលប្រាថ្នាដ៏ធំបំផុតដែលមនុស្សតែងចង់បានគឺការរស់នៅស្របគ្នាជាមួយនឹងធម្មជាតិ ។ ក៏ប៉ុន្តែការរស់នៅឲ្យបានស្របជាមួយនឹងធម្មជាតិនេះ គឺគ្មានអ្វីក្រៅតែអំពីការចៀសវាងកុំឲ្យធ្វើអ្វីផ្ទុយនឹងវិចារ-ណញ្ញាណដែលជាច្បាប់ទូទៅនិងជាច្បាប់រួមសម្រាប់គ្រប់មនុស្ស ។

*- ម្នាក់ៗត្រូវឱបក្រសោបយកកុសលធម៌ដោយសារតែឧត្តមគតិនេះវាល្អពីខ្លួនឯង ...ពុំមែនដោយសារការប្រាថ្នាចង់បានតុរង្វាន់នោះទេ ។ កុសលធម៌ ( ឬសីលធម៌ ឬការធ្វើអំពើល្អ ) មានតម្លៃពីខ្លួនឯងសម្រាប់ញុំាងឲ្យមនុស្សរស់នៅបានសុខសប្បាយ ។ មនុស្សដែលមានកុសលធម៌ក្នុងខ្លួនតែងបានទទួលសុភមង្គលដ៏គ្មានខ្ចោះ ... បើទោះជាពួកគេឋិតនៅកណ្តាលព្យុះសង្ឃរាបោកបាចយ៉ាងណាក៏ដោយ ។

– គ្មានអ្វីដែលមានប្រយោជន៍ជាងអ្វីៗដែលមានលក្ខណៈសុច្ចរិត ...ហើយអ្វីៗដែលជាតំណាងអំពើឧក្រិដ្ឋមិនអាចមានផលប្រយោជន៍សោះឡើយ ។

ពួកស្តូអ៊ីបានបន្ថែមថា ការសប្បាយស្រើបស្រាលនិងកាមតណ្ហាពុំមែនជាអំពើល្អនោះឡើយ ... ពីព្រោះសេចក្តីសម្រើបជារបស់មួយដែលមានលក្ខណៈទុច្ចរិត ។ ម្ល៉ោះហើយគេមិនអាចទាញសេចក្តីល្អចេញពីរបស់មួយ ដែលទុច្ចរិតនោះទេ ។

*- ពួកអ្នកប្រាជ្ញឥតមានខ្លាចអ្វីទាំងអស់ ដោយពួកគេគ្មានរបស់អ្វីជាថ្លៃថ្នូររុងរឿងនៅជាប់នឹងខ្លួនទេ ។ អ្នកប្រាជ្ញគ្មានសេចក្តីខ្វល់ខ្វាយ, គ្មានជាប់ចិត្តជាមួយនឹងកេរ្តិ៍ឈ្មោះ ក៏ដូចតែជាមួយគ្នានឹងការអ័ប្បយសនិងសេចក្តីថោកទាប។ ភារកិច្ចរបស់អ្នកប្រាជ្ញត្រូវមានការហ្មត់ចត់និងភក្តីភាព ។ គេមិនបានហាមប្រាមគាត់មិនឲ្យផឹកស្រានោះទេ... ចៀសវាងកុំឲ្យតែមានការស្រវឹងប៉ុណ្ណោះ, ក្នុងគោលបំណងកុំឲ្យបាត់បង់សូម្បីតែមួយនាទីក៏ដោយនៅក្នុងជីវិតនេះនូវការប្រើប្រាស់បញ្ញានិងវិចារណញ្ញាណ ។ អ្នកប្រាជ្ញត្រូវសំដែងសេចក្តីគោរពចំពោះព្រះ, ត្រូវធ្វើពលិកម្មថ្វាយព្រះ ... ហើយចៀសវាងកុំប្រព្រឹត្តអំពើអបាយមុខទាល់តែសោះ ។

*- គឺមានតែអ្នកប្រាជ្ញប៉ុណ្ណោះទេដែលអាចស្គាល់តម្លៃនៃមិត្តភាព ។ ម្ល៉ោះហើយគាត់មានកាតព្វកិច្ចត្រូវតែចូលជ្រៀតជ្រែក ធ្វើអន្តរាគមនៅក្នុងរឿងកង្វះខ្វះខាតនៃសាធារណរដ្ឋដើម្បីឃាត់ឃាំងអបាយមុខកុំឲ្យរីកដុះដាល ព្រមទាំងជំរុញប្ញូរីជន ( ប្រជាពលរដ្ឋ ) ឲ្យឱបក្រសោបយកកុសលធ៌មផង។ គឺមានតែអ្នកប្រាជ្ញប៉ុណ្ណោះទេដែលមានការចាំបាច់ចូលរួមចំណែកក្នុងការគ្រប់គ្រងរបស់រដ្ឋ, គឺមានតែគាត់ប៉ុណ្ណោះដែលអាចសម្រេចអំពីអ្វីៗដែលល្អនិងអាក្រក់ ។ គឺមានតែគាត់ទេដែលគេមិនអាចស្តីបន្ទោសបានអំពីរឿងសីលធ៌ម ។ គឺមានតែគាត់ទេដែលពុំមានលទ្ធភាពក្នុងការបង្ខិនបង្ខោចផលប្រយោជន៍របស់អ្នកដទៃ ។ គឺមានតែគាត់ទេដែលគ្មានទម្លាប់កោតស្ញប់ស្ញែង ចំពោះរបស់អ្វីៗដែលតែងតែធ្វើឲ្យមនុស្សក្នុងប្រភេទផ្សេងមានការភ្លឹកភ្លាំង ។

*- ពួកស្តូអ៊ីកបានសន្មត់ថា អំពើជាកុសលធ៌មទាំងឡាយតែងមានទំនាក់ទំនងជាមួយគ្នាយ៉ាងចាក់ស្រែះ... កាលណាគេរកប្រទះបានមួយហើយគេនឹងអាចឱបក្រសោបយកបានតែទាំងអស់ ។

*- គ្មានផ្លូវកណ្តាលសម្រាប់ដើរចន្លោះអបាយមុខ និងសីលធ៌មនោះឡើយ,

ពោលគឺគ្មានផ្លូវកណ្ដាលចែកគ្នារវាងអំពើល្អនិងអំពើអាក្រក់នោះជាដាច់ខាត, ពួកស្តូអ៊ីកបានពោលបន្ថែម ។ គឺពីព្រោះថាជាការចាំបាច់មនុស្សយើងមានលក្ខណៈឬមួយវៀចឬមួយត្រង់ ។ ចំណែកអំពើក៏ដូច្នោះដែរ, វាមានតែអំពើល្អ ឬអំពើអាក្រក់តែប៉ុណ្ណោះ ( ក.ក.ន.៖ គឺមិនមែនអាវៀចធ្វើកង់... អាត្រង់ធ្វើថែវនោះទេ ) ។

q

សេណុងបានរស់រហូតដល់អាយុ៩៨ឆ្នាំ ដោយមិនដែលមានឈឺថ្កាត់ ឬក៏បានជួបប្រទះទុក្ខលំបាកអ្វីទាំងអស់ ។ នៅពេលគាត់ស្លាប់ទៅអ្នកផងមានសេចក្ដីសោកស្ដាយចំពោះរូបគាត់គ្រប់ៗគ្នា ។ គ្រាន់តែបានទទួលព័តមាននេះភ្លាម, ស្ដេចអង់ទីគ្គោនុស្សមានសេចក្ដីវិតក្កជាខ្លាំង ។ « ឱ ! ព្រះជាម្ចាស់, ទ្រង់មានបន្ទូល, ខ្ញុំបានបាត់បង់នូវទស្សនិយភាពមួយដ៏សំខាន់ » ។ នៅពេលដែលគេសួរទ្រង់ថា ហេតុអ្វីបានជាទ្រង់ជាប់ចិត្តជាមួយនឹងទស្សនវិទូរម្នាក់នេះម្ល៉េះ? ទ្រង់បានឆ្លើយថា ៖

« ពីព្រោះរបស់អ្វីៗដែលខ្ញុំបានបញ្ជូនទៅឲ្យគាត់ទាំងប៉ុន្មាន មិនអាចធ្វើឲ្យគាត់រមៀលធ្លាក់ចូលក្នុងអំពើថោកទាបទាល់តែសោះ » ។

ស្ដេចក៏បញ្ជូនប្រ៉ិតិភូរបស់ទ្រង់ទៅទីក្រុងអាត្តែន ដើម្បីស្នើសុំយកខ្មោចរបស់សេណុងមកធ្វើបុណ្យនៅក្នុងបូរីសេរ៉ាមីក » ។ ចំណែកពួកអ្នកទីក្រុងអាត្តែនវិញក៏មានសេចក្ដីឈឺចាប់នឹងការបាត់បង់របស់សេណុង ដូចគ្នាតែនឹងស្ដេចអង់ទីគ្គោនុស្សផងដែរ ។ ពួកចៅក្រមដ៏សំខាន់ៗគ្រប់រូបនៅទីនោះបានលើកសរសើរដំកើងឈ្មោះគាត់បន្ទាប់ពីគាត់ស្លាប់ភ្លាមទៅ, ហើយដើម្បីឲ្យកិច្ចការនេះមានសភាពប្រត្យ័ក្សជាក់ស្ដែង ពួកគេក៏បានសរសេរក្រិត្យច្បាប់មួយជាសាធារណៈមានសេចក្ដីដូច្នេះថា ៖

ក្រិត្យច្បាប់ ៖

« ដោយហេតុថាសេណុង, កូនប្រុសរបស់ម៉ណាសេនៅសីទ្វី , បានចំណាយពេលវេលាជាយូរអង្វែងឆ្នាំដើម្បីបង្រៀនទស្សនវិជ្ជានៅទីក្រុងនេះ ; ដោយគាត់បានបង្ហាញថាគាត់ជាមនុស្សល្អនៅគ្រប់សកម្មភាពនានា ; ដោយគាត់បានជួយជំរុញជានិច្ចនិរន្តដល់ពួកយុវជនដែលគាត់បានបង្ហាត់បង្រៀនតាមគន្លងវិន័យរបស់គាត់ឲ្យបំពេញតែកិច្ចការប្រកបដោយគុណធ៌ម ; ដោយគាត់មានជីវិតរស់នៅសមប្រកបឥតខ្ចោះគ្រប់ពេលវេលាជាមួយនឹងសុភាសិត ដែលគាត់បានបង្ហាត់បង្រៀនចំពោះអ្នកដទៃ, ប្រជាពលរដ្ឋបានយល់ថា គឺជាទង្វើមួយដ៏សមគួរក្នុងការលើកសរសើរដម្កើងកេរ្តិ៍ឈ្មោះរបស់គាត់ជាសាធារណៈ ព្រមទាំងក្នុងការធ្វើ

អំណោយផងនូវម្កុដមាសមួយដែលសក្តិសមនឹងរូបគាត់ពន់ពេក ដោយសារតែកម្លាំងគុណធម៌មនិងចិត្តបរិសុទ្ធអត់ធ្មត់របស់គាត់; ព្រមទាំងការលើកកសាងផ្នូរមួយជូនគាត់នៅបូរីសេរ៉ាមីក, ដោយប្រើបច្ច័យរបស់សាធារណជន ។ ប្រជាពលរដ្ឋមានឆន្ទះចង់ឲ្យគេជ្រើសរើសមនុស្ស៥នាក់នៅទីក្រុងអាត្ហែន ដើម្បីទទួលភារកិច្ចធ្វើម្កុដនេះនិងកសាងផ្នូរជូនគាត់ឲ្យបានសម្រេច ។ ចូរឲ្យស្មៀននៃសាធារណរដ្ឋឆ្លាក់អក្សរនៃក្រិត្យច្បាប់នេះនៅលើសសរកន្លោងពីរ ... មួយត្រូវយកទៅដាក់តាំងនៅបណ្ឌិតសភា, មួយទៀតយកទៅតាំងនៅវិទ្យាល័យ ។ ទឹកប្រាក់ចាំបាច់ក្នុងការធ្វើសមិទ្ធិទាំងនេះ ត្រូវប្រគល់ជាបន្ទាន់ដល់អ្នកទទួលខុសត្រូវនៃកិច្ចការសាធារណៈ ដើម្បីឲ្យអ្នកផងបានដឹងថាពួកបូរីជននៅទីក្រុងអាត្ហែនតែងលើកកិត្តិយសដល់មនុស្សមានតម្លៃសំខាន់ៗជានិច្ច, ទោះជានៅពេលដែលអ្នកទាំងនេះនៅរស់ ក៏ដូចជាបន្ទាប់ពីពេលដែលពួកគេបានធ្វើមរណកាលទៅ » ។

កក្រិត្យច្បាប់នេះបានត្រូវផ្សាយនៅចំពេលដែលអារ៉េនីដាសបានឡើងធ្វើជាអារកុងនៃទីក្រុងអាត្ហែន, បីបួនថ្ងៃក្រោយមកបន្ទាប់ពីសេចក្តីស្លាប់របស់សេណុង ( អារកុង ៖ គឺជាថានៈចៅក្រមកំពូល ដែលមានភារៈកិច្ចត្រួតត្រាគ្រប់គ្រងសាធារណរដ្ឋក្រិកជំនាន់ដើម ) ។

តទៅនេះ គឺជាកាលៈទេសៈនៃមរណភាពរបស់សេណុង ៖

គេបានពោលថានៅថ្ងៃមួយ , ពេលដែលគាត់ដើរចេញពីសាលារបស់គាត់ទៅ ...គាត់បានដើរទៅប៉ះទង្គិចរបស់ម្យ៉ាង ដែលបណ្តាលឲ្យបាក់ម្រាមដៃរបស់គាត់ ។ គាត់បានយល់ថានេះជាអព្ភូតហេតុដែលព្រះនិងទេព្តាបានបញ្ជូនមកគាត់... ពោលគឺជាសញ្ញាដែលប្រាប់ថា គាត់បានធ្វើដំណើរមកជិតដល់សេចក្តីស្លាប់រួចហើយ ។ គាត់ក៏ចាប់ផ្តើមវាយតប់ព្រះធរណីដោយដៃរបស់គាត់ព្រមទាំងពោលថា ៖ « តើឯងត្រូវការរូបអញមែនឬ? អញកំពុងតែរៀបចំខ្លួនរួចជាស្រេចហើយ » ។ ដោយពុំបានរង់ចាំឲ្យយូរការជាងនេះទៀត, ហើយដោយពុំមាននឹកនារស្វែងរកថ្នាំដើម្បីព្យាបាលម្រាមដៃរបស់គាត់, ព្រមទាំងដោយគ្មានតក់ស្លុតបន្តិចបន្តួច, គាត់ក៏សម្រេចចិត្តច្របាច់កខ្លួនឯងទាល់តែស្លាប់ ។ រយៈពេលវេលាបានកន្លងមកចំនួន៨៨ឆ្នាំមកហើយ, តាំងពីគាត់បានចាប់ផ្តើមធ្វើគ្រូបង្រៀនទស្សនវិជ្ជាដោយគ្មានឈប់ឈរ, និង៦៨ឆ្នាំមកហើយ, តាំងពីគាត់បានចាប់ផ្តើមសិក្សាទស្សនវិជ្ជាក្រោមការដឹកនាំរបស់ក្រាតែសនៃក្រុមប៉ក្សស៊ីនីក ។

~ ចប់ ~

កំណាត់របស់អ្នកបកប្រែ ៖ អ្នកនិពន្ធបារាំងហ្វេណឺឡុង ( Fénelon ) កើតនៅក្នុងឆ្នាំ១៦៥១ ស្លាប់នៅឆ្នាំ១៧១៥ ។ ឈ្មោះលោកពិតប្រាកដគឺ François de Salignac de la Mothe-Fénelon ។ ឈ្មោះហ្វេណឺឡុងគឺគ្រាន់តែជា រហស្សនាមប៉ុណ្ណោះ ស្រង់ចេញពីឈ្មោះប្រាសាទរបស់លោកនៅ Périgord ។ លោកជាអ្នកនិពន្ធបារាំងល្បីឈ្មោះក្នុងជំនាន់ Molière, Racine, La Fontaine, La Bruyère ...។

លោកហ្វេណឺឡុង ជាមនុស្សម្នាក់មានចិត្តសុភាពរាបសារស្លូតទន់ភ្លន់, មានអ្នកផងស្រឡាញ់រាប់អានគ្រប់គ្នា ក៏ប៉ុន្តែលោកមិនចេះទទួលបង្គាប់បញ្ជាពីនរណាទេ ... សូម្បីតែពីព្រះរាជាឬពីព្រះជាម្ចាស់របស់លោក ដែលលោកទទួលបម្រើក៏ដោយ ។ លោកមានជំនឿតែទៅលើវិចារណញ្ញាណរបស់ខ្លួនឯងប៉ុណ្ណោះ ... ពោលគឺទៅលើអ្វីៗដែលលោកយល់ថា ជាសេចក្តីត្រឹមត្រូវនិងជាគតិយុត្តិធម៌ ។ នៅខាងផ្នែកអក្សរសាស្ត្រនិងខាងក្បួនអប់រំវិញ លោកហ្វេណឺឡុងមានអំណាចខ្លាំងណាស់ទៅលើអ្នកនិពន្ធដទៃទៀត ...គឺជាអំណាចមួយដែលលោកមានដោយមិនបាច់ប្រឹង, គឺមានដោយឯងៗ ដោយសារតែបុគ្គលិកលក្ខណៈរបស់លោកផ្ទាល់ ។ ជាឧទាហរណ៍កាលណាលោកហ្វេណឺឡុងឲ្យយោបល់អ្វីមួយ ទៅអ្នកដទៃ... គេច្រើនតែអនុលោមធ្វើតាមលោករហូតមកដល់សម័យឥឡូវ ។ អំពីប្រវត្តិសាស្ត្រ, លោកហ្វេណឺឡុងបានពោលថា ៖ « ប្រវត្តិវិទូពិតប្រាកដ មិនមែនជាមនុស្សរបស់ស្រុកណាមួយ ឬក៏របស់យុគសម័យណាមួយឡើយ » (Le vrai historien n'est d'aucun temps, ni d'aucun pays ) ពាក្យនេះ, ថ្ងៃក្រោយមក បានក្លាយទៅជារូបមន្ត ឬជាសុភាសិតអន្តរជាតិ ។ អំពីការបង្រៀនក្មេងស្រីៗ ឲ្យមានការចេះដឹងដែលជារបស់មួយហាមប្រាមនៅក្នុងយុគសម័យកណ្តាល គឺលោកគ្រូហ្វេណឺឡុងនេះហើយ ដែលបាននាំអាទិផ្តលព្រលំរបាំងឧបសគ្គនេះមុនគេ ពីព្រោះលោកយល់ថា ស្រីៗមានភារកិច្ចធ្វើមេផ្ទះ, មើលថែទាំគ្រួសារ, ទទួលបន្ទុកកសាងសុភមង្គលរបស់ប្តី ...ហើយត្រូវមានសមត្ថភាពខាងគ្រប់គ្រងទ្រព្យសម្បត្តិទៀតផង, ស្រីៗដែលមិនបានទទួលចំណេះវិជ្ជាខាងអក្សរសាស្ត្រ និងលេខនព្វន្ធ, ព្រមទាំងច្បាប់ក្រមគឺច្បាស់ជានឹងត្រូវចាញ់បោកគេ ។ ចាប់តាំងពីលោកហ្វេណឺឡុងបានបោះពុម្ពក្បួនអប់រំនារីកាលណាមក ( Traité de l'Education des filles ) ស្រីៗនៅទ្វីបអឺរ៉ុបនៅគ្រប់ស្រទាប់វណ្ណៈ ក៏បានត្រូវគេផ្តល់ចំណេះ វិជ្ជាជារៀងរហូតមក ។

លោកហ្វេណឺឡុងជាគ្រូសង្ឃកាតូលិកបារាំង ដែលបានទទួលភារកិច្ច ( នៅក្នុងឆ្នាំ១៦៨៩ ) បង្ហាត់បង្រៀនចៅមួយអង្គរបស់ព្រះមហាក្សត្រ ល្វីទី-១៤ គឺ Le Duc de Bourgogne ដើម្បីឲ្យទ្រង់មានចំណេះវិជ្ជាមានលទ្ធភាពឡើងគ្រប់គ្រងរា-

ជ្យ ។ ព្រះអង្គម្ចាស់អង្គនេះជាជនពាល, ច្រឡើសបើសមានលក្ខណៈព្រៃផ្សៃដូចជាសត្វព្រៃ  ក៏ប៉ុន្តែដោយសារបញ្ញាញាណនិងទេព្យកោសល្យខាងផ្នែកគរុវិជ្ជារបស់លោក ..លោកហ្វេណឺឡុងក៏បានធ្វើឲ្យកូនស្តេចអង្គនេះក្លាយទៅជា ស៊ីវិល័យជន ។  លុះដល់កិច្ចការនេះបានរួចរាល់ចប់សព្វគ្រប់ហើយ,លោកហ្វេណឺឡុងក៏បានក្លាយទៅជាសម្តេចសង្ឃនៅ Cambrai ដែលជាកិត្តិយសកំពូល នៅក្នុងជីវិតរបស់លោក ។

ស្នាដៃរបស់លោកជាច្រើនៗតែជាសៀវភៅធំមអាថ  ក៏ប៉ុន្តែស្នាដៃស៊ីវិលដែលគេស្គាល់ជាងគេគឺ «ក្បួនអប់រំនារី» ( Le traité de l'Education des filles -1687 ) ; តេឡេម៉ាក ( Télémaque -1699 ) និង «លិខិតទៅបណ្ឌិតសភា » ( Lettre à l'Académie- 1716) ។ ខ្ញុំមានចម្ងល់ដែរ ដោយនៅក្នុងជីវប្រវត្តិរបស់លោកហ្វេណឺឡុង  ...ពុំឃើញមានគេនិយាយអំពីសៀវភៅដែលរៀបរាប់អំពីជីវិតនៃទស្សនវិទូក្រិកទាល់តែសោះ  ។  ទោះជាយ៉ាងនេះក្តី សៀវភៅក្រោយនេះបានត្រូវបកប្រែនៅគ្រប់ភាសាក្នុងពិភពលោក  (Abrégé de la vie des plus illustres philosophes de l'antiquité, avec leurs dogmes, leurs systèmes, leur morale, et un recueil de leurs plus belles maximes. Ouvrage destiné à l'éducation de la jeunesse; Par François de Salignac de la Motte-Fénelon, Archevêque de Cambrai, et Précepteur de Mr le Duc de Bourgogne. Nouvelle édition, revue avec soin. LYON, Mme J. Buynand née Bruyset; Et chez Yvernault et Cabin.- 1811 ) ... គឺជាសៀវភៅដែលពិភពលោកបានស្គាល់ជាងគេបំផុតអំពីអ្នកនិពន្ធហ្វេណឺឡុង ។

ថ្ងៃក្រោយមក, ហ្វេណឺឡុងបានត្រូវសម្តេចសង្ឃប៉ាបចោទថាជាអ្នកគោរពសាសនាអាថកំបាំងនៃការស្ងឹងស្ងាធនិយម, ឬការសម្រន់អារម្មណ៍នៅក្នុង ធម៌វិបស្សនា ( Le Quiétisme ) ។ ចំណែកពួកអ្នកបម្រើវាំងស្តេចល្វីទី-១៤ បានចោទលោកថាជាអ្នកនិពន្ធវិទ្ធង្សនា ...  ពីព្រោះលោកបានសរសេរចំនុចខ្លះៗ នៅក្នុងរឿងតេឡេម៉ាកដែលប្រមាថព្រះមហាក្សត្រល្វីទី-១៤សឹងតែចំៗតែម្តង ។ នៅក្នុងរឿងតេឡេម៉ាត, ហ្វេណឺឡុងមិនបានអត់ឱនឲ្យស្តេចផងទេ, នៅក្នុងនាមជាជនគ្រីស្ទាន ពីព្រោះស្តេចបានបង្កើតសង្គ្រាម, នៅក្នុងនាមនៃពូជស្តេចដែរ គឺស្តេចបានបន្ថោកបន្ទាបពូជស្តេចដូចគ្នា, នៅក្នុងនាមនៃទស្សនវិទូ  គឺនយោបាយរបស់ស្តេចបានធ្វើឲ្យហិនហោចដល់ប្រជាពលរដ្ឋ ។  ស្តេចបារាំងល្វីទី-១៤ ដែលគេហៅថាព្រះកូណាព្រះអាទិត្យ បានដាក់របាស្សនាមឲ្យលោកហ្វេណឺឡុងថា ៖ « គឺជាបញ្ញាជនដ៏ខ្ពង់ខ្ពស់ជាងគេ ក៏ប៉ុន្តែជាបុគ្គលរវើរវាយចាក់ស្មុគ្រដ៏ខ្លាំងជាងគេ នៅក្នុងព្រះរាជាណាច-

ក្រុមរបស់ខ្ញុំ» ( « **C'est le plus bel esprit, disait Louis XIV, mais le plus chimérique de mon royaume»** ។ លោកហ្វេណឺឡុងមានកាតព្វកិច្ចឃុំខ្លួនលោកនៅក្នុងវិហាររបស់ខ្លួនឯង ឥតចេញទៅទីណាទាល់តែសោះ រហូតដល់ថ្ងៃគាត់ស្លាប់ ។ ក៏ប៉ុន្តែទោះជាយ៉ាងនេះក្តី, នៅក្នុងវិហារនោះមានគេស្រឡាញ់រូបលោកដូចជាព្រះមួយអង្គ ...។

**សុទ្ធ~ប៉ូលិន**

○ ○

○